# សៀវភៅណែនាំ
# សម្រាប់គ្រូបង្រៀន

## វិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥–១៩៧៩)



មជ្ឈមណ្ឌល
ឯកសារកម្ពុជា
និង ក្រសួងអប់រំ
យុវជន និងកីឡា

# សៀវភៅណែនាំសម្រាប់គ្រូបង្រៀន

## វិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)



*សិស្សានុសិស្សទទួលសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” នៅវិទ្យាល័យព្រះយុគន្ធរ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា កាលពីខែតុលា ឆ្នាំ២០០៩ ។ រូបថត : ដី ទេវិទ្ធិ ។ ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

មជ្ឈមណ្ឌលឯកសារកម្ពុជា និង ក្រសួងអប់រំ យុវជន និងកីឡា

ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារលេខ ៖ (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីមែល ៖ dccam@online.com.kh
គេហទំព័រ ៖ www.dccam.org | www.cambodiatribunal.org | www.cambodiasri.org

សៀវភៅណែនាំសម្រាប់គ្រូបង្រៀន ៖ វិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥–១៩៧៩)
បណ្ឌិត ជា ផល្លា និង បណ្ឌិត គ្រីស្តូហ្វ័រ ឌៀរីង

ក្រុមបកប្រែភាសាខ្មែរ
ឌី ខាំបូលី, ផេង ពង្សរ៉ាស៊ី, ប្រាក់ កែវតារា

ក្រុមត្រួតពិនិត្យភាសាខ្មែរ និង អង់គ្លេស
ទេព ម៉េងឃាន, ឆាំង យុ, កែវ ដាស៊ីល, គ្រីស្តូហ្វ័រ ឌៀរីង, អេង កុកថាយ, វ៉ាន់ថាន់ ពៅដារ៉ា, ឡុង ដានី, លី សុខឃាង, ឌី ខាំបូលី, ជី ទេរិទ្ធិ, ជា ផល្លា, ញាណ សុជាតិ, សេង គន្ធី, គឹមស្រួយ សុខវិសាល, ម៉ែន ពិចិត្រ, លី សុខចំរើន, ទាវ សារះមុនិន្ទ

គណៈកម្មការត្រួតពិនិត្យរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា

| | | | | |
|---|---|---|---|---|
| អាឡិច ហ៊ីនតុន | បែន នាង | អេលីហ្សាបែត វ៉ាន់ស្កាក់ | ជា កល្យាណ | ចេង ហុង |
| ឈឹម ឌីណា | កែវ ដាស៊ីល | ដេវីដ ឆេនល័រ | ប្រែហ្វង ឆក | ចច ឈីហ្គាស |
| ហ្គីយេ ហ្គាល់ហ្វូស | អៀត ប៊ុនឡេង | អ៊ឹម កុច | អ៊ឹម សិទ្ធី | ប្រាក់ កែវតារា |
| ខេវិន មើភី | ឌី ខាំបូលី | អេង កុកថាយ | គង់ ហាក់ | លាង សេងហាក់ |
| ឡេង សារី | លី រមនី | ម៉ៅ វាសនា | មាស សុក្ខខន | មីរៀម ម័រហ្គិនស៊្ទើន |
| មុំ ម៉េត | មួង សុផាត | ណេឡា ណាវ៉ារ៉ូ | ណែត ពេជ្រចិន្តា | ញិល សល្យ |
| ណូអា ណូវ៉ូរ៉ូតស្គី | វ៉ាន់ថាន់ ពៅដារ៉ា | ផេង ពង្សរ៉ាស៊ី | សំ សុវណ្ណតារា | សំបូរ ម៉ាណ្ណារ៉ា |
| សារ៉ា ចនឌីកគិន | ស៊ីរិ សារីណា | សើ សាយ្យាណា | សេក សុខា | សេង ពិសិដ្ឋនារី |
| ស៊ីម សុភ័ក្ត្រ | ស៊ីវ ធួន | សោមនស្ស ភិរម្យ | តែន គឹមតុន | តេង សុភាលក្ស្មី |
| ថម ឡាព័នតេ | ទន់ សាអ៊ីម | យិន សុធា | យិត សុភក្ត្រ័ | ឆាំង យុ |
| សេង ដារា | សូ ហ្វារីណា | លី សុខឃាង | | |

១) កម្ពុជា-ប្រវត្តិសាស្ត្រ-អក្សរសិល្ប៍-សីលធម៌ពលរដ្ឋ
២) កម្ពុជា-ប្រវត្តិសាស្ត្រ និងរដ្ឋាភិបាល-១៩៧៥-១៩៧៩

ជំនួយទ្រទ្រង់សម្រាប់ប្រតិបត្តិការរបស់គម្រោងនេះ ត្រូវបានផ្តល់ឲ្យដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ស៊ុយអែត និងជំនួយទ្រទ្រង់របស់ប្រទេសកាណាដា ។

ការបោះពុម្ពនេះ រួមទាំងការរចនា សេចក្តីព្រាង និងសេចក្តីបញ្ចប់នៃជំពូក "ការជម្លៀសដោយបង្ខំ" ត្រូវបានឧបត្ថម្ភដោយជំនួយទ្រទ្រង់របស់សេវាសន្តិភាពនៃសង្គមស៊ីវិលអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការអន្តរជាតិ (GIZ) GmbH ។

ទស្សនៈដែលឆ្លុះបញ្ចាំងនៅក្នុងសៀវភៅនេះជាគំនិតរបស់អ្នកនិពន្ធ និងអ្នកត្រួតពិនិត្យផ្ទាល់ ដែលមិនបង្ហាញពីជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ ។



ផ្កាអង្គាបុស្បដ៏កម្រ ដែលលោក ឆាំង យុ បានដាំនៅក្នុងសាលាបឋមសិក្សា ពោ អ៊ុ ក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីឆ្នាំ១៩៦៧ ។
រូបថត : ជី ទេវិទ្ធិ ។

---

រក្សាសិទ្ធិ ឆ្នាំ២០០៩ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និង ក្រសួងអប់រំ យុវជន និងកីឡា ។

រក្សាសិទ្ធិគ្រប់បែបយ៉ាង ។ មិនមានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានបោះពុម្ពឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ណាមួយ ឬក្នុងមធ្យោបាយបែបណាឡើយ ដែលរួមមានការថតចម្លង ការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពបានឡើយ ។

**គំនិត និង រចនាសៀវភៅ**

គំនិតផ្នែកសិល្បៈ : ឆាំង យុ
ជ្រើសរើសរូបថត និងចំណងជើងរូបថត : កែវ ដាស៊ីល
រចនាសៀវភៅ : អ៊ីវ៉ុន វ៉ុង

**ក្របសៀវភៅ :** *រូបថតក្មេងនៅប្រាសាទអង្គរវត្ត ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កុមារកម្ពុជារាប់សែននាក់ ក្លាយជាកុមារកំព្រា ។ រូបថតនេះ ថតនៅក្នុងឆ្នាំ១៩៧៩ ដោយកងទ័ពវៀតណាម (ខេត្តសៀមរាប) ។*

**កម្ពុជា : ការសិក្សាពីអំពើប្រល័យពូជសាសន៍ គឺជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

ISBN-9789995060145

បោះពុម្ពនៅកម្ពុជា ឆ្នាំ២០០៩
បោះពុម្ពឡើងវិញនៅកម្ពុជា ឆ្នាំ២០១៤

9 789995 060183

■

**សំណួររបស់អ្នក មានឥទ្ធិពលនិងផ្តល់អត្ថន័យដល់អ្នកដែលមានការឈឺចាប់។ សួរសំណួរទៅកាន់ឪពុកម្តាយ និងជីដូនជីតារបស់អ្នកអំពីរបបខ្មែរក្រហម នឹងធ្វើឱ្យមានការផ្សះផ្សានៅក្នុងសង្គមកម្ពុជា។**

■

**បង្រៀនក្មេងៗអំពីរបបខ្មែរក្រហម មានន័យថាបង្រៀនសិស្សានុសិស្សឱ្យចេះបែងចែកល្អ និងអាក្រក់ និង ចេះអភ័យទោសឱ្យគ្នា។ សង្គមដែលបែកបាក់ ចាំបាច់ត្រូវស្វែងយល់អំពីអតីតកាល ដើម្បីកសាងអនាគតកាលរបស់ខ្លួន។**

■

**បង្រៀនក្មេងៗអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ក៏ដូចជាជំរុញឱ្យមានការពិភាក្សារវាងក្មេងៗ និងឪពុកម្តាយ ព្រមទាំងជីដូនជីតារបស់ខ្លួនអំពីអ្វីដែលបានកើតឡើង គឺមានសារសំខាន់ណាស់ចំពោះការការពារអំពើប្រល័យពូជសាសន៍ទាំងនៅក្នុងប្រទេសកម្ពុជា និងពិភពលោកទាំងមូល។**

*ស្ថិតក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា មជ្ឈមណ្ឌលឯកសារកម្ពុជាបាន និងកំពុងរៀបចំដាក់ពាក្យស្លោករំឭកពីការចងចាំ និងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមសាលាមធ្យមសិក្សាចំនួន១៣២១ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ទស្សនៈទាំងបីខាងលើនេះ នឹងត្រូវដាក់បញ្ចូលក្នុងពាក្យស្លោកទាំងនោះ ដែលជាចេតនាក្នុងការជំរុញឲ្យមានការស្វែងយល់ និងឆ្លុះបញ្ចាំងដ៏មានសារសំខាន់ ទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងពិធីសម្ពោធឲ្យប្រើប្រាស់ពាក្យស្លោកទាំងនេះ អ្នកចូលរួមទាំងអស់នឹងទទួលបានសៀវភៅ«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ម្នាក់មួយច្បាប់ ។ គិតចាប់តាំងពីពេលបោះពុម្ពដំបូង សៀវភៅចំនួនជាង បីសែនក្បាលត្រូវបានចែកចាយរួចមកហើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តការចែកចាយសៀវភៅនេះដល់សិស្សានុសិស្សចាប់ពីថ្នាក់ទី៩ដល់ថ្នាក់ទី១២ ដើម្បីធានាថា សិស្សានុសិស្សទាំងនោះមានសៀវភៅនេះផ្ទាល់ខ្លួនម្នាក់មួយច្បាប់ ។*



# អារម្ភកថា



រាមឥសូរបានដេញតាមនាងមេខឡានៅលើពពក ហើយបានគប់ពូថៅពេជ្រយ៉ាងសាហាវទៅលើនាង ដែលបង្កើតឲ្យមានសំឡេងផ្គរលាន់ឡើង ។ នាងមេខឡាបានប្រើខែលជាដុំវេទមន្តកែវចរណៃ ដែលជាអំណោយពីលោកគ្រូរបស់នាង ដើម្បីបាំងការពារខ្លួន ។ ភ្លាមនោះ ការប៉ះទង្គិចបានបញ្ចេញជាពន្លឺភ្លឺចិញ្ចែងចិញ្ចាចពាសពេញផ្ទៃមេឃ ។ រឿងនិទាននេះ គឺជាផ្នែកមួយនៃរឿងដ៏ចំណាស់ជាងគេមួយរបស់កម្ពុជា គឺរឿងរាមកេរ្តិ៍ ដែលនិទានអំពីការតស៊ូរវាងអំពើល្អ និងអំពើអាក្រក់ ។ អំពើដ៏អាក្រក់បំផុតមួយ ដែលបានកើតមាននៅក្នុងប្រទេសកម្ពុជា គឺការបណ្តែតបណ្តោយឲ្យអំពើឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ កើតឡើងក្នុងចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ ដែលបណ្តាលឲ្យបាត់បង់ជីវិតមនុស្សប្រមាណពី១.៧លានទៅ២.២លាននាក់ និងមនុស្សជាច្រើននាក់ផ្សេងទៀតទទួលរងការឈឺចាប់ ខ្លោចផ្សាក្នុងកណ្តាប់ដៃដ៏ឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រៀបដូចនៅក្នុងរឿងនិទានរាមកេរ្តិ៍ ដែលពូថៅរបស់រាមឥសូរបានប៉ះទង្គិចគ្នាជាមួយនឹងកែវចរណៃរបស់នាងមេខឡាអ៊ីចឹង នេះគឺជាពេលវេលាដ៏ប្រសើរសម្រាប់ប្រទេសកម្ពុជា ក្នុងការរកខុសត្រូវចំពោះប្រវត្តិសាស្ត្រដ៏ឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ជាលើកដំបូងបំផុតក្នុងរយៈពេលបីទសវត្សរ៍កន្លងទៅ ភាពស្ងប់ស្ងាត់ដែលបានញាំញីសាលារៀនទាំងឡាយនៅក្នុងប្រទេសកម្ពុជានឹងត្រូវបានរលាយបាត់អស់ ដោយជំនួសមកវិញនូវឱកាសសម្រាប់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សទាំងឡាយក្នុងការនិយាយ និងស្វែងយល់អំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលបានកើតឡើងពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ នេះគឺជាព្រឹត្តិការណ៍ដាច់ដោយឡែកមួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ សៀវភៅសិក្សា និងកម្មវិធីសិក្សាស្តីពីអំពើប្រល័យពូជសាសន៍ មិនត្រឹមតែអប់រំយុវជនខ្មែរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតជាវេទិកាពិភាក្សាមួយ ដែលប្រជាជនកម្ពុជាគ្រប់រូបអាចចូលរួមបាន ។ តាមរយៈការប្រឈមមុខនឹងទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត យើងអាចចាប់ផ្តើមទទួលស្គាល់នូវការតស៊ូដែលពោរពេញដោយការឈឺចាប់របស់សមាជិកគ្រួសារ និងមិត្តភក្តិរបស់យើង ។ វិញ្ញាណជីដូនជីតាបានខ្សឹបប្រាប់យើងនៅតាមវាលស្រែ និងហៅឈ្មោះយើងឲ្យជួយរំដោះគាត់ឲ្យចេញពីភាពអយុត្តិធម៌ និងអមនុស្សធម៌ ។ ក្នុងនាមជាអ្នកថែរក្សាកេរដំណែលដ៏ឈឺចាប់ ការទទួលស្គាល់អំពីអតីតកាលក៏អាចជួយឲ្យយើងដឹងអំពីបច្ចុប្បន្នបានដែរ ដែលនោះគឺជាការដោះស្រាយ និងការតស៊ូរបស់អ្នកដែលនៅរស់រានមានជីវិត ។ អ្នកទាំងនោះគឺជាបុរស និងស្ត្រីជាជនសាមញ្ញ ដែលបានខិតខំធ្វើការដោយឥតឈប់ឈរដើម្បីកសាងសង្គម និងផ្ទះសម្បែងឡើងវិញ បន្ទាប់ពីគ្រោះ មហន្តរាយ និងសោកនាដកម្មដ៏ឃោរឃៅនេះ ។

លោកគ្រូ អ្នកគ្រូ មានតួនាទីយ៉ាងសំខាន់ និងមិនអាចកាត់ថ្លៃបានក្នុងការថែរក្សាប្រវត្តិសាស្ត្រកម្ពុជា ។ លោកគ្រូ អ្នកគ្រូ គឺជាអ្នកបញ្ជាចង្កូតនាវាប្រវត្តិសាស្ត្រ ដែលដឹកនាំសិស្សានុសិស្សទាំងអស់ឆ្លងកាត់ព្យុះសង្ឃរានៃអតីតកាលដ៏វឹកវររបស់ជាតិយើង ដើម្បីឆ្ពោះទៅកាន់អនាគតដ៏រុងរឿងមួយ ។ ដោយក្តីសង្ឃឹមយ៉ាងមុតមាំ សៀវភៅណែនាំគ្រូនេះនឹងអាចធ្វើជា

ត្រីវិស័យដើម្បីចង្អុលបង្ហាញទិសដល់លោកគ្រូ អ្នកគ្រូ ឲ្យឈានទៅរកការពិត យុត្តិធម៌ និងចំណេះដឹង ដើម្បីបង្រៀនកូនខ្មែរជំនាន់ក្រោយអំពីផលវិបាកដែលបានបន្សល់ទុកដោយឧក្រិដ្ឋកម្ម និងអំពើអាក្រក់ផ្សេងៗទៀត ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤



**ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន**
**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**
**ព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំសម្រាប់គ្រូបង្រៀន មិនអាចសរសេរឡើងបានដោយពុំមានការប្រឹងប្រែងពីបុគ្គលជាច្រើន ដែលអ្នកទាំងអស់នេះជាកត្តានាំមកនូវភាពជោគជ័យសម្រាប់ការតាក់តែងសៀវភៅនេះ ។ ខ្ញុំបាទសូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រ ដល់ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន ចំពោះការយកចិត្តទុកដាក់របស់ឯកឧត្តមក្នុងការអប់រំស្តីពីអំពើប្រល័យពូជសាសន៍ដល់កូនខ្មែរជំនាន់ក្រោយ និងស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ ខ្ញុំបាទសូមថ្លែងអំណរគុណដល់លោកជំទាវ ទន់ សាអ៊ឹម ចំពោះកិច្ចខិតខំប្រឹងប្រែងដោយឥតនឿយហត់ ដើម្បីធានាថា ការអប់រំពីអំពើប្រល័យពូជសាសន៍នេះពិតជាផ្តល់សារប្រយោជន៍ដល់សិស្សានុសិស្សទាំងអស់នៅប្រទេសកម្ពុជា ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់បណ្ឌិត ជា ដល្លា និងលោក គ្រីស្តូហ្វ័រ ឌៀរីង ដែលបានរៀបចំអត្ថបទសម្រាប់សៀវភៅណែនាំសម្រាប់គ្រូបង្រៀននេះ ព្រមទាំងក្រុមការងារបកប្រែ និង ក្រុមត្រួតពិនិត្យខ្លឹមសារ លោកគ្រូ អ្នកគ្រូជាតិទាំង២៨រូប និងគ្រូបង្រៀន អ្នកជំនាញ និងបញ្ញាជនអន្តរជាតិទាំងអស់ ដែលបានជួយដល់ការបង្កើតសៀវភៅណែនាំសម្រាប់គ្រូបង្រៀនដ៏មានសារសំខាន់នេះឡើង ។ កិច្ចការនេះអាចលេចចេញជារូបរាងឡើងបាន ក៏ដោយសារមានជំនួយសប្បុរសពីប្រទេសប៊ែលហ្ស៊ិក ដាណឺម៉ាក ណ័រវ៉េ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែត ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ប្រទេសកាណាដា និងសេវាសន្តិភាពនៃសង្គមស៊ីវិលអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការអន្តរជាតិ ។ ប្រទេសទាំងអស់នេះក៏បានផ្តល់ការគាំទ្រយ៉ាងមុតមាំក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតមានឡើងនៅលើពិភពលោក និងកម្ពុជា នៅពេលអនាគត ។ ជាចុងក្រោយនេះ ខ្ញុំបាទសូមថ្លែងអំណរគុណដល់ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ដែលបានគាំទ្រ និងលើកទឹកចិត្តដល់ខ្ញុំបាទ និងជួយធ្វើឲ្យចេញជារូបរាងឡើងនូវសៀវភៅសិក្សា "ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)" និងលោក ឌី ខាំបូលី ចំពោះការព្យាយាមយ៉ាងមុតមាំក្នុងការនិពន្ធសៀវភៅប្រវត្តិសាស្រ្តដំបូងបង្អស់ស្តីអំពី



ក្រុមការងារសៀវភៅណែនាំគ្រូបង្រៀន និងសហការីមកពីក្រសួងអប់រំ យុវជន និងកីឡា ជាមួយឯកឧត្តម អ៊ុម សិទ្ធី (នៅចំកណ្តាល ក្នុងសម្លៀកបំពាក់អាវធំពណ៌ខ្មៅ) នៅពីមុខក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ប្រទេសកម្ពុជា ខែកក្កដា ឆ្នាំ២០០៩ ។
(រូបថត : មជ្ឈមណ្ឌលឯកសារកម្ពុជា)

របបខ្មែរក្រហម ។

សៀវភៅណែនាំសម្រាប់គ្រូបង្រៀនត្រូវបានប្រើប្រាស់នៅគ្រប់អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានសិស្សដែលរៀនពីថ្នាក់ទី៩ដល់ទី១២ចំនួនប្រមាណមួយលាននាក់ បានទទួលចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ដែលប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀននេះ ។ ។ ស្ថិតក្នុងផ្នែកមួយនៃគម្រោងស្តីពីការសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រូបង្រៀនមកពីអនុវិទ្យាល័យ និងវិទ្យាល័យចំនួនជាង ៣ពាន់នាក់ បានទទួលវគ្គបណ្តុះបណ្តាលអំពីរបៀបបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)» ។ មានតែការសិក្សាអំពីអតីតកាលប៉ុណ្ណោះ ដែលអាចឲ្យយើងចាប់ផ្តើមផ្សារភ្ជាប់ឡើងវិញនូវបំណែកបែកបាក់ទាំងអស់នៃសង្គមរបស់យើង ។ ក្នុងនាមជាកូនខ្មែរម្នាក់ ខ្ញុំមានសេចក្តីរីករាយបំផុត ដែលមានឱកាសបម្រើដល់បេសកកម្មដ៏គួរឲ្យស្ញប់ស្ញែង និងសំខាន់នេះសម្រាប់ប្រទេសកម្ពុជា ។ ខ្ញុំសូមឧទ្ទិសសៀវភៅនេះជូនចំពោះម្តាយរបស់ខ្ញុំ ។ គម្រោងការងារនេះបាន និងកំពុងក្លាយទៅជាគណៈកម្មការស្វែងរកការពិតនៅកម្ពុជា ។

**ឆាំង យុ**
**នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

# មាតិកា


| | |
|---|---|
| ***ផ្នែកទី១ ៖ សេចក្តីសង្ខេប*** | |
| តើប្រវត្តិសាស្ត្រគឺជាអ្វី? | ១ |
| គោលបំណងនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ | ២ |
| ទស្សនវិជ្ជានៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ | ៤ |
| សៀវភៅណែនាំសម្រាប់គ្រូបង្រៀន | ៥ |
| របៀបក្នុងការប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្ស | ៦ |
| សំណុំឯកសារនៃការសិក្សារបស់សិស្ស សម្រាប់វាយតម្លៃកម្មវិធីសិក្សា | ១១ |
| ***ផ្នែកទី២ ៖ មេរៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*** | **១២** |
| មេរៀនទី១ ៖ សេចក្តីផ្តើមនៃមេរៀន | ១៣ |
| មេរៀនទី២ ៖ ស្វែងយល់អំពីចំណេះដឹងពីមុនរបស់សិស្ស | ១៧ |
| **ជំពូក១ ៖ សេចក្តីសង្ខេប** | **២០** |
| មេរៀនទី១ ៖ អំណានជំពូក១ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ | ២០ |
| **ជំពូក២ ៖ តើខ្មែរក្រហមជាអ្នកណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?** | **២៦** |
| មេរៀនទី១ ៖ អំណានជំពូក២ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ | ២៦ |
| មេរៀនទី២ ៖ តើ ប៉ុល ពត ជាអ្នកណា? | ២៩ |
| **ជំពូក៣ ៖ ការជម្លៀសដោយបង្ខំ** | **៣១** |
| មេរៀនទី១ ៖ អំណានសំណួរស្វែងយល់ | ៣១ |
| មេរៀនទី២ ៖ សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) | ៣៦ |
| មេរៀនទី៣ ៖ បទពិសោធន៍នៃការជម្លៀសដោយបង្ខំ | ៤៣ |
| មេរៀនទី៤ ៖ ទួលពោធិ៍ជ្រៃ | ៤៧ |
| **ជំពូក៤ ៖ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម** | **៥៣** |
| មេរៀនទី១ ៖ អំណានជំពូក៣ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ | ៥៣ |
| មេរៀនទី២ ៖ ប្រអប់សង្គ្រោះជីវិត | ៥៥ |
| **ជំពូក៥ ៖ ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ** | **៥៧** |
| មេរៀនទី១ ៖ អំណានជំពូក៤ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ | ៥៧ |
| មេរៀនទី២ ៖ ពិនិត្យមើលក្រុមមេដឹកនាំខ្មែរក្រហម | ៦០ |

**ជំពូក៦ ៖ ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ** **៦២**
មេរៀនទី១ ៖ អំណានជំពូក៥ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៦៣
មេរៀនទី២ ៖ ការសម្តែងតួ "អំពីជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម" ៦៤
**ជំពូក៧ ៖ គម្រោងផែនការបួនឆ្នាំ (១៩៧៧-១៩៨០)** ៧៥
មេរៀនទី១ ៖ អំណានជំពូក៦ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៧៥
មេរៀនទី២ ៖ កាលបរិច្ឆេទ ៖ ការវិភាគ និងការវាយតម្លៃនៅក្នុងក្រុម ៧៧
មេរៀនទី៣ ៖ ការវិភាគទៅលើមនោគមន៍វិជ្ជារបស់ខ្មែរក្រហម ៧៩
**ជំពូក៨ ៖ ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ** **៨២**
មេរៀនទី១ ៖ អំណានជំពូក៧ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៨៣
មេរៀនទី២ ៖ កំណត់ហេតុអំពីជីវិតរបស់ខ្ញុំក្រោមរបបខ្មែរក្រហម ៨៥
មេរៀនទី៣ ៖ បទសម្ភាសន៍ ៖ រឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិតម្នាក់ ៩២
**ជំពូក៩ ៖ប្រព័ន្ធសន្តិសុខ** **៩៥**
មេរៀនទី១ ៖ អំណានជំពូក៨ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៩៥
មេរៀនទី២ ៖ ប្រវត្តិ ៖ សេចក្តីស្រឡាញ់ និង ពលិកម្មរបស់ប្អូនស្រីដែលពុំអាចបំភ្លេចបាន ៩៧
មេរៀនទី៣ ៖ ភ្ញៀវធ្វើបទបឋកថា ១០២
**ជំពូក១០ ៖ មន្ទីរស-២១ (គុកទួលស្លែង)** **១០៣**
មេរៀនទី១ ៖ អំណានជំពូក៩ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១០៣
មេរៀនទី២ ៖ នៅក្រោយជញ្ជាំងនៃមន្ទីរស-២១ ១០៦
**ជំពូក១១ ៖ ទំនាក់ទំនងការបរទេស** **១០៧**
មេរៀនទី១ ៖ អំណានជំពូក១០ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១០៧
មេរៀនទី២ ៖ បណ្ណស្តីអំពីទំនាក់ទំនងការបរទេស ១០៩
**ជំពូក១២ ៖ ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ** **១១១**
មេរៀនទី១ ៖ អំណានជំពូក១១ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១១១
មេរៀនទី២ ៖ រូបភាពថ្ងៃរំដោះ ១១៣
មេរៀនទី៣ ៖ ការធ្វើឲ្យប្រសើរឡើងនូវរបបអាហារ និងជីវជាតិសម្រាប់អ្នកដែលនៅរស់រានមានជីវិត ១១៥
មេរៀនទី៤ ៖ ការសិក្សាប្រៀបធៀបអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ១២០
មេរៀនទី៥ ៖ ខ្សែភាពយន្ត "កុមារកម្ពុជា" ១៤០
**សេចក្តីបញ្ចប់ ៖ ផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យមកលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ន** **១៤៣**
មេរៀនទី១ ៖ អំណានសេចក្តីបញ្ចប់ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៤៣
មេរៀនទី២ ៖ ពិការភាព និង អំពើប្រល័យពូជសាសន៍ ១៤៨
មេរៀនទី៣ ៖ កំណាព្យដើម្បីរំឭកគុណដល់ព្រលឹងជាតិខ្មែរ ១៥៣

មេរៀនទី៤ ៖ តារាង K-W-L ១៥៥

មេរៀនទី៥ ៖ ការតាំងពិព័រណ៍សារមន្ទីរនៅក្នុងថ្នាក់រៀន ១៥៦

មេរៀនទី៦ ៖ ការធ្វើឲ្យមានការផ្លាស់ប្ដូរ ១៦១

**សកម្មភាពសិក្សាបន្ថែម ១៦៤**

ក) សកម្មភាពបឋម ១៦៤

ខ) ល្ខោន ៖ ល្ខោននិយាយ ១៦៧

គ) គម្រោងនៃការសិក្សាអំពីការប្រៀបធៀបអំពើប្រល័យពូជសាសន៍ ១៦៨

ឃ) សកម្មភាព ៖ កំណាព្យ ១៧១

ង) គម្រោងស្រាវជ្រាវ ៖ បង្កើតតារាងបញ្ជី W ១៧២

ច) បង្កើតតារាងបញ្ជី L ៖ សកម្មភាពបន្ទាប់ពីគម្រោងស្រាវជ្រាវ ១៧៦

ឆ) ដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាដជើងឯក ១៧៦

**ផ្នែកទី៣ ៖ តារាងវាយតម្លៃ ១៧៨**

តារាងវាយតម្លៃក្នុងការឡើងពន្យល់ ១៧៨

តារាងវាយតម្លៃរបាយការណ៍ ១៧៩

តារាងវាយតម្លៃសៀវភៅកំណត់ហេតុ និងវិត្តប័ណ្ណ ១៨០

តារាងវាយតម្លៃការសូត្រកំណាព្យផ្ទាល់មាត់ ១៨០

តារាងវាយតម្លៃការសរសេរតែងសេចក្ដី ១៨១

តារាងវាយតម្លៃការសិក្សាប្រៀបធៀបអំពើប្រល័យពូជសាសន៍ ១៨២

**ផ្នែកទី៤ ៖ ប្រភពធនធាន និងឯកសារយោង ១៨៣**

តារាង ខេ-ដាប៊ីយូ-អិល (K-W-L) ១៨៣

តារាងទំនាក់ទំនងនៃសំណុំ វ៉ែន ដ្យ៉ាក្រាម ១៨៣

សកម្មភាពធ្វើការជាដៃគូ ១៨៤

សកម្មភាពធ្វើការជាក្រុម ជីក-សរ (Jigsaw) ១៨៤

ភាពយន្តឯកសារមួយចំនួន ១៨៤

គន្ថនិទ្ទេស ១៨៥

សៀវភៅបកប្រែជាភាសាខ្មែរមួយចំនួន ១៨៥

គេហទំព័រមួយចំនួន ១៨៦

ការប្រកាសអាសន្នជាបឋម ការទប់ស្កាត់ និងការកាត់ទោសបទឧក្រិដ្ឋ ១៨៧

អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ១៨៨

ការណែនាំបន្ថែមសម្រាប់គ្រូបង្រៀនលើការសិក្សាលំហាត់ប្រៀបធៀបនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ១៨៩
តារាងសម្រាប់ទាញយកភាពដូចគ្នា និងភាពខុសគ្នានៅក្នុងការប្រៀបធៀបអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ១៩០
កំណត់ចំណាំសម្រាប់គ្រូ ១៩១
    អ៊ីរ៉ាក់ ១៩២
    ហូឡូខសត៍-អាល្លឺម៉ង់ ១៩២
    រ៉្វាន់ដា ១៩៣
    អតីតយូហ្គោស្លាវី ១៩៤
ការប្រៀបធៀបអំពើប្រល័យពូជសាសន៍-អំពើឧក្រិដ្ឋធ្ងន់ធ្ងរ កម្ពុជា អ៊ីរ៉ាក់ អាល្លឺម៉ង់ រ៉្វាន់ដា និង អតីតយូហ្គោស្លាវី ១៩៥
    ប្រឡងបញ្ចប់ ក្រដាសចម្លើយ ៖ (ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩) ១៩៦
    ផ្នែកទី១ ៖ ចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៦
    ផ្នែកទី២ ៖ ស្វែងយល់ ៖ សំណួរដែលមានចម្លើយខ្លី ២០៣
    ផ្នែកទី៣ ៖ ការវិភាគ ៖ សំណួរសាកល្បង ២០៤
    ផ្នែកទី៤ ៖ ការផ្តល់មតិចំពោះកម្មវិធីសិក្សា ២០៤
ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ «១៩៧៥-១៩៧៩» នៅទូទាំងប្រទេស ២០៥



រូបថតនេះ បង្ហាញពីការលក់ដូរនៅផ្សារដំបូងបំផុតមួយក្នុងឆ្នាំ១៩៨០ នៅស្រុកកោះធំ ខេត្តកណ្តាល ។ ផ្សារនេះមានទីតាំងនៅត្រើយខាងលិចនៃទន្លេបាសាក់ ។ នៅត្រើយម្ខាងទៀតនៃទន្លេនេះ គឺជាទីតាំងគុករបស់ខ្មែរក្រហមមួយមានឈ្មោះថា មន្ទីរសន្តិសុខកោះខ្សាច់ទន្លា ។ អ្នករួចរស់ជីវិតភាគច្រើននៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ គឺជាស្ត្រី ។ ចាប់តាំងពីពេលនោះមក ស្ត្រីក្លាយជាកត្តាជំរុញដ៏សំខាន់ក្នុងការស្តាបនាប្រទេសកម្ពុជាឡើងវិញទាំងផ្នែកសេដ្ឋកិច្ច សង្គម និងស្មារតី ។ ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។

# ផ្នែកទី១ ៖ សេចក្តីសង្ខេប



សិស្សានុសិស្សនៃវិទ្យាល័យ ហ៊ុន សែន អង្គស្នួល កំពុងឈរចាំរថយន្តក្រុងក្រោមម្លប់ឈើនៅទីធ្លាខាងមុខសាលា ។ សិស្សានុសិស្សទាំងនេះបម្រុងនឹងទៅធ្វើទស្សនកិច្ចនៅសាលាក្តីខ្មែរក្រហម សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតជើងឯក ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០៧ ។ រូបថត ៖ កែវ ដាស៊ីល ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។

## តើប្រវត្តិសាស្ត្រ គឺជាអ្វី?

យោងតាមអ្នកនិពន្ធ និងអ្នកប្រវត្តិសាស្ត្រជនជាតិអាមេរិកឈ្មោះ វិលៀម មិកណែល បានធ្វើការកត់សម្គាល់ជាពិសេសនៅក្នុងសំណេររបស់គាត់អំពី«អារ្យធម៌បស្ចិមប្រទេស»ថា ប្រវត្តិសាស្ត្រត្រូវបានបែងចែកជាបីកម្រិតគឺ ៖

កម្រិតទី១ ៖ ប្រវត្តិផ្ទាល់ខ្លួន-ប្រវត្តិសាស្ត្រមូលដ្ឋាន

កម្រិតទី២ ៖ ប្រវត្តិសាស្ត្រជាតិ

កម្រិតទី៣ ៖ ប្រវត្តិសាស្ត្រសាកលលោក

«ចំណេះដឹងពីប្រវត្តិសាស្ត្រមិនមានលក្ខណៈលើសគ្នានឹងការចងចាំជារួម ដែលបានស្ថាបនាឡើងដោយប្រុងប្រយ័ត្ន និងប្រកបដោយការត្រិះរិះពិចារណាឡើយ» ។ ប្រសិនបើគ្មានការចងចាំជាបុគ្គលទេ មនុស្សម្នាក់ប្រាកដជាបាត់អត្តសញ្ញាណរបស់ខ្លួនតែម្តង ហើយបុគ្គលនោះក៏មិនដឹងថាតើត្រូវធ្វើដូចម្តេចពេលជួបជាមួយអ្នកដទៃដែរ ។ ការចងចាំមិនមែនស្ថិតនៅនឹងថ្កល់ និងស្ថិតស្ថេររហូតនោះទេ ។ ដោយហេតុថាពេលវេលាកន្លងហួសទៅ ការចងចាំពីបទពិសោធន៍របស់បុគ្គលនឹងវិវត្តទៅរកអត្ថន័យថ្មី ។ អ្នកប្រវត្តិសាស្ត្រ គឺតែងតែធ្វើការស្រាយបំភ្លឺឡើងវិញពីអតីតកាល ដោយចោទសួរសំណួរថ្មីៗ ស្វែងរកប្រភពថ្មីៗ និងរកឃើញអត្ថន័យថ្មីៗនៅក្នុងឯកសារចាស់ៗ ដើម្បីផ្តល់ជាគំនិតនៃចំណេះដឹង និងបទពិសោធន៍ថ្មីៗ ដែលជាប់ទាក់ទងដល់ការស្វែងយល់ពីអតីតកាល ។ ជាការពិតណាស់ កិច្ចការទាំងនេះមានន័យថា អ្វីដែលយើងដឹង និងជឿជាក់ពីប្រវត្តិសាស្ត្រ គឺកំពុងតែផ្លាស់ប្តូរជានិច្ចកាល ។ និយាយម្យ៉ាងទៀត ការចងចាំជារួម មានការផ្លាស់ប្តូរទៅតាមពេលវេលាដូចគ្នានឹងការចងចាំជាលក្ខណៈបុគ្គលដែរ ហើយផ្លាស់ប្តូរក្រោមមូលហេតុដូចគ្នា ។

ប្រវត្តិសាស្ត្រគឺមានសារសំខាន់ណាស់ ។ ចច អូវែល បានសរសេរថា “មនុស្សគឺជាអ្នកគ្រប់គ្រងអតីតកាល និងគ្រប់គ្រងអនាគតកាល” ។ ការយល់ឃើញរបស់យើងចំពោះអតីតកាល មានឥទ្ធិពលលើរបៀបដែលយើងឆ្លើយតបនឹងកាលៈទេសៈនាពេលបច្ចុប្បន្ន ។ ប្រសិនបើការយល់ឃើញរបស់យើងខុសចំពោះប្រវត្តិសាស្ត្រ យើងទំនងជាធ្វើការសម្រេចចិត្តខុសនាពេលបច្ចុប្បន្ននេះ ។ ការសម្រេចចិត្តខុសទាំងនេះ នឹងនាំឲ្យកើតមានជម្លោះ និងខ្ជះខ្ជាយប្រភពធនធាន ដែលទីបំផុតអាចឈានដល់ការសាបសូន្យដល់អារ្យធម៌ទាំងមូល ។

## គោលបំណងនៃការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

បេសកកម្មមួយក្នុងចំណោមបេសកកម្មផ្សេងទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជំរុញឲ្យមានការអប់រំអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងផលប៉ះពាល់នៃអំពើនេះមកលើជីវិតរស់នៅរបស់យើងនាពេលបច្ចុប្បន្ន ។ គម្រោងនៃការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានរៀបចំឡើងដើម្បីជំរុញឲ្យមានការផ្សះផ្សា យុត្តិធម៌ ការបង្រួបបង្រួមជាតិ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ លោក ឌី ខាំបូលី អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានសរសេរសៀវភៅមួយដែលមានចំណងជើងថា “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)” សម្រាប់ជាការប្រើប្រាស់នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់នៅទូទាំងប្រទេស ។ សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្ស នឹងជួយដល់ការប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន ។


សិស្សានុសិស្សនៅវិទ្យាល័យឥន្ទ្រទេវី លើកបង្ហាញសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” ។ ខណ្ឌទួលគោក ទីក្រុងភ្នំពេញ ខែកញ្ញា ឆ្នាំ២០០៩ ។ រូបថត ៖ ដេង ពង្សរ៉ាស៊ី ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។

## ហេតុអ្វីត្រូវបង្ហាត់បង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ?

ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្តល់នូវឱកាសដ៏មានសារសំខាន់មួយសម្រាប់ពិនិត្យមើលបែបគរុកោសល្យនៅលើបញ្ហាសីលធម៌ជាមូលដ្ឋានទាំងឡាយ ។ ការចោទសួរប្រកបដោយការរៀបគម្រោងយ៉ាងត្រឹមត្រូវមួយ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នឹងផ្តល់ជាមេរៀនដ៏មានសារសំខាន់សម្រាប់ការស្រាវជ្រាវអំពីឥរិយាបថរបស់មនុស្ស មនោគមន៍វិជ្ជា ជំនឿ និងយុត្តិធម៌ ហើយវានឹងជួយជំរុញឲ្យអ្នកសិក្សាពិចារណាអំពីផលប៉ះពាល់នៃរបបនេះមកលើជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សក្នុងពេលបច្ចុប្បន្ន ។

គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គួរតែព្យាយាមផ្សារភ្ជាប់ការសិក្សាអំពីរយៈពេលនោះនឹងគោលគំនិតរបស់សង្គមមនុស្ស និងការពិចារណា ដោយប្រើប្រាស់ឧទាហរណ៍ផ្សេងៗ ។ ជាឧទាហរណ៍ តើ«ការពិនិត្យ» មើលទៅលើបញ្ហាសីលធម៌មានន័យយ៉ាងដូចម្តេច? តើបញ្ហាសីលធម៌ជាអ្វី? តើយើងត្រូវដោះស្រាយជាមួយនឹងបញ្ហាទាំងនេះនៅក្នុងប្រវត្តិសាស្ត្រដោយរបៀបណា? តើភាពខុសប្លែកគ្នាក្នុងការដោះស្រាយបញ្ហាទាំងនេះមានអ្វីខ្លះ ៖ ក) នាពេលបច្ចុប្បន្ន នៅក្នុងស្ថានភាពច្បាស់លាស់ក្នុងជីវិតរបស់យើង ខ) តាមរយៈការសម្លឹងមើលទៅលើហេតុការណ៍ដែលបានកើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រ គ) ឬជាបញ្ហាសម្រាប់មនុស្សនៅក្នុងបរិបទប្រវត្តិសាស្ត្រដែលយើងប្រហែលជាមិនមានលទ្ធភាពស្វែងយល់ ។ ទស្សនៈមួយទៅលើប្រវត្តិសាស្ត្រអាចមានលក្ខណៈផ្សេងគ្នា ដោយផ្អែកទៅលើទស្សនៈជាសាកលរបស់មនុស្សម្នាក់ៗ ។ ការជំរុញសិស្សឲ្យធ្វើការពិនិត្យមើលឡើងវិញអំពីទស្សនៈសាកលនឹងអនុញ្ញាតឲ្យសិស្សមើលឃើញនូវតម្លៃកាន់តែច្បាស់ថែមទៀត គឺមិនត្រឹមតែភាពចម្រូងចម្រាសនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ថែមទាំងយល់ដឹងអំពីសង្គមកម្ពុជានាពេលបច្ចុប្បន្នទៀតផង ។

### សំណួរអំពីហេតុផល

គោលបំណងក្នុងការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺដើម្បីជំរុញការចង់ដឹងចង់ឮ ផ្នែកបញ្ញាញាណរបស់សិស្ស និងជំរុញការលើកទឹកចិត្តសិស្សឲ្យមានការត្រិះរិះពិចារណា និងការរីកចម្រើនផ្ទាល់ខ្លួន ។ ហេតុផលនៃការបង្រៀនប្រវត្តិសាស្ត្រ (ជាពិសេសប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ) ត្រូវតែទទួលបានការពិចារណានៅពេលរៀបចំមេរៀន អំពីប្រធានបទនេះ ។ មុននឹងចាប់ផ្តើមបង្ហាញអំពីអ្វីដែលត្រូវបង្រៀន និងថាតើត្រូវបង្រៀនដោយរបៀបណា គ្រូចាំបាច់ត្រូវតែពិចារណាទៅលើចំណុចមួយចំនួនដូចខាងក្រោម ៖

- ហេតុអ្វីបានជាសិស្សគួរសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ?
- តើប្រវត្តិសាស្ត្រផ្តល់ដល់យើងនូវចំណេះដឹងជ្រៅជ្រះអំពីថា តើយើងជានរណា ហើយយើងអាចជានរណាយ៉ាងដូចម្តេច?
- តើមេរៀនដ៏មានសារសំខាន់បំផុតដែលសិស្សអាចសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងអំពើប្រល័យពូជសាសន៍ គឺជាអ្វី?
- តើការទទួលបាននូវចំណេះដឹងអំពីកត្តាប្រវត្តិសាស្ត្រ កត្តាសង្គម កត្តានយោបាយ និងកត្តាសេដ្ឋកិច្ចនៃរបបនេះជួយឲ្យសិស្សទទួលបាននូវទស្សនវិស័យមួយ អំពីថាតើប្រវត្តិសាស្ត្រកើតឡើងដោយរបៀបណា និងថាតើការរួមបញ្ចូលគ្នារវាងកត្តាទាំងអស់នេះ នឹងនាំទៅដល់ការបែកបាក់នៃតម្លៃអរិយធម៌ និងយុត្តិធម៌ដោយរបៀបណា?

- តើការសិក្សាអំពីប្រវត្តិសាស្រ្តនេះ បង្កើតទំនាក់ទំនងរវាងសិស្ស និងមនុស្សជំនាន់មុនដោយរបៀបណា?
- តើការសិក្សាអំពីប្រវត្តិសាស្រ្តនេះ មានឥទ្ធិពលអ្វីខ្លះទៅលើអារម្មណ៍នៃសេចក្តីមេត្តា និងការអាណិតអាសូររបស់សិស្ស?
- តើការសិក្សាអំពីប្រវត្តិសាស្រ្តនេះ ជួយជំរុញលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាដោយរបៀបណា?

ក្នុងនាមជាអ្នកអប់រំម្នាក់ នៅពេលចំណាយពេលវេលាពិចារណាទៅលើវត្ថុបំណងនៃការបង្ហាត់បង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ គ្រូប្រហែលជាអាចជ្រើសរើសប្រធានបទទាំងឡាយណាដែលទាក់ទាញការចាប់អារម្មណ៍របស់សិស្ស និងផ្តល់ឲ្យសិស្សនូវការយល់ដឹងច្បាស់ជាងមុនមួយអំពីប្រវត្តិសាស្រ្តនេះ ។ សិស្សភាគច្រើនបង្ហាញអំពីការចាប់អារម្មណ៍កម្រិតខ្ពស់ នៅក្នុងការសិក្សាអំពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ ដោយសារតែប្រធានបទនេះ បានលើកឡើងអំពីបញ្ហាយុត្តិធម៌ ការគោរពតាមបញ្ជា ការស្លាប់ឳពុក ភាពភ័យខ្លាច និងទុក្ខវេទនារបស់មនុស្សជាតិ ដែលសុទ្ធសឹងជាបញ្ហាដែលយុវជនវ័យក្មេងប្រហែលជាធ្លាប់បានឆ្លងកាត់ ឬឃើញនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួនដែរ ។ សិស្សប្រហែលជាមានការចាប់អារម្មណ៍លើវិសាលភាពដ៏ធំធេងនៃអំពើឧក្រិដ្ឋកម្ម និងការពិតដែលថា មនុស្សជាច្រើននាក់ទទួលរងផលប៉ះពាល់ពីអំពើអមនុស្សធម៌ ដែលកើតមានឡើងមិនជាយូរប៉ុន្មាននេះ ។ សិស្សអាចសួរសំណួរខ្លះនៅផ្ទះរបស់ខ្លួន ហើយអាចនឹងចាប់អារម្មណ៍យកបទពិសោធន៍របស់សាច់ញាតិខ្លួន ប្រៀបធៀបនឹងបរិបទប្រវត្តិសាស្រ្តទូទៅមួយដែលធំជាងមុន ។

## ទស្សនវិជ្ជានៃការបង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ




សិស្សានុសិស្សនៃវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ កំពុងអានសៀវភៅប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យជាលើកទី១ ខែតុលា ឆ្នាំ២០០៩ ។ រូបថត : ដេង ពង្សរ៉ាស៊ី ។ ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ការបង្ហាត់បង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ ធ្វើឲ្យសិស្សមានចំណេះដឹងខ្លាំងជាងមុន មានបំណងប្រាថ្នាច្រើនជាងមុន ទទួលបានព័ត៌មាន បញ្ញាញាណច្រើនជាងមុន និងមានការយល់ដឹងច្រើនជាងមុនអំពីស្ថានភាពនៅក្នុងអតីតកាល និងបច្ចុប្បន្នកាល ។ ការបង្ហាត់បង្រៀនសិស្សអំពីរយៈកាលនៃប្រវត្តិសាស្រ្តនេះ ជាប់ពាក់ព័ន្ធនឹងការស្វែងរកការពិតយុត្តិធម៌ និងការផ្សះផ្សា តាមរយៈភ័ស្តុតាង ការស្រាវជ្រាវ ការវិភាគ ការពិភាក្សា និងការជជែកដេញដោលទៅលើអ្វីដែលបានកើតមានឡើងក្នុងអតីតកាល និងបច្ចុប្បន្នកាល ។

ដោយសារអំពើប្រល័យពូជសាសន៍ដ៏គួរឲ្យរន្ធត់ដែលទើបកើតឡើងថ្មីៗ នៅកម្ពុជា សិស្សជាច្រើននៅទូទាំងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន រស់នៅក្នុងស្ថានភាពមួយដែលការរស់នៅប្រចាំថ្ងៃជួបប្រទះនឹងភាពក្រីក្រ ភាពអត់ឃ្លាន ទុក្ខវេទនា និងការតស៊ូ ។ ដូច្នេះ អ្នកអប់រំនៅទូទាំងប្រទេសកម្ពុជាត្រូវតែផ្តល់ឲ្យសិស្សនូវសម្ភារ ចំណេះដឹងសមស្រប និងជំនាញ ដើម្បីជួយឲ្យសិស្សអាចជម្នះបាននូវឧបសគ្គទាំងនេះ និងអាចស្វែងរកជោគជ័យ នៅក្នុងសតវត្សរ៍ទី២១ ។

ដើម្បីឆ្លើយតបនឹងឧបសគ្គសង្គមទាំងឡាយ និងតម្រូវការដែលចេះតែកើតមានឡើងនៅក្នុងសតវត្សរ៍ទី២១ អ្នកអប់រំត្រូវ ៖

១) មានការអភិវឌ្ឍន៍ជំនាញ និងការបណ្តុះបណ្តាលជាប្រចាំអំពីទ្រឹស្តីនៃការអប់រំសម្រាប់គ្រូនាពេលបច្ចុប្បន្ន និងការអនុវត្តល្អៗ នៅក្នុងការអភិវឌ្ឍន៍ និងការរៀបចំកម្មវិធីសិក្សា ភាពខុសប្លែកគ្នាផ្នែកផ្សេងៗនៃមាតិកាការអាន និងការសិក្សាអំពីសាកលលោក ។

២) មានការយល់ដឹងបន្ថែមទៀតអំពីភាពចម្រូងចម្រាស និងលទ្ធភាពនៃការកើតមានឡើងនូវរឿងរ៉ាវ និងបញ្ហាទាំងឡាយនៅក្នុងសាកលលោក ដែលបានធ្វើការផ្លាស់ប្តូរជីវិតរបស់យើងទៅតាមព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រ និងស្ថានការណ៍នយោបាយ ។

៣) ផ្តល់បរិយាកាសមួយប្រកបដោយការយកចិត្តទុកដាក់នឹងប្រជាធិបតេយ្យ ដែលសិស្សអាចនិយាយ រៀនដោយបើកចំហ អាចពិភាក្សាប្រកបដោយភាពប្រាកដប្រជា និងអាចវិភាគប្រកបដោយការពិចារណាទៅលើបញ្ហាទាំងឡាយ ដូចជា អំពើហិង្សាក្នុងគ្រួសារ ការប្រើប្រាស់គ្រឿងស្រវឹង បញ្ហាសុខភាព ការរើសអើងភេទ ការរើសអើងពូជសាសន៍ ការស្អប់ខ្ពើមអំពើប្រល័យពូជសាសន៍ និងយុត្តិធម៌សង្គមជាដើម ។

៤) ផ្តល់នូវកម្មវិធីសិក្សាមួយ ដែលជំរុញដល់ការសួរសំណួរ និងការវាយតម្លៃដោយឯករាជ្យទៅលើប្រធានបទទាំងឡាយស្តីអំពីយុត្តិធម៌សង្គម ការអប់រំអំពីសាកលលោក សមធម៌ សន្តិភាព និងការផ្សះផ្សា ។

៥) បង្រៀនសិស្សឲ្យបានច្រើនជាងមេរៀនដែលមាននៅក្នុងថ្នាក់ ដើម្បីឲ្យសិស្សអាចស្វែងយល់ និងទទួលបាននូវបទពិសោធន៍ច្រើនបន្ថែមទៀត ។

៦) បង្រៀនសិស្សដោយប្រើប្រាស់បទពិសោធន៍ និងការរស់នៅផ្ទាល់របស់សិស្ស ។

៧) ជំរុញ និងលើកទឹកចិត្តសិស្សឲ្យសួរសំណួរ ធ្វើសកម្ម និងជំរុញឲ្យមានជោគជ័យ និងសមធម៌ តាមរយៈបទពិសោធន៍សិក្សាប្រកបដោយអត្ថន័យ ការអាន ការមើល និងសកម្មភាពផ្លាស់ប្តូរយោបល់គ្នា ។

៨) ជំរុញ និងលើកទឹកចិត្តសិស្សឲ្យធ្វើការរិះគន់ នឹងដើរតួនាទីយ៉ាងសកម្មមួយ ក្នុងការធ្វើឲ្យសាកលលោកក្លាយទៅជាកន្លែងមួយដែលមានសន្តិភាព និងសមភាពជាងមុន ។

## សៀវភៅណែនាំសម្រាប់គ្រូបង្រៀន

សៀវភៅណែនាំសម្រាប់គ្រូបង្រៀន ត្រូវបានរៀបចំឡើងដើម្បីជាជំនួយដល់គ្រូបង្រៀនថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ (ថ្នាក់ទី៩ - ១២) ក្នុងការបង្រៀនសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)” ដែលនិពន្ធដោយអ្នកស្រាវជ្រាវ ឌី ខាំបូលី បោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី១ នៃសៀវភៅណែនាំនេះ បង្ហាញអំពីសេចក្តីសង្ខេបនៃវគ្គសិក្សាទាំងមូល ។ ផ្នែកទី២ បង្ហាញអំពីមេរៀន និងដំបូន្មានអំពីការប្រើប្រាស់ ។

ផ្នែកទី៣ បង្ហាញអំពីរបៀបក្នុងការវាយតម្លៃ និងវាស់ស្ទង់ការសិក្សារបស់សិស្ស ។ ផ្នែកទី៤ បង្ហាញអំពីប្រភពធនធាន និងឯកសារយោងសម្រាប់ជាព័ត៌មាន និងជាជំនួយបន្ថែមទៀត ។



វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងពិភាក្សាជាមួយសិស្សានុសិស្សវិទ្យាល័យព្រះយុគន្ធរ អំពីសារសំខាន់នៃការថែរក្សាឯកសារ ភ្នំពេញ ខែតុលា ឆ្នាំ២០០៩ ។ រូបថត ៖ ដាត ពិសិដ្ឋ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

គ្រូមិនតម្រូវថា ត្រូវតែស្គាល់ ឬដឹងគ្រប់ព្រឹត្តិការណ៍លម្អិតនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនោះទេ ។ សៀវភៅណែនាំនេះរួមបញ្ចូលនូវមេរៀនគំរូ និងដំបូន្មានសម្រាប់ការបង្ហាត់បង្រៀនមួយចំនួន ដែលអាចជួយគ្រូ និងសិស្សក្នុងការសិក្សា និងការស្រាវជ្រាវ ។ ការជ្រើសរើសមេរៀន និងប្រភពធនធានគួរតែត្រូវធ្វើឡើងដោយផ្អែកទៅលើមូលដ្ឋាន គ្រឹះច្បាស់លាស់សម្រាប់សិស្ស និងសមស្របសម្រាប់មេរៀននីមួយៗ ។ គ្រូអាចជ្រើសរើសមេរៀនទាំងអស់ ឬមេរៀនមួយចំនួននៅក្នុងសៀវភៅណែនាំនេះ យកមកប្រើប្រាស់ ។ គ្រូត្រូវបានលើកទឹកចិត្តឲ្យពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការណែនាំបន្ថែមទៅលើមេរៀនដែលចាំបាច់ ។

សៀវភៅណែនាំសម្រាប់គ្រូបង្រៀន គឺឆ្លើយតបនឹងសៀវភៅលំហាត់សម្រាប់សិស្ស ។ នៅក្នុងពេលបង្រៀន គ្រូអាចដកស្រង់ចេញពីសៀវភៅណែនាំនេះ នៅក្នុងពេលវេលាសមស្រប ឬកាលៈទេសៈចាំបាច់ណាមួយ ។

## របៀបក្នុងការប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀនជាមួយសៀវភៅលំហាត់សម្រាប់សិស្ស

### វិធីសាស្ត្រទី១ក្នុងការប្រើប្រាស់សៀវភៅលំហាត់ ៖

**ក) ការពណ៌នាអំពីមេរៀន ៖ ការអានដោយយកចិត្តទុកដាក់ និងការធ្វើលំហាត់ជាក្រុម ។**

សិស្សប្រចាប់បញ្ចូលគ្នានូវជំនាញនៃការអាន ដូចជា ភ្ជាប់មេរៀនមួយទៅមេរៀនមួយទៀត ការពិចារណា ការអានតាមលំដាប់លំដោយ ការធ្វើសេចក្តីសន្និដ្ឋាន ការធ្វើសេចក្តីសរុបជាទូទៅ ការព្យាករណ៍ ការវិភាគ និងការវាយតម្លៃ ។

**ខ) ការណែនាំ ៖ សិស្សធ្វើការជាក្រុមដែលមានគ្នា២ឬ៣នាក់ ។ សិស្សអានអត្ថបទមេរៀនរៀងៗខ្លួន រួចឆ្លើយនិងពិភាក្សាសំណួរទាំងឡាយនៅលើក្រដាសលំហាត់ ។** សិស្សអាចពិភាក្សាសំណួរទាំងនោះជាមួយសមាជិកក្រុមរៀងៗខ្លួន ។ គ្រូរៀបចំថ្នាក់សាជាថ្មីឡើងវិញ បន្ទាប់ពីរយៈពេល៣០នាទី ហើយបកស្រាយសំណួរនៅលើក្រដាសលំហាត់ជាមួយសិស្ស ។ មកត្រឹមចំណុចនេះ គ្រូអាចដាក់ការងារបន្ថែមដើម្បីបង្កើននៃការសរសេរ ការឡើងពន្យល់ ឬជំនាញដំបូងក្នុងការស្រាវជ្រាវ ។

### វិធីសាស្ត្រទី២ក្នុងការប្រើប្រាស់សៀវភៅលំហាត់ ៖

**ក) ការពណ៌នាមេរៀន ៖ ការអានដោយយកចិត្តទុកដាក់ និងការធ្វើលំហាត់ជាឯកជន ។**

សិស្សប្រចាប់បញ្ចូលគ្នា នូវជំនាញនៃការអាន ដូចជា ភ្ជាប់មេរៀនមួយទៅមេរៀនមួយទៀត ការពិចារណា ការ

អានតាមលំដាប់លំដោយ ការធ្វើសេចក្ដីសន្និដ្ឋាន ការធ្វើសេចក្ដីសរុបជាទូទៅ ការព្យាករណ៍ ការវិភាគ និងការវាយតម្លៃ ។

**ខ)** **ការណែនាំ :** គ្រូហៅឈ្មោះសិស្សឲ្យអានផ្នែកខ្លះនៃមេរៀនៗ នៅក្នុងថ្នាក់ រួចផ្លាស់ប្ដូរអ្នកអានក្នុងរវាងមួយកថាខណ្ឌម្ដង ឬពីរ ឬបីកថាខណ្ឌម្ដង ។ នៅពេលដែលសិស្សម្នាក់កំពុងអាន សិស្សដទៃទៀតគួរបំពេញចម្លើយនៅក្នុងតារាងសំណួរក្នុងសៀវភៅលំហាត់ ។ បន្ទាប់ពីបញ្ចប់ការអានមេរៀនជាមួយសិស្ស គ្រូផ្ដល់ពេលវេលាពី៥ ទៅ១០ នាទី ឲ្យសិស្សបំពេញចន្លោះទាំងឡាយដែលមិនទាន់បានឆ្លើយ ។ មកដល់ត្រឹមចំណុចនេះ គ្រូអាចដាក់ការងារបន្ថែមទៀតដើម្បីបង្កើនការសរសេរ ការឡើងពន្យល់ ឬជំនាញដំបូងក្នុងការស្រាវជ្រាវ ។

ព័ត៌មានខាងក្រោមនេះ គឺជាការរៀបរាប់អំពីវត្ថុបំណងនៃមេរៀន និងអំពីរបៀបថា តើសកម្មភាពដ៏ជាក់លាក់ ការសួរសំណួរ និងឯកសារនានា អាចវាយតម្លៃ និងវាស់ស្ទង់បានថា តើសិស្សបានបំពេញទៅតាមគោលបំណងទាំងនេះបានល្អកម្រិតណា ។ ដោយប្រើប្រាស់មេរៀន និងដំបូន្មានទាំងឡាយនៅក្នុងសៀវភៅណែនាំនេះ គ្រូនឹងអាចស្វែងយល់ថាតើកន្លែងណាខ្លះដែល មានការចាំបាច់ក្នុងការផ្លាស់ប្ដូរ ការពណ៌នាអំពីវត្ថុបំណងនៃវគ្គសិក្សា ព្រមទាំងនៅក្នុងវិធីសាស្ត្រដែលត្រូវបានវាយតម្លៃ និងវាស់ស្ទង់ ។ សូមត្រឡប់ទៅមើលមាតិកានៃសៀវភៅណែនាំនេះ ដើម្បីស្វែងរកទីតាំងនៃមេរៀន និងសកម្មភាពជាក់លាក់ណាមួយ ។

### វត្ថុបំណងនៃវគ្គសិក្សា

១) សិស្សរៀបរាប់អំពីព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សដឹងព័ត៌មានលម្អិតសំខាន់ៗអំពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សពណ៌នាព័ត៌មានលម្អិតសំខាន់ៗអំពីទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ ។

៤) សិស្សស្វែងយល់ពីព្រឹត្តិការណ៍ និងព័ត៌មានសំខាន់ៗអំពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម ។

៥) សិស្សពន្យល់ព័ត៌មានលម្អិតសំខាន់ៗអំពីរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៦) សិស្សពន្យល់អំពីប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហម ។

៧) សិស្សប្រៀបធៀបអំពីទស្សនវិស័យ គំនិត និងការអង្កេតមួយចំនួនអំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៨) សិស្សវិភាគអំពីមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ខ្មែរក្រហម ។

៩) សិស្សវិភាគអំពីភាពខុសគ្នារវាងជីវិតនាពេលបច្ចុប្បន្ន និងជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

១០) សិស្សត្រិះរិះពិចារណាទៅលើមូលហេតុ ឥទ្ធិពល និងផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ ។

១១) សិស្សវិភាគទៅលើផលប៉ះពាល់មួយចំនួននៃរបបកម្ពុជាប្រជាធិបតេយ្យមកលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។

១២) សិស្សវាយតម្លៃអំពីមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ខ្មែរក្រហម ។

១៣) សិស្សវិភាគ និងវាយតម្លៃអំពីប្រវត្តិសាស្ត្រ និងជនរងគ្រោះនៃរបបខ្មែរក្រហម ដោយធ្វើការប្រៀបធៀបទៅនឹងបទពិសោធន៍នៃអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ដែលកើតមានឡើងនៅក្នុងប្រទេសផ្សេង ។

១៤) សិស្សវិភាគពីបញ្ហាចម្រូងចម្រាសមួយចំនួនទាក់ទងនឹងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

១៥) សិស្សពិចារណាអំពីការប្រើប្រាស់ ការរំលោភអំណាច តួនាទី និងការទទួលខុសត្រូវរបស់បុគ្គល ស្ថាប័ន និងសហគមន៍អន្តរជាតិ នៅពេលដែលត្រូវប្រឈមមុខជាមួយនឹងការរំលោភសិទ្ធិមនុស្ស ឬគោលនយោបាយប្រល័យពូជសាសន៍ ។

១៦) សិស្សទទួលបាននូវចំណេះដឹងពីប្រវត្តិសាស្ត្រ សង្គម នយោបាយ និងសេដ្ឋកិច្ចជាច្រើន ដែលនាំទៅដល់ការឡើងកាន់អំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សិស្សទទួលបានទស្សនវិស័យមួយថា តើប្រវត្តិសាស្ត្រកើតឡើងដោយរបៀបណា? និងថាតើការរួមបញ្ចូលគ្នានៃកត្តាទាំងអស់នេះ នាំទៅដល់ការបែកបាក់តម្លៃនៃអរិយធម៌ដោយរបៀបណា?

១៧) សិស្សឲ្យតម្លៃទៅលើចំណេះដឹងរបស់អ្នកដែលនៅរស់រានមានជីវិត និងជំរុញឲ្យមានការផ្លាស់ប្តូរតវិយាបថជាមួយនឹងមនុស្សជំនាន់មុនរបស់ខ្លួន (ដូចជាការធ្វើបទសម្ភាសន៍ ការសាកសួរពីប្រវត្តិគ្រួសារ និងសមាគមន៍ជាដើម) ។

១៨) សិស្សអភិវឌ្ឍការគិតដែលបង្ហាញពីសេចក្តីមេត្តា និងសេចក្តីអាណិតអាសូរ ។

១៩) សិស្សពិចារណាពីផលប៉ះពាល់អវិជ្ជមាននៃការសងសឹកគ្នាទៅវិញទៅមក នៅក្នុងសង្គមកម្ពុជា និងស្វែងយល់ពីតម្រូវការនៃការផ្សះផ្សាជាតិ ។

២០) សិស្សពន្យល់ពីអត្ថន័យនៃតម្លៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

២១) សិស្សរៀនពីការចូលរួម និងរស់នៅជាមួយគ្នាប្រកបដោយសុខសន្តិភាពនៅក្នុងសង្គម ។

## វិធីសាស្ត្របង្រៀន

**គោលដៅ :** កំណត់គោលដៅដើម្បីបង្ហាញអំពីវត្ថុបំណង និងហេតុផលដែលគ្រូ និងសិស្សត្រូវធ្វើក្នុងរយៈពេលសិក្សា ។ គ្រូប្រើប្រាស់ផ្នែកនេះ ដើម្បីបង្ហាញអំពីគោលដៅនៃមេរៀនដែលទាញចេញពីផែនការ និងសកម្មភាពមុនៗ ហើយកំណត់ជំហាន ដោយធ្វើការរៀបចំសិស្សសម្រាប់ការសិក្សាបន្តទៀត ។

**វត្ថុបំណង :** គ្រូផ្តោតទៅលើអ្វីដែលសិស្សរបស់ខ្លួនត្រូវតែធ្វើ ឬអាចធ្វើបានដើម្បីទទួលបាននូវចំណេះដឹង និងជំនាញផ្សេងៗបន្ថែមទៀត ។ វត្ថុបំណងទាំងឡាយសម្រាប់ផែនការមេរៀនប្រចាំថ្ងៃ ត្រូវទាញចេញពីវត្ថុបំណងធំនៃផែនការក្នុងជំពូកនីមួយៗ ប៉ុន្តែវត្ថុបំណងនេះសម្រេចបាននៅក្នុងពេលបង្រៀន ។



សិស្សានុសិស្សវិទ្យាល័យព្រះយុគន្ធរ កំពុងអានសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ជាមួយមិត្តភក្តិ ខែតុលា ឆ្នាំ២០០៩ ។ រូបថត : ដាត ពិសិដ្ឋ ។ ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភារឧបទេស :** សូមកំណត់ ៖ ក) តើត្រូវការពេលវេលាប៉ុន្មាន ក្នុងការរៀបចំស្វែងរកប្រភពធនធាន និងការគ្រប់គ្រង សម្រាប់ការអនុវត្តផែនការនេះ? ខ) តើឧបករណ៍ សៀវភៅ សម្ភារ និងប្រភពធនធាន ដែលត្រូវការជាចាំបាច់មានអ្វីខ្លះ?

**លំនាំបង្រៀន :** គ្រូផ្តល់ឲ្យសិស្សនូវការពណ៌នាជាជំហានៗ និងលម្អិតអំពីរបៀបក្នុងការបង្រៀន និងគោលដៅនៃ

ផែនការមេរៀន ដោយផ្តោតទៅលើអ្វីដែលសិស្សគួរធ្វើនៅក្នុងអំឡុងពេលនៃការបង្រៀន ។ ជាទូទៅ ផ្នែកនេះត្រូវបាន បែងចែកជាបីផ្នែក ៖ ការផ្តើមបង្រៀន ការបង្រៀន និងសំយោគ ។ នេះជាទម្រង់នៃការបង្រៀនដែលអាចគ្រប់គ្រងបាន មានភាពងាយស្រួល និងមានលក្ខណៈគរុកោសល្យ ។

**ដំណាក់កាលទី១ ៖ ការផ្តើមបង្រៀន (៥-១០នាទី)**

នេះជាពេលវេលាដែលគ្រូផ្តល់ឲ្យសិស្សនូវព័ត៌មានដែលសិស្សត្រូវការរៀនមេរៀន និងបំពេញលំហាត់ ឬកិច្ចការដែលត្រូវធ្វើ ។ គ្រូគួរផ្តល់ឲ្យសិស្សនូវសេចក្តីណែនាំច្បាស់លាស់ដើម្បីឲ្យសិស្សអាចធ្វើលំហាត់បាន ។ នេះគឺជាដំណាក់កាលសម្រាប់ពិនិត្យមើលចំណេះដឹងបឋមរបស់សិស្ស និងប៉ាន់ស្មានពីកម្រិតនៃការយល់ដឹងទៅលើប្រធានបទមួយ តាមរយៈការពិភាក្សាជាជំហានដំបូងនៅក្នុងថ្នាក់ទាំងមូល ។ នៅក្នុងដំណាក់កាលនេះ គ្រូត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីគោលដៅ និងការរំពឹងចង់បាន ។ ជាងនេះទៅទៀត គ្រូត្រូវពន្យល់អំពីហេតុផល ឬតម្លៃនៃការសិក្សា ។ នៅចុងបញ្ចប់នៃដំណាក់កាលនេះ សិស្សអាចយល់បានថា តើហេតុអ្វីបានជាប្រធានបទដែលខ្លួនកំពុងសិក្សានេះមានសារសំខាន់ ។ ខាងក្រោមគឺជាសំណួរសម្រាប់ពិចារណាក្នុងការរៀបចំផែនការបង្រៀនក្នុងដំណាក់កាលនេះ ៖

- តើខ្ញុំត្រូវចាប់ផ្តើមបង្រៀនមេរៀននេះដោយរបៀបណា?
- តើចំណេះដឹងដំបូងដែលសិស្សរបស់ខ្ញុំត្រូវការមានអ្វីខ្លះ?
- តើខ្ញុំចាំបាច់ត្រូវបង្រៀនមេរៀនកម្រិតទាប(ការណែនាំដោយផ្ទាល់)ជាមុនសិន ឬយ៉ាងណា?
- តើប្រភពធនធានដែលខ្ញុំត្រូវការដើម្បីជួយទ្រទ្រង់អត្ថន័យនៅក្នុងមេរៀនមានអ្វីខ្លះ? ដើម្បីធានាឲ្យបានថា ប្រភពធនធាន និងឯកសារ ឬភ័ស្តុតាងមានលក្ខណៈទាន់សម័យកាលនៅក្នុងឆ្នាំនេះ តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច?
- ដើម្បីយល់អំពីអត្ថន័យ និងទស្សនៈនៃមេរៀន តើសិស្សចាំបាច់ត្រូវដឹងអ្វីខ្លះ?
- តើខ្ញុំអាចធ្វើមេរៀនឲ្យទៅជារឿងផ្ទាល់ខ្លួន និងមានទំនាក់ទំនងជាមួយសិស្សដោយរបៀបណា?
- តើគុណសម្បត្តិ និងគុណវិបត្តិដែលខ្ញុំអាចប៉ាន់ប្រមាណទុកជាមុនបានមានអ្វីខ្លះ?
- តើមេរៀននេះត្រូវចំណាយពេលវេលាប៉ុន្មានក្នុងការបង្រៀន?

**ដំណាក់កាលទី២ ៖ ការបង្រៀន (១៥-៤៥នាទី)**

នេះជាដំណាក់កាល ដែលសិស្សធ្វើការជាបុគ្គល ឬជាក្រុម ដើម្បីស្វែងយល់ព័ត៌មាន ឬគំនិតនៅក្នុងមេរៀន ។ តួនាទីរបស់គ្រូ គឺដើរពីតុមួយទៅតុមួយ ហើយស្តាប់ការពិភាក្សារបស់សិស្សដោយយកចិត្តទុកដាក់ ។ គ្រូត្រូវពិនិត្យមើលថាតើសិស្សមានចម្ងល់ ឬប្រតិកម្មយ៉ាងណាខ្លះចំពោះមេរៀន ហើយត្រូវជួយសិស្សដែលរកចម្លើយមិនឃើញ ឬសិស្សដែលអាចទៅមុខបាន តាមរយៈការចោទសួរជាសំណួរ ដើម្បីជំរុញដល់ការគិតរបស់សិស្ស ។ ខាងក្រោមជាសំណួរ ដែលត្រូវពិចារណានៅពេលរៀបចំផែនការសម្រាប់ដំណាក់កាលនេះ ៖

- តើខ្ញុំត្រូវរៀបចំសិស្សឲ្យស្វែងរកព័ត៌មាន ឬចូលរួមនៅក្នុងលំហាត់ត្រិះរិះពិចារណាដោយរបៀបណា? (ធ្វើការជាបុគ្គល? ជាក្រុម? ជាដៃគូ?)
- តើឯកសារដែលសិស្សត្រូវការដើម្បីជំរុញដល់ការត្រិះរិះពិចារណាប្លែកៗ និងជំរុញដល់ការដោះស្រាយបញ្ហាមានអ្វីខ្លះ?
- តើមានវិធីសាស្ត្រផ្សេងទៀតអ្វីខ្លះដែលខ្ញុំរំពឹងចង់ឲ្យសិស្សអនុវត្ត?





សិស្សានុសិស្សកំពុងកត់ត្រាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅក្នុងវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០០៩។ រូបថត ៖ ដាត ពិសិដ្ឋ។ ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

- តើខ្ញុំអាចសួរសំណួរប្រភេទណាខ្លះ ដើម្បី ៖
  - ក) ជំរុញ និងស្ទង់មើលការគិតរបស់សិស្ស ប្រសិនបើការមិនចូលចិត្តមានកម្រិតខ្ពស់។
  - ខ) ជំរុញការសន្ទនា ការគិត និងការរៀនរវាងសិស្ស និងសិស្ស...។ល។

### ដំណាក់កាលទី៣ ៖ សំយោគ (១៥-២៥នាទី)

នេះគឺជាផ្នែកចម្បងនៃការបង្រៀន។ បញ្ចូលក្រុមទាំងអស់ជាមួយគ្នា ហើយឲ្យសិស្សឡើងសង្ខេបអំពីការគិត ឬការរៀនរបស់ខ្លួន។ តួនាទីរបស់គ្រូ គឺណែនាំសិស្សឲ្យសំយោគគោលគំនិតធំៗ ដើម្បីធានាឲ្យបានថា សិស្សស្ថិតនៅក្នុងទិសដៅរួមគ្នា ជាមួយនឹងវត្ថុបំណងមេរៀន។ ផ្នែកខ្លះនៃវត្ថុបំណងនៅក្នុងសំយោគ គឺដើម្បីអនុញ្ញាតឲ្យគ្រូធ្វើការប៉ាន់ស្មានថា តើសិស្សរបស់ខ្លួនមានការរីកចម្រើនបានល្អកម្រិតណា ឆ្ពោះទៅកាន់គោលដៅនៃមេរៀន។ ប្រើការពិភាក្សា ដើម្បីជាជំនួយក្នុងការកំណត់ថា តើគ្រូចាំបាច់ត្រូវការបង្ហាត់បង្រៀនបន្ថែម ឬសិស្សត្រូវស្វែងយល់បន្ថែមទៀតទេ មុនពេលចាប់ផ្តើមរៀនមេរៀនបន្ទាប់។ ខាងក្រោមជាសំណួរគួរពិចារណានៅពេលរៀបចំផែនការសម្រាប់ដំណាក់កាលនេះ ៖

- តើខ្ញុំត្រូវដឹកនាំការពិភាក្សាដើម្បីឲ្យសិស្សអាចសង្ខេបការសិក្សារបស់ខ្លួនបានដោយរបៀបណា?
- តើទស្សនៈនិងដំណើរការដែលត្រូវសិក្សាឲ្យបានស៊ីជម្រៅជាងមុនមានអ្វីខ្លះ?
- តើចំណុចដែលត្រូវគូសបញ្ជាក់មានអ្វីខ្លះ?
- តើគំនិតដែលមិនត្រូវការពិនិត្យបន្ថែមមានអ្វីខ្លះ?
- តើយើងអាចបង្រៀនលើសពីមេរៀននេះដោយរបៀបណា?
- តើមេរៀនអំពីវិធីសាស្ត្រណាមួយ ដែលអាចយកមកប្រើប្រាស់នៅក្នុងបរិបទផ្សេងបាន?
- តើសំណួរថ្មីៗដែលអាចកើតឡើងមានអ្វីខ្លះ?
- ដើម្បីដាក់គំនិតទាំងឡាយទៅក្នុងការអនុវត្តបន្ទាប់ពីសំយោគ តើខ្ញុំត្រូវធ្វើអ្វីខ្លះ?
- ដើម្បីធានាឲ្យបានថា ពេលវេលាដែលត្រូវចំណាយនៅក្នុងថ្នាក់សមស្របនឹងទំហំ និងវត្ថុបំណងរបស់មេរៀន

តើខ្ញុំត្រូវធ្វើដូចម្ដេច?

- តើផលវិបាកដែលខ្ញុំអាចប៉ាន់ប្រមាណទុកជាមុនមានអ្វីខ្លះ?

**កិច្ចការផ្ទះ (កិច្ចការបន្ថែម ឬការផ្ទុះបញ្ចាំងទៅលើមេរៀន) :** នេះគឺជាសកម្មភាព ឬការសិក្សាបន្ថែមសម្រាប់សិស្សធ្វើបន្ទាប់ពីថ្នាក់រៀន ។

**ការវាយតម្លៃ :** គ្រូត្រូវផ្ដោតទៅលើគោលដៅថាតើសិស្សបានមកដល់គោលដៅដែរឬទេ ។ គ្រូចាំបាច់ត្រូវប្រមូលភ័ស្ដុតាងមួយចំនួនដែលសិស្សបានធ្វើ ។ ជាទូទៅ កិច្ចការនេះធ្វើឡើងដោយការប្រមូលកិច្ចការរបស់សិស្ស និងធ្វើការវាយតម្លៃ ដោយប្រើប្រាស់តារាងពិន្ទុដែលផ្អែកទៅលើវត្ថុបំណងនៃមេរៀន (មើលមាតិកានៃសៀវភៅណែនាំនេះសម្រាប់ផ្នែក ឬលេខទំព័រនៃឧទាហរណ៍តារាងពិន្ទុ) ។ គ្រូអាចចោទសួរសិស្សទៅលើចំណុចផ្សេងៗជាច្រើនទៀត ។

## សំណាំឯកសារសិក្សារបស់សិស្សសម្រាប់វាយតម្លៃកម្មវិធីសិក្សា

គ្រូគួរធ្វើការជ្រើសរើសសិស្សយ៉ាងតិចពីរនាក់ (ស្រីម្នាក់ ប្រុសម្នាក់) ដើម្បីប្រមូលកិច្ចការទាំងអស់របស់សិស្សគ្រប់គ្នាសម្រាប់រក្សាទុកជាឯកសារ និងវាយតម្លៃកម្មវិធីសិក្សាក្នុងរយៈពេលនៃការបង្ហាត់បង្រៀនមុខវិជ្ជានេះ ។ សំណុំឯកសាររបស់សិស្សទាំងនេះ នឹងជួយដល់អ្នកវាយតម្លៃកម្មវិធីសិក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួង អប់រំ យុវជន និងកីឡា ក្នុងការវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធីសិក្សា និងកំណត់ចំណុចដែលត្រូវកែលម្អ ។

**សម្ភារឧបទេស :** ការប្រមូលកិច្ចការទាំងអស់របស់សិស្ស ៖ តែងសេចក្ដី កំណាព្យ រូបភាព និងសៀវភៅលំហាត់របស់សិស្ស ។

# ផ្នែកទី២
# មេរៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## មេរៀនទី១ ៖ សេចក្តីផ្តើមនៃមេរៀន

### វត្ថុបំណង

១) សិស្សសិក្សាពីស្នាដៃវប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរមុនសម័យខ្មែរក្រហម ។

២) សិស្សរៀបរាប់ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ ។

៤) សិស្សកំណត់ពីផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើជីវិតរស់នៅបច្ចុប្បន្ន ។

***សម្ភារឧបទេស*** ៖ សៀវភៅលំហាត់ កំណាព្យបង្ហាញពីបទពិសោធន៍នៃការឆ្លងកាត់ទុក្ខវេទនានៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារភ្លេងជាតិកម្ពុជាប្រជាធិបតេយ្យ រូបភាពប្រាសាទបុរាណ រូបភាពអគារល្បីៗ និងរូបភាពនៅពេលដែលប្រទេសកម្ពុជាមានសុខសន្តិភាព ។

### កំណាព្យ



ប្រាសាទអង្គរវត្ត នាពេលព្រឹកព្រលឹម
រូបថត ៖ ង៉ូច មករា

**ត្រឡប់រកឪពុក**

ពេលកូនចេញទៅ ពុកនៅលើគ្រែ
ញាក់ញ័រគ្មានល្ហែ ពុកនៅឯគោ

អត់បាយ អត់ទឹក ពុកពឹងពុទ្ធោ
ក្នុងប្រាណពេញពោរដោយក្តីឈឺផ្សា ។

ពុកពុំទៅទេ នៅការវេទនាធម៌
ប៉ុល-ពត បន្ទាំង បុត្រពីបិតា
ពេលនេះកូនមក ពុកបង់សង្ខារ
តើពុកវេទនា ខ្លោចផ្សាយ៉ាងណាទៅ!

## ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»

*ប្តូរពីទន្ទេញឈាម ទៅជាទន្ទេញនៃការបង្រួបបង្រួម*
*គឺជាទន្ទេញនៃការទទួលខុសត្រូវ ។*
*និយាយ! និយាយ! និយាយ!*



*ទស្សនីយភាពមួយនៅក្នុងសាច់រឿងល្ខោននិយាយរឿង ទម្លាយភាពស្ងៀមស្ងាត់ សម្តែងនៅទីក្រុងភ្នំពេញ ២០០៩ ។ រូបថត ៖ ជីម មីហ្សើស្ត៊ី*

## ភ្លេងជាតិកម្ពុជាប្រជាធិបតេយ្យ

*ឈាមក្រហមច្រាល ស្រោចស្រពក្រុងវាលកម្ពុជា មាតុភូមិ*
*ឈាមកម្មករកសិករដ៏ឧត្តម ឈាមយុទ្ធជន យុទ្ធនារីបដិវត្តន៍ ។*

*ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លា តស៊ូមោះមុត ១៧មេសា*
*ក្រោមទង់បដិវត្តន៍ ឈាមរំដោះផុត ពីភាពខ្ញុំគេ ។*

*ជយោ! ជយោ! ១៧មេសាជោគជ័យ មហាអស្ចារ្យ*
*មានន័យធំធេងលើសសម័យអង្គរ ។*

*យើងរួបរួមគ្នា កសាងកម្ពុជានិង សង្គមថ្មីបវរ ប្រជាធិបតេយ្យ*
*សមភាព និងយុត្តិធម៌ តាមមាគ៌ា ម្ចាស់ការឯករាជ្យ រឹងមាំ*
*ប្តេជ្ញាដាច់ខាត ការពារជាតិមាតុភូមិ ទឹកដីឧត្តម បដិវត្តន៍រុងរឿង ។*

*ជយោ! ជយោ! ជយោ កម្ពុជាថ្មី ប្រជាធិបតេយ្យ សម្បូរថ្កុំថ្កើង*
*ប្តេជ្ញាជ្រោងគ្រវីទង់បដិវត្តន៍ក្រហមខ្ពស់ឡើង*
*សាងមាតុភូមិយើងឲ្យចម្រើនលោតផ្លោះ មហារុងរឿង*
*មហាអស្ចារ្យ ។*




***សញ្ញាជាតិកម្ពុជាប្រជាធិបតេយ្យ*** ៖ *រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យចែងថា សញ្ញាជាតិ គឺមានប្រព័ន្ធស្រែ និងប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿន មានរោងចក្រជានិមិត្តរូបនៃឧស្សាហកម្ម មានកម្រងកួរស្រូវ ជាស្នែងក្របព័ទ្ធពីក្រៅ ហើយមានអក្សរ“កម្ពុជាប្រជាធិបតេយ្យ”នៅពីក្រោម ។ ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា*





***រូបខាងលើឆ្វេង*** ៖ *ណារីម និង ប៉ែល អ្នករបាំនៃអង្គការ សិល្បៈខ្មែរអម្រឹតា រាំនៅលើប្រាង្គប្រាសាទកោះកែរ ខេត្តព្រះវិហារ។ រូបថត ៖ ម៉ែន ពិចិត្រ។* ***រូបខាងលើខាងស្តាំ*** ៖ *រូបចម្លាក់អប្សរានៅលើជញ្ជាំងប្រាសាទអង្គរវត្ត ឆ្នាំ២០១៤ រូបថត ៖ ជី ទេវិទ្ធិ។* ***រូបខាងក្រោម*** ៖ *ប្រាសាទកោះកែរ ខេត្តព្រះវិហារ ព័ទ្ធជុំវិញដោយព្រៃស្រោង។ រូបថត ៖ អេង កុកថាយ*





**រូបខាងលើ ៖** ប្រាសាទព្រះវិហារ ស្ថិតនៅភាគខាងជើងប្រទេសកម្ពុជា សាងសង់ឡើងក្នុងរជ្ជកាលព្រះបាទសុរិយាវរ្ម័នទី១ និងសុរិយាវរ្ម័នទី២ ចន្លោះសតវត្សរ៍ទី១១-១២ ។ កាលពីខែកក្កដា ឆ្នាំ២០០៨ ប្រាសាទព្រះវិហារត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ ។ **រូបខាងក្រោម ៖** ប្រាសាទបន្ទាយឆ្មារសាងសង់ឡើងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ សតវត្សរ៍ទី១២ ខេត្តបន្ទាយមានជ័យ ។ រូបថត ៖ ញាណ សុជាតិ និង ឆាំង យុ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា



## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥ - ១០ នាទី)*

គ្រូណែនាំអំពីវត្ថុបំណងនៃមេរៀនទៅកាន់សិស្ស ។ សម្រាប់សេចក្ដីផ្ដើមក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គ្រូណែនាំសិស្សអំពីសោភ័ណភាព និងសមិទ្ធផលដ៏អស្ចារ្យនៃវប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ ។ គ្រូផ្ដល់ឱកាសឲ្យសិស្សគិតអំពីជីវិតមុនរបបកម្ពុជាប្រជាធិបតេយ្យ ដោយពិនិត្យមើលលើរូបភាពដែលបង្ហាញអំពីប្រាសាទបុរាណ សំណង់អគារល្បីល្បាញ និងរយៈកាលសន្តិភាពនៅកម្ពុជា ដើម្បីឲ្យសិស្សពណ៌នាសមិទ្ធផលដ៏ល្បីល្បាញនៃប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរនៅលើសាកលលោក ។ បន្ទាប់ពីពិនិត្យមើលសមិទ្ធផលទាំងនេះរួចមក គ្រូចែកឯកសារអំពីភ្លេងជាតិកម្ពុជាប្រជាធិបតេយ្យឲ្យសិស្សអាន ។ សកម្មភាពនេះ បង្ហាញពីការផ្លាស់ប្ដូរដ៏ខ្លាំងក្លា ឬការប្រៀបធៀបរវាងជីវិតមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីអានភ្លេងជាតិ សិស្សស្ដាប់កំណាព្យដែលសូត្រៗ នៅក្នុងថ្នាក់ដែលបង្ហាញពីបទពិសោធន៍សោកសៅក្នុងរបបខ្មែរក្រហម ដើម្បីពិនិត្យមើលការផ្លាស់ប្ដូរនៃពេលវេលា និងបទពិសោធន៍របស់ប្រជាជនកម្ពុជា ។

គ្រូណែនាំឲ្យសិស្សសិក្សាអំពីព្រឹត្តិការណ៍នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសយើងគឺពេលដែលអំពើអយុត្តិធម៌ ប្រកបដោយភាពភ័យរន្ធត់មួយបានកើតមានឡើងនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃកំណើតនៃការចាប់ផ្ដើមអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា ។ នៅពេលនោះ ប្រជាជនប្រមាណជិតពីរលាននាក់បានស្លាប់ដោយការអត់អាហារ ការធ្វើការហួសកម្លាំង ជំងឺ និងការសម្លាប់ក្នុងចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

មុនពេលពិភាក្សាលម្អិតអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គ្រូសួរសិស្សអំពីនិយមន័យនៃពាក្យប្រល័យពូជសាសន៍ ។ បន្ទាប់មកគ្រូសរសេរពាក្យសំខាន់ៗ នៅលើក្ដារខៀន ដែលទាក់ទងនឹងនិយមន័យនៃអំពើប្រល័យពូជសាសន៍ ។ គ្រូពន្យល់ សិស្សថា អំពើប្រល័យពូជសាសន៍ គឺជាការបំផ្លិចបំផ្លាញទៅលើក្រុមមនុស្សដោយចេតនា ដោយឈរលើមូលដ្ឋាននៃការកំណត់ធាតុផ្សំជាក់លាក់មួយចំនួនដូចខាងក្រោម ៖ (សរសេរធាតុផ្សំទាំងនេះ នៅលើក្ដារខៀន)

- សកម្មភាពប្រព្រឹត្តបទល្មើស
- ដោយចេតនា
- ការកម្ទេច (ទាំងស្រុង ឬដោយផ្នែក)
- ក្រុមមនុស្សដែលត្រូវបានកំណត់
- ការឲ្យនិយមន័យមនុស្ស ដោយផ្អែកលើចរិតលក្ខណៈជាក់លាក់ (ដូចជាជាតិសាសន៍ សាសនា ជាតិពន្ធុ) ។

បន្ទាប់ពីគ្រូពន្យល់និយមន័យរួច គ្រូឲ្យសិស្សផ្ដល់ឧទាហរណ៍ពីអំពើប្រល័យពូជសាសន៍នៅក្នុងសតវត្សរ៍ទី២០ (ចម្លើយអាចរួមមាន ហូឡូខសត៍ អាមីនៀ រ៉្វាន់ដា កម្ពុជា និងអតីតយូហ្គោស្លាវី) ។

គ្រូពន្យល់សិស្សថា បន្ទាប់ពីព្រឹត្តិការណ៍ ហូឡូខសត៍ ដែលជនជាតិជ្វីហប្រមាណ ៦លាននាក់ត្រូវស្លាប់ដោយការធ្វើទុក្ខបុកម្នេញពីក្រុមណាហ្ស៊ីតាមទម្រង់ផ្សេងៗមក សហគមន៍អន្តរជាតិបានសម្រេចថា អំពើនេះនឹងមិនអាចកើតមានឡើងសាជាថ្មីម្ដងទៀតទេ ។ អង្គការសហប្រជាជាតិដែលទើបបង្កើតឡើងថ្មី បានអនុម័តអនុសញ្ញានៃអំពើប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៤៨ ។ សន្ធិសញ្ញានេះ ផ្ដល់និយមន័យផ្លូវការនៃអំពើប្រល័យពូជសាសន៍ និងបានកំណត់កាតព្វកិច្ចឲ្យប្រទេសទាំងអស់ដែលផ្ដល់សច្ចាប័នទៅលើសន្ធិសញ្ញានេះ ត្រូវតែធ្វើអន្តរាគមន៍ទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅពេលណាដែល

អំពើនេះកើតមានឡើង ។

និយមន័យផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍ដែលកំណត់ដោយអង្គការសហប្រជាជាតិគឺ ៖ ជាអំពើទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លាញចោលទាំងស្រុង ឬមួយផ្នែកចំពោះក្រុម ជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬក្រុមសាសនាណាមួយដូចជា ៖

- ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម
- បង្កការឈឺចាប់ និងខូចខាតយ៉ាងធំធេងដល់ផ្នែករាងកាយ ឬស្មារតីដល់សមាជិកទាំងឡាយនៅក្នុងក្រុម
- បង្កឡើងដោយចេតនា នូវមហន្តរាយដល់ស្ថានភាពរស់នៅរបស់ក្រុម ដោយនាំមកនូវការបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុម
- ការបង្ខំង និងដាក់នូវវិធានការនានាដើម្បីបង្ការមិនឲ្យមានកំណើតទារកនៅក្នុងសង្គម
- យកកុមារចេញពីសង្គមមួយទៅដាក់នៅក្នុងសង្គមមួយទៀតដោយបង្ខំ

(មាត្រា២នៃអនុសញ្ញាស្ដីពីការបង្ការ និងការផ្ដន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍)

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សប្រើប្រាស់សៀវភៅលំហាត់ ដើម្បីសរសេរអំពីការផ្លាស់ប្ដូរយ៉ាងខ្លាំងដែលកើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សិស្សពិនិត្យមើលថា តើអំពើប្រល័យពូជសាសន៍ និងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរមានផលប៉ះពាល់មកលើខ្លួនអ្វីខ្លះ ។

បន្ទាប់ពីសិស្សបញ្ចប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនរួចមក គ្រូឲ្យសិស្សធ្វើកិច្ចការជាដៃគូ (សូមមើលសកម្មភាពធ្វើការជាដៃគូនៅក្នុងប្រភពធនធាន និងឯកសារយោង) ។ គ្រូពន្យល់សិស្សថា តើសកម្មភាពធ្វើការជាដៃគូនឹងត្រូវប្រើប្រាស់នៅក្នុងវគ្គសិក្សាយ៉ាងដូចម្ដេច (សិស្សចែករំលែកពីអ្វីដែលខ្លួនបានសរសេរជាមួយដៃគូរបស់ខ្លួនក្នុងពេលធ្វើការជាដៃគូ) ។

*សំយោគ (១៥-២៥នាទី)*

នៅចុងបញ្ចប់នៃសកម្មភាពធ្វើការជាដៃគូ សិស្សចែករំលែកការយល់ឃើញរបស់ខ្លួនជាមួយនឹងសិស្សទាំងអស់នៅក្នុងថ្នាក់អំពីការផ្លាស់ប្ដូរដែលកើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រខ្មែរ និងផ្ដល់ឧទាហរណ៍មួយចំនួនថាតើអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានផលប៉ះពាល់មកលើជីវិតរស់នៅប្រចាំថ្ងៃអ្វីខ្លះ?

## មេរៀនទី២ ៖ ស្វែងយល់អំពីចំណេះដឹងពីមុនរបស់សិស្ស

### វត្ថុបំណង

១) សិស្សរំឭកឡើងវិញនូវចំណេះដឹងពីមុនរបស់ខ្លួនពីរបបខ្មែរក្រហម ។
២) សិស្សប្រើប្រាស់តារាង K-W-L ដើម្បីកត់ត្រាពីអ្វីដែលខ្លួនបានដឹង និងចង់ដឹង ។
៣) សិស្សពន្យល់ពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។
៤) សិស្សពិចារណា និងពិភាក្សាថា តើរយៈកាលនៃរបបខ្មែរក្រហម មានផលប៉ះពាល់អ្វីខ្លះមកលើជីវិតរស់នៅប្រចាំថ្ងៃនៅកម្ពុជានាពេលបច្ចុប្បន្ន?

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ តារាង K-W-L និងសៀវភៅលំហាត់

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូណែនាំអំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងវត្ថុបំណងរួមនៃមេរៀនទាំងមូល ។ គ្រូបង្កើតតារាង K-W-L (អ្វីដែលយើងដឹងអ្វីដែលយើងចង់ដឹង និងអ្វីដែលយើងបានរៀន) នៅលើក្ដារខៀន ហើយសរសេរព័ត៌មាន ពីចំណេះដឹងរបស់សិស្សអំពីប្រវត្តិសាស្ត្រនៅក្នុងតារាង (សូមមើលផ្នែកទី៤ ៖ ប្រភពធនធាន និងឯកសារយោង សម្រាប់ព័ត៌មានបន្ថែម) ។ គ្រូពន្យល់សិស្សពីរបៀបប្រើប្រាស់តារាង K-W-L នៅក្នុងថ្នាក់ ។ គ្រូឲ្យសិស្សពិភាក្សា និងពិនិត្យមើលព័ត៌មានដែលទាក់ទងនឹងអ្វីដែលសិស្សបានដឹងរួចហើយអំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ គ្រូឲ្យសិស្សពិភាក្សាថា តើខ្លួនបានរៀនពីព័ត៌មានទាំងនេះដោយរបៀបណា? តើអ្វីខ្លះ ដែលសិស្សបានរៀនពីឪពុកម្ដាយ ជីដូនជីតា បងប្អូន ។ល ។

បន្ទាប់ពីសិស្សបំពេញតារាង K គ្រូសរសេរព័ត៌មាន ដែលសិស្ស«ចង់ដឹង» អំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងតារាង ។ គ្រូសួរសំណួរទៅសិស្សទាក់ទងនឹងថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ និងជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (សម្លៀកបំពាក់ អាហារ ការងារ កន្លែងស្នាក់នៅ ការអប់រំ សាសនា ។ល ។) គ្រូណែនាំសិស្សឲ្យបំពេញតារាង W «អ្វីដែលយើងបានរៀន» នៅចុងបញ្ចប់នៃវគ្គសិក្សា ។ គ្រូរក្សាតារាងនេះទុក ។

គ្រូបង្ហាញ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) ទៅសិស្ស ហើយសួរថា តើសិស្សធ្លាប់អានសៀវភៅបែបនេះពីមុនមកទេ ។ គ្រូពន្យល់ថា សៀវភៅនេះរួមមានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលផ្អែកលើអ្នកដែលនៅរស់រានមានជីវិត ការស្រាវជ្រាវ ឯកសារយោង និងឯកសារដែលបានប្រមូល និងចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។ គ្រូអានកថាមុខត្វា ដែលសរសេរដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា វិទ្យាស្ថានស្លឹករឹត និងសេចក្ដីថ្លែងអំណរគុណរបស់លោក ឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រនេះ ដើម្បីជាការចាប់ផ្ដើមនៃមេរៀន និងបង្ហាញអំពីគោលបំណងត្រួសៗនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

គ្រូបង្ហាញរូបភាពនៅទំព័រដំបូងបន្ទាប់ពីក្របសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (រូបភាពសោ និងច្រវាក់) ។ គ្រូសួរសិស្សថា តើរូបភាពនេះមានអត្ថន័យចំពោះខ្លួនយ៉ាងដូចម្ដេច? គ្រូសួរសំណួរដូចខាងក្រោម ៖

១) នៅពេលអ្នកសម្លឹងមើលរូបភាពនេះ តើវត្ថុអ្វីដែលអ្នកមើលឃើញដំបូងគេបង្អស់?

២) តើអ្នកគិតថា រូបភាពនេះតំណាង ឬបង្ហាញពីការទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យដូចម្ដេចខ្លះ?

៣) ហេតុអ្វីបានជាមានការឃុំឃាំង?

៤) ហេតុអ្វីបានជាអ្នកគិតថា ខ្មែរក្រហមធ្វើការឃុំឃាំងមនុស្ស (ទាំងផ្លូវកាយ ផ្លូវចិត្ត និងស្មារតី)? ហេតុអ្វីបានជាខ្មែរក្រហម ឃុំឃាំងមនុស្ស?

៥) តើនាពេលបច្ចុប្បន្ននេះ ប្រជាជននៅតែរក្សាការចងចាំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

៦) នៅពេលយើងលាក់ទុកអ្វីមួយនៅក្នុងចិត្ត តើមានអ្វីកើតឡើងខ្លះ?

៧) តើអ្នកគិតថា ពូថៅតំណាង ឬបង្ហាញអំពីអ្វី? (សេចក្ដីប្រាថ្នាក្នុងការរត់គេចចេញ ឬអសមត្ថភាពក្នុងការស្វែងរកសេរីភាព ។ល ។)

*ការបង្រៀន (១៥-៤៥នាទី)*

គ្រូឲ្យសិស្សធ្វើការជាដៃគូ (គិត-ប្រៀបធៀប-ចែករំលែក) (សូមមើលផ្នែកទី៤ ៖ ប្រភពធនធាន និងឯកសារយោង) ។ សិស្សម្នាក់ៗត្រូវបង្កើតតារាង បញ្ជីអំពីមូលហេតុនៃសារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកសិស្សចែករំលែកមូលហេតុទាំងឡាយជាមួយដៃគូរបស់ខ្លួន ។

*សំយោគ (១៥-២៥)*

នៅចុងបញ្ចប់នៃសកម្មភាពធ្វើការជាដៃគូ សិស្សចែករំលែកការយល់ដឹងរបស់ខ្លួនជាមួយសិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។ នៅក្នុងដំណាក់កាលនេះ គ្រូវាយតម្លៃការយល់ដឹង និងកម្រិតនៃការចាប់អារម្មណ៍របស់សិស្សអំពីប្រធានបទនេះ ។



ច្រវ៉ាក់ ពូថៅ និងមេសោផលិតនៅចិន រកឃើញនៅគុកភ្នំក្រោល ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ឆ្នាំ១៩៧៩ ។ ប្រភព ៖ ទីភ្នាក់ងារសារព័ត៌មានវៀតណាម និង មជ្ឈមណ្ឌលឯកសារកម្ពុជា

# ជំពូក១ ៖ សេចក្តីសង្ខេប



កម្មាភិបាលខ្មែរក្រហម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## មេរៀនទី១ ៖ អំណានជំពូក១

### វត្ថុបំណង

១) សិស្សកំណត់ព្រឹត្តិការណ៍សំខាន់ៗ នៅពេលខ្មែរក្រហមឡើងកាន់អំណាច ។

២) សិស្សពន្យល់អំពីមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សពណ៌នាពីការមើលឃើញបទពិសោធន៍ផ្សេងៗគ្នាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៤) សិស្សកំណត់និយមន័យនៃពាក្យ និងឈ្មោះសំខាន់ៗ ។

**សម្ភារទេបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ តារាង K-W-L ក្នុងមេរៀនទី២ និងសៀវភៅលំហាត់ ។

**ពន្យល់ពាក្យ និង ឈ្មោះសំខាន់ៗ** ៖

| | | |
|---|---|---|
| កម្ពុជាប្រជាធិបតេយ្យ | អង្គការបដិវត្តន៍ | ហេង សំរិន |
| ការជម្លៀស | ខ្មែរក្រហម | សឺន សាន |
| លទ្ធិម៉ៅនិយម | ម៉ាក្សនិយម | លទ្ធិលេនីននិយម |
| ការកេងប្រវ័ញ្ច | កម្លាំងចម្រុះ | សមមិត្ត |
| បដិវត្តន៍ | លន់ នល់ | ធម្មានុរូប |
| អង្គការសហប្រជាជាតិ | មហាសន្និបាតអង្គការសហប្រជាជាតិ | ការប៉ះពាល់ផ្លូវចិត្ត |

| | | |
|---|---|---|
| សម្ដេចព្រះ នរោត្ដម សីហនុ | សាធារណរដ្ឋខ្មែរ | រដ្ឋាភិបាលចម្រុះត្រីភាគី |
| បក្សកុម្មុយនីស្ដកម្ពុជា | សាធារណរដ្ឋប្រជាមានិតកម្ពុជា | |

## លំនាំបង្រៀន

### ការផ្ដើមបង្រៀន (៥-១០នាទី)

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងស្វែងយល់នូវអ្វីដែលសិស្សបានដឹងរួចហើយអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងខ្មែរក្រហម ។ គ្រូបិទតារាង K-W-L មុនការបង្រៀនមេរៀនទី២ នៅលើក្ដារខៀន និងពិនិត្យមើលឡើងវិញនូវអ្វីដែលសិស្សបានដឹងរួចហើយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងខ្មែរក្រហម ។ បន្ទាប់មកគ្រូពិនិត្យមើលពាក្យ និងឈ្មោះសំខាន់ៗ នៅក្នុងជំពូក "សេចក្ដីផ្ដើម" ។

### ការបង្រៀន (១៥-៤៥នាទី)

សិស្សអានដោយយកចិត្តទុកដាក់ និងកត់ត្រានូវការពិតសំខាន់ៗនៅក្នុងជំពូក "សេចក្ដីផ្ដើម" ។ បន្ទាប់មកសិស្សអានអត្ថបទខាងក្រោមឲ្យឮៗ ឬដោយស្ងាត់ស្ងៀម ។ សិស្សគួរឆ្លុះបញ្ចាំងទស្សនៈរបស់អ្នកផ្ដល់បទសម្ភាសន៍អំពីថា ៖ តើបទពិសោធន៍ ឬការចងចាំផ្សេងៗគ្នាមានអ្វីខ្លះ? ហេតុអ្វីបានជាបទពិសោធន៍ និងការចងចាំទាំងនេះខុសគ្នា? តើអ្វីដែលអាចពន្យល់ពីបទពិសោធន៍ផ្សេងៗគ្នាទាំងនេះបាន? សិស្សអានប្រវត្តិសង្ខេបរបស់ អៀង ធីរិទ្ធ នៅក្នុងសៀវភៅលំហាត់ ៖



ចុងចោទ អៀង ធីរិទ្ធ នៅក្នុងសវនាការសុំនៅក្រៅឃុំបណ្ដោះអាសន្ននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃ៣០ ខែមិថុនា ឆ្នាំ២០០៨ ។ រូបថត ៖ ហេង ស៊ីនិត ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

អៀង ធីរិទ្ធ ជាប្រពន្ធរបស់ អៀង សារី និងជាប្អូនស្រីរបស់ ខៀវ ប៉ុណ្ណារី ដែលជាប្រពន្ធរបស់ ប៉ុល ពត ។ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ អៀង ធីរិទ្ធ គឺជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ហើយជាប្រធានកាកបាទក្រហមកម្ពុជាប្រជាធិបតេយ្យ ។

អៀង ធីរិទ្ធ ត្រូវបានចាប់ខ្លួន ជាមួយប្ដីរបស់គាត់ អៀង សារី ក្រោមបទចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ គាត់ត្រូវបានចោទថា បានរៀបចំផែនការដឹកនាំសម្របសម្រួល និងបញ្ជាឲ្យធ្វើបន្សុទ្ធកម្មដ៏ធំធេង ក៏ដូចជាការសម្លាប់ក្រៅប្រព័ន្ធច្បាប់ និងការសម្លាប់សមាជិកបម្រើការនៅក្នុងក្រសួងសង្គមកិច្ច ។

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អៀង ធីរិទ្ធ ត្រូវបានសម្រេចថា មានបញ្ហាផ្លូវចិត្តដែលមិនអាចកាត់ក្ដីបាន ។ បន្ទាប់ពីរយៈពេលប្រហែលមួយឆ្នាំនៃការសម្រេចរបស់ចៅក្រមលើរឿងនេះ អៀង ធីរិទ្ធ ត្រូវបានបង្គាប់ឲ្យនៅក្រៅឃុំ ។ អៀង ធីរិទ្ធ ស្លាប់នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ។

### សក្ខីកម្មរបស់អ្នកនាំសំបុត្រម្នាក់របស់ អៀង ធីរិទ្ធ ៖

ស្ត្រីក្មេងម្នាក់មកពីខេត្តតាកែវ បានក្លាយទៅជាអ្នកនាំសំបុត្ររបស់ អៀង ធីរិទ្ធ នៅក្នុងឆ្នាំ១៩៧៦ ។ ទោះបីជាមានទំនាក់ទំនងការងារជិតស្និទ្ធយ៉ាងណាក៏ដោយ ក៏គាត់មិនដែលហ៊ានសម្ដែងអាកប្បកិរិយាធម្មតាជាមួយ អៀង ធីរិទ្ធ ដែរ ហើយមិនដែលសួរនាំអំពីរឿងរ៉ាវផ្ទាល់ខ្លួនឡើយ ។ ទោះជាយ៉ាងនេះក្ដី គាត់នៅតែចាត់ទុក អៀង ធីរិទ្ធ ជាមនុស្សល្អ គឺមិនមែន

ជាមនុស្សម្នាក់ដែលចិត្តអាក្រក់ ឬសាហាវនោះទេ តែជាមនុស្សម្នាក់ ដែលមិនដែលដំឡើងសំឡេង តែងតែនិយាយដោយសម្តីផ្អែមល្ហែម និងអផ្អែលក្បាល និងជាមនុស្សចិត្តទូលាយ ។ គាត់មិនជឿថា អៀង ធីរិទ្ធ ធ្លាប់សម្លាប់អ្នកណាម្នាក់ទេ ។ គាត់ក៏មិនជឿថា ប៉ុល ពត, នួន ជា, អៀង សារី ឬ ខៀវ សំផន ធ្លាប់សម្លាប់អ្នកណាម្នាក់ដោយ ផ្ទាល់ដៃនោះដែរ ។ គាត់ជឿថា ការសម្លាប់កើតមានឡើងតែនៅជនបទប៉ុណ្ណោះ គឺមិនមែននៅក្នុងទីក្រុងទេ ។ អៀង ធីរិទ្ធ មិនដែលនិយាយជាមួយគាត់ អំពីការគំរាមកំហែងរបស់ខ្មាំងនោះទេ ។ ចំណីអាហារមានគ្រប់គ្រាន់ ហើយរៀងរាល់ដប់ថ្ងៃម្តង មានបង្អែម ដូចជា នំសាំងវិច ឬអ្វីដែលផ្អែម ហើយមានកុនមើលទៀតផង ។ ជីវិតរស់នៅពោរពេញដោយភាពរីករាយ ។

*សក្ខីកម្មរបស់ស្ត្រីម្នាក់មកពីខេត្តតាកែវ :*

ស្ត្រីម្នាក់មកពីខេត្តតាកែវ ដែលបម្រើការជាពេទ្យទាហាននៅក្នុងមន្ទីរពេទ្យ៦មករា ក្នុងទីក្រុងភ្នំពេញពីឆ្នាំ១៩៧៧-១៩៧៨ មិនមានការចងចាំអ្វីទាំងអស់ពី អៀង ធីរិទ្ធ ប៉ុន្តែគាត់នៅចាំថា មិត្តរួមការងារដែលជាពេទ្យទាហានរបស់គាត់ត្រូវបាននាំយកទៅសម្លាប់ ហើយការបាត់ខ្លួនច្រើនជាងគេបង្អស់បានកើតឡើងនៅចុងឆ្នាំ១៩៧៧ និងក្នុងឆ្នាំ១៩៧៨ ។ គាត់បានអះអាងថា ជនរងគ្រោះភាគច្រើនមកពីខេត្តតាកែវ ហើយត្រូវបានចោទប្រកាន់ថា ជាជនក្បត់ ព្រោះមានទំនាក់ទំនងជិតស្និទ្ធជាមួយ«យួន» ប៉ុន្តែតាមការពិតត្រូវបាននាំយកទៅបាត់ ដោយសារតែលួចអង្ករ ត្អូញត្អែរពីរបបអាហារមិនគ្រប់គ្រាន់ ឬលួចស្រឡាញ់គ្នាជាដើម ។ ការប្រព្រឹត្តបែបនេះហាក់ដូចជាធ្វើឡើងដើម្បីបំបាត់ចោលនូវជាតិខ្មែរតែម្តង ។ គាត់និយាយថា ជនរងគ្រោះត្រូវបាននាំយកទៅមន្ទីរស-២១ ។

*សេចក្តីដកស្រង់ចេញពីអត្ថបទរបស់ ឆាំង យុ «គម្រោងសំខាន់ៗពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា» ទស្សនាវដ្តីស្វែងរកការពិត ទំព័រ២-៥ (ឆមាសទី១ ឆ្នាំ២០០៤)*

ក្នុងរយៈពេលជិតបួនឆ្នាំ របបនេះទទួលខុសត្រូវចំពោះការស្លាប់ជីវិតមនុស្សប្រមាណពីរលាននាក់ ឬជាងមួយភាគបួននៃប្រជាជនកម្ពុជាទាំងមូល ។ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្ញុំប្រមូលឯកសារពីឧក្រិដ្ឋកម្មទាំងនោះគឺច្រើនជាងចំនួនជនរងគ្រោះទាំងនេះ ដែលមានតួលេខមិនច្បាស់លាស់ទៅទៀត ។ សេចក្តីវន្ទត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ជារឿងរ៉ាវផ្ទាល់ខ្លួនមួយដែរ ។ ខ្ញុំគឺជាក្មេងម្នាក់នៅក្នុងរយៈកាលនោះ ហើយទទួលរងគ្រោះដូចប្រជាជនដទៃទៀតដែរ ។ នៅពេលខ្ញុំបេះត្រកួនឲ្យបងស្រីរបស់ខ្ញុំដែលមានផ្ទៃពោះ និងអត់ឃ្លាន ខ្ញុំត្រូវបានចោទប្រកាន់ថា ជាឧក្រិដ្ឋជន ។ ខ្ញុំត្រូវបានវាយនឹងពូថៅ រុញដួលទៅលើដី និងចាប់ចង ។ ឈ្លបភូមិដាក់ខ្ញុំនៅក្នុងគុកអស់រយៈពេលជាច្រើនសប្តាហ៍ ។ ម្តាយរបស់ខ្ញុំមិនហ៊ានយំទេ នៅពេលគាត់ដឹងថា កម្មាភិបាលកំពុងតែវាយដំខ្ញុំ ព្រោះខ្មែរក្រហមបានចាត់ទុកថា ការសម្តែងសេចក្តីសោកសៅក៏ជាអំពើឧក្រិដ្ឋកម្មមួយដែរ ។ បងស្រីរបស់ខ្ញុំម្នាក់ទៀត ស្លាប់ដោយសារគាត់មិនមានអាហារហូបគ្រប់គ្រាន់ នៅពេលខ្មែរក្រហមចោទប្រកាន់គាត់ពីបទលួចម្ហូបបន្តិចបន្តួច គាត់បានបដិសេធការចោទប្រកាន់នេះ ។ ខ្មែរក្រហមបានសម្លាប់គាត់ ដោយសារតែកម្មាភិបាលទាំងនោះមិនជឿគាត់ ។ ខ្ញុំមានសំណាងល្អ ។ ខ្ញុំបានរួចរស់ជីវិតពីរយៈកាលដ៏ឃោរឃៅនោះ ។

*សេចក្តីដកស្រង់ចេញពីអត្ថបទរបស់ សោម ប៊ុនថន «កម្មាភិបាលខ្មែរក្រហមគឺជាមនុស្សអាក្រក់ឬ?» ទស្សនាវដ្តីស្វែងរកការពិត ទំព័រ៥-៧ (ឆមាសទី៣ ឆ្នាំ២០០៨)*

នៅឆ្នាំ១៩៦៥ ប៉ូច បានបួសជាព្រះសង្ឃនៅវត្តតាំងខ្មៅដើម្បីសិក្សាអំពីពុទ្ធសាសនា ។ ពីរឆ្នាំក្រោយមក ប៉ូច ក៏បានលាចាកសិក្ខាបទ ។ នៅឆ្នាំ១៩៧១ បន្ទាប់ពីបានឮសេចក្តីអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ ឲ្យចូលព្រៃម៉ាគី និង

ចូលរួមការតស៊ូដើម្បីរំដោះប្រទេសពីរបប លន់ នល់ ប៉ូច បានស្ម័គ្រចិត្តចូលបម្រើកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ។ ប៉ូច ទទួលខុសត្រូវអប់រំអ្នកដែលមកពីទីក្រុង អំពីនយោបាយបដិវត្តន៍ និងទទួលខុសត្រូវទៅលើការផលិតអាហារសម្រាប់ប្រជាជន ។ ប៉ូច បានរំឭកថា នៅថ្ងៃមួយនៅពេលដែលកងកម្លាំងខ្មែរក្រហម និងទាហាន លន់ នល់ កំពុងច្បាំងគ្នា ក្មេងស្រីតូចម្នាក់ និងស្ត្រីម្នាក់ឈ្មោះ មុំ ដែលកំពុងតែស្វែងរកបងប្អូនត្រូវកងទ័ពខ្មែរក្រហមចាប់ខ្លួនបាន ។ ដោយសារតែគាត់ធ្លាប់រស់នៅក្នុងតំបន់ខ្មាំង (លន់ នល់) គាត់ត្រូវបានចោទប្រកាន់ថា ជាជនបង្កប់ក្នុងតំបន់រំដោះ ។ ដោយសារ ប៉ូច ធ្លាប់ស្គាល់អ្នកទាំងពីរ និងដឹងថា គាត់នឹងត្រូវទទួលទារុណកម្មឃោរឃៅ ដោយហេតុនេះ គាត់បានទៅធានាអ្នកទាំងពីរ ។

បន្ទាប់ពីជ័យជម្នះនៅឆ្នាំ១៩៧៥ អង្គការបានតែងតាំង ប៉ូច ជាគណៈស្រុករងនៃស្រុកស្អាង ទទួលមើលការខុសត្រូវលើកសិករ ។ ប្រាំពីរខែក្រោយមក អង្គការបានបញ្ជូន ប៉ូច ទៅស្រុកតាំងគោក តំបន់៤២នៃភូមិភាគកណ្ដាល ។ ទោះបីជាអង្គការបានឲ្យ ប៉ូច កត់ឈ្មោះអ្នក១៧មេសា ដែលលួចដំឡូង និងអង្ករ ឬអ្នកដែលមកធ្វើការមិនទៀងទាត់ក៏ដោយ ក៏ ប៉ូច មិនដែលរាយការណ៍ឈ្មោះអ្នកទាំងនោះទៅកម្មាភិបាលថ្នាក់តំបន់ ឬកម្មាភិបាលថ្នាក់មជ្ឈិមដែរ ។ ដោយសារប្រជាជនត្រូវបានជម្លៀសមកពីកន្លែងផ្សេងៗគ្នា គាត់មិនអាចបែងចែកសាវតារប្រជាជនទាំងនោះច្បាស់លាស់ទេ ហើយមានការភ័យខ្លាចចំពោះការចោទប្រកាន់មនុស្សគ្មានទោសពៃរ៍ ។ ជាលទ្ធផល តួនាទីរបស់ ប៉ូច ត្រូវបានទម្លាក់មកជាអនុប្រធានវិញ ។

នៅឆ្នាំ១៩៧៨ ពេលដែល ប៉ូច កំពុងតែច្បាំងនៅលើសមរភូមិ ប៉ូច បានជាន់មីនផ្ទុះដាច់ជើងម្ខាង ។ បន្ទាប់ពីជាពីរបួសវិញ គាត់ត្រូវបានចាត់តាំងឲ្យទៅគ្រប់គ្រងគ្រួសារកងទ័ពខ្មែរក្រហមចំនួន១៧គ្រួសារ ។ នៅចុងបញ្ចប់ មេបញ្ជាការរបស់គាត់ត្រូវកងកម្លាំងរដ្ឋាភិបាលចាប់ខ្លួនបានដូច្នេះ ប៉ូច បានរត់គេចចេញទៅរស់នៅជាមួយអ្នកភូមិ ។ ដោយសារ ប៉ូច បានធ្វើអំពើល្អប្រជាជនមួយចំនួនបានឲ្យអង្ករ ត្រីងៀត ហើយបានជួយលាក់ប្រវត្តិរូបជាអតីតកម្មាភិបាលខ្មែរក្រហមឲ្យគាត់ទៀត ។



ឆាំង យុ (ស្តាំ) និង យាយ ស៊ុម (ឆ្វេង) ប្រជាជននៅភូមិខ្មែរលើ ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ឆ្នាំ១៩៩៥ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

រហូតមកដល់ពេលបច្ចុប្បន្ន អ្នកភូមិនៅស្រុកបារាយណ៍ និងស្រុកតាំងគោកនៅតែមកលេងគាត់ម្តងម្កាលដែរ ។

**កំណត់ចំណាំសម្រាប់គ្រូ :** គោលបំណងនៃសកម្មភាពនេះមានពីរគឺ :

ទីមួយ គ្រូលើកទឹកចិត្តឲ្យដឹកនាំសិស្សក្នុងការពិនិត្យមើលថា ប្រវត្តិសាស្ត្រកើតឡើងតាមរយៈសាច់រឿង បទពិសោធន៍ និងការបកស្រាយផ្សេងៗគ្នាជាច្រើន ។ គ្រូអាចឲ្យសិស្សប្រៀបធៀបសាច់រឿង ១) អ្នករត់សំបុត្ររបស់ អៀង ធីរិទ្ធ ២) ស្ត្រីមកពីខេត្តតាកែវ ៣) អត្ថបទរបស់ លោក ឆាំង យុ និង ៤) រឿងរ៉ាវរបស់ ប៉ូច ។ តើរឿងរ៉ាវផ្សេងគ្នាទាំងនេះ បង្ហាញអ្វីខ្លះពីការសិក្សាប្រវត្តិសាស្ត្រ ។ គ្រូអាចលើកជាសំណួរនេះឡើង និងដឹកនាំសិស្សឲ្យមើលឃើញចំណុចរួមដែលថា មិនមានប្រវត្តិសាស្ត្រដាច់ខាតតែមួយនោះទេ ។ ផ្ទុយទៅវិញ សិស្សត្រូវរៀនប្រវត្តិសាស្ត្រតាមលក្ខណៈនៃការប្រមូលផ្តុំ ពិសោធន៍ និងទស្សនៈផ្សេងៗគ្នា ។ ជួនកាលអាចមានទស្សនៈផ្សេងគ្នាទៅលើអ្វីដែលបានកើតឡើង និងមូលហេតុនៃការកើតឡើង ។

ទីពីរ គ្រូត្រូវបានលើកទឹកចិត្តឲ្យណែនាំសិស្សពិនិត្យមើលថា តើបទពិសោធន៍ទាំងនេះខុសគ្នារបៀបណា និងថាតើបទពិសោធន៍ទាំងនេះ ជួយដល់សិស្សដូចម្តេចខ្លះ ក្នុងការស្វែងយល់ពីនិយមន័យនៃ«ជនរងគ្រោះ»និង«ជនដៃដល់» ។ ឧទាហរណ៍ តើអ្នករត់សំបុត្ររបស់ អៀង ធីរិទ្ធ គឺជា«ជនដៃដល់ដែរឬទេ?» តើអ្វីទៅជានិយមន័យនៃ«ជនដៃដល់» ។ ដើម្បីកំណត់មនុស្សម្នាក់ថាជា«ជនដៃដល់» តើមនុស្សម្នាក់នោះត្រូវតែធ្វើទុក្ខទោសទៅលើអ្នកដទៃផ្សេងទៀតដោយផ្ទាល់ឬយ៉ាងណា?

សំយោគ (១៥-២៥ នាទី)

គ្រូពិនិត្យមើលការគិតរបស់សិស្ស និងសួរសំណួរណែនាំខាងក្រោមទៅសិស្សទាំងអស់នៅក្នុងថ្នាក់ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

**សំណួរណែនាំ និងចម្លើយ**

១) តើខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជានៅពេលណា? ***ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។***

២) ហេតុអ្វីបានជាអ្នកគិតថា ខ្មែរក្រហមបង្ខំប្រជាជនប្រមាណពីរលាននាក់ឲ្យចាកចេញពីទីក្រុងភ្នំពេញ? ***គ្រូមិនគួរផ្តល់ចម្លើយឲ្យសិស្សទេ ។ ផ្ទុយទៅវិញ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីមូលហេតុដែលខ្មែរក្រហមធ្វើបែបនេះ ។***

៣) តើជីវិតមនុស្សដែលស្លាប់នៅក្រោមរបបខ្មែរក្រហមប្រហែលប៉ុន្មាននាក់? ***ចន្លោះពីមួយលានប្រាំពីរសែនទៅពីរលាននាក់ ។***

៤) តើហេតុអ្វីបានជាអ្នកគិតថា ខ្មែរក្រហមចង់ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាសង្គមជនបទ និងគ្មានវណ្ណៈ? ***គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីមូលហេតុដែលខ្មែរក្រហមធ្វើបែបនេះ ។***

៥) ប្រសិនបើរូបិយប័ណ្ណ និងផ្សារសេរីត្រូវបានលុបបំបាត់ តើអ្នកគិតថា ជីវិតនាពេលបច្ចុប្បន្ននឹងទៅជាយ៉ាងណា? ***គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីផលប៉ះពាល់នៃអំពើបែបនេះ មកលើជីវិតរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្ន ។ ចម្លើយរបស់សិស្សអាចខុសៗគ្នា ។***

៦) ប្រសិនបើសាលារៀនត្រូវបានលុបបំបាត់ តើអ្នកគិតថា ជីវិតនឹងទៅជាយ៉ាងណា? ***គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីផលប៉ះពាល់នៃអំពើបែបនេះមកលើជីវិតរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្ន ។ ចម្លើយរបស់សិស្សអាចខុសៗគ្នា ។***

៧) *ប្រសិនបើទ្រព្យសម្បត្តិឯកជនត្រូវបានលុបបំបាត់ តើអ្នកគិតថាជីវិតនឹងទៅជាយ៉ាងដូចម្តេច?* **គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីផលប៉ះពាល់នៃអំពើបែបនេះមកលើជីវិតរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្ន ។ ចម្លើយរបស់សិស្សអាចខុសៗគ្នា ។**

៨) *ប្រសិនបើសម្លៀកបំពាក់ស៊ីវិល័យតាមបែបបរទេសត្រូវបានលុបបំបាត់ តើអ្នកគិតថា ជីវិតនឹងទៅជាយ៉ាងដូចម្តេច?* **គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីផលប៉ះពាល់នៃអំពើបែបនេះមកលើជីវិតរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្ន ។ ចម្លើយរបស់សិស្សអាចខុសៗគ្នា ។**

៩) *ប្រសិនបើការគោរពជំនឿសាសនា និងវប្បធម៌ប្រពៃណីខ្មែរត្រូវបានលុបបំបាត់ តើអ្នកគិតថា ជីវិតនឹងទៅជាយ៉ាងដូចម្តេច?* **គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីផលប៉ះពាល់នៃអំពើបែបនេះមកលើជីវិតរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្ន ។ ចម្លើយរបស់សិស្សអាចខុសៗគ្នា ។**

១០) *តើអ្នកគិតថា ហេតុដូចម្តេចបានជារបបនេះហាមប្រាមមិនឲ្យមានការប្រមូលផ្តុំគ្នា ឬការពិភាក្សាជាសាធារណៈ?* **គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីផលប៉ះពាល់នៃអំពើបែបនេះ មកលើជីវិតរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្ន ។ ចម្លើយរបស់សិស្សអាចខុសៗគ្នា ។**

១១) *ពណ៌នាអំពីទំនាក់ទំនងរវាងកម្ពុជា និងវៀតណាម នៅចុងឆ្នាំ១៩៧៧ ។* **ទំនាក់ទំនងរវាងប្រទេសទាំងពីរក្លាយទៅជាសត្រូវនឹងគ្នា ។**

១២) *តើរបបនេះផ្តល់ផលប៉ះពាល់មកលើសង្គមកម្ពុជានាពេលបច្ចុប្បន្នអ្វីខ្លះ?* **គ្រូមិនត្រូវផ្តល់ចម្លើយឲ្យសិស្សនៅពេលនេះទេ ។ គ្រូគួរលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីផលប៉ះពាល់នៃអំពើបែបនេះ មកលើជីវិតរស់នៅរបស់ខ្លួននាពេលបច្ចុប្បន្ន ។ ចម្លើយរបស់សិស្សអាចខុសៗគ្នា ។**

១៣) *មើលរូបភាពនៅក្នុងទំព័រទី១នៃជំពូក១នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា "ក្រុមយុវជន និងយុវនារីនៅក្នុងសន្និសីទមួយក្នុង ខេត្តសៀមរាបនាថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៣" ។ ដោយសម្លឹងមើលទៅលើរូបភាព និងមិនបញ្ចេញយោបល់អ្វីទាំងអស់ តើអ្នកសង្កេតឃើញនៅក្នុងរូបភាពមានអ្វីខ្លះ? តើរូបភាពនេះបង្រៀនអ្នកអំពីមនោគមន៍វិជ្ជារបស់ខ្មែរក្រហមអ្វីខ្លះ? តើអ្នកគិតថា យុវជនក្មេងៗទាំងនេះកំពុងធ្វើអ្វីនៅក្នុងសន្និសីទនោះ?* **មិនមាន ចម្លើយត្រូវ ឬខុសទេសម្រាប់សំណួរនេះ ។ ចម្លើយដែលអាចទទួលយកបានគឺ :**

- **មនុស្សជាច្រើនស្លៀកសម្លៀក បំពាក់ពណ៌ខ្មៅ ។**
- **នារីភាគច្រើនកាត់សក់ខ្លី ។**

១៤) *សូមមើលរូបភាពនៅលើទំព័រទី១នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើអ្នកនៅក្នុងហ្វូងមនុស្សទាំងនោះ តើអ្នកមានអារម្មណ៍ដូចម្តេច?* **មិនមានចម្លើយត្រូវ ឬខុសទេសម្រាប់សំណួរនេះ ។ សិស្សអាចឆ្លើយថា អ្នកទាំងនោះគួរមានអារម្មណ៍ថា ត្រូវតែទះដៃ ឬស្រែកអបអរ ។ អ្នកទាំងនោះអាចមានអារម្មណ៍ទុកព្រួយ ភ័យខ្លាច ឬបំភិតបំភ័យ ។ អ្នកទាំងនោះអាចមានអារម្មណ៍សប្បាយរីករាយ ឬរំភើប ។ គោលបំណងនៃសំណួរនេះគឺដើម្បីណែនាំសិស្សឲ្យចេះឆ្លុះបញ្ចាំងពីមូលហេតុដែលខ្លួនគួរមានអារម្មណ៍ និងអ្វីដែលខ្លួនគួរគិតពិចារណាពីអ្វីដែលខ្លួនមើលឃើញក្នុងពេលនេះ ។**

# ជំពូក២ ៖ តើខ្មែរក្រហមជាអ្នកណា?
# តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?



យោធាខ្មែរក្រហមនៅពហុកីឡាដ្ឋានជាតិអូឡាំពិក ក្នុងអំឡុងពេលពិធីរំឭកខួបកងទ័ពបដិវត្តន៍ ភ្នំពេញ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## មេរៀនទី១ ៖ អំណានជំពូក២ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

***វត្ថុបំណង*** ៖

១) សិស្សទទួលបានចំណេះដឹងអំពីប្រវត្តិរបស់ខ្មែរក្រហម ។

២) សិស្សពណ៌នាអំពីអ្នកដែលដើរតួនាទីសំខាន់របស់ខ្មែរក្រហមក្នុងការដណ្តើមកាន់កាប់ប្រទេសកម្ពុជា នៅឆ្នាំ ១៩៧៥ ។

៣) សិស្សកំណត់និយមន័យនៃពាក្យ និងឈ្មោះសំខាន់ៗ ។

៤) សិស្សសង្ខេបការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

***សម្ភារឧបទេស*** ៖ សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

### ពន្យល់ពាក្យ និង ឈ្មោះសំខាន់ៗ ៖

| | | |
|---|---|---|
| អាណានិគមបារាំង | ឥណ្ឌូចិន | លេខាធិការ |
| រណសិរ្សឯកភាពឥស្សរៈ (ខ្មែរឥស្សរៈ) | សឺង ង៉ុកមិញ | ហូ ជីមិញ |
| ចាន់ សម័យ | និរទេស | រត់ចោលជួរ |
| អ្នកជាតិនិយម | បញ្ញវន្ត | សកម្មជន |
| សាឡុត ស (ប៉ុល ពត) | សុន សេន | ជននៅក្នុងការខុបត្ថម្ភ |
| ខៀវ សំផន | អៀង សារី | កែវ មាស |
| កសិករ | សោ ភឹម | អ្នកមូលធននិយម |
| នួន ជា | ស៊ីវ ហេង | កិច្ចព្រមព្រៀងក្រុងហ្សឺណែវ |
| គណៈកម្មាធិការមជ្ឈិម | វៀតមិញ | រដ្ឋសភា |
| កម្មាភិបាល | ទូ សាមុត | បក្សកុម្មុយនីស្តឥណ្ឌូចិន |
| បក្សប្រជាជនបដិវត្តន៍ខ្មែរ | បក្សប្រជាជនបដិវត្តន៍ខ្មែរ (សង្គមរាស្ត្រនិយម) | បក្សកុម្មុយនីស្តកម្ពុជា |

### លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូឲ្យសិស្សពិភាក្សាពីអ្វីដែលសិស្សបានដឹងអំពីរបបខ្មែរក្រហម និងពិភាក្សាពាក្យ និងឈ្មោះនៅក្នុងជំពូក២ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអានមេរៀនដោយយកចិត្តទុកដាក់ និងកត់ត្រានូវការពិតសំខាន់ៗនៅក្នុងជំពូក២ ។ សិស្សសរសេរនៅក្នុងសៀវភៅលំហាត់ដើម្បីបង្ហាញពីការសិក្សារបស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំជាមួយសិស្សនៅក្នុងថ្នាក់ទាំងអស់ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) ហេតុអ្វីបានជាចលនាកុម្មុយនីស្តនៅកម្ពុជាសហការជាមួយវៀតណាម? **ដើម្បីតស៊ូប្រឆាំង និងបណ្ដេញបារាំងឲ្យចេញផុតពីឥណ្ឌូចិន ។**

២) នៅខែមេសា ឆ្នាំ១៩៥០ គណៈប្រតិភូចលនាកុម្មុយនីស្តចំនួន២០០នាក់នៅកម្ពុជា បានមកជួបជុំគ្នានៅខេត្តកំពត និងបង្កើតជាក្រុមមួយ ។ តើក្រុមនោះមានឈ្មោះអ្វី? **រណសិរ្សឯកភាពឥស្សរៈ ឬខ្មែរឥស្សរៈ ។**

៣) តើមេដឹកនាំនៃក្រុមនេះជាអ្នកណា? **សឺង ង៉ុកមិញ ហៅ អាចារ្យមៀន ។**

៤) តើមនោគមន៍វិជ្ជារបស់ក្រុមនេះគឺជាអ្វី? **ម៉ាក្ស-លេនីន ។**

៥) តើសមាជិកសម្ងាត់នៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរមានអ្នកណាខ្លះ? (ឲ្យឈ្មោះចំនួន៤) **សឺង ង៉ុកមិញ, ស៊ីវ ហេង, ទូ សាមុត (ហៅអាចារ្យសុខ), ចាន់ សម័យ ។**

៦) *នៅឆ្នាំ១៩៥៥ តើគណបក្សណាឈ្នះបានកៅអីទាំងអស់នៅក្នុងរដ្ឋសភា?* ***គណបក្សសង្គមរាស្ត្រនិយម ។***

៧) *នៅចន្លោះឆ្នាំ១៩៥០ និងឆ្នាំ១៩៥៩ តើក្នុងបក្សប្រជាជនបដិវត្តន៍ខ្មែរមានអ្វីកើតឡើងខ្លះ?* ***យោងតាមសម្ដីរបស់ ប៉ុល ពត ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៩ សមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរប្រហែល៩០ ភាគរយត្រូវបានចាប់ខ្លួន និងសម្លាប់ ។ រហូតមកដល់ដើមឆ្នាំ១៩៦០ មានតែកម្មាភិបាលបក្សប្រហែល ៨០០នាក់ និងសាខាបក្សពីរនៅជនបទតែប៉ុណ្ណោះ ដែលនៅមានសកម្មភាព និងដំណើរការពេញលេញ ។ បញ្ហានេះកើតឡើងមួយផ្នែក ដោយសារតែ ស៊ីវ ហេង បានចុះចូលជាមួយរាជរដ្ឋាភិបាលរបស់សម្ដេចព្រះនរោត្តមសីហនុ នៅក្នុងឆ្នាំ១៩៥៩ ។***

៨) *តើសាខាបក្សនៅជនបទចំនួនពីរដែលនៅមានដំណើរការពេញលេញនៅឡើយនៅឆ្នាំ១៩៦០ មានអ្វីខ្លះ?* ***ភូមិភាគបូព៌ា ដែលមានមូលដ្ឋាននៅខេត្តកំពង់ចាម (ដឹកនាំដោយ សោ ភឹម) និងភូមិភាគនិរតីដែលមានមូលដ្ឋាននៅក្នុងខេត្តតាកែវ (ដឹកនាំដោយ ឈិត ជឿន ហៅ តាម៉ុក) ។***

៩) *នៅឯកិច្ចប្រជុំមហាសន្និបាតសម្ងាត់របស់បក្សប្រជាជនបដិវត្តន៍ខ្មែរពីថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ១៩៦០ តើមានអ្វីកើតឡើងខ្លះ?* ***មានសមាជិកចំនួន៧នាក់ពីសាខាបក្សនៅទីក្រុង និង១៤នាក់ពីសាខាបក្សនៅជនបទបានមកជួបជុំគ្នានៅក្នុងស្ថានីយរថភ្លើងក្នុងទីក្រុងភ្នំពេញ ។ មហាសន្និបាតបានរៀបចំបក្សសាជាថ្មី បង្កើតមាគ៌ានយោបាយថ្មី និងប្ដូរឈ្មោះបក្សទៅជាបក្សពលករកម្ពុជា ។ ទូ សាមុត ក្លាយជាលេខាបក្ស ហើយ នួន ជា ក្លាយជាអនុលេខាបក្ស ។ ប៉ុល ពត គឺជាអនុលេខាបក្សទី២ ក្នុងឆ្នាំ១៩៦១ ។***

១០) *បន្ទាប់ពី ប៉ុល ពត ត្រូវបានតែងតាំងជាលេខាបក្ស តើប្រទេសចំនួន២ដែលគាត់បានធ្វើដំណើរទៅទស្សនកិច្ចដើម្បីពិភាក្សាការងារមានប្រទេសណាខ្លះ?* ***ប្រទេសចិន និងប្រទេសវៀតណាម ។***

១១) *ហេតុអ្វីបានជា ប៉ុល ពត ផ្លាស់ប្ដូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៦៦?* ***គាត់ចង់បន្ថយឥទ្ធិពលរបស់វៀតណាម និងរឹតចំណងមិត្តភាពជាមួយចិន ។ គាត់ធ្វើការផ្លាស់ប្ដូរបែបនេះ ដើម្បីដាក់បក្សកម្ពុជាឲ្យនៅលើបក្សវៀតណាម ។***

១២) *នៅខែមីនា ឆ្នាំ១៩៧០ តើអ្នកណាដែលធ្វើរដ្ឋប្រហារបានសម្រេចក្នុងការទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែងប្រមុខរដ្ឋ?* ***សេនាប្រមុខ លន់ នល់ និងសហការីរបស់គាត់ដែលនិយមសហរដ្ឋអាមេរិក ។***

១៣) *តើឈ្មោះដើមរបស់ ប៉ុល ពត គឺអ្វី?* ***សាឡុត ស ។***

១៤) *តើ ប៉ុល ពត ក្លាយជាសមាជិកបក្សកុម្មុយនីស្តនៅឯណា?* ***ទីក្រុងប៉ារីស ប្រទេសបារាំង ។***

១៥) *តើ ប៉ុល ពត ក្លាយជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនៅពេលណា?* ***ឆ្នាំ១៩៧៦ ។***

១៦) *តើ ប៉ុល ពត លាលែងចេញពីតំណែងនៅពេលណា?* ***ឆ្នាំ១៩៧៩ ។***

១៧) *តើ ប៉ុល ពត ស្លាប់នៅថ្ងៃណា?* ***ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ។***

១៨) *ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ តើតួនាទីរបស់ នួន ជា ដូចដែលបានបង្ហាញនៅក្នុងអត្ថបទមានអ្វីខ្លះ?* ***ប្រធានសភាតំណាងប្រជាជនកម្ពុជា អនុលេខានៃគណៈកម្មាធិការមជ្ឈិម និងគណៈអចិន្ត្រៃយ៍បក្ស ។ គាត់ក៏ដើរតួនាទីសំខាន់នៅក្នុងបញ្ហាសន្តិសុខជាតិ និងជាសមាជិកខ្ពស់ជាងគេថ្នាក់ទី២នៅក្នុងជួរបក្ស ។***

១៩) តើ នួន ជា ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅពេលណា? **ឆ្នាំ១៩៩៨ ។**

២០) តើរដ្ឋាភិបាលនិរទេសដែលសម្តេចព្រះ នរោត្តម សីហនុ បង្កើតឡើងបន្ទាប់ពីព្រះអង្គត្រូវបានទម្លាក់ចេញពីតំណែងមានឈ្មោះថាអ្វី? **រាជរដ្ឋាភិបាលកម្ពុជារួបរួមជាតិកម្ពុជា ។**

២១) តើប្រទេសណាខ្លះគាំទ្រខ្មែរក្រហម នៅក្នុងការតស៊ូដើម្បីដណ្តើមកាន់កាប់អំណាច? **ប្រទេសចិន និងវៀតណាម ។**

២២) តើកងកម្លាំងយោធាបរទេសណាខ្លះ ដែលបានចូលមកក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧០? **កងកម្លាំងកុម្មុយនីស្តវៀតណាម និងកងកម្លាំងសហរដ្ឋអាមេរិក (ចូលក្នុងរយៈពេលខ្លី) ។**

២៣) ពីខែមករា ដល់ខែសីហា ឆ្នាំ១៩៧៣ តើរបបសាធារណរដ្ឋខ្មែរត្រូវបានជួយទ្រទ្រង់ដោយប្រទេសណា? **សហរដ្ឋអាមេរិក ។ ជំនួយសហរដ្ឋអាមេរិកបានបន្តរហូតដល់ថ្ងៃចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ ។**

២៤) សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកប្រមាណកន្លះលានតោនមកលើកម្ពុជា ។ តើការទម្លាក់គ្រាប់បែកនោះមានផលប៉ះពាល់ទៅលើក្រុមខ្មែរក្រហមដូចម្តេចខ្លះ? **ការទម្លាក់គ្រាប់បែកនេះបានពន្យារជោគជ័យរបស់ខ្មែរក្រហមបានរយៈពេលពីរឆ្នាំ ។**

២៥) តើការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក មានផលប៉ះពាល់មកលើប្រជាជនកម្ពុជាដូចម្តេចខ្លះ? **ការទម្លាក់គ្រាប់បែកនេះ បានសម្លាប់ប្រជាជនកម្ពុជាប្រមាណបីសែននាក់ ។ មនុស្សជាច្រើនត្រូវបាត់បង់សមាជិកគ្រួសាររបស់ខ្លួន ហើយភាគច្រើនបានចូលរួមជាមួយខ្មែរក្រហម ដែលជាវិធីមួយក្នុងការជំទាស់នឹងរដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។**

២៦) តើមានអ្វីកើតឡើងចំពោះទីប្រឹក្សាវៀតណាមភាគច្រើន ដែលបន្តស្ថិតនៅកម្ពុជាដើម្បីជួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា? **ទីប្រឹក្សាភាគច្រើនត្រូវបានធ្វើឃាតចាប់ពីឆ្នាំ១៩៧៣ ។**

## មេរៀនទី២ : តើ ប៉ុល ពត ជាអ្នកណា?

### វត្ថុបំណង

១) សិស្សរំឭកឡើងវិញនូវចំណេះដឹងពីមុនអំពី ប៉ុល ពត ។

២) សិស្សកំណត់ទិដ្ឋភាពសំខាន់ៗនៃប្រវត្តិខ្មែរក្រហម ។

៣) សិស្សវិភាគពីមនោគមន៍វិជ្ជារបស់ ប៉ុល ពត ។

៤) សិស្សពន្យល់ការគិតរបស់ខ្លួនអំពីមនោគមន៍វិជ្ជារបស់ ប៉ុល ពត ។

**សម្ភារឧបទេស** : ប្រវត្តិរូបសង្ខេបរបស់ ប៉ុល ពត និងមនោគមន៍វិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យ នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

(សូមអានសៀវភៅប្រវត្តិសាស្ត្រ ជំពូក២ សម្រាប់ប្រវត្តិរូបរបស់ ប៉ុល ពត)

(សូមអានជំពូក៧ ចំណុចទី១ សម្រាប់ព័ត៌មានអំពីការបង្កើតសហករណ៍)

(សូមអានជំពូក៧ ចំណុចទី២ វណ្ណៈសង្គមថ្មី២)

តារាង K-W-L នៅក្នុងសៀវភៅលំហាត់របស់សិស្ស

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូណែនាំសិស្សអំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូគូសតារាង K-W-L នៅលើក្ដារខៀន (អ្វីដែលយើងដឹង អ្វីដែលយើងចង់ដឹង និងអ្វីដែលយើងបានរៀន) ដោយសរសេរព័ត៌មានអំពីចំណេះដឹងរបស់សិស្ស ។ គ្រូពិនិត្យមើលព័ត៌មានទាក់ទងនឹងអ្វីដែលសិស្សបានដឹងរួចហើយ និងអ្វីដែលសិស្សចង់ដឹងអំពី ប៉ុល ពត ។ គ្រូឲ្យសិស្សពិភាក្សាថា តើសិស្សសិក្សាអំពីព័ត៌មានទាំងនេះនៅកន្លែងណា? តើសិស្សបានរៀនអ្វីខ្លះពីឪពុកម្ដាយ សមាជិកគ្រួសារ និងមិត្តភក្ដិ? តើសិស្សបានរៀនដោយខ្លួនឯងអ្វីខ្លះ? បន្ទាប់មក គ្រូឲ្យសិស្សបំពេញផ្នែក«អ្វីដែលសិស្សចង់ដឹង»អំពី ប៉ុល ពត ដាក់ក្នុងតារាង ។

គ្រូប្រាប់សិស្សឲ្យបំពេញតារាង «អ្វីដែលយើងបានរៀន» នៅចុងបញ្ចប់នៃវគ្គសិក្សា ។

*ការបង្រៀន (១៥-៤៥នាទី)*

គ្រូពន្យល់សិស្សអំពីពាក្យមនោគមន៍វិជ្ជា និងឲ្យសិស្សធ្វើការជាដៃគូ ។ បន្ទាប់ពីសកម្មភាពនេះ សិស្សម្នាក់ៗត្រូវសរសេរអំពីមនោគមន៍វិជ្ជារបស់ ប៉ុល ពត នៅក្នុងសៀវភៅលំហាត់រៀងៗខ្លួន ហើយចែករំលែកការយល់ដឹងរបស់ខ្លួនជាមួយនឹងដៃគូ ។ សិស្សអាចទៅមើលមនោគមន៍វិជ្ជានៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

*សំយោគ (១៥-២៥នាទី)*

នៅចុងបញ្ចប់នៃការងារជាដៃគូ សិស្សពិភាក្សាពីមនោគមន៍វិជ្ជាទាំងនេះនៅក្នុងថ្នាក់ ។ នៅក្នុងដំណាក់កាលនេះ គ្រូវាយតម្លៃចំណេះដឹង និងការយល់ដឹងរបស់សិស្ស ដោយឲ្យសិស្សបំពេញនៅក្នុងតារាង K-W-L ត្រង់ផ្នែក «អ្វីដែលយើងបានរៀន» នៅលើក្ដារខៀន ។



ប៉ុល ពត ក្នុងអង្គប្រជុំជាមួយកម្មាភិបាលចិន ក្នុងឆ្នាំ ១៩៧៨ ។ ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

# ជំពូក៣ ៖ ការជម្លៀសដោយបង្ខំ



*អៀង សារី កំពុងត្រួតពិនិត្យមើលផ្លូវរថភ្លើងក្នុងអំឡុងពេលការជម្លៀសប្រជាជនលើកទីពីរនាចុងឆ្នាំ១៩៧៥ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។*

## មេរៀនទី១ ៖ អំណានជំពូក៣

### វត្ថុបំណង

១) សិស្សពន្យល់ពីពេលវេលា និង វិសាលភាពនៃការជម្លៀសដោយបង្ខំ ។

២) សិស្សស្វែងយល់អំពីមូលហេតុដែលប្រជាជនត្រូវបានជម្លៀសដោយបង្ខំពីទីក្រុង និងទីប្រជុំជន នៅក្រោមរបបខ្មែរក្រហម ។

៣) សិស្សស្វែងយល់អំពីហេតុផលនៃការជម្លៀសដោយបង្ខំ គឺជាសកម្មភាពខុសច្បាប់ ។

៤) សិស្សធ្វើសេចក្តីសង្ខេបពីការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

**សម្ភារឧបទេស** ៖ អត្ថបទអំពីការជម្លៀសដោយបង្ខំ

**ពន្យល់ពាក្យសំខាន់ៗ**

| | | |
|---|---|---|
| ការជម្លៀសដោយបង្ខំ | ទីតាំងពិសោធន៍ | សហករណ៍ |
| ប្រជាជនចាស់ | ប្រជាជនថ្មី | |

## លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូណែនាំពីវត្ថុបំណងនៃមេរៀននៅក្នុងថ្ងៃនេះ និងពិភាក្សាអំពីអ្វីដែលសិស្សបានដឹងរួចហើយអំពីការជម្លៀសដោយបង្ខំ ។ បន្ទាប់មកគ្រូពិនិត្យមើលពាក្យសំខាន់ៗនៅក្នុងជំពូក៣នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ គ្រូសួរសំណួរដល់សិស្សដូចតទៅ តើការជម្លៀសដោយបង្ខំកើតឡើងនៅពេលណា? តើវិសាលភាពនៃការជម្លៀសដោយបង្ខំគឺជាអ្វី? ហេតុអ្វីបានជារបប ខ្មែរក្រហមបង្ខំប្រជាជនឲ្យផ្លាស់ទីកន្លែងពីទីក្រុង និងទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត? ហេតុអ្វីបានជាការជម្លៀសដោយបង្ខំទាំងនោះ គឺជាសកម្មភាពខុសច្បាប់?

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអានដោយយកចិត្តទុកដាក់ និងកត់ត្រានូវការពិតសំខាន់ៗពីជំពូក៣ និងពិភាក្សានៅក្នុងក្រុមតូចអំពីមូលហេតុដែលប្រជាជនត្រូវបានបង្ខំឲ្យផ្លាស់ទីកន្លែងពីទីក្រុង និងទីប្រជុំជនទៅកាន់ទីជនបទ ។

*សំយោគ (១០-១៥នាទី)*

គ្រូពិនិត្យមើលសំណួរណែនាំជាមួយសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

## ការជម្លៀសដោយបង្ខំ

គោលបំណងរួមរបស់បក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីអនុវត្តរបបបដិវត្តន៍សង្គមនិយមភ្លាមៗមួយនៅក្នុងប្រទេសកម្ពុជាតាមទ្រឹស្តី «មហាលោតផ្លោះ មហាអស្ចារ្យ» និងដើម្បីការពារបក្សពី«សត្រូវខាងក្នុង និងសត្រូវខាងក្រៅ» ។ វិធីចម្បងមួយនៅក្នុងការសម្រេចឲ្យបាននូវគោលដៅនេះ គឺការជម្លៀសប្រជាជនជាញឹកញាប់ពីទីក្រុង និងទីប្រជុំជននានាទៅកាន់ទីជនបទ ក៏ដូចជាពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត ។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនយ៉ាងច្រើនត្រូវបានជម្លៀសដោយបង្ខំពីផ្ទះរបស់ខ្លួនជាញឹកញយទៅកាន់ទីកន្លែងឆ្ងាយៗនៅទីជនបទ ។ ជួនកាល ខ្មែរក្រហមបានហៅទីតាំងទាំងនេះថា ជា«ទីតាំងពិសោធន៍សម្រាប់ប្រជាជនថ្មី» ។

គោលនយោបាយនៃការផ្លាស់ប្តូរប្រជាជនដោយបង្ខំពីទីតាំងមួយទៅកាន់ទីតាំងមួយទៀត (ឧទាហរណ៍ ការជម្លៀសដោយបង្ខំ) ដោយមិនបានផ្តល់ដំណឹងឲ្យដឹងជាមុន ផ្តល់ជាសំណង ឬផ្តល់មធ្យោបាយផ្លូវច្បាប់ណាមួយ និងបើកឲ្យមានការតវ៉ា បានបង្កឲ្យមានការឈឺចាប់ និងសម្ពាធយ៉ាងធ្ងន់ធ្ងរទៅលើប្រជាជន និងសហគមន៍ ។

នៅក្នុងរយៈពេល៤៥ខែ របបខ្មែរក្រហមបានដាក់ចេញនូវផែនការជម្លៀសប្រជាជនដោយបង្ខំពីតំបន់មួយ ទៅតំបន់មួយទៀត ។ ក្រុមគ្រួសារត្រូវបានបំបែក ប្តីត្រូវបានបំបែកចេញពីប្រពន្ធ កូនចេញពីឪពុកម្តាយ ហើយក្រុមគ្រួសារជាទីស្រឡាញ់ត្រូវបានបាត់ខ្លួនដោយមិនដឹងមូលហេតុ និងដោយគ្មានដាន ។ សមាជិកជាច្រើនរបស់របប លន់ នល់ និងប្រជាជនជាច្រើនដែលត្រូវបានសង្ស័យថា មានសមានចិត្ត ឬជាប់ពាក់ព័ន្ធនឹង«ខ្មាំង» ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។

គោលនយោបាយនៃការជម្លៀសដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា បានព្យាយាមបំបែកទំនាក់ទំនងរបស់មនុស្ស និងស្ថាប័នដែលធ្លាប់បានគ្រប់គ្រងការរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើននៅមុនបដិវត្តន៍ឲ្យដាច់ដោយឡែកពីគ្នា ។ ក្រៅពីរដ្ឋាភិបាលរបស់ លន់ នល់ គោលនយោបាយនេះ ត្រូវបានអនុវត្តទាំងទំនៀមទម្លាប់របស់គ្រួសារ សាសនា អង្គភាព



រូបគំនូរបង្ហាញពីការធ្វើការដោយកម្លាំងនៅតាមដងផ្លូវរថភ្លើងមួយក្នុងរបបខ្មែរក្រហម ។ ការធ្វើការដោយកម្លាំង គឺជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចបាននូវផលិតផលកសិកម្មក្នុងកម្រិតទ្រង់ទ្រាយធំ ។ រូបគំនូរនេះគូរដោយ តាំង ហ៍រអ៊ុ ។

សហគមន៍ជនជាតិភាគតិច និងខ្សែបណ្ដាញបញ្ញវន្ត ព្រមទាំងអ្នកជំនួញផង ។ ប្រសិនបើគ្មានទំនាក់ទំនង និងស្ថាប័នទាំងនេះទេ ក្រុមប្រឆាំងនឹងមានការលំបាកក្នុងការរៀបចំការតស៊ូណាមួយ ។ ប្រសិនបើការជម្លៀសដោយបង្ខំបានទប់ស្កាត់អ្នកទាំងនោះពីភាពស្មោះត្រង់ចំពោះឪពុកម្ដាយ ញាតិសន្ដាន សាសនា និងមេដឹកនាំសហគមន៍ទំនៀមទម្លាប់ដទៃទៀត វាជាការងាយស្រួលក្នុងការបញ្ចុះបញ្ចូលប្រជាជនកម្ពុជា ជាពិសេស ក្មេងៗឲ្យមានការជឿជាក់យ៉ាងស្មោះស្ម័គ្រលើ«អង្គការ» ។

ជារួម របបនេះបានបង្កើតឲ្យមានការជម្លៀសប្រជាជនចំនួនបីដំណាក់កាល ៖

១) ការជម្លៀសប្រជាជនចេញពីទីក្រុង ដូចជាភ្នំពេញ បាត់ដំបង សៀមរាប និងទីប្រជុំជនមួយចំនួនផ្សេងទៀត ដែលបានចាប់ផ្ដើមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ដោយរួមបញ្ចូលទាំងការជម្លៀសប្រជាជនតាមរថភ្លើងចេញនៅក្នុងអំឡុងពេល៦ខែបន្ទាប់មកទៀតដែរ) ។

២) ការជម្លៀសប្រជាជននៅទីជនបទ នៅក្នុងភូមិភាគកណ្ដាល និរតី បស្ចិម និងបូព៌ា ចាប់ពីចុងឆ្នាំ១៩៧៥ ទៅកាន់ផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា ។

៣) ការជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ានៅក្នុងឆ្នាំ១៩៧៧ ។

ប្រជាជនទទួលបានដំណឹង ឬការពន្យល់តិចតួចណាស់ សម្រាប់តម្រូវការនៃការចាកចេញពីផ្ទះរបស់ខ្លួន ។ នៅក្នុងរយៈពេលប៉ុន្មានថ្ងៃដំបូងបន្ទាប់ពីការដួលរលំនៃទីក្រុងភ្នំពេញ ប្រជាជនដែលរស់នៅក្នុងទីក្រុងត្រូវបង្ខំដោយចុងកាំភ្លើងឲ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួនជាបន្ទាន់ ។ ប្រជាជនមួយចំនួនមានបំណងចាកចេញពីទីក្រុងដោយរថយន្ត ប៉ុន្តែមានសាំងតិចតួចណាស់ ។ មិនយូរប៉ុន្មាន មធ្យោបាយធ្វើដំណើរទាំងនោះត្រូវបានបោះបង់ចោលនៅក្នុងចរាចរណ៍ដែលណែនណាន់តាន់តាប់ ឬត្រូវបានកងទ័ពខ្មែរក្រហមរឹបអូសយក ។

នៅក្នុង«ការជម្លៀស» ដោយបង្ខំចេញពីទីក្រុងភ្នំពេញ មន្ទីរពេទ្យ វត្តអារាម សាលារៀន ត្រូវបានបោសសម្អាត ហើយអ្នកជំងឺត្រូវបានបង្ខំឲ្យចាកចេញ ខណៈដែលអ្នកជំងឺនៅលើគ្រែរុញត្រូវបានអូស ឬរុញតាមរទេះ ។ ចាស់ជរា អ្នកជំងឺ កូនក្មេង និងស្ត្រីមានផ្ទៃពោះ ត្រូវបានបង្ខំឲ្យដើរទោះជាស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ ។ មនុស្សគ្រប់រូបត្រូវតែចាកចេញដោយមិនមានការលើកលែង ។

ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនាខែមេសា ឆ្នាំ១៩៧៥ ស្ថិតនៅក្នុងសភាពចលាចល ភ័យខ្លាច និងដោយបង្ខំ ។ ប្រជាជនត្រូវបានប្រាប់ឲ្យដឹងថា ខ្លួនត្រូវតែចាកចេញពីផ្ទះដោយគ្មានលក្ខខណ្ឌ ។ ការប្រយុទ្ធគ្នាបន្តិចបន្តួច

រវាងទាហាន លន់ នល់ និងកងកម្លាំងរបស់ខ្មែរក្រហមបានបន្តក្នុងអំឡុងពេលនៃការចាកចេញទាំងហ្វូងៗ ដោយបានកាត់ផ្តាច់ផ្នែកទាំងមូលនៃទីក្រុង និងបានទប់ស្កាត់សមាជិកគ្រួសារមិនឲ្យចាកចេញពីទីក្រុងជាមួយគ្នា ។ នៅគ្រប់ទីកន្លែងទាំងអស់ ដែលមានមនុស្សដើរ មនុស្សម្នាតែងតែមើលឃើញសាកសព និងទ្រព្យសម្បត្តិដែលត្រូវបានបោះបង់ចោល ។ ប៉ុស្តិ៍ត្រួតពិនិត្យត្រូវបានដាក់នៅតាមច្រកចេញ ដើម្បីកំណត់អត្តសញ្ញាណអតីតទាហាន និងមន្ត្រីរដ្ឋការរបស់របប លន់ នល់ ។ ប្រជាជនជាច្រើនបានលាក់អត្តសញ្ញាណរបស់ខ្លួន ដោយភ័យខ្លាចចំពោះការចាប់ខ្លួន ។

ទាហាន លន់ នល់ ត្រូវបានដឹងឮថា បានសម្លាប់អ្នកទោសជាច្រើន ។ ខ្មែរក្រហមបានឆ្លើយតបទៅវិញជាមួយនឹងការកាប់សម្លាប់ដូចគ្នា ។ មនុស្សគ្រប់រូបដែលត្រូវបានរកឃើញថា មានជាប់ពាក់ព័ន្ធជាមួយនឹងអតីតរបបចាស់ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលភ្លាមៗ ។ បញ្ញវន្ត អ្នកមានទ្រព្យសម្បត្តិ និងមនុស្សជាច្រើនដែលទទួលការសង្ស័យ ក៏ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលដែរ ។

ដូចការរំពឹងទុក ប្រជាជនបានសួរសំណួរថា « តើយើងត្រូវទៅទីណា? តើយើងត្រូវយកអ្វីទៅខ្លះ? ហើយតើពេលណាយើងនឹងត្រឡប់មកវិញ?

នៅពេលដែលខ្មែរក្រហមផ្តល់ចម្លើយផ្សេងៗគ្នា ហេតុផលចម្បងដែលកងទ័ពខ្មែរក្រហមជាច្រើននាក់បានលើកឡើងគឺថាសហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ ដូច្នេះប្រជាជនក្នុងទីក្រុងត្រូវតែចាកចេញ ។ មូលហេតុដែលត្រូវបានផ្តល់ឲ្យមួយទៀតគឺថា ខ្មែរក្រហមត្រូវសម្អាតទីក្រុងឲ្យអស់កម្លាំងរបស់ខ្មាំង ។ ប្រជាជនភាគច្រើនត្រូវបានប្រាប់ឲ្យយករបស់ស្រាលៗ ពីព្រោះប្រជាជនទាំងនោះនឹងត្រូវត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃ ។ ប្រជាជនជាច្រើនបានជឿពាក្យឃោសនានេះ ហើយបានចាកចេញជាមួយនឹងអាហារ ទឹក និងថ្នាំពេទ្យបន្តិចបន្តួចតែប៉ុណ្ណោះ ។

បន្ទាប់ពី«ការជម្លៀស» ដោយបង្ខំភ្លាម ទីក្រុងភ្នំពេញស្ទើរតែគ្មានមនុស្សរស់នៅ ប្រជាជនភាគច្រើនដែលបានចាកចេញត្រូវបានបញ្ជូនទៅកាន់ភូមិទាំងឡាយដែលនៅជាយក្រុង ជាកន្លែងដែលប្រជាជនទាំងនេះស្នាក់នៅ និងធ្វើការជាច្រើនខែ ។ នៅក្នុងករណីជាច្រើន ប្រជាជនបានធ្វើដំណើរទៅកាន់កន្លែងទាំងឡាយដែលខ្លួនមានសាច់ញាតិ ឬមានទំនាក់ទំនងផ្សេងៗទៀត ។ បន្ទាប់ពីរយៈពេលប៉ុន្មានខែក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត ជាញឹកញាប់ដោយរថយន្ត និងរថភ្លើង ទៅកាន់សហករណ៍ដែលបានបង្កើតឡើងនៅទូទាំងប្រទេស ។

ប្រជាជនជាច្រើនបានបោះបង់ចោលការរស់នៅក្នុងទីក្រុងភ្នំពេញទាំងមូល ដោយប្រហែលជាយកជាប់ខ្លួននូវគ្រឿងអលង្ការ លុយកាក់ ឬរបស់មានតម្លៃផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងករណីដែលខ្លួនត្រូវការផ្គត់ផ្គង់ ។ មិនមានអ្នកណាម្នាក់ដឹងថា តើខ្លួននឹងត្រូវចាកចេញពីផ្ទះរយៈពេលប៉ុន្មាន ហើយអ្នកដែលស្មានថា ខ្លួននឹងចាកចេញតែរយៈពេលបីថ្ងៃ ពិតជាមិនបានដឹងថា វាគឺជាពេលវេលាចុងក្រោយដែលខ្លួននឹងបានឃើញទីក្រុងភ្នំពេញ (ឬទីក្រុង ឬទីប្រជុំជនដែលខ្លួនរស់នៅ) រយៈពេល ជិតបួនឆ្នាំទៀត ។

ការជម្លៀសប្រជាជនជាច្រើនដោយបង្ខំ អាចនិយាយបានថា ជាសោកនាដកម្មមួយសម្រាប់មនុស្សជាច្រើន និងជាការចាប់ផ្តើមនៃយុគសម័យផ្តាច់ការថ្មីមួយសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ។ ដោយមានទំនាក់ទំនងជាមួយអ្នកនៅជនបទប្រជាជនជាច្រើនអាចជ្រកកោនជាមួយសាច់ញាតិឬមិត្តភក្តិ ដែលបានជួយខ្លួនឲ្យជៀសផុតពីទិដ្ឋភាពដ៏អាក្រក់បំផុតនៃការជម្លៀសដោយបង្ខំ ។ សម្រាប់ប្រជាជនកម្ពុជាជាច្រើនផ្សេងទៀត ជាពិសេសអ្នកដែលមានប្រវត្តិជាអ្នកទីក្រុង ឬវណ្ណៈថ្នាក់កណ្តាល ឬថ្នាក់លើ ការជម្លៀសដោយបង្ខំ បានបង្កឲ្យមានការឈឺចាប់យ៉ាងធំធេង និងការស្លាប់រាប់ពាន់នាក់ ។

នៅក្នុងឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់មួយ ដើម្បីបង្កើតតុលាការមួយសម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ តុលាការនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ច្បាប់នេះត្រូវបានកែប្រែនៅឆ្នាំ២០០៤ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការសហការឲ្យដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។



យុទ្ធជនបើកបររថភ្លើង ។ ការជម្លៀសប្រជាជនកម្ពុជាដោយបង្ខំ គឺជានិច្ចកាលស្ថិតនៅក្រោមការត្រួតពិនិត្យពីយុវជន និងក្មេងៗ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

មាត្រា៥ និងមាត្រា៦ នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចែងថា មេដឹកនាំជាន់ខ្ពស់ ឬជនទាំងឡាយណាដែលត្រូវបានចាត់ទុកថា ជាអ្នកដែល «ទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺត្រូវប្រឈមមុខនឹងការកាត់ទោសចំពោះតួនាទីរបស់ខ្លួនក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទឧក្រិដ្ឋដទៃទៀត ។ ការជម្លៀសដោយបង្ខំនូវជនណាម្នាក់ ដែលជនប្រព្រឹត្តបានដឹងថា ជននោះរស់នៅទីកន្លែងនោះដោយស្របច្បាប់ គឺជាទង្វើហាមឃាត់ដែលស្ថិតនៅក្នុងនិយមន័យដ៏ទូលំទូលាយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។

នៅក្នុងប្រវត្តិសាស្ត្រ រដ្ឋាភិបាលដែលរឹតបន្តឹងសិទ្ធិសេរីភាពរបស់ប្រជាជន និងគ្រប់គ្រងដោយប្រើអំណាច បានប្រើប្រាស់សកម្មភាពជម្លៀសដោយបង្ខំចំពោះប្រជាជនដែលលែងត្រូវការ ឬ ធ្វើឲ្យចុះខ្សោយ ដាក់ទណ្ឌកម្ម ឬគ្រប់គ្រងក្រុមខ្លះ ដែលកំពុងរស់នៅក្នុងតំបន់ត្រួតត្រារបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ការជម្លៀសដោយបង្ខំត្រូវបានហាមឃាត់ដោយច្បាប់អន្តរជាតិ ពីព្រោះសកម្មភាពនេះបានរំលោភលើសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ដោយរួមបញ្ចូលទាំងសិទ្ធិរស់នៅក្នុងផ្ទះរបស់នរណាម្នាក់ដោយមានសុវត្ថិភាព និងសេចក្ដីថ្លៃថ្នូរ ។ រដ្ឋាភិបាលអាចជម្លៀសប្រជាជនពីផ្ទះរបស់គេនៅពេលដែលប្រជាជនទាំងនោះយល់ព្រមឲ្យមានការជម្លៀសដោយមិនមានការគាបសង្កត់ហួសហេតុពេក ឬក្នុងករណីខ្លះរដ្ឋាភិបាលផ្ដល់ដល់អ្នកទាំងនោះនូវសំណងផ្នែកហិរញ្ញវត្ថុដែលសមរម្យ និងផ្ដល់ឱកាសឲ្យបញ្ចេញយោបល់តាមផ្លូវច្បាប់ចំពោះការជម្លៀសនេះ ។ គម្រោងការជម្លៀសដោយបង្ខំធំមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនបានផ្ដល់ឲ្យជនរងគ្រោះនូវសំណងសមរម្យ និងឱកាសសម្រាប់យុត្តិធម៌ឡើយ ។ នៅក្នុងចំណោមអ្នកជំនាញច្បាប់ វាច្បាស់ណាស់ថា ការជម្លៀសដោយបង្ខំ គឺជាអំពើខុសច្បាប់ ។

### សំណួរណែនាំ និងចម្លើយ

១) តើអ្នកកំណត់និយមន័យនៃការ «ជម្លៀសដោយបង្ខំ» យ៉ាងដូចម្ដេច? **ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះ ទីប្រជុំជន និងទីក្រុង ដើម្បីទៅរស់នៅទីជនបទថ្មីមួយ ។**

២) *តើដំណាក់កាលចម្បងៗបីនៃការជម្លៀសដោយបង្ខំ នៅក្រោមរបបខ្មែរក្រហមមានអ្វីខ្លះ?* ***ដំណាក់កាលទាំងបីរួមមាន ៖ ក) ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ខ) ការជម្លៀសប្រជាជន ចេញពីភូមិភាគកណ្តាល និរតី បស្ចិម និង បូព៌ា ចុងឆ្នាំ១៩៧៥ ។ គ) ការជម្លៀសប្រជាជននៅក្នុងភូមិភាគបូព៌ា ឆ្នាំ១៩៧៧ ។***

៣) *តើជាទូទៅប្រជាជនត្រូវបានជម្លៀសដោយបង្ខំទៅកាន់ទីកន្លែងណា?* ***ជាញឹកញយប្រជាជនជាច្រើនត្រូវបានជម្លៀសដោយបង្ខំពីផ្ទះរបស់ខ្លួន ទៅកាន់តំបន់ឆ្ងាយៗនៅទីជនបទ ពីទីក្រុង និងទីប្រជុំជនទៅកាន់តំបន់ជនបទ ក៏ដូចជាពីតំបន់ជនបទមួយទៅកាន់តំបន់ជនបទមួយទៀត ។***

៤) *តើប្រជាជនត្រូវបានប្រព្រឹត្តមកលើដូចម្តេចខ្លះ នៅពេលដែលខ្លួនត្រូវបានជម្លៀសដោយបង្ខំ?* ***ក្រុមគ្រួសារត្រូវបានបំបែក ។ ប្តីត្រូវបានបំបែកចេញពីប្រពន្ធ ហើយសមាជិកគ្រួសារជាទីស្រលាញ់រាប់មិនអស់បានបាត់ខ្លួនដោយគ្មានដាន ។ សមាជិកនៃរបប លន់ នល់ និងអ្នកទាំងឡាយណាដែលត្រូវបានសង្ស័យថាមានសមានចិត្ត ឬមានទំនាក់ទំនងជាមួយ“ខ្មាំង” ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។***

៥) *តើខ្មែរក្រហមបានពន្យល់អំពី“ការជម្លៀស” ឬ “ការជម្លៀសដោយបង្ខំ”នូវប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ (និង៦ខែក្រោយមកទៀតដោយរថភ្លើងទៅកាន់ខេត្តផ្សេងៗ) ដោយរបៀបណា?* ***ខ្មែរក្រហមបានផ្តល់ចម្លើយផ្សេងៗគ្នា ។ មូលហេតុចម្បងដែលកងទ័ពខ្មែរក្រហមភាគច្រើនប្រាប់ប្រជាជនគឺថាសហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ ដូច្នេះប្រជាជនត្រូវតែចាកចេញ ។ មូលហេតុមួយទៀតគឺថា ខ្មែរក្រហមត្រូវបោសសម្អាតកម្លាំងរបស់ខ្មាំងឲ្យអស់ពីទីក្រុង ។ ប្រជាជនជម្លៀសភាគច្រើនត្រូវបានប្រាប់ឲ្យវេចខ្ចប់របស់បន្តិចបន្តួច ពីព្រោះប្រជាជនទាំងនេះនឹងត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃ ។***

៦) *ហេតុអ្វីបានជាការជម្លៀសដោយបង្ខំ រំលោភច្បាប់អន្តរជាតិ?* ***ការជម្លៀសដោយបង្ខំ បានរំលោភសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះដែលរស់នៅក្នុងផ្ទះរបស់ខ្លួនយ៉ាងមានសុវត្ថិភាព និងប្រកបដោយសេចក្តីថ្លៃថ្នូរ ។ ជនរងគ្រោះមិនបានយល់ព្រមឡើយ ហើយរបបកម្ពុជាប្រជាធិបតេយ្យមិនបានផ្តល់ឲ្យជនរងគ្រោះនូវសំណងសមរម្យ ឬឱកាសសម្រាប់យុត្តិធម៌ឡើយ ។***

## មេរៀនទី២ ៖ សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### វត្ថុបំណង

១) សិស្សរៀបរាប់អំពីបទពិសោធន៍នៃការជម្លៀសដោយបង្ខំ ។

២) សិស្សប្រៀបធៀបសក្ខីកម្ម ដែលផ្តល់ឲ្យដោយដើមបណ្តឹងរដ្ឋប្បវេណីប្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

៣) សិស្សសរសេរព័ត៌មានអំពីរឿងរ៉ាវស្តីពីការជម្លៀសដោយបង្ខំ ចំនួនមួយទំព័រ ។

៤) សិស្សសម្តែងចិត្តអាណិតអាសូរដល់ប្រជាជន ដែលត្រូវរបបខ្មែរក្រហមបង្ខំឲ្យចាកចេញពីផ្ទះរបស់ខ្លួន ។

**សម្ភារឧបទេស ៖** រូបភាពថ្ងៃដួលរលំទីក្រុងភ្នំពេញ និងអត្ថបទ«សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។



ស្ត្រី និងកុមារីម្នាក់កំពុងសម្លឹងមើលកម្មាភិបាលខ្មែរក្រហមកាប់សម្បកដូង ដើម្បីហូបទឹកក្នុងអំឡុងកិច្ចប្រជុំនៅភូមិជនបទមួយក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ។ ទឹកដូងត្រូវបានចាត់ទុកជាឱសថសម្រាប់ព្យាបាលជំងឺជាច្រើនមុខ ហើយប្រជាជនកម្ពុជាធម្មតាកម្របានហូបទឹកដូងណាស់ក្នុងរបបខ្មែរក្រហម ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញ និងយុវជនក្មេងៗជិះលើរថក្រោះអបអរសាទរថ្ងៃចូលឆ្នាំខ្មែរ និងការមកដល់នៃយោធាខ្មែរក្រហម ។
រូបថត ៖ រ៉ូឡង់ ណឺវឺ ។ ប្រភព ៖ ការដួលរលំទីក្រុងភ្នំពេញ ថ្ងៃ១៧ មេសា ១៩៧៥ ។





## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូណែនាំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងប្រាប់សិស្សឲ្យអានអត្ថបទ«សំឡេងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។

*ការបង្រៀន (១៥ - ៤៥ នាទី)*

សិស្សដើរតួជាអ្នកកាសែត ដែលអមដំណើរលោក រ៉ូឡង់ ណឺវី ខណៈពេលដែលលោកបានថតរូបថ្ងៃដួលរលំទីក្រុងភ្នំពេញ ។ សិស្សម្នាក់ៗសរសេរព័ត៌មានចំនួនមួយទំព័រ អំពីទិដ្ឋភាពនៃការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ដោយប្រើប្រាស់សំណួរខាងក្រោម ជាការណែនាំសម្រាប់សរសេររឿងរ៉ាវព័ត៌មានរបស់ខ្លួន ។

១) តើសិស្សបានឃើញអ្វីខ្លះ នៅពេលដែលប្រជាជនកំពុងត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង?

២) តើសិស្សបានឃើញប្រជាជនយកអ្វីខ្លះតាមខ្លួន?

៣) តើប្រជាជនមានអារម្មណ៍ដូចម្ដេច នៅពេលចាកចេញពីផ្ទះ?

៤) តើព័ត៌មានលម្អិតអ្វីខ្លះ ដែលសាធារណជនគួរដឹងអំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ?

*សំយោគ (១០ - ១៥ នាទី)*

សិស្សបង្ហាញរឿងរ៉ាវព័ត៌មានរបស់ខ្លួនទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។ គ្រូប្រើប្រាស់រឿងរ៉ាវព័ត៌មានដើម្បីវាយតម្លៃការសិក្សារបស់សិស្ស ។ គ្រូអាចមើលទៅលើសេចក្ដីសង្ខេបនៃផ្ទៃរឿងសំខាន់ៗ នៅចុងបញ្ចប់នៃមេរៀននេះ សម្រាប់គម្រោងក្នុងការពិភាក្សា ។

## សំឡេងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អ្នកស្រី យឹម សុវណ្ណ ដែលជាដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប នៅចំពោះមុខដំណើរការកាត់សេចក្ដីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងសំណុំរឿង០០២ រៀបរាប់អំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ៖

> ពេលនោះម៉ោងប្រហែលជា៣រសៀល មុនដំបូងឪពុករបស់គាត់បដិសេធមិនព្រមចាកចេញ ។ «ពួកគេបានមកដល់ដោយមានកាំភ្លើង និងអង្ករខ្លះ ហើយពួកគេប្រាប់ពុកខ្ញុំថា «មិត្តត្រូវតែចាកចេញ បើមិនដូច្នោះទេ អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ» ។ ពុករបស់ខ្ញុំប្រញាប់ប្រញាល់ទៅរៀបចំវ៉ាលិស និងយកអង្ករខ្លះមុនពេលចាកចេញពីកន្លែងរបស់យើង ។ វាពិតជាលំបាកខ្លាំងណាស់ក្នុងការចាកចេញ ។» អ្នកស្រី សុវណ្ណ បានរំឭកទៀតថា «ពួកគេមានសុទ្ធតែអាវុធទាំងប្រុស ទាំងស្រី ។ ពួកគេស្លៀកឯកសណ្ឋានពណ៌ខ្មៅ និងក្រមាពណ៌ក្រហម ។ ពួកគេបានប្រាប់គ្រួសារយើងថា «អង្គការលើ» បានប្រាប់យើងឲ្យចាកចេញ ហើយយើងត្រូវទៅភូមិកំណើតរបស់យើងចំនួនបីថ្ងៃ បើមិនដូច្នេះទេ អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក និងសម្លាប់ពួកយើង ។ ពួកកងទ័ពឲ្យពេលយើងតែ១៥ នាទី ប៉ុណ្ណោះដើម្បីចាកចេញ ហើយប្រសិនបើយើងប្រកែក ពួកគេនឹងចាត់វិធានការ» ។
>
> អ្នកស្រីរៀបរាប់ថា អ្នកស្រីបានឃើញកងទ័ពបាញ់ផ្ដាច់សោទ្វារផ្ទះមួយនៅម្ដុំផ្សារអូរឫស្សី ហើយបន្ទាប់មកពួកកងទ័ពបានបាញ់ប្រជាជននៅពេលដែលប្រជាជនរត់ចេញពីផ្ទះ ។ អ្នកស្រីក៏បានឃើញទាហាន លន់ នល់ ដែលរង

របួសនៅឯពេទ្យទាហានមួយនៅម្តុំបុរីកីឡា ដែលជាកន្លែងកងយោធារបស់ លន់ នល់ ។ កងទ័ពខ្មែរក្រហមរុញពួកគេទម្លាក់ពីលើគ្រែ ។ អ្នករបួសមួយចំនួនត្រូវបានសាច់ញាតិយកទៅ ប៉ុន្តែអ្នកផ្សេងទៀតត្រូវបានទុកចោលឲ្យស្លាប់ ។

មិនមានអ្នកណាម្នាក់ដែលស្លាប់នៅក្នុងអំឡុងពេលជម្លៀស ទទួលបានការធ្វើបុណ្យសពនោះទេ ។ សាកសពត្រូវបានបោះចោលទៅក្នុងប្រឡាយទឹក ឬទុកចោលនៅតាមដងផ្លូវ ។

លោក ឈុំ សុខា ដែលជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានឡើងផ្តល់សក្ខីកម្មអំពីដំណើរចាកចេញពីទីក្រុងភ្នំពេញរបស់ក្រុមគ្រួសាររបស់គាត់ ៖

លោក សុខា បានរៀបរាប់ថា គាត់បានឃើញសាកសពនៅតាមចិញ្ចើមផ្លូវ ដែលមើលឃើញ ដោយសារភ្លើងឡាន ផ្សេងភ្លើងឆេះផ្ទះ និងសាកសពដែលត្រូវបានដុត នៅម្តុំពោធិ៍ចិនតុង និងនៅខាងមុខនាយកដ្ឋានដឹកជញ្ជូន ។

លោក សុខា បានពន្យល់ថា គាត់ ម្តាយរបស់គាត់ ប្អូនស្រី ពូ និងជីដូនជីតា បានធ្វើដំណើរទៅមុនដោយថ្មើរជើង ហើយឪពុក និងពូរបស់គាត់បានទៅតាមទាន់ពួកគាត់ បន្ទាប់ពីដើរបានពីរគីឡូម៉ែត្រ ។ លោក សុខា បានផ្តល់ សក្ខីកម្មថា ឪពុករបស់គាត់បានប្រាប់ថា គាត់ត្រូវចាប់ខ្លួន ប៉ុន្តែ ដោយគាត់សម្គាល់ឃើញថា មនុស្សមួយក្រុមត្រូវបានចាប់ចងមួយខ្សែ គាត់បានរត់គេច ហើយបានប្រាប់ក្រុមគ្រួសារឲ្យប្រញាប់ប្រញាល់ ។ លោកបានរៀបរាប់ថា ក្រុមគ្រួសាររបស់គាត់បានសម្រាកនៅវត្តអង្គក្រូច អស់រយៈពេលជាច្រើនថ្ងៃ ពីព្រោះប្អូនស្រីរបស់គាត់ហើមជើងមិនអាចដើរបាន ។ ក្រោយមកអង្គការបានប្រាប់ថា ក្រុមគ្រួសាររបស់គាត់ត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់ភូមិកំណើតដែលស្ថិតនៅភូមិត្បូងក្តី ក្នុងខេត្តព្រៃវែង ។

ដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ថា ប្អូនស្រីរបស់គាត់នៅតែមានបញ្ហាជើងនៅឡើយ ដូច្នេះ ម្តាយរបស់គាត់បានដូរគ្រឿងអលង្ការ និងខោអាវល្អៗ ដើម្បីឲ្យប្អូនស្រីគាត់អាចធ្វើដំណើរតាមរទេះបាន ។បន្ទាប់មក ក្រុមគ្រួសារបានមកដល់ភូមិមួយនៅក្បែរបឹងមួយក្នុងស្រុកបាទី ។ ពួកគាត់បានស្នាក់នៅទីនោះមួយយប់ មុនពេលបន្តដំណើរទៅកាន់ភូមិបឹងខ្នាក់ ។

លោក សុខា បានផ្តល់សក្ខីកម្មថា រយៈពេលមួយខែបន្ទាប់ពីចាកចេញពីទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់គាត់បានមកដល់ភូមិត្បូងក្តី ក្នុងខេត្តព្រៃវែង ដែលជាភូមិកំណើតរបស់គ្រួសារ ។

អ្នកស្រី ឡាយ ប៊ុននី ដែលជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានឡើងផ្តល់សក្ខីកម្មអំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ៖

អ្នកស្រី ប៊ុននី បានផ្តល់សក្ខីកម្មថា កងទ័ពខ្មែរក្រហមបានប្រាប់ប្រជាជនឲ្យចាកចេញតាមគ្រប់មធ្យោបាយដែលមាន ។ កងទ័ពទាំងនេះមិនបានប្រាប់ប្រជាជនថា តើរបស់របរជាប់ខ្លួនអ្វីខ្លះដែលត្រូវយកទៅជាមួយនោះទេ ។ គាត់និយាយថា គ្រួសាររបស់គាត់មិនបានយកអង្ករទៅជាមួយទេ ។ ក្រុមគ្រួសារគាត់យកតែលុយ ដែលខ្លួនគិតថាអាចប្រើប្រាស់បាននៅតាមផ្លូវ ។ គាត់បានបន្ថែមថា កងទ័ពខ្មែរក្រហមមិនបានប្រាប់អ្នកស្រីថា លុយមិនមានប្រយោជន៍ទេ ហើយគាត់“មានការអស់សង្ឃឹម” នៅពេលដែលគាត់បានដឹងអំពីរឿងនេះនៅតាមផ្លូវ ។

អ្នកស្រី ប៊ុននី ពន្យល់ថា ប្រជាជនដែលមិនអាចដើរដោយខ្លួនឯងបាន ដូចជាអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ“នឹងត្រូវរុញដោយរទេះពេទ្យ ឬសែងដោយស្នែង ឬអង្រឹង ។ អ្នកខ្លះដែលមានជំងឺធ្ងន់ធ្ងរអាចត្រូវមនុស្សម្នាក់ទៀតអៀវពីក្រោយខ្នង” ។ គាត់បានរំឭកថា មនុស្សមួយចំនួនសម្រាលកូននៅតាមផ្លូវ ហើយអ្នកជម្លៀសអាចឮសំឡេងស្រែកយំ ។ អ្នកស្រីបន្ថែមថា នៅទីបញ្ចប់ អ្នកជម្លៀសមួយចំនួនរកបានពេទ្យឆ្មបដើម្បីជួយខ្លួន ។





ការមើលឃើញមួយភ្លែតពីលើរថភ្លើងក្នុងខេត្តពោធិ៍សាត់ ។ តាមរយៈរូបភាពព្រាលៗពីម៉ាស៊ីនថត អ្នកធ្វើដំណើរដោយថ្មើរជើងមិនស្គាល់ឈ្មោះទាំងនេះ ដែលរែកសំណាបធ្ងន់ៗដូចគោក្របី ជាសញ្ញាបញ្ជាក់ប្រាប់ពីស្ថានភាពរបស់ប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម ។ ក្នុងពេលជាមួយគ្នា ប្រជាជនមួយចំនួនត្រូវបានជម្លៀសដោយបង្ខំឲ្យធ្វើដំណើរទៅកាន់ទីជនបទតាមរថភ្លើង ប្រជាជនដទៃទៀតក៏ត្រូវបានបង្ខំឲ្យធ្វើដំណើរដោយថ្មើរជើង ។ ដោយគ្មានអ្វីសោះ ក្រៅពីរបស់របរប្រើប្រាស់ផ្ទាល់ខ្លួនបន្តិចបន្តួចដែលអាចយកតាមខ្លួនបាន ប្រជាជនកម្ពុជាត្រូវបានបង្ខិតបង្ខំឲ្យផ្លាស់ប្តូរទីលំនៅក្នុងទូទាំងប្រទេស ។ ពេលខ្លះអាចនិយាយបានថាប្រជាជនដែលធ្វើដំណើរតាមរថភ្លើងគឺជាភ័ព្វសំណាងមួយសម្រាប់អ្នកទាំងនោះ ។ ប៉ុន្តែ នេះមិនមែនជាករណីចាំបាច់ទេ ។ អ្នកនៅរស់រានមានជីវិតម្នាក់ ដែលជាប់ទាក់ទងនឹងរឿងរ៉ាវនេះរៀបរាប់ថា "គ្រួសាររបស់ខ្ញុំបានស្ថិតនៅលើរថភ្លើងដែលឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់ ។ យើងត្រូវបំបែកចេញពីគ្នានៅពេលដែលរថភ្លើងបានមកដល់ស្ថានីយរថភ្លើងខេត្ត ។ ពេលនោះ ខ្ញុំស្ថិតនៅជាមួយប្អូនស្រីខ្ញុំនៅឡើយទេ ប៉ុន្តែ មួយរយៈពេលក្រោយមក នាងត្រូវបានសម្លាប់យ៉ាងឃោរឃៅ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា និងមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា

អ្នកស្រី ប៊ុននី ត្រូវបានបណ្តេញដោយបង្ខំជាមួយនឹងកូនស្រីអាយុ៩ឆ្នាំ ។ អ្នកស្រី ប៊ុននី បានរំឭកអំពីរឿងរបស់កូនស្រីអាយុ៩ឆ្នាំថា ៖

> នៅពេលយើងមកដល់ស្រុកខ្សាច់កណ្តាល កូនស្រីរបស់ខ្ញុំបានឈឺអស់ពីរបីថ្ងៃរួចទៅហើយ ។ នាងមានជំងឺរាកធ្ងន់ធ្ងរ ។ ខ្ញុំត្រូវបានប្រាប់ឲ្យបេះស្លឹកឈើខ្លះដើម្បីព្យាបាលជំងឺរបស់នាង ។ គ្រប់ក្រុមគ្រួសារទាំងអស់មានជំងឺគ្រុន ។ នៅពេលដែលមីងរបស់ខ្ញុំឃើញដូចនេះ គាត់ចង់យកកូនស្រីរបស់ខ្ញុំទៅនៅជាមួយគាត់ ដើម្បីឲ្យនាងទទួលបានការព្យាបាល ។ ខ្ញុំបានយល់ព្រមឲ្យនាងទៅ ។ ខ្ញុំជឿជាក់ថា កូនស្រីរបស់ខ្ញុំនឹងទទួលបានការព្យាបាល និងថែរក្សាបានត្រឹមត្រូវ ប៉ុន្តែ ខ្ញុំបែរជាបានទទួលដំណឹងថា នាងបានស្លាប់បាត់ទៅហើយ ។
>
> អ្នកស្រី ប៊ុននី ត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីកន្លែងម្តងទៀត ពីស្រុកខ្សាច់កណ្តាលទៅខេត្តពោធិ៍សាត់ ដែលនៅទីនោះអ្នកស្រីរៀបរាប់ថា «អាហារមានសភាពអាក្រក់ ។ អ្នកជម្លៀសហូបតាមផ្លូវ ហើយអាហារទាំងនោះ មិនល្អសម្រាប់យើងទេ ។ វាប៉ះពាល់ដល់ក្រពះ» ។

### ពិភាក្សាផ្ទៃរឿងសំខាន់ៗ

១) កងទ័ពខ្មែរក្រហមបានប្រើប្រាស់ការបំភិតបំភ័យ និងការគំរាមកំហែងដើម្បីបង្ខំប្រជាជនឲ្យចេញពីផ្ទះសម្បែង ។ ប្រជាជនគ្មានសិទ្ធិក្នុងការតវ៉ាប្រឆាំងនឹងការជម្លៀសនេះបានឡើយ ហើយក៏ពុំមានការអនុវត្តន៍តាមច្បាប់ណាមួយឡើយ ។

២) ប្រជាជនដែលចាកចេញពីផ្ទះសម្បែងរបស់ខ្លួន បានយកទៅជាមួយនូវរបស់របរដែលខ្លួនគិតថាជាតម្រូវការប្រចាំថ្ងៃ ដែលរួមមានម្ហូបអាហារ និងគ្រឿងមានតម្លៃសម្រាប់ដោះដូរ ។

៣) ប្រជាជនដែលចាកចេញពីទីក្រុង មានការភ័យខ្លាច និងមានភាពស្រពិចស្រពិលអំពីអនាគតរបស់ខ្លួន ព្រោះថាគ្មាននរណាម្នាក់បានដឹងឡើយថា តើខ្លួនកំពុងធ្វើដំណើរទៅកាន់ទីណា ឬតើនរណាដែលអាចនៅរស់ឡើយ ។

៤) នៅក្នុងឆ្នាំ១៩៧៥ ទាំងជនជាតិខ្មែរ និងជនបរទេស សុទ្ធតែបានដឹងថា សកម្មភាពរបស់ខ្មែរក្រហម គឺពុំដូចជាអ្នករំដោះប្រជាជនកាលពីចូលកាន់កាប់ទីក្រុងភ្នំពេញបន្ទាប់ពីទទួលបានជ័យជម្នះក្នុងសង្គ្រាមឡើយ ។ ផ្ទុយទៅវិញ កម្មាភិបាលទាំងនោះបានរំលោភសិទ្ធិរបស់ប្រជាជន ។ ខ្មែរក្រហមបានបង្ខំប្រជាជនឲ្យចាកចេញពីផ្ទះសម្បែង បាញ់សម្លាប់ជនស៊ីវិល និងស្លូតត្រង់ ចាប់ផ្តើមសម្លាប់សមាជិករដ្ឋាភិបាល លន់ នល់ ព្រមទាំងបានប្រាប់ដល់អ្នកជម្លៀសទាំងអស់ថា ក្រដាសប្រាក់របស់អ្នកជម្លៀសមិនមានប្រយោជន៍ទៀតទេ ។ ហេតុការណ៍ទាំងអស់នេះបានបង្ហាញឲ្យឃើញថា របបកម្ពុជាប្រជាធិបតេយ្យថ្មី គឺជារបបឃោរឃៅ និងជ្រុលនិយមខាងមនោគមន៍វិជ្ជា ។

## មេរៀនទី៣ ៖ បទពិសោធន៍នៃការជម្លៀសដោយបង្ខំ

### វត្ថុបំណង

១) សិស្សពន្យល់អំពីផលប៉ះពាល់មួយចំនួននៃការជម្លៀសដោយបង្ខំ ។

២) សិស្សរៀបរាប់ពីភាពភ័យខ្លាច ដែលប្រជាជនជួបប្រទះនៅពេលដែលត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះយ៉ាងឆាប់រហ័ស ។

៣) សិស្សយល់អំពីសកម្មភាព និងការសម្រេចចិត្ត ដែលប្រជាជនធ្វើឡើងនៅក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំ ។

៤) សិស្សធ្វើការប្រៀបធៀបពីបទពិសោធន៍របស់ជនរងគ្រោះម្នាក់ៗ ។

**សម្ភារឧបទេស** : អត្ថបទ "សំឡេងពីដើមបណ្តឹងរដ្ឋប្បវេណី ដែលជាវេជ្ជបណ្ឌិត"

## លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូណែនាំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងពិភាក្សា អំពីអ្វីដែលសិស្សបានរៀនអំពីការជម្លៀសដោយបង្ខំ ។

*ការបង្រៀន (១៥-៤៥នាទី)*

គ្រូបែងចែកសិស្សទៅជា៥ក្រុម ។ ក្រុមនីមួយៗអាន"សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាវេជ្ជបណ្ឌិត" ។ បន្ទាប់ពីអានរួច ក្រុមនីមួយៗត្រូវឆ្លើយតបនឹងសំណួរខាងក្រោម ។

ក្រុមទី១ :

១) ហេតុអ្វីបានជាប្រជាជនភាគច្រើនរងរបួសនៅក្នុងពេលមានអំពើហិង្សាកាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៦? **គ្រាប់បែកត្រូវបានទម្លាក់នៅផ្សារឌុយម៉ិច ។**

២) តើប្រជាជនប្រភេទណាដែលទទួលរងរបួស? **ទាហាន និងប្រជាជនស្ទួតត្រង់ជាអ្នកដែលទទួលរងរបួស ដែលរួមមានទាហានខ្មែរក្រហម ជនស៊ីវិល និងក្មេងៗ ។**

ក្រុមទី២ :

១) ក្នុងនាមជាវេជ្ជបណ្ឌិត ហេតុអ្វីបានជាគាត់ជួយកងទ័ពខ្មែរក្រហម? **គាត់បានបូជាជីវិតរបស់គាត់ ដើម្បីជួយអ្នកជំងឺទាំងអស់របស់គាត់ ។**

២) តើលោកវេជ្ជបណ្ឌិតមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលដែលក្មេងស្រីតូចម្នាក់អង្វរគាត់ឲ្យជួយ? **គាត់មានអារម្មណ៍អស់សង្ឃឹម នៅពេលដែលគាត់មិនអាចជួយក្មេងស្រីបាន ទោះបីជាពេលនោះគាត់មានភារកិច្ចជាវេជ្ជបណ្ឌិតដែលមានកាតព្វកិច្ចជួយដល់អ្នកជំងឺក៏ដោយ ។**

ក្រុមទី៣ :

១) ហេតុអ្វីបានជាគាត់មិនមានលទ្ធភាពជួយក្មេងស្រីតូចបាន? **គាត់ត្រូវបានបង្ខំឲ្យចាកចេញពីមន្ទីរពេទ្យ ។**

២) តើខ្មែរក្រហមបានផ្តល់ ឬមានគម្រោងសម្រាប់ការថែរក្សាសុខភាពដល់អ្នកដែលត្រូវបានផ្លាស់ប្តូរដោយបង្ខំចេញពីទីក្រុងភ្នំពេញដែរឬទេ? **គ្មានទេ ។ ពុំមានបុគ្គលិកពេទ្យខ្មែរក្រហម ឬទាហានដែលទទួលបន្ទុក នៅមន្ទីរពេទ្យឡើយ ។**

ក្រុមទី៤ :

១) ហេតុអ្វីបានជាអ្នកគិតថា លោកវេជ្ជបណ្ឌិតនៅតែនឹកឃើញរូបភាពរបស់ក្មេងស្រីតូចនោះ? **នាងនៅក្មេង ហើយលោកវេជ្ជបណ្ឌិតមិនអាចជួយនាងបាន ។ លោកវេជ្ជបណ្ឌិតក៏ជួបផលវិបាកក្នុងការចាកចេញចោល**

**អ្នកជំងឺដែលកំពុងត្រូវការគាត់ជួយ ។**

២) តើលោកវេជ្ជបណ្ឌិតមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលដែលគាត់ដឹងថា គាត់ត្រូវចាកចេញពីទីក្រុងភ្នំពេញ? **គាត់មានអារម្មណ៍អស់សង្ឃឹម និងគ្មានលទ្ធភាពអាចទទួលបានព័ត៌មានអំពីក្មេងស្រីតូចម្នាក់នោះ ។**

*ក្រុមទី៥ :*

១) តើលោកវេជ្ជបណ្ឌិតសង្ឃឹមថា នឹងអាចរកប្រពន្ធគាត់ឃើញនៅកន្លែងណា? **នៅភូមិកំណើតប្រពន្ធរបស់គាត់ ។**

២) ហេតុអ្វីបានជាលោកវេជ្ជបណ្ឌិតចាប់ផ្តើមកុហកកងសន្តិសុខខ្មែរក្រហមនៅតាមផ្លូវទៅកាន់ទីជនបទ? **គាត់មិនជឿថា គាត់អាចជឿជាក់លើកងសន្តិសុខបានទេ ពីព្រោះគាត់បានឃើញកងសន្តិសុខទាំងនោះកំពុងបោកប្រាស់ប្រជាជននៅតាមផ្លូវមួយចំនួន ។**

*សំយោគ (១៥-២៥នាទី)*

ក្រុមទាំងអស់ចែករំលែកចម្លើយរបស់ខ្លួនទៅមិត្តទាំងអស់នៅក្នុងថ្នាក់ ។ គ្រូប្រមូលចម្លើយដើម្បីវាយតម្លៃ ។ គ្រូអាចមើលទៅលើសេចក្តីសង្ខេបនៃផ្ទៃរឿងនៅផ្នែកចុងក្រោយនៃមេរៀននេះ សម្រាប់គម្រោងក្នុងការពិភាក្សាដោយសង្ខេប ។

## សំឡេងពីដើមបណ្តឹងរដ្ឋប្បវេណី ដែលជាវេជ្ជបណ្ឌិត

លោក មាស សារ៉ាន់ ជាវេជ្ជបណ្ឌិតម្នាក់ធ្វើការនៅក្នុងទីក្រុងភ្នំពេញនៅមុនថ្ងៃជ័យជម្នះរបស់កងទ័ពខ្មែរក្រហមលើកម្លាំងយោធារបស់ លន់ នល់ ។ គាត់ពន្យល់ពីស្ថានភាពនាពេលនោះយ៉ាងសង្ខេបមុនពេលជម្លៀស ៖

នៅឯបុរីកីឡា នៅពេលនោះខ្ញុំ (លោក មាស សារ៉ាន់) កំពុងធ្វើការនៅក្នុងបន្ទប់វះកាត់មួយ ។ មានផ្នែកវះកាត់ ចំនួន៥ដែលត្រូវទទួលអ្នករបួស ។ នេះគឺជាកន្លែងដំបូងដែលអ្នករបួសត្រូវចូល ។

នៅថ្ងៃទី១៦ មានការទម្លាក់គ្រាប់បែកនៅម្តុំផ្សារឱុយមិច ។ មនុស្សទទួលរងរបួស ហើយត្រូវបានបញ្ជូនទៅទីនោះ ។ ខ្ញុំមិនចាំចំនួនអ្នកជំងឺទេ ប៉ុន្តែផ្នែកនីមួយៗបន្តទទួលអ្នករបួស ហើយមិនមានគ្រែគ្រប់គ្រាន់សម្រាប់ទទួលអ្នករបួសទេ ។ ដូច្នេះយើងត្រូវតែឲ្យអ្នករបួសដែលចូលមកថ្មីសម្រាកនៅលើឥដ្ឋ ។

មនុស្សមួយចំនួនមិនមានរបួសធ្ងន់ធ្ងរទេ ហើយពួកគេអាចដើរបាន ។ ខ្លះទៀតមានរបួសជើង មិនអាចដើរបាន ហើយត្រូវតែនៅលើគ្រែ ។ ខ្ញុំនឹកឃើញក្មេងស្រីអាយុ៧ឆ្នាំម្នាក់ដែលមានរបួសជាទម្ងន់ ។ នាងបានប្រាប់ខ្ញុំថា នាងរបួសដោយសារតែគ្រាប់បែក ។ ក្មេងស្រីនោះដេកនៅលើឥដ្ឋ ។ ខ្ញុំមិនអាចជួយសង្គ្រោះជីវិតនាងបាន នៅពេលដែលខ្ញុំត្រូវបានជម្លៀសចេញពីមន្ទីរពេទ្យ ។

នៅព្រឹកថ្ងៃទី១៧ នៅពេលដែលខ្ញុំត្រូវបានប្រាប់ឲ្យចាកចេញ មនុស្សនៅក្នុងមន្ទីរពេទ្យត្រូវបានប្រាប់ឲ្យចេញទៅក្រៅ ។ អ្នកជំងឺមួយចំនួននៅលើគ្រែត្រូវរុញតាមរទេះ ។

លោក សារ៉ាន់ បាននិយាយអំពីអារម្មណ៍របស់គាត់អំពីព្រឹត្តិការណ៍ទាំងនេះ ក្នុងនាមជាវេជ្ជបណ្ឌិត ដែលមានវិជ្ជាជីវៈម្នាក់ ៖

ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំឲ្យធ្វើជាវេជ្ជបណ្ឌិត មិនមែនទាហានទេ ។ ខ្ញុំបានបូជាជីវិតដើម្បីជួយអ្នកជំងឺ ដែលរួមទាំងកងទ័ពរបួសរបស់ខ្មែរក្រហមផង ។ ខ្ញុំព្យាបាលរបួសឲ្យកងទ័ពខ្មែរក្រហមពីរនាក់ ។ នៅពេលដែលខ្ញុំត្រូវបានបញ្ជាឲ្យចាកចេញពីភ្នំពេញ ខ្ញុំមានអារម្មណ៍ពិបាកខ្លាំងណាស់ ពីព្រោះនៅពេលនោះ ខ្ញុំគិតថា អ្នកជំងឺ អ្នករបួស នឹងទទួលបានជំនួយយ៉ាងល្អ

នៅក្នុងអំឡុងពេលជម្លៀស ប៉ុន្តែក្នុងពេលជាមួយគ្នានោះដែរ ខ្ញុំមិនច្បាស់នៅក្នុងចិត្តទេ ថាតើអ្នកទាំងនោះនឹងទទួលបានការថែរក្សាសមរម្យ ។ ខ្ញុំនឹកឃើញដល់ក្មេងស្រីម្នាក់ ដែលមានរបួសធ្ងន់ធ្ងរ ហើយបានអង្វរខ្ញុំឲ្យយកនាងចេញទៅជាមួយផង ។ ខ្ញុំមិនអាចជួយនាងបានទេ ។ ខ្ញុំមានកាតព្វកិច្ចត្រូវតែជួយនាងក្នុងនាមជាវេជ្ជបណ្ឌិត ប៉ុន្តែខ្ញុំមិនអាចជួយនាងឲ្យហួសពីអ្វីដែលខ្ញុំអាចធ្វើបានទេ ។

លោក សារ៉ាន់ បានបន្តថា ៖

«នៅពេលនោះ មិនមានបុគ្គលិកពេទ្យ ឬកងទ័ពខ្មែរក្រហមណាម្នាក់នៅទីនោះដើម្បីទទួលមើលការខុសត្រូវក្នុងមន្ទីរពេទ្យឡើយ ។ ខ្ញុំមិនបានដឹងថា មានរឿងអ្វីកើតឡើងបន្ទាប់មកទៀតទេ ។ ប៉ុន្តែ នៅពេលនោះ ខ្ញុំប្រាកដក្នុងចិត្តណាស់ថា មិនមានអ្នកណាម្នាក់នៅទីនោះ ដើម្បីជួយបុគ្គលិកពេទ្យនៅក្នុងអំឡុងពេលនៃការជម្លៀសទេ ។»

លោក សារ៉ាន់ បានបន្តរៀបរាប់អំពីអារម្មណ៍របស់គាត់នៅពេលដែលគាត់ត្រូវបានបង្ខំឲ្យចាកចេញពីអ្នកជំងឺរបស់គាត់ ៖

ក្នុងនាមខ្ញុំជាបុគ្គលិកពេទ្យ វាគឺជាកាតព្វកិច្ចរបស់ខ្ញុំ ។ និយាយតាមត្រង់ទៅ ខ្ញុំមានអារម្មណ៍ពិបាកក្នុងខ្លួនណាស់ ក្នុងការទុកអ្នកជំងឺចោល ។ នៅក្នុងចិត្តរបស់ខ្ញុំ នៅពេលដែលខ្ញុំទុកពួកគេចោល ទីមួយ ពួកគេនឹងស្លាប់ ហើយទីពីរប្រសិនបើខ្មែរក្រហមជួយពួកគេ ពួកគេនឹងអាចរស់បាន ។ ប៉ុន្តែ រឿងគឺថា តើខ្ញុំអាចជួយអ្វីដល់ពួកគេបានក្នុងនាមខ្ញុំជាគ្រូពេទ្យ? ខ្ញុំមិនអាចជួយអ្វីបានច្រើនទេ ។ នៅពេលដែលខ្ញុំចាកចេញ ខ្ញុំបានចាកចេញទាំងអារម្មណ៍មិនស្រួល ហើយខ្ញុំនៅតែគិតអំពីប្រពន្ធរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍មិនស្រួលសោះនៅពេលដែលខ្ញុំចាកចេញ ពីព្រោះខ្ញុំបានទុកអ្នកជំងឺចោល ជាពិសេសក្មេងស្រីម្នាក់ ហើយខ្ញុំនៅតែនឹកឃើញរូបភាពក្មេងស្រីនេះនៅឡើយ ។

មុនដំបូង យើងត្រូវចាកចេញពីភ្នំពេញតែបីថ្ងៃប៉ុណ្ណោះ ហើយនៅក្នុងអំឡុងពេលបីថ្ងៃនេះ វាមានការលំបាកខ្លាំងណាស់ នៅពេលដែលយើងធ្វើដំណើរនៅតាមផ្លូវ ។ បន្ទាប់មក យើងឆ្លងកាត់ស្ពានព្រះមុនីវង្ស ។ បន្ទាប់ពីរយៈពេលបីថ្ងៃ បានកន្លងផុតទៅនៅតែមានមនុស្សច្រើននៅឡើយនៅត្រើយស្ពានម្ខាងទៀត ។ ខ្ញុំនៅតែរង់ចាំប្រពន្ធរបស់ខ្ញុំ ហើយខ្ញុំនៅតែមានសង្ឃឹមថា ខ្ញុំនឹងត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅវិញបន្ទាប់ពីរយៈពេលបីថ្ងៃ ។ ខ្ញុំមានការបារម្ភអំពីប្រពន្ធរបស់ខ្ញុំខ្លាំងណាស់ ដោយសារ គាត់មានផ្ទៃពោះ និងមិនស្គាល់ភ្នំពេញច្បាស់ ។ បន្ទាប់ពីរយៈពេលបីថ្ងៃបានកន្លងផុតទៅ ខ្ញុំបានស្វែងរកប្រពន្ធរបស់ខ្ញុំនៅក្នុងចំណោមហ្វូងមនុស្ស ដែលកំពុងតែឆ្លងកាត់ស្ពាននៅឡើយ ។ នៅទីបញ្ចប់ ខ្ញុំអស់សង្ឃឹម ហើយខ្ញុំត្រូវតែស្វែងរកមធ្យោបាយផ្សេងទៀត ដើម្បីស្វែងរកប្រពន្ធរបស់ខ្ញុំនៅភូមិកំណើតរបស់ប្រពន្ធខ្ញុំ ។

បន្ទាប់ពីរយៈពេលបីថ្ងៃបានកន្លងផុតទៅ មានការប្រកាសមួយពីភ្នំពេញតាមមេក្រូអំពាវនាវឲ្យអតីតមន្ត្រីរដ្ឋការត្រឡប់ទៅធ្វើការនៅភ្នំពេញវិញ ។ ខ្ញុំបានឃើញមនុស្សមួយចំនួនត្រឡប់ទៅភ្នំពេញវិញ ។ ប៉ុន្តែអ្នកទាំងនោះ ទៅតែខ្លួនឯងដោយមិនមានសមាជិកគ្រួសាររបស់ពួកគេទៅជាមួយទេ ហើយខ្ញុំមិនបានឃើញពួកគេត្រឡប់មកវិញទេ ។ ជាមួយនឹងស្ថានភាពនេះ ខ្ញុំគិតថា មានបញ្ហាអ្វីមួយកើតឡើងនៅភ្នំពេញមិនខាន ហើយខ្ញុំមានការខ្វល់ខ្វាយអំពីបញ្ហានេះណាស់ ។

លោកវេជ្ជបណ្ឌិត បានបន្តពន្យល់អំពីរបៀបដែលគាត់ឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យជាច្រើននៅតាមផ្លូវទៅកាន់ភូមិកំណើតរបស់ប្រពន្ធគាត់ ។ គាត់ត្រូវបានសួរចម្លើយនៅគ្រប់ប៉ុស្តិ៍ត្រួតពិនិត្យនីមួយៗ ហើយគាត់បានរៀនកុហកខ្មែរក្រហម បានយ៉ាងឆាប់រហ័ស ពីព្រោះលោកមិនទុកចិត្តខ្មែរក្រហមទាំងនោះ ។

និយាយតាមត្រង់ទៅ ខ្ញុំមិនទុកចិត្តពួកគេទេ ។ ខ្ញុំមិនទុកចិត្ត ពីព្រោះខ្ញុំមើលឃើញថា អ្នកដែលត្រូវបានហៅឲ្យត្រឡប់



កងកម្លាំងប្រដាប់អាវុធកម្ពុជាក្នុងឯកសណ្ឋានថតក្នុងអំឡុងពេលហ្វឹកហាត់នៅទីក្រុងភ្នំពេញ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅភ្នំពេញវិញ មិនដែលឃើញត្រឡប់មកវិញទេ ។ ខ្ញុំមិនទុកចិត្ត ពីព្រោះពួកគេនិយាយអំពីការទម្លាក់គ្រាប់បែកភ្លាមៗ ហើយយើងត្រូវតែជម្លៀសរយៈពេលបីថ្ងៃប៉ុណ្ណោះ ប៉ុន្តែពួកគេកុហក ។ រឿងនេះមិនបានកើតឡើងទេ ។ ជាការពិតណាស់ ប្រសិនបើប្រជាជនត្រូវបានអនុញ្ញាតឲ្យត្រឡប់មកវិញ ពួកគេប្រាកដជាអាចរស់រានមានជីវិតបាន ។ ប៉ុន្តែ រឿងនេះមិនបានកើតឡើងទេ ដូច្នេះខ្ញុំបានសម្រេចចិត្តថា ខ្ញុំត្រូវតែកុហក ។

មកដល់ព្រឹត្តិការណ៍ដែលបានកើតឡើង បន្ទាប់ពីលោកបានមកដល់ភូមិកំណើតរបស់ប្រពន្ធគាត់បាននិយាយថា ៖

នៅពេលដែលខ្ញុំបានមកដល់ភូមិ ម្ដាយក្មេកខ្ញុំយំ ពីព្រោះគាត់មិនបានឃើញប្រពន្ធរបស់ខ្ញុំ ។ ខ្ញុំខ្លួនឯងមានការខកចិត្តយ៉ាងខ្លាំង ពីព្រោះខ្ញុំមិនបានឃើញប្រពន្ធរបស់ខ្ញុំ ។

### ពិភាក្សាផ្ទៃរឿងសំខាន់ៗ

១) ការជម្លៀសដោយបង្ខំ បង្កឲ្យប្រជាជនភាគច្រើនទទួលរងជំងឺ និងរបួស ដោយសារពុំមានការថែរក្សាសុខភាពឲ្យបានត្រឹមត្រូវ ។

២) ទាំងសង្គ្រាម ទាំងការជម្លៀសដោយបង្ខំ បានបង្កើតឲ្យមានភាពលំបាកដល់ប្រជាជនដែលមិនអាចជៀសផុត ដូច លោក មាស សារ៉ាន់ អ៊ីចឹង ។ គាត់បានគិតថា តើគាត់ព្យាបាលជំងឺឲ្យយោធាខ្មែរក្រហមឬអត់ ហើយបន្ទាប់មក គាត់គិតថា តើត្រូវកុហកយោធាខ្មែរក្រហមឬអត់?

៣) អំពើឃោរឃៅរបស់ខ្មែរក្រហមបាននាំឲ្យមានភាពភ័យខ្លាច និងបាត់បង់ភាពទុកចិត្តគ្នារវាងមនុស្ស និងមនុស្ស និងរវាងមនុស្ស និងរដ្ឋាភិបាល ។

## មេរៀនទី៤ ៖ ទួលពោធិ៍ជ្រៃ

### វត្ថុបំណង

១) សិស្សយល់អំពីស្ថានភាពដែលនៅជុំវិញការសម្លាប់រង្គាល ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ នៅចុងខែមេសា ឆ្នាំ១៩៧៥ ។

២) សិស្សពន្យល់អំពីទិដ្ឋភាពនៃការសម្លាប់រង្គាល ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ ។

៣) សិស្សយល់អំពីរឿងរ៉ាវផ្សេងៗគ្នា នៃអ្វីដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ ។

៤) សិស្សសង្ខេបការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

**សម្ភារឧបទេស** : ទួលពោធិ៍ជ្រៃ និងអត្ថបទ «សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»

**លំនាំបង្រៀន**

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូណែនាំអំពីវត្ថុបំណងនៃមេរៀនសម្រាប់ក្នុងថ្ងៃនេះ ហើយឲ្យសិស្សអានអត្ថបទអំពី «ទួលពោធិ៍ជ្រៃ» ។

*ការបង្រៀន (១០-១៥នាទី)*

សិស្សអានដោយយកចិត្តទុកដាក់ និងកត់ត្រានូវការពិតសំខាន់ៗ ហើយពិភាក្សានៅក្នុងក្រុមតូចអំពីរឿងរ៉ាវផ្សេងៗគ្នាព្រមទាំងមូលហេតុដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ ។ សិស្សគួរយោងអត្ថបទអំពី ទួលពោធិ៍ជ្រៃ និងអត្ថបទអំពីសំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីបំពេញសំណួរណែនាំ ។

*សំយោគ (១៥នាទី)*

គ្រូពិនិត្យមើលសំណួរណែនាំជាមួយសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសំយោគការសិក្សារបស់សិស្ស ។

## ទួលពោធិ៍ជ្រៃ

នៅឆ្នាំ១៩៧៥ ទួលពោធិ៍ជ្រៃគឺជាវាលដ៏ធំមួយ ដែលស្ថិតនៅជិតទន្លេសាប និងព្រៃលិចទឹក ។ ទោះជាយ៉ាងនេះក្តី នៅខែមេសា ឆ្នាំ១៩៧៥ កន្លែងនេះត្រូវបានដឹងថា ជាទីតាំងសម្លាប់ទាហាន លន់ នល់ និងជនស៊ីវិលរាប់ពាន់នាក់ ។ ទីតាំងនេះជាទីតាំងដែលមានការសម្លាប់រង្គាលដ៏អាក្រក់បំផុតមួយក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំជាលើកដំបូងរបស់របបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលខ្មែរក្រហមធ្វើការបោសសម្អាតទីក្រុង និងចម្រាញ់រកអតីតមន្ត្រីរបស់ លន់ នល់ និងអ្នកដែលមានចិត្តមេត្តា ។

នៅថ្ងៃទី១៧ មេសា ១៩៧៥ កងយោធារបស់ លន់ នល់ ក្នុងខេត្តពោធិ៍សាត់ បានទទួលសេចក្តីណែនាំតាមរយៈវិទ្យុជាតិផ្សាយពីភ្នំពេញឲ្យទម្លាក់អាវុធចុះ ។ មកដល់ថ្ងៃទី១៩ ខែមេសា ខ្មែរក្រហមបានចូលកាន់កាប់ខេត្តពោធិ៍សាត់ ។ ភ្លាមៗបន្ទាប់ពីនេះ ខ្មែរក្រហមបានដឹកទាហាន លន់ នល់ តាមរថយន្តទៅកាន់ការិយាល័យនៅទីរួមខេត្ត ទៅជួបមេដឹកនាំខ្មែរក្រហម ។ កិច្ចប្រជុំមានរយៈពេលបីទៅបួនម៉ោង ហើយមានទាហាន និងមន្ត្រីរដ្ឋការស៊ីវិលប្រមាណជា៥០០នាក់បានចូលរួម ។

នៅឯកិច្ចប្រជុំ ទាហាន លន់ នល់ ទទួលបានវគ្គបណ្តុះបណ្តាលអប់រំនយោបាយ ដើម្បីត្រៀមខ្លួនជួបជាមួយអង្គការនៅថ្ងៃបន្ទាប់ ។ ខ្មែរក្រហមក៏បានជំរុញឲ្យអ្នករស់នៅក្នុងទីរួមខេត្តពោធិ៍សាត់ចាកចេញដែរ ។ ទាហាន នល់ នល់ ត្រូវបានប្រាប់ថា ខ្លួននឹងត្រូវបានបញ្ជូនទៅចូលរួមវគ្គបណ្តុះបណ្តាល និងទៅជួបជាមួយសម្តេចព្រះ នរោត្តម សីហនុ ។ ទាហានទាំងនោះក៏ត្រូវបានប្រាប់បន្ថែមទៀតថា ខ្លួននឹងទទួលបានតួនាទីរបស់ខ្លួនឡើងវិញបន្ទាប់ពីកិច្ចប្រជុំ ។ អ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំរួមមានមន្ត្រីយោធារបស់ លន់ នល់ ដែលមានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីរហូតដល់ឧត្តមសេនីយ៍ ។

បន្ទាប់ពីកិច្ចប្រជុំ ទាហាន លន់ នល់ ហាក់ដូចជាមានការសប្បាយចិត្ត ដោយបាននិយាយលេងជាមួយសាច់ញាតិ ខណៈពេលរង់ចាំ ហើយប្រាប់សាច់ញាតិថា ខ្លួននឹងទៅចូលរួមវគ្គសិក្សា និងជួបជាមួយសម្តេចឳ ។

យោងតាមសក្ខីកម្មរបស់លោក សាត លីម បន្ទាប់ពីកិច្ចប្រជុំជាមួយខ្មែរក្រហម ទាហាន លន់ នល់ ត្រូវបានដឹកតាមឡានទៅកាន់កន្លែងប្រជុំជាមួយអង្គការ ដែលសំដៅទៅកាន់ទួលពោធិ៍ជ្រៃ ។ បើយោងតាមមនុស្សម្នាក់ទៀតឈ្មោះ អ៊ុង ឆាត់ ទាហាន លន់ នល់ ហាក់ដូចជាឡើងឡានដោយស្ម័គ្រចិត្ត ។ នៅឯបន្ទាយភូមិពោរ ខ្មែរក្រហមបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យ ដើម្បីការពារកុំឲ្យប្រជាជនធ្វើដំណើរចូលទៅកាន់តំបន់នោះ ។ ខ្មែរក្រហមអនុញ្ញាតឲ្យឡានចូលទៅកាន់បន្ទាយម្តង តែមួយប៉ុណ្ណោះ ។

ឡានដែលពេញទៅដោយទាហាន លន់ នល់ បានចាកចេញពីបន្ទាយភូមិពោរម្តងមួយ ក្នុងចន្លោះពី២០នាទីម្តង ។ របាយការណ៍មួយចំនួនអះអាងថា ឡានទាំងនោះដឹកសុទ្ធតែទាហាន និងមន្ត្រីស៊ីវិលរបស់ លន់ នល់ ។ ខ្មែរក្រហមនឹងមិនអនុញ្ញាតឲ្យឡានមួយទៀតចូលទៅកាន់ទួលពោធិ៍ជ្រៃ រហូតដល់ពួកគេឃើញឡានដែលចូលទៅមុនត្រឡប់មកវិញ ។ អ្នកភូមិកត់សម្គាល់ឃើញថា ទាហាន លន់ នល់ ហាក់ដូចជាមានអារម្មណ៍ធូរស្រាលនៅលើឡានឆ្ពោះទៅកាន់ទីតាំងនោះ ដោយសារទាហានទាំងនេះត្រូវបានប្រាប់ថា ខ្លួននឹងជួបជាមួយអង្គការ និងសម្តេចឳ ។ ទោះជាយ៉ាងនេះក្តី ឡានត្រឡប់មកវិញ ដោយគ្មានមនុស្សជិះ ។ អ្នកភូមិបានរាយការណ៍ថា បានឮសំឡេងគ្រាប់កាំភ្លើងនៅក្បែរភូមិ ។ ទាហាន លន់ នល់ ដែលត្រូវបានបញ្ជូនទៅកាន់ទួលពោធិ៍ជ្រៃត្រូវបានសម្លាប់ ។ វាមិនច្បាស់លាស់ទេ ថាតើមានទាហាន លន់ នល់ ប៉ុន្មាននាក់ ដែលត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ ហើយការប៉ាន់ស្មានគឺពីចន្លោះយ៉ាងតិច ២ពាន់នាក់ ហើយអាចមានចំនួនច្រើនរហូតដល់ទៅ ៨ពាន់នាក់ ។

វាលពិឃាតទួលពោធិ៍ជ្រៃមានប្រតិបត្តិការចាប់ពីចុងឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ដែលនៅក្នុងរយៈពេលនោះ ការសម្លាប់អតីតទាហាន និងមន្ត្រីស៊ីវិលក្នុងទ្រង់ទ្រាយធំត្រូវបានធ្វើឡើង ។

## សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

លោក សាត លីម ដែលជាអតីតទាហានខ្មែរក្រហម និងជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០២ បានធ្វើសក្ខីកម្មអំពីអ្វីដែលលោកបានឃើញ និងឮនៅពេលលោកស្ថិតនៅក្នុងតំបន់ទួលពោធិ៍ជ្រៃ ក្នុងខែមេសា ឆ្នាំ១៩៧៥ ។

លោក លីម បានផ្តល់សក្ខីកម្មថា ទាហាន លន់ នល់ ប្រមាណ ៣ពាន់នាក់ត្រូវបានសម្លាប់នៅក្នុងអំឡុងពេលនៃការវាយប្រហារចុងក្រោយទៅលើទួលពោធិ៍ជ្រៃ នៅថ្ងៃទី១៧ មេសា ១៩៧៥ ។ លោក លីម កត់សម្គាល់ឃើញថា ទាហាន លន់ នល់ បានចុះចាញ់ដោយលើកទង់ស នៅឯបន្ទាយទួលពោធិ៍ជ្រៃ ។ លោកជឿជាក់ថា មានទាហានប្រហែល ១០០នាក់ ដែលស្លៀកសម្លៀកបំពាក់យោធា និងកងកុម្ម៉ង់ដូប៉ុន្មាននាក់នៅក្នុងសម្លៀកបំពាក់ស៊ីវិល ។ នៅពេលដែលទាហានទាំងនោះចុះចាញ់ ពួកគេត្រូវបានដកហូតអាវុធ ហើយត្រូវបានប្រមូលផ្តុំជាក្រុមៗ ។ នៅទីបញ្ចប់ ទាហាន លន់ នល់ ត្រូវបានបញ្ជូនចេញពីទីរួមខេត្តទៅកាន់ទួលពោធិ៍ជ្រៃ ដែលនៅទីនោះពួកគេត្រូវបានសម្លាប់ ។

អ្នកស្រី យឹម សុវណ្ណ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងសំណុំរឿង០០២ បានផ្តល់សក្ខីកម្មអំពីអ្វីដែលគាត់បានឃើញ និងបានឮនៅពេលដែលគាត់នៅឯតំបន់

ទួលពោធិ៍ជ្រៃ នៅចុងឆ្នាំ១៩៧៦ ។

អ្នកស្រី សុវណ្ណ បានឆ្លងកាត់ឃុំទួលពោធិ៍ជ្រៃជាញឹកញាប់នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ដើម្បីទៅប្រមូលស្បៀវ ។ អ្នកភូមិនៅពោធិ៍សាត់បានប្រាប់គាត់ថា ទាហាន លន់ នល់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ ។ អ្នកស្រី សុវណ្ណ បានឮពីកងទ័ពខ្មែរក្រហមថា ទាហាន លន់ នល់ បន្ទាប់ពីទទួលបានការណែនាំពីកងទ័ពខ្មែរក្រហម ត្រូវបានដឹកតាមឡានទៅកាន់ទួលពោធិ៍ជ្រៃដើម្បីសម្លាប់នៅខែមេសា ឆ្នាំ១៩៧៥ ។ អ្នកភូមិបានប្រាប់អ្នកស្រី សុវណ្ណ ទៀតថា ការសម្លាប់បានកើតឡើងប្រហែល"កន្លះខែ" ។ អ្នកស្រីក៏បានឃើញទួលមួយដែលពោរពេញទៅដោយពំនូកដីនៅឯទួលពោធិ៍ជ្រៃ ដែលគាត់សន្និដ្ឋានថាជាកន្លែង"កប់ខ្មោច" ។ អ្នកស្រីបានជួបជាមួយប្រជាជន ដែលមកពីសហករណ៍ក្បាលឈើពុក ដែលសាច់ញាតិរបស់ពួកគេត្រូវបានសម្លាប់នៅទីនោះ ។ អ្នកស្រីបានពណ៌នាទីតាំងនោះថា ជាវាលធំមួយ ដែលស្ថិតនៅជិតទន្លេសាប និងជិតព្រៃលិចទឹក ។ អ្នកស្រី សុវណ្ណ បានកត់សម្គាល់ថា គាត់មិនបានដឹងអំពីតួលេខពិតប្រាកដអំពីចំនួនទាហាន លន់ នល់ ដែលបានស្លាប់នៅទួលពោធិ៍ជ្រៃនោះទេ ។ អ្នកស្រីបានកត់សម្គាល់ឃើញថា មិនមែនតែទាហាន លន់ នល់ នោះទេ មន្ត្រីស៊ីវិលពីរបបចាស់ក៏ត្រូវបានប្រមូលផ្តុំ ហើយបញ្ជូនទៅសម្លាប់នៅទួលពោធិ៍ជ្រៃដែរ ។

លោក អ៊ុង ឆាត់ ដែលជាអតីតកងទ័ពខ្មែរក្រហម និងជាសាក្សីមួយរូបនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានធ្វើសក្ខីកម្មអំពីអ្វីដែលលោកបានឃើញ និងបានឮ នៅពេលដែលលោកនៅទួលពោធិ៍ជ្រៃក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥ ។

លោក ឆាត់ បានរៀបរាប់ថា លោកបានប្រទះឃើញទាហាន លន់ នល់ នៅឯបន្ទាយទួលពោធិ៍ជ្រៃ ។ "អង្គការអនុញ្ញាតឲ្យឡានចូលទៅទីនោះម្តងមួយតែប៉ុណ្ណោះ ។ ខ្ញុំបានឃើញកងទ័ពខ្មែរក្រហមរាប់រយនាក់ឡោមព័ទ្ធទាហាន លន់ នល់ ។ កងទ័ពខ្មែរក្រហមក៏បានដាក់ប៉ុស្តិ៍ត្រួតពិនិត្យនៅទីនោះ ដើម្បីហាមឃាត់មិនឲ្យប្រជាជនធ្វើដំណើរទៅកាន់តំបន់នោះ ។ ខ្ញុំត្រូវបានពួកគេបញ្ឈប់ ហើយសាកសួរ ។ ប៉ុន្តែដោយសារខ្ញុំមានក្រដាសអនុញ្ញាត ពួកគេបានអនុញ្ញាតឲ្យខ្ញុំឆ្លងកាត់ ។ នៅពេលដែលខ្ញុំនៅទីនោះ ខ្ញុំបានឃើញពួកគេអនុញ្ញាតឲ្យឡានឆ្លងកាត់តំបន់នោះម្តងមួយៗ ក្នុងចន្លោះ២០នាទីម្តង ។ ខ្មែរក្រហមនឹងមិនអនុញ្ញាតឲ្យឡានមួយទៀតចូលទៅកាន់ទួលពោធិ៍ជ្រៃទេ រហូតដល់ពួកគេបានឃើញឡានដែលចូលទៅមុន ត្រឡប់មកវិញ ។ ក្រោយមក ខ្ញុំបានឃើញឡានដែលបានដឹកទាហាន លន់ នល់ ទៅកាន់ទីនោះមុននេះបន្តិច ត្រឡប់មកវិញដោយគ្មានមនុស្សជិះ" ។

ក្រោយមក លោក ឆាត់ និងអ្នកភូមិពីរនាក់ទៀត បានទៅមើលសាកសពនៅក្នុងបន្ទាយទួលពោធិ៍ជ្រៃ ។ លោកបានរាយការណ៍ថា សាកសពទាហានទាំងអស់ស្ថិតនៅលើដី ដែលមានក្បាលបែរទៅទិសខាងជើង ។ ទាហានទាំងនេះស្លៀកសម្លៀកបំពាក់ស៊ីវិល ជាជាងឯកសណ្ឋានយោធា ។ សាកសពត្រូវបានចងភ្ជាប់គ្នាជាក្រុមដោយខ្សែពួរ ដែលមានពី១៥ទៅ២០នាក់ ដោយដៃរបស់ពួកគេត្រូវបានចងទៅខាងក្រោយ ។

លោក សុម អាឡាត ដែលជាអតីតទាហាន លន់ នល់ និងជាសាក្សីមួយរូបនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានផ្តល់សក្ខីកម្មអំពីអ្វីដែលលោកបានឃើញ និងបានឮនៅពេលដែលលោកនៅតំបន់ទួលពោធិ៍ជ្រៃក្នុងខែមេសា ឆ្នាំ១៩៧៥ ។

នៅឯកិច្ចប្រជុំនៅសាលាខេត្ត ពួកគេបានអប់រំយើងអំពីគោលនយោបាយផ្ទះផ្សា និងអំពីការកសាងប្រទេស ។ ហើយចុងក្រោយ ពួកគេនិយាយអំពីការជឿជាក់នៅក្នុងការទៅទទួលអង្គការ ។ នេះគឺជាវិធីសាស្ត្ររបស់ពួកគេ ដូច្នេះយើង

មានការជឿជាក់ទៅលើពួកគេ ។ ជាទូទៅ យើងមិនបានដឹងថា នឹងមានអ្វីកើតឡើងនោះទេនៅពេលអនាគត ប៉ុន្តែយើងទាំងអស់គ្នាយល់ព្រមទៅចូលរួមការជួបជុំនោះ ។

ទួលពោធិ៍ជ្រៃមានចម្ងាយប្រហែល២០គីឡូម៉ែត្រពីខេត្ត ។ នៅពេលដែលយើងត្រូវបានប្រមូលផ្តុំឲ្យទៅទួលពោធិ៍ជ្រៃដែលនេះគឺជាការទៅទទួលអង្គការ ខ្ញុំបានយល់ព្រមទៅ ប៉ុន្តែនៅពេលនោះ រថយន្តដែលខ្ញុំជិះ ឈប់នៅពាក់កណ្តាលផ្លូវ ។ តាមពិតទៅ ខ្ញុំចង់ទៅជាមួយនឹងឡានមួយនោះ ប៉ុន្តែដោយវាមានមនុស្សពេញទៅហើយ ខ្ញុំត្រូវបានប្រាប់ឲ្យចាំជិះឡានបន្ទាប់ ។ ដូច្នេះ ខ្ញុំខ្លួនឯងមិនបានទៅដល់ទួលពោធិ៍ជ្រៃទេ ។ ទោះជាយ៉ាងនេះក្តី បីថ្ងៃក្រោយមក ខ្ញុំបានឮថាមនុស្សទាំងនោះត្រូវបានសម្លាប់ ។

ទាក់ទងនឹងការទៅទទួលអង្គការ យើងមិនដែលបានឮអំពីអង្គការទេ នៅពេលដែលយើងបានឮអំពីផ្នែករដ្ឋបាល ។ ដូច្នេះ យើងត្រូវបានប្រាប់ថា យើងនឹងទៅទទួលអង្គការ ។ យើងចង់ជួបអង្គការ ពីព្រោះយើងសង្ឃឹមថា បន្ទាប់ពីយើងផ្សះផ្សាជាមួយគ្នារួច យើងនឹងប្រមូលកម្លាំងគ្នាដើម្បីកសាងប្រទេស ប៉ុន្តែខ្ញុំមិនដែលដឹងថា អង្គការជាអ្នកណាទេ ។

### សំណួរណែនាំ និងចម្លើយ

១) បន្ទាប់ពីខ្មែរក្រហមកាន់កាប់បានខេត្តពោធិ៍សាត់ តើពួកគេយកទាហាន លន់ នល់ ទៅទីណា? **ទាហាន លន់ នល់ ត្រូវបានដឹកតាមឡានទៅកាន់សាលាខេត្ត ដើម្បីជួបថ្នាក់ដឹកនាំខ្មែរក្រហម ។**

២) នៅក្នុងអំឡុងពេលប្រជុំ តើទាហាន លន់ នល់ ត្រូវបានប្រាប់ដូចម្តេចខ្លះ? **នៅក្នុងកិច្ចប្រជុំ ទាហាន លន់ នល់ ត្រូវបានប្រាប់ថា ខ្លួននឹងត្រូវបានបញ្ជូនទៅចូលរួមវគ្គរៀនសូត្រ និងទៅជួបសម្តេចព្រះ នរោត្តម សីហនុ ហើយថា ពួកគេនឹងទទួលបានតំណែងចាស់ឡើងវិញបន្ទាប់ពីវគ្គរៀនសូត្រ ។**

៣) តើទាហាន លន់ នល់ មានការព្រួយបារម្ភ ខ្វល់ខ្វាយ និងភ័យខ្លាចដែរឬទេ បន្ទាប់ពីប្រជុំរួច? តើអារម្មណ៍ជាទូទៅរបស់អ្នកទាំងនោះមានលក្ខណៈដូចម្តេច? **បន្ទាប់ពីប្រជុំរួច ទាហាន លន់ នល់ ហាក់ដូចជាសប្បាយចិត្ត ដោយបាននិយាយលេងជាមួយសាច់ញាតិ ហើយបានប្រាប់សាច់ញាតិថា ខ្លួននឹងទៅរៀនសូត្រ និងទៅជួបសម្តេចឪ ។**

៤) តើអ្វីដែលបានបង្ខំឲ្យទាហាន លន់ នល់ ជឿជាក់លើខ្មែរក្រហម? **ខ្មែរក្រហមបានប្រាប់ឲ្យទាហាន លន់ នល់ ឲ្យជឿជាក់លើពួកគេ ហើយខ្មែរក្រហមនិយាយអំពីការផ្សះផ្សា និងការជួបជាមួយអង្គការ និងសម្តេចឪ ។ ដូចដែលសាក្សីមួយរូបបានលើកឡើង «យើងចង់ជួបជាមួយអង្គការ ពីព្រោះយើងសង្ឃឹមថា បន្ទាប់ពីយើងបានផ្សះផ្សាគ្នាហើយ យើងនឹងរួមកម្លាំងគ្នាកសាងប្រទេស» ។**

៥) បន្ទាប់ពីប្រជុំ តើទាហាន លន់ នល់ ត្រូវបានដឹកយកទៅកាន់កន្លែងណា? **ទាហាន លន់ នល់ ត្រូវបានដឹកតាមឡានទៅកាន់ទួលពោធិ៍ជ្រៃ ។**

៦) ចូររៀបរាប់អំពីប្រព័ន្ធដែលខ្មែរក្រហមប្រើនៅក្នុងការដឹកជញ្ជូនទាហាន លន់ នល់ ទៅកាន់ទួលពោធិ៍ជ្រៃ ។ និយាយម្យ៉ាងទៀត តើខ្មែរក្រហមរក្សាការគ្រប់គ្រងទៅលើទាហាន លន់ នល់ ដ៏ច្រើន ដែលចូលទៅកាន់តំបន់ទួលពោធិ៍ជ្រៃ ដោយរបៀបណា? **ឡានដែលដាក់ពេញទៅដោយទាហាន លន់ នល់ ចូលទៅកាន់បន្ទាយទួលពោធិ៍ជ្រៃម្តងមួយៗ ក្នុងចន្លោះប្រហែល២០នាទីម្តង ។ ការរាយការណ៍ខ្លះអះអាងថា ឡានគឺពេញទៅដោយទាហាន លន់ នល់ និងមន្ត្រី ស៊ីវិល ។ ខ្មែរក្រហមនឹងមិនឲ្យរថយន្តមួយទៀតចូលទៅកាន់ទួលពោធិ៍ជ្រៃទេ**

**រហូតដល់ពួកគេបានឃើញរថយន្ត ដែលចូលទៅពីមុនចេញមកវិញសិន ។**

៧) *តើប្រជាជនប៉ុន្មាននាក់ដែលត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ?* **វាមិនច្បាស់លាស់ទេ អំពីចំនួនទាហាន លន់ នល់ ដែលត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ ។ ការប៉ាន់ស្មាន គឺមានចន្លោះពី២ពាន់ទៅ៨ពាន់នាក់ ។**

# ជំពូក៤ ៖ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម



ទាហានខ្មែរក្រហមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## មេរៀនទី១ ៖ អំណានជំពូក៣ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

***វត្ថុបំណង***

១) សិស្សពណ៌នាពីការឡើងកាន់កាប់អំណាចរបស់ខ្មែរក្រហម ។

២) សិស្សពន្យល់អំពីបរិបទប្រវត្តិសាស្ត្រ និងសង្គម ដែលរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ។

៣) សិស្សកំណត់និយមន័យនៃពាក្យ និងឈ្មោះសំខាន់ៗ ។

៤) សិស្សសំយោគពីអ្វីដែលខ្លួនបានរៀន ដោយឆ្លើយនឹងសំណួរណែនាំ ។

***សម្ភារឧបទេស*** ៖ សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

***ពន្យល់ពាក្យ និង ឈ្មោះសំខាន់ៗ*** ៖

| | | |
|---|---|---|
| អន្តរាគមន៍បរទេស | ការទម្លាក់គ្រាប់បែក | កម្ទេចចោល |
| ក្រុមខុទ្ទាម | រំដោះ | មានតែឈ្មោះ |
| ឡុង នល់ | ជនសកម្មប្រយុទ្ធ | រដ្ឋបាល |
| លន់ ណុន | ការជម្លៀស | អ្នកការទូត |
| ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ | អំពើពុករលួយ | រឹបអូស |

## លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូឲ្យសិស្សពិភាក្សាថា តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា និងឲ្យនិយមន័យនៃពាក្យ និងឈ្មោះសំខាន់ៗនៅក្នុងជំពូក៣ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

*ការបង្រៀន (១៥-៤៥នាទី)*

គ្រូឲ្យសិស្សអានមេរៀនដោយយកចិត្តទុកដាក់ និងកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗក្នុងជំពូក៣ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក សិស្សសរសេរនៅក្នុងសៀវភៅលំហាត់ ដើម្បីបង្ហាញពីការសិក្សារបស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សនៅក្នុងថ្នាក់ទាំងអស់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) តើទីក្រុងភ្នំពេញធ្លាក់ទៅក្រោមការកាន់កាប់របស់កងកម្លាំងខ្មែរក្រហមនៅថ្ងៃណា? **ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។**

២) នៅពេលកងទ័ពខ្មែរក្រហមធ្វើដំណើរចូលមកក្នុងទីក្រុងភ្នំពេញ តើកងទ័ពទាំងនោះស្លៀកពាក់ឯកសណ្ឋានពណ៌អ្វី? **ពណ៌ខ្មៅ និងពណ៌អាចម៍សេះ ។**

៣) តើខ្មែរក្រហមបានប្រកាសតាមវិទ្យុទៅកាន់ប្រជាជនយ៉ាងដូចម្តេចខ្លះ? **ខ្មែរក្រហមបានប្រកាសតាមវិទ្យុថា ខ្លួនមិនមែនមកដើម្បីចរចាជាមួយអ្នកណាទាំងអស់ ហើយនឹងធ្វើការប្រហារជីវិតមន្ត្រីជាន់ខ្ពស់ និងមេបញ្ជាការកងទ័ពរបស់រដ្ឋាភិបាលចាស់ ។** ចំពោះសេចក្តីប្រកាសនេះ តើអ្នកគិតថាប្រជាជនមានប្រតិកម្មយ៉ាងដូចម្តេច? **ចម្លើយអាចមានច្រើន ។**

៤) តើជនបរទេស និងជនជាតិខ្មែរមួយចំនួនស្វែងរកការជ្រកកោននៅកន្លែងណា? **សណ្ឋាគារឡឺភ្នំ (បច្ចុប្បន្ន សណ្ឋាគារឡឺរ៉ូយ៉ាល់) ដែលកាកបាទក្រហមអន្តរជាតិបានប្រកាសជាតំបន់អព្យាក្រឹត ។**

៥) តើមន្ត្រីជាន់ខ្ពស់របស់របបសាធារណរដ្ឋខ្មែរចំនួន៣រូប ដែលត្រូវខ្មែរក្រហមប្រហារជីវិតមានឈ្មោះអ្វីខ្លះ? **នាយករដ្ឋមន្ត្រី ឡុង បូរ៉េត ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ និង លន់ ណុន (ប្អូនប្រុសរបស់ លន់ នល់) ។**

៦) ចំពោះប្រជាជនដែលរស់នៅក្នុងទីក្រុង តើខ្មែរក្រហមធ្វើដូចម្តេចខ្លះ? **ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុង និងទៅធ្វើស្រែចម្ការនៅតាមទីជនបទ ។**

៧) តើមានអ្វីខ្លះកើតឡើងចំពោះអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ? **អ្នកជំងឺត្រូវបានបង្ខំឲ្យចាកចេញពីមន្ទីរពេទ្យដែរ ។**

៨) តើហេតុផលដែលខ្មែរក្រហមបានពន្យល់ចំពោះការបណ្តេញប្រជាជនឲ្យចេញពីទីក្រុងមានអ្វីខ្លះ? (ឲ្យហេតុផល ចំនួន៣) :

**១) ខ្មែរក្រហមបានប្រាប់ប្រជាជនថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ ។**

**២) អៀង សារី បានប្រាប់អំពីការខ្វះខាតមធ្យោបាយដឹកជញ្ជូនក្នុងការនាំម្ហូបអាហារមកកាន់ទីក្រុង ។**

**៣) ប៉ុល ពត បាននិយាយថា ការជម្លៀសនេះមានសារសំខាន់ណាស់ ដើម្បីបំបែកក្រុមចារកិច្ចរបស់ខ្មាំង ។**

៩) តើប្រវត្តិវិទូភាគច្រើនយល់ឃើញយ៉ាងដូចម្តេច ចំពោះហេតុផលនៃការជម្លៀសរវាងឆ្នាំ១៩៧៥-១៩៧៦ នេះ? **ខ្មែរក្រហមយល់ឃើញថា ទីក្រុងភ្នំពេញគឺជាកន្លែងដែលអាចបង្កឲ្យមានការកេងប្រវ័ញ្ច និងសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ហើយមានតែកសិករនៅតាមតំបន់ជនបទប៉ុណ្ណោះ ដែលតំណាងឲ្យគោលដៅ និងឧត្តមគតិ**

**របស់បដិវត្តន៍ ។ ខ្មែរក្រហមចង់ប្រែក្លាយប្រទេសជាតិឲ្យទៅជាសង្គមរបស់កសិករនិងកម្មករ ដែលអំពើពុករលួយ សក្តិភូមិនិយម និងមូលធននិយម នឹងត្រូវលុបបំបាត់ចោលទាំងស្រុង ។ ខ្មែរក្រហមមិនមានចំណីអាហារដើម្បីចែកចាយដល់ប្រជាជន ហើយបដិសេធមិនទទួលយកជំនួយបរទេស ។**

១០) តើមេដឹកនាំដែលមានតែឈ្មោះក្នុងរបបខ្មែរក្រហមជានរណា? **សម្តេចព្រះ នរោត្តម សីហនុ ។**

## មេរៀនទី២ : ប្រអប់សង្គ្រោះជីវិត

### វត្ថុបំណង

១) សិស្សសម្តែងចិត្តអាណិតអាសូរចំពោះអ្នកនៅរស់រានមានជីវិតនៃរបបខ្មែរក្រហម ។

២) សិស្សពណ៌នាពីស្ថានភាពរស់នៅក្រោមរបបខ្មែរក្រហម ។

៣) សិស្សរៀបចំគម្រោង និងសម្រេចធ្វើអ្វីដែលខ្លួនចង់ជួយដើម្បីសង្គ្រោះជនរងគ្រោះ ។

៤) សិស្សអនុវត្ត និងពន្យល់ពីជំនាញរបស់ខ្លួនក្នុងការសង្គ្រោះជនរងគ្រោះ ។

**សម្ភារឧបទេស** : សៀវភៅប្រវត្តិសាស្ត្រ ប្រអប់ កាវ កន្ត្រៃ ទស្សនាវដ្តី ក្រដាស ខ្មៅដៃពណ៌ និង ប៊ិចហ្វឺត

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងណែនាំសិស្សឲ្យធ្វើសកម្មភាព ។ គ្រូឲ្យសិស្សប្រើការត្រិះរិះពិចារណារបស់ខ្លួនដើម្បីធ្វើ «ប្រអប់សង្គ្រោះជីវិត» ។ ដោយផ្អែកលើ ចំណេះដឹងរបស់សិស្សពីជីវិតរស់នៅក្រោមរបបខ្មែរក្រហម តើសិស្សអាចរស់នៅ និងនៅមានជីវិតរបៀបម៉េច ប្រសិនបើខ្លួនស្ថិតនៅក្នុងរបបខ្មែរក្រហម និងតើអាចមានប្រអប់មួយដើម្បីដាក់ឧបករណ៍ផ្សេងៗដែរឬទេ?

កំណត់ចំណាំសម្រាប់គ្រូ ៖ សកម្មភាពនេះ តម្រូវឲ្យសិស្សសម្ភាសជាមួយឪពុកម្តាយ ឬសមាជិកគ្រួសាររបស់ខ្លួនដើម្បីសិក្សាពីព័ត៌មានទាំងនេះនៅមុនពេលចាប់ផ្តើមមេរៀន ។ គ្រូអាចប្រាប់សិស្សឲ្យសម្ភាសឪពុកម្តាយ ពីអ្វីដែលគាត់គិតថាគាត់គួរចង់បានអ្វីដើម្បីសង្គ្រោះជីវិត និងចង់បានសម្រាប់គ្រួសារ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សគួរពិចារណាលើចំណុចខាងក្រោមនេះ ៖

អ្នករស់នៅជាមួយឪពុកម្តាយរបស់អ្នកកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ អ្នកនិងគ្រួសារអ្នកត្រូវតែចាកចេញភ្លាមពីផ្ទះឆ្ពោះទៅកាន់ទីជនបទ ។ តើអ្នកគួរតែធ្វើអ្វីខ្លះ? ឬ តើអ្នកគួរព្យាយាមចង់បានអ្វី ដើម្បីសង្គ្រោះខ្លួនអ្នក និងឪពុកម្តាយរបស់អ្នកឲ្យរួចផុតជីវិត?

សិស្សប្រើប្រាស់ឧបករណ៍ដែលគ្រូផ្តល់ឲ្យដើម្បីបង្កើត«ប្រអប់សង្គ្រោះជីវិត»មួយ ។ នៅក្នុងប្រអប់នោះសិស្សត្រូវសរសេរអក្សរ ឬដាក់រូបភាពនៅលើវត្ថុទាំងឡាយដែលអាចជួយទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃរបស់ក្រុមគ្រួសារបាន ដូចជា អង្ករ ក្រណាត់ ស្លាបព្រា ចាន ឆ្នាំង សាច់ បន្លែ ផ្លែឈើ ថ្នាំពេទ្យ ស្បែកជើង សៀវភៅ កាំបិត សំណាញ់បង់ត្រី រូបថត ។ល ។

**សំយោគ (១៥-២៥នាទី)**

សិស្សម្នាក់ៗបង្ហាញ«ប្រអប់សង្គ្រោះជីវិត»របស់ខ្លួនទៅកាន់សិស្សផ្សេងទៀតនៅក្នុងថ្នាក់ រួចពន្យល់ពីមូលហេតុដែលខ្លួនសរសេរអក្សរ ឬដាក់របស់របរផ្សេងៗទៅក្នុងប្រអប់ ។ បន្ទាប់មកគ្រូគួរពន្យល់សិស្សថា គ្រួសារមួយចំនួនមិនមានអ្វីៗច្រើនដែលខ្លួនត្រូវការនោះទេ ហើយជាទូទៅអ្នកទាំងនោះបានបោះបង់របស់ទាំងនោះចោល ។ ប្រជាជនមួយចំនួនមិន

បានដឹងច្បាស់ថា គាត់ត្រូវចាកចេញពីផ្ទះសម្បែងក្នុងរយៈពេលយូរនោះទេ ដូច្នេះហើយ បានជាគាត់មិនបានគិតដល់ថា ត្រូវនាំយករបស់របរទាំងនោះតាមខ្លួនឡើយ ។ ជាការពិត បន្ទាប់ពីសហគមន៍នានាត្រូវបានកែទម្រង់មកជាកម្មសិទ្ធិរួម ខ្មែរក្រហមបានប្រកាសថា នរណាមានរបស់របរប្រើប្រាស់ផ្ទាល់ខ្លួនជាអំពើខុសឆ្គងនឹងមាគ៌ារបស់បក្ស ។ អ្វីៗទាំងអស់ ត្រូវតែជា«របស់រួម»ក្នុងរបបខ្មែរក្រហម ។ ទោះជាយ៉ាងណាក៏ដោយ គ្រួសារ និងប្រជាជនមួយចំនួននៅតែរក្សាលួចលាក់ ទុកនូវរបស់របរ និងចំណីអាហារមួយចំនួនសម្រាប់ខ្លួនឯង និងក្រុមគ្រួសារ ។ ប្រសិនបើអ្នកទាំងនោះត្រូវបានចាប់ខ្លួន ខ្មែរក្រហមនឹងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត ហើយជាញឹកញាប់ត្រូវនាំយកទៅសម្លាប់ចោល ដើម្បីបញ្ឈប់ពីទង្វើដែល ខ្លួនបានប្រព្រឹត្ត ។





***រូបថតខាងលើ*** ៖ *ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ថតដោយ រ៉ូឡង់ នើវើ ។ ប្រភព ៖ ការដួលរលំនៃទីក្រុងភ្នំពេញ ៖ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។* ***រូបថតខាងក្រោម*** ៖ *ស្ត្រីម្នាក់ ធ្វើដំណើរជាមួយកូនរបស់នាង និងឥវ៉ាន់ នៅតាមផ្លូវ អំឡុងពេលជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ។*

# ជំពូក៥ ៖ ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ



*មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។ ពីឆ្វេងទៅស្តាំៈ ប៉ុល ពត (លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ) នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា) អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស) សុន សេន (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារ ជាតិ) និង វន វ៉េត (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច) ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

## មេរៀនទី១ ៖ អំណានជំពូក៤ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### *វត្ថុបំណង*

១) សិស្សកំណត់នូវព្រឹត្តិការណ៍សំខាន់ៗ នៃការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សកំណត់និយមន័យនៃពាក្យ និងឈ្មោះសំខាន់ៗ ។

៣) សិស្សវិភាគភ្លេងជាតិ ដើម្បីយល់កាន់តែច្បាស់ថែមទៀតអំពីមនោគមន៍វិជ្ជារបស់ខ្មែរក្រហម ។

៤) សិស្សសំយោគអ្វីដែលខ្លួនបានរៀន ដោយឆ្លើយនឹងសំណួរណែនាំ ។

***សម្ភារឧបទេស*** ៖ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅលំហាត់ និងភ្លេងជាតិកម្ពុជាប្រជាធិបតេយ្យ ។

***ពន្យល់ពាក្យ និង ឈ្មោះសំខាន់ៗ*** ៖

| | | |
|---|---|---|
| អង្គការ | តាម៉ុក | ញឹម រស់ |
| កែ ពក | សោ ភឹម | រដ្ឋធម្មនុញ្ញ |
| វន វ៉េត | សុន សេន | ភ្លេងជាតិ |

## ភ្លេងជាតិកម្ពុជាប្រជាធិបតេយ្យ : ១៧ មេសា មហាជោគជ័យ

*ឈាមក្រហមច្រាល ស្រោចស្រពក្រុងវាលកម្ពុជា មាតុភូមិ ឈាមកម្មករ*
*កសិករដ៏ឧត្តម ឈាមយុទ្ធជន យុទ្ធនារីបដិវត្តន៍ ។*

*ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លា តស៊ូមោះមុត ១៧មេសា*
*ក្រោមទង់បដិវត្តន៍ ឈាមរំដោះផុត ពីភាពខ្ញុំគេ ។*

*ជយោ! ជយោ! ១៧មេសាជោគជ័យ*
*មហាអស្ចារ្យ មានន័យធំធេងលើសសម័យអង្គរ ។*

*យើងរួបរួមគ្នា កសាងកម្ពុជានិង សង្គមថ្មីបវរ ប្រជាធិបតេយ្យ*
*សមភាព និងយុត្តិធម៌ តាមមាគ៌ា ម្ចាស់ការឯករាជ្យ រឹងមាំ ប្ដេជ្ញាដាច់ខាត*
*ការពារជាតិមាតុភូមិ ទឹកដីឧត្តម បដិវត្តន៍រុងរឿង ។*

*ជយោ! ជយោ! ជយោ កម្ពុជាថ្មី ប្រជាធិបតេយ្យ សម្បូរថ្កុំថ្កើង*
*ប្ដេជ្ញាជ្រោងគ្រវីទង់បដិវត្តន៍ក្រហមខ្ពស់ឡើង សាងមាតុភូមិយើងឲ្យចម្រើនលោតផ្លោះ*
*មហារុងរឿង មហាអស្ចារ្យ ។*

### លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងពិភាក្សាអំពីអ្វីដែលសិស្សបានដឹងរួចហើយក្នុងការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក គ្រូឲ្យសិស្សពិភាក្សាពាក្យ និងឈ្មោះសំខាន់ៗ នៅក្នុងជំពូក៤នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងឲ្យសិស្សប្រើជំនាញក្នុងការគិតរបស់ខ្លួន ហើយវិភាគភ្លេងជាតិ ដើម្បីឲ្យយល់កាន់តែច្បាស់ថែមទៀតអំពីមនោគមន៍វិជ្ជារបស់ខ្មែរក្រហម ។ គ្រូឲ្យសិស្សពិភាក្សាសំណួរខាងក្រោម :

១) ហេតុអ្វីបានជាពាក្យ "ឈាម" ត្រូវបានលើកឡើងច្រើនដង?

២) ហេតុអ្វីបានជាភ្លេងជាតិសំដៅទៅពាក្យ "អង្គរ"?

៣) តើភ្លេងជាតិនេះ ឬភ្លេងជាតិដទៃទៀត មានគោលបំណងអ្វី?

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអានដោយយកចិត្តទុកដាក់ និងកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជំពូក៤ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ សិស្សសរសេរព្រឹត្តិកាណ៍ទាំងនេះ នៅក្នុងសៀវភៅលំហាត់ ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសរុបការសិក្សារបស់សិស្ស ។

*សំណួរណែនាំ និងចម្លើយ ៖*

១) តើអ្នកណាខ្លះជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា នៅខែកញ្ញាឆ្នាំ១៩៧៥? **ប៉ុល ពត, នួន ជា, សោ ភឹម, អៀង សារី, សុន សេន, តាម៉ុក និង វន វេត ។**

២) តើអ្នកណាខ្លះចូលជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧៧? (ឲ្យឈ្មោះចំនួន៣នាក់) **ញឹម រស់, ខៀវ សំផន, និង កែ ពក ។**

៣) នៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ យាងចូលមកប្រទេសកម្ពុជាវិញនៅដើមខែកញ្ញា ឆ្នាំ១៩៧៥ តើព្រះអង្គមានតួនាទីអ្វីខ្លះ? តើតួនាទីនេះមានអំណាចត្រឹមណាខ្លះ? **ព្រះអង្គត្រូវបានប្រគល់តំណែងជាប្រមុខរដ្ឋ ប៉ុន្តែមិនមានអំណាចអ្វីទាំងអស់ ។**

៤) តើមានអ្វីកើតឡើងខ្លះចំពោះរាជវង្សានុវង្សរបស់សម្តេចព្រះ នរោត្តម សីហនុ នៅក្រោមរបបខ្មែរក្រហម? **រាជវង្សានុវង្សប្រមាណ២០អង្គបានសុគត ហើយយ៉ាងហោចណាស់ក៏មានរាជវង្សានុវង្សចំនួន៧អង្គផ្សេងទៀត ត្រូវបានផ្ញើគុតនៅគុកទួលស្លែង ។**

៥) រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រូវបានប្រកាសនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ។ រដ្ឋធម្មនុញ្ញនេះ បានបង្កើតសភាតំណាងប្រជាជនមួយចំនួនមាន២៥០អាសនៈ ដែលតំណាងឲ្យក្រុមណាខ្លះ? **១៥០រូបតំណាងឲ្យវណ្ណៈកសិករ ៥០រូបតំណាងឲ្យវណ្ណៈកម្មករនិងពលករ និង៥០រូបទៀតតំណាងឲ្យកងទ័ពបដិវត្តន៍កម្ពុជា ។**

៦) តើផ្ទៃពណ៌ក្រហម និងប្រាសាទពណ៌លឿងចំកណ្តាលទង់ជាតិកម្ពុជាប្រជាធិបតេយ្យតំណាងឲ្យអ្វី? **ផ្ទៃពណ៌ក្រហមជានិមិត្តរូបនៃចលនាបដិវត្តន៍ ការប្រយុទ្ធមោះមុតអង់អាចក្លាហានក្នុងការរំដោះជាតិ ការពារជាតិ និងកសាងជាតិកម្ពុជាជារបស់ប្រជាជន ។ ប្រាសាទពណ៌លឿងចំកណ្តាលជានិមិត្តរូបនៃប្រពៃណីជាតិ និងប្រជាជនកម្ពុជា ដែលជាអ្នកការពារប្រទេស ជាអ្នកស្ថាបនាប្រទេសឲ្យកាន់តែថ្កុំថ្កើងរុងរឿង ។**

៧) នៅលើសញ្ញាជាតិ តើប្រព័ន្ធស្រែនិងប្រឡាយតំណាងឲ្យអ្វី? **ប្រព័ន្ធទាំងនេះតំណាងឲ្យកសិកម្មជឿនលឿន ។**

៨) តើគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា បានជួបប្រជុំគ្នាដើម្បីពិភាក្សាពីការសុំលាលែងចេញពីតំណែងរបស់សម្តេចព្រះ នរោត្តម សីហនុ នៅពេលណា? **នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ។**

៩) តើប្រមុខរដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ១៩៧៦ជានរណា? **ខៀវ សំផន ។**

១០) តើប្រធានសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យជានរណា? **នួន ជា ។**

១១) តើនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យជានរណា? **ប៉ុល ពត ។**

១២) តើឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសជានរណា? **អៀង សារី ។**

១៣) តើឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជានរណា? **វន វេត ។**

១៤) តើឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិជានរណា? **សុន សេន ។**

១៥) តើថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាគោរពរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែរឬទេ? **ថ្នាក់ដឹកនាំទាំងនោះមិនបានគោរពរដ្ឋធម្មនុញ្ញទេ ។**

១៦) ហេតុអ្វីបានជាគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាសម្រេចយកឆ្នាំ១៩៦០ មិនយកឆ្នាំ១៩៥១ ជាឆ្នាំកំណើតបក្ស? **គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា បានសម្រេចថា អ្នកណាដែលចូលបក្សមុនឆ្នាំ១៩៦០ នឹងមិនត្រូវចាត់ទុកជាសមាជិកបក្សទៀតទេ ។ គណៈកម្មាធិការមជ្ឈិមនៃបក្ស**

***កុម្មុយនីស្តកម្ពុជា មិនចង់ទទួលស្គាល់សារសំខាន់នៃការជួយជ្រោមជ្រែងរបស់វៀតណាមមុនឆ្នាំ១៩៦០ និងចង់បដិសេធចោលឥទ្ធិពលរបស់វៀតណាមមកលើបក្ស និងកាត់ផ្តាច់ទំនាក់ទំនងទាំងអស់ជាមួយវៀតណាម ។***

## មេរៀនទី២ ៖ ពិនិត្យមើលក្រុមមេដឹកនាំខ្មែរក្រហម

### វត្ថុបំណង

១) សិស្សពណ៌នាពីតួនាទីរបស់មេដឹកនាំខ្មែរក្រហមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សកំណត់ឈ្មោះមេដឹកនាំខ្មែរក្រហមសំខាន់ៗ ។

៣) សិស្សពន្យល់បរិបទប្រវត្តិសាស្ត្រ និងសង្គម ដែលកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ។

៤) សិស្សបង្កើតតារាងនៃមេដឹកនាំខ្មែរក្រហម ដោយបញ្ជាក់ពីឈ្មោះ ប្រវត្តិរបស់មេដឹកនាំ តំណែង និងការទទួលខុសត្រូវ ។



មេដឹកនាំខ្មែរក្រហមពីឆ្វេងទៅស្តាំ និងពីលើចុះក្រោម ៖ ប៉ុល ពត, កាំង ហ្កេចអ៊ាវ (ឌុច), អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន និង អៀង សារី ។ ប៉ុល ពត ស្លាប់នៅឆ្នាំ១៩៩៨ ។ នៅឆ្នាំ២០១២ ឌុច ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ សម្លាប់ និងធ្វើទណ្ឌកម្មក្នុងអំឡុងពេលធ្វើជាប្រធានមន្ទីរសន្តិសុខ ស-២១ ។ ឌុច ត្រូវបានកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត ។ នួន ជា អៀង ធីរិទ្ធ ខៀវ សំផន និង អៀង សារី គឺជាចុងចោទនៅក្នុងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទោះជាយ៉ាងនេះក៏ដោយ អៀង ធីរិទ្ធ ត្រូវតុលាការដោះលែងឲ្យនៅក្រៅឃុំ ដោយសារមានបញ្ហាផ្នែកសុខភាព ដែលមិនអាចប្រឈមនឹងការកាត់ទោសបាន ។ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ដោយជំងឺប្រចាំកាយ នៅខេត្តប៉ៃលិន ។ ប្តីរបស់ អៀង ធីរិទ្ធ គឺ អៀង សារី ត្រូវបានចោទប្រកាន់ពីបទបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទីបំផុត អៀង សារី បានស្លាប់ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ មុនពេលដែលសំណុំរឿងរបស់គាត់ត្រូវបានកាត់ក្តី ។ នួន ជា និង ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម ។ នួន ជា ក៏ត្រូវបានចោទប្រកាន់បន្ថែមពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ចាប់តាំងពីការបោះពុម្ពសៀវភៅនេះដំបូង មេដឹកនាំកំពូលៗទាំងនេះ កំពុងរង់ចាំការកាត់ក្តីនៅក្នុងសំណុំរឿង០០២/០១ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅលំហាត់ និងរូបថតរបស់មេដឹកនាំខ្មែរក្រហម ។

**លំនាំបង្រៀន**

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងរំឭកជំពូក៤ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឡើងវិញ ។

*ការបង្រៀន (១៥-៤៥នាទី)*

គ្រូប្រើប្រាស់សៀវភៅលំហាត់ដើម្បីកំណត់ឈ្មោះ តំណែង តួនាទី និងប្រវត្តិរបស់មេដឹកនាំខ្មែរក្រហម ។

*សំយោគ (១៥-២៥នាទី)*

សិស្សបង្ហាញពីតារាងកំណត់មេដឹកនាំខ្មែរក្រហមទាំងអស់ទៅកាន់សិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។





**រូបខាងលើ** ៖ ក្រុមអ្នកប្រយុទ្ធខ្មែរក្រហមអនុញ្ញាតឲ្យអ្នកថតរូប រ៉ូឡង់ ណឺវើ ឡើងលើរថយន្ត ។ លោក រ៉ូឡង់ ណឺវើ បានអះអាងថា ក្រុមអ្នកប្រយុទ្ធទាំងនេះ បានសម្រាកនៅជាយក្រុងភ្នំពេញ និងមិនបានផ្ញូតទឹកពីរ-បីថ្ងៃមកហើយមុននឹងចូលមកទីក្រុងភ្នំពេញ ។ **រូបខាងក្រោម** ៖ នៅថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញ បានធ្លាក់ក្នុងកណ្ដាប់ដៃរបស់ខ្មែរក្រហម ដោយពុំមានការប្រយុទ្ធខ្លាំងក្លាទេ ។ ក្រុមខ្មែរក្រហម ធ្វើដំណើរចូលទីក្រុងភ្នំពេញគ្រប់ច្រកទាំងអស់ ។ រូបថត ៖ រ៉ូឡង់ ណឺវើ ។ ប្រភព ៖ ការធ្លាក់ចុះនៃទីក្រុងភ្នំពេញ ៖ ១៧ មេសា ១៩៧៥ ។

# ជំពូក៦ ៖ ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ




*ផែនទីភូមិភាគ និងតំបន់របស់កម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦ ។ ប្រភពផែនទី ៖ ក្រសួងអប់រំកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៧ ។ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

## មេរៀនទី១ : អំណានជំពូក៥ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### វត្ថុបំណង

១) សិស្សរៀបរាប់ពីការបែងចែកតំបន់រដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សប្រៀបធៀបពីភាពខុសគ្នារវាងភូមិភាគនីមួយៗ និងមូលហេតុដែលភូមិភាគទាំងនេះត្រូវបានបែងចែក ។

៣) សិស្សកំណត់និយមន័យនៃពាក្យសំខាន់ៗមួយចំនួន ។

៤) សិស្សសំយោគការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

**សម្ភារឧបទេស :** សៀវភៅប្រវត្តិសាស្ត្រ ផែនទីកម្ពុជាប្រជាធិបតេយ្យ និងសៀវភៅលំហាត់ ។

**ពន្យល់ពាក្យ និង ឈ្មោះសំខាន់ៗ :**

| | | |
|---|---|---|
| ស្រុក | ឃុំ | ភូមិភាគកណ្តាល |
| សហករណ៍ | ភូមិភាគបូព៌ា | ភូមិភាគឦសាន |
| ភូមិភាគឧត្តរ | ភូមិភាគពាយ័ព្យ | ស្វយ័ត |
| ភូមិភាគនិរតី | ភូមិភាគបស្ចិម | |

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូឲ្យសិស្សពិភាក្សា ថាតើសិស្សបានដឹងអ្វីខ្លះអំពីការបែងចែកភូមិសាស្ត្ររដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកគ្រូឲ្យសិស្សពិភាក្សាពាក្យសំខាន់ៗនៅក្នុងជំពូក៥ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអាន និងកត់ត្រាព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជំពូក៥ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយយកចិត្តទុកដាក់ ។ សិស្សសរសេរនៅក្នុងសៀវភៅលំហាត់ ដើម្បីបង្ហាញពីការសិក្សារបស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សនៅក្នុងថ្នាក់ទាំងអស់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) តើភូមិភាគដែលត្រូវបានបង្កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានប៉ុន្មាន? **៦ភូមិភាគ ។**

២) តើភូមិភាគទាំងអស់ត្រូវបានបែងចែកទៅជាប៉ុន្មានតំបន់? **៣២តំបន់ ។**

៣) តើលេខាភូមិភាគបូព៌ារហូតដល់ឆ្នាំ១៩៧៨ជាអ្នកណា? **សោ ភឹម ។**

៤) តើលេខាភូមិភាគនិរតីជាអ្នកណា? **ឈិត ជឿន ហៅ តាម៉ុក ។**

៥) តើលេខាភូមិភាគឧត្តរពីឆ្នាំ១៩៧០-១៩៧៦ ជាអ្នកណា? **កុយ ធួន ហៅ ធុច ។**

៦) តើលេខាភូមិភាគឧត្តរពីឆ្នាំ១៩៧៦-១៩៧៧ ជាអ្នកណា? **កែ ពក ។**

៧) តើលេខាភូមិភាគឧត្តរចាប់ពីឆ្នាំ១៩៧៧ ជាអ្នកណា? **កង ចាប ។**

៨) តើលេខាភូមិភាគពាយ័ព្យជាអ្នកណា? **ញឹម រស់ ។**

៩) តើលេខាភូមិភាគបស្ចិមជាអ្នកណា? **ជូ ជេត ។**

១០) តើលេខាភូមិភាគឦសានរហូតដល់ឆ្នាំ១៩៧៦ជាអ្នកណា? **ណៃ សារ៉ាន់ ហៅ យ៉ា ។**

## មេរៀនទី២ ៖ ការសម្ដែងតួ «ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម»

### វត្ថុបំណង

១) សិស្សសម្ដែងតួដោយប្រើអត្ថបទសម្ភាសន៍របស់ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។

២) សិស្សសម្ដែងចិត្តអាណិតអាសូរអ្នកដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សពិនិត្យមើល និងពិចារណាអំពីឥរិយាបថ និងជំនឿរបស់ប្រជាជននៅក្នុងបរិបទនៃជីវិតក្រោមរបបខ្មែរក្រហម ។

៤) សិស្សកត់ត្រា និងសរសេរកថាខណ្ឌពីការសម្ដែងតួ ។

**សម្ភារទេសទេស** ៖ សៀវភៅលំហាត់ គំរូអត្ថបទសម្ភាសន៍របស់ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។

### លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ បន្ទាប់មកគ្រូពន្យល់ពីកិច្ចការដែលសិស្សត្រូវធ្វើ និងជ្រើសរើសសិស្សឲ្យសម្ដែងតួជាជនរងគ្រោះម្នាក់ដែលត្រូវបានកំណត់ថាជា "ប្រជាជនថ្មី" ឬជាកម្មាភិបាលខ្មែរក្រហម ។ សិស្សកត់ត្រាពីការសម្ដែងតួ ហើយសរសេរកថាខណ្ឌមួយ ។

*ការបង្រៀន (៣០ - ៤៥ នាទី)*

គ្រូឲ្យសិស្សសម្ដែងតួទៅលើសក្ខីកម្មខាងក្រោម ។ សិស្សទាំងអស់ត្រូវសរសេរសេចក្ដីសង្ខេបមួយអំពីថាតើជីវិតរស់នៅមានលក្ខណៈដូចម្ដេចខ្លះនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ គ្រូអាចជ្រើសរើសការឡើងសម្ដែងតួទៅលើសក្ខីកម្មមួយ ច្រើន ឬក៏ទាំងអស់អាស្រ័យទៅលើពេលវេលា ។

### សេចក្ដីណែនាំចំពោះអ្នកសម្ដែងតួ

១) មិនត្រូវផ្ដល់គំនិតផ្ទាល់ខ្លួនអំពីមនុស្សនៅក្នុងសក្ខីកម្ម ។ អ្នកត្រូវតែមានភាពមិនលម្អៀង និងអព្យាក្រឹតឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ។ ប្រសិនបើអ្នកមានការខឹងសម្បារចំពោះមនុស្សម្នាក់នោះ ព្យាយាមកុំនិយាយចេញមក ។

២) សិក្សាអំពីមនុស្សម្នាក់នោះ ។ ព្យាយាមយល់ថា តើគាត់គិតពីអ្វី? តើប្រវត្តិរូប និងប្រវត្តិនៃការសិក្សារបស់គាត់ដូចម្ដេចខ្លះ? ហេតុអ្វីបានជាគាត់និយាយដូច្នេះ? កាតព្វកិច្ចរបស់អ្នកគឺត្រូវវិភាគទៅលើសម្ដីរបស់គាត់ ហើយពន្យល់ប្រាប់មិត្តភក្ដិរបស់អ្នកឲ្យបានច្រើនតាមតែអាចធ្វើទៅបានអំពីមនុស្សម្នាក់នោះ និងបទពិសោធន៍របស់គាត់ ។

៣) ដើម្បីបញ្ជាក់ម្ដងទៀតអំពីគោលការណ៍ទី១ ព្យាយាមកុំធ្វើការវិនិច្ឆ័យទៅលើមនុស្សម្នាក់នោះ ។ អ្នកអាចមានអារម្មណ៍ខឹងនឹងមនុស្សម្នាក់នោះ ប៉ុន្តែព្យាយាមកុំបង្ហាញអារម្មណ៍នោះចេញមកក្រៅក្នុងពេលអ្នកឡើងបង្ហាញ ។ គោលបំណងគឺដើម្បីស្វែងយល់អំពីមូលហេតុនិងស្ថានភាព ដែលនាំឲ្យមនុស្សម្នាក់នោះមាន អាកប្បកិរិយាដូចដែលគាត់បានធ្វើ និងអំពីរបៀបថាតើមនុស្សម្នាក់ផ្សេងទៀតអាចបញ្ចេញអាកប្បកិរិយាដូចគ្នានៅក្នុងស្ថានភាពដូចគ្នាដែរឬទេ ។



***រូបខាងលើ*** *៖ បុគ្គលិកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសម្ភាសអ្នកភូមិដែលរួចរស់ជីវិតពីសម័យខ្មែរក្រហម នៅក្នុងខេត្តស្ទឹងត្រែង នៅឆ្នាំ ២០០៥ ។ រូបថត ៖ ផាត ពិសិទ្ធ ។* ***រូបខាងក្រោម*** *៖ អតីតកម្មាភិបាលខ្មែរក្រហមម្នាក់កំពុងបណ្តើរគោនៅស្រុកម៉ាឡៃ ដែលជាអតីតតំបន់ខ្មែរក្រហម ។ រូបថត ៖ ហេង ស៊ីនិត ។*



ខាងក្រោមគឺជាសំណួរណែនាំមួយចំនួនសម្រាប់ការពិភាក្សានៅក្នុងថ្នាក់ ៖

១) តើគាត់មានបទពិសោធន៍អ្វីខ្លះ នៅក្នុងរយៈកាលនៃរបបខ្មែរក្រហម? តើគាត់ធ្វើអ្វីខ្លះជារៀងរាល់ថ្ងៃនៅក្នុងរបបខ្មែរក្រហម?

២) តើបទពិសោធន៍របស់គាត់មានផលប៉ះពាល់អ្វីខ្លះមកលើខ្លួនគាត់?

៣) តើបទពិសោធន៍របស់គាត់មានផលប៉ះពាល់អ្វីទៅលើអ្នកដទៃដែរឬទេ ហើយប៉ះពាល់ដោយរបៀបណា?

៤) ផ្អែកលើលំហាត់នៃការសម្ដែងតួ តើអ្វីខ្លះទៀតដែលអ្នកគិតថា ជាការពិតទាក់ទងនឹងគាត់ ការសិក្សារបស់គាត់ និងអត្តចរិតរបស់គាត់?

៥) តើគាត់ធ្វើអ្វី នៅក្នុងស្ថានការណ៍ដែលគាត់បានពណ៌នា?

## សក្ខីកម្មទី១



យ៉ាន់ ឈីម អាយុ៥២ឆ្នាំ ជាស្ត្រីមេម៉ាយមានកូនស្រី៣នាក់ រស់នៅភូមិត្រពាំងស្កុក ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ប្រកបរបរធ្វើស្រែ និងត្បាញហូលផាមួង ។ ប្តីរបស់គាត់ឈ្មោះ មាស ប៉ា ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅក្នុងឆ្នាំ១៩៧៧ ។

ស្រុកកំណើតរបស់ ឈីម បានក្លាយជាតំបន់រំដោះតាំងពីឆ្នាំ១៩៧២ ។ ឈីម បានឲ្យដឹងថា កាលពីដំបូង ប្រជាជន១៧មេសា ដែលបានមកដល់ស្រុកកោះធំមានចំនួនច្រើនដែរ ប៉ុន្តែបន្ទាប់ពីស្នាក់នៅបានមួយរយៈពេលខ្លី អង្គការក៏ជម្លៀសអ្នកទាំងនោះឲ្យទៅនៅខេត្តបាត់ដំបងវិញ ។

នៅឆ្នាំ១៩៧៥ ស្រុកកោះធំមិនទាន់បង្កើតសហករណ៍នៅឡើយទេ ប្រជាជននៅហូបបាយតាមផ្ទះរៀងៗខ្លួននៅឡើយ ។ ឈីម និយាយទៀត ថាការហូបចុករវាងអ្នកថ្មី (អ្នក១៧មេសា) និងអ្នកមូលដ្ឋានមិនស្មើគ្នាទេ ។ ប្រជាជនមូលដ្ឋានមានស្រូវអង្ករដែលជាកម្មសិទ្ធិរបស់ខ្លួនឯង ចំណែកប្រជាជនថ្មីត្រូវរង់ចាំរបបដ៏តិចតួចស្តួចស្តើងដែលអង្គការចែកឲ្យ ។

នៅឆ្នាំ១៩៧៦ រដ្ឋអំណាចស្រុកកោះធំបានចាប់ផ្តើមរៀបចំបង្កើតសហករណ៍ ។ ប្រជាជនត្រូវបែងចែកជាបីកង ។ កងទី១ ហៅថា "កងពេញសិទ្ធិ" គឺប្រជាជនដែលជាអតីតកសិករមូលដ្ឋាន ក្រីក្រ បាតដៃទទេ គ្មានទ្រព្យសម្បត្តិ គ្មានកម្មសិទ្ធិដីស្រែចម្ការ ។ ប្រជាជនដែលនៅក្នុងកងនេះមានតួនាទីធ្វើជាប្រធានកង ប្រធានក្រុមក្តោបក្តាប់កងពីរផ្សេងទៀត ។ ប្រជាជនក្នុងកងនេះធ្វើតែការងារស្រាលៗដូចជា ដើរបេះបន្លែដេញចាបជាដើម ។ កងទី២ ហៅថា "កងត្រៀម" គឺជាអតីតប្រជាជនមូលដ្ឋានដែរ ប៉ុន្តែមានជីវភាពខ្ពស់បន្តួរ មានទ្រព្យសម្បត្តិ មានកម្មសិទ្ធិដីស្រែចម្ការ ។ ចំណែកការងារមិនសូវជាលំបាកប៉ុន្មានទេ ។ កងទី៣ហៅថា "កងផ្ញើ" ។ ប្រជាជននៅក្នុងកងផ្ញើនេះ ជាប្រជាជន ១៧មេសា សុទ្ធសាធ ។ ក្នុងចំណោមកងទាំងបីខាងលើ កងទី៣ធ្វើការយ៉ាប់យ៉ឺនបំផុត ហើយការហូបចុក ក៏ខ្វះខាតបំផុតដែរ ។ ឈីម ស្ថិតនៅក្នុងកងទី៣ (កងផ្ញើ) ។ គាត់ត្រូវធ្វើការងារជាច្រើន និងគ្មានរបបហូបចុកគ្រប់គ្រាន់ បណ្តាលឲ្យរាងកាយចុះស្គម ។ ឈីម មានខោអាវតែមួយចង្កេះផ្ទេះជាប់នឹងខ្លួន ពេលចុះធ្វើការទទឹកខ្លួនជោក ដល់ពេលឈប់សម្រាកគាត់ពាក់អាវទទឹកដដែលនេះរហូត

ដល់ស្លូតវិញ ។

ក្នុងឆ្នាំ១៩៧៦នេះ ឈីម មានផ្ទៃពោះ ហើយសម្រាលបានកូនស្រីម្នាក់ ។ ប្រធានកងបានអនុញ្ញាតឲ្យ ឈីម ឈប់សម្រាករយៈពេល២០ថ្ងៃ បន្ទាប់មកត្រូវចុះទៅធ្វើការវិញ ។ ឆ្នាំនោះជាឆ្នាំរាំង ទឹកធំ ផ្លូវមួយចំនួនត្រូវទឹកលិចដោយអន្លើៗ ។ ឈីម ត្រូវដើរកាត់ទឹកត្រឹមដើមទ្រូងទៅមកៗជាច្រើនសាដើម្បីចម្ពងកូនតូចៗទាំង៣ ។ បន្ទាប់ពីយកកូនៗទៅដាក់នៅមណ្ឌលកុមារអស់ហើយ ទើប ឈីម ទៅធ្វើការនៅក្នុងអង្គភាពរបស់គាត់ដោយដើរផងរត់ផងឲ្យទាន់ពេលវេលា ។ ពេលល្ងាច អ្នកមូលដ្ឋានទៅយកកូនចៅមកផ្ទះវិញស្ងាត់ឈឹងអស់ នៅសល់តែកូនរបស់ ឈីម ដែលត្រូវមូសរោមខាំពេញខ្លួន ពីព្រោះទម្រាំគាត់ត្រឡប់មកពីធ្វើការគឺព្រលប់ទៅហើយ ។ ថ្ងៃមួយ ពេលកូនរបស់គាត់ឈឺ ឈីម បានសុំមេកងទៅមើលកូននៅឯផ្ទះ មេកងបានចំអកឲ្យគាត់វិញថា “មិត្តឯងពេទ្យឬ?” ។ ទោះបីជាមេកងចំអកឡកឡាយឲ្យគាត់យ៉ាងណាក៏ដោយ ក៏ ឈីម នៅតែទទូចអង្វរករហូតដល់មេកងយល់ព្រមឲ្យមកមើលកូននៅចន្លោះម៉ោងពេលឈប់សម្រាកថ្ងៃត្រង់ ប៉ុន្តែបានដាក់កម្រិតឲ្យគាត់ត្រឡប់ទៅធ្វើការវិញឲ្យទាន់ពេលវេលា ។ បានការអនុញ្ញាតពីមេកង ហើយ ឈីម មិនរវេរវល់បាយទឹកឡើយ ។ គាត់ដើរផងរត់ផងមកផ្ទះដែលមានចម្ងាយផ្លូវបួនប្រាំគីឡូម៉ែត្រ ។ នៅពេលឃើញមុខម្តាយ កូនរបស់ ឈីម ដើរឆ្លេឆ្លាចុះឡើងៗនៅលើផ្ទះដោយគ្រេកអរពេក មិនបានប្រយ័ត្នក៏ធ្លាក់មកដីបែកក្បាលចេញឈាមរហូតដល់សន្លប់ ។ ឈីម រន្ធត់ជាខ្លាំង យំបណ្តើរស្រែកហៅអ្នកជិតខាងឲ្យជួយកូនបណ្តើរ ។ ភ្លាមៗនោះ អ្នកមូលដ្ឋានដែលនៅផ្ទះជិតខាងគ្នាបានយកថ្នាំមកជួយលាបរីត រហូតកូនគាត់បានដឹងខ្លួនឡើងវិញ ។ អ្នកមូលដ្ឋានមួយចំនួនបានប្រើសម្តីចំអកឲ្យ ឈីម ថា “ហ្នឹងហើយជ្រួលជ្រើមៗមករកកូនទាល់តែកូនធ្លាក់ពីលើផ្ទះរហូតដល់សន្លប់បែបនេះ” ។ ឈីម ឈឺចាប់ក្នុងចិត្តណាស់ ប៉ុន្តែគាត់នៅស្ងៀមមិនតបតឡើយ ។ ពេលនាំកូនទៅដាក់លើផ្ទះហើយ ឈីម រូតរះវិលត្រឡប់ទៅធ្វើការវិញភ្លាមឲ្យទាន់ពេលកំណត់ ។

កូនស្រីទីពីររបស់ ឈីម មានជំងឺគ្រុនក្តៅ កម្មាភិបាលពេទ្យខ្មែរក្រហមបានឲ្យថ្នាំគ្រាប់ពណ៌ខ្មៅៗមកលេប ។ ឈីម រៀបរាប់ថា “ឈឺពោះក៏ឲ្យលេបថ្នាំហ្នឹង ឈឺក្បាលក៏លេបថ្នាំហ្នឹង គ្រុនចាញ់ក៏លេបថ្នាំហ្នឹងដែរ” ។ ដោយសារថ្នាំខ្មៅៗនោះមិនមានប្រសិទ្ធភាព កូនរបស់ ឈីម ក្តៅខ្លួនខ្លាំងឡើងៗរហូតប្រកាច់សរសៃបណ្តាលឲ្យខូចជើងម្ខាង ។ ពេលយប់ ឈីម និងប្តីបានលួចពកូនដើរសសៀរតាមដងទន្លេទៅរកគ្រូពេទ្យម្នាក់ឈ្មោះ ប៊ូ ខេង ដែលគាត់ធ្លាប់ស្គាល់ពីមុនឲ្យជួយព្យាបាល ។ គ្រូពេទ្យនោះបានយកថ្នាំដែលគាត់នៅមានសេសសល់មកចាក់ឲ្យកូនស្រី ឈីម រហូតបានជាសះស្បើយឡើងវិញ ប៉ុន្តែជើងម្ខាងនៅស្វិតបន្តិចដើរមិនដូចប្រក្រតី ។ ឈីម បន្តទៀតថា “ពេលកូនខ្ញុំឈឺ ខ្ញុំខំដើរទៅរើសសន្ទុំពោតដែលសេសសល់ក្នុងចម្ការបាន២-៣គីឡូក្រាម ដើម្បីដោះដូរត្រីសាច់យកមកឲ្យកូនហូប ប៉ុន្តែអ្នកមូលដ្ឋានមិនព្រមដូរឲ្យទេ ថែមទាំងស្តីឲ្យខ្ញុំថា “មិត្តឯងមកស៊ីដោយសារគេ ហេតុអីហ៊ានយកពោតទៅដូរត្រី? មិត្តឯងអីក៏ហ៊ានម្ល៉េះ? មិត្តឯងឲ្យដឹងខ្លួនខ្លះផងគេខំរំដោះម៉ោ” ។ “ទោះបីជាត្រូវប្រមាថមើលងាយយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនដែលតបតនឹងគេវិញដែរ ចៀសវាងកុំឲ្យកើតមានរឿង” ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ប្តីរបស់ ឈីម ត្រូវខ្មែរក្រហមយកទៅសម្លាប់ ដោយគាត់មិនបានដឹងទាល់តែសោះ ។ ឈីម និយាយទាំងអួលណែនដើមកថា “ក្នុងឆ្នាំនោះ ប្តីរបស់ខ្ញុំត្រូវគេឲ្យទៅធ្វើការនៅកងផ្សេង ។ កងនោះគេដាក់សុទ្ធតែអ្នកថ្មី (អ្នក១៧មេសា) ។ ប្តីប្រពន្ធខ្ញុំបានឃើញមុខគ្នាតែនៅថ្ងៃដែលអង្គការរៀបចំធ្វើសន្និបាតក្នុងរវាងថ្ងៃ១០ ឬថ្ងៃ២០ម្តងប៉ុណ្ណោះ ។ ពេលធ្វើសន្និបាតម្តងៗ ប្រជាជនទាំងអស់ត្រូវអង្គការដាក់កំហិតឲ្យទៅចូលរួមប្រជុំ ។ អ្នកទៅចូលរួម

ប្រជុំត្រូវអង្គុយតាមក្រុមជាជួរៗ ។ អ្នកថ្មីអង្គុយមួយក្រុម អ្នកមូលដ្ឋានអង្គុយមួយក្រុម កងបុរសអង្គុយផ្សេង កងនារីអង្គុយផ្សេង ។ ប្ដីខ្ញុំនៅក្នុងកងបុរស១៧មេសា ។ កងនេះតែងតែបាត់សមាជិកម្នាក់ឬពីរនាក់ ជារៀងរាល់យប់ ។ រាល់ពេលប្រជុំខ្ញុំតែងលួចសម្លឹងរកមើលប្ដីជានិច្ច ។ ពេលឃើញមុខប្ដី ខ្ញុំលួចត្រេកអរក្នុងចិត្តថា ប្ដីអញនៅរស់ទេ ។ ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧ ប្រជាជនមូលដ្ឋានដែលអាណិតស្រឡាញ់រាប់អានខ្ញុំ បានមកប្រាប់ខ្ញុំថា «មិត្ត ឈីម មិត្តឯងអត់ដឹងទេ ប្ដីមិត្តឯងគេយកទៅបាត់ហើយ» ។ គ្រាន់តែឮប៉ុណ្ណឹង ខ្ញុំចង់សន្លប់ ភ្លេចបាយភ្លេចទឹក អង្គុយបង្ហូរទឹកភ្នែកតែម្នាក់ឯង ។

ខ្ញុំមិនដឹងថា ថ្ងៃណាដល់វេនខ្ញុំត្រូវស្លាប់ទេ ព្រោះជាធម្មតាឲ្យតែយកប្ដីទៅសម្លាប់ចោលហើយ មិនយូរមិនឆាប់គេច្បាស់ជាយកប្រពន្ធទៅសម្លាប់ដែរ ។» ចាប់តាំងពីពេលនោះមក ឈីម ខំប្រឹងប្រែងធ្វើការទ្វេឡើងទៀត ដើម្បីជីវិតរស់ និងដើម្បីអនាគតកូនៗ ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ឈីម ក៏បាននាំកូនស្រីទាំងបីចាកចេញពីស្រុកកោះធំ ដែលជាទីកន្លែងពោរពេញទៅដោយភាពល្វីងជូរចត់ ខ្លោចផ្សា និរាសព្រាត់ប្រាស់ក្រុមគ្រួសារ វិលទៅរស់នៅភូមិកំណើតរបស់គាត់វិញ ។

## សក្ខីកម្មទី២

វេង ឆេង ដែលជាស្ត្រីក្មេងម្នាក់ពីខេត្តតាកែវ បានក្លាយជាអ្នករត់សំបុត្ររបស់ អៀង ធីរិទ្ធ នៅក្នុងឆ្នាំ១៩៧៦ បានរំឭកឡើងវិញថា អៀង ធីរិទ្ធ មានផ្ទះ៣ឬ៤ខ្នង ប៉ុន្តែបានចំណាយពេលភាគច្រើននៅក្នុងផ្ទះមួយខ្នងនៅក្បែរព្រះបរមរាជវាំង ដែលមានអ្នកធំៗស្នាក់នៅ និងធ្វើការងារ ។ ស្ត្រីម្នាក់នេះជាអ្នកនាំសំបុត្រឲ្យ អៀង ធីរិទ្ធ ។ គាត់តែងតែជិះកង់ជាមួយនឹងអ្នកនាំផ្លូវម្នាក់ឈ្មោះ ពូ វ៉ា ដែលមានកាំភ្លើងខ្លី១ដើម ។ សំបុត្រមួយចំនួនត្រូវបញ្ជូនទៅក្រសួងការបរទេសឲ្យ អៀង សារី សំបុត្រ មួយចំនួនទៀតត្រូវបញ្ជូនឲ្យ ប៉ុល ពត, នួន ជា និង ខៀវ សំផន ហើយមួយចំនួនទៀតទៅរោងចក្រដែល អៀង ធីរិទ្ធ ទទួលខុសត្រូវ ។

គាត់ចងចាំថា គាត់ធ្លាប់បានឮពីមន្ទីរស-២១ នៅពេលគាត់ធ្វើជាអ្នករត់សំបុត្រឲ្យ អៀង ធីរិទ្ធ ប៉ុន្តែមិនដឹងថា នៅកន្លែងណា និងជាអ្វីនោះទេ ។ គាត់មិនដែលបានឮឈ្មោះ ឌុច ហើយក៏មិនដែលនាំសំបុត្ររបស់ អៀង ធីរិទ្ធ ទៅទីនោះដែរ ព្រោះ អៀង ធីរិទ្ធ បានប្រាប់គាត់ថា មន្ទីរស-២១ នៅឆ្ងាយពេកសម្រាប់គាត់នាំទៅ ។ អ្នកនាំសំបុត្រចាស់ៗគួរធ្វើកិច្ចការនេះ ។ គាត់បានរៀបរាប់ឈ្មោះអ្នកនាំសំបុត្រដូចខាងក្រោម ៖ ស្ត្រីឈ្មោះ ផល និងបុរសឈ្មោះ ភាព ធ្លាប់បាននាំសំបុត្រ អៀង ធីរិទ្ធ ទៅមន្ទីរស-២១ ។ ចំពោះកិច្ចការពិតប្រាកដ ការងារ និងការទទួលខុសត្រូវរបស់ អៀង ធីរិទ្ធ គាត់មិនត្រូវបានអនុញ្ញាតឲ្យដឹងនោះទេ ។ អៀង ធីរិទ្ធ ចូលរួមក្នុងអង្គប្រជុំនៅក្នុងទីក្រុងភ្នំពេញនៅតាមក្រសួងនានា រួមទាំងក្រសួងការបរទេសទៀតផង ។ អៀង ធីរិទ្ធ និង អៀង សារី ជាប្ដីប្រពន្ធនឹងគ្នា ប៉ុន្តែជួនកាលគាត់មិនរស់នៅក្នុងផ្ទះតែមួយនោះទេ ហើយក៏មិនធ្វើការជាមួយគ្នាញឹកញាប់ដែរ ដែលហាក់ដូចជាជួបគ្នាតែក្នុងការប្រជុំផ្លូវការធំៗ ។

ក្នុងអំឡុងពេល២សប្ដាហ៍ម្ដង វេង ឆេង តែងតែធ្វើដំណើរតាមរថយន្តជាមួយ អៀង ធីរិទ្ធ ជាទូទៅគឺទៅចូលរួមប្រជុំនៅក្នុងមន្ទីរធំៗ ក្បែរព្រះបរមរាជវាំង ដែលនៅទីនោះគាត់បានឃើញមេដឹកនាំជាន់ខ្ពស់ជាច្រើនរូប ដែលភាគច្រើនមានក្បាលពោះធំៗ ។ គាត់បានបន្តថា អ្នកធំតែងតែធ្វើការប្រជុំជាបន្តបន្ទាប់ ហើយកម្រចុះទៅមើលថា តើមានអ្វីកើតឡើងពិតប្រាកដណាស់ ទោះបីជាគាត់ទទួលបានរបាយការណ៍ជាទៀងទាត់ពីថ្នាក់ក្រោមក៏ដោយ ។

អៀង ធីរិទ្ធ មិនដែលមានអ្នកមកពីជនបទជួបគាត់ទេ ទោះបីជាពេលខ្លះគាត់បានធ្វើដំណើរទៅអង្គរវត្ត ដោយមានមិត្ត លី ទៅជាមួយចំនួន២ដងក៏ដោយ ។ នៅតាមផ្លូវ លី ឃើញមនុស្សវែកដី និងលាមក ប៉ុន្តែ អៀង ធីរិទ្ធ មិនដែលចុះពីឡានទេ ហើយប្រជាជននៅឆ្ងាយពីផ្លូវណាស់ ។

ទោះបីជាមានទំនាក់ទំនងការងារជិតស្និទ្ធយ៉ាងណាក៏ដោយ ក៏គាត់មិនដែលហ៊ានលេងសើចជាមួយ អៀង ធីរិទ្ធ ឬសួរនាំពីបញ្ហាផ្ទាល់ខ្លួនដែរ ។ ទោះជាយ៉ាងនេះក្តី គាត់នៅតែចាត់ទុក អៀង ធីរិទ្ធ ថាជាមនុស្សល្អជានិច្ច មិនមែនជាមនុស្សម្នាក់ដែលមានចិត្តអាក្រក់ ឬសាហាវនោះទេ តែជាមនុស្សម្នាក់ដែលមិនដែលដំឡើងសំឡេង ហើយតែងតែនិយាយដោយសម្តីផ្អែមល្ហែម អង្អែលក្បាល លី និងជាមនុស្សចិត្តល្អ ។ គាត់មិនជឿថា អៀង ធីរិទ្ធ ធ្លាប់សម្លាប់អ្នកណាម្នាក់នោះទេ ហើយគាត់ក៏មិនជឿថា ប៉ុល ពត, នួន ជា, អៀង សារី និងខៀវ សំផន ធ្លាប់សម្លាប់អ្នកណាម្នាក់ដោយផ្ទាល់ដៃដែរ ។ គាត់ជឿថា ការសម្លាប់កើតមានឡើងតែនៅជនបទប៉ុណ្ណោះ ដែលប្រជាជនសម្លាប់គ្នាទៅវិញទៅមក គឺមិនមែននៅក្នុងទីក្រុងទេ ។ អៀង ធីរិទ្ធ មិនដែលនិយាយជាមួយគាត់អំពីការគំរាមកំហែងពីខ្មាំងសោះឡើយ ។ ចំណីអាហារមានគ្រប់គ្រាន់ ហើយរៀងរាល់ដប់ថ្ងៃម្តងមានបង្អែមដូចជា នំសាំងវិច ឬអ្វីដែលផ្អែម ហើយមានកុនមើលទៀតផង ។ ជីវិតមានការសប្បាយរីករាយ ។

## សក្ខីកម្មទី៣



បើតាមការចងចាំរបស់ រីម បានឲ្យដឹងថា គាត់បានមកដល់គុកទួលស្លែងជាលើកដំបូងនៅឆ្នាំ១៩៧៦ ជាមួយនឹងកូនស្រីរបស់គាត់ដែលទើបតែមានអាយុបីខែ ។ រីម ត្រូវអង្គការចាប់បញ្ជូនមកពីកន្លែងបង្កបង្កើនផលគៀនឃ្លាំង ជាមួយនឹងប្រពន្ធរបស់កម្មាភិបាលខ្មែរក្រហម៥នាក់ទៀតដែលអង្គការចោទថា ជាក្រុមក្បត់ ។ ពាក់កណ្តាលអធ្រាត្រ រថយន្តមួយគ្រឿងដែលបិទដំបូលជិតដោយក្រណាត់ខ្មៅ បានដឹកស្ត្រីទាំង៦នាក់ មកឈប់នៅកន្លែងមួយដែល រីម អះអាងថា ជាគុកទួលស្លែង ។

រីម បានឃើញគំនរខោអាវ និងស្បែកជើងនៅក្នុងបន្ទប់មួយដែលស្ថិតនៅសងខាងនោះ ។ មួយសន្ទុះក្រោយមក សន្តិសុខបាននាំ រីម ចូលទៅក្នុងបន្ទប់មួយដែលធុំក្លិនស្អុយស្ទើរតែទ្រាំមិនបាន ។ សន្តិសុខបានបញ្ជាឲ្យគាត់អង្គុយនៅលើគ្រែមួយទល់មុខអ្នកសួរចម្លើយ ដែលកំពុងអង្គុយនៅលើកៅអី និងមានតុមួយនៅកណ្តាល ។ អ្នកសួរចម្លើយបានទាញមេសោនៅលើតុមកវាយឮសូរផ្ទង មុននឹងចាប់ផ្តើមសួរសំណួរអំពីប្រវត្តិរូបផ្ទាល់ខ្លួន និងសកម្មភាពមុន និងក្រោយពេលចូលបដិវត្តន៍របស់ រីម ។ បន្ទាប់មកអ្នកសួរចម្លើយចាប់ផ្តើមសួរអំពីប្រវត្តិរូប និងសកម្មភាពក្បត់របស់ប្តីគាត់ ។ រីម ឆ្លើយថា គាត់មិនបានដឹងអំពីប្រវត្តិ និងសកម្មភាពក្បត់របស់ប្តីគាត់ទេ ព្រោះគាត់ទើបតែរៀបការតាមបញ្ជារបស់អង្គការបានរយៈពេលមួយឆ្នាំប៉ុណ្ណោះ ហើយមុនពេលរៀបការ គាត់មិនដែលបានស្គាល់ប្តីរបស់គាត់ទាល់តែសោះ ។ ដោយមិនទាន់ទទួលនូវចម្លើយដែលខ្លួនចង់បាន អ្នកសួចម្លើយបានសួរនូវសំណួរដដែលៗ ហើយសម្លុតគំរាមកំហែងថា នឹងធ្វើទារុណកម្ម បើ រីម នៅតែចចេសមិនព្រមសារភាព ។

ប្តីរបស់ រីម ឈ្មោះ ថោង ហ៊ិន មាននាទីជាប្រធានកងអនុសេនាតូច (នៅក្នុងប្រវត្តិរូបបានសរសេរថា ថោង ហ៊ិន

មានមុខងារជាប្រធានអនុសេនាធំ) ។ ហ៊ិន ត្រូវអង្គការចាប់ខ្លួនបន្ទាប់ពីបានទទួលលិខិតអញ្ជើញមួយច្បាប់ពីសេនាធិការឲ្យទៅប្រជុំរៀនសូត្រ និងធ្វើទស្សនកិច្ចនៅកំពង់សោម ។ ៦ថ្ងៃក្រោយពេលដែល ហ៊ិន ចេញទៅប្រជុំ រីម រួមទាំងប្រពន្ធរបស់កម្មាភិបាលប្រមាណ៣០នាក់ទៀត ត្រូវអង្គការហៅទៅប្រជុំប្រាប់ថា ប្តីរបស់គាត់ជាសមាសភាពមិនល្អ មានផែនការក្បត់ជាតិ ចង់លក់ទឹកដីឲ្យបរទេស ។ រីម តក់ស្លុតយ៉ាងខ្លាំងពេលដែលឮដូច្នេះ ។ ចិត្តមួយនឹកអាណិត ហ៊ិន មិនដឹងជាសុខទុក្ខយ៉ាងណា ចិត្តមួយទៀតនឹកភ័យអំពីវាសនារបស់ខ្លួនឯង និងកូនស្រីដែលនៅតូច ។ រំលងបានបីថ្ងៃ ខ្មែរក្រហមបានមកប្រាប់ រីម ទាំងយប់ថា អង្គការចាត់តាំងឲ្យទៅនៅសហករណ៍ ។ រីម ត្រូវបង្ខំឲ្យចាកចេញទាំងប្រញាប់ប្រញាល់ ដោយមិនបានយកអីវ៉ាន់ទៅជាមួយផងទេ សូម្បីតែទឹកដោះគោសម្រាប់កូនបៅក៏មិនបានយកទៅដែរ ។ រីម គ្មានឱកាសប្រកែកតវ៉ា ឬសួរដេញដោលរកហេតុផលអ្វីទាំងអស់ ព្រោះខ្មែរក្រហមបានបញ្ជាថា «បើអង្គការចាត់តាំងថ្មើរម៉ាន ត្រូវតែអនុវត្តតាមថ្មើរហ្នឹង កុំចេសពេក មិនបាច់រៀបចំអីវ៉ាន់អីច្រើនទេ នៅកន្លែងអង្គការមានមិនខ្វះ បើអង្គការហ៊ានហៅទៅ អង្គការចេះដោះស្រាយឲ្យហើយ» ។

ក្រោយពេលសួរចម្លើយជាច្រើនដងក្នុងយប់នោះ សន្តិសុខបាននាំ រីម មកថតរូប ។ មុនពេលថត រីម ត្រូវបានសន្តិសុខដកហូតយកអីវ៉ាន់ទាំងអស់ដែលមាននៅជាប់នឹងខ្លួន សូម្បីតែក្រមានិងស្បែកជើងដែលកំពុងពាក់ក៏ត្រូវដកហូតដែរ ។ បន្ទាប់មក រីម ត្រូវបានយកទៅឃុំទុកក្នុងបន្ទប់មួយតែឯងដោយពុំមានដាក់ខ្នោះដៃជើងទេ ។ ស្អែកឡើង អ្នកសួរចម្លើយបានមកសួរគាត់ម្តងទៀត ប៉ុន្តែគឺជាមនុស្សផ្សេងពីយប់ម្សិល ។ នៅយប់ទីពីរនេះ រីម ត្រូវសួរចម្លើយបួនដងមុននឹងត្រូវបញ្ជូនទៅគុកព្រៃស ។ រីម ត្រូវអ្នកសួរចម្លើយសម្លុតសួរសំណួរដដែលៗដូចយប់មុន ហើយគាត់នៅតែឆ្លើយដដែលៗថា គាត់មិនដឹងរឿងរបស់ ហ៊ិន ទេ ។ រីម ត្រូវអ្នកសួរចម្លើយទះកំផ្លៀងមួយដៃដួលផ្ងប់នឹងជញ្ជាំង ហើយចាប់សក់ក្បាលរបស់គាត់បោកផ្ទប់នឹងជញ្ជាំងបន្ថែមទៀត ដោយសារអ្នកសួរមិនពេញចិត្តនឹងចម្លើយរបស់គាត់ ។ ក្រោយពេលសួរចម្លើយរួចហើយ ម៉ោង១២យប់ រីម និងកូនស្រីត្រូវបានបញ្ជូនចេញទៅព្រៃសជាមួយនារីម្នាក់ទៀត ។ រីម មិនបានដឹងអំពីវាសនារបស់នារីផ្សេងទៀតដែលមកជាមួយគាត់ទេ ។

ពេលមកដល់ព្រៃសមិនទាន់បានសម្រាកបាត់ហត់ផង រីម ត្រូវប្រធានកងបញ្ជាឲ្យចេញទៅធ្វើការនៅម៉ោង៣ទៀបភ្លឺដូចអ្នកទោសដទៃទៀតដែរ ។ ជារៀងរាល់ថ្ងៃ រីម សែនធុញទ្រាន់នឹងសំឡេងកញ្ចែដាស់ឲ្យក្រោកតម្រង់ជួរទៅកាប់ដីជីកប្រឡាយ ស្ទូងស្រូវ តាំងពីម៉ោង៣ភ្លឺរហូតដល់ម៉ោង៨យប់ ពេលខ្លះរហូតដល់ម៉ោង១២អធ្រាត្រក៏មាន ។ ជួន កាលមានផែនការក្តៅ អ្នកទោសទាំងអស់ត្រូវចេញទៅធ្វើការតាំងពីម៉ោង១ភ្លឺ ហើយលទ្ធផលនៃការខំប្រឹងប្រែងធ្វើការនេះ អ្នកទោសបានទទួលត្រឹមតែបបររាវៗប៉ុន្មានវែកដែលហូបមិនឆ្អែតក្នុងមួយថ្ងៃពីរពេលតែប៉ុណ្ណោះ ។ រីម និយាយថា «ធ្វើការងារធ្ងន់ធ្ងរ ហើយទទួលបានត្រឹមតែបបរមួយហុត ម្នាក់ៗហេវហត់អស់កម្លាំងស្ទើរតែស្លាប់ទៅហើយ» ។ ដោយសារតែភាពស្រេកឃ្លានគ្រប់គ្នាអាចហូបបានទាំងអស់នូវអ្វីដែលបានប្រទះឃើញហើយអាចដាក់ចូលក្នុងមាត់បាន ទោះជាដឹងថា ការធ្វើរបៀបនេះនឹងត្រូវទទួលទោស ឬបណ្តាលឲ្យមានជំងឺក៏ដោយ ។ នៅវាលស្រែ ប្រសិនបើមានកណ្តូប ឬក៏ក្តាមមួយវារកាត់មុខអ្នកទោសរត់ប្រញាប់ដណ្តើមគ្នាចាប់យកមកហូបទាំងឆៅ ។ មានអ្នកទោសខ្លះ ត្រូវឈ្លបខ្មែរក្រហមចាប់គក់រហូតទាល់តែចេញក្អួត ឬចាប់ខ្ទេះយកក្តាម ឬត្រីចេញពីមាត់វិញ ដោយចោទថា ហូបអត់មានរបៀបរបប មិនខំប្រឹងធ្វើការ ។ ប្រសិនបើអ្នកទោសណាម្នាក់អវត្តមាននៅកន្លែងធ្វើការជាច្រើនដង ប្រាកដជាបាត់ខ្លួនមិនខាន ។

ពេលវេលាទាំងអស់របស់ រីម ត្រូវចំណាយទៅលើការងារ ។ រីម គ្មានពេលនៅមើលថែរក្សាកូនស្រីតូចរបស់គាត់ដែល

ទើបតែមានអាយុ៣ខែនោះទេ ។ មុនពេលចេញទៅធ្វើការ រីម ត្រូវយកកូនទៅដាក់នៅកន្លែងមើលក្មេងដែលមានយាយចាស់
ម្នាក់ជាអ្នកមើលក្មេងៗ៦០នាក់ ។ នៅព្រៃសបានមួយខែ សុខភាពកូនស្រីរបស់ រីម មានសភាពកាន់តែទ្រុឌទ្រោមទៅៗ
មុខរបស់នាងស្លេកស្លាំង ផ្តាល់ផត ខ្លួនប្រាណស្គមល្ហិតល្ហៃព្រោះគ្មានអ្វីហូប ។ រីម គ្មានទឹកដោះឲ្យកូនបៅទេ ។ មួយថ្ងៃៗកូន
របស់គាត់បានទទួលត្រឹមតែទឹកបបររាវៗ ឬជួនកាលទឹកឆៅប៉ុន្មានតំណក់ដែលគាត់បន្តក់ឲ្យមុន និងក្រោយពេលទៅធ្វើការតែ
ប៉ុណ្ណោះ ។ អាហារទាំងនេះ មិនអាចទ្រទ្រង់រាងកាយរបស់ទារកបានយូរឡើយ នៅទីបំផុតកូនស្រីរបស់គាត់ក៏ស្លាប់ដោយសារ
កង្វះអាហារ ។ រីម នៅតែនឹកឃើញជានិច្ចនូវរាងកាយដ៏តូចរបស់កូនស្រីដែលស្លាប់នៅលើដៃគាត់ ។

អារម្មណ៍ភ័យខ្លាចដែលមាននៅក្នុងចិត្តរបស់ រីម តាំងពីត្រូវខ្មែរក្រហមបង្ខំឲ្យចេញពីកន្លែងបង្កបង្កើនផល នៅតែ
ស្ថិតនៅក្នុងខួរក្បាលរបស់គាត់ជានិច្ច ។ រីម តែងតែគិតថា គាត់ត្រូវបញ្ជូនទៅស្លាប់នៅរាល់ពេលដែលអង្គការបញ្ជូនគាត់
ចេញពីកន្លែងមួយទៅកន្លែងមួយទៀត ។ នៅព្រៃស រីម បានឃើញអ្នកទោសត្រូវបញ្ជូនចេញទាំងឡានៗ ហើយអ្នកទោស
ថ្មីៗជាច្រើននាក់ក៏ត្រូវបញ្ជូនចូលមកស្ទើរតែរាល់ថ្ងៃដែរ ។ រីម និយាយថា «អ្នកដែលគេបញ្ជូនចេញគឺយកទៅសម្លាប់
ហើយខ្ញុំរស់នៅទីនោះ រង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ថ្ងៃនេះគេ ថ្ងៃក្រោយយើង ទោះបីជាយើងចង់ចៀសក៏ចៀសមិនផុតដែរ» ។
រីម ជាប់នៅគុកព្រៃសរហូតដល់ឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ ។

ពេលរំឭកទៅដល់រឿងអតីតកាល រីម និយាយថា «ខ្ញុំសោកស្តាយណាស់ដែលជឿតាមការឃោសនារបស់គេ ខិតខំ
តស៊ូបម្រើបដិវត្តន៍តាំងពីឆ្នាំ១៩៧៣ មិនខ្លាចហត់នឿយ រត់កាត់គ្រាប់កាត់ភ្លៀងដើម្បីរំដោះជាតិមាតុភូមិ សង្ឃឹមថា នឹងបាន
រស់នៅសុខស្រួលទាំងអស់គ្នា តែលទ្ធផលចុងក្រោយបានត្រឹមតែចូលគុកដោយមិនដឹងខ្លួនថា ខ្លួនឯងប្រព្រឹត្តអ្វីខុសសោះ» ។
ឥឡូវនេះ រីម ចង់ឃើញតុលាការយុត្តិធម៌ និងត្រឹមត្រូវមួយកើតឡើងដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហមធំៗ ដែលបាន
ធ្វើខុសចំពោះប្រជាជនកម្ពុជារាប់លាននាក់ ព្រោះអ្នកដែលប្រព្រឹត្តខុសគួរតែទទួលទោសឲ្យស័ក្តិសមនឹងកំហុស ដែលបានធ្វើ
គឺមិនមែនចាប់អ្នកដែលគ្មានកំហុសយកទៅដាក់គុកធ្វើទារុណកម្ម ដើម្បីជំរិតយកចម្លើយ និងសម្លាប់ចោល ដូចនៅក្នុងរបប
ខ្មែរក្រហមនោះទេ ។

## សក្ខីកម្មទី៤

ខ្ញុំ និងប្តីខ្ញុំឈ្មោះ ញ៉ែម នឿន បានរៀបការនៅឆ្នាំ១៩៦២នៅខេត្តកំពង់ចាម ។ ប្តីខ្ញុំត្រូវជាបងជីដូនមួយ តែខ្ញុំ
ហៅគាត់ថា «ពូ» ។ ក្រោយមកយើងបានទៅរស់នៅខេត្តសៀមរាប ប៉ុន្តែប្តីខ្ញុំគាត់នៅរៀនឯកំពង់ចាម ហើយមិនបានមក
សៀមរាបញឹកញាប់ទេ ។

ប្តីខ្ញុំបានចូលរួមជាមួយបដិវត្តន៍តាំងពីមុនពេលយើងរៀបការម្ល៉េះ ។ គាត់ទៅជាមួយមិត្តរួមសាលាពីរនាក់គឺ ហ៊ូ នឹម និង
ហ៊ូ យន់ ។ ពីរនាក់នេះហើយជាអ្នកអប់រំខ្ញុំនៅពេលបដិវត្តន៍ ។

ឆ្នាំ១៩៧០ខ្ញុំទៅរស់នៅជាមួយប្តីនៅខេត្តសៀមរាប ។ គាត់ធ្វើជាយុទ្ធជនខ្មែរក្រហម ប៉ុន្តែគាត់មិនបានចូលប្រយុទ្ធទេ
គ្រាន់តែដឹកស្បៀងអាហារទៅសមរភូមិប៉ុណ្ណោះ ។ អំឡុងពេលបដិវត្តន៍ គាត់ជាគ្រូបង្រៀន ។

កែ ពក ហៅខ្ញុំឲ្យចូលបដិវត្តន៍នៅឆ្នាំ១៩៧០ ។ គាត់នោះ ជាចៅហ្វាយខេត្ត ហើយបងថ្លៃរបស់គាត់ឈ្មោះ អឿន
ជាគណៈឃុំ ។ គាត់ បង្រៀនខ្ញុំដោយផ្ទាល់អស់រយៈពេលជាងពីរឆ្នាំ ។ ដំបូង ខ្ញុំបដិសេធមិនព្រមចូលបដិវត្តន៍ទេ ដោយសារតែ
រវល់ជួយមើលការខុសត្រូវឪពុកម្តាយ និងប្តី ។ ខ្ញុំមិនយល់សោះថា ហេតុអ្វីខ្ញុំត្រូវចូលបដិវត្តន៍ទៀត បើប្តីខ្ញុំបម្រើបដិវត្តន៍

ទៅហើយ ប៉ុន្តែ កែ ពក នៅតែព្យាយាមបញ្ចុះបញ្ចូលខ្ញុំ ។ គាត់ស្លូតបូត ប៉ិនកំប្លែង និងធ្លាប់មានប្រវត្តិជាអ្នកហ៊ឺហាម្នាក់ដែរ ។ បើមានអ្នកណាម្នាក់ និយាយអ៊ីខុសឆ្គង គាត់មើលមុខអ្នកនិយាយភ្លាម ធ្វើឲ្យអ្នកនោះភ័យខ្លាច ។



នៅឆ្នាំ១៩៧៣ កែ ពក សង់ផ្ទះមួយឲ្យខ្ញុំ ។ គាត់និយាយថា ចង់ឲ្យខ្ញុំបូជាគ្រប់យ៉ាងដើម្បីបដិវត្តន៍ ។ គាត់តែងតែមកផ្ញួតទឹករាល់ៗល្ងាច និងចេញទៅវិញនៅម៉ោង៤-៥ទៀបភ្លឺ ។

គាត់ដេកស្រមុកព្ញៗណាស់ ប៉ុន្តែបើមានមនុស្សដើរកាត់ផ្ទះតែបន្តិច គាត់ព្ញ និងដឹងភ្លាមថា ជាអ្នកណា ។ មានពេលមួយក្រោយហូបបាយរួច គាត់ចង់សរសេរសំបុត្រ ប៉ុន្តែគាត់មិនដឹងថា ត្រូវសរសេរយ៉ាងម៉េច ខ្ញុំក៏បង្រៀនគាត់អំពីរបៀបសរសេរ ។

ខ្ញុំបានស្ម័គ្រចិត្តធ្វើជាប្រធានកងនារីនៅខេត្តសៀមរាប ។ ខ្ញុំធ្វើដូច្នេះដោយសារតែបដិវត្តន៍ខ្វះមនុស្សកាន់តំណែងនេះ ។ អ្នកភូមិដែលខ្ញុំធ្វើការជាមួយសុទ្ធតែចាស់ៗហើយក្រីក្រទៀត ។ ឃើញដូច្នេះ ខ្ញុំក៏សរសេរសំបុត្រទៅ កែ ពក ស្នើសុំកប្បាសខ្លះ ។ គាត់បានបញ្ជូនក្រណាត់ប្រហែល២០ដុំ និងឲ្យម៉ាស៊ីនតម្បាញពីរបីគ្រឿងទៀតមកឲ្យខ្ញុំ ។ ខ្ញុំណែនាំឲ្យអ្នកភូមិត្បាញសូត្រ ហើយកាត់ខោអាវឲ្យគាត់ ។

នៅឆ្នាំ១៩៧៤ មានការប្រជុំមេខ្មែរក្រហមធំៗនៅភ្នំគូលែន ។ ខ្ញុំជាចុងភៅម្នាក់នៅក្នុងអង្គប្រជុំនេះ ។ ខ្ញុំដេរខោអាវឲ្យអ្នកដែលមកចូលរួមប្រជុំទាំងអស់ ។ ធ្វើដូចនេះ អ្នកមកចូលរួមអាចប្តូរសម្លៀកបំពាក់មួយថ្ងៃបីដង ។ ពេលខ្ញុំនិងប្តីខ្ញុំចុះពីភ្នំទៅផ្ទះ យើងដឹងថា កូនប្រុសយើងឈ្មោះ សុធា បានស្លាប់ដោយសារជំងឺគ្រុនចាញ់ ។ សុធាទើបតែមានអាយុបួនឆ្នាំ ។ កាលពីឆ្នាំ១៩៦៦កូនដំបូងរបស់យើងក៏ស្លាប់ដោយសារជំងឺដូចគ្នានេះដែរ ពេលដែលអាយុបាន២ឆ្នាំ ។

ចាប់ពីពេលនោះមកខ្ញុំលាលែងឈប់ធ្វើគណៈឃុំ ព្រោះការងារនោះយ៉ាប់ ម្យ៉ាងខ្ញុំត្រូវដើរឆ្ងាយណាស់ទម្រាំទៅដល់ភូមិ ។ ខ្ញុំគ្រាន់តែស្នើទៅអង្គការសុំឈប់ អង្គការក៏យល់ព្រម ។ នេះក៏ប្រហែលជាដោយសារការស្លាប់របស់កូនប្រុសខ្ញុំដែរ ។

ប្តីខ្ញុំជាគណៈស្រុកនៅខេត្តសៀមរាប ។ យើងរស់នៅដាច់ដោយឡែកពីគ្នា ព្រោះគាត់ធ្វើការកន្លែងខុសពីខ្ញុំ ។ ជួនកាលគាត់សម្រាកនៅផ្ទះ ជួនកាលគាត់គ្រាន់តែមកលេងជាមួយកូនៗប៉ុណ្ណោះ ។ កូនយើងបីនាក់នៅរស់ ហើយកូនបងតែងតែសួររកឪពុកចង់ឲ្យឪពុកម្តាយរស់នៅជុំគ្នា តែខ្ញុំមិនព្រម ។ នៅឆ្នាំ១៩៧៥ ខ្ញុំចាប់ផ្តើមធ្វើស្រែ និងត្បាញនៅសហករណ៍ភ្នំគូលែន ខ្ញុំធូរបន្តិចពេលរស់នៅឆ្ងាយពីប្តីខ្ញុំ ។

នឿន ត្រូវអង្គការចាប់ខ្លួននៅឆ្នាំ១៩៧៧ ។ មានមនុស្សប្រាប់ខ្ញុំថា ខ្មែរក្រហមច្រកគាត់ចូលក្នុងបាវ ហើយទម្លាក់ក្នុងទឹកទន្លេ ។ មានអ្នកនិយាយថា កែ ពក ចាប់គាត់ដាក់ឡានដឹកចេញទៅ ។

ខ្ញុំគិតថា ខ្ញុំពិតជាត្រូវអង្គការចាប់ខ្លួនបន្តពីប្តីខ្ញុំហើយ ។ ខ្ញុំគិតថា បើទៅជាមួយអ្នកទាំងនោះ ខ្ញុំពិតជាស្លាប់ ។ កាលណោះកូនប្រុសខ្ញុំ ឈ្មោះ សុឃិន នៅសហករណ៍ តែកូនស្រីខ្ញុំឈ្មោះ គា និង សុខនី តាមខ្ញុំទៅមន្ទីរស្រុកសូទ្រនិគម ។ ខ្ញុំជាប់គុកបានមួយខែទើបកើតកូនស្រីមួយទៀត ឈ្មោះ សុខា ។

នៅក្នុងគុក ខ្មែរក្រហមសួរចម្លើយខ្ញុំ និងចោទខ្ញុំថា ក្បត់បដិវត្តន៍ ។ ខ្ញុំនិយាយមិនដូចអ្នកសៀមរាប អ្នកណាក៏ដឹងដែរ ។

អ្នកនៅគុកឃើញខ្ញុំមកពីកំពង់ចាមក៏ជួយលាក់ការណ៍ខ្ញុំ ព្រោះប្តីខ្ញុំធ្លាប់មើលថែអ្នកទាំងនោះពេលមានជំងឺឈឺថ្កាត់ និងឲ្យខោអាវគ្រាន់ស្លៀកពាក់ ។ ក្រោយពេលខ្ញុំឆ្លងទន្លេថ្មីៗ កែ ពក មកមើលមន្ទីរឃុំឃាំង ហើយឃើញខ្ញុំដោយចៃដន្យ ។ កូនៗខ្ញុំចំណាំគាត់ បានភ្លាមស្រែកឡើងថា «ម៉ែៗអ៊ំមកហើយ» ។ គាត់និយាយថា គាត់តាមរកខ្ញុំមិនឃើញសោះ ។ គាត់បានបញ្ជាឲ្យសន្តិសុខយកបាយម្ហូបឲ្យខ្ញុំហូប ។ សន្តិសុខក៏យកត្រីងៀតឲ្យខ្ញុំហូប ។

កាលពីដើម កែ ពក សង្ហា មានមុខមាត់ស្អាតបាត ។ ខ្ញុំពីមុន ជួនកាលមិនទាំងហ៊ានមើលមុខគាត់ចំផង ព្រោះខ្ញុំ ខ្មាសគាត់ ។ ពេលគាត់មកមើលគុក ខ្ញុំសម្លឹងមើលគាត់ ហើយបង្ហូរទឹកភ្នែក ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំធ្វើបដិវត្តន៍ដើម្បីទាមទារសិទ្ធិសេរីភាពឲ្យប្រជាជន តែឥឡូវអង្គការបែរជាចោទថា ប្តីខ្ញុំក្បត់ ។ តើ នឿន បានធ្វើអីខុស? ខ្ញុំបានប្រាប់ កែ ពក ថា គាត់ជាអ្នកនាំខ្ញុំមកទីនេះ ឥឡូវហេតុអីក៏ធ្វើបែបនេះចំពោះខ្ញុំ ។ ខ្ញុំសុំឲ្យគាត់ប្រាប់ខ្ញុំអំពី នឿន ។ កែ ពក ព្រមទទួលថា គាត់បានយកប្តីខ្ញុំទៅរៀនសូត្រ ហើយគាត់ថែមទាំងស្បថ ចំពោះខ្ញុំថា នឿន មិនទាន់ស្លាប់ទេ ប៉ុន្តែត្រូវអង្គការបញ្ជូនទៅខេត្តរតនគិរីហើយ ។ កែ ពក ប្រាប់ខ្ញុំកុំឲ្យភ័យខ្លាចអី ។ ខ្ញុំជឿសម្តីគាត់ ព្រោះខ្ញុំទុកចិត្តគាត់ ។

ក្រោយមកគាត់លែងខ្ញុំ និងបញ្ជូនខ្ញុំទៅសហករណ៍ឲ្យរែកដី និងបុកស្រូវ ។ ខ្មែរក្រហមបានសួរអ្នកនៅទីនោះអំពីសាវតារប្តីខ្ញុំ ប៉ុន្តែអ្នកភូមិនៅទីនោះចិត្តល្អជាមួយខ្ញុំដែរ ព្រោះកាលណោះ ខ្ញុំទើបតែសម្រាលកូនរួច ។ នៅទីនោះយើងហូបចុកពីរបីពេលក្នុងមួយថ្ងៃ ។ ខ្ញុំហូបបបរបាយ ជួនកាលធ្វើការរួចខ្ញុំឆ្លៀតរកត្រី ប៉ុន្តែអង្គការក៏មិនដាក់ទោសខ្ញុំដែរ ។ ក្រោយពេលខ្មែរក្រហមដួលរលំ ខ្ញុំបានធ្វើដំណើរទៅស្រុកសូទ្រនិគមយកកូនខ្ញុំត្រឡប់មកវិញ ។ ខ្ញុំគិតដល់ប្តីខ្ញុំជារៀងរាល់ថ្ងៃ ពេលខ្លះខ្ញុំមានអារម្មណ៍ថា គាត់នៅរស់នៅឡើយ គ្រាន់តែគាត់មិនទាន់មកដល់ភូមិនៅពេលនេះ ។ ខ្ញុំនៅតែរង់ចាំគាត់ ។ គាត់ជាអ្នកមើលថែរក្សា និងយកចិត្តទុកដាក់ចំពោះខ្ញុំ ។ តាំងពីនោះមក ខ្ញុំមិនដែលបានដំណឹងអ្វីពី កែ ពក ទាល់តែសោះ ។ បងប្អូនខ្ញុំម្នាក់មកពីអន្លង់វែង បានប្រាប់ខ្ញុំថា សព្វថ្ងៃគាត់រស់នៅក្បែរផ្ទះរបស់ កែ ពក ។ ពេលដែលខ្ញុំដឹងថា កែ ពក ស្លាប់ ខ្ញុំអាណិតគាត់ ព្រោះគាត់ចិត្តល្អណាស់ ។ បើខ្ញុំមានលុយ ប្រហែលជាខ្ញុំបានទៅចូលរួមបុណ្យសពគាត់ជាមិនខាន ។

## សក្ខីកម្មទី៥

មុនរបបលន់ នល់ ឪពុកខ្ញុំធ្វើជាគ្រូបង្រៀនផង និងជាជាងថតរូបការផង ។ គាត់ជាអ្នកថតរូបមួយសន្លឹកនេះឲ្យខ្ញុំ និងលោកយាយ ។ នៅឆ្នាំ១៩៧៤ ឪពុកខ្ញុំនាំខ្ញុំមកភូមិនេះមកលេងយាយ គឺដំណាលគ្នានឹងពេលដែលខ្មែរក្រហមដឹកព្រះសង្ឃប្រមាណ១៥ឡានពីខេត្តសៀមរាបទៅកំពង់ចាម ។ ក្រោយរំដោះ ខ្ញុំត្រឡប់មករស់នៅជាមួយយាយនៅទីនេះ ។ ឪពុកម្តាយខ្ញុំនៅសៀមរាបទាំងអស់គ្នា ។ ពេលខ្ញុំអាយុបាន១០ឆ្នាំ អង្គការយកខ្ញុំចូលបដិវត្តន៍ ។ ខ្ញុំដើរកើបអាចម៍គោនៅភូមិនេះ ក្រោយមកអង្គការឲ្យខ្ញុំ ទៅរែកដីសង់ទំនប់នៅទឹកឆា និងទូលត្របែក ។ ខ្ញុំនៅកងកុមាររស់នៅឆ្ងាយពីយាយ ។ នៅពេលយប់យើងរស់នៅក្នុងខ្ទមធំមួយ ។ ក្មេងប្រុសៗដេកជាជួរ ។ កាលណោះខ្ញុំរងាណាស់ព្រោះគ្មានខោអាវស្លៀកពាក់ មានតែភួយមួយ និងក្រមាមួយ ។ បើមានអ្នកណាហ៊ានលួចអ៊ីហូប មុខជាត្រូវខ្មែរក្រហមចាប់ចងទាត់ធាក់មិនខាន ។ អង្គការថែមទាំងដាក់ទោសអ្នកដែលរកត្រីតាមស្រែទៀតផង ។ ខ្ញុំឃើញខ្មែរក្រហមដកក្រចកក្មេងៗដែលលួចស្រូវអង្ករលាក់ទុក ។

ខ្ញុំមិនដែលធ្វើអ្វីខុសទេ ព្រោះមានយាយតាមការពារខ្ញុំ ។ គាត់មិនឲ្យខ្ញុំយកអ៊ីហូបផ្តេសផ្តាសទេ ទោះជាឃ្លានក៏ដោយ ។ ខ្ញុំមិនរវេរវល់នឹងអ្វីទាំងអស់ ។ ក្រោយវៀតណាមចូលរំដោះនៅឆ្នាំ១៩៧៩ ខ្ញុំបានវិលត្រឡប់ទៅរស់នៅជាមួយយាយរបស់ខ្ញុំវិញ ។ នៅពេលនោះដោយខ្មែរក្រហមចង់បញ្ជូនមនុស្សទៅសម្លាប់នៅឯលិចភូមិដែលទើបតែជីករណ្តៅរួមមួយ ។ ខ្ញុំ

មិនដឹងថា ហេតុអីបានជាខ្មែរក្រហមចង់សម្លាប់អ្នកភូមិទាំងអស់ទេ ។

*សំយោគ (១៥-២៥នាទី)*

គ្រូពិនិត្យកិច្ចការសិស្ស និងសួរសិស្សអំពីបទពិសោធន៍ក្នុងការសម្តែង ។ គ្រូដាក់ពិន្ទុឲ្យសិស្ស ផ្អែកតាមតារាងខាងក្រោម ៖

**តារាងសម្រាប់ដាក់ពិន្ទុ**

| វត្ថុបំណង | លទ្ធផលទាប | លទ្ធផលល្អ | លទ្ធផលល្អណាស់ |
|---|---|---|---|
| សិស្សយល់ពីព័ត៌មានបឋមអំពីមនុស្សម្នាក់ៗ ។ | សិស្សផ្តល់ព្រឹត្តិការណ៍១ អំពីបទពិសោធន៍របស់មនុស្សម្នាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្មើនឹង១ពិន្ទុ ។ ប្រសិនបើពុំបានផ្តល់ទេ ស្មើនឹង០ពិន្ទុ ។ | សិស្សផ្តល់ព្រឹត្តិការណ៍ ២ អំពីបទពិសោធន៍របស់មនុស្សម្នាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្មើនឹង ២ ពិន្ទុ ។ | សិស្សផ្តល់ព្រឹត្តិការណ៍ ៣ ឬច្រើនជាងនេះ អំពីបទពិសោធន៍របស់មនុស្សម្នាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យស្មើនឹង៣ពិន្ទុ ។ |
| សិស្សវាយតម្លៃទៅលើស្ថានភាព ឬបទពិសោធន៍របស់មនុស្សម្នាក់ៗ | សិស្សមិនមានយោបល់អ្វីទាំងអស់អំពីថា តើគាត់ទទួលរងផលប៉ះពាល់ពីបទពិសោធន៍ដែលខ្លួនជួបប្រទះ ឬថាតើគាត់មានអារម្មណ៍យ៉ាងម៉េចចំពោះបទពិសោធន៍ទាំងនេះ សិស្សនឹងទទួលបាន០ពិន្ទុ ។ | | សិស្សផ្តល់យោបល់ទៅលើថា តើគាត់ទទួលរងផលប៉ះពាល់ពីបទពិសោធន៍ដែលគាត់បានជួបប្រទះ ឬថាតើគាត់មានអារម្មណ៍យ៉ាងណាដែរចំពោះស្ថានការណ៍បែបនោះ ។ សិស្សនឹងទទួលបាន២ពិន្ទុ ។ |

***កំណត់ចសម្គាល់សម្រាប់ការបង្រៀន : តារាងដាក់ពិន្ទុនេះក៏មាននៅក្នុងសៀវភៅលំហាត់សម្រាប់សិស្សដែរ ។*** គ្រូត្រូវតែបេះប្រែប្រួលចំពោះតារាងដាក់ពិន្ទុនេះ ។ ឧទាហរណ៍ ប្រសិនបើសិស្សផ្តល់ការពិត២យ៉ាងអំពីមនុស្សម្នាក់ ប៉ុន្តែផ្តល់គំនិតវែង និងលម្អិតអំពីថា តើគាត់មានអារម្មណ៍យ៉ាងដូចម្តេចនោះ គំនិតនេះនឹងទទួលបាន៣ពិន្ទុ ។ វត្ថុបំណងរបស់លំហាត់នេះ គឺមិនមែនសម្រាប់ដាក់ទណ្ឌកម្មសិស្សនោះទេ ប៉ុន្តែដើម្បីលើកទឹកចិត្តសិស្សឲ្យខិតខំប្រឹងប្រែងរៀនសូត្រដើម្បីយល់អំពីជីវិតរបស់មនុស្សដែលខ្លួនកំពុងតែសិក្សា ។ គ្រូគួរតែផ្តល់ពិន្ទុខ្ពស់ទៅឲ្យសិស្សភាគច្រើន ហើយប្រសិនបើជាទូទៅសិស្សមិនអាចទទួលបានពិន្ទុខ្ពស់សម្រាប់លំហាត់ទេ គ្រូគួរតែធ្វើលំហាត់នេះម្តងទៀត និងពន្យល់ការណែនាំសាជាថ្មី ដូច្នេះសិស្សមិនមានការភាន់ច្រឡំអំពីវត្ថុបំណងនៃការធ្វើលំហាត់ទេ ។

# ជំពូក៧ ៖ គម្រោងផែនការ៤ឆ្នាំ (១៩៧៧-១៩៨០)



កម្មាភិបាលខ្មែរក្រហមកំពុងបញ្ជាម៉ាស៊ីនកាត់ឈើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## មេរៀនទី១ ៖ អំណានជំពូក៦ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### វត្ថុបំណង

១) សិស្សពណ៌នាអំពីផែនការ៤ឆ្នាំរបស់កម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សពន្យល់អំពីមនោគមន៍វិជ្ជាដែលនៅពីក្រោយផែនការ៤ឆ្នាំ ។

៣) សិស្សកំណត់និយមន័យនៃពាក្យសំខាន់ៗទាក់ទងនឹងផែនការ៤ឆ្នាំ ។

៤) សិស្សសំយោគការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

## ពន្យល់ពាក្យ និង ឈ្មោះសំខាន់ៗ ៖

| | | |
|---|---|---|
| សមូហភាវូបនីយកម្ម | ផែនការ៤ឆ្នាំ | ពាក្យស្លោក |
| ផលិតកម្ម | របប | មនោគមន៍វិជ្ជា |

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ រួចឲ្យសិស្សមើលរូបភាព និងពិនិត្យមើលពាក្យសំខាន់ៗក្នុងជំពូក៦ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអាន និងកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗ ។ សិស្សសរសេរព្រឹត្តិការណ៍ទាំងនោះនៅក្នុងសៀវភៅលំហាត់របស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

## សំណួរណែនាំ និងចម្លើយ

១) ហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជនទាំងអស់ឲ្យចេញពីទីក្រុង? **ដើម្បីកម្ទេចចោលអ្នករស់នៅក្នុងទីក្រុង និងកសាងកម្ពុជាថ្មីមួយដោយផ្អែកទៅលើការពង្រីកផលិតកម្មស្រូវ ។**

២) តើផែនការ៤ឆ្នាំ (១៩៧៧-១៩៨០)គឺជាអ្វី? **ផែនការ៤ឆ្នាំតម្រូវឲ្យធ្វើការប្រមូលផ្ដុំនូវទ្រព្យសម្បត្តិឯកជនទាំងអស់ និងដាក់អាទិភាពរបស់ជាតិទៅលើការដាំដុះស្រូវ ។**

៣) តើសមូហភាវូបនីយកម្មមានផលប៉ះពាល់មកលើគ្រួសារខ្មែរដូចម្ដេចខ្លះ? **ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ហើយប្រជាជនត្រូវបានចាត់តាំងទៅតាមក្រុម ។ ប្ដីត្រូវបានបំបែកចេញពីប្រពន្ធ ហើយកូនក្មេងត្រូវបំបែកចេញពីឪពុកម្ដាយ និងត្រូវចាត់តាំងឲ្យទៅធ្វើការនៅជំរំផ្សេងគ្នា ។**

៤) តើអាទិភាពចម្បងពីររបស់កម្ពុជាប្រជាធិបតេយ្យជាអ្វី? **សមូហភាវូបនីយកម្មដើម្បីធ្វើការដាំដុះ ស្រូវ និងការការពារជាតិប្រឆាំងនឹងវៀតណាម ។**

៥) តើសមូហភាវូបនីយកម្មមានន័យយ៉ាងដូចម្ដេច? **មានន័យថា រាល់កម្មសិទ្ធិឯកជនទាំងអស់ (ដែលរួមទាំងសម្ភារផ្ទះបាយ) នឹងត្រូវប្រមូលផ្ដុំដើម្បីប្រើប្រាស់រួម ។ ទ្រព្យសម្បត្តិឯកជនត្រូវបានហាមឃាត់ ហើយការដាំដុះស្រូវត្រូវធ្វើឡើង ដោយក្រុមការងារនៅឯជំរំធ្វើការប្រមូលផ្ដុំ ។**

៦) តើគោលបំណងរបស់សមូហភាវូបនីយកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាអ្វី? **គោលបំណងគឺដើម្បីធ្វើឲ្យប្រទេសកម្ពុជាមានឯករាជភាពទាំងស្រុង ទាំងផ្នែកសេដ្ឋកិច្ចនិងនយោបាយ និងដើម្បីប្រែក្លាយប្រទេសកម្ពុជាពីប្រទេសកសិកម្មអន់ថយឲ្យទៅជាប្រទេសកសិកម្មជឿនលឿនមួយ ។**

៧) តើលទ្ធផលនៃសមូហភាវូបនីយកម្ម និងគោលនយោបាយផ្សេងៗទៀតរបស់ខ្មែរក្រហមមានអ្វីខ្លះ? (ផ្ដល់ចម្លើយយ៉ាងហោចណាស់ចំនួន៣)

- **គ្រោះអត់ឃ្លាន នៅពេលដែលផលិតកម្មស្រូវមិនបានគ្រប់គ្រាន់ ឬមិនត្រូវបានបែងចែកទៅឲ្យប្រជាជន ។**

- ជំងឺរាតត្បាតដែលបណ្ដាលមកពីការទទួលទានអាហារមិនបានគ្រប់គ្រាន់ និងការខ្វះថ្នាំសង្កូវ ។
- ការកាប់សម្លាប់បញ្ញវន្ត អ្នកបច្ចេកទេស និងអតីតមន្ត្រីនៃរបបចាស់ ។
- ការខ្វះការអប់រំ ដោយសារតែសាកលវិទ្យាល័យ និងសាលារៀនត្រូវបិទទ្វារ ។
- ការប្រើប្រាស់កម្លាំងពលកម្មមិនបានសមស្រប ។ កសិករដែលមិនមានបទពិសោធន៍ ត្រូវបានដាក់ឲ្យធ្វើការនៅក្នុងរោងចក្រ ។
- គ្មានភាពស្មើគ្នា ដោយសារតែកងទ័ព និងកម្មាភិបាលខ្មែរក្រហមមានហូបគ្រប់គ្រាន់ នៅពេលដែលប្រជាជនសាមញ្ញទទួលរងគ្រោះដោយការអត់ឃ្លាន ។

## មេរៀនទី២ : កាលបរិច្ឆេទ : ការវិភាគ និងការវាយតម្លៃនៅក្នុងក្រុម

### វត្ថុបំណង

១) សិស្សពណ៌នាអំពីព្រឹត្តិការណ៍ទាំងមូល ដែលកើតមានឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សពន្យល់អំពីសារសំខាន់នៃព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សរៀបចំព្រឹត្តិការណ៍សំខាន់ៗ រៀបតាមកាលបរិច្ឆេទ ។

៤) សិស្សវិភាគ និងវាយតម្លៃព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**សម្ភារទេសទេស** : សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

### លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមបង្រៀន គ្រូណែនាំអំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូរៀបចំក្រុមដែលមានសមាជិក៣ ឬ៤នាក់ និងណែនាំសិស្សអំពីរបៀបនៃការបំពេញសកម្មភាពតាមកាលបរិច្ឆេទ ។ គ្រូប្រគល់កាតដែលមានព្រឹត្តិការណ៍ផ្សេងៗគ្នា ។ កិច្ចការរបស់សិស្សគឺដាក់កាតទាំងនោះទៅតាមកាលវេលាជាលំដាប់លំដោយ ។ បន្ទាប់មក គ្រូឲ្យសិស្សពន្យល់អំពីរបៀបដែលខ្លួនរៀបកាតតាមលំដាប់លំដោយ ។ សិស្សត្រូវតែផ្ដល់មូលហេតុថា តើហេតុអ្វីបានដាក់ព្រឹត្តិការណ៍មួយមុន ឬក្រោយព្រឹត្តិការណ៍ដទៃទៀត ។ ឧទាហរណ៍ សិស្សគួរពន្យល់ថា "មូលហេតុរបស់ខ្ញុំសម្រាប់ការរៀបចំនេះគឺថា..." បន្ទាប់មកគ្រូធ្វើការកែតម្រូវ និងសរុបបញ្ជីថ្ងៃខែ ។ គ្រូប្រាប់សិស្សឲ្យសរសេរកាលបរិច្ឆេទទាំងនេះទៅតាមពេលវេលាត្រឹមត្រូវ ហើយឡើងពន្យល់ទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។

**បញ្ជីគំរូនៃព្រឹត្តិការណ៍ និងការតំរៀបតាមលំដាប់លំដោយ (អក្សរដិតគឺជាចម្លើយ)**

១) សម្ដេចព្រះ នរោត្ដម សីហនុ ត្រូវបានដកហូតតំណែងនៅ **(ខែមីនា ឆ្នាំ១៩៧០)** ។

២) កងកម្លាំងខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅ **(ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥)** ។

៣) គម្រោងផែនការបួនឆ្នាំដំបូងរបស់ខ្មែរក្រហមពីឆ្នាំ **(ឆ្នាំ១៩៧៧-ឆ្នាំ១៩៨០)** ។

៤) សង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម **(ឆ្នាំ១៩៧៧-ឆ្នាំ១៩៧៨)** ។

៥) ការវាយដណ្ដើមយកទីក្រុងភ្នំពេញ និងការដួលរលំរបស់របបកម្ពុជាប្រជាធិបតេយ្យនៅ **(ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩)** ។

*ការបង្រៀន (២០-៤៥នាទី)*

ពេលអានត្រួសៗនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ក្រុមសិស្សទាំងអស់ត្រូវកត់ត្រានូវព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យឲ្យបានច្រើនតាមដែលអាចធ្វើទៅបាននៅក្នុងសកម្មភាពទី១ ។ នៅក្នុងសកម្មភាពទី២ សិស្សពិភាក្សា និងវាយតម្លៃព្រឹត្តិការណ៍ទាំងនោះ និងកំណត់ព្រឹត្តិការណ៍សំខាន់ៗជាងគេចំនួន៥ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ សិស្សឡើងពន្យល់ពីការរកឃើញនេះនៅក្នុងថ្នាក់ ។ នៅក្នុងសកម្មភាពទី៣ គ្រូកំណត់ព្រឹត្តិការណ៍ដ៏មានសារសំខាន់មួយទៅឲ្យក្រុមទាំងអស់ ហើយណែនាំឲ្យសិស្សពិភាក្សា និងវាយតម្លៃថា តើព្រឹត្តិការណ៍មួយនេះមានផលប៉ះពាល់មកលើសង្គមកម្ពុជាដូចម្តេចខ្លះ ។ ជាងនេះទៅទៀត គ្រូណែនាំសិស្សឲ្យពិចារណាថា តើប្រទេសកម្ពុជា និងប្រជាជនកម្ពុជាមានភាពខុសប្លែកគ្នាយ៉ាងដូចម្តេចខ្លះ ប្រសិនបើព្រឹត្តិការណ៍នោះមិនបានកើតឡើង ។ រាល់សកម្មភាពទាំងអស់ តម្រូវឲ្យក្រុមទាំងអស់ឡើងពន្យល់អំពីការរកឃើញរបស់ខ្លួន ។

*សកម្មភាពទី១ ៖ ការកំណត់កាលបរិច្ឆេទ*

ផ្តល់ពេលវេលាឲ្យសិស្ស១០នាទី ដើម្បីធ្វើការជាមួយក្រុមក្នុងការកំណត់កាលបរិច្ឆេទមួយនៃរបបខ្មែរក្រហម ដោយប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ។ សិស្សឡើងពន្យល់កាលបរិច្ឆេទដែលខ្លួនបានរៀបចំទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។

*សកម្មភាពទី២ ៖ ការវិភាគនៅក្នុងក្រុម*

គ្រូរក្សាក្រុមទាំងអស់ឲ្យនៅដដែលដូចដែលបានកំណត់នៅក្នុងសកម្មភាពទី១ និងណែនាំឲ្យសិស្សពិភាក្សានៅក្នុងក្រុមរៀងៗខ្លួននូវអ្វីដែលខ្លួនជឿជាក់ថា ជាព្រឹត្តិការណ៍សំខាន់ៗជាងគេចំនួន៥ ដែលកើតមានឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមទាំងនោះគួរពិភាក្សាអំពីមូលហេតុដែលខ្លួនគិតថា ព្រឹត្តិការណ៍ទាំង៥នេះ ជាព្រឹត្តិការណ៍ដែលមានសារសំខាន់បំផុត ។ ក្រុមនីមួយៗត្រូវរៀបចំការឡើងពន្យល់អំពីសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលមានរយៈពេលពី៥-១០នាទី ។

ការឡើងពន្យល់របស់ក្រុមវិភាគ ៖ ក្រុមនីមួយៗមានពេល៥-១០នាទីដើម្បីឡើងពន្យល់ការរកឃើញរបស់ខ្លួន ។ គោលបំណងនៃសកម្មភាពនេះ គឺដើម្បីឲ្យសិស្សពន្យល់អំពីព្រឹត្តិការណ៍សំខាន់ជាងគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យចំនួន៥ និងពន្យល់ថា តើហេតុអ្វីបានជាក្រុមទាំងនោះយល់ថា ព្រឹត្តិការណ៍ទាំង៥នេះ មានសារសំខាន់ជាងព្រឹត្តិការណ៍ផ្សេងៗទៀត ។

*សកម្មភាពទី៣ ៖ ការវាយតម្លៃនៅក្នុងក្រុម*

គ្រូកំណត់ឲ្យក្រុមនីមួយៗវិភាគព្រឹត្តិការណ៍ច្បងជាក់លាក់មួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលសមាជិកក្រុមទាំងអស់ឬភាគច្រើនគិតថាមានសារសំខាន់ ។ គោលបំណងនៃកិច្ចការនេះ គឺដើម្បីឲ្យក្រុមនីមួយៗពិភាក្សា និងកំណត់ថា តើប្រទេសកម្ពុជានឹងមានភាពខុសប្លែកបែបណា ប្រសិនបើព្រឹត្តិការណ៍នេះមិនបានកើតឡើងឬកើតឡើងរបៀបផ្សេង ។

បន្ទាប់ពីបញ្ចប់ការពិភាក្សា ក្រុមនីមួយៗត្រូវរៀបចំការឡើងពន្យល់ការរកឃើញទាំងឡាយរបស់ខ្លួនទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។ ការឡើងពន្យល់គួរផ្តោតទៅលើសំណួរ២ដូចខាងក្រោម ៖

១) តើប្រទេសកម្ពុជាទទួលរងផលប៉ះពាល់ពីព្រឹត្តិការណ៍នេះដោយរបៀបណា?

២) ប្រសិនបើព្រឹត្តិការណ៍នេះមិនបានកើតឡើង ឬកើតឡើងរបៀបផ្សេង តើសង្គមកម្ពុជាមានសភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ?

*សំយោគ (១៥-២៥នាទី)*

បន្ទាប់ពីបញ្ចប់សកម្មភាពកំណត់កាលបរិច្ឆេទរួចមក គ្រូណែនាំក្រុមនីមួយៗឲ្យឡើងពន្យល់នៅមុខសិស្សទាំងអស់នៅក្នុងថ្នាក់ និងសង្ខេបអ្វីដែលខ្លួនបានរៀន ។ បន្ទាប់ពីសិស្សបានបញ្ចប់ពីការធ្វើបទបង្ហាញរបស់ខ្លួន ក្រោយការវាយតម្លៃអំពីអត្ថប្រយោជន៍ និងការរីកចម្រើនពីសកម្មភាពទាំងនេះនឹងត្រូវធ្វើឡើង ។ គ្រូត្រូវសួរសំណួរដូចខាងក្រោម ៖

១) តើអ្នកបានរៀនអំពីសកម្មភាពនេះដូចម្ដេចខ្លះ?

២) តើអ្នកចង់រៀនអំពីអ្វីទៀត ទាក់ទងនឹងព្រឹត្តិការណ៍សំខាន់ៗនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ?

៣) តើអ្នកចូលចិត្តអំពីសកម្មភាពនេះដូចម្ដេចខ្លះ?

៤) តើអ្នកមិនចូលចិត្តអំពីសកម្មភាពនេះដោយសារអ្វី?

## មេរៀនទី៣ : ការវិភាគលើមនោគមន៍វិជ្ជារបស់ខ្មែរក្រហម



ទង់ជាតិកម្ពុជាប្រជាធិបតេយ្យ ។ មាត្រា១៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ រៀបរាប់ពីការរចនា និងអត្ថន័យរបស់ទង់ជាតិ ។ ផ្ទៃខាងក្រោយមានពណ៌ក្រហម និងមានប្រាសាទកំពូល៣ពណ៌លឿងនៅចំកណ្ដាល ។ ផ្ទៃពណ៌ក្រហមតំណាងឲ្យចលនាបដិវត្តន៍ ការតស៊ូយ៉ាងអង់អាចក្លាហានរបស់ប្រជាជនកម្ពុជា ដើម្បីរំដោះ ការពារ និងកសាងប្រទេស ។ ប្រាសាទពណ៌លឿងតំណាងឲ្យប្រពៃណីជាតិ ប្រជាជនកម្ពុជាដែលជាអ្នកការពារ និងកសាងជាតិឲ្យក្លាយជាប្រទេសថ្កុំថ្កើងរុងរឿង ។ ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

### វត្ថុបំណង

១) សិស្សវិភាគ និងវាយតម្លៃពាក្យស្លោករបស់ខ្មែរក្រហម ដើម្បីអភិវឌ្ឍការយល់ដឹងអំពីមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ខ្មែរក្រហម ។

២) សិស្សដោះស្រាយបញ្ហាដែលប្រកបដោយភាពចម្រូងចម្រាស នៅក្នុងលក្ខណៈមួយដែលមានអត្ថន័យបំផុត ។

៣) សិស្សពិចារណាទៅលើសីលធម៌ និងជំនឿផ្ទាល់ខ្លួន ។

៤) សិស្សកំណត់និយមន័យនៃពាក្យស្លោក និងមនោគមន៍វិជ្ជា ។

***សម្ភារឧបទេស*** **:** សៀវភៅប្រវត្តិសាស្ត្រ សៀវភៅលំហាត់ និងបញ្ជីពាក្យសំខាន់ៗ ។

**លំនាំបង្រៀន**

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូណែនាំសិស្សអំពីវត្ថុបំណងនៃមេរៀននៅក្នុងថ្ងៃនេះ និងពន្យល់អំពីមូលដ្ឋាននិងសារសំខាន់នៃសីលធម៌និងជំនឿ ។ គ្រូឲ្យសិស្សពិភាក្សាអំពីមនោគមន៍វិជ្ជា នយោបាយ និងនិយមន័យនៃពាក្យស្លោករបស់ខ្មែរក្រហម ។

សកម្មភាពនេះមានលក្ខណៈជាការបំផុសគំនិតដែលគ្រូត្រូវអានពាក្យស្លោក បន្ទាប់មកសួរសំណួរទី១ ដល់១៣ ខាងក្រោម ទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។

**បញ្ជីពាក្យស្លោក :**

កំណត់ចំណាំ : លេខទំព័រនីមួយៗ គឺយោងទៅលើសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

១) លាក់ការណ៍ជាកត្តាជ័យជម្នះ ។ លាក់ការណ៍ខ្ពស់ រស់បានយូរ ។ (សូមមើលទំព័រទី៧)

២) អ្នក១៧មេសាជាជនបញ្ញើក្អែក ។ អ្នក១៧មេសា គឺជាអ្នកចាញ់សង្គ្រាម និងជាឈ្លើយសឹក ។ (សូមមើលទំព័រទី៣៨)

៣) ទុកក៏មិនចំណេញ ដកចេញក៏មិនខាត ។ (សូមមើលទំព័រទី៣៨)

៤) បដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ ។ (សូមមើលទំព័រទី៤២)

៥) អង្គការគ្មានទេសញ្ញាប័ត្រ មានតែសញ្ញាឃើញ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅទំនប់ ប្រឡាយ ។ (សូមមើលទំព័រទី៤៣)

៦) ការរៀនអក្សររៀនលេខមិនសំខាន់ទេ ការសំខាន់គឺការងារ និងចលនាបដិវត្តន៍ ។ (សូមមើលទំព័រទី ៤៣)

៧) អង្គការយកម្លប់ឈើធ្វើជាសាលារៀន និងកន្ទែងធ្វើមីទ្ទីង ។ (សូមមើលទំព័រទី៤៣)

៨) ធ្វើបណ្តើររៀនបណ្តើរ ធ្វើកាន់តែច្រើន ចេះកាន់តែច្រើន ។ (សូមមើលទំព័រទី៤៣)

៩) អង្គការជាឪពុកម្តាយរបស់កុមារាកុមារី និងយុវជនយុវនារី ។ បើម៉ែឪវាយកូន មានន័យថាមើលងាយអង្គការ ដូច្នេះអង្គការមិនប្រណីឡើយ ។ (សូមមើលទំព័រទី៤៥)

១០) អង្គការជាម៉េច ត្រូវធ្វើយ៉ាងហ្នឹង! អង្គការដាក់ទិស ត្រូវអនុវត្តឲ្យបានសម្រេច! មិត្តមិនបាច់គិតថ្ងៃ! ។ (សូមមើលទំព័រទី៥៥)

១១) ត្រូវចេះតាមដានគ្នាទៅវិញទៅមក ។ ត្រូវរាយការណ៍ជូនអង្គការ ។ (សូមមើលទំព័រទី៥៥)

១២) សុខចិត្តចាប់ខុស១០ មិនឲ្យលែងខុស១ ។ (សូមមើលទំព័រទី៥៦)

១៣) ជីកស្មៅ ត្រូវជីកទាំងឫស ។ (សូមមើលទំព័រទី៥៧)

**កំណត់ចំណាំសម្រាប់គ្រូ** : ចម្លើយអាចប្រែប្រួល ។ គោលបំណងគឺដើម្បីឲ្យសិស្សត្រឡប់ទៅអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រង់ទំព័រដែលមានទំនាក់ទំនងនឹងពាក្យស្លោក ដើម្បីយល់អំពីអត្ថន័យនៃពាក្យស្លោកទាំងនេះ ។ បន្ទាប់មកសិស្សត្រូវរកចម្លើយចំពោះសំណួរណែនាំទាំងអស់ និងតម្រូវឲ្យមានការពិចារណាយ៉ាងល្អិតល្អន់ ។ ដោយសារហេតុផលនេះហើយ បានជាសៀវភៅណែនាំនេះមិនកំណត់ឲ្យមានចម្លើយត្រូវ ឬល្អឥតខ្ចោះនោះទេ ។ សិស្សត្រូវតែ

ផ្តល់គំនិតផ្ទាល់ខ្លួនចំពោះសំណួរទាំងនេះ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សសរសេរតែងសេចក្តីមួយអំពីមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ខ្មែរក្រហម ។ សិស្សអាចប្រើសំណួរណែនាំខាងក្រោមជាជំនួយដល់ការវាយតម្លៃអំពីមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ខ្មែរក្រហម ។

១) តើពាក្យស្លោកជាក់លាក់ណាមួយឬក្រុមណាខ្លះ ដែលបានបង្ហាញអំពីរបបខ្មែរក្រហម?

២) តើពាក្យស្លោកទាំងនោះមានគោលបំណងអ្វី? អ្នកណាខ្លះជាអ្នកទទួលពាក្យស្លោកទាំងនោះ?

៣) តើការព្យាយាមអនុវត្តពាក្យស្លោកទាំងនោះ គឺដើម្បីទទួលបានអ្វីមកវិញ?

៤) តើពាក្យស្លោកនេះមានចំណុចទាក់ទាញអ្វីខ្លះ? ហេតុអ្វីបានជាប្រជាជនមានការជំរុញលើកទឹកចិត្តដោយសារតែពាក្យស្លោកទាំងនោះ?

៥) តើពាក្យស្លោកទាំងនោះត្រូវបានផ្សព្វផ្សាយដោយរបៀបណា? តើពាក្យស្លោកទាំងនោះ មានផលប៉ះពាល់មកលើប្រជាជនយ៉ាងដូចម្តេចខ្លះ?

សិស្សអាចប្រើប្រាស់ពាក្យស្លោកទាំងឡាយខាងលើ ដែលត្រូវបានប្រើប្រាស់នៅក្នុងរយៈកាលនៃរបបខ្មែរក្រហមជាផ្នែកនៃការសរសេរកថាខណ្ឌរបស់ខ្លួន ។ កិច្ចការរបស់សិស្សគឺវិភាគពាក្យស្លោកទាំងនេះដែលទាក់ទងនឹងមនោគមន៍វិជ្ជា គោលនយោបាយរបស់ខ្មែរក្រហម និងផលប៉ះពាល់មកលើប្រជាជនកម្ពុជា ។ សិស្សអាចវិភាគទៅលើពាក្យស្លោកមួយឬច្រើន ។ វាគឺជាជម្រើសរបស់សិស្ស ។ សូមមើលតារាងខាងក្រោមសម្រាប់ការដាក់ពិន្ទុលើការបកស្រាយរបស់សិស្ស ។

ប្រសិនបើសិស្សមានការភាន់ច្រឡំអំពីគោលបំណងនៃការបកស្រាយ ឬត្រូវការជំនួយក្នុងការសរសេរ គ្រូអាចចំណាយពេលពី៥ ទៅ១០ នាទី ដើម្បីពន្យល់សំណួរណែនាំខាងលើ ។

*សំយោគ (១៥-២៥នាទី)*

សិស្សឡើងពន្យល់ការបកស្រាយរបស់ខ្លួន និងពន្យល់ពាក្យស្លោកដែលគ្រូផ្តល់ឲ្យ ។

**ការវាយតម្លៃ**

កិច្ចការរបស់សិស្សនឹងត្រូវបានដាក់ពិន្ទុ ដោយប្រើប្រាស់តារាងខាងក្រោមដែលមានសំណុំនៃធាតុផ្សំសម្រាប់វាយតម្លៃកិច្ចការរបស់ខ្លួន ។

**តារាងដាក់ពិន្ទុទៅលើការវិភាគអំពីមនោគមន៍វិជ្ជារបស់ខ្មែរក្រហម**

| គោលបំណង | មិនឆ្លើយទៅនឹងសំណួរ | ឆ្លើយទៅនឹងសំណួរ |
|---|---|---|
| សំណួរណែនាំទី១ | ០ ពិន្ទុ | ១ពិន្ទុ |
| សំណួរណែនាំទី២ | ០ ពិន្ទុ | ១ពិន្ទុ |
| សំណួរណែនាំទី៣ | ០ ពិន្ទុ | ១ពិន្ទុ |
| សំណួរណែនាំទី៤ | ០ ពិន្ទុ | ១ពិន្ទុ |
| សំណួរណែនាំទី៥ | ០ ពិន្ទុ | ១ពិន្ទុ |
| ពិន្ទុសរុប | | |

# ជំពូក៨ : ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ





*ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនធ្វើការងារដោយកម្លាំងបាយក្នុងសភាពយ៉ាប់យ៉ឺនជាពន់ពេក និងទទួលបានរបបអាហារតិចតួចបំផុត ។*
***រូបខាងលើ*** *: កងស្រ្តីកំពុងសាងសង់ឃ្លាំង ។* ***រូបខាងក្រោម*** *: កងយុវជនកំពុងធ្វើស្រែ ។ ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

## មេរៀនទី១ ៖ អំណានជំពូក៧ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### វត្ថុបំណង

១) សិស្សពន្យល់គំនិតសំខាន់ៗអំពីជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សវិភាគប្រកបដោយការត្រិះរិះពិចារណាថា តើជីវិតមានលក្ខណៈយ៉ាងដូចម្តេចនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។

៣) សិស្សកំណត់និយមន័យនៃពាក្យសំខាន់ៗមួយចំនួន ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃនៅក្រោមរបបខ្មែរក្រហម ។

៤) សិស្សវាយតម្លៃព័ត៌មាន និងភ័ស្តុតាងអំពីគ្រួសារ និងអ្នកដទៃទៀត ។

**សម្ភារឧបទេស ៖** សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

**ពន្យល់ពាក្យ ៖**

| | | |
|---|---|---|
| ប្រជាជនមូលដ្ឋាន | ប្រជាជនថ្មី | កសាង-រៀនសូត្រ |
| បន្សុទ្ធកម្ម | អ្នកស្មោះត្រង់ | ការសម្លាប់រង្គាល |
| ការសម្លាប់ | ភ្នាក់ងារស៊ើបការណ៍សម្ងាត់សូវៀត (កា-ហ្សេ-បេ) | ភ្នាក់ងារស៊ើបការណ៍សម្ងាត់អាមេរិក (សេ-អ៊ី-អា) |

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងដឹកនាំការពិភាក្សាពីអ្វីដែលសិស្សបានដឹងអំពីជីវិតរស់នៅប្រចាំថ្ងៃក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក គ្រូឲ្យសិស្សពិភាក្សាលើពាក្យសំខាន់ៗនៅក្នុងជំពូក៧ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអាន និងកត់ត្រាដោយយកចិត្តទុកដាក់ទៅលើព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជំពូក៧ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយសរសេរព្រឹត្តិការណ៍ទាំងនេះនៅក្នុងសៀវភៅលំហាត់របស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សនៅក្នុងថ្នាក់ទាំងអស់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) ហេតុអ្វីបានជាខ្មែរក្រហមបង្កើតសហករណ៍? **ដើម្បីសម្រួលដល់ដំណើរការលុបបំបាត់ចោលនូវកម្មសិទ្ធិឯកជន និងមូលធននិយម និងដើម្បីពង្រឹងឋានៈរបស់កម្មករ និងកសិករ ។**

២) ចំពោះខ្មែរក្រហម តើសហករណ៍មានន័យយ៉ាងដូចម្តេច? **សហករណ៍មានន័យថា ប្រជាជនត្រូវរស់នៅជាមួយគ្នា ធ្វើការងារជាមួយគ្នា ហូបជាមួយគ្នា និងចូលរួមប្រជុំជីវភាពនៅក្នុងការរៀនសូត្រ អប់រំឃោសនាជាមួយគ្នា ។**

៣) តើវណ្ណៈសង្គមថ្មី២នៅក្នុងរបបខ្មែរក្រហមមានអ្វីខ្លះ? **ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ។ ហេតុអ្វីបានជាខ្មែរ**

**ក្រហមធ្វើការបែងចែកក្រុមមនុស្សយ៉ាងដូច្នេះ? ចម្លើយអាចមានច្រើន ។**

៤) *សូមឲ្យលក្ខណៈសម្គាល់យ៉ាងតិច២ ចំពោះ«ប្រជាជនមូលដ្ឋាន» ៖*

- **រស់នៅតំបន់ជនបទដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។**
- **ត្រូវបានចាត់ទុកថា ជាប្រជាជនពេញសិទ្ធិ ។**
- **ត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ឈរឈ្មោះឲ្យគេបោះឆ្នោត និងធ្វើជាប្រធានសហករណ៍ ។**
- **ជាទូទៅ មិនមានបងប្អូនដែលធ្លាប់បម្រើការឲ្យរបបសាធារណរដ្ឋខ្មែរទេ ។**

៥) *សូមឲ្យលក្ខណៈសម្គាល់យ៉ាងតិច២ ចំពោះ«ប្រជាជនថ្មី» ៖*

- **អ្នក១៧មេសា ។**
- **ត្រូវបានជម្លៀសចេញពីទីក្រុង និងទីប្រជុំជននានា នៅខែមេសាឆ្នាំ១៩៧៥ ។**
- **ត្រូវបានចាត់ទុកថា ជាមនុស្សមិនអាចជឿទុកចិត្តបាន ។**
- **ទទួលការមាក់ងាយ និងសង្ស័យពីសំណាក់អង្គការ ។**
- **ត្រូវបានចាត់ទុកជា«ជនបញ្ញើក្អែក» និងមានសិទ្ធិតិចតួចណាស់ (បើយោងតាមពាក្យស្លោករបស់ខ្មែរក្រហម) ។**
- **ជាញឹកញាប់ទទួលរងការធ្វើទុក្ខបុកម្នេញយ៉ាងឃោរឃៅអាស្រ័យទៅតាមតំបន់ ។**

៦) *តើស្ត្រី និងបុរសនៅក្នុងរបបខ្មែរក្រហមរៀបការយ៉ាងដូចម្តេច?* **រៀបការនៅក្នុងពិធីរួមមួយដែលពិធីតូចមានពី៣ទៅ១០គូ ហើយពិធីធំមានពី៣០ទៅ១០០គូនៅក្នុងពិធីនីមួយៗ ។ តើពិធីរៀបការបែបនេះមានលក្ខណៈខុសពីពិធីរៀបការតាមបែបប្រពៃណីខ្មែរដូចម្តេចខ្លះ? ចម្លើយអាចមានច្រើន ។**

៧) *ហេតុអ្វីបានជាខ្មែរក្រហមប្រើប្រាស់ពិធីមង្គលការរួម?* **ខ្មែរក្រហមយល់ឃើញថា ពិធីរៀបមង្គលការ គឺជាការចំណាយពេលឥតប្រយោជន៍ ហើយមិនបានជួយអ្វីទាំងអស់ដល់ការបង្កបង្កើនផល ។ ពិធីមង្គលការរួមត្រូវបានធ្វើឡើង ពីព្រោះត្រូវចំណាយពេលតិច ហើយពេលវេលាដែលនៅសល់នឹងត្រូវចំណាយទៅលើការងារសហករណ៍ និងអ្វីដែលខ្មែរក្រហមហៅថា «បដិវត្តន៍មហាលោតផ្លោះ មហាអស្ចារ្យ» ។ គោលបំណងសំខាន់នៃការរៀបមង្គលការ គឺមិនមែនដើម្បីបង្កើតក្រុមគ្រួសារនោះទេ ប៉ុន្តែដើម្បីបង្កើតកូនក្មេងដែលអាចបម្រើបដិវត្តន៍បាន ។**

៨) *តើការផ្តោតការយកចិត្តទុកដាក់ជាបឋមនៅក្នុងការអប់រំរបស់ខ្មែរក្រហមគឺអ្វី?* **គឺការអប់រំនយោបាយ ។**

៩) *តើការអប់រំដ៏ល្អបំផុតរបស់ខ្មែរក្រហមស្ថិតនៅកន្លែងណា?* **កន្លែងធ្វើការ វាលស្រែ ទំនប់ ប្រឡាយ និងកន្លែងធ្វើពលកម្មដទៃទៀត ។**

១០) *តើការងារមួយថ្ងៃក្នុងរបបខ្មែរក្រហមមានរយៈពេលប៉ុន្មានម៉ោង?* **មនុស្សស្ទើរគ្រប់រូបដែលមិនមានជំងឺធ្វើការច្រើនជាង១២ម៉ោងក្នុងមួយថ្ងៃ ជាញឹកញយ៧ថ្ងៃក្នុងមួយសប្តាហ៍ដោយមិនមានពេលសម្រាក និងមិនមាន ម្ហូបអាហារគ្រប់គ្រាន់ឡើយ ។**

១១) *បន្ទាប់ពីការប្រយុទ្ធគ្នាជាមួយវៀតណាមនៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ តើខ្មែរក្រហមបានប្រព្រឹត្តទៅលើប្រជាជនក្នុងភូមិភាគបូព៌ាយ៉ាងដូចម្តេចខ្លះ?* **ខ្មែរក្រហមបានចោទប្រកាន់ប្រជាជន និងអតីតកម្មាភិបាលនៅ**

**ក្នុងភូមិភាគបូព៌ាថា បានសហការជាមួយវៀតណាមដែលនាំទៅដល់ការចាប់ខ្លួន និងសម្លាប់ចោលមនុស្សជាច្រើនដែលរួមទាំងដៃគូនយោបាយស្មោះត្រង់ដ៏យូរលង់ផង ដូចជា សោ ភឹម ដែលបានធ្វើអត្តឃាតខ្លួនឯង ។**

១២) តើតំបន់ណាខ្លះដែលបានរៀបរាប់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលកើតមានចលនារដ្ឋប្រហារ ការបះបោរ និងបន្សុទ្ធកម្ម **កងទ័ពនៅភូមិភាគបូព៌ាបានបះបោរប្រឆាំងនឹងកងទ័ពកម្ពុជាប្រជាធិបតេយ្យ ។ ការបះបោរក៏កើតមានឡើងនៅភូមិភាគនិរតី និងភូមិភាគខត្តរដែរ ។**

## មេរៀនទី២ ៖ កំណត់ហេតុអំពីជីវិតរបស់ខ្ញុំក្រោមរបបខ្មែរក្រហម



*ក្មេងស្រីកំពុងត្បាញអំបោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

### វត្ថុបំណង

១) សិស្សប្រើប្រាស់ព័ត៌មានដែលខ្លួនបានរៀនអំពីជីវិតនៅក្នុងរបបខ្មែរក្រហម ដើម្បីសរសេរអំពីស្ថានភាពរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សវិភាគ និងវាយតម្លៃអំពីផលប៉ះពាល់នៃការរស់នៅក្នុងរបបខ្មែរក្រហមមកលើខ្លួន ក្រុមគ្រួសាររបស់ខ្លួន និងប្រជាជនកម្ពុជាទាំងមូល ។

៣) សិស្សរៀបរាប់អំពីស្ថានភាពរស់នៅជាមូលដ្ឋាននៅក្នុងរបបខ្មែរក្រហម ។

៤) សិស្សពន្យល់អំពីគោលនយោបាយរបស់របបខ្មែរក្រហម ដែលបានបង្កើតឡើងនូវស្ថានភាពរស់នៅបែបនេះ ។

**សម្ភារឧបទេស ៖** សៀវភៅប្រវត្តិសាស្ត្រ សេចក្តីដកស្រង់ពីសៀវភៅកំណត់ហេតុ និងសៀវភៅលំហាត់ ។

# ភាពរន្ធត់ និងការឈឺចាប់ ដែលខ្ញុំបានជួបប្រទះជាលើកទី១ ដែលមិនអាចបំភ្លេចបាន

***ឡឿ សេរីឡែន***

*នៅឆ្នាំ១៩៧៥ ខ្ញុំនៅវ័យកុមារនៅឡើយ ហើយរស់នៅក្នុងឋានៈខ្ពង់ខ្ពស់ ដោយសារប៉ាជាមន្ត្រីរាជការមានឋានន្តរសក្តិក្នុងជួរយោធា ។ ខ្ញុំជាកូនពៅក្នុងចំណោមបងប្អូនប្រាំបួននាក់ (ប្រុស៧ ស្រី២) ។*

*ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំត្រូវបង្ខំចិត្តចេញពីផ្ទះទៅស្នាក់នៅផ្ទះបងប្អូននៅមុំផ្សារអូរឬស្សី ព្រោះផ្ទះរបស់ខ្ញុំជាមុខសញ្ញាដែលគេត្រូវផ្លោងគ្រាប់កម្ទេច (ជាផ្ទះរដ្ឋ នៅក្នុងបន្ទាយឃ្លាំងរំសេវ) ។ យើងពុំបានយកទ្រព្យសម្បត្តិអ្វីទាំងអស់ក្រៅពីគ្រឿងអលង្ការដែលពាក់ជាប់នឹងខ្លួន ។*

*នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពីឈរទះដៃអបអរសាទរជ័យជម្នះរបស់ខ្មែរក្រហម ប្រជាជនត្រូវបានជម្លៀសចេញពីទីក្រុង ។ គ្រួសារខ្ញុំគ្មានសម្ភារអ្វីជាប់ខ្លួនក្រៅពីឡានបីគ្រឿងម៉ាក មែរសីដេស ហ៊ីមបឺរស្ព័រ និង អូស្ទីន ដែលដឹកលោកតាខាងប៉ាដែលឈឺស្ទាប់មួយចំហៀងខ្លួន សមាជិកគ្រួសារមានគ្នា១៣នាក់ និងក្រុមគ្រួសារមិត្តភក្តិរបស់ម៉ាក់ ដែលជម្លៀសខ្លួនពីតាខ្មៅចំនួន២២នាក់ទៀត ។*

*ប៉ាបានជូនឡានអូស្ទីនដល់មិត្តភក្តិរបស់ម៉ាក់ដើម្បីងាយស្រួលក្នុងការធ្វើដំណើររួមគ្នា ។ អ្នកដែលពេញកម្លាំងត្រូវជួយរុញឡាន ។ អ្នកដែលមានសិទ្ធិអង្គុយនៅក្នុងឡានមានតែក្មេងតូចៗ អ្នកកូនខ្ចី ចាស់ជរា និងម៉ាក់តែប៉ុណ្ណោះចំណែកបងស្រីជាអ្នកកាន់ចង្កូត ។ យើងធ្វើដំណើរដោយប្រើកម្លាំងផ្ទាល់ខ្លួនមិនបានប្រើម៉ាស៊ីនទេ ព្រោះតាមផ្លូវកកស្ទះទៅដោយហ្វូងមនុស្ស ។ ពីផ្សារអូរឬស្សីដល់វង្វង់មូលក្បាលថ្នល់ត្រូវចំណាយពេលមួយថ្ងៃពេញ ។ នៅតាមផ្លូវយើងគ្មានអ្វីទទួលទានក្រៅពីទឹកបន្តិចបន្តួចដើម្បីផ្សើមបំពង់កឡើយ ។ ខ្ញុំ និងក្មេងៗរួមដំណើរឃ្លានខ្លាំងណាស់យំទ្រហឹងពេញឡាន ។ លោកយាយអាណិតយើងក៏ដាច់ចិត្តដើរទៅសុំបាយអ្នកដទៃ ប៉ុន្តែមិនឃើញគាត់វិលត្រឡប់មករកឡានវិញទេ ហើយយើងក៏បែកគ្នារហូតដល់ពេលនេះ ។ ពេលនោះប៉ាខឹងណាស់ ហើយហាមផ្តាច់មិនឲ្យនរណាម្នាក់ចាកចេញឆ្ងាយពីឡានទេ បើគ្មានការអនុញ្ញាតពីគាត់ ទោះជាឃ្លានយ៉ាងណាក៏ដោយ ។ យប់មកដល់ យើងត្រូវផ្អាកដំណើរដើម្បីរកកន្លែងសម្រាក ។ ខ្ញុំយំរហូតគេងលក់ ព្រោះតាំងពីកើតមក នេះជាលើកដំបូងហើយដែលខ្ញុំជួបហេតុការណ៍បែបនេះ ។ ក្រោយភ្ញាក់ពីដេក ខ្ញុំលែងយំហើយ ទោះបីជាឃ្លានខ្លាំងក៏ត្រូវអត់ទ្រាំដែរ ព្រោះមេឃងងឹតខ្ញុំខ្លាចខ្មោច ហើយនៅជុំវិញខ្លួនសុទ្ធតែសាកសពហើម ភាយក្លិនស្អុយតិចៗ ។ ប៉ាបាននាំបងប្រុសធំទាំងពីរចេញទៅបាត់មួយសន្ទុះធំ ក៏ត្រឡប់មកវិញដោយនាំមកជាមួយនូវអង្ករមួយបាវ ទឹកពីរយួរ ទឹកត្រីមួយយួរ ឆ្នាំងពីរ កំសៀវមួយ ។ មួយសន្ទុះធំយើងក៏បានញ៉ាំបាយ ប៉ុន្តែគ្មានម្ហូបទេ គឺញ៉ាំជាមួយទឹកត្រី ។ ទាហានខ្មែរក្រហមបានមកឆែកឆេរឡានរបស់យើងរួចហើយសើចចំអកឲ្យយើង ព្រោះថាគ្មានអ្វីសោះក្រៅពីឆ្នាំងបាយ និងកំសៀវទឹក ។ ម៉ាក់នៅខឹងប៉ាដែលពុំស្តាប់តាមគាត់ ម្ល៉ោះហើយគាត់ពុំសូវនិយាយស្តីទេ ក្រៅតែពីសម្រក់ទឹកភ្នែក ។ ប៉ាតែងតែលួងលោមម៉ាក់ថា “បដិវត្តន៍សង្គមនិយមមិនសម្លាប់ជាតិឯងទេ យ៉ាងច្រើនគេធ្វើឲ្យស្មើភាព គ្មានអ្នកមាន គ្មានអ្នកក្រ ។ យើងមានផ្ទះ មានឡាន២–៣អ៊ីចឹងអង្គការនឹងដកទុកឲ្យយើងតែផ្ទះមួយឡានមួយប៉ុណ្ណោះ ។ ម៉ាក់មានគម្រោងចង់ធ្វើដំណើរតាមផ្លូវជាតិលេខ១ ប៉ុន្តែប៉ាជំទាស់ដាច់ខាត ព្រោះគាត់ជានាយទាហានធ្លាប់ច្បាំង ។ មូលហេតុទី១ ប៉ាស្អប់យួន ទី២ ប៉ាយល់ថាធ្វើដំណើរតាមផ្លូវទឹកប្រសើរជាងដូចពាក្យស្លោកថា “ស៊ូអត់បាយ កុំឲ្យអត់ទឹក” ។ យើងក៏ធ្វើដំណើរតាមផ្លូវព្រែកប្រាដែលនៅប្របដងទន្លេមេគង្គ ។*

*នៅតាមផ្លូវ ប៉ាបានដាក់ខ្លួនទៅជួយលីអង្ករ ថ្នាំជក់ឲ្យគេដើម្បីដូរយកអង្ករ ត្រី ប្រហុក ទៅតាមសេចក្តីអាណិតអាសូររបស់អ្នកមូលដ្ឋាន ។ ប៉ាលាក់ប្រវត្តិរូបដោយប្រាប់អ្នកដទៃថា គាត់ជានាយផ្នែកខាងកីឡាបាល់ទះ ។*

យើងគ្មានទិសដៅពិតប្រាកដទេ ព្រោះស្រុកកំណើតជាអ្នកភ្នំពេញ ម៉្លោះហើយប៉ាបានសុំប្រធានភូមិពោធិ៍អណ្តែត ស្រុកស្អាង ខេត្តកណ្តាល ដើម្បីស្នាក់នៅបណ្តោះអាសន្ន រង់ចាំអង្គការអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ ។ ប្រធានភូមិបាន អនុញ្ញាតឲ្យខ្ញុំ បងស្រីរបស់ខ្ញុំ កុមារតូចៗ និងមីងម្នាក់ដែលមានកូនខ្ចី ស្នាក់នៅផ្ទះរបស់គាត់ ចំណែកប៉ាម៉ាក់ខ្ញុំ និងមនុស្សចាស់ ផ្សេងទៀតស្នាក់នៅក្រោមដើមឈើក្បែរវត្តពោធិ៍អណ្តែត ។ ប្រធានភូមិនោះចូលចិត្តប៉ាណាស់ ព្រោះឃើញប៉ាខស្យាហ៍ និងចេះជួយអ្នកដទៃ ដោយមិនប្រកាន់ខ្លួន ។ មិនបានមួយខែផងប្រវត្តិរូបរបស់ប៉ាត្រូវបែកការណ៍ ដោយសារមីងមានកូនខ្ចី ដែលរួមដំណើរជាមួយយើងចាញ់ការលួងលោមរបស់ប្រធានភូមិនោះ ហើយបាននិយាយប្រាប់អំពីប្រវត្តិរបស់ប៉ា ។ បងស្រីខ្ញុំបានស្តាប់ឮការសន្ទនានោះ ។ គាត់ភិតភ័យយ៉ាងខ្លាំង ហើយធ្វើពុតជាចុកពោះដើម្បីចេញពីផ្ទះទៅផ្តល់ដំណឹងដល់ ប៉ាម៉ាក់ដែលនៅក្រោមដើមឈើ ។ ម៉ាក់បានអង្វរប៉ាឲ្យជួលទូកជិះរត់ទៅប្រទេសវៀតណាម ប៉ុន្តែប៉ាប្រកែកមិនព្រម ទៅជាដាច់ខាត ។

យប់មួយនោះ ម៉ាក់ និងបងៗនាំគ្នាដើរសួរអ្នកស្រុកពេញភូមិព្រោះបាត់ប៉ា ។ សូម្បីតែប្រធានភូមិ និងកងឈ្លប ក៏នាំគ្នា ជួយរកប៉ាដែរ ។ លុះរំលងអធ្រាត្រទើបមានអ្នកមកប្រាប់ថា ប៉ាត្រូវកងពិសេសមកពីភ្នំពេញហៅទៅសួរប្រវត្តិរូប នៅលើ វិហារ សូម្បីតែអ្នកស្រុកក៏ពុំអាចចូលទៅបានដែរ (នេះជាបញ្ឆោរអង្គការមជ្ឈិម) ។ ម៉ាក់លែងធ្វើអ្វីកើតក្រៅតែពីអង្គុយយំ ។ ប្រធានភូមិបានធានាជួយតាមដានរឿងនេះឲ្យ ។ ជិតភ្លឺទើបឃើញប៉ាត្រឡប់មកវិញ ។ ទាំងប្រធានភូមិ ទាំងកងឈ្លបបានមក សួរដេញដោលប៉ាពីរឿងអង្គការហៅទៅ ។ ប៉ាប្រាប់ថា អង្គការច្រឡំបងប្រុសរបស់គាត់ដែលជាអ្នកការទូត ហើយស្រពេចស្រពិលថា គាត់មិនមែនជាជនស៊ីវិល គឺជាទាហាន ហើយព្យាយាមសួរប៉ាជាច្រើនលើក ប៉ុន្តែប៉ានៅតែឆ្លើយថា គាត់ជាគ្រូ កីឡា ។ គាត់បានប្រាប់ប្រធានភូមិថា ពេលគាត់ធុញនឹងសំណួរដដែលៗ គាត់ក៏សួរទៅប្រធានភូមិវិញថា "បើគាត់ជាជនស៊ីវិល វាយ៉ាងម៉េច? បើគាត់មានសក្តិជាទាហានវាយ៉ាងម៉េច?" ប្រធានភូមិតបថា "អង្គការចង់ដឹងឲ្យច្បាស់ហើយនាំចូលធ្វើការ តាមមុខតំណែងវិញ" ។ ប៉ានៅតែឆ្លើយចម្លើយដដែល ទើបប្រធានភូមិឲ្យប៉ាត្រឡប់មកវិញ ។ ម៉ាក់ស្តាប់យ៉ាងយកចិត្តទុកដាក់ ហើយអង្វរប៉ាឲ្យនាំគ្នាគេចពីភូមិនេះ ប៉ុន្តែប៉ាមិនត្រឹមតែខឹងទេ ថែមទាំងចេសខ្លាំងណាស់ ។ គាត់អះអាងថា គ្មាននរណា សម្លាប់ជាតិសាសន៍ឯងទេ យ៉ាងច្រើនគេយកទៅអប់រំតែប៉ុណ្ណោះ ។

ដូចម៉ាក់បានគិតបារម្ភមែន មិនបានប៉ុន្មានផង ប្រធានភូមិបានមកហៅប៉ាឲ្យរៀបចំខោអាវ ដោយប្រាប់ថា "អង្គការ ហៅឲ្យទៅរៀនសូត្រ" ។ ប៉ាគ្មានខោអាវរៀបទេ ។ អ្នកទាំងអស់នាំគ្នាយំមានតែប៉ាម្នាក់ទេដែលនៅតែរឹងមាំដដែល ។ ប៉ា និយាយដោយម៉ឺងម៉ាត់ថា "ម៉ាក់នាំកូនៗឆ្គត" ។ ពាក្យដែលគាត់និយាយដដែលៗគឺ "កុំភ័យអង្គការមិនសម្លាប់ជាតិសាសន៍ ខ្លួនឯងទេ" ។ ប៉ាទៅបាត់មួយថ្ងៃ ម៉ាក់បានយកគ្រឿងអលង្ការទៅសូកប្រធានភូមិដើម្បីឲ្យគាត់ជូនបងប្រុសធំទៅមើលប៉ា ។ បងប្រុសបាននាំដំណឹងថា "ប៉ានៅមន្ទីរស្រុកមានគ្នាប្រហែល៥០នាក់ទៅជាមួយដូចជាទាហាន គ្រូ បង្រៀន ពេទ្យ..." ។ ម៉ាក់ បានធូរចិត្តបន្តិចព្រោះគិតថា គេមិនដែលយកគ្រូនិងពេទ្យទៅសម្លាប់ទេ ។ បងប្រុសធំក៏សុំម៉ាក់ទៅជាមួយប៉ាដើម្បីបាន ជាគ្នា ។ ម៉ាក់ក៏សុំយោបល់ពីប្រធានភូមិ ប្រធានភូមិក៏ទៅសុំគណៈស្រុក ហើយក៏បានទទួលការអនុញ្ញាត ។ រហូតមកដល់ ពេលនេះ ប៉ា និងបងប្រុសធំបាត់ដំណឹងសូន្យ ។ លោកតាបានស្លាប់នៅទីនោះដោយរោគរបស់គាត់ និងគ្មានថ្នាំព្យាបាល ។ ប្រហែលបីសប្តាហ៍ក្រោយមក មាននាវាធំៗចូលចតនៅមាត់ច្រាំងដើម្បីដឹកអ្នកថ្មីឲ្យទៅរស់នៅតាមទិសដៅដែលអង្គការ កំណត់ ។ ម៉ាក់អរណាស់ ព្រោះគាត់ចង់ចាកចេញពីភូមិនេះយូរហើយ ។ ប្រពន្ធប្រធានភូមិបានមកឱបម៉ាក់កុំឲ្យចាកចេញ ព្រោះអង្គការពុំបាននាំយើងទៅផ្ទះទេ ប៉ុន្តែម៉ាក់គិតថានៅក៏ស្លាប់ ទៅក៏ស្លាប់ ដូច្នេះគាត់ក៏សម្រេចចិត្តទៅ ។ នាវាទាំងអស់មាន

៤គ្រឿង ហើយបានដាក់អ្នកជម្លៀសពេញព្រៀបទាំង៤ សូម្បីតែនៅលើដំបូល ក៏មានមនុស្សជិះដែរ ។ ពេលមកដល់ទន្លេមុខបួន មានភ្លៀងធ្លាក់យ៉ាងធំហើយមានខ្យល់ខ្លាំងផង នាវាមួយគ្រឿងបានលិច ដោយសារប្រជាជនជ្រួលច្របល់ខ្លាំងពេក ។ ពេលនោះខ្ញុំពុំដឹងថា អ្នកណាស្លាប់អ្នកណារស់ទេ ព្រោះគ្មានអ្នកណាអើពើ ។ យើងនាំគ្នាឱបរឹតគ្នាយ៉ាងតឹង ព្រោះរងារដោយទឹកភ្លៀង និងខ្លាចប៉ើងតាមខ្យល់ធ្លាក់ទឹក ព្រោះមានក្មេងជាច្រើន បានប៉ើងធ្លាក់ទឹក ចំណែកម្តាយបានត្រឹមតែយំសោកព្រោះគ្មានអ្នកណាជួយ ។ ភ្លៀងរាំង យើងដោះខោអាវពូតឲ្យស្ងួត ។ យើងគ្មានខោអាវសម្រាប់ផ្លាស់ប្តូរទេ សំណាងល្អដែលម៉ាក់បានដាក់ថ្នាំតាមខ្លួនខ្លះឲ្យយើងលេបបង្ការគ្រុន ។

ពេញ២ថ្ងៃ១យប់ទើបយើងទៅដល់ខេត្តកំពង់ឆ្នាំង ។ ទាហានខ្មែរក្រហមឲ្យយើងចុះពីនាវា រួចបញ្ជូនយើងទៅស្នាក់នៅតាមផ្ទះទីកមួយយប់ ព្រឹកឡើងទើបបញ្ជូនតាមឡានទៅខេត្តពោធិ៍សាត់ ។ ទៅដល់ទីនោះ យើងត្រូវស្នាក់នៅហាលភ្លៀងហាលខ្យល់ពីរយប់តាមគែមផ្លូវរថភ្លើង ទើបមានរថភ្លើងមកដឹកទៅខេត្តបាត់ដំបង ។ ពេលនោះ ខ្ញុំ និងបងប្រុសទី២រិះតែព្រាត់ពីម៉ាក់ ព្រោះខ្ញុំរាកបងនាំទៅលាងទឹកក្បែរនោះ ហើយរថភ្លើងចេញចោល បានអ្នកនៅចុងទូឈោងទាញដៃបងប្រុសខ្ញុំដែលពខ្ញុំរត់តាម ។ ដល់រទេះភ្លើងឈប់ ទើបខ្ញុំ និងបងប្រុសដើររកម៉ាក់ឃើញ ។ ទៅដល់ខេត្តបាត់ដំបង ខ្មែរក្រហមចែកប្រជាជនថ្មីជាក្រុមៗ ហើយបញ្ជូនឡើងឡានទ្រុងទៅតាមស្រុកភូមិចុងកាត់មាត់ញក ។ ក្រុមគ្រួសារខ្ញុំជិះរទេះគោមករស់នៅភូមិចារ ឃុំអន្លង់វុន ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ផ្ទះក្បឿងមួយខ្នងនៅជុំគ្នា៧គ្រួសារ មានអ្នកថ្មី (អ្នក១៧មេសា) និងអ្នកមូលដ្ឋានចាស់ ក្នុងនោះក៏មានគ្រួសារកងឈ្លបដែរ ។ យើងបានជួបជុំគ្នាតែមួយយប់ប៉ុណ្ណោះ ។ ព្រឹកស្អែកឡើង អង្គការបានមកយកបងៗខ្ញុំទៅការដ្ឋានអស់ នៅតែខ្ញុំ និងម៉ាក់ ។ ដំបូងខ្ញុំត្រូវចូលរៀន ប៉ុន្តែខ្ញុំចេះអក្សរខ្លះហើយ (ព្រោះខ្ញុំរៀនថ្នាក់ទី១០ចាស់) ។ ម៉ាក់ត្រូវអង្គការចាត់តាំងឲ្យទៅដកស្ទូងតាមភូមិ ។ ម៉ាក់អត់ស្គាល់សំណាបទេ ហើយគាត់ត្រូវប្រធានកងកាត់របបជាញឹកញាប់ដោយចោទថា ធ្វើពុត ។ ដោយម៉ាក់ចេះតែឲ្យមាសពេជ្រ ទៅប្រធានកង ណាមួយដោយសារម៉ាក់ពិការជើងម្ខាងផង ទើបប្រធានកងឲ្យម៉ាក់មកមើលក្មេងៗក្បែររោងបាយ ។ មិនបានប៉ុន្មានថ្ងៃផង អង្គការបានបញ្ជូនខ្ញុំទៅកងកុមារ ខ្ញុំបានរត់មករកម៉ាក់ជាញឹកញាប់ហើយត្រូវប្រធានកងមកតាមចាប់វាយបណ្តើរទៅវិញ ។ ទម្រាំខ្ញុំទម្លាប់បាន ខ្ញុំត្រូវមេកងវាយទ្រមខ្លួន ហើយធ្លាក់ខ្លួនគ្រុនស្ទើរគ្មានពេលលស់ ។ ពេលដែលខ្លួនខ្ញុំឡើងកម្តៅខ្លាំងស្ទើរឆេះ ខ្ញុំគ្មានគិតអ្វីក្រៅពីហក់ចូលទឹកស្ទឹងដើម្បីសម្រន់កម្តៅឡើយ ។ ម៉ាក់តែងតែលួចលាក់យកមាសពេជ្រដែលមានជាប់ខ្លួនទៅដូរដោះយកម្ហូបអាហារសម្រាប់គាត់ និងខ្ញុំ ។ បងៗរបស់ខ្ញុំពុំដឹងទៅដល់ទីណាទេ ។ ខ្ញុំលួចរត់មករកម៉ាក់ជារៀងរាល់យប់ ហើយត្រឡប់ទៅវិញក្រោយពីជួបម៉ាក់មួយភ្លែត ព្រោះខ្លាចមេកងវាយធ្វើបាបទៀត ។ ក្មេងៗជាច្រើនត្រូវអង្គការបំពាក់បំប៉ន ហើយរាយការណ៍អំពីឪពុកម្តាយរបស់ខ្លួនឯង ប៉ុន្តែខ្ញុំចេះដឹងខ្លះ ខ្ញុំមិនដែលស្តាប់ការបំពាក់បំប៉នទាំងនោះទេ ។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការអនុញ្ញាតឲ្យចូលភូមិវិញដើម្បីកើបអាចម៍គោ និងកាប់ដើមទន្ទ្រានខេត្ត ។ ខ្ញុំឃើញបងស្រីរបស់ខ្ញុំ ដេកឈឺស្គមកំព្រឹងរាកមួលគ្មានអ្នកថែទាំ ។ គាត់ស្លាប់ដោយមាត់ទន្ទេញតែពាក្យថា ចង់ញ៉ាំពងទាចៀនស្អំ ។ បន្ទាប់មកបងប្រុសទី២ក៏ត្រូវបញ្ជូនមកវិញក្នុងសភាពខ្វិនជើងដោយសារដំបៅនៅត្រង់ជង្គង់ និងភ្នែកគោរ ហើយក៏ស្លាប់ទៀត ។

រវាងឆ្នាំ១៩៧៧ និង១៩៧៨ ភូមិរបស់ខ្ញុំត្រូវលិចទឹកគ្មានសល់ ។ ពេលនោះខ្ញុំឃើញអង្គការបញ្ជូនបងប្រុសខ្ញុំទាំង៥នាក់មកភូមិវិញក្នុងសភាពដុនដាបជាខ្លាំង គឺហើម និងរាកមួល ។ ម៉ាក់មិនអាចជួយអ្វីបងខ្ញុំក្រៅតែពីបង្ហូរទឹកភ្នែកដោយក្តីអាណិតអាសូរប៉ុណ្ណោះ ។ នៅទីបំផុតបងៗទាំង៥បានស្លាប់ក្នុងខែតែមួយ ។ ម៉ាក់ប្រៀបដូចជានាងបដាចារ ។ អារម្មណ៍លែងនឹងនរ ព្រោះសពអ្នកទាំង៥ត្រូវបណ្តែតទៅតាមទឹកដោយគ្មានដីកប់ ។ បើកុំតែសល់ខ្ញុំម្នាក់ កុំអីម៉ាក់ប្រហែលជាវិកល

ចរិតហើយ ។ ពេលនោះខ្ញុំគ្រាន់តែដឹងថា ស្រុកភូមិហាក់ដូចជាត្រូវផ្លាស់ប្តូរ ។ អង្គការបានបណ្តោយឲ្យប្រជាជនធ្វើអ្វីៗតាមចិត្ត គឺមានសិទ្ធិដើរពីភូមិមួយទៅភូមិមួយ ។ ប្រជាជននៅក្នុងភូមិខ្ញុំដែលសល់ពីស្លាប់ទាំងអ្នកចាស់ និងអ្នកថ្មីបាននាំគ្នាភៀសខ្លួនទៅរស់នៅដីគោក គឺប្រមូលផ្តុំទៅនៅដីទួលក្នុងវត្តមួយដែលខ្ញុំមិនចាំឈ្មោះ ។ ពេលនោះខ្ញុំឃើញប្រជាជនធ្វើដំណើរស្រទៅស្រមកដូរដោះរបស់គ្នាតាមទំនើងចិត្ត គឺគ្មានអ្នកណាត្រួតត្រាអ្នកណាទេ គឺរករស់តែរៀងៗខ្លួន ។ ក៏ប៉ុន្តែ សេរីភាពនេះមិនស្ថិតស្ថេរបានយូរទេ ។ អង្គការថ្មីមកពីនិរតីបានប្រមូលប្រជាជនឲ្យចូលភូមិវិញ ។ ទឹកចាប់ផ្តើមស្រកជាបណ្តើរៗ ។ ប្រជាជននៅក្នុងភូមិមិនថាចាស់ មិនថាថ្មីបានស្លាប់បន្តបន្ទាប់ ដោយអត់ឃ្លានផង ដោយការសម្លាប់ផង ។ ខ្ញុំកើតដំបៅពេញខ្លួន ប៉ុន្តែសំណាងល្អមិនប៉ះចំកន្លែងសំខាន់ដូចជាបងប្រុសរបស់ខ្ញុំ ទើបខ្ញុំចៀសផុតពីសេចក្តីស្លាប់ ។ ដំបៅខ្ញុំជាដោយសារឈ្លើងទាមផង ដោយការស្ងោរស្លឹកអម្ពិលលាងផង និងកម្ទេចសត្វគីង្គក់បុកឲ្យហ្មត់ រោយពីលើផង ហើយបន្សល់ស្លាកស្នាមធំៗពេញទាំងខ្លួន ។

យប់មួយ ម៉ាក់ត្រូវអង្គការបណ្តើរយកទៅដោយសារតែខ្ញុំ ។ គាត់បានពឹងអ្នកភូមិឲ្យជួយដូរមាន់មួយ ហើយគាត់ចែកឲ្យមនុស្សទាំងអស់ដែលនៅក្នុងផ្ទះជាមួយគ្នា ទុកតែភ្លៅសម្រាប់គាត់ និងខ្ញុំប៉ុណ្ណោះ ។ ខ្ញុំញាំមិនឆ្អែតក៏រករឿងគាត់ ហើយត្រូវគាត់ក្តិចឲ្យយំ ។ គាប់ជួនអង្គការដើរមកដល់ឮខ្ញុំយំ ក៏ហៅម៉ាក់ឲ្យចុះដី រួចបណ្តើរម៉ាក់ទៅក្នុងព្រៃ ។ អ្នកនៅក្នុងផ្ទះបានបន្ទោសខ្ញុំគ្រប់ៗគ្នា ថាជាអ្នកធ្វើឲ្យម៉ាក់ស្លាប់ ។ ពេលនោះខ្ញុំរន្ធត់ខ្លាំងណាស់ ខ្ញុំរត់ទៅរកម៉ាក់បណ្តើរស្រែកយំខ្លាំងៗប្រាប់អង្គការបណ្តើរថា "ខ្ញុំយំដោយខ្លួនឯង ម៉ាក់មិនបានធ្វើអីខ្ញុំទេ" ប៉ុន្តែខ្ញុំរត់រកម៉ាក់មិនឃើញឡើយ ។ ខ្ញុំចាំម៉ាក់នៅមាត់ជណ្តើរស្រែកយំថា "គាត់គ្មានកំហុស" រហូតដល់គេងលក់ ។ ខ្ញុំដឹងខ្លួនវិញនៅពេលមានតំណក់ទឹកក្តៅខណ្ឌៗធ្លាក់ចំថ្ពាល់ទើបខ្ញុំបើកភ្នែកឃើញម៉ាក់កំពុងយំឱបខ្ញុំ ។ ខ្ញុំអរខ្លាំងណាស់ប្រៀបដូចជាមានជីវិតម្តងទៀត ។

ម៉ាក់បានប្រាប់ថា អង្គការចាប់គាត់បណ្តើរទៅក្នុងព្រៃក្រោយភូមិ ។ ទៅដល់ទីនោះ កងឈ្លបបានចងភ្នែកគាត់ ។ ពេលនោះប្រធានឈ្លបក៏ទៅដល់ ហើយចងម៉ាក់ទុកចោលនៅនឹងដើមឈើមួយសន្ទុះធំ ទើបអ្នកទាំងអស់នោះត្រឡប់ទៅវិញស្រាយចំណងឲ្យម៉ាក់ហើយប្រាប់ថា "ត្រូវកែខ្លួន ឈប់ធ្វើបាបកូនរបស់អង្គការ" ។ ចាប់ពីថ្ងៃនោះមកខ្ញុំឈប់រករឿងម៉ាក់ ទោះជាឃ្លានស្ទើរដាច់ពោះស្លាប់ក៏ខ្ញុំស៊ូទ្រាំដែរ ព្រោះខ្ញុំខ្លាចបាត់បង់ម៉ាក់ទៀត ។

នៅចុងឆ្នាំ១៩៧៨ ភូមិរបស់ខ្ញុំមានភាពវឹកវរម្តងទៀត ។ អង្គការមកពីនិរតីវេចបង្វេចរត់គេចខ្លួន ។ ឆ្លៀតពេលនោះម៉ាក់ក៏នាំខ្ញុំរត់គេចដែរ ។ យើងធ្វើដំណើរតាមគេ តាមឯងរហូតមកដល់ភូមិល្បើកព្រៃក្នុងខេត្តសៀមរាប ដែលជាភូមិមួយដាច់ស្រយាល និងជាតំបន់យោធា ។ ទីនេះគ្មានអ្នក១៧មេសាទេ មានតែខ្ញុំ និងម៉ាក់ រួមទាំងមីងម្នាក់ទៀត ដែលដើរតាមគ្រួសារមួយឈ្មោះ គួន ដែលមានបងស្រីម្នាក់ឈ្មោះ គូ នៅទីនោះ ។ ប្រធានភូមិបានស្វាគមន៍ យើងទាំងអស់គ្នាហើយដាំបាយឲ្យហូប ។ ខ្ញុំហូបបាយទាល់តែឆ្អែតហល់រកកលស្លាប់ ទាល់តែបានចាស់ៗចាប់ជើងសំយុងក្បាលរលាក់ឲ្យក្អួតមកខ្លះទើបធូរ ។ យើងញ៉ាំឆ្អែត ដេកស្រួលបានតែមួយអាទិត្យប៉ុណ្ណោះ ក៏ត្រូវអង្គការមកប្រមូលដឹកតាមរទេះគោយកទៅដាក់នៅភូមិត្រយូង ជាកន្លែងដែលយើងត្រូវកសាងខ្លួន ។ អ្នកនៅទីនោះមិនអាចជជែកគ្នាបានទេ ហើយអង្គការកំណត់កន្លែងឲ្យដើរ ។ ពេលទៅងូតទឹកឬទៅធ្វើការត្រូវយកខ្សែចងជើងជាប់គ្នាប្រវែង៣ម៉ែត្រ និងមានកងឈ្លបក្មេងៗស្ពាយកាំភ្លើងមិនផុតពីដីជាអ្នកត្រួតពិនិត្យ ។ ឈ្លបក្មេងៗទាំងនោះសាហាវខ្លាំងណាស់ ។ ជារៀងរាល់ថ្ងៃ ពួសូវតែស្នូរគ្រាប់កាំភ្លើងបាញ់អ្នកលួចរត់ និងអ្នកមិនធ្វើការតាមបញ្ជា ។ ទោះជាហត់ហេវយ៉ាងណាក៏ខ្ញុំ និងម៉ាក់ខំត្រដរធ្វើការដែរដើម្បីរក្សាជីវិត ។ ពេលឡើងភ្នំកាប់ទន្រ្ទានខេត្ត ខ្ញុំតែងតែលួចឡើងបេះផ្លែពុទ្រាព្រៃ ម្កាក់ព្រៃ និងវល្លិផ្អែម ផ្ញើម៉ាក់ ជានិច្ច ។ ថ្ងៃមួយ ឈ្លបមកទាន់ខ្ញុំកំពុងតែ

នៅលើដើមពុទ្រា ក៏ឡើងទៅវាយខ្ញុំនៅលើដើមពុទ្រារហូតខ្ញុំធ្លាក់មកដី ហើយចុះមកវាយក្បាលជង្គង់ខ្ញុំរហូតហើមដើរលែងរួច ។ មេកងចងខ្ញុំបង្អត់បាយ៣ថ្ងៃដើម្បីជាគំរូដល់អ្នកដទៃ ។ ដោយឈឺជើងផងហេវស្ទើរដាច់ខ្យល់ស្លាប់ម្ដងៗផង ខ្ញុំចង់តែស្លាប់ភ្លាមៗដើម្បីឲ្យផុតកម្ម ប៉ុន្តែខ្ញុំមិនអាចធ្វើបាន ។ ម៉ាក់បានត្រឹមតែឈរយំពីចម្ងាយ ។ រយៈពេល៣ថ្ងៃ មេកងបានដោះលែងខ្ញុំឲ្យមានសេរីភាពវិញ ប៉ុន្តែខ្ញុំត្រូវកាត់របបព្រោះខ្ញុំឈឺ ទៅធ្វើការមិនកើត ។ ម៉ាក់បានយករបបរបស់គាត់ឲ្យខ្ញុំ ។ ពេលឈប់សម្រាក ម៉ាក់បានទៅកាច់ស្លឹកកំភ្លីងមកដុតឲ្យក្ដៅរួចយកមករុំជង្គង់ឲ្យខ្ញុំអស់រយៈពេលមួយសប្ដាហ៍ ទើបខ្ញុំដើរបានតិចៗ ។ ខ្ញុំត្រូវបង្ខំចិត្តទៅធ្វើការទាំងឈឺដើម្បីដូរយករបបអាហារ ។ នៅទីនោះខ្មែរក្រហមបាញ់សម្លាប់មនុស្សនៅនឹងមុខប្រជាជនដោយឥតញញើតដៃ ។ ឈ្លបទាំងនោះសុទ្ធតែជាកងកុមារដាច់ខាតរបស់អង្គការ ។

ថ្ងៃមួយ មេកងបានអនុញ្ញាតឲ្យប្រជាជនឈប់សម្រាកមួយថ្ងៃ ហើយធ្វើបបរគ្រឿងយ៉ាងរាវកក្កូកឲ្យញុំា ព្រោះជាថ្ងៃបុណ្យ ប៉ុន្តែមិនដឹងជាថ្ងៃបុណ្យស្អីទេ ។ ថ្ងៃនោះយើងមានសិទ្ធិជជែកគ្នា ។ ខ្ញុំឮចាស់ៗខ្សឹបគ្នាថា អ្នកចាស់ៗត្រូវសម្លាប់ជិតអស់ហើយអ្នកថ្មីមានមុខកាន់តែច្រើន ។ ពេលនោះ មីងគួន ដែលមានបងស្រីឈ្មោះ គូ នៅភូមិល្បើកព្រៃបានពកូនមករកម៉ាក់ ។ គាត់បានខ្សឹបជាមួយម៉ាក់ ឲ្យម៉ាក់អនុវខ្ញុំឲ្យរត់ជាមួយកូនស្រីធំរបស់គាត់ដើម្បីរក្សាពូជម្នាក់មួយ ព្រោះថាបើមិនឲ្យខ្ញុំរត់ទេ យើងនឹងត្រូវស្លាប់ដាច់ពូជទាំងអស់ ព្រោះគាត់ចាស់ៗគ្មានសង្ឃឹមនឹងរត់រួចទេ មានតែក្មេងៗនេះហើយដែលងាយស្រួលរត់ ព្រោះខ្មែរក្រហមពុំបានចងជើង ឬចែកដីឲ្យដើរដូចមនុស្សចាស់ទេ ។ ពីដំបូងខ្ញុំមិនព្រមរត់ចោលម៉ាក់ទេ ព្រោះយើងនៅសល់តែពីរនាក់ម្ដាយ និងកូន ស្លាប់ឬរស់ត្រូវស៊ូនៅជួបជុំគ្នា ប៉ុន្តែម៉ាក់បានអង្វរខ្ញុំ និងពន្យល់ជាច្រើនសា នៅទីបំផុតខ្ញុំក៏យល់ព្រម ។ ម៉ាក់មិចភ្នែកដាក់ មីងគួន ជាសញ្ញាថាស្អែកព្រឹកនឹងឲ្យកូនៗរត់ ។ ម៉ាក់បានយកមាសពេជ្រដែលសេសសល់មកដេរហោប៉ៅដាក់ក្នុងខោស្ទីបរបស់ខ្ញុំ ហើយយើងទាំងពីរនាក់ស្លៀកសម្លៀកបំពាក់ត្រួតគ្នា (យើងមានសម្លៀកបំពាក់តែពីរសម្រាប់ប៉ុណ្ណោះ) ។ ព្រហាមស្រាងៗម៉ាក់បានដាស់ខ្ញុំ ។ យើងយំឱបលាគ្នា ប៉ុន្តែពុំហ៊ានយំឮទេ ព្រោះខ្លាចបែកការណ៍ ។ មីងគួន បានធ្វើសញ្ញាឲ្យម៉ាក់បង្ខំទៅឲ្យលឿនឲ្យទាន់ពេលឈ្លបនាំអ្នកទោសស្រាលទៅធ្វើការនៅខាងក្រៅ ។ ពេលដែលមេកងរាប់ចំនួនរួចហើយ ខ្ញុំ និងនាង គូ ក៏បន្ទំខ្លួនចូលក្នុងជួររួចធ្វើដំណើរចេញពីជំរំជាមួយអ្នកផ្សេងទៀត ។ ចេញផុតពីជំរំ ខ្ញុំនិងនាង គូ បានគេចពីហ្វូងមនុស្ស ។ ដោយសារមេឃនៅងងឹតនៅឡើយ និងដោយសារមានចាស់ៗមួយចំនួនជួយយកអាសា ទើបយើងងាយស្រួលក្នុងការគេចចេញ ។ ឈ្លបខ្មែរក្រហមមានគ្នាតែពីរនាក់ទេគឺ ម្នាក់ដើរខាងមុខជួរ និងម្នាក់ដើរខាងក្រោយជួរ ហើយមនុស្សដែលត្រូវនាំចេញសុទ្ធតែចាស់ៗ និងត្រូវដាក់ខ្នោះច្រវាក់ជាប់គ្នា ទើបឈ្លបមិនពិបាកត្រួតពិនិត្យមិនចំណាយគ្នាច្រើន និងមិនចាប់អារម្មណ៍ខ្ញុំទាំងពីរនាក់ ។

ខ្ញុំ និងនាង គូ បានគេចពីកងឈ្លបដោយសុវត្ថិភាព ហើយធ្វើដំណើរតាមផ្លូវជាតិឆ្លងស្ពានតាប៉ុន រួចដើរតាមផ្លូវរទេះគោសំដៅទៅភូមិល្បើកព្រៃដែល នាងគូ ធានាថា ចាំផ្លូវច្បាស់ ។

នាង គូ និងខ្ញុំ បានវង្វេងក្នុងព្រៃអស់២ថ្ងៃ ហើយបរិភោគតែផ្លែរពាក់ និងផ្លែតន្ត្រៀបក្ដាម ជាអាហារ ។ ពេលយប់យើងទាំងពីរនាក់ឡើងដេកលើចុងឈើ ។ ខ្ញុំសង្វេគនឹកម៉ាក់ចង់ត្រឡប់ក្រោយវិញ ប៉ុន្តែខ្លាចខ្មែរក្រហមសម្លាប់ ព្រោះយើងរត់ចេញបីថ្ងៃហើយ ។ នៅយប់ទី៣ខ្ញុំឡើងដើមឈើសម្ល៉ីងរកមើលភ្លើងដើម្បីរកភូមិ គាប់ជួនខ្ញុំឃើញភ្លើងគោមមួយចេះតែរសាត់មកជិតឡើងៗ ។ ខ្ញុំ និងនាងគូ នាំគ្នាបិទភ្នែក ព្រោះគិតថា ខ្មោច ។ លុះឮសំឡេងដេញគោទើបដឹងថា មនុស្ស ក៏ហក់ចុះពីលើដើមឈើសុំដោយសាររទេះគោ ។ ម្ចាស់រទេះបានសួរនាំយើងទាំងពីរនាក់ ។ យើងប្រាប់ថា ម្ដាយរបស់យើងស្លាប់អស់ហើយ ហើយយើងវង្វេងផ្លូវក៏នាំគ្នាទៅរកភូមិល្បើកព្រៃ ដែលមានអ៊ំស្រីរស់នៅទីនោះ ។ ម្ចាស់រទេះគោ គឺជាប្រធានភូមិ

ល្បើកព្រៃនោះឯង ។ គាត់និយាយថា គាត់អត់ចំណាំយើងទាំងពីរនាក់ទេ (ព្រោះយើងរុំកន្សែងជិតមុខ) ។ គាត់បានដឹកយើងទៅដាក់នៅផ្ទះអ៊ំរបស់ នាងគួ ។ មួងនេះខ្ញុំលែងខ្វល់អ្វីហើយ ព្រោះបានញ៉ាំឆ្អែត តែខ្ញុំនឹកដល់ម៉ាក់ខ្លាំងណាស់ពុំដឹងជាគាត់ជួបទុក្ខបែបណាខ្លះទេ ។ នាងគួ ត្រូវបានអ៊ំស្រីយកទៅចិញ្ចឹម ចំណែកខ្ញុំរស់នៅជាមួយប្អូនស្រីរបស់ប្រធានភូមិ ។ យាយតា និងឪពុកម្តាយធម៌របស់ខ្ញុំស្រឡាញ់ថ្នាក់ថ្នមខ្ញុំដូចកូនបង្កើត លែងឲ្យទៅធ្វើការទៀត គឺដាក់ប្អូននៅពីមុខគិតតែពីញ៉ាំ ។ នៅទីនោះគ្មានអ្នក១៧មេសាទេ ។ ប្រជាជននៅទីនោះញ៉ាំរួមមែន ប៉ុន្តែបើមិនឆ្អែតអាចលួចដាំបាយញ៉ាំនៅក្នុងផ្ទះបាន ។ ពេលដែលខ្ញុំបានញ៉ាំឆ្អែតញ៉ាំឆ្ងាញ់ ខ្ញុំតែងនឹកឃើញដល់ម៉ាក់ ដែលអត់ឃ្លានជានិច្ច ។ ខ្ញុំនឹកម៉ាក់ខ្លាំងណាស់ ។ ខ្ញុំនៅតែលាក់ថា ម៉ាក់ស្លាប់ដោយខ្លាចប្រធានភូមិបញ្ជូនខ្ញុំទៅសម្លាប់ ឬធ្វើបាប ព្រោះខ្ញុំជាអ្នក១៧មេសា ។

នៅថ្ងៃរំដោះឆ្នាំ១៩៧៩ ខ្ញុំមិនដឹងថា ទៅរកម៉ាក់ឯណាទេ មិនដឹងជាគាត់ស្លាប់ ឬក៏រស់ ទៅរកនាង គួ ក៏បាត់ ។ ខ្ញុំក៏សម្រេចចិត្តទៅតាមម្តាយចិញ្ចឹមរបស់ខ្ញុំ ។

ថ្ងៃមួយ ពេលដែលខ្ញុំកំពុងពបូនចិញ្ចឹមលេងលោតមឹក ខ្ញុំឮសំឡេងប្លែកស្រែកហៅឈ្មោះពិតរបស់ខ្ញុំ "អាណែតកូន!" ។ ប្រធានភូមិបានបន្ទឹបន្ថែម "មីង៉ែត! ម៉ែហងមករក" (នៅភូមិនេះគ្រប់គ្នា ហៅខ្ញុំថា មីង៉ែត) ។ ខ្ញុំបែររកសំឡេងទាំងរន្ធត់ចិត្ត ។ ពុទ្ធោ! ម៉ាក់ខ្ញុំមែនទាំងសាច់ទាំងឈាម ។ ខ្ញុំបែរជាឈរទ្រឹងពុំរត់ទៅរកម៉ាក់ទេ ព្រោះរន្ធត់ខ្លាំង អរខ្លាំងពេក ខ្មាសក៏ខ្លាំង ព្រោះភរគេថា ម៉ាក់ស្លាប់ ។ ម៉ាក់ឱបខ្ញុំយ៉ាងខ្លាំង ទឹកភ្នែកស្រក់ដោកក្បាលខ្ញុំ ។ គាត់និយាយទាំងសំឡេងញ័រៗ "តោះកូន យើងទៅភ្នំពេញវិញទៅរកប៉ា និងបងៗ" ។ មុនដំបូងខ្ញុំអង្វរឲ្យម៉ាក់រស់នៅភូមិល្បើកព្រៃ ព្រោះទីនោះសម្បូរញ៉ាំ ។

ខ្ញុំមិនចង់ទៅតាមម៉ាក់វិញទេ ព្រោះខ្លាចអត់ឃ្លាន និងខ្លាចត្រូវខ្មែរក្រហមវាយធ្វើបាបទៀត ។ កុំតែម៉ាក់នៅសល់តែខ្ញុំម្នាក់ កុំអីម្តាយឪពុក និងយាយតា ចិញ្ចឹមរបស់ខ្ញុំមិនឲ្យខ្ញុំទៅម៉ាក់វិញទេ ព្រោះគាត់ទាំងអស់ស្រឡាញ់ខ្ញុំណាស់ ។ យើងរស់រានមានជីវិតម្តងទៀតហើយ ។ ប្រជាជនមីរដេរដាសធ្វើដំណើរតាមផ្លូវជាតិ ទៅរកស្រុកភូមិរបស់ខ្លួនវិញ ។

គ្រួសារមួយមានសមាជិក២២នាក់ ដែលបានរួមដំណើរជាមួយក្រុមគ្រួសារខ្ញុំពីភ្នំពេញទៅរស់នៅក្នុងភូមិជាមួយគ្នាបានស្លាប់អស់មួយពូជ ។ ចំណែកម្តាយមីងដែលក្រុមគ្រួសារខ្ញុំស្នាក់នៅជាមួយនៅអូរឫស្សីនោះក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងពូជដែរ ព្រោះប្តីគាត់ជាគយ ។ ខ្ញុំគ្មានសល់អ្វីទេ ក្រៅពីជីវិតម្តាយ និងកូនកម្សត់តែលតោល គ្មានផ្ទះសម្បែង គ្មានទីពឹង ។ ខ្ញុំ និងម៉ាក់បានចូលទៅមើលគុកទួលស្លែងរកមើលរូបថតប៉ា និងបងប្រុស ប៉ុន្តែអត់ឃើញ ឃើញតែមិត្តភក្តិរបស់គាត់ ។ (ប៉ាខ្ញុំឈ្មោះ ឡឿ គីមសៀវ ស័ក្តិ៥) ។

ខ្ញុំមិនចង់ចងចាំរឿងរ៉ាវខ្មែរក្រហមនៅក្នុងខួរក្បាលទេ ព្រោះវាឈឺចាប់ណាស់ ប៉ុន្តែខ្ញុំក៏មិនអាចបំភ្លេចទិដ្ឋភាពទាំងនោះបានដែរ ។ វាហាក់ដូចជានៅតែតាមលងខ្ញុំរៀងរាល់ថ្ងៃ ។

## លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូណែនាំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ហើយឲ្យសិស្សអានឮៗនូវអត្ថបទដកស្រង់ពីសៀវភៅកំណត់ហេតុរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។ គ្រូគួរអានត្រឹមតែផ្នែកខ្លះនៃកំណត់ហេតុនេះ ហើយផ្នែកដែលនៅសល់ គ្រូត្រូវចាត់តាំងសិស្សយកទៅអាននៅផ្ទះ ឬគ្រូគួរចាត់តាំងឲ្យសិស្សប្តូរគ្នាអានកំណត់ហេតុទាំងមូលឲ្យឮៗ ។

*ការបង្រៀន (១៥-៤៥នាទី)*

បន្ទាប់ពីអានកំណត់ហេតុខាងលើរួចមក សិស្សគិតប្រកបដោយការត្រិះរិះពិចារណា និងសរសេរកំណត់ហេតុ ដោយប្រើប្រាស់ព័ត៌មានដែលខ្លួនបានរៀនអំពីជីវិតក្រោមរបបខ្មែរក្រហម ។ សិស្សគួរគិតថា តើជីវិតរបស់ខ្លួននឹងមានលក្ខណៈដូចម្តេច ក្នុងនាមជាក្មេងជំទង់ម្នាក់រស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សិស្សអាចយោងតាមសំណួរខាងក្រោមសម្រាប់ជាការណែនាំទៅលើការសរសេររបស់ខ្លួន ៖

១) តើអ្នកពណ៌នាពីបទពិសោធន៍ផ្ទាល់ខ្លួនដោយរបៀបណា?

២) តើអ្នកគិតថា បទពិសោធន៍របស់អ្នកអាចជួយតម្រង់ជីវិតរបស់យើងដោយរបៀបណា?

៣) ប្រសិនបើអ្នកចង់ឲ្យសិស្សអានរឿងរ៉ាវរបស់អ្នក តើអ្នកចង់ឲ្យសិស្សដឹងអំពីអ្វី?

៤) សិស្សជ្រើសរើសបទពិសោធន៍ និងបញ្ចប់ការសរសេរដោយខ្លួនឯង ។

*សំយោគ (១៥-២៥នាទី)*

សិស្សចែករំលែកសៀវភៅកំណត់ហេតុរបស់ខ្លួន ជាមួយសិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។

## មេរៀនទី៣ : បទសម្ភាសន៍ : រឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិតម្នាក់

### វត្ថុបំណង

១) សិស្សពណ៌នាពីរបៀបធ្វើសម្ភាស ។

២) សិស្សបង្កើតសំណួរ ដែលឆ្លើយតបនឹងការផ្តើងផ្តល់អំពីជីវិតនៅក្រោមរបបខ្មែរក្រហម ។

៣) សិស្សប្រើប្រាស់ជំនាញក្នុងការសម្ភាស ។

៤) សិស្សសំយោគការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

**សម្ភារឧបទេស :** សៀវភៅលំហាត់ និងបញ្ជីនៃពាក្យ : សេចក្តីមេត្តា អារម្មណ៍ ការគោរព និងការអាណិតអាសូរ ។




និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងសម្ភាសជាមួយអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តកណ្តាល ខែកញ្ញា ឆ្នាំ២០០៦ ។ រូបថត : កែវ ដាស៊ីល

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមបង្រៀន គ្រូណែនាំសិស្សអំពីវត្ថុបំណងសម្រាប់ថ្ងៃនេះ ។ គ្រូសួរសិស្សអំពីសារសំខាន់នៃការធ្វើសម្ភាស និងធ្វើការជាមួយសិស្សដើម្បីបង្កើតសំណួរ និងវិធីសាស្ត្រក្នុងការធ្វើសម្ភាស ។ គ្រូតម្រូវឲ្យសិស្សប្រើប្រាស់សំណួរទាំងនេះដើម្បីសម្ភាសជាមួយមនុស្សណាម្នាក់ដែលខ្លួនស្គាល់ និងធ្លាប់ឆ្លងកាត់របបខ្មែរ ។ សំណួរសម្រាប់សម្ភាសរួមមាន ៖

១) នៅពេលខ្មែរក្រហមឡើងកាន់អំណាច តើអ្នកមានអាយុប៉ុន្មាន?
២) តើអ្នកជាសិស្ស ឬធ្វើការនៅមុនពេលខ្មែរក្រហមឡើងកាន់អំណាច? តើអ្នករស់នៅឯណា?
៣) តើអ្នកនៅចាំអំពីការមកដល់របស់ខ្មែរក្រហមដូចម្ដេចខ្លះ? តើអ្នកបានរៀនពីមនុស្សដែលអ្នកទុកចិត្ត និងស្គាល់ដូចម្ដេចខ្លះ?
៤) តើអ្នកត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះដែរឬទេ? តើអ្នកនៅជាមួយក្រុមគ្រួសាររបស់អ្នកដែរឬទេ?
៥) នៅក្នុងរបបខ្មែរក្រហម តើអ្នកធ្វើអ្វី? តើអ្នកមានតួនាទីអ្វី?
៦) តើជីវិតនៅក្នុងរបបខ្មែរក្រហមមានសភាពដូចម្ដេចខ្លះ?
៧) តើអ្នកមានបាត់បង់សមាជិកគ្រួសារដែរឬទេ?
៨) នៅចុងបញ្ចប់នៃរបបខ្មែរក្រហម តើអ្នកធ្វើអ្វី?
៩) តើអ្នកប្រកបរបរអ្វីដើម្បីចិញ្ចឹមជីវិតឥឡូវនេះ?
១០) សព្វថ្ងៃនេះ តើអ្នកមានអារម្មណ៍ចំពោះខ្មែរក្រហមយ៉ាងណាដែរ? តើអ្នកគិតអំពីរឿងនេះញឹកញាប់ដែរឬទេ? តើអ្នកមាននិយាយអំពីរឿងនេះជាមួយក្មេងៗដែរឬទេ? ហេតុអ្វី?
១១) តើអ្នកយល់ឃើញយ៉ាងណាដែរចំពោះតុលាការខ្មែរក្រហម?
១២) ប្រសិនបើអ្នកជួបមុខផ្ទាល់ជាមួយមនុស្សដែលអ្នកធ្លាប់ស្គាល់ពីមុន តើអ្នកនិយាយឬធ្វើយ៉ាង ដូចម្ដេច?
១៣) ដើម្បីបញ្ឈប់អំពើឧក្រិដ្ឋបែបនេះកុំឲ្យកើតមានឡើងជាថ្មីម្ដងទៀតនៅទីនេះ ក៏ដូចជានៅកន្លែងផ្សេងទៀតនៅលើសាកលលោក តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ?

## វិធីសាស្ត្រក្នុងការធ្វើសម្ភាស

១) ពន្យល់អ្នកដែលត្រូវសម្ភាសអំពីអ្វីដែលអ្នកបានរៀននៅសាលា និងមូលហេតុនៃការធ្វើបទសម្ភាសន៍ ។
២) ប្រាប់គាត់ថា អ្នកបានរៀបចំសំណួរដើម្បីសួរ ហើយថាតើបទសម្ភាសន៍នឹងធ្វើឡើងក្នុងរយៈពេលប៉ុន្មាន?
៣) អ្នកត្រូវតែស្ដាប់ដោយយកចិត្តទុកដាក់ ។
៤) ត្រូវផ្ដោតការចាប់អារម្មណ៍ ។
៥) ត្រូវចេះគួរសម ។
៦) ត្រូវកត់ត្រាព័ត៌មានទុក ។
៧) ត្រូវសួរដេញតាមហេតុការណ៍ ឬប្ដូរទម្រង់សំណួរ ប្រសិនបើអ្នកមិនអាចទទួលបាននូវចម្លើយដែលអ្នកចង់បាន ។

៨) ត្រូវសួរអ្នកដែលយើងសម្ភាស តើគាត់ចង់ចែករំលែកអ្វីផ្សេងទៀតដែលអ្នកមិនបានសួរ ដើម្បីជួយឲ្យអ្នកសិក្សាបន្ថែមអំពីជីវិតនៅក្នុងរបបខ្មែរក្រហម ។

៩) នៅពេលបញ្ចប់ អ្នកត្រូវអរគុណគាត់ដែលបានចំណាយពេលវេលាផ្តល់បទសម្ភាសន៍ ។ ប្រាប់គាត់អំពីអ្វីដែលអ្នកបានរៀនដែលជាលទ្ធផលនៃបទសម្ភាសន៍នេះ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអនុវត្តសំណួរ និងវិធីសាស្ត្រក្នុងការសម្ភាសន៍ជាមួយដៃគូរបស់ខ្លួន ។ បន្ទាប់ពីការអនុវត្ត សិស្សបង្កើតសំណួរផ្សេងៗ ឬក៏ធ្វើការផ្លាស់ប្តូរសំណួរ ដើម្បីទទួលបានចំណេះដឹងបន្ថែមទៀតអំពីជីវិតនៅក្នុងរបបខ្មែរក្រហម ។

*សំយោគ (១៥-២៥នាទី)*

សិស្សឡើងពន្យល់ទៅកាន់សិស្សឯទៀតនៅក្នុងថ្នាក់អំពីយោបល់របស់ខ្លួន ដើម្បីធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍ល្អក្នុងការសម្ភាសន៍ជាមួយអ្នកដែលនៅរស់រានមានជីវិត ។

# ជំពូក៩ ៖ ប្រព័ន្ធសន្តិសុខ



រូបថតអ្នកទោសនៅមន្ទីរស-២១ (បច្ចុប្បន្នសារមន្ទីរទួលស្លែង) ជាមន្ទីរសន្តិសុខថ្នាក់ខ្ពស់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## មេរៀនទី១ ៖ អំណានជំពូក៨ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### វត្ថុបំណង

១) សិស្សកំណត់គោលគំនិតសំខាន់ៗនៃប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហម ។

២) សិស្សពន្យល់អំពីផលប៉ះពាល់នៃប្រព័ន្ធសន្តិសុខមកលើប្រជាជនកម្ពុជា ។

៣) សិស្សកំណត់និយមន័យនៃពាក្យសំខាន់ៗមួយចំនួនទាក់ទងនឹងប្រព័ន្ធសន្តិសុខ ។

៤) សិស្សសំយោគការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

**ពន្យល់ពាក្យ** ៖

| | | |
|---|---|---|
| មន្ទីរសន្តិសុខ | ជំរំពលកម្ម | ជនជាតិភាគតិចចាម |
| ការសួរចម្លើយ | សត្រូវខាងក្នុង | ជនក្បត់ជាតិ |
| សត្រូវខាងក្រៅ | ការឃុំឃាំង | ការឃោសនា |
| បញ្ញវន្ត | ជនជាតិភាគតិច | ជនជាតិតំបន់ភ្នំ |

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ហើយពិភាក្សាពីអ្វីដែលសិស្សបានដឹងអំពីប្រព័ន្ធសន្តិសុខ ។ បន្ទាប់មក គ្រូឲ្យសិស្សពន្យល់ពាក្យសំខាន់ៗ នៅក្នុងជំពូក៩ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអាន និងកត់ត្រាដោយយកចិត្តទុកដាក់នូវព្រឹត្តិការណ៍សំខាន់ៗពីជំពូក៩ ។ សិស្សសរសេរនៅក្នុងសៀវភៅលំហាត់របស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) តើគុកនៅក្នុងរបបខ្មែរក្រហមមានចំនួនប្រហែលប៉ុន្មាន? **ប្រហែល២០០ ។**

២) តើខ្មែរក្រហមបានហៅគុកទាំងអស់នេះថាយ៉ាងដូចម្ដេច? **មន្ទីរសន្តិសុខ ។**

៣) តើអ្នកណាខ្លះដែលត្រូវបានចាត់ទុកថាជា "អ្នកបដិវត្តន៍ស្អាតស្អំបំផុត" នៅក្នុងរបបខ្មែរក្រហម? **កសិករក្រីក្រ ។**

៤) តើក្រុមមនុស្សដែលត្រូវបានចាត់ទុកថាជា "សត្រូវខាងក្នុង" ជាក្រុមមនុស្សប្រភេទណាខ្លះ? **មន្ត្រីនៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បញ្ញវន្ត ក្រុមជនជាតិភាគតិចដូចជា ជនជាតិតំបន់ភ្នំ ចាម វៀតណាម ចិន និងជនដែលសង្ស័យថាក្បត់ ។**

៥) តើអ្នកណាខ្លះត្រូវបានចាត់ទុកថាជា "សត្រូវខាងក្រៅ"? **សហរដ្ឋអាមេរិក ថៃ និងប្រទេសសង្គមនិយមមួយចំនួនជាពិសេសវៀតណាម និងអតីតសហភាពសូវៀត ។ ខ្មែរក្រហមបានចាត់ទុកប្រជាជនកម្ពុជាទាំងឡាយណាដែលអាចនិយាយភាសាបរទេសថា ជាភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់បរទេស ។**

៦) តើអ្នកគិតថា ទារុណកម្ម និងការសម្លាប់ មានផលប៉ះពាល់ដូចម្ដេចខ្លះ ដល់អ្នកដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ? **ចម្លើយអាចប្រែប្រួល ។**

៧) តើការស៊ើបយកការណ៍ និងការភ័យខ្លាចចំពោះការដែលត្រូវបានគេឃ្លាំមើល មានផលប៉ះពាល់ចំពោះបុគ្គលម្នាក់ៗ នៅក្នុងសង្គមដូចម្ដេចខ្លះ? **ចម្លើយអាចប្រែប្រួល ។**

៨) តើប្រជាជនរត់គេច និងរួចជីវិតពីរយៈកាលកម្ពុជាប្រជាធិបតេយ្យដោយរបៀបណា? **ចម្លើយអាចប្រែប្រួល ។**

៩) ប្រសិនបើអ្នករស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើអ្នកគិតថា អ្នកនឹងមានភាពខុសប្លែកពីពេលឥឡូវនេះយ៉ាងណា? **ចម្លើយអាចប្រែប្រួល ។**

## មេរៀនទី២ ៖ ប្រវត្តិ ៖ សេចក្តីស្រឡាញ់ និងពលិកម្មរបស់ប្អូនស្រីដែលពុំអាចបំភ្លេចបាន



*ម្តាយរបស់ ម៉ុក ស៊ិនហៀង (កណ្តាល) និងគ្រួសារ ។ កម្មសិទ្ធិរូបថត របស់ ម៉ុក ស៊ិនហៀង*

### វត្ថុបំណង

១) សិស្សស្វែងយល់ពីស្ថានភាពរស់នៅដ៏លំបាកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សឆ្លុះបញ្ចាំងពីភាពអស់សង្ឃឹមរបស់មនុស្ស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សពិចារណាពីវិធីដែលប្រជាជនខំប្រឹងប្រែង ដើម្បីរស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៤) សិស្សឆ្លុះបញ្ចាំងពីការប៉ះពាល់ផ្លូវចិត្តនៃរបបកម្ពុជាប្រជាធិបតេយ្យ មកលើអ្នករស់រានមានជីវិតនាពេលបច្ចុប្បន្ន ។

**សម្ភារឧបទេស ៖** សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ហើយពិភាក្សាពីអ្វីដែលសិស្សបានដឹងអំពីជីវិតរស់នៅប្រចាំថ្ងៃក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ផ្នែកមួយនៃការពិភាក្សានេះ គ្រូសួរសំណួរខាងក្រោម ដើម្បីណែនាំពីប្រវត្តិរឿងរ៉ាវរបស់អ្នករួចរស់ជីវិត និងគ្រួសារ ។

១) តើជីវិតប្រចាំថ្ងៃក្រោមរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈដូចម្តេច? ***ចម្លើយអាចប្រែប្រួល ប៉ុន្តែជាទូទៅ សិស្សគួរលើកឡើងពីស្ថានភាពរស់នៅយ៉ាងលំបាក ភាពខ្វះម្ហូបអាហារ ការបង្ខំឲ្យធ្វើការជាទម្ងន់ ការបង្ខំឲ្យរៀបការ ការគំរាមកំហែងចាប់ដាក់គុក ការធ្វើទារុណកម្ម និងសម្លាប់ ។ សិស្សអាចលើកឡើងពីកង្វះ***

***ខាតការថែរក្សាសុខភាពឲ្យបានសមរម្យ ការជម្លៀសដោយបង្ខំ និងការប្រព្រឹត្តបទល្មើសយ៉ាងឃោរឃៅ ព្រមទាំងឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិដទៃទៀត ។***

២) *តើមនុស្សម្នាក់អាចគេចផុតពីស្ថានភាពដ៏គួរឲ្យរន្ធត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ? ប្រសិនបើអាចគេចផុតមែន តើត្រូវធ្វើដូចម្តេច?* ***ចម្លើយអាចប្រែប្រួល ហើយពុំមានចម្លើយខុស ឬត្រូវឡើយ ។ ជាទូទៅ សិស្សគួរលើកឡើងថា មនុស្សអាចភៀសខ្លួនចេញពីប្រទេស (ដែលពិបាកជាទីបំផុត) ឬអាចព្យាយាមរស់ និងលាក់ខ្លួននៅក្នុងព្រៃ (ដែលពិបាកជាទីបំផុត) ។ ចម្លើយផ្សេងទៀតគឺថា មនុស្សអាចបង្ហាញពីភាពស្មោះត្រង់របស់ខ្លួន ឬចូលរួមបម្រើរបបនោះ ដែលសង្ឃឹមថាអាចជួយកាត់បន្ថយកម្រិតនៃការគំរាមសម្លាប់ ឬចាប់ដាក់គុក ហើយប្រហែលជាអាចធ្វើឲ្យស្ថានភាពរស់នៅបានប្រសើរឡើង ។ ចម្លើយដទៃទៀតក៏អាចលើកឡើងបានដែរ ។ គោលបំណងនៃសំណួរនេះ គឺដើម្បីបំផុសសិស្សឲ្យចេះត្រិះរិះពិចារណាពីភាពអស់សង្ឃឹមរបស់មនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណុចសំខាន់ជាងគេក្នុងសំណួរនេះ គឺសិស្សគួរពិចារណាពីវិធីផ្សេងៗ ដែលមនុស្សព្យាយាមដើម្បីរស់ពីរបបនោះ ដោយខំព្យាយាមសម្របខ្លួន ស្ម័គ្រចិត្តចូលបម្រើ និងគាំទ្រប្រព័ន្ធវប្បធម៌ និងនយោបាយរបស់ខ្មែរក្រហម ។***

*ការបង្រៀន (១៥-៤៥នាទី)*

*សិស្សអានដោយយកចិត្តទុកដាក់ និងកត់ត្រាពីប្រវត្តិរឿងរ៉ាវ «សេចក្តីស្រឡាញ់ និងពលិកម្មរបស់ប្អូនស្រីដែល មិនអាចបំភ្លេចបាន» និងពិភាក្សានៅក្នុងក្រុមតូចពីសំណួរណែនាំ ។*

*សំយោគ (១៥-២៥នាទី)*

*គ្រូពិភាក្សាសំណួរណែនាំជាមួយសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។*



*ពីឆ្វេងទៅស្តាំ ៖ បងប្អូនជីដូនមួយរបស់ ម៉ុក ស៊ិនហៀង, ម៉ុក ស៊ិនហៀង, ម៉ុក ស៊ិនអ៊ូ និងប្អូនជីដូនមួយម្នាក់ទៀត ថតនៅសួនផ្កាក្នុងផ្ទះរបស់ ម៉ុក ស៊ិនហៀង ។ កម្មសិទ្ធិរូបថតរបស់ ម៉ុក ស៊ិនហៀង*

## សេចក្តីស្រឡាញ់ និងពលិកម្មរបស់ប្អូនស្រីដែលមិនអាចបំភ្លេចបាន

*ខ្ញុំបានកើតធំធាត់នៅទួលគោក ក្នុងឆ្នាំ១៩៥២ ។ ឪពុករបស់ខ្ញុំឈ្មោះ ម៉ុក លាន គឺជាគ្រូពេទ្យផ្នែកវិកលវិជ្ជាដំបូងគេនៅកម្ពុជាកាលពីមុនសង្គ្រាមស៊ីវិលកើតឡើង ។ ខ្ញុំគឺជាកូនស្រីច្បងក្នុងចំណោមបងប្អូនបីនាក់ ។ ប្អូនស្រីទាំងពីររបស់ខ្ញុំឈ្មោះ ម៉ុក ស៊ិនហុង និង ម៉ុក ស៊ិនអ៊ូ ។ ក្នុងនាមជាបងស្រី ខ្ញុំគឺជាអ្នកមើលថែប្អូនៗ ។*

*នៅពេលដែលទាហានខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់ ខ្ញុំបានផ្ញើខ្ញុំ និងប្អូនស្រីទាំងពីរ ឲ្យស្នាក់នៅជាណ្តោះអាសន្នក្នុងមន្ទីរពេទ្យជាមួយម្តាយមីង ដែលកំពុងបម្រើការជាវេជ្ជបណ្ឌិតនៅទីនោះដែរ ។ នៅទីបំផុតប្អូនស្រីទាំងពីរ ម្តាយមីង និងខ្ញុំ ត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីលំនៅទៅកាន់ភូមិមួយនៅក្នុងខេត្តពោធិ៍សាត់ ។*

## រៀបការដើម្បីរស់

*នៅក្នុងខេត្តពោធិ៍សាត់ ម្តាយមីងខ្ញុំបានបញ្ចុះបញ្ចូលប្អូនស្រីខ្ញុំឈ្មោះ ម៉ុក ស៊ិនហុង ឲ្យរៀបការជាមួយទាហានខ្មែរក្រហមម្នាក់ ។ បើទោះជាប្អូនស្រីខ្ញុំ*

ប្រកែកមិនព្រមរៀបការជាមួយទាហានម្នាក់នោះ ក៏ដោយ (ហើយខ្ញុំក៏ជំទាស់ដែរ) ភ្លាមៗនោះ ខ្ញុំបានធ្លាក់ខ្លួនឈឺ និងអស់កម្លាំងជាខ្លាំង ។

អ្នកជំងឺ (និងជាពិសេសប្រជាជនថ្មី) គឺជាមុខសញ្ញាកម្ទេច ពីព្រោះអ្នកទាំងនោះត្រូវបានចាត់ទុកថា ជាមនុស្សគ្មានប្រយោជន៍ ឬក្លាយជាបន្ទុករបស់អង្គការ ។ ហេតុដូច្នេះ ហើយទើបជឿជាក់ថា ប្រសិនបើប្អូនស្រីខ្ញុំអាចរៀបការជាមួយទាហានខ្មែរក្រហមនោះមែន កាលៈទេសៈបែបនេះពិតជាអាចជួយការពារខ្ញុំពីការនាំយកទៅសម្លាប់ ។ លើសពីនេះទៀត ម្តាយមីង និងគ្រួសាររបស់ខ្ញុំជឿជាក់ថា ប្រសិនបើប្អូនស្រីរបស់ខ្ញុំអាចរៀបការជាមួយទាហានខ្មែរក្រហមមែននោះ ពិតជាអាចជួយដល់ស្ថានភាពគ្រួសាររបស់យើងទាំងមូល និងជាឱកាសរបស់យើងក្នុងការរស់នៅតទៅទៀត ។



ម៉ុក សុិនហៀង (ទីពីររាប់ពីខាងស្តាំ) ក្នុងថ្ងៃរៀបការមិត្តភក្រ្ត ។ កម្មសិទ្ធិរូបថតរបស់ ម៉ុក សុិនហៀង

បន្ទាប់ពីប្អូនស្រីរៀបការរួច នាង និងគ្រួសារនាងត្រូវបានបញ្ជូនទៅរស់នៅភូមិមួយផ្សេងទៀតក្បែរបឹងទន្លេសាប ។ ពីរបីខែក្រោយមក នាង និងម្តាយក្មេកបានវិលត្រឡប់មករស់នៅជាមួយពួកយើងវិញ ។ ពេលនោះ នាងមានផ្ទៃពោះ ហើយប្តីរបស់នាងមិនបាននៅជាមួយនាងឡើយ ។ ដោយសារតែមានរឿងនេះ ប្តីរបស់នាងត្រូវបានសង្ស័យថា ជាយួន ហើយគាត់ត្រូវបានចាប់ខ្លួន ។

ពីរថ្ងៃក្រោយមក នៅពេលដែលប្អូនស្រី សុិនហុង កំពុងស្រោចបន្លែនៅក្រោយផ្ទះនាពេលព្រលប់ កងឈ្លបបីនាក់ដែលមានបង់កក្រមាពណ៌ក្រហម បានមកដល់មាត់ទ្វារផ្ទះ ។ អ្នកទាំងបីបានប្រាប់មនុស្សគ្រប់គ្នានៅក្នុងផ្ទះឲ្យរៀបចំឥវ៉ាន់ជាប្រញាប់ ដើម្បីផ្លាស់ប្តូរទៅកាន់មន្ទីរអប់រំកែប្រែ ។ ជាមួយនឹងពាក្យសម្តីនេះ យើងទាំងអស់គ្នាបានចាកចេញពីភូមិភ្លាមៗ ហើយបានធ្វើដំណើរឆ្ពោះទៅកាន់កន្លែងផ្សេងទៀត ទីបំផុតយើងបានមកដល់ភូមិក្បាលឈើពុក ។

នៅពេលដែលយើងបានមកដល់ភូមិក្បាលឈើពុក កងឈ្លបបានឃុំឃាំងប្អូនស្រី សុិនហុង និងម្តាយក្មេកនាង ។ ប៉ុន្តែខ្ញុំមិនត្រូវបានឃុំឃាំងឡើយ ។ ខ្ញុំបានអង្វរកម្មាភិបាលខ្មែរក្រហមឲ្យដោះលែងប្អូនស្រី ប៉ុន្តែអ្នកទាំងនោះបានបដិសេធ ។

ថ្ងៃមួយ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្នុងភូមិមួយដែលស្ថិតនៅក្បែរកន្លែងដែលប្អូនស្រីខ្ញុំកំពុងធ្វើការដែរ ។ ខ្ញុំមើលសុិនហុង មិនស្គាល់ទេ ។ នាងស្គមស្គាំងយ៉ាងខ្លាំង ហើយមានជំងឺទៀត ។ ដោយអារម្មណ៍ស្លុតចិត្តខ្លាំងពេក ខ្ញុំទ្រហោយំឱបនាង ។ ខ្ញុំបានធ្វើការនៅក្បែរកងរបស់នាងម្តងទៀត ប៉ុន្តែយើងមិនដែលបានជួបគ្នាទេ ។ នាងបានសរសេរសំបុត្រមួយច្បាប់ផ្ញើមកឲ្យខ្ញុំយកធ្យូងដែលសល់ពីការដុតមែកឈើ និងបំណែកក្រដាសសុីម៉ងត៍ ដោយរៀបរាប់ថា នាងនឹងត្រូវសម្រាលកូនក្នុងពេលឆាប់ៗ ហើយថា នាងត្រូវការម្ហូបដែលមានជីវជាតិដើម្បីហូប ។ សំបុត្រនេះ បានធ្វើឲ្យខ្ញុំមានកម្លាំងឡើងវិញ ។ ខ្ញុំបានចាប់ផ្តើមដាំបន្លែនៅក្រោយផ្ទះរបស់ខ្ញុំ ដើម្បីត្រៀមសម្រាប់ទទួលនាង ។ តែនាងមិនបានមកទេ ហើយខ្ញុំលែងបានឃើញមុខនាងរហូត ។

ខ្ញុំបានឮអ្នកទោសម្នាក់ដែលជាប់ឃុំឃាំងជាមួយប្អូនស្រីខ្ញុំ និយាយថា សុិនហុង ត្រូវបានកម្មាភិបាលខ្មែរក្រហមសម្លាប់ដោយអារកនឹងធាងត្នោត ពីព្រោះនាងបានលួចដឹកទឹកត្នោតដោយគ្មានការអនុញ្ញាត ។ ការដាក់ទណ្ឌកម្មបែបនេះ បានធ្វើឡើង

នៅចំពោះអ្នកទោសគ្រប់គ្នា ដើម្បីទុកជាការព្រមាន ។

ប្អូនស្រីខ្ញុំម្នាក់ទៀតឈ្មោះ ស៊ិនអ៊ូ ត្រូវបានបង្ខំឲ្យលើកទំនប់ ។ ដោយភាពស្រេកឃ្លានជាពន់ពេក ស៊ិនអ៊ូ បានចាប់ផ្ដើមវង្វេងវង្វាន់លែងដឹងស្មារតី ។ នាងតែងតែធ្វើដូចជា បរិភោគអាហារនៅក្នុងចាន ខណៈដែលចាននោះគឺជាចានទទេ ។

ដោយសារតែនាងពុំអាចអត់ទ្រាំនឹងលក្ខខណ្ឌការងារធ្ងន់ៗបាន ថ្ងៃមួយ ស៊ិនអ៊ូ បានដួលដើបលែងរួច និងបាត់បង់ស្មារតីនៅឯការដ្ឋានលើកទំនប់ ។ ឃើញដូច្នេះ ខ្ញុំបានលើកប្អូនស្រីត្រឡប់ទៅផ្ទះ ។

ទោះជាខ្ញុំខំព្យាយាមយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនអាចជួយនាងបានឡើយ ។ នៅយប់មួយនោះ ស៊ិនអ៊ូ បានដឹងខ្លួនវិញ ហើយបាននិយាយមកខ្ញុំ ។ ខ្ញុំអាចនិយាយបានថា នាងវង្វេងវង្វាន់ដោយសារការស្រេកឃ្លានខ្លាំងពេក ។ ស៊ិនអ៊ូ ហាក់ដូចជាដឹងខ្លួនមុនថា នាងនឹងស្លាប់ ដោយសារតែនាងបាននិយាយពីអនុស្សាវរីយ៍ល្អៗកាលពីនៅផ្ទះ ។ ខ្ញុំបានឱបប្អូនស្រីដែលកំពុងតែគ្មានកម្លាំងកំហែង ។ យើងបានលង់លក់ទាំងអស់គ្នា ។ លុះព្រឹកឡើង ខ្ញុំបានព្យាយាមដាស់នាង ប៉ុន្តែនាងបានស្លាប់បាត់ទៅហើយ ។

### **កេរដំណែល និងការចង់បានយុត្តិធម៌**

ខ្ញុំគឺជាមនុស្សតែម្នាក់គត់ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។ ស៊ិនហុង ត្រូវបានសម្លាប់ ហើយ ស៊ិនអ៊ូ បានស្លាប់ដោយភាពអត់ឃ្លាន ។ ឪពុករបស់ខ្ញុំ ប្អូនប្រុសចិញ្ចឹមទាំងពីររបស់ខ្ញុំ (ម៉ក់ បណ្ឌិត និង ម៉ក់ បុទ្ធីយ៉ា) ព្រមទាំងប្អូនស្រីចិញ្ចឹមម្នាក់ទៀត (ម៉ក់ ស៊ិនហេង) បានបាត់ខ្លួន ។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែមានភាពសោកស្ដាយ និងមានវិប្បដិសារីចំពោះមង្គលការរបស់ ស៊ិនហុង ជាមួយនឹងទាហានខ្មែរក្រហម ។

ខ្ញុំនៅតែមានអារម្មណ៍ថា ប្អូនស្រីខ្ញុំបានប្រថុយប្រថាននឹងគ្រោះថ្នាក់ ដើម្បីការពារក្រុមគ្រួសារ ។ ប្អូនស្រីខ្ញុំ មានសុខភាពល្អណាស់ ព្រមទាំងស្វាហាប់ទៀតផង ។ ខ្ញុំជឿជាក់ថា នាងមិនគួរស្លាប់ទេ ប្រសិនបើនាងមិនបានរៀបការជាមួយទាហានខ្មែរក្រហមម្នាក់នោះ ។ ប៉ុន្តែ នាងបានរៀបការដើម្បីជួយសង្គ្រោះជីវិតខ្ញុំ ។

ខ្ញុំក៏មិនអាចបំភ្លេចប្អូនស្រី ស៊ិនអ៊ូ ដែលបានស្លាប់នៅក្នុងរង្វង់ដៃខ្ញុំដែរ ។

ខ្ញុំមិនអាចបំភ្លេចពីការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ នៅក្នុងរបបនោះបានឡើយ ។ ខ្ញុំក៏មិនអាចឈរមើលដើមត្នោតបានដែរ ព្រោះធ្វើឲ្យខ្ញុំនឹកឃើញដល់ប្អូនស្រីខ្ញុំ ដែលស្លាប់ដោយសារតែខ្មែរក្រហមអារកនាងនឹងធាងត្នោត ។ នៅពេលដែលខ្ញុំគិតដល់ ស៊ិនអ៊ូ ខ្ញុំក៏មិននឹកស្មានដល់ថា កូនស្រីរបស់គ្រូពេទ្យផ្នែកវិកលវិទ្យាដ៏ល្បីឈ្មោះម្នាក់ បានស្លាប់យ៉ាងអណោចអាធ័មយ៉ាងដូច្នេះសោះ ។


ម៉ុក ស៊ិនហៀង នៅអតីតផ្ទះរបស់គាត់ដែលធ្លាប់រស់នៅជាមួយគ្រួសារនៅទួលគោក រាជធានីភ្នំពេញ (២០១៣) ។ រូបថត ញាណ សុជាតិ

ខ្ញុំចង់បានយុត្តិធម៌ពីតុលាការកាត់ទោសខ្មែរក្រហម សម្រាប់ប្អូនស្រីទាំងពីររបស់ខ្ញុំ និងចង់បានការផ្សះផ្សារបួសផ្លូវចិត្តរបស់ខ្ញុំ ។ ខ្ញុំនឹងរក្សាការចងចាំនេះ

ក្នុងចិត្តរហូតដល់ថ្ងៃស្លាប់ ។

### សំណួរណែនាំ និងចម្លើយ

១) *រឿងរ៉ាវនេះ ពណ៌នាអំពីបងប្អូនស្រីបីនាក់ ។ តើអ្នកទាំងនោះមានឈ្មោះអ្វីខ្លះ ហើយតើនរណាជាកូនច្បង?* **ឈ្មោះអ្នកទាំងបីគឺ ម៉ុក ស៊ិនហុង, ម៉ុក ស៊ិនអ៊ួ និងអ្នកនិទានរឿង ម៉ុក ស៊ិនហៀង ជាកូនច្បង ។**

២) *តើប្អូនស្រីមួយណាដែលបានរៀបការ?* **ម៉ុក ស៊ិនហុង ។**

៣) *តើ ស៊ិនហុង រៀបការជាមួយនរណា? ហើយហេតុអ្វីបានជានាងរៀបការជាមួយបុរសនោះ?* **នាងបានរៀបការជាមួយទាហានខ្មែរក្រហមម្នាក់ ពីព្រោះនាងជឿជាក់ថា ប្រសិនបើនាងរៀបការជាមួយទាហាននោះ នាងប្រាកដជាអាចជួយ ម៉ុក ស៊ិនហៀង (អ្នកនិយាយរឿងរ៉ាវ) និងជួយធ្វើឲ្យប្រសើរឡើងនូវស្ថានភាពគ្រួសារក្នុងរបបខ្មែរក្រហមទៀតផង ។**

៤) *តើមានរឿងអ្វីកើតឡើងចំពោះប្ដីរបស់នាង បន្ទាប់ពីគាត់រៀបការជាមួយនាងរួច?* **គាត់ត្រូវបានចាប់ខ្លួនដោយសង្ស័យថា ជាជនជាតិវៀតណាម ។**

៥) *តើមានរឿងអ្វីកើតឡើងចំពោះ ស៊ិនហុង បន្ទាប់ពីប្ដីរបស់នាងត្រូវបានចាប់ខ្លួន?* **កងឈ្លបខ្មែរក្រហមបានចាប់នាង និងគ្រួសាររបស់នាងទៅដាក់ក្នុងមន្ទីរអប់រំកែប្រែមួយកន្លែង ប៉ុន្តែនាង និងគ្រួសារបានរត់គេចចេញ ។ តែនៅទីបំផុត នាង និងគ្រួសារក៏ត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំងវិញ ។ ក្រោយមក ស៊ិនហុង ត្រូវបាន សម្លាប់ដោយសារនាងបានលួចជីកទឹកត្នោត ។ នាងត្រូវបានសម្លាប់ដោយអារកនឹងធាងត្នោត ។**

៦) *តើមានរឿងអ្វីកើតឡើងចំពោះប្អូនស្រីរបស់ ស៊ិនហុង ឈ្មោះ ស៊ិនអ៊ួ?* **នាងបានស្លាប់ដោយអត់អាហារក្នុងរង្វង់ដៃរបស់ ស៊ិនហៀង ។**

៧) *តើ ស៊ិនហៀង មានអារម្មណ៍យ៉ាងដូចម្ដេចចំពោះការស្លាប់របស់ប្អូនស្រីទាំងពីរ?* **ស៊ិនហៀង មានអារម្មណ៍សោកស្ដាយ និងមានវិប្បដិសារីជាខ្លាំង ចំពោះការរៀបការរបស់ប្អូនស្រីជាមួយនឹងទាហានខ្មែរក្រហម ពីព្រោះនាងជឿជាក់ថា ប្រសិនជា ស៊ិនហុង មិនបានរៀបការនោះទេ ស៊ិនហុង ប្រហែលជាអាចនៅមានជីវិតមកដល់បច្ចុប្បន្ននេះ ។ នាងមានអារម្មណ៍ថា ស៊ិនហុង បានបូជាជីវិតខ្លួនឯង ដើម្បី ស៊ិនហៀង និងក្រុមគ្រួសារទាំងមូល ។ នាងក៏មានអារម្មណ៍សោកស្ដាយចំពោះភាពគ្មានលទ្ធភាពគ្រប់គ្រាន់ ដែលបណ្ដាលឲ្យប្អូនស្រី ស៊ិនអ៊ួ ស្លាប់ក្នុងដៃរបស់នាង ។**

៨) *តើអ្នកគិតថា ស៊ិនហៀង មានអារម្មណ៍យ៉ាងដូចម្ដេច នៅពេលដែលគាត់ជាមនុស្សតែម្នាក់គត់នៅក្នុងគ្រួសារដែលរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ?* **ចម្លើយអាចប្រែប្រួល ប៉ុន្តែជាទូទៅ នាងច្បាស់ជាមានអារម្មណ៍វិលវល់ជាច្រើន ដូចជា មានកំហុស វិប្បដិសារី ទុក្ខព្រួយ ឯកោ និងច្របូកច្របល់ក្នុងចិត្ត ។ នាងមានអារម្មណ៍ថា មានកំហុស និងវិប្បដិសារី ចំពោះភាពគ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីជួយប្អូនស្រីរបស់នាងទាំងពីរ ។ នាងមានអារម្មណ៍ទុក្ខព្រួយ និងឯកោដោយគ្មានប្អូនស្រីទាំងពីរនាពេលបច្ចុប្បន្ននេះ ។ នាងក៏អាចមានអារម្មណ៍ច្របូកច្របល់ដែលនាងគឺជាមនុស្សតែម្នាក់គត់ដែលអាចនៅមានជីវិត ។ ទីបំផុត នាងក៏មិនអាចបំភ្លេចបានឡើយ ពីផលប៉ះពាល់ផ្លូវចិត្តដែលបន្សល់ទុកពីរបបខ្មែរក្រហម ហើយនាងសង្ឃឹមថា បានទទួលការផ្សះផ្សាផ្លូវចិត្តខ្លះៗ តាមរយៈការទទួលបានយុត្តិធម៌នៅក្នុងតុលាការខ្មែរក្រហម ។**

## មេរៀនទី៣ ៖ ត្រៀមធ្វើបទបឋកថា



កងសន្តិសុខក្មេងៗ ស្ថិតក្នុងការកិច្ចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

### វត្ថុបំណង

១) សិស្សរៀបរាប់អំពីប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហម ។

២) សិស្សពន្យល់ពីលក្ខខណ្ឌជីវិតរបស់អ្នកនៅរស់រានមានជីវិតម្នាក់នៅក្នុងប្រព័ន្ធសន្តិសុខខ្មែរក្រហម ។

៣) សិស្សស្វែងយល់ និងកត់ត្រាពីប្រវត្តិរឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតម្នាក់ ។

៤) សិស្សសម្តែងចិត្តអាណិតអាសូរចំពោះអ្នកដែលឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។

***សម្ភារឧបទេស*** ៖ សៀវភៅលំហាត់ (ណែនាំឲ្យអានសៀវភៅ ៖ ជនរងគ្រោះ និងជនដៃដល់) ដែលសរសេរដោយ អៀ ម៉េងទ្រី និង ស៊ឹម សូរិយា (មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូណែនាំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ហើយពិភាក្សាជាមួយសិស្សពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ ដែលនៅរស់រានមានជីវិតក្រោយរបបខ្មែរក្រហម និងណែនាំសិស្សឲ្យស្តាប់ដោយប្រុងប្រយ័ត្ន ហើយត្រូវតែមានការគោរពចំពោះវាគ្មិន និងបទពិសោធន៍របស់គាត់ ។

*ការបង្រៀន (១៥ - ៤៥ នាទី)*

សិស្សស្តាប់ដោយប្រុងប្រយ័ត្ន សួរសំណួរ និងសរសេររឿងរ៉ាវលម្អិតសំខាន់ៗរបស់ភ្ញៀវ ។ សិស្សត្រូវឆ្លើយទៅនឹងសំណួរមួយចំនួនដូចជា ៖ តើថ្នាក់ដឹកនាំខ្មែរក្រហមមានការភ័យខ្លាចចំពោះអ្វី? ហេតុអ្វីបានជាខ្មែរក្រហមបង្កើតប្រព័ន្ធសន្តិសុខ? តើបទពិសោធន៍របស់អ្នកដែលស្ថិតនៅក្នុងប្រព័ន្ធសន្តិសុខទាំងនោះមានលក្ខណៈរបៀបណា?

*សំយោគ (១៥ - ២៥ នាទី)*

សិស្សចែករំលែកនូវអ្វីដែលខ្លួនបានរៀនពីភ្ញៀវទៅមិត្តភក្តិ ។

# ជំពូក១០ ៖ មន្ទីរស-២១ (គុកទួលស្លែង)



*គុកទួលស្លែង (ស-២១) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

## មេរៀនទី១ ៖ អំណានជំពូក៩ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

**វត្ថុបំណង**

១) សិស្សកំណត់និយមន័យនៃពាក្យសំខាន់ៗមួយចំនួនទាក់ទងនឹងគុកទួលស្លែង ។

២) សិស្សពន្យល់អំពីព័ត៌មានសំខាន់ៗទាក់ទងនឹងគុកទួលស្លែង ។

៣) សិស្សពន្យល់អំពីព័ត៌មានសំខាន់ៗទាក់ទងនឹងជីវិតនៅក្នុងគុកទួលស្លែង ។

៤) សិស្សពន្យល់ថា តើការបន្ទិតបន្ទំ នឹងមានផលប៉ះពាល់មកលើជម្រើសនៃវប្បធម៌ ដែលយើងកំពុងតែប្រឈមមុខអ្វីខ្លះ ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅលំហាត់ ភាពយន្តឯកសារ និងសៀវភៅរូបភាពមន្ទីរស-២១ ។

**ពន្យល់ពាក្យ** ៖

| | | |
|---|---|---|
| មន្ទីរស-២១(គុកទួលស្លែង) | ចម្លើយសារភាព | ដើងឯក |
| ការសម្លាប់ | ការឃុំឃាំង | ការធ្វើទារុណកម្ម |
| អង្គភាពឯកសារ | បទបញ្ញត្តិ | ឌុច |
| ជនក្បត់ជាតិ | ខ្មោះប្រវ៉ាក់ | |




*សិស្សវិទ្យាល័យពីរនាក់មើលទៅពិព័រណ៍រូបថតក្មេងរស់រានមានជីវិតពីគុកទួលស្លែង នៅក្រោមប្រធានបទ«ការចងចាំសារមន្ទីរទួលស្លែង» ដែលបានដាក់តាំងនៅក្នុងបរិវេណសារមន្ទីរនៅខែមេសា ឆ្នាំ២០១៤ ។ រូបថត : ញាណ សុជាតិ*

### លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ហើយពិភាក្សាពីអ្វីដែលសិស្សបានដឹងអំពីមន្ទីរស-២១(គុកទួលស្លែង) ។ បន្ទាប់មក គ្រូឲ្យសិស្សពន្យល់ពាក្យសំខាន់ៗនៅក្នុងជំពូក៩នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអាន និងកត់ត្រាដោយយកចិត្តទុកដាក់នូវព្រឹត្តិការណ៍សំខាន់ៗពីជំពូក៩ ។ សិស្សសរសេរព្រឹត្តិការណ៍ទាំងនោះនៅក្នុងសៀវភៅលំហាត់ ដើម្បីឆ្លុះបញ្ចាំងពីការសិក្សារបស់សិស្ស ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) តើអ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរស-២១ (គុកទួលស្លែង) មានប៉ុន្មាននាក់? **ប្រហែល១ម៉ឺន ៤ពាន់នាក់ ។**

២) តើអ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរស-២១ជាអ្នកទោសប្រភេទណាខ្លះ? **អ្នកទោសស្ទើរតែទាំងអស់ជាកម្មាភិបាល និងកងទ័ពខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទក្បត់បដិវត្តន៍ ។**

៣) តើអ្នកទោសនៅមន្ទីរស-២១ដែលបានរួចរស់ជីវិតបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមមានប៉ុន្មាននាក់? **ប្រហែល១២នាក់ (ឬច្រើនជាងនេះ) ។**

៤) ហេតុអ្វីបានជាអ្នកទោសទាំងនោះអាចរួចរស់ជីវិតបាន? **អ្នកទោសទាំងនោះអាចរួចរស់ជីវិតដោយសារតែមានជំនាញរបស់ខ្លួន ដូចជា ជាងគំនូរ ជាងជួសជុលនាឡិកា និងជាងចម្លាក់ ដែលមានប្រយោជន៍សម្រាប់មន្ទីរស-២១ ។**

៥) តើអ្នកទោសស្ត្រីត្រូវទទួលរងការធ្វើបាបយ៉ាងដូចម្តេច? **អ្នកទោសស្ត្រីមួយចំនួនត្រូវអ្នកសួរចម្លើយចាប់រំលោភ ។**

៦) តើបន្ទប់តូចៗ នៅជាន់ទី១ នៃមន្ទីរស-២១ ដែលប្រើប្រាស់សម្រាប់ឃុំឃាំងអ្នកទោសម្នាក់ៗ មានទំហំប៉ុន្មាន? **បន្ទប់នីមួយៗ មានប្រវែង០,៨០ម៉ែត្រគុណនឹង២ម៉ែត្រ ។**

៧) តើអ្នកទោសភាគច្រើននៅមន្ទីរស-២១ ក្រៅពីជនជាតិខ្មែរ ជាជនជាតិអ្វី? **វៀតណាម ។**

៨) តើនរណាជាប្រធានមន្ទីរស-២១? **ឌុច ដែលមានឈ្មោះដើម កាំង ហ្កេកអ៊ាវ ។**

៩) តើក្រុមរង៣ នៅក្នុងអង្គភាពសួរចម្លើយរបស់មន្ទីរស-២១ មានអ្វីខ្លះ? និងមានតួនាទីអ្វីខ្លះ? **“ក្រុមរងក្តៅ” ត្រូវបានអនុញ្ញាតឲ្យប្រើទណ្ឌកម្ម ។ “ក្រុមរងត្រជាក់” ឬហៅថា “ក្រុមស្លូត” មិនត្រូវបានអនុញ្ញាតឲ្យប្រើទណ្ឌកម្មដើម្បីចម្រាញ់យកចម្លើយសារភាពនោះទេ ។ “ក្រុមរងអន្លៀម” ធ្វើការជាមួយករណីសំខាន់ ។**

១០) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើ សុន សេន មានតួនាទីអ្វី? **គាត់ជាឧបនាយករដ្ឋមន្ត្រីទី៣ ទទួលបន្ទុកការពារជាតិ និងទទួលខុសត្រូវដោយផ្ទាល់ទៅលើមន្ទីរស-២១ ។**

១១) នៅពេលដែលអស់កន្លែងសម្រាប់កប់ខ្មោច តើអ្នកទោសត្រូវបញ្ជូនទៅសម្លាប់នៅកន្លែងណា? **នៅជើងឯក ដែលមានចម្ងាយប្រហែល១៣គីឡូម៉ែត្រ ភាគនិរតីទីក្រុងភ្នំពេញ ។**






**រូបខាងឆ្វេង** ៖ រូបថតអ្នកទោស ចាន់ គឹមស្រ៊ុន ហៅ សាង ។ ចាន់ គឹមស្រ៊ុន គឺជាប្រពន្ធរបស់កម្មាភិបាលខ្មែរក្រហមដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ។ បច្ចុប្បន្នកូនស្រីម្នាក់របស់អ្នកទាំងពីរនៅរស់រានមានជីវិត និងរស់នៅខេត្តកំពង់ស្ពឺ ។

**រូបខាងលើ** ៖ សេក សាយ បច្ចុប្បន្នអាយុ៤៩ឆ្នាំ ជាកូនស្រីតែម្នាក់របស់ ចាន់ គឹមស្រ៊ុន ដែលនៅរស់ ។ នៅក្នុងរូបថតដែលថតនៅចុងខែវិច្ឆិកា ឆ្នាំ២០១០ សេក សាយ បង្ហាញពីរូបថត ដែលលោក ឆាំង យុ រៀបរាប់ពីប្រវត្តិរបស់ ចាន់ គឹមស្រ៊ុន ទៅកាន់លោកស្រី ហ៊ីលឡារី គ្លីនតុន រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលបានធ្វើទស្សនកិច្ចជាផ្លូវការលើកទីមួយនៅកម្ពុជាកាលពីខែវិច្ឆិកា ឆ្នាំ២០១០ ។ រូបថត ៖ ញាណ សុជាតិ

## មេរៀនទី២ ៖ នៅក្រោយជញ្ជាំងនៃមន្ទីរស-២១

*តម្រូវឲ្យមាន ឌីវីឌី និង វីស៊ីអរ (DVD/VCR) សម្រាប់បញ្ចាំងខ្សែភាពយន្ត (សកម្មភាពនេះគឺឥតកំហិត)*

**វត្ថុបំណង**

១) សិស្សមើលឃើញការមកដល់របស់ខ្មែរក្រហម និងការផ្លាស់ប្តូរដែលខ្មែរក្រហមបានធ្វើទៅលើប្រជាជន និង អត្តចរិតពិតប្រាកដរបស់ខ្មែរក្រហម ។

២) សិស្សបង្ហាញពីអ្វីដែលខ្លួនឃើញ ។

៣) សិស្សធ្វើការប្រៀបធៀបបទពិសោធន៍របស់ជនរងគ្រោះ និងកម្មាភិបាលនៅក្រោមរបបខ្មែរក្រហម ។

៤) សិស្សត្រិះរិះពិចារណា ពេលតាមដានខ្សែភាពយន្ត ឬមើលផ្ទាំងរូបភាព ។

**សម្ភារឧបទេស** ៖ ខ្សែភាពយន្ត «នៅក្រោយជញ្ជាំងនៃមន្ទីរស-២១» ឬផ្ទាំងរូបភាព និងសៀវភៅលំហាត់ ។

**លំនាំបង្រៀន**

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងសម្រាប់មេរៀននៅក្នុងថ្ងៃនេះ និងសង្ខេបខ្សែភាពយន្ត ឬផ្ទាំងរូបភាព ។ គ្រូបង្ហាញពីសេចក្តីដកស្រង់នៃខ្សែភាពយន្ត ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សសរសេរការយល់ឃើញផ្ទាល់ខ្លួនអំពីខ្សែភាពយន្ត ឬផ្ទាំងរូបភាពនៅក្នុងសៀវភៅលំហាត់ ។

*សំយោគ (១៥-២៥នាទី)*

គ្រូពិភាក្សាអំពីអត្ថន័យនៃខ្សែភាពយន្ត ឬផ្ទាំងរូបភាព និងរបៀបនៃខ្សែភាពយន្ត ឬផ្ទាំងរូបភាពនេះ ដែលបានផ្លាស់ប្តូរ ឬគាំទ្រគំនិត ឬចំណេះដឹងដែលសិស្សមានអំពីរបបខ្មែរក្រហម ។







**រូបខាងលើ** ៖ ទិដ្ឋភាពខាងក្នុងគុកទួលស្លែង បច្ចុប្បន្នសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។

**រូបខាងក្រោម** ៖ ផ្នូរអ្នកទោសដែលសាកសពត្រូវបានគេឃើញនៅគុកទួលស្លែង នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្នុងបរិវេណសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ រូបថត ៖ កែវ ដាស៊ីល

# ជំពូក១១ ៖ ទំនាក់ទំនងការបរទេស



យោធាខ្មែរក្រហម និងទីប្រឹក្សាចិន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## មេរៀនទី១ ៖ អំណានជំពូក១០ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

**វត្ថុបំណង**

១) សិស្សរៀបរាប់អំពីអ្វីដែលជាកំហុសនៅក្នុងអតីតកាល និងអ្វីដែលចាំបាច់ត្រូវធ្វើនៅក្នុងពេលបច្ចុប្បន្នដើម្បីស្តារឡើងវិញនូវអ្វីដែលបានបាត់បង់ ។

២) សិស្សប្រៀបធៀបជីវិតនាពេលបច្ចុប្បន្ន និងជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

៣) សិស្សពន្យល់ពីសារសំខាន់នៅនៃលទ្ធិប្រជាធិបតេយ្យ ។

៤) សិស្សកំណត់ និងឲ្យនិយមន័យពាក្យសំខាន់ៗមួយចំនួន ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

**ពន្យល់ពាក្យ** ៖

| | | |
|---|---|---|
| ស្ថានទូត | ឥទ្ធិពល | ពាណិជ្ជកម្មក្រៅប្រទេស |
| ការនាំចូល | ទំនាក់ទំនងការបរទេស | ការនាំចេញ |
| ការចរចា | សិទ្ធិមនុស្ស | ប្រជាធិបតេយ្យ |
| សិទ្ធិជនជាតិភាគតិច | | |

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូណែនាំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងពិភាក្សាពីភាពខុសគ្នារវាងជីវិតនាពេលបច្ចុប្បន្ន និងជីវិតនៅក្នុងរបបខ្មែរក្រហម ។ បន្ទាប់មកគ្រូឲ្យសិស្សពិភាក្សាពាក្យសំខាន់ៗនៅក្នុងជំពូក១០ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងពិភាក្សាថា តើរបបខ្មែរក្រហមមានផលប៉ះពាល់មកលើជីវិតនាពេលបច្ចុប្បន្នដូចម្ដេចខ្លះ ។ គ្រូសួរសិស្សនូវសំណួរដូចតទៅ ៈ តើយើងត្រូវស្ដារឡើងវិញនូវអ្វីដែលយើងបានបាត់បង់ដោយរបៀបណា? តើលទ្ធិប្រជាធិបតេយ្យមានន័យដូចម្ដេចចំពោះអ្នក? ហេតុអ្វីបានជាលទ្ធិប្រជាធិបតេយ្យមានសារសំខាន់?

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអាន និងកត់ត្រាដោយយកចិត្តទុកដាក់អំពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជំពូក១០ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ សិស្សសរសេរព្រឹត្តិការណ៍ទាំងនោះនៅក្នុងសៀវភៅលំហាត់ដើម្បីបង្ហាញពីការសិក្សារបស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) តើកម្ពុជាប្រជាធិបតេយ្យ ធ្វើទំនាក់ទំនងការទូតជាមួយប្រទេសណាខ្លះ? (ឲ្យឈ្មោះប្រទេសទាំង៩) **ចិន កូរ៉េខាងជើង វៀតណាម ឡាវ គុយបា រូម៉ានី យូហ្គោស្លាវី អាល់បានី និងអេហ្ស៊ីប ។**

២) តើប្រទេសដែលមានចំណងមិត្តភាពល្អជាមួយកម្ពុជាប្រជាធិបតេយ្យមានប្រទេសណាខ្លះ? **ចិន កូរ៉េខាងជើង និង ឡាវ ។**

៣) តើបក្សកុម្មុនីស្តកម្ពុជាមានគោលនយោបាយចំពោះអ្នកដែលមានទំនាក់ទំនងជាមួយវៀតណាមយ៉ាងណា? **ជាទូទៅអ្នកទាំងនោះត្រូវបានធ្វើបាបសម្លាប់ (លើកលែងតែ សុន សេន និង អៀង សារី) ។**

៤) តើកោះដែលមានការប្រយុទ្ធគ្នារវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមមានឈ្មោះអ្វី? **កោះត្រល់ ឬហៅជា ភាសាវៀតណាមថា "កោះភូកុក" ។**

៥) តើប្រទេសណាគាំទ្រកម្ពុជាប្រជាធិបតេយ្យឲ្យប្រឆាំងនឹងវៀតណាម? តើប្រទេសណាគាំទ្រវៀតណាមឲ្យប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ? **ចិនគាំទ្រខ្មែរក្រហម ហើយសូវៀតគាំទ្រវៀតណាម ។**

៦) តើផលិតផលនាំចេញសំខាន់ៗរបស់កម្ពុជាប្រជាធិបតេយ្យមានអ្វីខ្លះ? (ឲ្យឈ្មោះយ៉ាងតិច៣) **ស្រូវ កៅស៊ូ និង សរីរាង្គសត្វ (ដូចជាស្បែក ក្អក និងស្នូក) ។**

៧) តើផលិតផលនាំចូលសំខាន់ៗរបស់កម្ពុជាប្រជាធិបតេយ្យមានអ្វីខ្លះ? (ឲ្យឈ្មោះយ៉ាងតិច៣) **អាវុធ រថក្រោះ កាំភ្លើងធំ គ្រឿងចក្រកសិកម្ម សារធាតុគីមី និងក្រណាត់ ។**

៨) នៅពេលដែលកម្ពុជាប្រជាធិបតេយ្យស្នើសុំឲ្យចិនជួយច្បាំងតទល់នឹងវៀតណាម តើចិនឆ្លើយតបមកវិញយ៉ាងដូចម្ដេច? **ចិនបានបដិសេធសំណើនេះ ហើយស្នើឲ្យមានបទឈប់បាញ់គ្នា និងធ្វើការចរចា ។ កម្ពុជាប្រជាធិបតេយ្យបានទាត់ចោលសំណើនោះ ។**

៩) តើ អៀង សារី ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំណា? **ឆ្នាំ១៩៩៦ ។**

## មេរៀនទី២ ៖ ប័ណ្ណស្ដីអំពីទំនាក់ទំនងការបរទេស



កម្មាភិបាលខ្មែរក្រហម និងទីប្រឹក្សាចិន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

### វត្ថុបំណង

១) សិស្សពន្យល់អំពីសារសំខាន់នៃចំណងការទូតជាមួយបរទេស ប្រកបដោយការស្ថាបនា ។

២) សិស្សពណ៌នាពីទំនាក់ទំនងជាមួយចិន វៀតណាម និងសហរដ្ឋអាមេរិក ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សបង្កើតប័ណ្ណមួយ ដើម្បីសរសេរ និងផ្ដល់យោបល់អំពីវិធីស្ថាបនា និងពង្រឹងទំនាក់ទំនងការបរទេស ។

៤) សិស្សរៀបចំផែនការ និងលើកឡើងពីការធ្វើឲ្យប្រសើរឡើង ឬរក្សានិរន្តភាពទំនាក់ទំនងការបរទេស ។

**សម្ភារឧបទេស ៖** សៀវភៅប្រវត្តិសាស្ត្រ សៀវភៅលំហាត់ និងក្រដាសសបត់ជាពផ្នត់ ។

### លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូណែនាំអំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងពិភាក្សាអំពីប្រទេសមួយចំនួនដែលកម្ពុជាធ្លាប់មានចំណងការទូតទាំងមុនក្នុងរយៈកាល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សសរសេរអំពី «របៀបធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងការបរទេស» នៅក្នុងទម្រង់ជាប័ណ្ណ១សន្លឹក ។ ខណៈពេលដែលសិស្សកំពុងស្រង់គំនិត គ្រូអាចចោទសំណួរដូចជា ៖

១) តើអ្វីជាគោលបំណង ក្នុងការមានទំនាក់ទំនងល្អជាមួយប្រទេសផ្សេងទៀត?

២) តើកម្ពុជាអាចជំរុញទំនាក់ទំនងប្រកបដោយសន្តិភាព ជាមួយប្រទេសផ្សេងទៀតបានដោយរបៀបណា?

៣) តើកម្ពុជាទទួលបានផលប្រយោជន៍អ្វីខ្លះក្នុងការធ្វើទំនាក់ទំនងជាមួយប្រទេសជិតខាង?

៤) តើផលប្រយោជន៍ ឬតម្លៃអ្វីខ្លះ ដែលកម្ពុជាគួរពិចារណា នៅពេលធ្វើការជាមួយប្រទេសផ្សេងទៀត?
(ឧទាហរណ៍ ៖ សេដ្ឋកិច្ច ការផ្លាស់ប្តូរវប្បធម៌ សន្តិភាព និង ចំណងមិត្តភាពជាប្រវត្តិសាស្ត្រ)

៥) ប្រសិនបើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើង នៅក្នុងប្រទេសជិតខាង តើឧក្រិដ្ឋកម្មទាំងនេះមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះមកលើកម្ពុជា?

សិស្សត្រូវបត់ក្រដាសសជាពាក់កណ្តាល ៗ ដោយប្រើប្រាស់ព័ត៌មានដែលបានសិក្សារួច ។ សិស្សត្រូវបង្ហាញអំពីសារសំខាន់ និងផលប្រយោជន៍ក្នុងការកសាងទំនាក់ទំនងការបរទេស ហើយពន្យល់ពីរបៀបដែលនឹងអាចធ្វើឲ្យប្រសើរឡើង ឬរក្សាទំនាក់ទំនងទាំងនេះ ។

សំយោគ (១៥-២៥នាទី)

សិស្សចែករំលែកគំនិតរបស់ខ្លួនដែលបានសរសេរនៅក្នុងប័ណ្ណជាមួយសិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។

# ជំពូក១២ ៖ ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ



អ្នកភូមិប្រមូលផ្តុំគ្នាដើម្បីពិភាក្សាពីការធ្វើញត្តិរណសិរ្សដែលចងក្រងពីឧក្រិដ្ឋកម្មរបស់ ប៉ុល ពត ឆ្នាំ១៩៨២ ។
ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា និងទីភ្នាក់ងារសារព័ត៌មានវៀតណាម

## មេរៀនទី១ ៖ អំណានជំពូក១១ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### វត្ថុបំណង

១) សិស្សពន្យល់អំពីកម្រិតប៉ះពាល់នៃអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើជីវិត និងសតិអារម្មណ៍របស់ជនរងគ្រោះ ។

២) សិស្សពណ៌នាពីសេចក្តីក្លាហាន និងកម្លាំងតស៊ូរបស់ជនរងគ្រោះពីអំពើឧក្រិដ្ឋក្នុងរបបខ្មែរក្រហម ។

៣) សិស្សកំណត់និយមន័យនៃពាក្យសំខាន់ៗមួយចំនួន ដែលទាក់ទងនឹងការរួចរស់ជីវិតពីអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។

៤) សិស្សសំយោគការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ និងសៀវភៅលំហាត់ ។

**ពន្យល់ពាក្យ និង ឈ្មោះសំខាន់ៗ** ៖

| | | |
|---|---|---|
| បាក់កម្លាំង | ការដួលរលំ | ហ៊ុនស៊ិនប៉ិច |
| ការវាយប្រហារ | ការដកថយ | ការរំលាយទ័ព |
| កន្ទុះជីវជាតិ | ទុរ្ភិក្ស | មាតុភូមិនិវត្តន៍ |
| រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា | យុត្តិធម៌ដោយហឹង្សមនុស្ស | |

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀននៅថ្ងៃនេះ និងពិភាក្សាអំពីអ្វីដែលសិស្សបានដឹងទាក់ទងនឹងការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក គ្រូឲ្យសិស្សពិភាក្សាពាក្យ និងឈ្មោះសំខាន់ៗនៅក្នុងជំពូក១១ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គ្រូសួរសិស្សនូវសំណួរដូចតទៅ ៖ តើព្រឹត្តិការណ៍សំខាន់ៗក្រោយរបបខ្មែរក្រហមមានអ្វីខ្លះ? ដើម្បីចាប់ផ្ដើមជីវិតសាជាថ្មីឡើងវិញ តើអ្នកនៅរស់រានមានជីវិតត្រូវធ្វើអ្វីខ្លះ? តើគុណសម្បត្តិផ្ទាល់ខ្លួនដែលចាំបាច់នាពេលនោះ មានអ្វីខ្លះ? (ឧទាហរណ៍ ៖ សេចក្ដីក្លាហាន ភាពរឹងមាំ ភាពដែលមិនអាចបំបែកបាន ការអត់ធ្មត់ និងភាពទន់ភ្លន់) ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអាន និងកត់ត្រាដោយយកចិត្តទុកដាក់អំពីព្រឹត្តិការណ៍សំខាន់ៗ ហើយសរសេរក្នុងសៀវភៅលំហាត់ ដើម្បីឆ្លុះបញ្ចាំងពីការសិក្សារបស់ខ្លួន ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

### សំណួរណែនាំ និងចម្លើយ

១) តើមូលហេតុ៣យ៉ាងនៃការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យមានអ្វីខ្លះ? **១) សភាពទុក្ខទោមរបស់ប្រជាជន ២) បន្សុទ្ធកម្ម និង ៣) ការប៉ះទង្គិចជាមួយវៀតណាម ។**

២) នៅពេលដែលផលិតផលស្រូវមិនគ្រប់តាមផែនការកំណត់ តើកម្មាភិបាលខ្មែរក្រហមធ្វើយ៉ាងដូចម្ដេចដើម្បីដោះស្រាយជាមួយនឹងការខ្វះខាតនេះ? **គឺរាយការណ៍បន្លំ និងបញ្ជូនស្រូវទៅតាមផែនការកំណត់របស់មជ្ឈិមបក្សដោយបង្អត់អាហារប្រជាជន ។**

៣) តើភូមិភាគណាដែលទទួលការពិន័យពី ប៉ុល ពត នៅឆ្នាំ១៩៧៧? **ភូមិភាគបូព៌ា ។**

៤) តើខ្មែរក្រហមបានចាត់វិធានការប្រឆាំងនឹងវៀតណាមនៅពាក់កណ្ដាលឆ្នាំ១៩៧៧បែបណា? **ខ្មែរក្រហមបាន បាញ់ផ្លោងចូលខេត្តចូវដុក ស្រុកហាទៀង និងខេត្តមួយចំនួនទៀតរបស់វៀតណាម ។**

៥) នៅខែធ្នូ ឆ្នាំ១៩៧៧ វៀតណាម បានបើកការវាយប្រហារក្នុងទ្រង់ទ្រាយធំមួយមកលើកម្ពុជាប្រជាធិបតេយ្យ តើវៀតណាមកាន់កាប់បានតំបន់ណាខ្លះ? **វៀតណាមកាន់កាប់បានតំបន់ចំពុះ‌ទា (ចំពុះសេក) ក្នុងខេត្តស្វាយរៀង ។**

៦) នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨ តើវិទ្យុក្រុងហាណូយបានប្រកាសអំពីការបង្កើតរណសិរ្សអ្វី? **រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។**

៧) តើអ្នកដឹកនាំរណសិរ្សនេះជានរណា? **សមមិត្ត ហេង សំរិន ដែលបានភៀសខ្លួនទៅវៀតណាម នៅចុងឆ្នាំ១៩៧៨ ។**

៨) តើវៀតណាមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃខែឆ្នាំណា? **ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។**

៩) វៀតណាមបានជួយបង្កើតរបបថ្មីមួយនៅក្នុងទីក្រុងភ្នំពេញ តើរបបនោះមានឈ្មោះអ្វី? **សាធារណរដ្ឋប្រជាមានិតកម្ពុជា ។**

១០) តើចលនាតស៊ូមិនមែនកុម្មុយនីស្តដំបូងបំផុតនៅកម្ពុជា ដែលប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានឈ្មោះអ្វី? **រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។**

១១) តើរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ រួមមានក្រុមនយោបាយណាខ្លះ? **ក្រុមរាជានិយមហ៊្វុនស៊ិនប៉ិច ក្រុមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងក្រុមខ្មែរក្រហម ។ ខ្មែរក្រហមគឺជាក្រុមធំជាងគេនៅក្នុងរដ្ឋាភិបាលនេះ ។**

១២) តើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ត្រូវបានចុះហត្ថលេខាដោយភាគីខ្មែរទាំងអស់នៅថ្ងៃខែឆ្នាំណា? **ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។**

**១៣)** តើភាគីណាធ្វើពហិការមិនព្រមចូលរួមការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ និងបដិសេធមិនព្រមកាត់រំសាយទ័ពរបស់ខ្លួន? **ខ្មែរក្រហម ។**

១៤) តើមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមដែលចុះចូលជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៨ មានឈ្មោះអ្វីខ្លះ? កែ ពក នួន ជា និង ខៀវ សំផន ។ តើការចុះចូលនេះមានបញ្ហាអ្វីខ្លះ? **ចម្លើយអាចប្រែប្រួល ។**

១៥) តើ តាម៉ុក ត្រូវបានចាប់ខ្លួននៅពេលណា? **ខែមីនា ឆ្នាំ១៩៩៩ ។**

## មេរៀនទី២ : រូបភាពថ្ងៃរំដោះ



ប្រជាជនកម្ពុជាមានទឹកមុខសប្បាយរីករាយ ។ បដាសរសេរថា (ពីឆ្វេងទៅស្តាំ) “ជយោ! ប្រទេសកម្ពុជាបានរំដោះទាំងស្រុង” និង “ជយោ! ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា” ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ប្រភព: បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា និងទីភ្នាក់ងារសារព័ត៌មានវៀតណាម

### វត្ថុបំណង

១) សិស្សបង្ហាញពីចិត្តអាណិតអាសូរចំពោះប្រជាជនកម្ពុជាទូទៅ និងយល់អំពីការបដិសេធសិទ្ធិជាមូលដ្ឋានរបស់មនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សពន្យល់អំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ និងផលចាំពីអំពើឃោរឃៅដែលមនុស្សធ្វើមកលើមនុស្សដូចគ្នា ។

៣) សិស្សពិពណ៌នាអំពីរូបភាពនៅថ្ងៃរំដោះ រួចសរសេររបាយការណ៍អំពីរូបភាពនោះ ។

៤) សិស្សបង្កើតរបាយការណ៍ព័ត៌មាន ដែលអធិប្បាយពីថ្ងៃរំដោះ ។

**សម្ភារឧបទេស :** ក្រដាស ប៊ិចពណ៌ ខ្មៅដៃ ទស្សនាវដ្ដី កាវ កន្ត្រៃ សៀវភៅរូបភាព និងសៀវភៅលំហាត់

**លំនាំបង្រៀន**

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូណែនាំអំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ហើយឲ្យសិស្សពិនិត្យមើលរូបថត និងរូបភាពផ្សេងៗទៀតនៃថ្ងៃរំដោះ នៅក្នុងសៀវភៅលំហាត់ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សពណ៌នា និងសរសេររបាយការណ៍មួយអំពីទិដ្ឋភាពនៅថ្ងៃទី៧ មករា ១៩៧៩ ដោយផ្អែកទៅលើការអាន និងចំណេះដឹងដែលមានពីមុនមក ។ សិស្សសម្ភាសឪពុកម្ដាយអំពីបទពិសោធន៍របស់គាត់ និងសួរថា តើគាត់មានអារម្មណ៍ចង់សងសឹក ឬឲ្យមានយុត្តិធម៌តាមផ្លូវតុលាការ ។





ប្រជាជនកម្ពុជាធ្វើដំណើរដ៏វែងឆ្ងាយត្រឡប់ទៅកាន់ស្រុកកំណើតវិញ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

*សំយោគ (១៥-២៥នាទី)*

សិស្សឡើងបង្ហាញរូបភាព និងរបាយការណ៍ព័ត៌មានរបស់ខ្លួនទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។ គ្រូប្រើប្រាស់របាយការណ៍ព័ត៌មាននេះ ដើម្បីវាយតម្លៃការសិក្សារបស់សិស្ស ។

## មេរៀនទី៣ ៖ ការធ្វើឱ្យប្រសើរឡើងនូវរបបអាហារ និងជីវជាតិសម្រាប់អ្នកដែលនៅរស់រានមានជីវិត

### វត្ថុបំណង

១) សិស្សរៀបរាប់តារាងនៃចំណីអាហារជាមូលដ្ឋាន ។

២) សិស្សពន្យល់អំពីការខ្វះខាតចំណីអាហារ និងការបង្កឲ្យមានជំងឺខ្វះជីវជាតិ និងជំងឺផ្សេងៗទៀត ។

៣) សិស្សកំណត់ចំណីអាហារជាមូលដ្ឋាន ដែលចាំបាច់សម្រាប់ជីវិតប្រកបដោយសុខភាពល្អ ។

៤) សិស្សបង្កើតបញ្ជីឈ្មោះនៃរបបអាហារដែលប្រកបដោយសុខភាព ។

**សម្ភារឧបទេស ៖** សៀវភៅលំហាត់ តារាងណែនាំអំពីចំណីអាហារដែលមានជីវជាតិ និងរូបថត ។

### ការជម្នះកង្វះជីវជាតិជាមួយនឹងអាហារដែលមានគុណភាព

កង្វះជីវជាតិ គឺជាកត្តាគ្រោះថ្នាក់ដ៏ចម្បងបំផុត ដែលបណ្ដាលឲ្យមនុស្សគ្រប់វ័យកើតមានជំងឺ និងស្លាប់ សូម្បីតែទារក និងកុមារតូចៗក៏ប្រហែលជាអាចទទួលរងគ្រោះថ្នាក់នេះខ្លាំងជាងគេ ពីព្រោះជីវជាតិទាំងអស់ គឺមានសារសំខាន់ណាស់ សម្រាប់ការធ្វើឲ្យធំធាត់ និងការវិវត្ត ។ អង្គការសុខភាពពិភពលោក បានឲ្យនិយមន័យពាក្យ កង្វះអាហារូបត្ថម្ភ ថា ជាការខ្វះខាតជីវជាតិសមល្មមសម្រាប់ការថែទាំ ការលូតលាស់ និងការវិវត្តរបស់មនុស្ស ។ កង្វះអាហារូបត្ថម្ភ ជាកត្តានាំឲ្យមានការស្លាប់កុមារជាងពាក់កណ្ដាលនៅលើពិភពលោក ។ ប្រជាជនដែលរស់នៅក្នុងតំបន់សង្គ្រាម តំបន់ដែលមានគ្រោះធម្មជាតិ ឬតំបន់ដែលទទួលរងនូវភាពក្រីក្រ ទទួលរងគ្រោះថ្នាក់ធំជាងគេបង្អស់ចំពោះកង្វះជីវជាតិ ព្រោះតែភាពមិនទៀងទាត់នៃការផលិត និងការចែកចាយចំណីអាហារ ។

ដោយយោងតាមភាពធ្ងន់ធ្ងរនៃការធ្លាក់ចុះនូវជីវជាតិ កង្វះអាហារូបត្ថម្ភ ប្រហែលជាប៉ះពាល់ទាំងរាងកាយ និងស្មារតី ។ ខាងក្រោមគឺជារោគសញ្ញានៃការខ្វះជីវជាតិ ៖

- មិនគ្រប់ទម្ងន់
- វិលមុខ
- មានការលំបាកក្នុងការផ្ដោតអារម្មណ៍
- ខ្សោយសាច់ដុំ
- ជ្រុះសក់
- ធ្មេញពុក
- ហើម និងចេញឈាមតាមអញ្ចាញធ្មេញ
- ស្បែកស្ងួតហើយរបក
- នឿយហត់ និងអស់កម្លាំង
- ឆ្អឹងស្រួយ ដែលបណ្ដាលឲ្យងាយបាក់
- រារាំងដល់ការលូតលាស់
- ហើមក្រពះ
- ប្រព័ន្ធការពារចុះខ្សោយ
- មុខងារសរីរាង្គកាយមានបញ្ហា

បញ្ហាកង្វះជីវជាតិ អាចត្រូវបានព្យាបាល ដោយទទួលទានអាហារគ្រប់គ្រាន់ និងមានគុណភាព (សូមមើលតារាងអាហារប្រកបដោយសុខភាព) ។ អាហារដែលមានគុណភាព មានន័យថា ការទទួលបាននូវប្រភេទ និងបរិមាណអាហារ ព្រមទាំងភេសជ្ជៈត្រឹមត្រូវ ដើម្បីផ្គត់ផ្គង់ជីវជាតិ និងថាមពលសម្រាប់ថែរក្សាដំណើរការនៃរាងកាយ ក៏ដូចជាសម្រាប់ទ្រទ្រង់ការលូតលាស់ និងការវិវត្តន៍ធម្មតា ។ អាហារដែលមានគុណភាព តម្រូវឲ្យមានប្រភេទអាហារផ្សេងៗគ្នាពីក្រុមអាហារមួយក្នុងចំណោមក្រុមអាហារទាំង៦ ។ អាហារដែលមានគុណភាព ផ្ដោតទៅលើផ្លែឈើ បន្លែ និងទឹកដោះគោ ឬផលិតផលទឹកដោះគោ ដែលមិនមានជាតិខ្លាញ់ ឬមានជាតិខ្លាញ់ទាប ។ វាក៏រួមបញ្ចូលនូវសាច់សុទ្ធ មាន់ ត្រី ស៊ុត គ្រាប់ធញ្ញជាតិ និងអាហារ ដែលមានជាតិខ្លាញ់ទាបដែរ ។

## តារាងអាហារប្រកបដោយសុខភាព

| ក្រុមអាហារ | អាហារ | បរិមាណអាហារប្រចាំថ្ងៃ សម្រាប់កុមារ | បរិមាណអាហារប្រចាំថ្ងៃ សម្រាប់មនុស្សពេញវ័យ |
|---|---|---|---|
| គ្រាប់ធញ្ញជាតិ | អង្ករ,<br>នំបញ្ចុក,<br>នំប៉័ង | គ្រាប់ធញ្ញជាតិ ៤ចានតូចសម្រាប់កុមារអាយុ ២-៥ឆ្នាំ<br>៥ចានតូចសម្រាប់កុមារ អាយុដែលចូលរៀនហើយ | ពី៥ - ១០ចានតូច |
| បន្លែ | ត្រកួន, ល្ហុងខ្ចី,<br>ផ្កាខាត់ណាខៀវ,<br>ស្ពៃក្តោប, ការ៉ុត,<br>ត្រសក់, ល្ពៅ,<br>ប៉េងប៉ោះ, ជី,<br>ត្រប់វែង,<br>សណ្តែកទ្រើង | ២ចានតូចសម្រាប់កុមារ អាយុពី២-៥ឆ្នាំ<br>៣ចានតូចសម្រាប់កុមារ ដែលចូលរៀនហើយ | ២-៤ចានតូច |
| ផ្លែឈើ | ចេក, ស្វាយ,<br>ល្ហុង, សាវម៉ាវ,<br>គូលែន, ត្របែក,<br>ឪឡឹក, មៀន | ២ចានតូច | ១-៣ចានតូច |
| ប្រូតេអ៊ីន | សាច់, ត្រី<br>ស៊ុត, មាន់<br>សណ្តែកទ្រើង<br>សណ្តែកដី<br>តៅហ៊ូ | ១ចានតូច | ១-២ចានតូច |
| ផលិតផលទឹកដោះគោ | ទឹកដោះគោ,<br>យ៉ាអួរ, ហ្វ្រូម៉ា | ២-៣កែវ ឬហ្វ្រូម៉ា២ ចំណិត | ១-២កែវ<br>ឬហ្វ្រូម៉ា២ ចំណិត |
| ប្រេងឆា ស្ករ និង ខ្លាញ់ | ប្រេងធ្វើពីបន្លែ<br>(អូលីវ និង ពោត) | ប្រេងឆា១ស្លាបព្រា ឬបន្ថែមមួយចានតូច | ប្រេងឆា១ស្លាបព្រា ឬ<br>បន្ថែមមួយចានតូច |



សម្លម្ជូរជាមួយមាន់អាំង បន្លែ ទឹកជ្រលក់ និងបាយ ។ រូបថត ៖ កែវ ដាស៊ីល

ពិនិត្យមើលឧទាហរណ៍ខាងក្រោម ៖

**អាហារពេលព្រឹក ៖** អាហារនេះរួមមានគុយទាវសាច់គោជាមួយសណ្ដែកបណ្ដុះ និងជី ។ មានក្រុមអាហារចំនួន៣ខុសគ្នា ៖ គ្រាប់ធញ្ញជាតិ សាច់ និងបន្លែ ដែលរួមបញ្ចូលនៅក្នុងអាហារនេះ

- គុយទាវ = ១ចានតូច
- សាច់គោ = មួយភាគបួននៃចានតូច
- សណ្ដែកបណ្ដុះ = មួយភាគបួននៃចានតូច
- ជី = មួយភាគបួននៃចានតូច
- ទឹក = មួយពែង

**អាហារថ្ងៃត្រង់ ៖** អាហារនេះរួមមានសាច់មាន់ឆាខ្ញី បាយ ចេក និងទឹកក្រូចមួយកែវ ។ មានក្រុមអាហារចំនួន៥ខុសគ្នា ៖ គ្រាប់ធញ្ញជាតិ សាច់មាន់ បន្លែ ប្រេងឆា និងផ្លែឈើ នៅក្នុងអាហារនេះ ។

- បាយ = ២ចានតូច
- សាច់មាន់ = មួយភាគបួននៃចានតូច
- ខ្ញី = មួយភាគបួននៃចានតូច
- ប្រេងឆា = ១ស្លាបព្រា
- ចេក = ១
- ទ្រុះដូង = ១ពែង

**អាហារពេលល្ងាច ៖** អាហារនេះរួមមានអាហារសមុទ្រ សម្លម្ជូរបន្លែ បាយ បង្អែម និងកាហ្វេ ។ មានក្រុមអាហារ៥ផ្សេងគ្នា ៖ គ្រាប់ធញ្ញជាតិ ត្រី និងង៉ាវ បន្លែ ផ្លែឈើ និងបង្អែម ដែលរួមបញ្ចូលនៅក្នុងអាហារនេះ ។

- បាយ = ១ចានតូច
- បង្គា = មួយភាគបួននៃចានតូច
- ត្រី = មួយភាគបួននៃចានតូច

- ប៉េងប៉ោះ = មួយភាគបួននៃចានតូច
- មើមឈូក = មួយភាគបួននៃចានតូច
- ម្ទេស = មួយភាគបួននៃចានតូច
- ជី = មួយភាគបួននៃចានតូច
- បាយដំណើប = កន្លះចានតូច
- ស្វាយ = មួយភាគបួននៃចានតូច
- ទឹក = មួយពែង




អាហារសម្រន់ទូទៅ និងផ្លែឈើនៅប្រទេសកម្ពុជា ។ រូបថត ៈ កែវ ដាស៊ីល

ឲ្យសិស្សធ្វើការជាដៃគូ ដើម្បីបង្កើតបញ្ជីអាហារប្រកបដោយសុខភាពមួយសម្រាប់មួយថ្ងៃ ដែលស្របតាមការណែនាំនៅក្នុងតារាងអាហារ ។ សិស្សអាចបញ្ចូលអាហារដែលខ្លួនបរិភោគ ក៏ដូចជាអាហារផ្សេងទៀតដែលខ្លួនគិតថា មានសុខភាពល្អ និងឆ្ងាញ់ ។ ទុកពេលវេលាឲ្យក្រុមទាំងអស់ ដើម្បីចែករំលែកបញ្ជីអាហារ ជាមួយសិស្សទាំងអស់នៅក្នុងថ្នាក់ ។

### សកម្មភាពបន្ថែម

១) គ្រូឲ្យសិស្សពិភាក្សាអាហារដែលខ្លួនចូលចិត្ត? តើអាហារទាំងអស់នេះ ស្ថិតនៅក្នុងក្រុមអាហារមួយណា? តើអាហារទាំងអស់នេះមានសុខភាពល្អដែរឬទេ?

២) គ្រូឲ្យសិស្សរាយបញ្ជីអាហារដែលសិស្សបរិភោគជាធម្មតាក្នុងមួយថ្ងៃ ៈ អាហារពេលព្រឹក អាហារថ្ងៃត្រង់ អាហារសម្រន់ និងអាហារពេលល្ងាច ។ បង្ហាញអំពីរបៀបរាយឈ្មោះអាហារនីមួយៗ ។ គ្រូទុកពេលឲ្យសិស្សនៅក្នុងថ្នាក់រាយអាហារដែលខ្លួនបានបរិភោគរួចហើយ ។

៣) គ្រូឲ្យសិស្សប្រៀបធៀបអាហារដែលខ្លួនបានបរិភោគ ជាមួយអាហារនៅក្នុងតារាងអាហារសុខភាព ។ តើមុខម្ហូបប៉ុន្មានមុខដែលសិស្សបានបរិភោគ? តើអាហារដែលសិស្សបានបរិភោគ ស្របនឹងបរិមាណដែលបានណែនាំដែរឬទេ? តើក្រុមអាហារធញ្ញជាតិចំនួនប៉ុន្មានដែលសិស្សបានបរិភោគ? តើបរិមាណនេះសមស្របទៅនឹងបរិមាណណែនាំដែរឬទេ? សិស្សអាចប្រើប្រាស់តារាងអាហារសុខភាព ដើម្បីប្រៀបធៀបជាមួយអ្វីដែលខ្លួនបានបរិភោគជាមួយនឹងបរិមាណអាហារដែលបានណែនាំ ។



ប្រជាជនកំពុងចម្អិនអាហារនៅពហុកីឡដ្ឋានជាតិអូឡាំពិក បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ប្រភព ៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា

គ្រូឲ្យសិស្សធ្វើការជាដៃគូ ដើម្បីពិភាក្សាពីអាហារដែលខ្លួនបានបរិភោគ និងប្រៀបធៀបជាមួយនឹងតារាងអាហារសុខភាព ។ គ្រូឲ្យសិស្សស្ម័គ្រចិត្តពន្យល់ពីអ្វីដែលខ្លួនបានរៀន ។ តើសិស្សបំពេញបាននូវតម្រូវការនៃតារាងអាហារបានល្អកម្រិតណា? តើបរិមាណអាហារកម្រិតណា ដែលសិស្សបានបរិភោគពីក្រុមអាហារនៅខាងក្រោមនៃតារាង? តើសិស្សត្រូវធ្វើដូចម្តេចដើម្បីធានាឲ្យបានថា ខ្លួនបរិភោគអាហារប្រកបដោយគុណភាពល្អ?

**លំនាំបង្រៀន**

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមបង្រៀន គ្រូណែនាំអំពីវត្ថុបំណងនៃមេរៀនក្នុងថ្ងៃនេះ ហើយពិភាក្សាថាតើមនុស្សទទួលរងគ្រោះយ៉ាងខ្លាំងដូចម្តេចខ្លះពីការអត់អាហារ និងកង្វះអាហារូបត្ថម្ភនៅក្នុងរយៈកាលនៃរបបខ្មែរក្រហម ។ បន្ទាប់មក គ្រូពិនិត្យមើលពីសារសំខាន់នៃជីវជាតិ និងផលប៉ះពាល់នៃកង្វះអាហារូបត្ថម្ភ ។ (សូមមើលគេហទំព័រសុខភាពនិងជីវជាតិ និងអង្គការដែលមានរាយឈ្មោះនៅផ្នែកបញ្ចប់នៃសៀវភៅនេះ ដើម្បីជាប្រភពធនធាន) ។ គ្រូនឹងពិភាក្សាពីជំងឺដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភ និងសួរសំណួរខាងក្រោមទៅកាន់សិស្ស ៖ ហេតុអ្វីបានជាគុណភាពអាហារមានសារសំខាន់? តើអ្វីខ្លះ គឺជាធាតុផ្សំនៃរបបអាហារដ៏ល្អមួយ? តើអាហារមិនល្អមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះទៅលើសុខភាព និងសុខមាលភាពរបស់សង្គម?

*ការបង្រៀន (១៥-៤៥នាទី)*

(កំណត់ចំណាំ ៖ ដោយសារចំណីអាហារមិនមានលក្ខណៈដូចគ្នានៅទូទាំងប្រទេសកម្ពុជា គ្រូត្រូវតែផ្តោតអារម្មណ៍ទៅលើលទ្ធភាពដែលសិស្សប្រហែលជាមិនមានជម្រើសច្រើនក្នុងការកំណត់«ម្ហូបអាហារដែលមានគុណភាព» ។ ដោយសារមេរៀននេះ ជាមេរៀនដែលពិបាក គ្រូអាចរំលងមេរៀននេះចោល ដោយហេតុថា អាចនឹងកើតមានផលប៉ះពាល់ ឬការព្រួយបារម្ភណាមួយនៅតាមតំបន់ដែលខ្លួនបង្រៀនជាយថាហេតុ) ។

សិស្សសម្ភាសឪពុកម្ដាយ និងសរសេរតែងសេចក្ដីអំពីរបៀបក្នុងការធ្វើឲ្យប្រសើរឡើងនូវរបបអាហារ និងជីវជាតិ សម្រាប់អ្នកដែលនៅរស់រានមានជីវិត ដើម្បីធ្វើឲ្យប្រសើរឡើងនូវសុខភាពរបស់គាត់ បន្ទាប់ពីឆ្លងកាត់របបខ្មែរក្រហម ។

*សំយោគ (១៥-២៥នាទី)*

សិស្សចែករំលែកការផ្ដល់យោបល់ទៅលើអាហារប្រកបដោយសុខភាពរបស់ខ្លួន ទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។ គ្រូនឹងវាយតម្លៃការសិក្សារបស់សិស្សនៅក្នុងពេលនេះ ។

## មេរៀនទី៤ ៖ ការសិក្សាប្រៀបធៀបអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ

### វត្ថុបំណង

១) សិស្សសិក្សាកាន់តែស៊ីជម្រៅថែមទៀត អំពីបទពិសោធន៍របស់ប្រជាជននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សពន្យល់មិត្តរួមថ្នាក់ អំពីបទពិសោធន៍របស់ប្រជាជននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សប្រៀបធៀបអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាមួយនឹងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗទៀតដែលកើតមាននៅក្នុងប្រវត្តិសាស្ត្រសាកលលោក ។

៤) សិស្សវិភាគ និងវាយតម្លៃអំពីប្រវត្តិរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម និងបទពិសោធន៍របស់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលកើតមានឡើងនៅក្នុងប្រទេសផ្សេងទៀត ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅកត់ត្រា អត្ថបទ សៀវភៅ និងប្រភពធនធានផ្សេងៗទៀតដែលទាក់ទងនឹងប្រធានបទនេះ ។

### ប្រធានបទទី១ ៖ ប្រទេសកម្ពុជា របបខ្មែរក្រហម

**បរិបទប្រវត្តិសាស្ត្រ** ៖ សិស្សអាចត្រឡប់ទៅមើលសៀវភៅកត់ត្រា សៀវភៅប្រវត្តិសាស្ត្រ និងការសិក្សាពីមុនមក ។

**រឿងរ៉ាវផ្ទាល់ខ្លួន** ៖ សិស្សអាចត្រឡប់ទៅមើលប្រវត្តិរឿងរ៉ាវរបស់ជនរងគ្រោះនៅក្នុងកំណត់ហេតុរបស់ខ្លួន សៀវភៅប្រវត្តិសាស្ត្រ និងការសិក្សាពីមុនរបស់ខ្លួននៅក្នុងថ្នាក់ ឬមើលសៀវភៅលំហាត់ ។

### ប្រធានបទទី២ ៖ អាល្លឺម៉ង់

**បរិបទប្រវត្តិសាស្ត្រ** ៖ ពាក់កណ្ដាលសតវត្សរ៍ទី២០ ឆ្នាំ១៩៥៥

**រឿងរ៉ាវផ្ទាល់ខ្លួន** ៖ សិស្សអាចត្រឡប់ទៅមើលរឿងរ៉ាវនៅក្នុងកំណត់ហេតុ សៀវភៅ និងអំណានផ្សេងៗមុនពេលរៀន ឬសៀវភៅលំហាត់ ។

សម្រាប់ប្រជាជនអាល្លឺម៉ង់ភាគច្រើន បរាជ័យរបស់ប្រទេសអាល្លឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទីមួយ គឺជាភាពអាម៉ាស់ និងជាការអាប់ឱនកិត្តិយសជាតិជាទីបំផុតមួយ ។ បរាជ័យនេះ បានក្លាយជាលទ្ធផលនៃការបាត់បង់អំណាច ភាពអាម៉ាស់ដ៏យូរអង្វែង និងការសងបំណុលផ្នែកសេដ្ឋកិច្ចទៅឲ្យប្រទេសអឺរ៉ុបជាច្រើនទៀត ។ បរាជ័យនេះបាននាំទៅដល់ការ

រៀបចំបង្កើតរដ្ឋាភិបាលបែបលទ្ធិប្រជាធិបតេយ្យមួយ ប៉ុន្តែដោយសារតែភាពគ្មានការងារធ្វើដ៏ធំ អតិផរណា និងអស្ថិរភាពផ្នែកសេដ្ឋកិច្ច បណ្តាលឲ្យមានការទាមទារសម្រាប់ទិសដៅថ្មី និងនិយមន័យថ្មីមួយទៀតសម្រាប់ប្រទេសអាល្លឺម៉ង់ ។ បរាជ័យរបស់អាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទីមួយជាមួយនឹងឱនភាពសេដ្ឋកិច្ច បានជំរុញឲ្យប្រជាជនអាល្លឺម៉ង់ធ្វើការស្វែងរកនូវមនោគមន៍វិជ្ជាថ្មី ដែលនឹងអាចជួយបង្រួបបង្រួម និងផ្តល់នូវក្តីសង្ឃឹមថ្មីសម្រាប់ប្រជាជនអាល្លឺម៉ង់ ។ ក្រុមនិយមឆ្វេងស្តាំបានធ្វើការតស៊ូ ដើម្បីការគ្រប់គ្រងដែលស្តែងចេញសម្រាប់ភាពស្មោះត្រង់របស់ប្រជាជនអាល្លឺម៉ង់ទាំងអស់ ។ ក្រោយពីការតស៊ូអស់រយៈពេលជាច្រើនឆ្នាំ ក្រុមណាហ្ស៊ីដែលស្ថិតនៅក្រោមការដឹកនាំរបស់ អាល់ដូហ្វ ហ៊ីត្លែ បានសម្រេចក្តោបក្តាប់អំណាចដែលទទួលបានពីអ្នកបោះឆ្នោតនៅក្នុងប្រទេសអាល្លឺម៉ង់ ។ ក្នុងកិច្ចប្រឹងប្រែងបង្រួបបង្រួមប្រទេសដឹកនាំដោយគណបក្សណាហ្ស៊ី មេដឹកនាំបក្សណាហ្ស៊ីរូបនេះបានជឿលើទ្រឹស្តីបន្លាស់ប្តូរគោលនយោបាយជាតិពន្ធុ និងទ្រឹស្តីវិទ្យាសាស្ត្រដែលមិនពិត ។ ទ្រឹស្តីទាំងនេះត្រូវបានប្រើសម្រាប់បង្រួបបង្រួមប្រជាជនអាល្លឺម៉ង់ ឲ្យស្ថិតនៅក្រោមមនោគមន៍វិជ្ជាមួយដែលត្រូវបានគេហៅថា ភាពបរិសុទ្ធនៃជាតិពន្ធុ មោទកភាពជាតិ និងបរាជ័យរបស់សត្រូវផ្ទៃក្នុង និងសត្រូវបរទេសរបស់អាល្លឺម៉ង់ ។

ដោយស្ថិតនៅក្រោមស្លាកភាពបរិសុទ្ធនៃពូជសាសន៍ មោទកភាពជាតិ និងការស្តារកិត្តិយសជាតិអាល្លឺម៉ង់ឡើងវិញ ក្រុមណាហ្ស៊ីបានបង្កើតកម្មវិធីជាច្រើនប្រភេទ ដើម្បីរៀបចំសង្គមអាល្លឺម៉ង់ឡើងវិញជាថ្មីម្តងទៀត ។ ក្រុមណាហ្ស៊ី បានប្រមូលផ្តុំប្រជាជនអាល្លឺម៉ង់ឲ្យស្ថិតនៅពីក្រោយបុព្វហេតុរបស់ខ្លួន ដោយចាត់ទុកមនុស្សមួយចំនួនថា ជាមនុស្សអាក្រក់ និងជាដើមហេតុនៃបញ្ហារបស់អាល្លឺម៉ង់ ។ ជនជាតិ ជ្វីហ្វ (Jews) ជីពស៊ីស (Gypsies) និងប្រជាជនស្លាវិក (Slavic) គឺស្ថិតនៅក្នុងចំណោមក្រុមមនុស្សដទៃទៀតដែលត្រូវបានចាត់ទុកជាមនុស្សអាក្រក់ ។ ការវាយប្រហារលើក្រុមប្រជាជនទាំងនេះ គឺជាដំណាក់កាលដំបូងបង្អស់នៃគម្រោងការរបស់ក្រុមណាហ្ស៊ី ក្នុងការធ្វើឲ្យ «ប្រជាជាតិអាល្លឺម៉ង់» មានភាពបរិសុទ្ធ ។

ប្រជាជនអាល្លឺម៉ង់ ត្រូវបានជំរុញលើកទឹកចិត្តឲ្យមានភាពស្អប់ខ្ពើមលើជនជាតិជ្វីហ្វ ដែលមិនត្រូវបានឲ្យតម្លៃជាមនុស្សក្នុងសង្គម និងត្រូវបានទុកដោយឡែកឲ្យនៅឆ្ងាយពីសង្គម ។ ជនជាតិជ្វីហ្វ បានតម្រូវឲ្យពាក់រូបសញ្ញា "ផ្កាយ" នៅខាងក្រៅសម្លៀកបំពាក់របស់ខ្លួន ដើម្បីធ្វើការសម្គាល់ជនជាតិជ្វីហ្វ ឲ្យដាច់ដោយឡែកពីប្រជាជនដទៃផ្សេងទៀត ។ ការប្រកបរបររកស៊ីរបស់ជនជាតិជ្វីហ្វត្រូវបានបដិសេធ និងដកហូត ។ ជនជាតិជ្វីហ្វទាំងអស់ ត្រូវបានបង្ខំឲ្យផ្លាស់ទៅរស់នៅក្នុងជំរំប្រមូលផ្តុំដាច់សង្វែងមួយ ដែលមានភាពងាយស្រួលក្នុងការគ្រប់គ្រង ។ ជនជាតិជ្វីហ្វ ត្រូវបានពណ៌នាថា ជាមនុស្សកាចសាហាវ ។

ជាមួយនឹងការចាប់ផ្តើមនៃសង្គ្រាមលោកលើកទី២ និងការកាន់កាប់លើទ្វីបអឺរ៉ុប និងដែនដីសូវៀត ក្រុមណាហ្ស៊ី មានផែនការពង្រីកបន្ថែមទៀតនូវផែនការធ្វើឲ្យបរិសុទ្ធជនជាតិអាល្លឺម៉ង់នៅក្នុងតំបន់កាន់កាប់ខាងលើនេះ ។ កងសន្តិសុខពិសេស ត្រូវបញ្ជូនទៅកាន់តំបន់កាន់កាប់ទាំងនោះ ក្នុងគោលបំណងរៀបចំការសម្លាប់ក្នុងទ្រង់ទ្រាយធំលើជនជាតិជ្វីហ្វ ។

នៅទីបញ្ចប់ នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៤២ សមាជិកបក្សណាហ្ស៊ី និងមេដឹកនាំរបស់រដ្ឋាភិបាលមួយចំនួនបានជួបជុំគ្នាដើម្បីពិភាក្សាលើ «ដំណោះស្រាយចុងក្រោយ» ទាក់ទងនឹងបញ្ហារបស់ជនជាតិជ្វីហ្វ» ។ «ដំណោះស្រាយចុងក្រោយ» បានក្លាយជាសញ្ញាសម្គាល់របស់ក្រុមណាហ្ស៊ីសម្រាប់ការសម្លាប់ក្នុងទ្រង់ទ្រាយធំលើជនជាតិជ្វីហ្វនៅទ្វីបអឺរ៉ុបដែលបានគ្រោងទុកជាមុន និងធ្វើឡើងដោយមានចេតនា ។ ឧត្តមសេនីយ៍ រីនហាត ហេយឌ្រីច (Reinhard Heydrich) បានស្នើថា ជនជាតិជ្វីហ្វចំនួន១១លាននាក់ ដែលមកពីប្រទេសចំនួន២០ក្នុងទ្វីបអឺរ៉ុប នឹងត្រូវសម្លាប់នៅក្នុងផែនការនេះ ។

ដំណោះស្រាយចុងក្រោយ គឺជាគោលនយោបាយរបស់រដ្ឋាភិបាលអាល្លឺម៉ង់ ក្នុងការសម្លាប់រង្គាលនូវពូជសាសន៍មួយទាំងស្រុង ដោយប្រើប្រាស់ជំរំប្រមូលផ្តុំដែលគ្រប់គ្រងដោយរដ្ឋ ។ បុរស ស្ត្រី និងកុមារជនជាតិជ្វីហ្វ ត្រូវបានដឹកជញ្ជូនតាមរថភ្លើងមកពីគ្រប់ប្រទេសទាំងអស់ ក្នុងទ្វីបអឺរ៉ុបទៅកាន់ជំរំអូស្វិច (Auschwitz) ទ្រីប្លីកា (Treblinka) និងមូលដ្ឋានសម្លាប់សំខាន់ៗបួនកន្លែងទៀត ដែលកាន់កាប់ដោយអាល្លឺម៉ង់នៅក្នុងប្រទេសប៉ូឡូញ ។ រហូតមកដល់ឆ្នាំ១៩៤៥ អាល្លឺម៉ង់ និងសហការីរបស់ខ្លួនបានសម្លាប់ ឬបានបង្កឲ្យមានការសម្លាប់មកលើជនជាតិជ្វីហ្វរហូតដល់ទៅ ៦លាននាក់ ។ សហគមន៍រាប់រយរបស់ជនជាតិជ្វីហ្វនៅអឺរ៉ុប ដែលខ្លះមានអាយុកាលជាច្រើនសតវត្សរ៍មកហើយ ត្រូវបានរលាយសាបសូន្យជារៀងរហូត ។

សតវត្សរ៍នៃការរើសអើងសាសនាប្រឆាំងនឹងជនជាតិជ្វីហ្វនៅក្នុងទ្វីបអឺរ៉ុប ដែលកាន់សាសនាគ្រិស្តត្រូវបានពង្រឹងឡើងវិញ ដោយគោលនយោបាយប្រឆាំងនឹងជនជាតិជ្វីហ្វ តាមបែបសម័យទំនើបមួយដែលវិវត្តចេញមកពីការរួមផ្សំគ្នានៃគំនិតជាតិនិយមជ្រុលហួសហេតុ អសន្តិសុខផ្នែកហិរញ្ញវត្ថុ ភាពភ័យខ្លាចចំពោះមនោគមន៍វិជ្ជាកុម្មុយនីស្ត និងវិទ្យាសាស្ត្រនៃការពិនិត្យមើលជាតិសាសន៍ដែលបានផ្តល់ជាកម្លាំងបន្ថែមដល់ដំណើការនៃការកាប់សម្លាប់ជនជាតិជ្វីហ្វ ។

**សេចក្តីដកស្រង់ចេញពីសាច់រឿង**

*ជនជាតិជ្វីហ្វ និងប្រជាជនដទៃទៀតដែលជាមុខសញ្ញារបស់ក្រុមណាហ្ស៊ី ត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងជំរំប្រមូលផ្តុំ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រង និងការដឹកជញ្ជូនជនជាតិជ្វីហ្វទៅកាន់ជំរំប្រមូលផ្តុំ ឬជំរំពលកម្មដោយបង្ខំ ។ ជាញឹកញាប់ អ្នកដែលមិនអាចធ្វើការបានដោយសារតែវ័យចាស់ជរា ជំងឺ ឬពិការភាព ត្រូវបានសម្លាប់ចោល ។ សម្រាប់ប្រជាជនភាគច្រើន ការងារពលកម្ម គឺជាឱកាសមួយសម្រាប់បង្ហាញតម្លៃរបស់ខ្លួនទៅកាន់អ្នកចាប់ចង ។ ម្យ៉ាងវិញទៀត នេះគឺជាហេតុផលតែមួយគត់ដែលអ្នកខ្លះអាចរួចរស់ជីវិតបាន ។ នៅចំណុចនេះ ជនរងគ្រោះ បានពិពណ៌នានូវបទពិសោធន៍មួយនៅឯរោងចក្រកាត់ដេរ ជាកន្លែងដែលនាងត្រូវបានបង្ខំឲ្យធ្វើការងារ ។*

ជី (G) កើតនៅក្នុងគ្រួសារជនជាតិជ្វីហ្វមួយ ដែលមានជីវភាពមធ្យមនៅទីក្រុងមួយក្នុងប្រទេសប៉ូឡូញ ដែលជាទីក្រុងមួយល្បីល្បាញខាងសិប្បកម្មវាយនភណ្ឌរបស់ប្រទេសប៉ូឡូញ ។ នាងចាប់ផ្តើមចូលរៀននៅសាលាសារដ្ឋ ក្នុងប្រទេសប៉ូឡូញ ប៉ុន្តែក្រោយមកនាងចូលរៀននៅក្នុងសាលាកាតូលិកសម្រាប់សិស្សស្រី ។ មេដឹកនាំសាសនារបស់ជនជាតិជ្វីហ្វ ត្រូវបានអនុញ្ញាតឲ្យចូលបង្រៀនសិស្សជនជាតិជ្វីហ្វ សម្រាប់មុខវិជ្ជាសាសនា ។

បន្ទាប់ពីត្រូវបានផ្លាស់ទៅកាន់ជំរំប្រមូលផ្តុំបីលស្កូ (Bielsko) នៅឆ្នាំ១៩៤២ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅរោងចក្រវាយនភណ្ឌនៅបូលខិនហាន (Bolkenhain) ក្នុងទីក្រុងស៊ីលីសៀ (Silesia) ។ ទោះបីជាមានភាពអត់ឃ្លាន និងការងារពលកម្មធ្ងន់ធ្ងរយ៉ាងណាក្តី ក៏អ្នកជាប់ឃុំឃាំងទាំងអស់ចេះជួយយកអាសាគ្នាទៅវិញទៅមក ។ អ្នកទទួលការខុសត្រូវជនជាតិអាល្លឺម៉ង់ម្នាក់ គឺអ្នកស្រី ខេ បានជួយជីវិតរបស់ខ្ញុំ ។ ខ្ញុំបានធ្លាក់ខ្លួនឈឺ និងត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យនៅក្នុងជំរំ ។ អ្នកស្រីដឹងថា កងសន្តិសុខនឹងធ្វើការត្រួតពិនិត្យ ហើយសម្លាប់អ្នកជំងឺចោលដោយប្រើផ្សែងពុល ។ អ្នកស្រី ខេ អៀវខ្ញុំមកកាន់រោងចក្រវិញ ដោយចាប់យកកីតម្បាញរបស់ខ្ញុំហើយដាក់ខ្ញុំឲ្យអង្គុយនៅពីមុខកីនោះ ។ ខ្ញុំវង្វេងស្មារតីដោយសារតែជំងឺគ្រុនក្តៅ ប៉ុន្តែខ្ញុំបានគេចផុតពីការតាមដាន ។

**សេចក្តីដកស្រង់ចេញពីសាច់រឿង**

*ជនជាតិជ្វីហ្វ ជីពស៊ីស និង ជនជាតិស្លាវិក ជាមួយនឹងក្រុមមនុស្សជាច្រើនទៀតដែលជាមុខសញ្ញារបស់ក្រុម*

*ណាហ្ស៊ី ត្រូវបានប្រមូលផ្តុំ និងយកទៅដាក់នៅក្នុងមន្ទីរឃុំឃាំងសម្រាប់ធ្វើជាទាសករពលកម្ម និងសម្លាប់ចោល ។ មន្ទីរឃុំឃាំងដែលបានពិពណ៌នាក្នុងចម្លើយដកស្រង់នេះ មានឈ្មោះថា ម៉ាដដានេក (Majdanek) ។*

យើងបានមកដល់ម៉ាដដានេកនៅក្នុងខែកក្កដា ។ ខ្ញុំគិតថាប្រហែលជាខែសីហា ឆ្នាំ១៩៤៣ ។ យើងត្រូវតែឈរជីកប្រឡាយ ហើយឪពុករបស់ខ្ញុំឈរជីកបន្ទាប់ពីខ្ញុំ ។ ឪពុករបស់ខ្ញុំក៏ជាអ្នកទោសដូចខ្ញុំដែរ ។ បុរសជនជាតិប៉ូឡូញម្នាក់បានដើរកាត់កន្លែងខ្ញុំធ្វើការ ស្រាប់តែភ្លាមនោះ បុរសនោះបានទាញយកដុំថ្មគប់ចំឪពុករបស់ខ្ញុំ ។ ដុំថ្មនោះប៉ះចំជើងរបស់គាត់ ។ ពេលនោះខ្ញុំមិនដឹងថាជើងរបស់គាត់បាក់ឬក៏យ៉ាងណាទេ ។ នៅពេលយប់ ពេលយើងដើរត្រឡប់មកបន្ទាយទាហានវិញ ឪពុករបស់ខ្ញុំមិនអាចដើរបានឡើយ ។ ដូច្នេះខ្ញុំ និងមិត្តភក្តិ ត្រូវតែគ្រាហ៍គាត់ ឬពេលខ្លះអៀវគាត់ ។ ខ្ញុំបាននាំគាត់ចូលក្នុងបន្ទាយ ហើយដាក់គាត់ឲ្យដេកសណ្តូកជើង ។ គ្រាន់តែក្នុងរយៈពេលមួយភ្លែតសោះ ជើងរបស់គាត់បានហើមធំឡើង ។ ឃើញដូច្នេះ បុរសម្នាក់បាននិយាយថា យើងគួរតែទៅហៅពេទ្យ ឬនរណាម្នាក់មកជួយ ។ នៅទីនោះ អ្នកទាំងអស់គ្នាហៅគ្រូពេទ្យថា "សាន់នីតឺ" (Sanitaer) ។ សម្រាប់ខ្ញុំនៅពេលនោះ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងនោះទេ នៅពេលដែលមានមនុស្សឈឺ ។ ខ្ញុំមិននឹកស្មានថា មានរឿងដូច្នេះកើតឡើងឡើយ ។ ខ្ញុំគិតថានៅពេលមាននរណាម្នាក់ឈឺនោះ គ្រូពេទ្យនឹងមកធ្វើការព្យាបាល ។ បុរសដែលមកពិនិត្យឪពុកខ្ញុំ គាត់ពាក់អាវពេទ្យដែលមានរូបសញ្ញាបូកពណ៌ក្រហម ។ ពេលឃើញសភាពរបស់ឪពុកខ្ញុំហើយ បុរសនោះក៏នាំឪពុកខ្ញុំចេញទៅដោយបាននិយាយទៅកាន់ឪពុកខ្ញុំថា "អ្នកដឹងទេថា អ្នកត្រូវតែទៅមន្ទីរពេទ្យ" ។ បុរសនោះបាននិយាយមកកាន់ខ្ញុំថា គេនឹងនាំឪពុកខ្ញុំមកវិញនៅថ្ងៃស្អែក ។ ចាប់ពីពេលនោះមក ខ្ញុំមិនដែលបានជួបឪពុករបស់ខ្ញុំទៀតឡើយ ។ យ៉ាងណាមិញ បុរសជនជាតិប៉ូឡូញនោះមិនមានហេតុផលអ្វីដែលត្រូវយកដុំថ្មមកគប់លើនរណាម្នាក់ឡើយ ។ ឪពុកខ្ញុំគ្រាន់តែឈរនៅមួយកន្លែងសោះ ។ ដុំថ្មនោះគួរតែគប់មកចំខ្ញុំ ប៉ុន្តែវាបែរជាចំឪពុកខ្ញុំទៅវិញ ។

**សេចក្តីដកស្រង់ចេញពីសាច់រឿង**

*ជនជាតិជ្វីហ្វ ជីពស៊ី និងជនជាតិស្លាវិក ជាមួយនឹងក្រុមមនុស្សជាច្រើនដែលជាមុខសញ្ញារបស់ក្រុមណាហ្ស៊ី ត្រូវបានប្រមូលផ្តុំ និងយកទៅដាក់នៅក្នុងមន្ទីរឃុំឃាំងសម្រាប់ធ្វើជាទាសករពលកម្ម និងសម្លាប់ ។ នៅពេលនេះ ជនរងគ្រោះនឹងពិពណ៌នាអំពីការមកដល់ការជ្រើសរើស និងការបែកគ្នាពីក្រុមគ្រួសាររបស់គាត់នៅមន្ទីរឃុំឃាំងមួយនៅអូសស្វិច ។*

វាយប់ជ្រៅណាស់ទៅហើយ នៅពេលយើងបានមកដល់ អូសស្វិច ។ នៅពេលដែលយើងដើរចូលទៅ ទ្វាររបងក៏របើកឡើង ហើយយើងបានឮសំឡេងមនុស្សស្រែក សំឡេងឆ្កែព្រុស ហើយយើងបានទទួលការវាយក្បាលពីកងសន្តិសុខ ៗ ។ បន្ទាប់មក យើងក៏នាំគ្នាចេញពីរថភ្លើង ។ រំពេចនោះ អ្វីៗទាំងអស់កើតឡើងយ៉ាងរហ័ស មនុស្សរត់ពីឆ្វេងទៅស្តាំ ឬពីស្តាំទៅឆ្វេង ។ ប្តីបែកពីប្រពន្ធ កូនក្មេងរបូតដៃវង្វេងពីម្តាយ ហើយក្រុមមនុស្សចាស់ត្រូវបានដេញវាយធ្វើបាបដូចជាសត្វធាតុ ។ ចំណែកឯអ្នកជំងឺ និងជនពិការ ទទួលការគំរាមកំហែង និងទាត់ឲ្យនៅមួយកន្លែងដូចសំរាម ។ ក្រោយមកអ្នកទាំងអស់ក៏ត្រូវគ្រវែងឲ្យទៅម្ខាងទាំងអស់គ្នា ជាមួយនឹងវ៉ាលិសដែក និងហិប ។ ម្តាយរបស់ខ្ញុំបានរត់មកឱបស្មាខ្ញុំហើយប្រាប់ខ្ញុំថា "ម៉ែមិនអាចជួបកូនបានទៀតឡើយ មើលប្អូនប្រុសរបស់ឯងផង" ។

**សេចក្តីដកស្រង់ចេញពីសាច់រឿង**

*(ជនជាតិជ្វីហ្វ ត្រូវបានជម្លៀសចេញពីកន្លែងរស់នៅរបស់ខ្លួននៅតាមទីក្រុងជាច្រើន ហើយត្រូវបានបង្ខំឲ្យ*

ទៅរស់នៅក្នុងជំរំប្រមូលផ្តុំ ដើម្បីដាក់ជនជាតិជ្វីហ្វឲ្យនៅដាច់ដោយឡែកពីសង្គម និងដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងជនជាតិជ្វីហ្វទាំងអស់នេះ ។ នៅពេលនេះ ជនរងគ្រោះនឹងពិពណ៌នាអំពីការដើរស្វែងរកចំណីអាហារនៅក្នុងព្រៃ ដើម្បីស្រោចស្រង់ជីវិតបន្ទាប់ពីលួចរត់ចេញពីជំរំប្រមូលផ្តុំ ហូរ៉ូឆូវ (Horochow) ។

ខ្ញុំនឹងរៀបរាប់ប្រាប់ពីការរស់នៅរបស់ខ្ញុំនៅក្នុងព្រៃ ។ ខ្ញុំមិនដឹងអ្វីទាំងអស់ ប៉ុន្តែវាជារឿងដ៏អស្ចារ្យណាស់សម្រាប់ខ្ញុំ ។ នៅពេលដែលមនុស្សម្នាក់ឃ្លាន និងអស់សង្ឃឹម អ្នកនោះនឹងក្លាយជាមនុស្សច្នៃប្រឌិត ។ ទោះបីជាពេលនេះខ្ញុំនឹងនិយាយពីបទពិសោធន៍នាពេលនោះក៏ដោយ ក៏ខ្ញុំខ្លួនឯងស្ទើរតែមិនជឿដែរ ។ ខ្ញុំបានហូប ដង្កូវ សត្វល្អិត និងអ្វីទាំងអស់ដែលខ្ញុំអាចដាក់ចូលក្នុងមាត់របស់ខ្ញុំបាន ។ ខ្ញុំមិនស្គាល់អ្វីទាំងអស់នៅក្នុងព្រៃ ពេលខ្លះខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់ ។ នៅក្នុងនោះមានផ្សិតព្រៃ ហើយខ្ញុំក៏ដឹងថា ផ្សិតទាំងនោះគឺជាផ្សិតពុលដែរ ។ ប៉ុន្តែ ខ្ញុំមិនដឹងថា ផ្សិតមួយណាពុលនោះទេ ហើយក្រោយមកខ្ញុំក៏ធ្លាក់ខ្លួនឈឺ ។ ពោះរបស់ខ្ញុំគឺពោរពេញទៅដោយបញ្ហា ប៉ុន្តែខ្ញុំនៅតែព្យាយាមស្វែងរកអ្វីមកដាក់ក្នុងមាត់របស់ខ្ញុំពីព្រោះថា ខ្ញុំត្រូវការអ្វីហូប ។ ខ្ញុំដងទឹកភក់ពីគ្រប់កន្លែងទាំងអស់ដែលខ្ញុំអាចស្វែងរកបានយកមកផឹក ។ ពេលខ្លះ ខ្ញុំបានលួចចូលទៅក្នុងបន្ទប់ដាក់ដំឡូងបារាំងនៅក្រោមដី ដែលក្រុមកសិករបានធ្វើនៅជុំវិញភូមិរបស់គេ ហើយកន្លែងនេះគឺជាទីកន្លែងដ៏ល្អមួយសម្រាប់លាក់ខ្លួន ព្រោះតែបន្ទប់នេះធ្វើឲ្យមានភាពកក់ក្តៅនៅរដូវរងា ។ ប៉ុន្តែនៅក្នុងបន្ទប់នោះពោរពេញទៅដោយសត្វកណ្តុរ ហើយបើនិយាយពីរឿងនេះ ខ្ញុំបានហូបសត្វកណ្តុរទាំងរស់ ។ ជាក់ស្តែងខ្ញុំពិតជាចង់រស់ណាស់ ។ ខ្ញុំបានប្រព្រឹត្តនូវសកម្មភាពជាច្រើនដែលពិបាកនឹងបរិយាយ ។ ខ្ញុំបានហូបអ្វីៗដែលគ្មាននរណាម្នាក់អាចនឹកស្មានដល់ ។ យ៉ាងណាមិញ ខ្ញុំអាចរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។ ខ្ញុំក៏មិនដឹងថា មូលហេតុអ្វីដែលធ្វើឲ្យខ្ញុំនៅមានជីវិតដែរ ។ ខ្ញុំនៅតែសួរខ្លួនឯងរហូត ។

## ប្រធានបទទី៣ : អ៊ីរ៉ាក់

***សាសនា*** : ម៉ូស្លីម៩៧ភាគរយ, គ្រិស្ត និងសាសនាដទៃទៀត៣ភាគរយ ។

***ការបែងចែកក្រុមជាតិពន្ធុ*** : អារ៉ាប់៧៥-៨០ភាគរយ, ជនជាតិឃឺដ (Kurdish) ១៥-២០ភាគរយ, ជនជាតិទួកុម៉ាន (Turkoman) ជនជាតិអាស៊ីរៀន (Assyrian) និង ជនជាតិដទៃទៀតសរុប៥ភាគរយ ។

***បរិបទប្រវត្តិសាស្ត្រ*** : ទសវត្សរ៍ឆ្នាំ១៩៨០

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ អ៊ីរ៉ង់ និងអ៊ីរ៉ាក់បានធ្វើសង្គ្រាមនឹងគ្នា ។ ក្នុងសង្គ្រាមនេះជនជាតិឃឺដ ទាំងអស់ដែលស្ថិតនៅក្នុងភូមិភាគខាងជើងបានធ្វើការការពារគ្រប់គ្រងយ៉ាងខ្លាំងក្លានៅលើដែនដីរបស់ខ្លួន ហើយក៏បានធ្វើការចងសម្ព័ន្ធមិត្តជាមួយនឹងប្រទេសអ៊ីរ៉ង់ជាប្រទេសជិតខាង (ដែលកំពុងតែធ្វើសង្គ្រាមជាមួយអ៊ីរ៉ាក់) ។ រដ្ឋាភិបាលអ៊ីរ៉ាក់ ដែលដឹកនាំដោយ សាដាម ហ៊ូសេន (Saddam Hussein) មានអារម្មណ៍ថា ខ្លួនកំពុងតែស្ថិតនៅក្រោមការគំរាមកំហែង ដោយសារតែការពង្រីកទីតាំងយ៉ាងលឿនរបស់ជនជាតិឃឺដ ហើយក៏សម្រេចធ្វើការគ្រប់គ្រងទៅលើតំបន់ដែលជនជាតិឃឺដកំពុងតែកាន់កាប់ ។ រដ្ឋាភិបាលអ៊ីរ៉ាក់បានប្រកាសថា ជនជាតិឃឺដទាំងអស់ដែលរស់នៅក្នុង«តំបន់ហាមឃាត់» មួយចំនួននឹងត្រូវសម្លាប់ចោល ។ យុទ្ធនាការនេះត្រូវបានស្គាល់ថា ជាយុទ្ធនាការ «អាន់ហ្វល» (Anfal) ហើយជាយុទ្ធនាការដែលបង្ហាញអំពីដំណោះស្រាយរបស់រដ្ឋាភិបាលចំពោះបញ្ហាជនជាតិឃឺដ ។

កងទ័ពអ៊ីរ៉ាក់បានបាញ់កាំភ្លើងធំ ទម្លាក់គ្រាប់បែក និងប្រើប្រាស់អាវុធជីវសាស្ត្រមកលើអ្នកភូមិជនជាតិឃឺដរាប់ពាន់នាក់ ។ នៅចន្លោះខែកុម្ភៈ និងខែកញ្ញា ឆ្នាំ១៩៨៨ ដោយការប៉ាន់ស្មានមានភាពខុសគ្នា ជនជាតិឃឺដប្រមាណពីប្រាំម៉ឺនទៅមួយសែនប្រាំបីម៉ឺននាក់ ត្រូវបានសម្លាប់នៅក្នុងអំឡុងពេលនៃយុទ្ធនាការប្រឆាំងនឹងជនជាតិឃឺដ ។ ពាក្យ "អាន់ហ្វាល" មានន័យជាភាសាអារ៉ាប់ថា "ពួកស្អុយរលួយ" ដែលពាក្យនេះគឺជាយុទ្ធនាការយោធាដំណាក់កាលទី៨ ប្រឆាំងនឹងជនជាតិឃឺដនៅអ៊ីរ៉ាក់ ។ ជនជាតិឃឺដជាច្រើននាក់បានស្លាប់ដោយសារខស្ម័នពុល ។ ទោះបីជាយុទ្ធនាការនេះជាជម្លោះរវាងកងកម្លាំងយោធាអ៊ីរ៉ាក់ជាមួយនឹងកងកម្លាំងឃឺដក៏ដោយ ក៏យុទ្ធនាការ"អាន់ហ្វាល"នេះ បានបណ្ដាលឲ្យមានការសម្លាប់រង្គាល និងការបាត់ខ្លួនរបស់ជនជាតិឃឺដរាប់រយពាន់នាក់ ហើយបានបំផ្លាញភូមិឋានប្រមាណចំនួនពីរពាន់ភូមិ ។ លើសពីនេះ អ្នកភូមិរាប់រយពាន់នាក់ត្រូវបានផ្លាស់ទីកន្លែង ។

សាក្សី (ឈ្មោះត្រូវបានដាក់ឲ្យ)

ឆ្នាំកំណើត ៖ ឆ្នាំ១៩៥៤

មុខរបរ ៖ កសិករ

ទីកន្លែងកំណើត ៖ ភូមិឃីរីមី (Kurimi) ឃុំវិគឡាជ (Vilklage) តំបន់ដូហូក (Duhuk)

បន្ទាប់ពីធ្វើពាក្យសម្បថ សាក្សីបាននិយាយដូចតទៅ ៖

ខ្ញុំបាទ គឺជាប្រជាជនមួយរូបក្នុងភូមិឃីរីមី ។ នៅក្នុងយប់មួយចន្លោះពីថ្ងៃទី២៥ដល់២៦ ខែសីហា ឆ្នាំ១៩៨៨ យើងបានឮថាកងកម្លាំងអ៊ីរ៉ាក់នឹងធ្វើការវាយប្រហារមកលើតំបន់របស់យើង ។ ដូច្នេះយើងត្រូវតែរត់ចេញឲ្យទៅដល់ផ្លូវដែលអាចចេញពីតំបន់នេះបាន ប៉ុន្តែយើងមិនអាចឆ្លងផ្លូវនេះបានទេ ។ ប្រជាជនទាំងអស់ក៏នាំគ្នាត្រឡប់មកវិញ ហើយនាំគ្នាពួននៅក្នុងរោងកសិដ្ឋាន និងរូងថ្ម ដែលយើងកំពុងរស់នៅ ។ នៅម៉ោងប្រាំព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨៨ យើងត្រូវបានកងទ័ពអ៊ីរ៉ាក់វាយប្រហារ និងហ៊ុមព័ទ្ធពីគ្រប់ច្រកផ្លូវទាំងអស់ ។ យើងក៏សុំធ្វើការចុះចាញ់ ។ បន្ទាប់មកកងទ័ពអ៊ីរ៉ាក់ក៏នាំយើងត្រឡប់ទៅកាន់ភូមិរបស់យើងវិញ ។ កងទ័ពអ៊ីរ៉ាក់បានធ្វើការបែងចែកបុរស ស្ត្រី និងកូនក្មេង ហើយក្រោយមកកងទ័ពទាំងនោះក៏យកស្ត្រី និងកូនក្មេងចេញទៅ ។ ក្រុមបុរសជាច្រើនត្រូវបានរក្សាទុកនៅក្នុងភូមិ ហើយនាយទាហានមួយរូបបានបញ្ជាឲ្យយើងឈរក្នុងជួរតែមួយ រួចនាំយើងទៅខាងត្បូងភូមិ ដែលនៅទីនោះ ខ្ញុំបានឃើញទាហានចំនួន១៦នាក់ ។ នាយទាហានពីរនាក់ បញ្ជាយើងទាំងអស់គ្នាឲ្យអង្គុយចុះ ក្រោយមកនាយទាហានម្នាក់ទៀតបានបញ្ជាឲ្យបាញ់យើង ។ កងទាហានទាំងអស់បានធ្វើការបាញ់រះមកលើក្រុមបុរសនៅក្នុងភូមិ ហើយយើងទាំងអស់គ្នាដួលក្រាបទៅដី ។ ក្រោយមកនាយទាហានម្នាក់បានបញ្ជាឲ្យយើងយកកាំភ្លើងបាញ់ក្នុងឯងទៅវិញទៅមក ។ នាយទាហានដែលបញ្ជាឲ្យយើងបាញ់គ្នាឯងនោះ បានធ្វើឲ្យខ្ញុំមានរបួសនៅលើថ្ពាស ។ ខ្ញុំនឹងបង្ហាញស្លាកស្នាមនេះទៅតុលាការ (តុលាការក៏បានធ្វើការពិនិត្យមើលទៅលើស្លាកស្នាមដ៏ច្បាស់នេះ) ។ ពេលដែលទាហានទាំងនោះចាកចេញផុតទៅ ខ្ញុំក៏ព្យាយាមក្រោកពីដី ហើយខ្ញុំបានឃើញឪពុក និងបងប្អូនប្រុស រួមទាំងសាច់ញាតិរបស់ខ្ញុំផង (១៨នាក់) ដេកស្លាប់ទាំងអស់នៅលើដី ។ ខ្ញុំបានឃើញបងប្អូនជីដូនមួយរបស់ខ្ញុំមានរបួសនៅលើជើង ។ ឃើញដូច្នេះ ខ្ញុំក៏បានដាក់គាត់ចូលទៅក្នុងរណ្ដៅធំមួយ ។ ស្របពេលនោះដែរ ខ្ញុំបានឃើញ (ឈ្មោះត្រូវបានដាក់ឲ្យ) មនុស្សម្នាក់វារចេញមកពីគំនរសាកសព ។ ខ្ញុំបានដាក់បញ្ជូនបញ្ជីឈ្មោះអ្នកដែលត្រូវបានសម្លាប់នៅក្នុងកិច្ចប្រតិបត្តិការប្រហារជីវិតនេះ ។ ជាមួយគ្នានោះខ្ញុំបានឃើញពូរបស់ខ្ញុំ

(ឈ្មោះត្រូវបានដាក់ឲ្យ) ដែលជើងម្ខាងរបស់គាត់បានបាក់ ។ បន្ទាប់មកខ្ញុំជាមួយនឹងមនុស្សម្នាក់ទៀត (ឈ្មោះត្រូវបានដាក់ឲ្យ) បានលាក់ខ្លួននៅក្នុងរូងថ្មមួយ ហើយ (ឈ្មោះត្រូវបានដាក់ឲ្យ) មនុស្សម្នាក់ទៀតបានមកលាក់ខ្លួននៅទីនោះដែរ ។ យើងបានស្នាក់នៅទីនោះរហូតដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៨៨ ដោយគ្មានអាហារ និងទឹកសម្រាប់បរិភោគឡើយ ។ ក្រោយមកទៀត យើងបានធ្វើដំណើរទៅកាន់ភូមិមួយដែលនៅទីនោះមានកងវរសេនាធំការពារជាតិជាច្រើន បានប្រាប់យើងថាមានការលើកលែងទោសហើយ ។ ព្រោះដូច្នេះ យើងបានទៅរកកងវរសេនាធំការពារជាតិទាំងនោះ ហើយបន្ទាប់មក កងវរសេនាធំ បាននាំយើងទៅកាន់ទីស្នាក់ការរបស់គណបក្ស“បាស” ដែលស្ថិតក្នុងភូមិនោះ ។ កងវរសេនាធំទាំងនោះបានបញ្ជូនយើងទៅកាន់ទីស្នាក់ការមេបញ្ជាការកងពលតូច ដែលនៅទីនោះយើងត្រូវបានគេវាយធ្វើបាប និងមាក់ងាយ មុនពេលយើងត្រូវបានបញ្ជូនទៅកាន់ជំរំមួយទៀត ។ នៅជំរំនោះ ខ្ញុំបានឃើញបុរស និងស្ត្រីរាប់ពាន់នាក់ស្នាក់នៅក្នុងវិហារមួយ ។ ក្រោយមកទៀត យើងត្រូវបានបញ្ជូនទៅកាន់វាលលំហមួយ ដែលនៅទីនោះខ្ញុំបានឃើញក្មេងៗស្លាប់ជាច្រើន ហើយខ្ញុំបានចូលរួមកប់សពរបស់ក្មេងទាំងនោះដែរ ។ ម្យ៉ាងវិញទៀត យើងតែងតែឃើញមានរថយន្តមកយកក្រុមអ្នកកាន់សាសនាគ្រិស្ត និងយ៉ីដឌីស ចេញទៅកាន់កន្លែងផ្សេងទៀត ដែលយើងមិនដឹង ។ រហូតមកដល់ពេលនេះ យើងនៅតែមិនដឹងអំពីវាសនារបស់អ្នកទាំងនោះនៅឡើយ ។

សាក្សី (ឈ្មោះត្រូវបានដាក់ឲ្យ)

មុខរបរ ៖ កម្មករ

សាក្សីបាននិយាយដូចខាងក្រោមបន្ទាប់ពីធ្វើពាក្យសម្បថ ៖

ខ្ញុំបានចុះចាញ់ ក្រោយពីខ្ញុំត្រូវទាហានក្នុងភូមិម្នាក់ប្រាប់ខ្ញុំអំពីការលើកលែងទោស ។ ខ្ញុំត្រូវបាននាំទៅកាន់អគ្គការទទួលបន្ទុកជនជាតិឃឺដភាគខាងជើង ហើយនៅទីនោះខ្ញុំត្រូវបានគេធ្វើបាប ។ បន្ទាប់ពីខ្ញុំ និងមនុស្សដទៃទៀតត្រូវឃុំឃាំងមួយរយៈពេលក្រោយមក ខ្ញុំក៏ត្រូវបញ្ជូនតាមរថយន្ត ។ ខ្ញុំ និងមនុស្សនៅទីនោះទាំងអស់ត្រូវបានប្រាប់ថា ទាហាននឹងនាំទៅកាន់ទីក្រុងបាដាត ។ បន្ទាប់ពីចាកចេញបានបន្តិច រថយន្តទាំងនោះ ក៏ឈប់ស្ងៀម ហើយក្រុមទាហានបាននាំយកអ្នកទោសដែលជាប់ឃុំឃាំងចេញឆ្ងាយពីរថយន្ត ។ ពេលនោះខ្ញុំជាអ្នកទោសទី១៧ ដែលត្រូវនាំចេញពីរថយន្ត ។ ក្រុមទាហានទាំងនោះបាននាំអ្នកទោសទាំងអស់ទៅយ៉ាងឆ្ងាយពីរថយន្ត ។ ក្រោយមក យើងត្រូវបានបញ្ជាឲ្យអង្គុយចុះ ។ នៅពេលខ្ញុំអង្គុយចុះ ខ្ញុំបានឃើញរណ្ដៅមួយ ។

ខ្ញុំត្រូវទាហានម្នាក់វាយពីក្រោយចំក្បាលហើយធ្លាក់ចូលទៅក្នុងរណ្ដៅនោះ ។ ពេលធ្លាក់ចូលក្នុងរណ្ដៅនោះភ្លាម ខ្ញុំបានឃើញបុរសម្នាក់ក្នុងចំណោមបុរសជាច្រើនទៀត ប៉ុន្តែក្រោយមកខ្ញុំក៏បាត់បង់ស្មារតី ។ ខណៈពេលដែលខ្ញុំដឹងខ្លួនវិញ ខ្ញុំដឹងថា ពាក់កណ្ដាលខ្លួនរបស់ខ្ញុំត្រូវបានកប់ដោយដីខ្សាច់ ហើយខ្ញុំក៏ឃើញទាហានដើរចេញពីរណ្ដៅដើម្បីយកខ្សាច់មកចាក់បន្ថែមទៀត ។ ខ្ញុំបានព្យាយាមវារចេញពីរណ្ដៅរួចដោយសារតែភាពងងឹត និងធូលីដី និងក៏ដោយសារតែអ្នកយាមរណ្ដៅទាំងអស់នោះកំពុងតែរវល់នាំអ្នកទោសមកបន្ថែមទៀត ។ ក្រោយមកខ្ញុំក៏វារចេញរួចពីរណ្ដៅនោះ ។ ខ្ញុំជឿជាក់ថា ក្រុមទាហានទាំងនោះមិនបានធ្វើការបាញ់សម្លាប់អ្នកទោសទេ ។ មើលទៅទាហានទាំងនោះកំពុងតែយកអ្នកទោសមកដាក់ក្នុងរណ្ដៅ ហើយកប់អ្នកទោសទាំងនោះទាំងរស់តែម្ដង ។

សាក្សី (ឈ្មោះត្រូវបានដាក់ឲ្យ)

មុខរបរ ៖ អ្នកគ្រប់គ្រងវិស័យអប់រំក្នុងក្រសួងអប់រំ

សាក្សីបាននិយាយដូចខាងក្រោមបន្ទាប់ពីធ្វើពាក្យសម្បថ ៖

ខ្ញុំគឺជាប្រជាជនមកពីភូមិ ជី.ធី ។ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៨៨ ខ្ញុំបានកត់សម្គាល់ទៅលើភាពចលាចលរបស់កងទ័ពដែលសកម្មភាពនេះធ្វើឲ្យខ្ញុំមានការសង្ស័យ ។ យើងមានអារម្មណ៍ថា ជីវិតរបស់យើងកំពុងតែស្ថិតនៅក្នុងគ្រោះថ្នាក់ហើយ ។ នៅថ្ងៃនោះ ខ្ញុំបានឃើញយន្តហោះចម្បាំងដែលខ្ញុំមិនអាចចាំលេខបាន ។ យន្តហោះចម្បាំងទាំងនោះបានធ្វើការទម្លាក់គ្រាប់បែកលើភូមិដទៃទៀតជាច្រើន ។ ជាមួយគ្នានោះដែរ ភូមិរបស់យើងក៏ត្រូវគ្រាប់បែកទម្លាក់ចំ ហើយមានផ្សែងខ្ជួលខ្មាញ់ហុយឡើងលើ ។ ស្នូរសំឡេងលេចចេញពីការទម្លាក់គ្រាប់បែកឮសូរតិចទេ ប៉ុន្តែខ្យល់នៅតែបន្តបក់ ។ ពេលនោះ ខ្ញុំកំពុងតែឈរនៅចំទិសបញ្ច្រាសខ្យល់ ។ ឃើញដូចនេះ ខ្ញុំបានស្រែកហៅប្រជាជននៅក្នុងភូមិ ។ ដោយហេតុថា ខ្ញុំធ្លាប់បម្រើការជាទាហានក្នុងកងបែងចែកសារធាតុជីវសាស្ត្រ ខ្ញុំបានដឹងថា ភូមិរបស់ខ្ញុំត្រូវគ្រាប់បែកទម្លាក់ចំ និងបានទទួលរងការបាញ់អាវុធជីវសាស្ត្រ ។ ខ្ញុំធ្លាប់បានធ្វើការហ្វឹកហាត់ឲ្យចេះប្រើប្រាស់អាវុធជីវសាស្ត្រដែរ ។ នៅពេលដែលគ្រាប់បែកទម្លាក់ចំភូមិរបស់ខ្ញុំ ខ្ញុំចាំបានថា សមាជិកគ្រួសាររបស់ខ្ញុំចំនួន២៥នាក់ ម្តាយ(ឈ្មោះត្រូវបានដាក់ឲ្យ) ប្រពន្ធ(ឈ្មោះត្រូវបានដាក់ឲ្យ) និងកូនៗ(ឈ្មោះត្រូវបានដាក់ឲ្យ)របស់ខ្ញុំបានស្លាប់ ។ លើកលែងតែកូនស្រីរបស់ខ្ញុំម្នាក់(ឈ្មោះត្រូវបានដាក់ឲ្យ)នៅមានជីវិត ។ ខ្ញុំបានបាត់បង់បងប្អូនប្រុសពីរនាក់(ឈ្មោះត្រូវបានដាក់ឲ្យ) រួមទាំងប្រពន្ធ និងកូនរបស់គាត់ដែលត្រូវបាត់បង់ជីវិតនៅក្នុងឧប្បត្តិហេតុនេះ និងប្រជាជននៅក្នុងភូមិជីធីនេះដែរ ។ ដប់នាទីក្រោយពីការបាញ់ និងទម្លាក់គ្រាប់បែក យើងក៏បាននាំគ្នាដើរឆ្ពោះទៅកាន់ភូមិវិញ ។ ខ្ញុំបានរួមដំណើរជាមួយបងប្រុសថ្លៃ និងមិត្តរបស់ខ្ញុំទាំងអស់មានគ្នាបួននាក់ ។ ខ្ញុំបានប្រាប់គាត់ឲ្យយកខ្សែក្រវាត់ស្បែរបស់ជនជាតិខឺដ មកពាក់ធ្វើជាកន្សែងបិទមុខ ក្រោយពីកន្សែងនោះត្រូវបានជ្រលក់ក្នុងទឹក ។ ខ្ញុំបានយកកន្សែងស្បែនោះមកបិទមាត់ ច្រមុះ និងភ្នែករបស់ខ្ញុំដើម្បីការពារពីផ្សែងពុលជីវសាស្ត្រ ។ នៅពាក់កណ្តាលផ្លូវ ខ្ញុំបានជួបក្មេងស្រីម្នាក់ដែលនិយាយមកកាន់ខ្ញុំថា «គ្មាននរណាម្នាក់នៅជាមួយខ្ញុំទេ» ដែលឃ្លានេះជាភាសាអារ៉ាប់មានន័យថា «សមាជិកគ្រួសាររបស់ខ្ញុំទាំងអស់បានស្លាប់ចោលខ្ញុំអស់ហើយ» ។

ភូមិរបស់ខ្ញុំត្រូវរងការបាញ់ដោយកាំភ្លើង និងទម្លាក់គ្រាប់បែកលើទីតាំងបីកន្លែង ពីព្រោះថា ប្រជាជនភាគច្រើនរស់នៅក្នុងតំបន់ត្រីកោណនេះ ។ ភូមិនេះត្រូវបានទម្លាក់ចំថ្ងៃរាម៉ាដានពេលថ្ងៃរៀបលិច ដោយសារតែក្នុងអំឡុងពេលនេះមានមនុស្សជាច្រើននាក់កំពុងតែជួបជុំគ្នាហូបបាយ ។ ជាការពិត ភូមិរបស់ខ្ញុំត្រូវបានបាញ់ដោយកាំភ្លើង និងទម្លាក់គ្រាប់បែកនៅពេលយប់ ពីព្រោះថានៅពេលយប់ប្រជាជនមិនអាចជួយសង្គ្រោះគ្នាដោយងាយស្រួលទេ និងម្យ៉ាងទៀតកងទាហាននោះមានបំណងចង់ឲ្យមនុស្សស្លាប់ និងរងរបួសច្រើនផង ។ ពេលដែលភូមិខ្ញុំកំពុងតែទទួលរងការវាយប្រហារដោយឧស្ម័នជីវសាស្ត្រ គ្រួសារខ្ញុំបានព្យាយាមរត់ទៅកាន់អូរ ដើម្បីប្រើប្រាស់ទឹកសម្រាប់ការពារខ្លួន ។ ខ្ញុំឮសំឡេងថ្ងូរយំរបស់ក្មេងតូចម្នាក់ ។ នៅពេលនោះ ខ្ញុំមានចង្កៀងអគ្គិសនីយួរដៃមួយ បន្ទាប់មកខ្ញុំយកវាមកឆ្លុះមើលចំនួនមនុស្សដែលរងរបួស និងស្លាប់ ។ មានមនុស្សប្រហែល៧០នាក់របួស និងស្លាប់ដេកនៅលើដីដែលមានទំហំប្រមាណប្រាំរយម៉ែត្រការ៉េ ។ ប៉ុន្តែខ្ញុំមិនបានរាប់មើលចំនួនមនុស្សដែលរងរបួស និងស្លាប់ឲ្យបានត្រឹមត្រូវនោះទេ ។ ម្យ៉ាងវិញទៀត មនុស្សទាំងអស់នេះសុទ្ធសឹងតែជាសមាជិកគ្រួសាររបស់ខ្ញុំ ដែលអ្នកទាំងនោះបានរងរបួស និងស្លាប់ដោយសារអាវុធជីវសាស្ត្រ ។ ខ្ញុំបាន

ឃើញ ស្ត្រីម្នាក់ដេកក្រាបនៅក្បែរមាត់អូរ និងបានឮសំឡេងយំរបស់កូនង៉ែតដែលដេកនៅក្បែរស្ត្រីនោះ ។ ការពិតស្ត្រីនោះព្យាយាមការពារកូនរបស់គាត់ពីខស្ទ័នពុលជីវសាស្ត្រ ។ ឃើញដូច្នេះ ខ្ញុំក៏បីកូនង៉ែតនោះចូលទៅក្នុងផ្ទះ ហើយដោះសម្លៀកបំពាក់របស់កូនង៉ែតនោះចេញ និងយកក្មេងនោះទៅលាងសម្អាតខ្លួនរួចរុំនឹងភួយ បន្ទាប់មកខ្ញុំក៏ចាកចេញពីផ្ទះនោះទៅ ។

ក្រោយមកទៀត ខ្ញុំបានឃើញស្ត្រីម្នាក់ផ្សេងទៀតដេកផ្កាប់មុខនៅមាត់អូរ ។ នៅពេលដែលខ្ញុំផ្ងារខ្លួនស្ត្រីនោះឡើង ខ្ញុំដឹងថា ស្ត្រីនោះគឺជាម្តាយរបស់ខ្ញុំ ។ បន្ទាប់ពីបានឃើញសមាជិកគ្រួសាររបស់ខ្ញុំបាត់បង់ជីវិត ខ្ញុំក៏ចាកចេញពីភូមិនេះទៅ ។ ប្រាំថ្ងៃក្រោយមកខ្ញុំ មិនមានអ្វីសម្រាប់ហូបទេ ហើយខ្ញុំក៏មិនដឹងថា ខ្ញុំត្រូវទៅទីណាដែរ ។ នៅក្នុងពេលធ្វើដំណើរមានមនុស្សប្រាំនាក់ចូលរួមដំណើរជាមួយខ្ញុំ ។ ខ្ញុំបានព្យាយាមត្រឡប់ទៅភូមិវិញ ប៉ុន្តែខ្ញុំបានដឹងថា ទាហានជាច្រើននាក់កំពុងតែប្រមូលផ្តុំនៅក្នុងភូមិរបស់ខ្ញុំ ។ ទាហានទាំងអស់នោះ បានចាប់អ្នកនៅរស់ក្នុងភូមិឃុំ ហើយបានដុតបំផ្លាញផ្ទះក្នុងភូមិចោល ។ ដូច្នេះក្រុមរបស់ខ្ញុំក៏សម្រេចគេចខ្លួនពីទាហានទាំងនេះ ដោយនាំគ្នាទៅពួននៅក្រោយថ្មធំមួយ ។ ខ្ញុំបានឃើញ(ឈ្មោះត្រូវបានដាក់ឲ្យ)មនុស្សម្នាក់ ដែលមកពីភូមិចាលម័រ (Jalmur) ។ គាត់មើលទៅដូចជាស្ថិតនៅក្នុងសភាពប្រញាប់ប្រញាល់ ។ ក្រុមរបស់ខ្ញុំបានសួរថា គាត់បានឃើញអ្វីខ្លះ? ហើយគាត់ក៏បានឆ្លើយថា មានកងយោធាច្រើននាក់ណាស់កំពុងតែនាំគ្នាមកកាន់ភូមិរបស់ខ្ញុំ និងចាប់អ្នកភូមិផ្សេងទៀតផង ។ គាត់បានក្រើនរំឭកក្រុមខ្ញុំថា ទាហានទាំងនោះនឹងមកដល់ទីនេះ ដូច្នេះយើងត្រូវតែរត់ដើម្បីការពារជីវិតរបស់ខ្លួន ។ ខ្ញុំក៏បានសួរគាត់អំពីដំណឹងរបស់ឪពុកខ្ញុំដែរ តែគាត់គ្រាន់តែនិយាយថា អ្នកនៅក្នុងភូមិទាំងអស់ត្រូវបានចាប់ខ្លួន ។



ទិដ្ឋភាពទីផ្សារមួយនៅប្រទេសអ៊ីរ៉ាក់ ឆ្នាំ២០០៦ ។ រូបថត ៖ ឆាំង យុ ។

## ប្រធានបទទី៤ ៖ អតីតយូហ្គោស្លាវី

**សាសនា** ៖ អ៊ីស្ទើនអកតូដុក (Eastern Orthodox) ៥០ភាគរយ រ៉ូម៉ាំង-កាតូលិក (Roman Catholic) ៣០ភាគរយ ម៉ូស្លីម ៩ភាគរយ ប្រូតេស្តង់ (Protestant) ១ភាគរយ និងសាសនាផ្សេងៗទៀត១០ភាគរយ ។

**ការបែងចែកជាតិពន្ធុ** ៖ ស៊ែប (Serb) ៣៦,៣ភាគរយ ក្រូអាត (Croat)១៩,៧ភាគរយ ម៉ូស្លីម ៨,៩ភាគរយ អាល់បានី (Albanian) ៧,៧ភាគរយ ម៉ាសេដូនី (Macedonian) ៥,៩ភាគរយ ជនជាតិយូហ្គោស្លាវី (Yugoslave) ៥,៤ភាគរយ ម៉ុងតេនីហ្គ្រីន (Montenegrin) ២,៥ភាគរយ ជនជាតិហុងគ្រី (Hungarian) ១,៩ភាគរយ និងជនជាតិដទៃទៀត៣,៩ភាគរយ (ការស្រង់ចំនួនប្រជាជននៅឆ្នាំ១៩៨១) ។

**បរិបទប្រវត្តិសាស្ត្រ** ៖ ទសវត្សរ៍ឆ្នាំ១៩៩០

ការបែកបាក់គ្នារបស់អតីតយូហ្គោស្លាវី បានបង្កឲ្យមានជម្លោះដាច់ដោយឡែកពីគ្នាជាច្រើន ។ ជម្លោះដ៏ខ្លាំងក្លាជាងគេ គឺជម្លោះដែលពាក់ព័ន្ធនឹងតំបន់ បូស្នៀ និងហឺហ្សីហ្គូវីណា ។

តំបន់ បូស្នៀ និង ហឺហ្សីហ្គូវីណា បានប្រកាសអធិបតេយ្យភាពរបស់ខ្លួនចេញពីប្រទេសយូហ្គោស្លាវី នៅខែតុលា ឆ្នាំ១៩៩១ ។ នៅខែមីនា ឆ្នាំ១៩៩២ ការបោះឆ្នោតមួយដោយមានការធ្វើពហិការពីជនជាតិស៊ែប បាននាំមកនូវសេចក្តីប្រកាសឯករាជភាពមួយ ។ ជនជាតិស៊ែបក្នុងតំបន់បូស្នៀ ដោយមានការគាំទ្រពីប្រទេសស៊ែប៊ី និងម៉ុងតេនីហ្គ្រីន បានចាប់ផ្តើមធ្វើការតស៊ូប្រដាប់អាវុធ ក្នុងគោលបំណងបែងចែករដ្ឋតាមជាតិពន្ធុ ក្នុងតំបន់កាន់កាប់របស់ជនជាតិស៊ែប ដោយបង្កើតទៅជា«មហាប្រទេសស៊ែប៊ីមួយ» ។ គណបក្សប្រជាធិបតេយ្យស៊ែប៊ី បានបង្កើតតំបន់ឯករាជ្យក្រាជីណា (Krajina) ហៅកាត់ថា (ARK) ។ តំបន់ភូមិសាស្ត្រ ដែលជាផ្នែកមួយរបស់តំបន់ឯករាជ្យក្រាជីណា ក៏បានក្លាយជាតំបន់របស់សាធារណរដ្ឋស៊ែប៊ីជាផ្លូវការ ។ មេដឹកនាំគណបក្សប្រជាធិបតេយ្យ ស៊ែប៊ី បានចាត់ទុកប្រជាជនក្រូអាត-បូស្នៀ និងម៉ូស្លីម-បូស្នៀ រស់នៅក្នុងតំបន់ដែលបានប្រកាសថា ជាតំបន់របស់សាធារណរដ្ឋស៊ែប៊ី ថាជាឧបសគ្គចម្បងមួយដល់ការបង្កើតជារដ្ឋផ្លូវការរបស់ជនជាតិស៊ែប៊ី ។ ហេតុផលនេះ បានផ្តើមឲ្យមានគោលនយោបាយការផ្លាស់លំនៅអចិន្ត្រៃយ៍ ឬការបោសសម្អាតជាតិពន្ធុនៃជនជាតិក្រូអាត-បូស្នៀ និងម៉ូស្លីម-បូស្នៀ ស្ទើរតែទាំងអស់ ។ ការដឹកនាំរបស់អ្នកស្នេហាជាតិស៊ែប បានចាត់ទុកជនជាតិម៉ូស្លីម-បូស្នៀ និងក្រូអាត-បូស្នៀ ថាជាមនុស្សជ្រុលនិយម ដែលមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើប្រជាជនស៊ែប៊ី ក្នុងតំបន់បូស្នៀ និងហឺហ្សីហ្គូវីណា ។ ការសម្លាប់ និងអំពើប្រល័យពូជសាសន៍ដ៏ធំបានកើតឡើងលើជនស៊ីវិលជាច្រើននាក់ ។ សកម្មភាពនេះ បានក្លាយជាលទ្ធផលនៃការសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ ដើម្បីធានាឲ្យបាននូវការការពារសុវត្ថិភាពរបស់ប្រជាជនស៊ីវិល ។ ទីកន្លែងដ៏មានសុវត្ថិភាពមួយកន្លែងដែលស្ថាបនាដោយអង្គការសហប្រជាជាតិ គឺទីក្រុងស្រ៊ីប្រេនីកា (Srebrenica) ។ នៅខែកក្កដា ឆ្នាំ១៩៩៥ កងទ័ពបូស្នៀ-ស៊ែប បានក្តោបក្តាប់ទីក្រុងទាំងមូល និងតំបន់ដែលនៅជុំវិញ ។ រយៈពេលប្រាំថ្ងៃក្រោយមក ទាហានស៊ែបបានសម្លាប់បុរសនិងក្មេងប្រុសចំនួនប្រាំពីរពាន់នាក់នៅតាមវាលស្រែ សាលារៀន និងឃ្លាំងដាក់អីវ៉ាន់ ។

**សេចក្តីដកស្រង់ចេញពីសាច់រឿង**

*សាក្សីទី៥០ គឺជាក្មេងស្រីមូស្លីមមកពីភូមិមួយនៅក្នុងតំបន់ក្រុង F ភាគពាយ័ព្យបូស្នៀ និង ហឺហ្សីហ្គូវីណា នៅពេលដែលសង្គ្រាមចាប់ផ្តើមនៅខែមេសា ឆ្នាំ១៩៩២ ។*

នៅដើមខែឧសភា ឆ្នាំ១៩៩២ សាក្សីទី៥០និងគ្រួសាររបស់នាងបានចាប់ផ្តើមរស់នៅក្នុងព្រៃ ព្រោះខ្លាចថាខ្លួនអាចនឹងត្រូវដុតសម្លាប់ជាមួយនឹងផ្ទះរបស់នាងនៅក្នុងភូមិដែលនាងនិយាយថា ផ្ទះជាច្រើននៅក្នុងភូមិ ត្រូវបានដុតបំផ្លាញចោល ។ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៩២ ភូមិរបស់សាក្សីទី៥០ ត្រូវបានទទួលរងនូវការវាយប្រហារ ហើយក្នុងរយៈពេលពីរបីថ្ងៃក្រោយមក ទាហានគ្មានឯកសណ្ឋានប្អូននាក់រួមមានទាំងអ្នកនៅក្បែរផ្ទះរបស់នាងម្នាក់ផងបានចាប់ខ្លួនអ្នកភូមិ ។

ក្នុងអំឡុងពេលដែលសាក្សីទី៥០ជាប់ឃុំឃាំង នាងបានឃើញទាហានស៊ែបនាំក្មេងស្រីជាច្រើននាក់ពីក្រុមរបស់ទាហានដោយចង្អុលទៅកាន់ក្មេងស្រីទាំងនោះថា “ឯង ឯង ឬ ឯង” ។ នាងនិយាយថា ក្មេងស្រីទាំងនេះនឹងត្រូវនាំយកចេញទៅរាល់ពេលដែលទាហានទាំងនោះត្រូវការ ។ រៀងរាល់យប់ ក្មេងស្រីខ្លះនឹងត្រូវបានសម្លាប់ចោលនៅកន្លែងផ្សេងៗជាមួយនឹងទាហានទាំងនោះ ។ សាក្សីទី៥០បាននិយាយថា នៅពេលដែលក្មេងស្រីៗត្រឡប់មកវិញ ក្មេងស្រីទាំងនោះយំ ។ ចំណែកឯក្មេងស្រីដទៃទៀត មានឈាមហូរចេញតាមច្រមុះ ស្រែក ឬត្រូវបានទាហានជោចសក់ ។

**សេចក្តីដកស្រង់ចេញពីសាច់រឿង**

លោកវេជ្ជបណ្ឌិត M មានអាយុ៣៣ឆ្នាំ ជាគ្រូពេទ្យជាតិប៊ូស្នៀ មកពីទីក្រុង P ក្នុងភាគពាយ័ព្យប្រទេសប៊ូស្នៀ និងហឺហ្សីហ្គូវីណា នៅពេលដែលសង្គ្រាមចាប់ផ្តើមនៅខែមេសា ឆ្នាំ១៩៩២ ។ មុនសង្គ្រាម លោកវេជ្ជបណ្ឌិត M និយាយថា គាត់មិនបានកត់សម្គាល់លើបញ្ហាមួយចំនួនរវាងជនជាតិផ្សេងៗ ដែលរស់នៅក្នុងទីក្រុង P នេះទេ ។ លោកវេជ្ជបណ្ឌិត M និយាយថា “ខ្ញុំមានមិត្តច្រើនណាស់ ដែលជាជនជាតិស៊ែប” ។ “ខ្ញុំគិតថា ខ្ញុំមានមិត្តភក្តិជាជនជាតិស៊ែប ច្រើនជាងជនជាតិដទៃផ្សេងទៀត” ។

កាលពីថ្ងៃ២៤ ខែឧសភា ឆ្នាំ១៩៩២ នៅពេលរសៀល កងកម្លាំងរបស់ជនជាតិស៊ែបបានវាយប្រហារមកលើទីក្រុង K ដោយគ្មានផ្តល់ឱកាសដល់ស្ត្រីក្មេងៗ និងមនុស្សចាស់ជរា បានចាកចេញមុនការវាយប្រហារនេះឡើយ ។ នៅពេលនោះ លោកវេជ្ជបណ្ឌិត M កំពុងតែធ្វើការនៅគ្លីនិកក្នុងក្រុង ។ ក្នុងរយៈពេលពីរថ្ងៃដែលការវាយប្រហារបានបញ្ចប់ គាត់បានព្យាបាលជនស៊ីវិលជាច្រើននាក់ ដែលរងរបួសដោយសារតែគ្រាប់ផ្លោង ។ នៅក្នុងចំណោមជនរងគ្រោះទាំងនោះមានក្មេងពីរនាក់ ។ លោកវេជ្ជបណ្ឌិតនិយាយថា “មានក្មេងស្រីម្នាក់ដេកនៅទីនោះ ដែលជើងទាំងពីររបស់នាងត្រូវដាច់ហើយក្មេងស្រីនោះក៏ស្លាប់ទៅ” ។ លោកវេជ្ជបណ្ឌិត M បានព្យាយាមជម្លៀសក្មេងទាំងពីរនាក់ចេញ ប៉ុន្តែត្រូវបានបដិសេធមិនឲ្យយកចេញ ។ គាត់ត្រូវបានទាហានប្រាប់ថា “ឲ្យពួកវាទាំងអស់ហ្នឹងបាលីចា (balija)” ជាពាក្យប្រមាថនៃភាសារបស់ម៉ូស្លីម ដែលមានន័យថា “ងាប់នៅទីនោះហើយ” ទោះជាយ៉ាងណាក៏“យើងនឹងសម្លាប់ពួកឯងទាំងអស់គ្នាតែងដែលហ្នឹង” ។

លោកវេជ្ជបណ្ឌិត M និយាយថា បុរសប្រហែលជាពីររយនាក់ត្រូវបានសម្លាប់នៅក្នុងទីក្រុង ចំណែកឯមនុស្សដទៃទៀតបានស្លាប់ដោយសារតែបុគ្គលិកពេទ្យ មិនបានផ្តល់ការព្យាបាលឲ្យបានត្រឹមត្រូវដល់អ្នកទាំងនោះ ។

**សេចក្តីដកស្រង់ចេញពីសាច់រឿង**

សាក្សីឈ្មោះ O ទើបតែនឹងមានអាយុ១៧ឆ្នាំ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៥ នៅពេលដែលកងទ័ពប៊ូស្នៀ-ស៊ែប បានសម្រុកចូលទីក្រុងស្រ៊ីប្រេនីកាភាគខាងត្បូងប៊ូស្នៀ និងហឺហ្សីហ្គូវីណា ។ នៅថ្ងៃនោះសាក្សី O និងឪពុករបស់គាត់ បានសម្រេចចិត្តចូលរួមជាមួយនឹងក្រុមយុវជនដែលមានអវៈយវៈពេញលេញរាប់ពាន់នាក់

មកពីស្រុីប្រេទីកា ក្នុងបំណងគៀសខ្លួនទៅតំបន់កាន់កាប់របស់ជនជាតិប៊ូស្នៀ-មូស្លីម ដោយសារតែអ្នកទាំងនោះមានភាពភ័យខ្លាចថា ជីវិតរបស់ខ្លួននឹងអាចបាត់បង់ ។

ពេលកំពុងតែលាក់ខ្លួនក្នុងព្រៃ សាក្សី O បានចូលរួមជាមួយនឹងក្រុមយុវជនជាច្រើនពាន់នាក់ ដែលចូលមកនៅក្នុងព្រៃ ។ សាក្សី O និយាយថា គាត់មិនបានដឹងថា ក្រុមយុវជនទាំងអស់នេះបានសុំចុះចាញ់នោះទេ ។

កាលពីរសៀលថ្ងៃទី១៤ ខែកក្កដា កងកម្លាំងប៊ូស្នៀ-ស៊ែបបាននាំសាក្សី O និងអ្នកជាប់ឃុំឃាំងដទៃជាច្រើននាក់ទៀតយកទៅដាក់ក្នុងបន្ទប់មួយចំនួនរបស់សាលារៀនមួយខ្នង ។ ទាហានប៊ូស្នៀ-ស៊ែបម្នាក់បានសួរថា “ដីនេះជារបស់អ្នកណា?” បន្ទាប់មកទាហាននោះបានឆ្លើយដោយខ្លួនឯងថា “នេះគឺជាដីរបស់ជនជាតិស៊ែប ។ ដីនេះធ្លាប់ជារបស់ជនជាតិស៊ែប ហើយនឹងជារបស់ជនជាតិស៊ែបជារៀងរហូត” ។ ទាហានស៊ែបបានសួរបន្ថែមទៀតថា “តើទីក្រុងស្រុីប្រេទីកា ជាកម្មសិទ្ធិរបស់អ្នកណា?” ទាហានទាំងនោះក៏បានឆ្លើយដោយខ្លួនឯងថា “ទីក្រុងស្រុីប្រេទីកា គឺជារបស់ជនជាតិស៊ែប ។ ទីក្រុងនេះធ្លាប់ជាកម្មសិទ្ធិរបស់ជនជាតិស៊ែប ហើយនឹងក្លាយជារបស់ជនជាតិស៊ែបជារៀងរហូត” ។

នាពេលមេឃងងឹត សាក្សី O បានឮសំឡេងស្រែកហៅក្រុមយុវជននៅបន្ទប់ផ្សេងឲ្យចេញជាក្រុមតូចៗ ។ នៅពេលក្រុមយុវជនទាំងនោះចុះមកឈរនៅមុខសាលា សាក្សី O បានឮស្នូរបាញ់កាំភ្លើង ។ សំឡេងបាញ់កាំភ្លើងនេះ បានបន្តឮឡើងរហូតដល់ពាក់កណ្ដាលអធ្រាត្រ ។

ក្រោយមកទាហានម្នាក់បានចូលមកដល់បន្ទប់របស់សាក្សី O ហើយបាននិយាយថា ដល់វេនរបស់ក្រុមយុវជនរបស់សាក្សី O ហើយ ។ ទាហាននោះបានបន្ថែមទៀតថា សាក្សីត្រូវចេញមកម្ដងពីរៗនាក់ ។ សាក្សី O បានសួរពូរបស់គាត់ថា តើគាត់គួរតែចេញទៅក្រៅជាមួយពូរបស់គាត់ឬទេ? ពូរបស់សាក្សី O បាននិយាយថា “ទេ យើងនឹងមិនទៅជាមួយគ្នាទេ” ។ សាក្សី O ចេញទៅជាមួយនឹងបុរសម្នាក់ទៀតមុនពូរបស់គាត់ ។ ក្រោយពីពេលនោះមកសាក្សី O មិនដែលបានឃើញពូរបស់គាត់ឡើយ ។

ទាហានបានចងដៃរបស់សាក្សី O ពីក្រោយខ្នងជាមួយនឹងខ្សែដ៏មាំ បន្ទាប់មកក៏យកគាត់ទៅដាក់នៅក្នុងបន្ទប់រៀនមួយទៀត ដែលគាត់មានអារម្មណ៍ថា ដូចជាមានក្រណាត់ខោអាវនៅពីក្រោមជើងរបស់គាត់ ។ នៅពេលដែលដៃរបស់យុវជនទាំងអស់ត្រូវបានចងរួចជាស្រេចហើយ ទាហានទាំងនោះបាននាំសាក្សីចេញទៅក្រៅអគារ ហើយយកសាក្សីទៅដាក់ក្នុងរថយន្តមួយ ។ បុរសម្នាក់ដែលនៅពីក្រោយសាក្សី O ដែលអាចស្រាយចំណងដៃរបស់ខ្លួនរួចនោះ បានសួរទៅកាន់សាក្សី O ថាតើសាក្សី O ចង់ឲ្យបុរសនោះស្រាយចំណងដៃឬទេ ។ សាក្សី O បាននិយាយថា “ទេ!ទេ! ខ្ញុំមិនចង់ស្រាយចំណងនេះទេ ពីព្រោះថា ខ្ញុំនឹងត្រូវបានសម្លាប់ឥឡូវហើយ ។” សាក្សី O បានឮសំឡេងមនុស្សស្រែកថា “ឲ្យទឹកយើងផឹកសិនមកចាំសម្លាប់យើងតាមក្រោយ” ។ សាក្សី O បាននិយាយក្នុងចម្លើយសារភាពរបស់គាត់ថា ពេលនោះគាត់គិតតែម្នាក់ឯងថា គាត់ពិតជាមានអារម្មណ៍អាណោចអាធ័មណាស់ដែលគាត់ត្រូវស្លាប់ទាំងស្រេកទឹក ។

នៅព្រលឹមស្រាងៗថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៥ ទាហានទាំងនោះបាននាំយកសាក្សី O ចេញពីរថយន្តទៅកាន់កន្លែងមួយ ដែលនៅទីនោះគាត់បានឃើញមនុស្សជាច្រើនជួរ ត្រូវបានសម្លាប់រួចហើយ ។ ពេលដែលសាក្សីO ចាកចេញពីរថយន្ត គាត់បានគិតថា គាត់នឹងស្លាប់ភ្លាមដោយគ្មានភាពឈឺចាប់អ្វីទាំងអស់ ។ “ពេលនោះខ្ញុំគិតថា ម្ដាយរបស់ខ្ញុំនឹងមិនដឹងថាជីវិតរបស់ខ្ញុំត្រូវបានបញ្ចប់នៅកន្លែងណានោះទេ” ។

នៅពេលដែលស្នូរកាំភ្លើងលាន់ឮឡើង សាក្សី O បានដួលលើដី ហើយគាត់ដឹងថា គាត់មានភាពឈឺចាប់នៅលើដើមទ្រូងខាងស្ដាំ និងដើមដៃខាងស្ដាំរបស់គាត់ ។ សាក្សី O បានឮសំឡេងស្រែកថ្ងូររបស់បុរសម្នាក់នៅខាងស្ដាំដៃរបស់គាត់ ប៉ុន្ដែសាក្សី O មិនបានស្រែកឬយំឡើយ ។ សាក្សី O បានគិតថា គាត់រង់ចាំគ្រាប់កាំភ្លើងមួយគ្រាប់ទៀតបាញ់មកចំគាត់ ។ ពេលដែលសាក្សី O កំពុងរង់ចាំសេចក្ដីស្លាប់ គាត់បានឮសំឡេងកាំភ្លើងផ្ទុះឡើងជាបន្ដបន្ទាប់ ហើយចំណែកឯមនុស្សក៏ដួលដេកលើដីគ្មោលៗ ។ នៅពេលដែលទាហានបញ្ចប់ការបាញ់សម្លាប់សាក្សី O បានឮទាហានទាំងនោះនិយាយថា «រដ្ឋាភិបាលរបស់ពួកឯងនឹងបោះបង់ពួកឯងចោល ទោះបីជាពួកឯងស្លាប់ហើយក៏ដោយ» ។ សាក្សី O បាននិយាយថា ទាហានទាំងនោះបានមើលមកមនុស្សដេកស្លាប់លើដី ហើយនាំគ្នានិយាយចំអកថា «មើលអាមួយនេះ វាងាប់ទៅដូចស្ដែក្ដោបអីចឹង» ។

ក្រោយពីការបាញ់សម្លាប់ត្រូវបានបញ្ចប់ និងក្រោយពេលទាហានទាំងនោះបាននាំគ្នាចាកចេញទៅសាក្សី O បានព្យាយាមគេចខ្លួនរួចជាមួយនឹងអ្នកនៅមានជីវិតដទៃទៀតទៅកាន់ទឹកដីកាន់កាប់ដោយជនជាតិប៊ូស្នៀ ។

[នៅក្នុងតុលាការកាត់ក្ដីឧក្រិដ្ឋកម្មអន្ដរជាតិរបស់អតីតយូហ្គោស្លាវី O ជាកន្លែងដែលសាក្សី បានផ្ដល់ចម្លើយប្រឆាំងនឹងជនត្រូវចោទ.....]

ដូចដែលធ្លាប់អនុវត្តកន្លងមក ប្រធានចៅក្រម អាល់មីរ៉ូ រ៉ូឌ្រីក (Almiro Rodrigues) បានសួរទៅ សាក្សី O ថាតើគាត់មានពាក្យសម្ដីអ្វីបន្ថែមទៀតទេ ។ សាក្សី O បាននិយាយដូចខាងក្រោម ៖

«អ្វីទាំងអស់ដែលខ្ញុំបានឃើញ ខ្ញុំអាចនិយាយជាសរុបបានថា សកម្មភាពសម្លាប់នេះគឺត្រូវបានរៀបចំឡើងយ៉ាងល្អិតល្អន់ ។ នេះគឺជាការសម្លាប់ដែលមានលក្ខណៈជាប្រព័ន្ធ ។ បន្ថែមពីលើនេះ អ្នករៀបចំគម្រោងការនេះមិនសមនឹងទទួលបាននូវសេរីភាពទេ ។ ប្រសិនបើខ្ញុំទទួលបានសិទ្ធិ និងសេចក្ដីក្លាហាន ក្នុងនាមជាជនគ្មានទោស និងជនរងគ្រោះទាំងអស់នោះ ខ្ញុំនឹងធ្វើការលើកលែងទោសដល់ជនដែលដល់ចំពោះការសម្លាប់នោះ ពីព្រោះថាជនទាំងនោះបានយល់ខុស ។ ខ្ញុំសូមបញ្ចប់ត្រឹមនេះ» ។



***រូបខាងលើ*** ៖ *ការជីករណ្តៅសាកសពរួម នៅស្រីប្រេនីកា ប្រទេសបូស្នៀ នៅខែកក្កដា ឆ្នាំ២០០៧ ។* ***រូបខាងក្រោម*** ៖ *ពិធីបញ្ចុះមឈូសតម្កល់សាកសពរបស់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅបូស្នៀ នៅខែកក្កដា ឆ្នាំ២០០៧ ។ រូបថត ៖ កែវ ដាស៊ីល*



## ប្រធានបទទី៥ ៖ រ៉្វាន់ដា

**សាសនា** ៖ *រ៉ូម៉ាំង-កាតូលិក៦៥ភាគរយ ប្រូតេស្តង់៩ភាគរយ មូស្លីម១ភាគរយ ជំនឿតាមតំបន់ និងសាសនាដទៃទៀត ២៥ភាគរយ*

**ការបែងចែកជាតិពន្ធុ** ៖ *ហ៊ូទូ ទូតស៊ី ត្វា និងជនជាតិផ្សេងៗទៀត*

**បរិបទប្រវត្តិសាស្ត្រ** ៖ *ឆ្នាំ១៩៩៤*

*យុទ្ធនាការសម្លាប់រង្គាលដែលបានកើតឡើងនៅក្នុងប្រទេសរ៉្វាន់ដា ក្នុងឆ្នាំ១៩៩៤ មានបុសគល់ចេញមកពីបទពិសោធន៍នាសម័យអាណានិគម ។ រ៉្វាន់ដា ត្រូវបានកាន់កាប់ដំបូងដោយអាល្លឺម៉ង់ និងក្រោយមកទៀតធ្លាក់ក្រោមការគ្រប់គ្រងរបស់បែលហ្ស៊ិក ។ ដោយប្រើការពិនិត្យលើបុគ្គលិកលក្ខណៈ និងលើរូបរាងខាងក្រៅសម្រាប់កំណត់ការបែងចែកពូជសាសន៍ អាណានិគមអឺរ៉ុបបានសម្រេចថា ជនជាតិហ៊ូទូ និងទូតស៊ី គឺជាពូជសាសន៍ពីរដាច់ដោយឡែកពីគ្នា ។ ដោយសារតែជនជាតិទូតស៊ីមើលទៅហាក់បីដូចជា ខ្ពស់ ស្គើង និងដូចជនជាតិអឺរ៉ុបជាងជនជាតិហ៊ូទូ ជនជាតិទូតស៊ីត្រូវបានសន្មតថា ជា«ពូជសាសន៍មេ» ។ ប្រការនេះបានធ្វើឲ្យជនជាតិទូតស៊ីមានទំនាក់ទំនងល្អជាមួយនឹងអាណានិគមបែលហ្ស៊ិក ។ អត្តសញ្ញាណប័ណ្ណត្រូវបានបង្កើតឡើងដោយបែលហ្ស៊ិក ដើម្បីសម្គាល់រវាងជនជាតិហ៊ូទូ និងជនជាតិទូតស៊ី ។ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ពេលដែលប្រទេសក្នុងទ្វីបអាហ្វ្រិក បានធ្វើដំណើរឆ្ពោះទៅការទាមទារឯករាជ្យពីអាណានិគមជនជាតិទូតស៊ីបានដើរឆ្ពោះទៅរកការបង្កើតឯករាជភាពសម្រាប់ប្រទេសរ៉្វាន់ដាដែរ ។ ដំណើរនេះបានជំរុញឲ្យបែលហ្ស៊ិក ប្តូរទិសដៅទៅចងចំណងមិត្តភាពជាមួយជនជាតិហ៊ូទូវិញម្តង ។ ជនជាតិហ៊ូទូជាច្រើននាក់បានឆក់យកឱកាសនេះដើម្បីវាយប្រហារទៅលើជនជាតិទូតស៊ី ក្នុងរវាងឆ្នាំ១៩៥៩-១៩៦២ ។ តាមការសន្និដ្ឋានជនជាតិទូតស៊ីប្រហែលមួយសែននាក់ បានភៀសខ្លួនទៅប្រទេសជិតខាង ។ ក្រោយឆ្នាំ១៩៨៦ ជនជាតិទូតស៊ីក្នុងប្រទេសអ៊ុយហ្គាន់ដា បានបង្កើតជាកងកម្លាំងទ័ពព្រៃមួយដែលមានឈ្មោះថា រណសិរ្សស្នេហាជាតិរ៉្វាន់ដា ដែលមានបំណងដណ្តើមយកអំណាចគ្រប់គ្រងលើប្រទេសរ៉្វាន់ដា និងផ្តួលរំលំរបបរបស់លោកប្រធានាធិបតីហាបីយ៉ារីម៉ាណា ។*

*នៅឆ្នាំ១៩៩០ រណសិរ្សស្នេហាជាតិរ៉្វាន់ដា បានលុកលុយចូលប្រទេសរ៉្វាន់ដា និងបានកាន់កាប់លើតំបន់មួយចំនួន ។ របបរបស់លោកប្រធានាធិបតី ហាបីយ៉ារីម៉ាណា សម្រេចទទួលស្គាល់រណសិរ្សស្នេហាជាតិរ៉្វាន់ដា ថាជាអំណាចនយោបាយមួយនៅក្នុងប្រទេសរ៉្វាន់ដា នៅពេលដែលខ្លួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពសម្រុះសម្រួលជាអន្តរជាតិមួយ ។ អង្គការសហប្រជាជាតិបានបញ្ជូនកងរក្សាសន្តិសុខចំនួនប្រាំពាន់នាក់ទៅកាន់ប្រទេសរ៉្វាន់ដា ដើម្បីផ្តល់នូវសន្តិសុខដ៏ពិតប្រាកដមួយ ។ ក្រុមហ៊ូទូជ្រុលនិយមមួយចំនួនមិនទទួលស្គាល់កិច្ចព្រមព្រៀងសន្តិភាពនេះទេ ហើយបានចាប់ផ្តើមបង្កើតគម្រោងមួយដែល«បញ្ហារបស់ជនជាតិទូតស៊ី»អាចនឹងត្រូវបានដោះស្រាយ ។ កាលពីថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៤ យន្តហោះរបស់លោកប្រធានាធិបតី ហាបីយ៉ារីម៉ាណា ត្រូវបានបាញ់ទម្លាក់ ហើយក្នុងរយៈពេលមួយថ្ងៃ ការបិទផ្លូវត្រូវបានធ្វើឡើងនៅក្នុងរដ្ឋធានី ។ ការបិទផ្លូវទាំងនេះត្រូវបានគ្រប់គ្រងដោយកងកម្លាំងយោធា ដែលជាក្រុមបងធំដែលបំពាក់ដោយអាវុធ ។ ជនជាតិទូតស៊ី ត្រូវបានសម្លាប់ជាបន្តបន្ទាប់នៅទូទាំងប្រទេសក្នុងល្បឿនមួយយ៉ាងលឿន ។ មូលហេតុមួយផ្នែកទៀត ទាក់ទងនឹងការសម្លាប់រង្គាលនេះ អាចបណ្តាលមកពីការប្រើប្រាស់កម្មវិធីវិទ្យុរបស់រដ្ឋាភិបាលដែលជំរុញឲ្យមានការសម្លាប់លើជនជាតិទូតស៊ី ។ ក្នុងរយៈពេលតែពីរបីថ្ងៃប៉ុណ្ណោះ ជនជាតិទូតស៊ីរាប់ពាន់*

នាក់ត្រូវបានសម្លាប់ ហើយជាញឹកញាប់ត្រូវបានសម្លាប់នឹងកាំបិត ។ យុទ្ធនាការប្រល័យពូជសាសន៍នេះបានបន្តកើតមានឡើងអស់រយៈពេលជាច្រើនខែ រហូតមកដល់ពេលរណសិរ្សស្នេហាជាតិរ៉្វាន់ដា ដឹកនាំដោយជនជាតិទូតស៊ីបានធ្វើការគ្រប់គ្រងលើទីក្រុងគីហ្គាលី នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៤ ។ បរាជ័យនៅទីក្រុងគីហ្គាលី មិនបានបញ្ចប់ការកាប់សម្លាប់នោះទេ ។ ក្នុងពេលនោះដែរ ការសងសឹកក្នុងទ្រង់ទ្រាយធំប្រឆាំងនឹងជនជាតិហ៊ូទូ ដែលត្រូវបានចោទប្រកាន់ថាបានចូលរួមនៅក្នុងយុទ្ធនាការកាប់សម្លាប់ត្រូវបានធ្វើឡើង ។ ការប៉ាន់ស្មានលើចំនួនអ្នកស្លាប់មានចំនួនខុសគ្នា ប៉ុន្តែចំនួនអ្នកស្លាប់សរុបទាំងអស់ត្រូវបានគេជឿថា មានចំនួនរាប់រយពាន់នាក់ក្នុងរយៈពេលប្រហែលតែមួយរយថ្ងៃប៉ុណ្ណោះ ។

### សក្ខីកម្ម និងសាច់រឿង

ខាងក្រោមនេះ គឺជាចម្លើយដកស្រង់ពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា លើករណីរបស់ជនត្រូវចោទ ជីន ប៉ូល អាកាយ៉េស៊ូ ។

### ជនត្រូវចោទ

ជីន ប៉ូល អាកាយ៉េស៊ូ កើតនៅឆ្នាំ១៩៥៣ ។ គាត់គឺជាកីឡាករជំនាញម្នាក់ និងជាសមាជិករបស់ក្រុមកីឡាករបាល់ទាត់ជាតិ ។ នៅឆ្នាំ១៩៧៨ គាត់បានរៀបការជាមួយនារីម្នាក់រស់នៅក្នុងភូមិជាមួយគាត់អស់រយៈពេលដប់ឆ្នាំ ។ គាត់ និងប្រពន្ធ នៅតែរស់នៅជាមួយគ្នា ហើយមានកូនប្រាំនាក់ ។

មុនពេលដែល អាកាយ៉េស៊ូ ត្រូវបានតែងតាំងជាអភិបាលក្រុងនៅឆ្នាំ១៩៩៣ គាត់ធ្លាប់បានធ្វើជាគ្រូបង្រៀន និងត្រូវបានដំឡើងតំណែងជាអ្នកគ្រប់គ្រងសាលាបឋមសិក្សា ។ នៅក្នុងសមាសភាពនេះ អាកាយ៉េស៊ូ ទទួលបន្ទុកលើការគ្រប់គ្រងវិស័យអប់រំក្នុងឃុំ និងដើរតួជាមេដឹកនាំគ្រូបង្រៀនទាំងអស់ ។ ជួនពេលខ្លះ អាកាយ៉េស៊ូ ត្រូវធ្វើជាគ្រូជំនួស ហើយការបង្រៀនរបស់គាត់តែងតែទទួលបាននូវភាពពេញចិត្តពីសិស្ស ។ និយាយជាទូទៅ អាកាយ៉េស៊ូ គឺជាបុគ្គលដែលមានប្រជាប្រិយភាពម្នាក់នៅក្នុងសហគមន៍របស់គាត់ ។

នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៤ អាកាយ៉េស៊ូ បានដឹកនាំធ្វើការប្រជុំមួយដែលគាត់ជំរុញឲ្យប្រជាជនទាំងអស់បញ្ឈប់អ្នកចូលដៃរបស់រណសិរ្សស្នេហាជាតិរ៉្វាន់ដា RPF (អង្គភាពទ័ពរបស់ជនជាតិទូតស៊ី) ឬជាឈ្មោះដែល អាកាយ៉េស៊ូ ហៅថា ជាអ្នកចូលដៃក្បត់ ។ មនុស្សចំនួនលើសពីមួយរយនាក់អវត្តមាននៅក្នុងអង្គប្រជុំនេះ ។ អាកាយ៉េស៊ូ បានបញ្ជាឲ្យប្រជាជនក្នុងស្រុកធ្វើការសម្លាប់មនុស្សដែលមានចំណេះដឹង និងមនុស្សដែលមានឥទ្ធិពលទាំងអស់ ។ គ្រូបង្រៀនចំនួនប្រាំនាក់ត្រូវបានសម្លាប់ក្រោមការបញ្ជារបស់ អាកាយ៉េស៊ូ ។ ប្រជាជនក្នុងស្រុកបានសម្លាប់គ្រូបង្រៀនទាំងប្រាំនាក់នេះ ដោយប្រើកាំបិត និងឧបករណ៍ធ្វើស្រែចម្ការ ។

គេឃើញមានភ័ស្តុតាងមួយចំនួនកាលពីមុនថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៤ ដែលបានកត់ត្រាថា អាកាយ៉េស៊ូ មានបំណងជៀសវាងអំពើហិង្សាកុំឲ្យកើតឡើងនៅក្នុងឃុំ ។ សាក្សីជាច្រើននាក់បានផ្តល់ចម្លើយគាំទ្រ លើការខិតខំប្រឹងប្រែងរក្សាសន្តិសុខនៅក្នុងឃុំ ហើយ អាកាយ៉េស៊ូ បានធ្វើការប្រឆាំងដោយប្រើកងកម្លាំង ក្នុងការចូលលុកលុយដែលធ្វើឡើងដោយចេតនា ដើម្បីធានាថា ការសម្លាប់ដែលចាប់ផ្តើមកើតមានឡើងនៅក្នុងទីក្រុងគីហ្គាលី កាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៤ មិនរីករាលដាលនៅក្នុងឃុំនេះទេ ។

សាក្សី “ក” បានឆ្លើយថា ពេលដែលកងទ័ពព្យាយាមចូលក្នុងឃុំរបស់យើង អាកាយ៉េស៊ូ បានធ្វើអ្វីៗទាំងអស់

ដើម្បីវាយប្រហារលើកងទ័ពទាំងនោះវិញ ហើយបានកោះហៅប្រជាជននៅក្នុងឃុំឲ្យធ្វើដំណើរទៅកាន់ព្រំប្រទល់ឃុំ ដើម្បីដេញកងទ័ពទាំងនោះឲ្យចេញពីឃុំ ។

យ៉ាងណាមិញ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានរកឃើញនូវភស្តុតាងដោយគ្មានការសង្ស័យ ដែលថា សកម្មភាពប្រព្រឹត្តរបស់ជនត្រូវចោទបានផ្លាស់ប្ដូរក្រោយពីថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៤ ដែលក្រោយពីកាលបរិច្ឆេទខាងលើ ជនត្រូវចោទមិនមានបំណងបញ្ឈប់ការកាប់សម្លាប់ទៅលើជនជាតិទូតស៊ី នៅក្នុងឃុំនោះទេ ។ តាមការពិតមានភស្តុតាងមួយដែលបង្ហាញថា អាកាយេស៊ូ មិនត្រឹមតែបានដឹង និងបានឃើញការសម្លាប់ប៉ុណ្ណោះទេ គាត់ថែមទាំងបានចូល និងបានផ្ដល់បទបញ្ជាលើការសម្លាប់ទៀតផង ។

**សេចក្ដីដកស្រង់របស់ជនរងគ្រោះ**

*ខណៈពេលដែលយុទ្ធនាការសម្លាប់ត្រូវបានបង្កើតឡើង កងទ័ព និងយោធាបានធ្វើសកម្មភាព ហាក់បីដូចជាខ្លួនទទួលបានការអនុញ្ញាតឲ្យសម្លាប់នរណាក៏បានឲ្យតែបុគ្គលនោះមានកិនភាគដូចជនជាតិទូតស៊ី ។ កាលពីថ្ងៃទី២៣ ខែមេសា ប្ដីប្រពន្ធជនជាតិហ្វេរៀន គឺលោក L និងប្រពន្ធរបស់គាត់កំពុងតែធ្វើដំណើរ ហើយឈប់នៅឯទីផ្សារមួយ ។ ពេលដែលលោក L កំពុងតែទិញអីវ៉ាន់ខ្លះ ប្រពន្ធរបស់គាត់បានចាំនៅក្នុងរថយន្ត ។ កងទ័ព និងយោធាដែលធ្វើដំណើរឆ្លងកាត់ទីនោះ បានសម្គាល់ឃើញប្រពន្ធរបស់លោក L ហើយសួររកអត្តសញ្ញាណប័ណ្ណរបស់គាត់ ។ នៅពេលគាត់មិនអាចឲ្យអត្តសញ្ញាណប័ណ្ណទៅកងយោធាទាំងនោះឆាប់រហ័ស កងយោធាទាំងនោះក៏បានបាញ់សម្លាប់គាត់នៅនឹងកន្លែងតែម្ដង ។*

**សេចក្ដីដកស្រង់របស់ជនរងគ្រោះ**

*ពេលខ្លះជនជាតិហ៊ូទូបានជួយជនជាតិទូតស៊ីភ្លាមៗ នៅក្នុងអំពើឧក្រិដ្ឋដែលត្រូវបានសម្រេច និងអនុវត្តភ្លាមៗ ។ ស្ត្រីជនជាតិទូតស៊ីម្នាក់ដែលទើបតែសម្រាលកូនថ្មីៗ និងបានលាក់ខ្លួននៅក្នុងផ្ទះរបស់ជនជាតិហ៊ូទូ បានដឹងថាសំឡេងយំរបស់កូនដែលទើបតែនឹងកើត នឹងធ្វើឲ្យមនុស្សតាមដានស្វែងរកហើយថែមទាំងអាចសម្លាប់ជនជាតិហ៊ូទូដែលការពារគាត់ រួមទាំងរូបគាត់ និងកូនរបស់គាត់ផង ។ ស្ត្រីរូបនេះ និងជនជាតិហ៊ូទូដែលជាអ្នកការពារគាត់បានជជែកពិភាក្សាគ្នាពីលទ្ធភាពដែលអាចធ្វើបានជាច្រើន រួមមានទាំងការសម្រេចចិត្តសម្លាប់ទារកនោះទៀតផង ។ នៅចុងបញ្ចប់អ្នកទាំងអស់គ្នាប្រថុយព្យាយាមសូកលុយឲ្យកងយោធា ហើយប្ដីប្រពន្ធនោះសុខចិត្តនាំស្ត្រីជាម្ដាយ និងកូនចេញពីសហគមន៍ជនជាតិហ៊ូទូ ដោយយកទារកនោះទៅលាក់ជាមួយនឹងគ្រាប់បែក និងគ្រាប់កាំភ្លើងនៅក្នុងរថយន្តរបស់យោធា ។*

**សេចក្ដីដកស្រង់របស់ជនរងគ្រោះ**

*នៅក្នុងឃុំមួយ បុរសម្នាក់ក្នុងចំណោមបុរសខ្លះទៀតដែលឈរនៅក្នុងភូមិ បាននាំសាច់ញាតិជាច្រើនចេញពីគ្រួសារទូតស៊ីរបស់ប្រពន្ធគាត់ រួមទាំងកូនធម៌ជនជាតិទូតស៊ី និងគ្រួសាររបស់គាត់ ។ កូនធម៌រូបនេះបាននិយាយរៀបរាប់ព្រឹត្តិការណ៍នៅយប់នោះថា ៖*

*នៅពេលដែលខ្ញុំមកដល់ទីកន្លែងរបស់គាត់ ខ្ញុំបានឃើញមនុស្សជាច្រើននាក់បានលាក់ខ្លួននៅទីនេះ ។ មកត្រឹមម៉ោងប្រាំមួយល្ងាច វាច្បាស់ណាស់ដែលយើងមិនអាចលាក់ខ្លួននៅទីនេះបានទេ ។ មនុស្សជាច្រើនបានឃើញយើងចូលមកក្នុងផ្ទះរបស់គាត់ ។ គាត់មិនបាននិយាយចេញមកទេ ប៉ុន្តែគាត់បានបង្ហាញឲ្យអ្នករាល់គ្នាដឹងថា*

អ្នកទាំងអស់គ្នាត្រូវតែចាកចេញពីផ្ទះរបស់គាត់ ។ គេបានចាកចេញដោយគ្មានសម្ដែងនូវការយំសោកស្ដាយ ឬមនោសញ្ចេតនាអ្វីទាំងអស់ លើកលែងតែក្មេងប្រុសម្នាក់ដែលបានសម្ដែងភាពភ័យខ្លាច ។ ក្មេងនេះមានសភាពញ័រចំប្រប់ នៅពេលដែលវាចាកចេញពីផ្ទះដែលវាលាក់ខ្លួន ។ នៅក្នុងចំណោមមនុស្សទាំងអស់នេះក៏មានកូនប្រសាប្រុសរបស់គាត់ដែលត្រូវជាប្ដីរបស់កូនស្រីគាត់ម្នាក់ដែរ ។ កូនស្រីរបស់បុរសជាជនជាតិហ្ស៊ីហ្វ បានដេកយំពេញមួយយប់ ។ នៅពេលដែលមនុស្សគ្រប់គ្នាកំពុងតែចាកចេញ គាត់បានមកខ្សឹបប្រាប់ខ្ញុំថានៅទីនេះហើយ ។ ដូច្នេះ ខ្ញុំ ប្រពន្ធនិងកូនរបស់ខ្ញុំបានស្នាក់នៅក្នុងផ្ទះរបស់គាត់នៅយប់នោះ ប៉ុន្តែគ្មាននរណាម្នាក់ដេកឡើយ ។ ខ្ញុំបានអង្គុយនៅលើកៅអី ចំណែកឯកូនស្រីរបស់ឪពុកធម៌ខ្ញុំបានយំ ពីព្រោះថា ឪពុករបស់នាងបានបញ្ជូនប្ដីរបស់នាងទៅកន្លែងផ្សេង ។ បន្ទាប់មកនៅពាក់កណ្ដាលយប់ យើងឮសំឡេងបាញ់កាំភ្លើង និងសំឡេងស្រែកថ្ងូរយ៉ាងអាណោចអាធ័ម ។ ខ្ញុំមិនដែលធ្លាប់ខ្លាចដូចជាពេលនោះទេ ។ ខ្ញុំអង្គុយញ័រខ្លួនលើកៅអីពេញមួយយប់ ។

នៅពេលព្រឹកឡើង បុរសជាសាក្សីបានចាកចេញពីកន្លែងដែលគាត់លាក់ខ្លួន ដោយសង្ឃឹមថា នឹងអាចរកបានឱកាសច្រើនថែមទៀតក្នុងការនាំប្រពន្ធ និងកូនរបស់គាត់ ចាកចេញដោយគ្មានការវាយប្រហារពីកងយោធា ។ នៅទីបញ្ចប់ រូបគាត់បានរួចរស់ជីវិត ប៉ុន្តែក្រុមគ្រួសាររបស់គាត់មិនបានរួចរស់ជីវិតទេ ។

## ការពន្យល់អំពីទស្សនៈនៃការសិក្សាជាក្រុម

នៅក្នុងសកម្មភាពនេះ សិស្សត្រូវបានបែងចែកជាក្រុមដែលមានសមាជិក៤ឬ៥នាក់ ។ សិស្សម្នាក់ត្រូវចាត់តាំងឲ្យធ្វើជាប្រធានក្រុម ។ ក្រុមនីមួយៗត្រូវបានដាក់ការងារឲ្យសិក្សាទៅលើប្រធានបទមួយ និងក្លាយទៅជា«អ្នកជំនាញ»នៃប្រធានបទនោះ ។ ក្រុមនីមួយៗធ្វើបទបង្ហាញអំពីការរកឃើញរបស់ខ្លួនទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ហើយពិភាក្សាពីភាពដូចគ្នា និងភាពខុសគ្នានៃករណីសិក្សារបស់ខ្លួនជាមួយករណីសិក្សារបស់ក្រុមឯទៀត ។

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥ - ១០ នាទី)*

មុនចាប់ផ្ដើមបង្រៀន គ្រូពន្យល់សិស្សពីរបៀបធ្វើការជាក្រុម ដូចមាននៅក្នុងគម្រោងជាជំហានៗខាងក្រោម ។

## តារាងជំនួយក្នុងការរៀបចំលំហាត់ធ្វើការងារជាក្រុម ជាជំហានៗ

| ជំហាន | សេចក្តីណែនាំ |
| --- | --- |
| ទី១ | គ្រូណែនាំសិស្សឲ្យបង្កើតក្រុមដែលមានមានសមាជិកពី៤ទៅ៥នាក់ ។ សិស្សនឹងរៀបចំតុរបស់ខ្លួន ដើម្បីឲ្យសមាជិកក្រុមអាចអង្គុយទល់មុខគ្នាជាក្រុមមួយ ។ មិនមានការកំណត់ចំនួនក្រុមនៅក្នុងថ្នាក់ទេ ។ |
| ទី២ | គ្រូនឹងផ្តល់ឲ្យក្រុមនីមួយៗនូវលេខរៀងពីលេខ១ដល់លេខ៥ ។ ក្រុមនីមួយៗត្រូវចាំលេខរៀងរបស់ខ្លួន ។ |
| ទី៣ | គ្រូសរសេរនៅលើក្តារខៀនដូចខាងក្រោម ៖<br>១ = កម្ពុជា, ២ = ណាហ្ស៊ី ហូឡូខសត៍, ៣ = អ៊ីរ៉ាក់, ៤ = អតីតយូហ្គោស្លាវី, ៥ = រ៉្វាន់ដា |
| ទី៤ | គ្រូពន្យល់ថា ផ្អែកលើលេខរៀងដែលបានកំណត់ក្រុមនីមួយៗនឹងសិក្សា ហើយក្លាយជាអ្នកជំនាញលើករណីសិក្សាជាក់លាក់របស់ខ្លួន ។ សិស្សត្រូវតែពិភាក្សានៅក្នុងក្រុមរបស់ខ្លួន ហើយរៀបចំរបាយការណ៍មួយដែលនឹងឆ្លើយទៅនឹងសំណួរពីរខាងក្រោម ។ ក្រុមនីមួយៗនឹងឡើងបង្ហាញពីរបាយការណ៍របស់ខ្លួនទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។<br>១) តើអ្វីជាព្រឹត្តិការណ៍សំខាន់ដែលមនុស្សម្នាក់ៗគួរដឹងអំពីរយៈកាលប្រវត្តិសាស្ត្រដែលអ្នកកំពុងសិក្សា? សូមផ្តល់ព្រឹត្តិការណ៍ពិតចំនួន ៥ អំពីរយៈកាលនោះ ។<br>២) តើអ្វីជាការសង្កេតសំខាន់ៗ អំពីជនរងគ្រោះដែលទទួលរងការឈឺចាប់នៅក្នុងប្រវត្តិសាស្ត្រនេះ?<br>សូមផ្តល់ការសង្កេតចំនួន៥អំពីរយៈកាលនោះ ។ |
| ទី៥ | គ្រូសួរ ប្រសិនបើសិស្សមានសំណួរ ហើយសិស្សចាប់ផ្តើមការសិក្សា និងការរៀបចំករណីសិក្សារបស់ខ្លួន ។ |
| ទី៦ | ក្រុមទាំងអស់បញ្ចប់ការសិក្សា និងធ្វើការកែតម្រូវចុងក្រោយទៅលើបទបង្ហាញរបស់ខ្លួនទៅកាន់សិស្សឯទៀតនៅក្នុងថ្នាក់ ។ |
| ទី៧ | គ្រូជ្រើសរើសក្រុមមួយចំនួនឲ្យឡើងធ្វើបទបង្ហាញនៅក្នុងថ្នាក់ ។ |
| ទី៨ | គ្រូពិភាក្សាការឡើងធ្វើបទបង្ហាញជាក្រុម ដោយសួរសំណួរដូចខាងក្រោម ៖<br>១) តើអ្វីជាភាពស្រដៀងគ្នានៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងអស់?<br>២) តើអ្វីជាភាពខុសគ្នានៃអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងអស់?<br>៣) តើអ្វីជាលក្ខណៈពិសេស ឬភាពខុសប្លែកពីគេនៃរបបខ្មែរក្រហម? |
| ទី៩ | គ្រូឲ្យសិស្សម្នាក់ ឬពីរនាក់ធ្វើសំយោគអំពីអ្វីដែលបានរៀនសម្រាប់មេរៀននេះ ។ |

## តារាងបង្ហាញអំពីអ្វីដែលក្រុមនីមួយៗនឹងសិក្សា






ដើមឆ្នាំ១៩៧៩ កូនប្រុសខ្ញុំ និងខ្ញុំ វិលត្រឡប់ទៅស្រុកកំណើតរបស់យើងវិញ នៅខេត្តបាត់ដំបង ។ កូនប្រុសខ្ញុំនៅតែទន្ទេញសួររកឪពុក តែខ្ញុំតែងតែកុហកកូនខ្ញុំថា ពេលទៅដល់ផ្ទះវិញនឹងបានជួបឪពុកហើយ ។ ពេលយើងធ្វើដំណើរទៅដល់ភូមិកំណើតយើងវិញ បងប្អូនសាច់ញាតិចេញមកទទួលរាក់ទាក់ខ្ញុំ និងកូនខ្ញុំ តែមិនឃើញប្តីខ្ញុំទេ ។ គាត់ឈ្មោះ ថាច់ គឹម ។ ខ្ញុំបានសួររកគាត់គ្រប់ទីកន្លែង ។ ពេលនោះខ្ញុំលែងសង្ឃឹមថាគាត់អាចរស់ទៀតហើយ ។ ខ្ញុំទៅវត្ត និងធ្វើបុណ្យឧទ្ទិសកុសល និងអំពើល្អជូនគាត់ ។ ថាច់ គឹម ត្រូវបានចាប់ខ្លួននៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ និងបានបញ្ជូនទៅមន្ទីរស-២១ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សធ្វើការសិក្សា និងធ្វើបទបង្ហាញពីករណីសិក្សា ដើម្បីដាក់រយៈពេលនៃរបបខ្មែរក្រហមនៅក្នុងគំនិត ។

**តារាងដាក់ពិន្ទុសម្រាប់គ្រូ**

| សំណួរ | មិនឆ្លើយនឹងសំណួរ ០ពិន្ទុ | ឆ្លើយនឹងសំណួរ ១ពិន្ទុ |
|---|---|---|
| តើក្រុមនេះឆ្លើយនឹងសំណួរទី១ដែរឬទេ? | | |
| តើក្រុមនេះឆ្លើយនឹងសំណួរទី២ដែរឬទេ? | | |
| តើក្រុមនេះឆ្លើយនឹងសំណួរទី៣ដែរឬទេ? | | |
| **គ្រូដាក់ពិន្ទុសរុបទៅឲ្យក្រុម** | | |

*សំយោគ (១៥-២៥នាទី)*

សិស្សពន្យល់អំពីការយល់ដឹង និងការវិភាគរបស់ខ្លួនទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ។ គ្រូវាយតម្លៃកិច្ចការសរសេររបស់សិស្ស និងការឡើងពន្យល់ផ្ទាល់មាត់ ។

## មេរៀនទី៥ ៖ ខ្សែភាពយន្ត «កុមារកម្ពុជា»

*តម្រូវឲ្យមាន ឌីវីឌី (DVD) និងវីស៊ីអរ (VCR) ដើម្បីបញ្ចាំងខ្សែភាពយន្ត (សកម្មភាពនេះគឺឥតកំហិត)*

**វត្ថុបំណង**

១) សិស្សពន្យល់ពីអត្ថន័យនៃពាក្យ ចលាចល ការឈឺចាប់ ការរស់រានមានជីវិត ការផ្សះផ្សា យុត្តិធម៌ និងសន្តិភាព ។

២) សិស្សសរសេរសំបុត្រទៅអ្នកផលិតខ្សែភាពយន្ត ដោយផ្តល់ជាទស្សនៈ និងសំណួរ ។

៣) សិស្សវិភាគពីឥទ្ធិពលរបស់ខ្សែភាពយន្ត ។

៤) សិស្សស្វែងយល់ថា តើហេតុអ្វីបានជាខ្សែភាពយន្តប្រភេទនេះ មានសារសំខាន់សម្រាប់ឲ្យសាកលលោកបានដឹង ។

**សម្ភារឧបទេស** ៖ ខ្សែភាពយន្ត“កុមារកម្ពុជា” និងសៀវភៅលំហាត់សម្រាប់សិស្ស ។

**លំនាំបង្រៀន**

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូណែនាំពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ និងពិភាក្សាថាតើស្ថានភាពរស់នៅក្រោមរបបខ្មែរក្រហមមានផលប៉ះពាល់ដូចម្តេចខ្លះមកលើជីវិតរស់នៅក្នុងអំឡុងពេល និងក្រោយរបបនេះ ។ បន្ទាប់មកគ្រូពិភាក្សាខ្សែភាពយន្តជាមួយសិស្ស ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សសរសេរសំបុត្រទៅអ្នកផលិតខ្សែភាពយន្ត ដោយពន្យល់អំពីឥទ្ធិពលរបស់ខ្សែភាពយន្តទៅលើខ្លួន ។ គ្រូលើកទឹកចិត្តសិស្សឲ្យសួរសំណួរទៅកាន់អ្នកផលិតខ្សែភាពយន្តតាមរយៈសំបុត្ររបស់ខ្លួន ហើយពិភាក្សាអំពីអត្ថន័យនៅក្នុងសំបុត្រជាមួយមិត្តភក្តិនៅក្នុងថ្នាក់ ។

*សំយោគ (១៥-២៥នាទី)*

គ្រូពិភាក្សាអំពីអត្ថន័យរបស់ខ្សែភាពយន្ត និងថាតើហេតុអ្វីបានខ្សែភាពយន្តប្រភេទនេះមានសារសំខាន់សម្រាប់ឲ្យសាកលលោកបានដឹង ។







***រូបខាងលើ*** ៖ *បណ្ឌិត ជា ផល្លា (ឆ្វេង) និង គ្រីស្តូហ្វ័រ ឌៀរីង (ស្តាំ) កំពុងធ្វើសេចក្តីណែនាំអំពីការបង្រៀន នៅក្នុងវគ្គបណ្តុះបណ្តាលស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។* ***រូបខាងក្រោម*** ៖ *លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួង អប់រំ យុវជន និងកីឡា និង លោក ឆាំង យុ កំពុងចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សវិទ្យាល័យបឹងត្របែក ឆ្នាំ២០១១ ក្នុងអំឡុងពិធីសម្ពោធពាក្យស្លោកស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។ រូបថត ៖ ញាណ សុជាតិ*



# សេចក្តីបញ្ចប់ ៖ ផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ន




*មេឃុំកំពុងកត់ត្រា "វិន័យសន្តិបាល" ដែលដាក់បង្ហាញនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង នៅខែមករា ឆ្នាំ២០០៧ ។*
*រូបថត ៖ កែវ ដាស៊ីល*

## មេរៀនទី១ ៖ អំណានសេចក្តីបញ្ចប់ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### វត្ថុបំណង

១) សិស្សពន្យល់អំពីផលប៉ះពាល់នៃបទពិសោធន៍ក្នុងរបបខ្មែរក្រហមមកលើជីវិតរស់នៅនាពេលបច្ចុប្បន្ន ។
២) សិស្សពន្យល់អំពីតម្រូវការនៃការព្យាបាលរបួសផ្លូវចិត្ត ការផ្សះផ្សា យុត្តិធម៌ សន្តិភាព និងការអភិវឌ្ឍន៍ ។
៣) សិស្សកំណត់និយមន័យនៃពាក្យសំខាន់ៗទាក់ទងនឹងការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌ ។
៤) សិស្សសំយោគការសិក្សារបស់ខ្លួន ដោយឆ្លើយនឹងសំណួរណែនាំ ។

***សម្ភារឧបទេស*** ៖ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅលំហាត់ និងអត្ថបទស្តីអំពីការព្យាបាលរបួសផ្លូវចិត្ត ការផ្សះផ្សា សន្តិភាព និងយុត្តិធម៌ ។

## ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា



មេឃុំជួបសំណេះសំណាលជាមួយមន្ត្រីតុលាការនៅក្នុងសាលសវនាការ នៅខែមករា ឆ្នាំ២០០៧ ។
រូបថត ៖ កែវ ដាស៊ីល

### តើអ្វីជាការផ្សះផ្សា?

ខណៈដែលអ្នកស្រាវជ្រាវ និងអ្នកជំនាញច្បាប់ជាច្រើនបានសរសេរយ៉ាងច្រើនលើសលប់អំពីការផ្សះផ្សា និយមន័យនៃពាក្យ ផ្សះផ្សា នៅមិនទាន់ត្រូវបានទទួលស្គាល់ទូលំទូលាយនៅឡើយទេ ។

អ្នកស្រាវជ្រាវមួយចំនួនបានបកស្រាយពីភាពមិនច្បាស់នេះ តាមរយៈការកំណត់និយមន័យនៃពាក្យផ្សះផ្សាថាជាដំណើការមួយជាជាងជាគោលដៅមួយទៅវិញ ។ យោងទៅតាមទស្សនៈនេះ ការផ្សះផ្សា "គឺជាការដោះស្រាយជាមួយអតីតកាលក្នុងរបៀបមួយដែលនាំឲ្យមានការផ្លាស់ប្តូរឥរិយាបថចំពោះអ្នកដទៃ ចំពោះខ្លួនឯង និងចំពោះទំនាក់ទំនងរវាង "ភាគីជម្លោះ" ។ អ្នកឯកទេសខាងការផ្សះផ្សាផ្សេងទៀតបានគូសបញ្ជាក់ថា ទោះជាមានភាពខុសគ្នាក្នុងការកំណត់និយមន័យយ៉ាងណាក៏ដោយ ក៏ខ្លឹមសារមួយចំនួនបានលេចឡើងយ៉ាងស្របគ្នា ។

នៅពេលដែលប្រជាជនកម្ពុជាសាមញ្ញ ត្រូវបានសួរដើម្បីកំណត់និយមន័យនៃពាក្យ “ផ្សះផ្សា” គំនិតដូចៗគ្នាបានលេចឡើង ។ ប្រការនេះមានភាពច្បាស់លាស់ ពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការស្ទាបស្ទង់មតិអំពីថា តើអ្នកចូលរួមពិពណ៌នាថា“ការផ្សះផ្សា”មានន័យយ៉ាងម៉េច ។ ទោះបីជា អ្នកចូលរួមមានគំនិតខុសប្លែកគ្នាយ៉ាងច្រើនអំពីការផ្សះផ្សាក៏ដោយ ក៏ខ្លឹមសារដូចជា “ការចងចាំ” និង “យុត្តិធម៌” ត្រូវបានលើកឡើងដដែលៗ ។ លើសពីនេះទៀត ប្រជាជនកម្ពុជាភាគច្រើនបំផុត បានចាត់ទុកគោលដៅនៃការផ្សះផ្សា ថាជា“គោលដៅតែមួយគត់ដែលអាចនាំឲ្យប្រទេសជាតិមានការរួបរួម វិបុលភាព និងអភិវឌ្ឍន៍” ជាសង្គមមួយ “ដែលគ្មានអំពើហិង្សា និងជម្លោះ” និងជាសង្គមមួយដែល“រស់នៅក្រោមវិធាននៃច្បាប់” ។

ការស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញឲ្យឃើញថា អ្នកចូលរួមនៅក្នុងការស្ទាបស្ទង់ មានការយល់ដឹងអំពីបញ្ហាផ្សះផ្សាទៅលើបួនកម្រិតផ្សេងៗគ្នា ៖ ជាបញ្ហាផ្ទាល់ខ្លួន ជាបញ្ហារវាងបុគ្គល និងបុគ្គល ជាបញ្ហានៅក្នុងសហគមន៍ និងជាបញ្ហារបស់ជាតិទាំងមូល ។ លទ្ធផលបានបង្ហាញថា ការផ្សះផ្សាត្រូវបានមើលឃើញថា ជាដំណើរការមួយដែលមានច្រើនដំណាក់កាល ហើយផ្សារភ្ជាប់ទៅនឹងសញ្ញាណនៃសម្បទា នយោបាយ ភូមិសាស្ត្រ សេដ្ឋកិច្ច និងការរួមបញ្ចូលផ្នែកវប្បធម៌ ។

ប្រហែលជាដោយសារតែមានការលំបាកក្នុងការកំណត់និយមន័យ អ្នកស្រាវជ្រាវ និងបុគ្គលមួយចំនួនបានចោទសួរអំពីទស្សនៈដោយនិយាយថាតើវាចាំបាច់ ឬអាចទៅរួចដែរទេ ។ អ្នកទាំងនេះបានចោទសួរថា តើ“ការដោះស្រាយជាមួយអតីតកាល”ផ្តល់ផលប្រយោជន៍ពិតប្រាកដ ឬថាតើផលប្រយោជន៍មានតម្លៃស្មើនឹង“ភាពលែងខ្វាយខ្វល់” និង “គម្លាតចិត្តសាស្ត្រ”ដែរឬយ៉ាងណា ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនកម្ពុជាភាគច្រើនបំផុតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្ទាបស្ទង់ ជឿថាទម្រង់នៃការផ្សះផ្សាមួយចំនួន គឺមានភាពចាំបាច់ ។

## ការផ្សះផ្សានៅកម្ពុជា

ខណៈពេលដែលប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិ បានសម្រេចជាចុងក្រោយថា តុលាការខ្មែរក្រហមមានលក្ខណៈសមរម្យជាងកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀត ត្រូវបានធ្វើឡើងដើម្បីផ្តល់មធ្យោបាយបន្ថែមចំពោះការផ្សះផ្សា ។ តាមការពិត ដំណើរការនៃការផ្សះផ្សាបានចាប់ផ្តើមធ្វើឡើងតាំងពីឆ្នាំ១៩៧៩ គឺតាំងពីមុនការបង្កើតអង្គជំនុំជម្រះវិសាមញ្ញទៅទៀត ។

នៅក្នុងឆ្នាំ១៩៧៩ មេដឹកនាំខ្មែរក្រហមមួយចំនួនត្រូវបានកាត់ទោស និងកាត់ទោសកំបាំងមុខ ។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍អន្តរជាតិបានថ្កោលទោសចំពោះការកាត់សេចក្តីនោះ ដោយសារតែមិនបានឆ្លើយតបទៅតាមបទដ្ឋានអន្តរជាតិ ។ ការកាត់សេចក្តីនេះមានតួនាទី ជាវេទិកាផ្សព្វផ្សាយព័ត៌មានអំពីសម័យខ្មែរក្រហម ហើយក៏បានបង្ហាញពីការថ្កោលទោសជាសាធារណៈ អំពីអំពើឃោរឃៅដែលបានប្រព្រឹត្តនៅក្នុងសម័យនោះដែរ ។

ក្រោយការកាត់សេចក្តីឆ្នាំ១៩៧៩ រដ្ឋាភិបាលបានបង្កើតគណៈកម្មការស្រាវជ្រាវមួយ ដើម្បីស៊ើបអង្កេតបទឧក្រិដ្ឋកម្មនៅសម័យខ្មែរក្រហម ។ គណៈកម្មការនេះ សហការជាមួយប្រធានភូមិឃុំ និងចៅហ្វាយស្រុកដែលចងក្រងបញ្ជីអ្នកដែលត្រូវបានសម្លាប់ និងទ្រព្យសម្បត្តិដែលត្រូវបានបំផ្លិចបំផ្លាញ ។ អង្គការក្រៅរដ្ឋាភិបាលក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើការផ្សះផ្សានេះដែរ ។ អង្គការដូចជា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បានបើកវេទិកាជាច្រើននៅតាមបណ្តាខេត្ត ដើម្បីផ្តល់ឲ្យជនរងគ្រោះនូវឱកាសចែករំលែករឿងរ៉ាវរបស់ខ្លួន ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីសាលាក្តីខ្មែរក្រហម ។

ទស្សនាវដ្ដី «ស្វែងរកការពិត» ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពផ្សាយ បានសរសេរបទវិចារណកថា ព័ត៌មានផ្នែកច្បាប់ និងព័ត៌មានទូទៅអំពីខ្មែរក្រហម ។ បន្ថែមពីនេះទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់ដល់សាធារណជន នូវឱកាសទទួលបានឯកសារ និងព័ត៌មានដែលមជ្ឈមណ្ឌលនេះបានប្រមែប្រមូលអស់រយៈពេលជាង១០ឆ្នាំមកហើយ ។

បើទោះជាមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់រដ្ឋាភិបាល អង្គជំនុំជម្រះ និងអង្គការក្រៅរដ្ឋាភិបាល ទោះយ៉ាងណាក៏ដោយ ក៏អត្ថន័យ និងផ្លូវឆ្ពោះទៅកាន់ការផ្សះផ្សាបានជិតជាប់ជាមួយបុគ្គលម្នាក់ៗ ។ មនុស្សម្នាក់ៗត្រូវតែសម្រេចចិត្តដោយខ្លួនឯងថា អ្វីទៅដែលនាំឲ្យមានការផ្សះផ្សា តើការផ្សះផ្សាអាចសម្រេចទៅបានតាមវិធីណាខ្លះ ឬតើការផ្សះផ្សាអាចសម្រេចបានដែរឬទេ? ប្រសិនបើមានខ្លឹមសារនៃការពិភាក្សាជាប្រចាំ និងការព្យាយាមកំណត់និយមន័យនៃពាក្យផ្សះផ្សានោះមានន័យថា ការផ្សះផ្សាជាដំណើការមួយតែមិនមែនជាគោលដៅមួយនោះទេ ។ ប្រទេសនីមួយៗដែលជួបប្រទះនូវអំពើហិង្សា និងអំពើឃោរឃៅធ្ងន់ធ្ងរ ត្រូវតែរិះរកមធ្យោបាយស្តាឡើងវិញដោយខ្លួនឯង ចំណែកបុគ្គលម្នាក់ៗដែលរស់ឆ្លងកាត់សម័យកាលនោះ និងក្មេងៗក៏ត្រូវធ្វើដូចគ្នាដែរ ។

### ពន្យល់ពាក្យ

| | | |
|---|---|---|
| សោកនាដកម្ម | ជនភៀសខ្លួន | ការផ្សះផ្សា |
| ពិការភាព | ការគាបសង្កត់ | ការរិះគន់ |
| ឧបសគ្គ | ជំងឺផ្លូវចិត្ត | ការលើកលែងទោស |



ផ្នែកមួយនៃសកម្មភាពរបស់គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មេឃុំកំពុងចូលរួមពិធីបង្សុកូលនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ឆ្នាំ២០០៧ ។ រូបថត ៖ កែវ ដាស៊ីល

## លំនាំបង្រៀន

*ការផ្ដើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្ដើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូពិនិត្យមើលសាឡើងវិញនូវអ្វីដែលសិស្សបានដឹងទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកគ្រូឲ្យសិស្សពិភាក្សាពាក្យសំខាន់ៗ នៅក្នុងសេចក្ដីបញ្ចប់ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សអានដោយយកចិត្តទុកដាក់ និងកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗ ចេញពីសេចក្ដីបញ្ចប់ និងសរសេរព្រឹត្តិការណ៍ទាំងនោះនៅក្នុងសៀវភៅលំហាត់ ។ សិស្សអានអត្ថបទអំពីការផ្សះផ្សាខាងលើ និងសរសេរចម្លើយទៅនឹងសំណួរនៅក្នុងសៀវភៅលំហាត់ ដើម្បីពិនិត្យមើលការយល់ដឹងរបស់សិស្សទៅលើអត្ថបទ ។

*សំយោគ (១៥-២៥នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។

## សំណួរណែនាំ និងចម្លើយ

១) តើជីវិតមនុស្សដែលស្លាប់នៅក្នុងរបបខ្មែរក្រហមមានប៉ុន្មាននាក់? **ជិត២លាននាក់ ។**

២) សូមផ្ដល់អំពីផលប៉ះពាល់យ៉ាងតិច៣ នៃរបបខ្មែរក្រហមមកលើប្រជាជនកម្ពុជា ។

- ***របបនេះបានបន្សល់ទុកនូវស្ត្រីមេម៉ាយ និងក្មេងកំព្រារាប់ម៉ឺននាក់ ។***
- ***ប្រជាជនកម្ពុជារាប់សែននាក់បានរត់ចេញពីប្រទេស ។***
- ***គ្រាប់មីនរាប់លានគ្រាប់ត្រូវបានកប់នៅក្នុងដី ដែលបណ្ដាលឲ្យមនុស្សរាប់ពាន់នាក់ស្លាប់ និងពិការចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ ។***
- ***ប្រជាជនកម្ពុជាជាច្រើនមានបញ្ហាផ្លូវចិត្ត ដោយសារតែបាត់បង់សមាជិកគ្រួសារ ហើយសតិអារម្មណ៍ត្រូវបានបំផ្លាញ ។***
- ***បញ្ញវន្ត មេដឹកនាំសាសនា និងអតីតមន្ត្រីរដ្ឋាភិបាល ត្រូវបានសម្លាប់ដោយបានកាត់បន្ថយសមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការកសាងស្ថាប័នសង្គម និងសេដ្ឋកិច្ច ។***
- ***អ្នកដែលប្រឆាំងនឹងរបបនេះក៏ត្រូវបានសម្លាប់ ។***
- ***សាសនា រូបិយប័ណ្ណ និងប្រពៃណីត្រូវបានបំផ្លាញ ។***
- ***សិទ្ធិ និងតម្រូវការជាមូលដ្ឋានមិនត្រូវបានយកចិត្តទុកដាក់ ហើយទ្រព្យសម្បត្តិឯកជនត្រូវបានរឹបអូស ។***

៣) តើអ្វីខ្លះជាអត្ថន័យរួមនៃពាក្យផ្សះផ្សា? ***អត្ថន័យមួយចំនួនមានដូចជា ដំណើរការព្យាបាលជំងឺផ្លូវចិត្ត ការចងចាំ និងយុត្តិធម៌ ។ ជាងនេះទៅទៀត ប្រជាជនកម្ពុជាភាគច្រើន បានចាត់ទុកគោលដៅនៃការផ្សះផ្សា គឺការសម្រេច បាននូវប្រជាជាតិតែមួយ ដែលមានការរួបរួមគ្នា រុងរឿង និងអភិវឌ្ឍន៍ ជាប្រជាជាតិមួយ ដែលគ្មានអំពើហិង្សា ជម្លោះ និងប្រជាជាតិមួយដែលរស់នៅក្រោមដំបូលច្បាប់ ។ លទ្ធផលនៃការស្ទាបស្ទង់មតិបានបង្ហាញថា ការផ្សះផ្សាត្រូវបានមើលឃើញថា ជាដំណើរការមួយដែលមានច្រើនដំណាក់កាល ហើយដែលផ្សារភ្ជាប់ទៅនឹងការរួមបញ្ចូលឡើងវិញទាំងផ្នែកសម្បទា នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។***

៤) តើអ្វីខ្លះជាបញ្ហា និងការខ្វល់ខ្វាយអំពីការផ្សះផ្សានៅកម្ពុជា? **ដោយសារតែមានការលំបាកក្នុងការកំណត់និយមន័យនៃពាក្យផ្សះផ្សា អ្នកស្រាវជ្រាវ និងបុគ្គលមួយចំនួនបានដាក់ជាសំណួរទៅលើទស្សនាទាននៃពាក្យនេះទៅវិញថា តើដំណើរការនេះចាំបាច់ ឬអាចសម្រេចបានឬទេ? បុគ្គលទាំងអស់នេះបានចោទសួរថា តើការដោះស្រាយបញ្ហានៅក្នុងអតីតកាលនឹងអាចផ្តល់នូវអត្ថប្រយោជន៍ពិតប្រាកដដែរឬទេ និងថាតើផលប្រយោជន៍ ទាំងនោះមានតម្លៃគួរនឹងឲ្យយើងចំណាយទៅលើផលវិបាក និងគម្លាតផ្នែកចិត្តសាស្ត្រដែលអាចនឹងកើតមានដែរឬទេ?**

៥) ចាប់តាំងពីចុងបញ្ចប់នៃរបបខ្មែរក្រហម តើការព្យាយាមអ្វីខ្លះដែលត្រូវបានធ្វើឡើង ដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សានៅកម្ពុជា? **សិស្សអាចរៀបរាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គណៈកម្មការស្រាវជ្រាវដែលបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជា និងការខិតខំប្រឹងប្រែងដែលធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ។**

៦) រាយបញ្ហាដែលកម្ពុជាកំពុងតែជួបប្រទះនាពេលបច្ចុប្បន្នឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ។ **ចម្លើយអាចប្រែប្រួល ។**

៧) ដោយប្រើប្រាស់បញ្ជីដែលជាចម្លើយបានមកពីសំណួរទី៦ សូមគូសវង្វង់នៅលើបញ្ហាទាំងឡាយដែលអ្នកគិតថាមានទំនាក់ទំនងគ្នា (ដោយផ្ទាល់ឬដោយប្រយោល) ទៅនឹងមរតកដែលបន្សល់ទុកពីរយៈកាលនៃរបបខ្មែរក្រហម ។ **ចម្លើយអាចប្រែប្រួល ។**

៨) តើកម្ពុជាអាចដោះស្រាយបញ្ហាទាំងអស់នេះបានដោយរបៀបណា? **ចម្លើយអាចប្រែប្រួល ។**

៩) តើប្រជាជនកម្ពុជាម្នាក់ៗ អាចចូលរួមក្នុងដំណើរការដោះស្រាយបញ្ហានេះបានដោយរបៀបណា? **ចម្លើយអាចប្រែប្រួល ។**

## មេរៀនទី២ ៖ ពិការភាព និង អំពើប្រល័យពូជសាសន៍

### វត្ថុបំណង

១) សិស្សត្រិះរិះពិចារណាឲ្យស៊ីជម្រៅពីបទពិសោធន៍មនុស្សពិការទាំងរូបរាងកាយ និងបញ្ញាស្មារតី ដែលបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សទទួលស្គាល់ និងកោតសរសើរពីភាពរឹងមាំ និងការប្តេជ្ញាចិត្តរបស់មនុស្សពិការនាពេលបច្ចុប្បន្ន ។

៣) សិស្សត្រិះរិះពិចារណាពីការតស៊ូដែលកំពុងតែបន្ត សម្រាប់អ្នកពិការទាំងរូបរាងកាយ និងបញ្ញាស្មារតី ក្នុងពេលបច្ចុប្បន្ន ។

៤) សិស្សពន្យល់ពីភាពលំបាកក្នុងការទទួលបានយុត្តិធម៌ពីសង្គ្រាមរ៉ាំរ៉ៃ ។

**សម្ភារឧបទេស** ៖ *អត្ថបទ "ពិការភាព គថ្លង់ ក្នុងរបបប្រល័យពូជសាសន៍" និងសៀវភៅលំហាត់ ។*

**លំនាំបង្រៀន**

*ការផ្តើមបង្រៀន (៥-១០ នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូពិភាក្សាសំណួរជាលំដាប់លំដោយ ដើម្បីឲ្យសិស្សអានអត្ថបទដូចខាងក្រោម ។

១) តើពិការភាពគឺជាអ្វី? **និយាយជាទូទៅ ពិការភាព គឺជាភាពមិនពេញលក្ខណៈនៃរូបរាងកាយ ខួរក្បាល បញ្ញា ឬការចុះខ្សោយខាងស្មារតី ។ មនុស្សខ្លះកើតមកពិការពីកំណើតតែម្តង ។ ទោះជាយ៉ាងនេះក៏ដោយ មនុស្សខ្លះទៀតពិការដោយសារគ្រោះថ្នាក់អ្វីមួយ ជំងឺ ឬក្នុងកាលៈទេសៈដែលបណ្តាលមកពីជំងឺ ។**

២) តើមានឧទាហរណ៍នៃពិការភាពអ្វីខ្លះ? **ខ្វាក់ គថ្លង់ សរសៃប្រសាទ គឺជាឧទាហរណ៍ដែលកើតមានច្រើនជាងគេនៃពិការភាព ។ មនុស្សដែលធ្លាប់ជួបប្រទះបទពិសោធន៍គ្រោះថ្នាក់ អាចបាត់បង់អវៈយវៈ និងអាចអង្គុយនៅក្នុងកៅអីកង់រហូត ។ ពិការភាពផ្នែកខួរក្បាលមានដូចជា ការភ័យខ្លាចចំពោះបរិយាកាសសង្គម ឬពុំមានលទ្ធភាពទទួលបានព័ត៌មានជាដើម ហើយក៏អាចមានជំងឺដែលបណ្តាលមកពីការប៉ះទង្គិចអារម្មណ៍ផ្ទាល់ខ្លួន និងជំងឺផ្សេងទៀត ដែលធ្វើឲ្យប៉ះពាល់លទ្ធភាពរបស់មនុស្សម្នាក់ក្នុងការមានទំនាក់ទំនងក្នុងសង្គម ឬគ្រប់គ្រងអារម្មណ៍ ឬការគិតរបស់ខ្លួន ។ ទាំងអស់នេះ គឺជាឧទាហរណ៍នៃពិការភាព ។**

*ការបង្រៀន (១៥-៤៥ នាទី)*

សិស្សអាន និងកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗពីអត្ថបទ "ពិការភាព គថ្លង់ នៅក្នុងរបបប្រល័យពូជសាសន៍" រួចពិភាក្សានៅក្នុងក្រុមតូចៗ ដោយឆ្លើយទៅនឹងសំណួរណែនាំ ។

*សំយោគ (១៥-២៥ នាទី)*

គ្រូសួរសំណួរណែនាំទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ដើម្បីវាយតម្លៃ និងសង្ខេបការសិក្សារបស់សិស្ស ។



កែវ កុលធីតា ឯកសក្ក័

## ពិការភាព គថ្លង់ នៅក្នុងរបបប្រល័យពូជសាសន៍

ក្នុងនាមជាសាក្សីមួយរូបដែលបានឆ្លងកាត់ភាពព្រៃផ្សៃនៃរបបខ្មែរក្រហម និងក្នុងនាមជាអ្នកស្រាវជ្រាវម្នាក់ ដែលបានចំណាយពេលវេលាអស់ជាច្រើនឆ្នាំ ដើម្បីសិក្សាស្រាវជ្រាវ និងចងក្រងឯកសារអំពីរឿងរ៉ាវរបស់បុគ្គលដែលបានឆ្លងកាត់ទទួលរងគ្រោះ និងស្លាប់នៅក្នុងរបបខ្មែរក្រហម ខ្ញុំតែងតែគិតខ្លួនឯងថា ខ្ញុំយល់ពីទិដ្ឋភាពជាច្រើននៃប្រវត្តិសាស្ត្រខ្មែរក្រហម ។ ជាការពិត ខ្ញុំបានរៀនសូត្ររឿងរ៉ាវអំពីភាពនៃមនុស្សជាតិគ្រប់បែបយ៉ាងទាំងអស់របស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបខ្មែរក្រហម ។ គ្មានពេលណាមួយដែលខ្ញុំមិនស្ញើចសរសើរដល់ស្មារតីដ៏អង់អាច ភាពរឹងមាំដ៏អស្ចារ្យរបស់ប្រជាជនកម្ពុជានោះទេ ។ ក៏ប៉ុន្តែ ពេលខ្លះខ្ញុំបានជួបរឿងរ៉ាវផ្សេងៗទៀត ហើយរឿងទាំងនោះធ្វើឲ្យខ្ញុំរឹតតែចង់ដឹង ចង់ពុកាន់តែខ្លាំងថែមទៀតនូវអ្វីដែលខ្ញុំធ្លាប់បានដឹងរួចមកហើយ ។

បងស្រីរបស់ខ្ញុំឈ្មោះ កែវ កុលធីតា ឯកសក្ក័ កើតឆ្នាំ១៩៥៩ ។ គាត់មានពិការភាពជាមនុស្សគ តាំងពីកំណើត ។ គាត់គឺជាបងស្រីពៅក្នុងចំណោមបងស្រីទាំងប្រាំនាក់របស់ខ្ញុំ ។ ដោយសារតែគាត់ជាមនុស្សគ អ្នកផ្សេងទៀតមិនសូវជាមកនិយាយលេងសំណេះសំណាលជាមួយនឹងគាត់នោះទេ ។ គាត់ក៏មិនមានសមត្ថភាពទំនាក់ទំនងជាមួយអ្នករាល់គ្នាដែរ លើកលែងតែអ្នកដែលចេះភាសាកាយវិការសម្រាប់មនុស្សគតែប៉ុណ្ណោះ ។ ហេតុដូច្នេះ ក្នុងសកម្មភាពទំនាក់ទំនងប្រចាំថ្ងៃ គាត់ធ្វើកិច្ចការអ្វីៗដោយខ្លួនឯងទាំងស្រុង ហើយមានតែមនុស្សមួយចំនួនប៉ុណ្ណោះ ដែលមានការអត់ធ្មត់ និងចង់ស្គាល់គាត់ ។ ម្តាយរបស់ខ្ញុំឈ្មោះ កែវ ណាន ដែលសព្វថ្ងៃមានវ័យ៨៥ឆ្នាំ តែងតែមើលថែទាំបងស្រីខ្ញុំយ៉ាងយកចិត្តទុកដាក់ ។ ដោយសារតែបងស្រីខ្ញុំមានអាយុខុសគ្នាតែពីរឆ្នាំ ខ្ញុំនិងគាត់ហាក់បីដូចជាមិត្តស្និតស្នាលដូច្នេះដែរ ។ ក៏ប៉ុន្តែនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច យើងទាំងពីរនាក់ក៏ព្រាត់ប្រាស់គ្នា ហើយយើងមិនដែលបានជួបមុខគ្នាទេ រហូតដល់របបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ។

នៅពេលដែលខ្ញុំ និងបងស្រីខ្ញុំជួបគ្នាឡើងវិញក្រោយរបបខ្មែរក្រហម យើងទាំងពីរនាក់ភ្លេចភាសាកាយវិការ ដែលយើងធ្លាប់ប្រើសម្រាប់ទំនាក់ទំនងគ្នាកាលពីមុនរបបខ្មែរក្រហម ហើយអស់រយៈពេលជាច្រើនឆ្នាំ យើងមិនសូវមានទំនាក់ទំនងជាមួយគ្នាច្រើនទេ ដោយសារតែខ្ញុំបានទៅរស់នៅសហរដ្ឋអាមេរិក ។ ខ្ញុំដឹងថា អស់រយៈពេលជាច្រើនឆ្នាំ ដែលយើងមិនសូវបានជួបមុខគ្នា បងស្រីខ្ញុំតែងមានវិធីសាស្ត្រផ្សេងៗ ដើម្បីប្រាប់អ្នកដទៃអំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ ។ ក្រោយរបបខ្មែរក្រហម គាត់បានបង្រៀនខ្លួនឯងឲ្យចេះគូររូប គូរគំនូរនៅលើផ្ទាំងក្រណាត់ និងក្រដាស ដើម្បីប្រាប់អ្នកដទៃអំពីអារម្មណ៍របស់គាត់ ។

ថ្មីៗនេះ គាត់ត្រូវបានរកឃើញថា មានជំងឺមហារីកដំណាក់កាលចុងក្រោយ ។ ដំណឹងនេះធ្វើឲ្យខ្ញុំចំណាយពេលវេលាច្រើននៅក្បែរគាត់ ។ ខ្ញុំ និងបងស្រីខ្ញុំបានទៅមើលផ្ទះចាស់នៅម៉ុំទួលគោក ដែលគ្រួសាររបស់យើងធ្លាប់រស់នៅកាលពីមុនរបបខ្មែរក្រហម និងបានរៀបរាប់ពីប្រវត្តិដើមអំពីការស្លាប់ និងការបាត់ខ្លួនសមាជិកគ្រួសារជាទីស្រលាញ់របស់យើង ។ ចំណុចមួយក្នុងពេលដែលយើងកំពុងនិយាយគ្នា ធ្វើឲ្យគាត់នឹកឃើញដល់បទពិសោធន៍របស់គាត់កាលពីរបបខ្មែរក្រហម ។

នៅក្នុងរបបខ្មែរក្រហម បងស្រីខ្ញុំធ្វើការនៅសហករណ៍ភូមិត្រពាំងវែង ដាំដំឡូង និងកាប់ឆ្ការព្រៃ ក្រោមការត្រួតត្រារបស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីដឹកនាំដោយ តាម៉ុក និង យាយចែម ។ តាម៉ុក គឺជាអតីតមេបញ្ជាការយោធាម្នាក់របស់កងយោធាខ្មែរក្រហម ។ មេភូមិមកពីភូមិភាគនិរតី គឺជាស្ត្រីវ័យក្មេងចំនួនបីរូប គឺ សមមិត្តនារី ម៉ន, សមមិត្តនារី ហាន និង សមមិត្តនារី អូន ។ កម្មាភិបាលទាំងបីនេះមានអាយុប្រហាក់ប្រហែលនឹងបងស្រីខ្ញុំដែរ ។ ដូចអ្នកផ្សេងទៀតដែរ បងស្រីរបស់ខ្ញុំខិតខំត្រដររស់នៅដោយស្មារតីសម្បជញ្ញៈរបស់គាត់ ។ នៅពេលដែលគាត់ឃ្លានខ្លាំង គាត់បានស្វែងរកឫសឈើ ស្លឹកឈើ និងសត្វល្អិតនានា ដើម្បីហូបជាអាហារ ។ ថ្ងៃមួយគាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់ ។ ក្នុងរបបខ្មែរក្រហម អង្គការគឺជាម្ចាស់កម្មសិទ្ធិលើអ្វីគ្រប់យ៉ាងទាំងអស់ មិនថាដំណាំបន្លែ ផ្លែឈើទេ សូម្បីតែសត្វល្អិតនិងស្លឹកឈើក៏ជាកម្មសិទ្ធិរបស់អង្គការដែរ ។ កម្មាភិបាលខ្មែរក្រហមបានឃើញបងស្រីខ្ញុំ ហូបឫសដំឡូងជ្វាដែលគាត់ជីកបាន ហើយបានចាប់ខ្លួនគាត់ភ្លាមដោយចងដៃគាត់ទៅក្រោយ ។ កម្មាភិបាលទាំងនោះជេរស្តីគាត់ ហើយដោះលែងគាត់វិញ ។

ខ្ញុំ និងបងស្រីខ្ញុំបានសន្ទនាជាមួយគ្នាដោយភាសាកាយវិការអស់រយៈពេលជាច្រើនម៉ោង អំពីបទពិសោធន៍របស់គាត់ ។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ គាត់ចាំថា កាលនោះខ្ញុំនៅផ្ទះតែម្នាក់ឯង រីឯអ្នកដទៃទៀតបានភៀសខ្លួនទៅកន្លែងផ្សេងបាត់អស់ទៅហើយ ។ គាត់បានប្រាប់ខ្ញុំទៀតថា ក្នុងរបបខ្មែរក្រហមគាត់ចង់ដឹងរាល់ថ្ងៃ ថាតើមានរឿងអ្វីកើតឡើងចំពោះខ្ញុំ ព្រោះពេលនោះខ្ញុំ និងគាត់មិនបាននៅជាមួយគ្នាទេ ។ គាត់បានរំឭកអំពីការស្លាប់ដោយខ្លោចផ្សារបស់កូនស្រីរបស់បងស្រីយើងម្នាក់ឈ្មោះ គាន់ កែវកេតនា កើតក្នុងឆ្នាំ១៩៧៥ ការស្លាប់របស់ឪពុកយើង និងការបាត់ខ្លួនសមាជិកគ្រួសារដទៃទៀតរបស់យើង ។ នៅពេលដែលខ្ញុំដឹងពីប្រវត្តិរឿងរ៉ាវរបស់គាត់ ខ្ញុំមានអារម្មណ៍ក្តុកក្តួល និងរំជួលចិត្តយ៉ាងខ្លាំង ។ ខ្ញុំគិតថា ខ្ញុំជាមនុស្សមានសំណាងណាស់ ដែលបានដឹងពីប្រវត្តិរបស់គាត់ ហើយពេលនោះដែរខ្ញុំក៏មានអារម្មណ៍ទុក្ខសោក និងមានអារម្មណ៍ថា បានធ្វើខុសយ៉ាងខ្លាំងចំពោះគាត់ ។

ដោយសារតែគាត់គឺជាមនុស្សគ មិនសូវមាននរណាមកសួរនាំគាត់អំពីបទពិសោធន៍គាត់កាលពីរបបខ្មែរក្រហមទេ ។ អស់រយៈពេលជាងសាមសិបបួនឆ្នាំក្រោយរបបខ្មែរក្រហម ខ្ញុំមិនទាំងដឹងអំពីរឿងពិតរបស់គាត់កាលពីរបបខ្មែរក្រហមផង ។ នៅពេលដែលខ្ញុំសន្ទនាជាមួយគាត់អំពីរឿងរ៉ាវជីវិតរបស់គាត់ ដែលគាត់បានទទួលរងកាលពីរបបខ្មែរក្រហម ធ្វើឲ្យខ្ញុំងឿងឆ្ងល់ថា តើបទពិសោធន៍របស់គាត់មានលក្ខណៈខុសពីអ្នកផ្សេងយ៉ាងដូចម្តេច ព្រោះគាត់ជាមនុស្សគ និងឆ្ងល់ថា តើគាត់មានកម្លាំងចិត្ត និងប្រាជ្ញាស្មារតីអ្វីខ្លះដើម្បីធ្វើឲ្យគាត់អាចរស់រានមានជីវិតពីរបបខ្មែរក្រហមបាន? ខ្ញុំក៏មានការងឿងឆ្ងល់ដែរថា តើមានមនុស្សពិការ និងមានវិបត្តិផ្លូវចិត្តប៉ុន្មាននាក់ទៀត ដែលទទួលរងទុក្ខតែម្នាក់ឯងបែបនេះ? តើមានរឿងរ៉ាវប៉ុន្មានទៀតដែលត្រូវបានបំភ្លេចចោល មើលរំលង ហើយមិនដែលដឹងរឿងរ៉ាវរបស់អ្នកទាំងនោះទាល់តែសោះ?

សោកនាដកម្មដែលមិនអាចជៀសផុតនៃរបបឃោរឃៅទ្រង់ទ្រាយធំទាំងឡាយ គឺជាការបាត់បង់ប្រវត្តិសាស្ត្រ ។ ក៏ប៉ុន្តែ ក្រោយពីបានរៀនសូត្រ និងសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំយល់ឃើញថា រឿងរ៉ាវរបស់បងស្រីខ្ញុំគឺជាសក្ខីកម្មមួយឆ្លុះបញ្ចាំងឲ្យឃើញថា តើកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអម្បាលមាណដើម្បីទាមទារយុត្តិធម៌នៅមានកម្រិតខ្វះខាតប៉ុណ្ណា? បងស្រីខ្ញុំមិនទាំងដឹងថាមានតុលាការមួយដើម្បីស្វែងរកយុត្តិធម៌សម្រាប់ប្រទេសកម្ពុជាផង ។

រឿងរ៉ាវរបស់បងស្រីខ្ញុំ ធ្វើឲ្យខ្ញុំពិចារណាសាជាថ្មីនូវអ្វីដែលខ្ញុំធ្លាប់អះអាងថា ខ្ញុំដឹងច្រើនពីរបបខ្មែរក្រហម ហើយខ្ញុំមានជំនឿថា រឿងរ៉ាវរបស់គាត់គឺជាការលំបាកមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ។ នៅប្រទេសកម្ពុជាយើងមិនអាចនិយាយអំពីប្រជាធិបតេយ្យ យុត្តិធម៌ ឬសិទ្ធិមនុស្ស ដោយគ្មានគិតពី

ប្រវត្តិសាស្ត្រនោះទេ ។ ដើម្បីនិយាយអំពីប្រធានបទអ្វីមួយក្នុងចំណោមប្រធានបទទាំងនោះ គឺតម្រូវឲ្យមានការបកស្រាយពីបញ្ហាមួយផ្សេងទៀតដោយជៀសមិនផុត ។

សាច់រឿង និងបទពិសោធន៍របស់បងស្រីខ្ញុំ គឺជាសាច់រឿងមួយផ្នែកតូចនៃរបបខ្មែរក្រហម ហើយក៏ជាសាច់រឿងផ្ទាល់ខ្លួនសម្រាប់ខ្ញុំដែរ ។ ដូចគ្នាទៅនឹងអ្នកមានពិការភាពពីកំណើតផ្សេងទៀតដែរ ដែលមិនមានលទ្ធភាពក្នុងការនិយាយចេញមក ។ រឿងរ៉ាវរបស់បងស្រីខ្ញុំ បានបន្តជាខបសត្តដល់យើង ដើម្បីវាយតម្លៃអំពីនិយមន័យនៃពាក្យយុត្តិធម៌ និងដើម្បីវាយតម្លៃ ថាតើយើងបានធ្វើអ្វីគ្រប់យ៉ាងអស់ហើយ ឬនៅ សម្រាប់អ្នកដែលមិនមានសំឡេងដើម្បីប្រាប់យើងនោះ?

### សំណួរណែនាំ និងចម្លើយ

១) តើ កែវ កុលធីតា ឯកស័ក្ក ក្លាយជាមនុស្សគថ្លង់ ដោយរបៀបណា? **នាងគថ្លង់ពីកំណើត ។**

២) ពេលដែលគាត់នៅក្មេង តើអ្នកផ្សេងទៀតធ្វើមកលើគាត់ខុសពីគេឯង ដោយសារតែពិការភាពរបស់គាត់ដែរ ឬទេ? តើអ្នកទាំងនោះធ្វើមកលើគាត់ខុសពីគេឯងយ៉ាងដូចម្តេច? **ជាមនុស្សគថ្លង់ អ្នកផ្សេងទៀតមិនសូវជាមកនិយាយលេង និងសំណេះសំណាលជាមួយគាត់ឡើយ ហើយគាត់ត្រូវរៀនរស់ដោយខ្លួនឯង ។ ម្យ៉ាងវិញទៀត ម្តាយរបស់គាត់តែងតែមើលថែទាំគាត់យ៉ាងយកចិត្តទុកដាក់បំផុត ។**

៣) ហេតុអ្វីបានជាអ្នកគិតថា អ្នកផ្សេងទៀតមិនសូវមកនិយាយលេងជាមួយគាត់? **ចម្លើយអាចប្រែប្រួល ប៉ុន្តែមានមូលហេតុច្រើនដែលត្រូវឆ្លើយ ។ ទី១) អ្នកផ្សេងអាចមិនដឹងពីរបៀបដែលអាចទំនាក់ទំនងជាមួយគាត់ និងហាក់ដូចជាមិនសូវចង់ចំណាយពេលវេលាច្រើនជាមួយគាត់ ។ ទី២) អ្នកផ្សេងទៀតអាចមានអារម្មណ៍ឆ្គាំឆ្គងក្នុងការព្យាយាមនិយាយជាមួយគាត់ ហើយភាពឆ្គាំឆ្គងនេះធ្វើឲ្យអ្នកទាំងនោះមានអារម្មណ៍ពិបាក ។ មនុស្សយើងអាចមិនយល់ថា ហេតុអ្វីបានជាគាត់គថ្លង់ ។ ជួនកាលមនុស្សយើងជឿថា ប្រសិនបើនរណាម្នាក់មាន ពិការភាពនោះគឺជាកំហុស ឬបណ្តាលមកពីខ្លួនបានប្រព្រឹត្តអ្វីខុស ។**

៤) តើ កែវ កុលធីតា ឯកស័ក្ក គេចផុតពីសេចក្តីស្លាប់ពីរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងដូចម្តេច? **គាត់ស្ទើរស្លាប់ដោយសារភាពស្រេកឃ្លាន ហើយគាត់បានស្វែងរកឫសឈើ ស្លឹកឈើ និងសត្វល្អិតនានាដើម្បីហូបជាអាហារ ។**

៥) តើអ្នកគិតយ៉ាងដូចម្តេចចំពោះបទពិសោធន៍របស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពិបាកជាងមនុស្សផ្សេងទៀតដែលពុំមានពិការភាព? **នៅពេលដែលការអត់អាហារ ធ្វើការដោយបង្ខំ និងបរិយាកាសដ៏គួរឲ្យខ្លាចជះឥទ្ធិពលដល់ប្រជាជនកម្ពុជារាប់លាននាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កែវ កុលធីតា ឯកស័ក្ក បានជម្នះភាពលំបាកក្នុងការធ្វើទំនាក់ទំនង ។ លើសពីនេះទៀត ពិការភាពដែលត្រូវបានមើលឃើញយ៉ាងច្បាស់ពីអ្នកដទៃ បានធ្វើឲ្យគាត់ស្ថិតក្នុងសភាពគ្រោះថ្នាក់នៃការរើសអើងកាន់តែខ្ពស់ឡើង ។**

៦) តើគាត់បង្ហាញពីអារម្មណ៍របស់គាត់ដែលជាមនុស្សគថ្លង់ម្នាក់យ៉ាងដូចម្តេច ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ? **គាត់បានបង្រៀនខ្លួនឯងឲ្យចេះគូររូប និងគូរគំនូរ ។**

៧) ហេតុអ្វីបានជាអ្នកគិតថា អ្នកផ្សេងទៀតមិនដែលសួរនាំគាត់អំពីប្រវត្តិរឿងរ៉ាវរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? **ចម្លើយអាចប្រែប្រួល ប៉ុន្តែមានមូលហេតុច្រើនក្នុងការឆ្លើយសំណួរនេះ ។ ទីមួយ អ្នកផ្សេងទៀតអាចមិនសួរនាំគាត់ ពីព្រោះជារឿងដែលលំបាកបំផុតក្នុងការធ្វើទំនាក់ទំនងជាមួយគាត់ ។ អ្នកផ្សេងទៀត**

**អាចសន្មតដែរថា មកពីគាត់មិនអាចធ្វើទំនាក់ទំនងបានល្អ ហើយគាត់ពុំមានរឿងរ៉ាវដែលត្រូវនិយាយប្រាប់ ។ ចុងបញ្ចប់ គាត់អាចមិនបានដឹងពីអ្វីដែលត្រូវនិយាយ ហើយគាត់អាចគិតថា អ្នកដទៃមិនយកចិត្តទុកដាក់អំពីរឿងរ៉ាវរបស់គាត់ ។**

៨) *ហេតុអ្វីបានជាអ្នកនិពន្ធគិតថា រឿងរ៉ាវរបស់បងស្រីគាត់គឺជាសក្ខីកម្មមួយដែលឆ្លុះបញ្ចាំងឲ្យឃើញពីភាពខ្វះខាតក្នុងការទាមទារយុត្តិធម៌?* **ចម្លើយអាចប្រែប្រួល ហើយពុំមានចម្លើយខុស ឬត្រូវដែរ ។ ជាទូទៅយើងអាចនិយាយបានថា អ្នកនិពន្ធចាត់ទុកប្រវត្តិរឿងរ៉ាវរបស់បងស្រីគាត់ជាឧទាហរណ៍មួយនៃភាពអន្តរាយដែលបានកើតឡើងនៅក្នុងសង្គមកម្ពុជា ហើយតើវាពិបាករបៀបម៉េចសម្រាប់ប្រទេសកម្ពុជា ក្នុងការស្វែងរកការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌នាពេលបច្ចុប្បន្ននេះ ។ គ្មានចំនួនទឹកប្រាក់ ឬការដាក់ទណ្ឌកម្ម (ឬយុត្តិធម៌) ណាមួយ ដែលអាចប៉ះប៉ូវឲ្យការបែកបាក់នៃគ្រួសារ ការបាត់បង់ និងរបួសផ្លូវចិត្តដែលបានកើតមាននៅក្នុងប្រទេសកម្ពុជាបានឡើយ ។**

## មេរៀនទី៣ ៖ កំណាព្យដើម្បីរំឭកគុណដល់ព្រលឹងជាតិខ្មែរ



*ជនជាតិខ្មែរអ៊ីស្លាមបួងសួងដល់ជនរងគ្រោះនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ខែកុម្ភៈ ឆ្នាំ២០០៧ ។ រូបថត ៖ កែវ ដាស៊ីល*

### វត្ថុបំណង

១) សិស្សពណ៌នាអំពីភាពឃោរឃៅដែលមិនគួរឲ្យជឿនៃរបបខ្មែរក្រហម ។

២) សិស្សពន្យល់អំពីការតស៊ូ និងជំងឺផ្លូវចិត្តដែលជនរងគ្រោះជួបប្រទះ បន្ទាប់ពីថ្ងៃដួលរលំនៃរបបខ្មែរក្រហម ។

៣) សិស្សកោតសរសើរចំពោះកម្លាំង និងការប្តេជ្ញាចិត្តរបស់អ្នកនៅរស់រានមានជីវិតក្នុងការកសាងជីវិតសាជាថ្មី ។

៤) សិស្សកោតសរសើរពីវីរភាព និងសប្បុរសធម៌របស់អ្នកដែលបានព្យាយាមជួយសង្គ្រោះ ។

៥) សិស្សពន្យល់អំពីតម្រូវការនៃការផ្សះផ្សា សន្តិភាព យុត្តិធម៌ និងសេចក្តីសង្ឃឹម ។

**សម្ភារឧបទេស ៖** ក្រដាស ខ្មៅដៃ ប៊ិចពណ៌ ការ៍ កន្ត្រៃ និងសៀវភៅលំហាត់ ។

**លំនាំបង្រៀន**

*ការផ្ដើមបង្រៀន (៥ - ១០ នាទី)*

មុនចាប់ផ្ដើមការបង្រៀន គ្រូបង្ហាញពីវត្ថុបំណងមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូពិភាក្សាជាមួយសិស្សអំពីបច្ចុប្បន្នកាល និងអនាគតកាលនៃប្រទេសកម្ពុជា ។ បន្ទាប់មកគ្រូសរសេរពាក្យមួយចំនួននៅលើក្ដារខៀនដើម្បីពិភាក្សា ៖ ការរស់រានមានជីវិត សន្តិភាព ការផ្សះផ្សា ការរើបឡើងវិញ យុត្តិធម៌ កម្លាំង ការប្ដេជ្ញាចិត្ត ការអត់ធន់ ការពិត សេចក្ដីក្លាហាន និងសេចក្ដីសង្ឃឹម ។ គ្រូឲ្យសិស្សស្វែងយល់ពីអត្ថន័យ និងសារសំខាន់នៃពាក្យទាំងនេះ ។



ពីឆ្វេងទៅស្ដាំ ៖ អ្នករួចរស់ជីវិតពីមន្ទីរស-២១ ៖ ជុំ ម៉ី, រុយ នាគង់, អៀម ចាន់, ហេង ណាត, ប៊ូ ម៉េង, ផាន ថនចាន់ និង អ៊ឹង ប៉ិច ។ ក្នុងចំណោមអ្នកទាំងនេះ មានតែ ជុំ ម៉ី និង ប៊ូ ម៉េង ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

*ការបង្រៀន (១៥ - ៤៥ នាទី)*

សិស្សមើលឃើញជាក់ស្ដែងពីបច្ចុប្បន្នកាល និងអនាគតកាលសម្រាប់ប្រជាជនកម្ពុជា ហើយតែងកំណាព្យជានិមិត្តរូបសម្រាប់ការរួចរស់ជីវិត សន្តិភាព ការផ្សះផ្សា ការរើបឡើងវិញ យុត្តិធម៌ កម្លាំង ការប្ដេជ្ញាចិត្ត ការអត់ធន់ ការពិត សេចក្ដីក្លាហាន និងសេចក្ដីសង្ឃឹម ។ បន្ទាប់ពីបញ្ចប់ការតែងកំណាព្យ សិស្សបញ្ចូលរូបភាពបន្ថែមដើម្បីធ្វើឲ្យកំណាព្យកាន់តែមានភាពរស់រវើក ។

*សំយោគ (១៥ - ២៥ នាទី)*

សិស្សចែករំលែកកំណាព្យរបស់ខ្លួនជាមួយសិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។ គ្រូប្រមូលកំណាព្យទាំងអស់ ដើម្បីដាក់បង្ហាញ ។



ព្រះពុទ្ធរូបបាក់បែក និងវត្ថុសិល្បៈដ៏មានតម្លៃជាច្រើនទៀតរបស់កម្ពុជា ទទួលរងនូវការបំផ្លិចបំផ្លាញ គាស់លួច ដើម្បីជួញដូរក្នុងទីផ្សារងងឹត ។
រូបថត ៖ អ៊ុំ មករា

## មេរៀនទី៤ ៖ តារាង *K-W-L* (ខេ-ដាប់បែលយូ-អិល)

### វត្ថុបំណង

១) សិស្សសង្ខេបពីអ្វីដែលខ្លួនបានសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សកំណត់នូវព្រឹត្តិការណ៍សំខាន់ៗអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សសហការគ្នា និងធ្វើការជាក្រុម ។

៤) សិស្សវាយតម្លៃការសិក្សារបស់ខ្លួនអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅកត់ត្រា តារាង K-W-L នៅក្នុងសៀវភៅលំហាត់ ។

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ បន្ទាប់មកគ្រូបែងចែកសិស្សជា ៤ឬ៥ក្រុម ។ សមាជិកក្រុមនីមួយៗនៅក្នុងក្រុមសហការ និងទទួលតួនាទីមួយដូចជា ៖

១) អ្នកសម្របសម្រួល

២) អ្នកកត់ត្រា

៣) អ្នកគ្រប់គ្រងពេលវេលា

៤) អ្នកឡើងពន្យល់

៥) អ្នកជំរុញលើកទឹកចិត្ត

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សធ្វើការនៅក្នុងក្រុមដើម្បីបំពេញផ្នែក "អ្វីដែលខ្លួនបានរៀន" នៅក្នុងតារាង K-W-L តើ ប៉ុល ពត ជាអ្នកណា? ហើយគ្រូស្វែងយល់អំពីចំណេះដឹងរបស់សិស្ស ។ (សូមមើលសៀវភៅប្រវត្តិសាស្ត្រជំពូក២ ចំណុចទី១) ។

*សំយោគ (១៥-២៥នាទី)*

តំណាងក្រុមសិស្សនីមួយៗ បង្ហាញពីអ្វីដែលក្រុមខ្លួនបានសិក្សា ។ សកម្មភាពនេះនឹងផ្តល់នូវលទ្ធផលរួមនៃការសិក្សារបស់សិស្ស ។

## មេរៀនទី៥ ៖ ពិព័រណ៍សារមន្ទីរនៅក្នុងថ្នាក់រៀន

### វត្ថុបំណង

១) សិស្សស្វែងយល់ពីមុខងារជាមូលដ្ឋាននៃពិព័រណ៍សារមន្ទីរ ។

២) សិស្សឆ្លុះបញ្ចាំងពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួន តាមរយៈការតាំងពិព័រណ៍សារមន្ទីរនៅក្នុងថ្នាក់រៀន ។

៣) សិស្សបកស្រាយពីការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួន តាមរយៈការបង្កើតពិព័រណ៍សារមន្ទីរ ។

៤) សិស្សពន្យល់ពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួន តាមរយៈការឡើងពន្យល់នៅក្នុងថ្នាក់ស្តីពីពិព័រណ៍សារមន្ទីរ ។

**សម្ភារឧបទេស** ៖ សៀវភៅប្រវត្តិសាស្ត្រ សៀវភៅកត់ត្រា និងសម្ភារផ្សេងទៀតសម្រាប់ការបង្កើតពិព័រណ៍តូចមួយ ។

គ្រូគួរប្រើប្រាស់សម្ភារដែលអាចប្រើប្រាស់បាន សម្រាប់ជួយដល់សិស្សក្នុងការបង្កើតការតាំងពិព័រណ៍តូចមួយ ។ ពិព័រណ៍នេះមិនតម្រូវឲ្យមានសម្ភារច្រើនពេកទេ ក្រៅពីការតែងកំណាព្យ ចម្រៀង រូបភាព គំនូរ ឬការស្រាយបំភ្លឺពីការសិក្សាផ្សេងទៀតរបស់សិស្សម្នាក់ៗ ។ សរុបសេចក្តីមក សិស្សគួរចេះច្នៃប្រឌិតក្នុងការបង្កើតពិព័រណ៍នេះ និងមិនត្រូវមានអារម្មណ៍រារែកដោយសារភាពខ្វះខាតសម្ភារឡើយ ។

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥-១០នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ បន្ទាប់មក គ្រូពន្យល់ពីគោលបំណងទូទៅនៃសារមន្ទីរ និងវិធីក្នុងការបង្កើត ព្រមទាំងការថែរក្សាសារមន្ទីរ ។ សំណួរ និងចម្លើយខាងក្រោមនេះនឹងជួយដល់ការពិភាក្សាក្នុងការបង្កើតសារមន្ទីរ ៖

១) តើប្រភេទព័ត៌មាន ឬសម្ភារដែលអាចមើលឃើញនៅក្នុងសារមន្ទីរមានអ្វីខ្លះ? ***សារមន្ទីរអាចមានផ្ទុកព័ត៌មាន ឬ សម្ភារដែលត្រូវបានចាត់ទុកថា ជាវត្ថុមានសារសំខាន់សម្រាប់សង្គម (ឬសហគមន៍) ដូចជាកិច្ចការសិល្បៈ ឯកសារ និងការប្រមូលផ្តុំវត្ថុបុរាណធម្មជាតិ និងបរិស្ថានផ្សេងទៀត ។ សារមន្ទីរក៏អាចមានផ្ទុកព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងទម្រង់ផ្សេងៗគ្នាដែរ រាប់តាំងពីបទភ្លេងរហូតដល់សំណេរ ពីរូបភាពរហូតដល់រូបសំណាកបុរាណ និងការបង្កើតឡើងនៃព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ឬធម្មជាតិ ។***


ភាពស្រឡាញ់ពេញចិត្ត
និងការលើកកម្ពស់
ព័ត៌មានស្តីអំពីវប្បធម៌
និងធម្មជាតិរបស់
សារមន្ទីរ
ការបកស្រាយ
និងការសិក្សា
ការថែរក្សា
និងការការពារ


ឆ្លុះបញ្ចាំងអំពីតម្លៃ
ជំនឿ ឥរិយាបថ
និងទម្លាប់
ពិភាក្សាអំពីអត្ថន័យ
នៃព័ត៌មាន
និងការតាំងពិព័រណ៍
បកស្រាយអំពីព័ត៌មាន
ឬតាំងពិព័រណ៍
បទពិសោធន៍សារមន្ទីរ
វាយតម្លៃ
អំពីព័ត៌មាន
ឬតាំងពិព័រណ៍
ប្រៀបធៀប
និងបញ្ហាញពីភាព
ខុសគ្នានៃព័ត៌មានថ្មី
ប្រដូចព័ត៌មានថ្មី
តាមរយៈ ញាណ
របស់យើង
ធ្វើឲ្យពេញចិត្ត
គោរព
និងភ្ជាប់ទំនាក់ទំនងគ្នា

២) តើគោលបំណងនៃការផ្ទុកព័ត៌មាន និងសម្ភារទាំងនេះគឺដើម្បីអ្វី? **គ្រូគួរឲ្យសិស្សបង្កើតតារាងបំផុសគំនិតមួយសម្រាប់កិច្ចការខាងក្រោម (ពិនិត្យមើលតារាងខាងក្រោម) ៖ សារមន្ទីរទាំងឡាយថែរក្សា បកស្រាយ និងលើកស្ទួយកេរតំណែលវប្បធម៌ និងធម្មជាតិនៃមនុស្ស ។ កិច្ចការទាំងអស់នេះធានាការបន្តការចងចាំប្រវត្តិសាស្ត្រ ក៏ដូចជាជួយដល់ការធ្វើឲ្យចម្រើនជឿនលឿនទៅមុខនៃចំណេះដឹង និងការស្រាវជ្រាវ ។ ការងារនេះជួយសង្គមឲ្យមានការគោរពដល់ការចែករំលែករបស់មនុស្សជំនាន់មុន ក៏ដូចជាការពិចារណាពីកំហុស ការធ្វើអំពើអាក្រក់ និងបញ្ហានានាកាលពីអតីតកាល ។ កិច្ចការទាំងនេះ ក៏អាចផ្ដល់នូវការមើលឃើញមួយជ្រុងក្នុងពេលបច្ចុប្បន្ន ដើម្បីជាកញ្ចក់ឆ្លុះបញ្ចាំងទៅថ្ងៃអនាគត ។**

៣) តើមនុស្សធ្វើកិច្ចការអ្វីខ្លះនៅក្នុងសារមន្ទីរ? **គ្រូគួរឲ្យសិស្សបង្កើតតារាងបំផុសគំនិតមួយ ។ កំណត់ចំណាំ ៖ តារាងនេះគឺគ្រាន់តែជាបញ្ជីនៃការផ្ដល់យោបល់ប៉ុណ្ណោះ ហើយក៏មិនមែនជាតារាងដែលផ្ដល់ចម្លើយដ៏លម្អិតដែរ ។**

### ការបង្រៀន (១៥-៤៥នាទី)

សិស្សត្រូវបែងចែកជាក្រុម ដែលក្រុមនិមួយៗមានសិស្សពី២ទៅ៣នាក់ ។ សិស្សក្នុងក្រុមនីមួយៗធ្វើការទាំងអស់គ្នាដើម្បីធ្វើគម្រោងផែនការ រចនា និងឡើងពន្យល់ពីពិព័រណ៍ទៅលើសំណួរ ឬប្រធានបទនៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

សិស្សគួរត្រូវបានលើកទឹកចិត្តឲ្យធ្វើការជាលក្ខណៈឯករាជ្យដោយគ្មានការដឹកនាំផ្ទាល់ពីគ្រូ ។ ទោះជាយ៉ាងនេះក៏ដោយគ្រូត្រូវតែវាយតម្លៃចំពោះការយល់ដឹង ក៏ដូចជាភាពជឿនលឿនរបស់សិស្សក្នុងការធ្វើកិច្ចការនេះ ។ ដូច្នេះសិស្សត្រូវស្ថិតនៅក្រោមការតាមដានរបស់គ្រូជាដរាប ។ បញ្ជីជាជំហានៗខាងក្រោមនេះ គឺជាវិធីសាស្ត្រមួយចំនួនសម្រាប់ជួយដល់គ្រូក្នុងការរៀបចំមេរៀន ។ វាមានសារសំខាន់ណាស់ក្នុងការកត់សម្គាល់ថា មេរៀននេះទំនងជាមានទំនាក់ទំនងជាមួយនឹងការអភិវឌ្ឍន៍មេរៀននៅក្នុងរយៈពេលពីរបីថ្ងៃ ឬមួយសប្ដាហ៍ទៅមុខទៀត ។ ម្យ៉ាងវិញទៀត សិស្សគួរបន្តធ្វើការនេះក្នុងមេរៀនដទៃទៀតសម្រាប់ថ្នាក់របស់ខ្លួន ប៉ុន្តែគ្រូគួរផ្ដល់ឲ្យសិស្សនូវពេលវេលាពីរបីនាទីដើម្បីធ្វើកិច្ចការនេះជារៀងរាល់ថ្ងៃ ព្រោះជាផ្នែកមួយនៃការរៀបចំពិព័រណ៍របស់សិស្ស ។ រយៈពេលដែលតម្រូវក្នុងការរៀបចំគម្រោង រចនា និងការឡើងពន្យល់ពីពិព័រណ៍ គឺអាស្រ័យទៅលើការយល់ដឹង និងការតាំងចិត្តរបស់សិស្សក្នុងការធ្វើកិច្ចការនេះ ក៏ដូចជាភាពស្មុគស្មាញរបស់ប្រធានបទទាំងមូល ។

#### ជំហានទី១ ៖ ការជ្រើសរើសប្រធានបទ

គ្រូគួរឲ្យសិស្សប្រើពេលវេលាដើម្បីពិចារណាពីប្រធានបទ ឬសំណួរអ្វីដែលសិស្សចង់បង្ហាញ ។ គ្រូអាចផ្ដល់ដល់សិស្សនូវគំនិតខ្លះៗ ។ គ្រូអាចប្រើប្រាស់ពេលវេលាពីរបីនាទីក្នុងមួយថ្ងៃ ដើម្បីអនុញ្ញាតឲ្យសិស្សជួប និងពិភាក្សាពីប្រធានបទរបស់ខ្លួន ។ ក្នុងដំណាក់កាលនេះ សិស្សគួរចាប់ផ្ដើមគិតពីអ្វីដែលខ្លួនចង់បង្កើត ៖ ឧទាហរណ៍ ការជ្រើសរើសរឿងរ៉ាវការបង្ហាញព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ រូបភាព ឬកំណាព្យ ក៏ដូចជាការសម្ដែងតួ ។

សិស្សគួរត្រូវបានអនុញ្ញាតឲ្យជ្រើសរើសប្រធានបទ ឬសំណួរផ្ទាល់ខ្លួន ។ ទោះជាយ៉ាងនេះក៏ដោយ គ្រូគួរប្រគល់ប្រធានបទ ឬសំណួរទៅឲ្យសិស្ស ប្រសិនបើការធ្វើបែបនេះមានប្រសិទ្ធិភាពជាងការឲ្យសិស្សជ្រើសរើសដោយខ្លួនឯង ។

ខាងក្រោមនេះជាបញ្ជីរាយប្រធានបទ ឬសំណួរ ។ បញ្ជីនេះ គ្រាន់តែជាការបំផុសគំនិតប៉ុណ្ណោះ ។ គ្រូ និងសិស្ស

គួរគិតពិចារណាពីគំនិតផ្សេងទៀតក្រៅពីបញ្ជីនេះបានដោយសេរី ។

១)  តើជីវិតរស់នៅប្រចាំថ្ងៃនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យជាអ្វី?

២)  តើ ប៉ុល ពត ជានរណា?

៣)  តើមនុស្សសំខាន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជានរណា?

៤)  អាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៥)  ម្ហូបអាហារ និងរបបអាហារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៦)  ទំនាក់ទំនងការបរទេសរវាងកម្ពុជាប្រជាធិបតេយ្យ និងពិភពលោក ។

៧)  ប្រព័ន្ធសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៨)  តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?

៩)  រឿងរ៉ាវផ្ទាល់ខ្លួន ៖ ការសង្កេតមើលមួយជ្រុងពីការរស់នៅរបស់មនុស្សក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

១០) មនោគមន៍វិជ្ជាខ្មែរក្រហម ។

១១) ការជម្លៀសដោយបង្ខំ ។

១២) ការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ។

១៣) ផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យមកលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។

### ជំហានទី២ ៖ ការស្រាវជ្រាវ

បន្ទាប់ពីការជ្រើសរើសប្រធានបទ និងការយល់ព្រមពីគ្រូទៅលើប្រធានបទរួចមក សិស្សត្រូវតែធ្វើការស្រាវជ្រាវទៅលើសម្ភារដែលមានស្រាប់ ដើម្បីធ្វើគម្រោងផែនការចំពោះការបង្កើតពិព័រណ៍សារមន្ទីររបស់ខ្លួន ។ សិស្សអាចប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើសៀវភៅនេះ គឺជាសម្ភារតែមួយគត់ដែលមានស្រាប់ ។ ទោះជាយ៉ាងណាក៏ដោយ គ្រូគួរតែលើកទឹកចិត្តសិស្សឲ្យសម្ភាសជាមួយសមាជិកនៅក្នុងសហគមន៍ ដែលកិច្ចការនេះជាផ្នែកមួយក្នុងដំណាក់កាលនៃការស្រាវជ្រាវ ។

សិស្សគួរជ្រើសរើសកន្លែងណាមួយក្នុងថ្នាក់រៀន ដើម្បីធ្វើការរចនា និងបង្ហាញពីពិព័រណ៍របស់ខ្លួន ។ ការធ្វើគម្រោងផែនការ និងដំណាក់កាលនៃការរចនានេះ គឺជាការចំណាយពេលវេលាយ៉ាងច្រើន ព្រោះថា សិស្សតម្រូវឲ្យធ្វើការស្រាវជ្រាវពីប្រធានបទរបស់ខ្លួន និងពន្យល់ពីផ្នែកដ៏មានសារសំខាន់បំផុតនៃព័ត៌មានដែលឈានដល់ការបង្កើតពិព័រណ៍នេះឡើង ។ សិស្សត្រូវតែពិចារណាថា តើមានព័ត៌មានប៉ុន្មានដែលខ្លួនអាចបង្ហាញនៅក្នុងរបៀបដ៏មានអត្ថន័យ និងនៅក្នុងទម្រង់អ្វី ។

សិស្សមិនគួរចម្លងផ្នែកខ្លះនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយបង្ហាញផ្នែកទាំងនោះថា ជាពិព័រណ៍នោះទេ ។ សិស្សគួរតែឆ្លុះបញ្ចាំងពីរបៀបនៃការប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឲ្យទៅជារបៀបនៃការបង្ហាញដ៏មានអត្ថន័យ ដែលបង្ហាញឲ្យឃើញពីចម្លើយជាក់លាក់មួយទៅលើប្រធានបទ ឬសំខាន់ជាងនេះទៀតទៅលើបទពិសោធន៍ដ៏ជាក់លាក់មួយ ឬជាគំនិតដែលសិស្សគិតថា វាមានសារសំខាន់ ។

### ជំហានទី៣ ៖ ការរចនាពិព័រណ៍

បន្ទាប់ពីសិស្សមានព័ត៌មានគ្រប់គ្រាន់ហើយ សិស្សគួរចាប់ផ្តើមធ្វើការរចនាពិព័រណ៍របស់ខ្លួន ។ សិស្សអាចស្វែងរកសម្ភារផ្សេងៗសម្រាប់ធ្វើកិច្ចការនេះ ។ ចេតនាក្នុងការធ្វើការងារនេះ គឺមិនតម្រូវឲ្យសិស្សចំណាយពេលវេលាច្រើនពេកទេ



*រមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំនាពេលបច្ចុប្បន្ន ។ សង់ឡើងក្នុងសតវត្សទី១៤ វត្តភ្នំត្រូវបានជួសជុល និងស្ថាបនាជាច្រើនលើកច្រើនសា ។ សព្វថ្ងៃរមណីយដ្ឋានវត្តភ្នំ គឺជាទីសក្ការបូជា ដែលប្រជាជនកម្ពុជាទៅគោរពបូជាតាមបែបពុទ្ធសាសនា ។ រូបថត ៖ អ៊ូច មករា*

ក្នុងការស្វែងរកសម្ភារដែលទាក់ទង ។ គ្រូគួរលើកទឹកចិត្ត សិស្សឲ្យរចនាពិព័រណ៍ដែលអាចត្រូវបានបង្កើតឡើង តាមរយៈការប្រើប្រាស់សម្ភារដែលមានស្រាប់នៅក្នុងគេហដ្ឋាន សហគមន៍ ឬនៅក្នុងថ្នាក់រៀនរបស់ខ្លួន ជាជាងចំណាយប្រាក់ទិញសម្ភារផ្សេងទៀត ។ ពិព័រណ៍ដែលប្រកបទៅដោយភាពច្នៃប្រឌិតមួយ គួរត្រូវបានរចនាឡើងតាមរយៈការប្រើប្រាស់ក្រដាសសៀវភៅ ប៊ិច ក្រដាសកាតុង (ក្រដាសរឹង) និងប៊ិចហ្វឺត ។ សិស្សអាចប្រាជ្ញាចង់រចនាពិព័រណ៍មួយ ដែលពឹងផ្អែកទាំងស្រុងលើមូលដ្ឋាននៃការសម្តែងតួ ។ ម្យ៉ាងវិញទៀត សិស្សអាចសម្តែងតួនៅក្នុងថ្នាក់ជំនួសឲ្យការបង្កើតពិព័រណ៍ជារូបភាព (វត្ថុដែលមើលឃើញ និងប៉ះបាន) ។ គោលដៅចុងក្រោយនៃមេរៀននេះ គឺមិនត្រឹមតែសំដៅលើការបង្ហាញទម្រង់ពិតប្រាកដនៃព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញពីការសម្តែងតួពីបទពិសោធន៍ដែលត្រូវបានបង្កើតឡើងសម្រាប់ថ្នាក់ដែរ ។

### ជំហានទី៤ ៖ ការឡើងបង្ហាញពីគម្រោងផែនការ

សិស្សមិនត្រឹមតែបង្កើតពិព័រណ៍តែមួយមុខទេ ប៉ុន្តែថែមទាំងគិតពីរបៀបដែលខ្លួនត្រូវឡើងពន្យល់នៅក្នុងថ្នាក់ទាំងមូល ។ ក្នុងការឡើងពន្យល់នៅក្នុងថ្នាក់ សិស្សគួរបង្ហាញពីរបាយការណ៍ត្រឹមតែពីរឬបីប៉ុណ្ណោះ ដែលរៀបរាប់អំពីពិព័រណ៍របស់ខ្លួន និងអត្ថន័យនៃពិព័រណ៍ ។ ប្រសិនបើសិស្សសម្តែងឆាកកំប្លែងខ្លីមួយ កំណាព្យ ឬចម្រៀង សិស្សគួរគិតពីគោលបំណងនៃការសម្តែងនេះ ព្រមទាំងភាពទាក់ទង ឬអត្ថន័យជាមូលដ្ឋានដែលបង្ហាញឲ្យឃើញតាមរយៈការសម្តែង ។

### ជំហានទី៥ ៖ ការឡើងពន្យល់នៅក្នុងថ្នាក់ស្តីពីពិព័រណ៍

ការឡើងពន្យល់អាចទទួលបានជោគជ័យ ដោយមានក្រុមនីមួយៗប្តូរវេនគ្នាឡើងពន្យល់ពីពិព័រណ៍របស់ខ្លួនទៅកាន់ថ្នាក់ទាំងមូល ។

*សំយោគ (១៥-២៥នាទី)*

សិស្សម្នាក់តំណាងឲ្យក្រុមនីមួយៗគួរឡើងពន្យល់ពីអ្វីដែលក្រុមរបស់ខ្លួនបានរៀន ។ សកម្មភាពនេះនឹងផ្តល់សេចក្តីសង្ខេបទាំងស្រុងស្តីពីការសិក្សារបស់សិស្ស ។



*នៅមុខក្រសួងអប់រំ យុវជន និងកីឡា (ពីឆ្វេងទៅស្តាំ) ៖ អាឡិចហ្សេនដឺ ហ៊ីនតុន (នាយកមជ្ឈមណ្ឌលសិក្សាអំពីប្រល័យពូជសាសន៍ និងសិទ្ធិមនុស្សនៅសកលវិទ្យាល័យរ៉ាត់ហ្គ័រ), ឯកឧត្តម អ៊ឹម សិទ្ធី (អតីតរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា), ចន ឆរឈើអារី (សាស្ត្រាចារ្យផ្នែកនយោបាយសាធារណៈ នៅសកលវិទ្យាល័យមីឈីហ្គេន), ឆាំង យុ (នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា), ដេវីដ ឆេនដ៍ល័រ (អ្នកជំនាញប្រវត្តិសាស្ត្រកម្ពុជាដ៏ល្បីល្បាញ) ។ ឈរនៅខាងក្រោយ (ពីឆ្វេងទៅស្តាំ) ៖ បណ្ឌិត ជា ផល្លា, បណ្ឌិត ផាត កុសល, និង សារ៉ា ឌិកឹន ។ រូបថត ៖ ផេង ពង្សរ៉ាស៊ី ។ ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

## មេរៀនទី៦ ៖ ការធ្វើឱ្យមានការផ្លាស់ប្តូរ

### វត្ថុបំណង

១) សិស្សត្រិះរិះពិចារណាអំពីអ្វីដែលអាចធ្វើបាន ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ។

២) សិស្សពន្យល់អំពីកម្រិតផ្សេងៗគ្នានៃតួនាទី និងអំណាច ។

៣) សិស្សត្រិះរិះពិចារណា តើប្រវត្តិនៃអំពើប្រល័យពូជសាសន៍ និងការសិក្សាអំពីអំពើប្រល័យពូជសាសន៍មានឥទ្ធិពលទៅលើការទប់ស្កាត់អំពើប្រល័យពូជសាសន៍យ៉ាងដូចម្តេច?

៤) សិស្សលើកជាគំនិតដែលអាចជួយឲ្យមានការផ្លាស់ប្តូរ ។

**សម្ភារឧបទេស ៖** ក្រដាសផ្ទាំង ។

### លំនាំបង្រៀន

*ការផ្តើមបង្រៀន (៥ - ១០ នាទី)*

មុនពេលចាប់ផ្តើមមេរៀន គ្រូបង្ហាញពីវត្ថុបំណងនៃមេរៀនសម្រាប់ថ្ងៃនេះ ។ គ្រូសរសេរពាក្យពនៅលើក្តារខៀន "មូលដ្ឋាន" "ជាតិ" និង "អន្តរជាតិ" ។ បន្ទាប់មកគ្រូឲ្យសិស្សផ្តល់យោបល់អំពីអ្វីដែលអាចធ្វើបាន ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងថ្នាក់នីមួយៗ ។ គ្រូឲ្យសិស្សចាប់ផ្តើមពិភាក្សាពីថ្នាក់មូលដ្ឋាន ហើយបញ្ចប់ជាមួយនឹងថ្នាក់អន្តរជាតិ រួចសរសេរចម្លើយនៅលើក្តារខៀន ។

**ចម្លើយរួមមាន ៖**

**ថ្នាក់មូលដ្ឋាន**

និយាយទៅកាន់មិត្តភក្តិ និងក្រុមគ្រួសារ ដើម្បីឲ្យអ្នកទាំងនោះចូលរួមជួយគាំទ្រអ្នកដែលរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ។

ជួយរៃអង្គាសប្រាក់ ដើម្បីជួយទ្រទ្រង់ក្រុមអង្គការមនុស្សធម៌ ដែលកំពុងតែផ្តល់ជំនួយចំណីអាហារ និងការអប់រំដល់អ្នកដែលរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ។

ជួយបង្កើនការយល់ដឹងអំពីអំពើប្រល័យពូជសាសន៍ក្នុងចំណោមយុវជនក្មេងៗ នៅក្នុងសាលារៀនខ្ញុំ និងសហគមន៍របស់ខ្ញុំ ។ ខ្ញុំអាចស្វែងយល់ពីអំពើអយុត្តិធម៌ដែលកើតមានឡើងនៅកន្លែងផ្សេងទៀតនាពេលបច្ចុប្បន្ន ។

ប្រជាជនចាត់វិធានការ និងជំរុញមេដឹកនាំរបស់ខ្លួនឲ្យធ្វើសកម្មភាព ។ ប្រជាជនអាចស្វែងរកព័ត៌មានអំពីប្រជាជននៃប្រទេសផ្សេងទៀត ហើយរំឭកមេដឹកនាំរបស់អ្នកទាំងនោះ អំពីភាពអយុត្តិធម៌ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។

**ថ្នាក់ជាតិ**

- ថ្នាក់ដឹកនាំធានាឲ្យបានថា សិស្សទទួលបានការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅតាមសាលារៀន ដូច្នេះសិស្សអាចដឹងអ្វីដែលបានកើតឡើង និងអ្វីដែលកំពុងតែកើតឡើង ។ សិស្សត្រូវប្រឹងប្រែងរៀនដើម្បីស្វែងយល់ពីរឿងរ៉ាវទាំងនេះ និងស្វែងរកព័ត៌មានថ្មីៗទៀត ។
- ថ្នាក់ដឹកនាំ រៀបគម្រោងថវិកាជាតិ ទៅឲ្យក្រុមដែលធ្វើការជួយសង្គ្រោះអ្នកដែលរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ។ ប្រជាជនអាចចូលរួមនៅក្នុងកិច្ចការនេះ ហើយជួយផ្សព្វផ្សាយស្មារតី ផ្នែកសីលធម៌ ។

**ថ្នាក់អន្តរជាតិ**

- ប្រទេសផ្សេងៗបញ្ជូនមនុស្ស និងកងទ័ពដើម្បីទៅជួយថែរក្សាសន្តិភាព ហើយបញ្ជូនអ្នកកាសែត និងអ្នកសង្កេតការណ៍ទៅធ្វើរបាយការណ៍អំពីអ្វីដែលកំពុងតែកើតមានឡើង ។
- គ្រប់ប្រទេសទាំងអស់សិក្សាពីកំហុសនៅក្នុងអតីតកាល ហើយព្យាយាមកុំប្រព្រឹត្តកំហុសនោះម្តងទៀត ។
- ទីភ្នាក់ងារអន្តរជាតិ និងរដ្ឋាភិបាលទាំងឡាយគួរបញ្ចូលអំពើប្រល័យពូជសាសន៍ទៅក្នុងគោលនយោបាយរបស់ខ្លួន ដើម្បីស្វែងយល់អំពីផលប៉ះពាល់មកលើប្រទេសក្រោយជម្លោះ ដែលគេចង់ជួយនៅក្នុងការអភិវឌ្ឍន៍ ។
- ការកែទម្រង់តួនាទីរបស់អង្គការសហប្រជាជាតិ ។

*ការបង្រៀន (១៥-៤៥នាទី)*

សិស្សដើរតួជានាយកមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍អចិន្ត្រៃយ៍មួយ ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម ។ ក្នុងនាមជានាយកមជ្ឈមណ្ឌល សិស្សម្នាក់ៗត្រូវសរសេរកថាខណ្ឌទី២ ទៅលើអ្វីដែលខ្លួនគិតថា មជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍អចិន្ត្រៃយ៍គួរធ្វើ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងជំរុញដល់ដំណើរការផ្សះផ្សាជាតិ ។ តើគំនិតដែលខ្លួនគិតថានឹងត្រូវអនុវត្ត ក្នុងនាមជានាយកមជ្ឈមណ្ឌលមានអ្វីខ្លះ? តើមជ្ឈមណ្ឌលគួរធ្វើការងារអ្វីខ្លះដើម្បីប្រជាជនកម្ពុជា? តើមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍អាចជួយដល់ប្រជាជនកម្ពុជាអ្វីខ្លះ? តើការអប់រំពីអំពើប្រល័យពូជសាសន៍អាចជួយដល់ប្រជាជនកម្ពុជាអ្វីខ្លះ? តើបុគ្គលនីមួយៗអាចធ្វើការងារអ្វីខ្លះដើម្បីជួយដល់

មជ្ឈមណ្ឌល? តើមជ្ឈមណ្ឌលនេះអាចដំណើរការនៅក្នុងបរិបទតំបន់ និងសាកលលោកបានដោយរបៀបណា? គំនិតមួយចំនួនអាចជា ៖

១) ផ្តល់ជំនួយដល់សាលារៀន សម្រាប់ការអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។
២) ស្រាវជ្រាវអំពីសេចក្តីវេទ្ទត់នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកការពិត ។
៣) ជួយប្រជាជនកម្ពុជាទូទៅ ដែលមានការប៉ះទង្គិចផ្នែកផ្លូវចិត្ត ។
៤) អប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។
៥) ពិភាក្សាអំពីគំនិតក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ។
៦) ជួយប្រជាជនកម្ពុជាក្នុងការសិក្សាអំពីមនុស្សជាទីស្រឡាញ់ដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។
៧) សហការជាមួយជំនាញការបរទេស ដែលមានជំនាញអំពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងប្រទេសផ្សេងទៀត ។
៨) ជំរុញឲ្យមានការពិភាក្សាជុំវិញបញ្ហានៃការស្អប់ខ្ពើម ការរើសអើងពូជសាសន៍ និងអំពើអាក្រក់ផ្សេងៗទៀត
៩) ជួយដល់ការផ្សះផ្សារវាងអតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះក្នុងសហគមន៍នៅតាមមូលដ្ឋាន ។
១០) ជំរុញការអប់រំអំពីសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ ។

*សំយោគ (១៥-២៥នាទី)*

សិស្សអានកថាខណ្ឌរបស់ខ្លួននៅក្នុងថ្នាក់ ។

# សកម្មភាពសិក្សាបន្ថែម

## ក) សកម្មភាពបឋម

សេចក្តីផ្តើមនៃអត្ថបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

តារាង K-W-L ៈ សកម្មភាពនៃការអាន

កំណត់ចំណាំ ៈ សកម្មភាពនេះអាចត្រូវបានប្រើម្តងទៀត សម្រាប់មេរៀនទាំងអស់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ដោយប្រើស្របគ្នាជាមួយនឹងសៀវភៅលំហាត់ ឬក៏ប្រើចម្រុះគ្នាអាស្រ័យទៅលើការសម្រេចរបស់គ្រូ ។

**សកម្មភាព** ៈ បង្កើតតារាង K-W-L (អំណានអត្ថបទ)

**ការពិពណ៌នា** ៈ

នៅក្នុងជួរ K សិស្សពិភាក្សាព័ត៌មានដែលខ្លួនបានដឹងរួចហើយអំពីរបបខ្មែរក្រហម ។

នៅក្នុងជួរ W សិស្សពិភាក្សាព័ត៌មានដែលខ្លួនគិតថា នឹងរៀននៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងជួរ L សិស្សពិភាក្សា ព័ត៌មានដែលខ្លួនបានរៀនពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់អ្នកស្រាវជ្រាវ ឌី ខាំបូលី ។

**វត្ថុបំណង**

១) សិស្សដឹងពីព័ត៌មានសំខាន់ៗអំពីប្រធានបទនៃជំពូកនីមួយៗ សម្រាប់រយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សរៀបចំព័ត៌មានដែលគេបានដឹងអំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៣) សិស្សវាយតម្លៃព័ត៌មានដែលសិក្សាសម្រាប់ប្រធានបទជាក់លាក់ណាមួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

៤) សិស្សរៀបចំព័ត៌មានដែលបានសិក្សាសម្រាប់ប្រធានបទជាក់លាក់ណាមួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

៥) សិស្សវាយតម្លៃព័ត៌មានអំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៦) សិស្សវិភាគទៅលើចំណុចចម្រូងចម្រាសក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

៧) សិស្សវាយតម្លៃការជជែកដេញដោលទៅលើចំណុចចម្រូងចម្រាសទាំងនេះ ។

៨) សិស្សពន្យល់គំនិតរបស់ខ្លួនទៅលើព័ត៌មានក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**គ្រូបង្រៀន** ៈ

**ជំហានទី១** ៈ គ្រូណែនាំឲ្យសិស្សគូសបន្ទាត់បញ្ឈរ៣នៅលើក្រដាស១សន្លឹកដើម្បីបង្កើតជា៣ជួរ ។ នៅក្នុងជួរទី១ គ្រូណែនាំ ឲ្យសិស្សសរសេរនៅផ្នែកខាងលើនៃបន្ទាត់បញ្ឈរ “អ្វីដែលខ្ញុំដឹងអំពីប្រធានបទនេះ” ។ បន្ទាប់មក គ្រូណែនាំឲ្យសិស្សសរសេរនូវរាល់ចំណុចទាំងអស់នៃព័ត៌មានដែលខ្លួនដឹងអំពីប្រធានបទនៅក្នុងតារាងជួរទី១ ។

កំណត់ចំណាំ ៈ ប្រធានបទត្រូវយកចេញពីជំពូកណាមួយនៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់

អ្នកនិពន្ធ ឌី ឝាំបូលី ដែលគ្រូកំណត់ឲ្យសិស្សអានសម្រាប់ថ្ងៃនេះ ។

**ជំហានទី២** ៖ គ្រូណែនាំឲ្យសិស្សពិភាក្សាពីអ្វីដែលខ្លួនបានសរសេរនៅក្នុងជួរទី១ ។ គ្រូត្រូវដឹកនាំការពិភាក្សាជាមួយសិស្សនូវសំណួរខាងក្រោម (នេះគ្រាន់តែជាយោបល់) ៖

១) ហេតុអ្វីបានជាអ្នកគិតថា ប្រធានបទនេះសំខាន់ក្នុងការអាន?

២) តើអ្នកដឹងអ្វីខ្លះអំពីប្រធានបទនេះ?

៣) តើអ្នកចង់ដឹងអំពីប្រធានបទនេះអ្វីខ្លះ?

៤) តើមានចំណុចចម្រូងចម្រាសអ្វីផ្សេងទៀតទាក់ទងនឹងប្រធានបទនេះដែរឬទេ?

៥) តើចំណុចចម្រូងចម្រាសនោះគឺជាអ្វី? តើមានការវែកញែកផ្សេងៗគ្នាទាក់ទងនឹងប្រធានបទនោះ យ៉ាងដូចម្ដេចខ្លះ?

៦) តើគំនិតរបស់អ្នកលើប្រធានបទនេះគឺអ្វី?

**ជំហានទី៣** ៖ គ្រូជ្រើសរើសសិស្សម្នាក់ ឬមួយចំនួនឲ្យអានឮៗនៅក្នុងថ្នាក់នូវចំណងជើងរងនៅក្នុងជំពូកនីមួយៗ ។ ប្រសិនបើគ្មានចំណងជើងរងទេនោះ គ្រូណែនាំសិស្សឲ្យអានឃ្លាទី១នៃកថាខណ្ឌនីមួយៗនៅក្នុងជំពូក ។

**ជំហានទី៤** ៖ គ្រូណែនាំសិស្សឲ្យបិទសៀវភៅប្រវត្តិសាស្ត្រ និងសរសេរនៅក្នុងជួរទី២ "អ្វីដែលខ្ញុំនឹងដឹងអំពីប្រធានបទនេះបន្ទាប់ពីអានរួច" ។

**ជំហានទី៥** ៖ គ្រូណែនាំសិស្សម្នាក់ៗឲ្យចំណាយពេល២នាទី ហើយសរសេរពីអ្វីដែលខ្លួនប៉ាន់ស្មានថា តើជំពូក ឬការអាននេះនិយាយអំពីអ្វី? សិស្សគួរសរសេររៀបរាប់អ្វីដែលខ្លួនគិតថា ខ្លួននឹងរៀនបន្ទាប់ពីការអាន លើកលែងតែចំណងជើងរង ។

**ជំហានទី៦** ៖ គ្រូណែនាំសិស្សឲ្យពិភាក្សាពីអ្វីដែលខ្លួនបានសរសេរនៅក្នុងជួរទី២ ។ គ្រូដឹកនាំការពិភាក្សា ជាមួយសិស្សនូវសំណួរទាំងឡាយខាងក្រោម (នេះគ្រាន់តែជាយោបល់) ៖

១) តើព័ត៌មានដែលអ្នកគិតថា អ្នកនឹងរៀនដោយផ្អែកទៅលើចំណងជើងរងទាំងនេះគឺអ្វីខ្លះ?

២) ហេតុអ្វីបានជាអ្នកគិតថា ព័ត៌មានទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុងជំពូកនេះ ឬនិយាយម្យ៉ាងទៀត ហេតុអ្វីបានជាអ្នកនិពន្ធដាក់បញ្ចូលព័ត៌មាននេះ?

៣) តើមានភាពចម្រូងចម្រាសអំពីចំណងជើងរងទាំងនេះដែរឬទេ?

៤) តើភាពចម្រូងចម្រាសនោះគឺជាអ្វី? តើការបកស្រាយផ្សេងៗគ្នាទៅលើភាពចម្រូងចម្រាសទាំងនោះគឺអ្វីខ្លះ?

៥) តើគំនិតរបស់អ្នកទៅលើប្រធានបទទាំងនេះមានអ្វីខ្លះ?

**ជំហានទី៧** ៖ គ្រូណែនាំឲ្យសិស្សអានជំពូក១នៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ដែលត្រូវបានកំណត់សម្រាប់មេរៀនថ្ងៃនេះ ។ គ្រូឲ្យសិស្សអានឮៗនៅក្នុងថ្នាក់ អានឮៗនៅក្នុងក្រុមតូចៗ ឬអានដោយស្ងៀមស្ងាត់រៀងៗខ្លួន ។ ប្រការនេះគឺអាស្រ័យទៅលើការសម្រេចចិត្តរបស់គ្រូ ការកំណត់ពេលវេលា និងចំនួនទំព័រនៃអត្ថបទ ។ សិស្សបំពេញការងារនៅក្នុងសៀវភៅលំហាត់នៃជំពូកនេះ ខណៈពេលកំពុងអាន ។ (កំណត់សម្គាល់ ៖ សៀវភៅលំហាត់នៃជំពូកនេះ គឺសំដៅទៅលើសៀវភៅលំហាត់របស់សិស្ស ។)

**ជំហានទី៨** ៖ បន្ទាប់ពីបញ្ចប់ការអាន គ្រូណែនាំសិស្សម្នាក់ៗឲ្យចំណាយពេល២នាទី ដើម្បីបំពេញតារាងជួរទី៣ "អ្វីដែលខ្ញុំបានរៀនពីជំពូកនេះ" ។ គ្រូណែនាំឲ្យសិស្សសរសេរនូវអ្វីៗទាំងអស់ដែលខ្លួនគិតថា បានសិក្សាពីជំពូកនេះក្នុង



គ្រូបង្រៀនរបាំបុរាណ ជា សាមី កំពុងតម្រង់កសិស្សរបស់គាត់ ។ អ្នកគ្រូ ជា សាមី ត្រូវបានគេលើកសរសើរថា ជាអ្នកជួយឲ្យរបាំបុរាណខ្មែររស់ឡើងវិញ បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។ កាលពីអាយុបាន ៣ឆ្នាំ អ្នកគ្រូបានចូលហាត់រាំរបាំបុរាណ នៅក្នុងព្រះបរមរាជវាំង ហើយនៅអាយុ៣០ឆ្នាំ គាត់បានក្លាយជាគ្រូបង្រៀនរបាំបុរាណដល់ក្រុមរបាំនៅក្នុងព្រះបរមរាជវាំង ។ នៅអាយុ៥៦ឆ្នាំ អ្នកគ្រូត្រូវបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរដូចប្រជាជនកម្ពុជាដទៃទៀតដែរ ក្នុងពេលខ្មែរក្រហមឡើកាន់អំណាចនៅឆ្នាំ១៩៧៥ ។ គាត់រួចរស់ជីវិតពីរបបខ្មែរក្រហមដោយសារតែលាក់អត្តសញ្ញាណរបស់គាត់ ។ គាត់ជាគ្រូបង្រៀនរបាំម្នាក់ក្នុងចំណោមគ្រូរបាំមួយចំនួនតូចប៉ុណ្ណោះ ដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម ។ អ្នកគ្រូទទួលអនិច្ចកម្មនៅក្នុង១៩៩៨ នៅក្នុងអាយុ៧៥ឆ្នាំ ដោយបានបន្សល់ទុកនូវកេរដំណែលដ៏មានតម្លៃ ។

រយៈពេលពី១ ទៅ២នាទី ។

**ជំហានទី៩** ៖ គ្រូណែនាំសិស្សឲ្យពិភាក្សាពីអ្វីដែលសិស្សបានសរសេរនៅក្នុងតារាងជួរទី៣ ។ គ្រូដឹកនាំសិស្សឲ្យពិភាក្សាសំណួរខាងក្រោម (នេះគ្រាន់តែជាយោបល់) ។

១) តើព័ត៌មានដែលអ្នកបានរៀនពីជំពូកនេះមានអ្វីខ្លះ?

២) តើព័ត៌មានទាំងនេះមានសារសំខាន់សម្រាប់ប្រធានបទដែរឬទេ? តើអ្នកចង់ដឹងព័ត៌មានអ្វីបន្ថែមទៀត?

៣) តើមានចំណុចចម្រូងចម្រាសនៅក្នុងជំពូកនេះដែរឬទេ?

៤) ហេតុអ្វីបានជាចំណុចទាំងនោះជាចំណុចចម្រូងចម្រាស? តើការវែកញែកខុសគ្នាទៅលើចំណុចចម្រូងចម្រាសទាំងនេះមានអ្វីខ្លះ?

៥) តើគំនិតរបស់អ្នកទៅលើប្រធានបទនេះជាអ្វី?

**ជំហានទី១០** ៖ គ្រូណែនាំសិស្សឲ្យសរសេរចម្លើយនៅលើក្រដាសដដែល ដោយឆ្លើយនឹងសំណួរខាងក្រោម ៖

១) តើសកម្មភាពនៃការអានបែបនេះបានជួយដល់ការយល់ដឹងរបស់អ្នកអំពីប្រធានបទនេះដែរឬទេ?

២) ចូរឲ្យចំណុចល្អចំនួន១ ឬ ២ ដែលអ្នកចូលចិត្តអំពីសកម្មភាពនេះ?

៣) ចូរឲ្យចំណុចចំនួន១ ឬ ២ ដែលអ្នកចង់ឲ្យមានការកែលម្អទៅលើសកម្មភាពនេះ?

៤) សរុបមក តើអ្នកចង់បានសកម្មភាពអានបែបនេះបន្ថែមទៀតទេ? ឬអ្នកចូលចិត្តអានរៀងៗខ្លួន អានជាក្រុម ឬអានពួកៗ នៅក្នុងថ្នាក់?

**ជំហានទី១១** ៖ គ្រូណែនាំសិស្សឲ្យសរសេរឈ្មោះនៅក្នុងតារាង ហើយប្រគល់ក្រដាសនោះទៅឲ្យគ្រូវិញ ។ គ្រូនឹងប្រមូលក្រដាសទាំងអស់ពីសិស្ស ហើយរក្សាទុកនៅក្នុងបណ្ដុំឯកសាររបស់សិស្សតាមលំដាប់លំដោយ ។ គ្រូគួរពិនិត្យមើលរាល់អត្ថបទទាំងអស់របស់សិស្ស និងសរសេរកំណត់សម្គាល់នៅកន្លែងដែលគ្រូសង្ស័យថាមានបញ្ហា ។ គ្រូគួរតែកត់ត្រានូវ

ចំណាប់ចំណូលចិត្តរបស់សិស្សចំពោះសកម្មភាពរៀន ។

## ខ) ល្ខោន : ល្ខោននិយាយ

សិស្សម្នាក់ៗត្រូវសិក្សាអំពីរឿងរ៉ាវជាក់លាក់របស់មនុស្សម្នាក់ ។ បន្ថែមពីលើការសិក្សានេះ សិស្សត្រូវចាំសាច់រឿងទាំងមូល ។ សិស្សនឹងស្លៀកពាក់ទៅតាមតួអង្គនីមួយៗ ហើយសម្ដែងតួនៅចំពោះមុខទស្សនិកជន ។ ទស្សនិកជន (ដែលជាសិស្សនៅក្នុងសាលានោះដែរ) ត្រូវទម្លាក់យោបល់កែលម្អទៅក្នុងប្រអប់ផ្ដល់យោបល់មុនពេលចាកចេញពីកន្លែងសម្ដែង ។

**វត្ថុបំណង**

១) សិស្សស្វែងយល់អំពីបទពិសោធន៍ប្លែកខុសគេរបស់តួអង្គ ក៏ដូចជាមនុស្សដទៃទៀតដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។

២) សិស្សវាយតម្លៃបទពិសោធន៍របស់តួអង្គដែលខ្លួនសិក្សា ។

៣) សិស្សប្រមូលព័ត៌មានអំពីបទពិសោធន៍របស់តួអង្គ ដែលជាមនុស្សនៅក្នុងការសម្ដែងល្ខោនរបស់ខ្លួន ។

៤) សិស្សឡើងសម្ដែងជាតួអង្គ ឬបង្ហាញសមត្ថភាពក្នុងការសម្ដែងរបស់ខ្លួន ។

**ការវាយតម្លៃ** : គ្រូវាយតម្លៃការសម្ដែងរបស់សិស្សទៅលើចំណុចដូចខាងក្រោម៖

១) តើសិស្សយល់ដឹងអំពីបទពិសោធន៍របស់តួអង្គនោះដែរឬទេ?

២) តើការសម្ដែងរបស់សិស្សបានឆ្លុះបញ្ចាំងពីបទពិសោធន៍របស់តួអង្គដែរឬទេ?

**គ្រូបង្រៀន** : គ្រូប្រាប់សិស្សឲ្យឡើងសម្ដែងសកម្មភាពបន្ទាប់បន្សំផ្សេងៗទៀតនៅសប្ដាហ៍ក្រោយ ។ ការសម្ដែងចុងក្រោយ គឺជាសកម្មភាពបន្ទាប់បន្សំទី៣ ដែលសិស្សត្រូវតែសម្ដែងជាតួអង្គបុគ្គលដែលប្រវត្តិរឿងរ៉ាវរបស់គាត់ មាននៅក្នុងអត្ថបទរបស់ខ្លួន ។ គ្រូគួរគូសបញ្ជាក់អំពីសារសំខាន់ និងលើកសរសើរពីសកម្មភាពនៃការសម្ដែងនេះ ។ សិស្សត្រូវសម្ដែងពីរឿងរ៉ាវពិតរបស់ប្រជាជនដែលរស់នៅក្រោមរបបខ្មែរក្រហម ហើយត្រូវបង្ហាញពីការគោរពគ្រប់ដំណាក់កាលទាំងអស់ចំពោះរឿងរ៉ាវរបស់គាត់ ។

**សកម្មភាពទី១** : សិស្សអានសេចក្ដីសង្ខេប ។

ការពិពណ៌នា : សិស្សអានអត្ថបទសម្ភាសន៍ អំពីតួអង្គដែលខ្លួនត្រូវបានចាត់តាំងឲ្យសិក្សា ។ សិស្សសរសេរកថាខណ្ឌដែលសង្ខេបពីបទពិសោធន៍ អារម្មណ៍ និងការគិតរបស់តួអង្គក្នុងអត្ថបទសម្ភាសន៍ ។

**ជំហានទី១** : គ្រូកំណត់តួនាទីទៅឲ្យសិស្សម្នាក់ៗ ។ សិស្សគ្រប់រូបទទួលបានការកំណត់ឲ្យដើរតួផ្សេងៗគ្នា ។

**ជំហានទី២** : គ្រូណែនាំសិស្សម្នាក់ៗឲ្យអានព័ត៌មានទាក់ទងនឹងមនុស្សដែលគ្រូបានកំណត់ឲ្យ ហើយសរសេរ កថាខណ្ឌអំពីអត្ថបទអាននេះ ។ សិស្សប្រគល់កថាខណ្ឌនេះទៅឲ្យគ្រូវិញ ។

**ជំហានទី៣** : គ្រូអានកថាខណ្ឌនីមួយៗ ហើយប្រៀបធៀបកថាខណ្ឌទាំងនេះជាមួយនឹងអត្ថបទរឿងរ៉ាវរបស់ជនរងគ្រោះ ឬអតីតកម្មាភិបាល ។ គ្រូផ្ដល់យោបល់ទៅលើអត្ថបទសង្ខេបទាំងអស់ដោយសរសេរពីការកត់សម្គាល់ទៅលើចំណុចដែលគួរឲ្យចាប់អារម្មណ៍ និងចំណុចល្អដែលសិស្សបានលើកឡើងក៏ដូចជាចំណុចដែលសិស្សមិនបានលើកឡើង ហើយគួរតែនិយាយទាក់ទងនឹងជនរងគ្រោះ ឬអតីតកម្មាភិបាលខ្មែរក្រហម ។

**ជំហានទី៤** : គ្រូពន្យល់ប្រាប់សិស្សទាំងអស់ឲ្យចាប់ផ្ដើមចងចាំ និងរៀបចំការឡើងសម្ដែងល្ខោនអំពីជនរងគ្រោះ

ឬអតីតកម្មាភិបាលខ្មែរក្រហម ដែលបានទទួលការចាត់តាំងពីគ្រូ ។

**ជំហានទី៥** : គ្រូប្រគល់អត្ថបទ និងកំណែដែលគ្រូបានកែទៅឲ្យសិស្សធ្វើការត្រួតពិនិត្យឡើងវិញ ២ ទៅ ៣ នាទី ។

**សកម្មភាពទី២** : សិស្សអនុវត្តការឡើងសម្ដែងទៅកាន់គ្រូ និងសិស្សដទៃទៀតនៅក្នុងថ្នាក់

សិស្សម្នាក់ៗគួរតែទៅឈរនៅខាងមុខក្ដារខៀន ហើយសម្ដែងអត្ថបទសាច់រឿងរបស់ខ្លួនដោយប្រើប្រាស់ការចងចាំពីអត្ថបទសម្ភាសន៍ ។ គ្រូផ្ដល់យោបល់ និងដំបូន្មានបន្ទាប់ពីបញ្ចប់ការសម្ដែងនីមួយៗរបស់សិស្ស ។

**សកម្មភាពទី៣** : សិស្សសម្ដែងល្ខោនទៅកាន់ទស្សនិកជន ។

**ជំហានទី១** : ដូចគ្នាទៅនឹងសកម្មភាពទី២ដែរ លើកលែងតែទស្សនិកជន ដែលនឹងមានការចូលរួមពីសាធារណជនផ្សេងៗទៀត ។

**ជំហានទី២** : គ្រូសង្កេតមើលការសម្ដែង និងវាយតម្លៃលើភាពប៉ិនប្រសប់របស់សិស្សម្នាក់ៗ រួចផ្ដល់ជាអនុសាសន៍ដោយសរសេរដាក់ក្នុងក្រដាសហើយប្រគល់ឲ្យសិស្ស ។

**ជំហានទី៣** : គ្រូឲ្យទស្សនិកជនគ្រប់រូបសរសេរនៅក្នុងសៀវភៅផ្ដល់យោបល់អំពីការយល់ឃើញរបស់ខ្លួន ចំពោះការសម្ដែងនេះ ជាពិសេសចំពោះតួសម្ដែង កាយវិការ និងចំណុចដែលត្រូវកែលម្អ ។

**ជំហានទី៤** : ពេលបញ្ចប់ការសម្ដែង គ្រូពិនិត្យមើលយោបល់របស់ទស្សនិកជន និងសិស្សម្នាក់ៗជាមួយសិស្សទាំងអស់នៅក្នុងថ្នាក់ ។

## គ) គម្រោងនៃការសិក្សាអំពីការប្រៀបធៀបអំពើប្រល័យពូជសាសន៍

(តម្រូវឲ្យមានកុំព្យូទ័រ និងអ៊ីនធឺណែត)

សិស្សធ្វើការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត ឬតាមប្រភពផ្សេងៗទៀត ចំពោះព័ត៌មានដែលចាំបាច់សម្រាប់ការឡើងពន្យល់អំពីការប្រៀបធៀបប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងប្រវត្តិសាស្ត្រដទៃទៀតដែលឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការរំលោភសិទ្ធិមនុស្សបានកើតមានឡើង ។ គ្រូវាយតម្លៃសិស្សដោយផ្អែកទៅលើមូលដ្ឋាននៃរបាយការណ៍ដែលសិស្សម្នាក់ៗបានរៀបចំឡើង និងការឡើងពន្យល់ជាក្រុម ។

**វត្ថុបំណង**

១) សិស្សពន្យល់អំពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សប្រៀបធៀបរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្សេងៗទៀត ។

៣) សិស្សពន្យល់ភាពដូចគ្នា និងភាពខុសគ្នារវាងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្សេងៗទៀត ។

៤) សិស្សវិភាគវិធានការដែលប្រើ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មសង្គ្រាម ។

៥) សិស្សវាយតម្លៃវិធានការដែលត្រូវប្រើ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មសង្គ្រាម ។

**ការវាយតម្លៃ** : សិស្សទទួលការវាយតម្លៃដោយផ្អែកលើរបាយការណ៍ផ្ទាល់ខ្លួន ក៏ដូចជាការឡើងពន្យល់ជាក្រុម ។ សកម្មភាពទាំង២ត្រូវបានវាយតម្លៃដោយប្រើប្រាស់តារាងដែលអ្នកបានឃើញនៅខាងក្រោម ៖

## គ្រូបង្រៀន ៖

**ជំហានទី១** ៖ គ្រូចាត់តាំងសិស្សជាក្រុម ដែលមានសិស្សពី៤ទៅ៥នាក់ក្នុងមួយក្រុមៗ ។

**ជំហានទី២** ៖ គ្រូកំណត់លេខរៀងទៅឲ្យសិស្សម្នាក់ៗ នៅក្នុងក្រុម ។

- សិស្សលេខរៀងទី១ ៖ ប្រៀបធៀបរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងហ្វូឡូខសត៍ ។
- សិស្សលេខរៀងទី២ ៖ ប្រៀបធៀបរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងយូហ្គោស្លាវី ។
- សិស្សលេខរៀងទី៣ ៖ ប្រៀបធៀបរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងរ៉្វាន់ដា ។
- សិស្សលេខរៀងទី៤ ៖ ប្រៀបធៀបរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងអ៊ីរ៉ាក់ ។
- សិស្សលេខរៀងទី៥ ៖ ប្រៀបធៀបរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងអាមេនៀ ។ (ក្នុងករណីដែលសិស្ស៥ នាក់ក្នុងក្រុម)

**ជំហានទី៣** ៖ សិស្សម្នាក់ៗតម្រូវឲ្យធ្វើការស្រាវជ្រាវទៅលើប្រធានបទរបស់ខ្លួន ដោយប្រើប្រាស់ព័ត៌មាននៅក្នុងអ៊ីនធឺណែត ។ សិស្សត្រូវបង្ហាញឯកសារយោងឲ្យបានច្បាស់លាស់សម្រាប់ព័ត៌មានដែលខ្លួនយកមកប្រើប្រាស់ ។

**ជំហានទី៤** ៖ សិស្សម្នាក់ៗត្រូវបានតម្រូវឲ្យធ្វើការស្រាវជ្រាវ និងសរសេររបាយការណ៍ដោយពន្យល់អំពីភាពដូចគ្នា និងភាពខុសគ្នា រវាងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រផ្សេងៗទៀត ទៅតាមប្រធានបទរបស់ខ្លួន ។ របាយការណ៍របស់សិស្សម្នាក់ៗគួរតែមានចំនួន២ទំព័រយ៉ាងតិច ចំពោះរបាយការណ៍ដែលវាយដោយកុំព្យូទ័រ និង៣ទំព័រចំពោះរបាយការណ៍ដែលសរសេរដោយដៃ ដែលរបាយការណ៍នីមួយៗគួរតែឆ្លើយនឹងសំណួរខាងក្រោម ។

១) តើមានព័ត៌មានជាមូលដ្ឋានអ្វីខ្លះនៅក្នុងករណីអំពើប្រល័យពូជសាសន៍នីមួយៗ ដែលយើងគួរតែបញ្ចូលដើម្បីឲ្យសិស្សយល់បរិបទនៃអំពើទាំងនោះ?

២) តើភាពប្រហាក់ប្រហែលគ្នារវាងរបបកម្ពុជាប្រជាធិបតេយ្យ និងរបបដែលអ្នកកំពុងតែស្រាវជ្រាវគឺអ្វីខ្លះ?

៣) តើភាពខុសគ្នាដូចម្តេចខ្លះរវាងរបបកម្ពុជាប្រជាធិបតេយ្យ និងរបបដែលអ្នកកំពុងស្រាវជ្រាវ?

៤) ដោយផ្អែកទៅលើការវាយតម្លៃរបស់សិស្សអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងរបបដែលខ្លួនកំពុងស្រាវជ្រាវ តើសិស្សផ្តល់អនុសាសន៍អំពីវិធានការដែលប្រទេសទាំងឡាយ និងអង្គការសហប្រជាជាតិគួរអនុវត្តដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតដូចដែល

| **សំណួរ** | **មិនឆ្លើយ ០ពិន្ទុ** | **មិនល្អ ១ពិន្ទុ** | **ល្អបង្គួរ ២ពិន្ទុ** | **ល្អណាស់ ៣ពិន្ទុ** |
|---|---|---|---|---|
| ព័ត៌មានបឋមអំពីប្រធានបទ | | | | |
| ភាពប្រហាក់ប្រហែលគ្នាជាមួយរបបកម្ពុជាប្រជាធិបតេយ្យ | | | | |
| ភាពខុសគ្នាជាមួយរបបកម្ពុជាប្រជាធិបតេយ្យ | | | | |
| ការផ្តល់យោបល់របស់សិស្ស | | | | |
| ពិន្ទុសរុប | | | | |

បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងរបបផ្សេងៗទៀតដែលសិស្សបានស្រាវជ្រាវមានអ្វីខ្លះ?

## តារាងសម្រាប់វាយតម្លៃការសម្ដែងរបស់សិស្ស

*កំណត់ចំណាំ ៖ គ្រូកំណត់ពេលវេលាសម្រាប់ឲ្យសិស្សប្រគល់របាយការណ៍រៀងៗខ្លួន ។*

**ជំហានទី៥** ៖ នៅពេលបញ្ចប់ និងប្រគល់របាយការណ៍រួចហើយ សិស្សម្នាក់ៗត្រូវជួបសមាជិកក្រុមរៀងៗខ្លួន ដើម្បីរៀបចំការឡើងពន្យល់រយៈពេលពី៥ ទៅ១០នាទីអំពីថា តើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភសិទ្ធិមនុស្សគួរត្រូវបានទប់ស្កាត់នៅក្នុងសតវត្សរ៍ទី២១ ដោយរបៀបណា? ការឡើងពន្យល់របស់សមាជិកក្រុមទាំងអស់ត្រូវបានវាយតម្លៃដោយផ្អែកទៅលើសំណួរទាំងឡាយខាងក្រោម ៖

១) តើអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាលក្រុមជនជាតិ និងការរំលោភសិទ្ធិមនុស្ស គួរត្រូវបានទប់ស្កាត់នៅក្នុងសតវត្សរ៍ទី២១ ដោយរបៀបណា? *កំណត់ចំណាំ ៖ ចំណុចនេះសង្កត់ធ្ងន់ទៅលើស្ថានភាពដែលសង្គ្រាមមិនទាន់ត្រូវបានប្រកាសជាផ្លូវការនៅឡើយ ហើយមានសញ្ញាដែលបង្ហាញអំពីអំពើហិង្សា និងជម្លោះនៅក្នុងប្រទេស ។*

២) តើឧក្រិដ្ឋកម្មសង្គ្រាមអាចត្រូវបានទប់ស្កាត់នៅក្នុងសតវត្សរ៍ទី២១ ដោយរបៀបណា? *កំណត់ចំណាំ ៖ ចំណុចនេះសង្កត់ធ្ងន់ទៅលើស្ថានភាព ដែលសង្គ្រាមត្រូវបានប្រកាសជាផ្លូវការ ហើយមានសញ្ញាដែលបង្ហាញអំពីអំពើហិង្សា និងជម្លោះនៅក្នុងប្រទេស ។*

| សំណួរ | មិនឆ្លើយ ០ពិន្ទុ | មិនល្អ ១ពិន្ទុ | ល្អបង្គួរ ២ពិន្ទុ | ល្អណាស់ ៣ពិន្ទុ |
|---|---|---|---|---|
| សំណួរទី១ | | | | |
| សំណួរទី២ | | | | |
| សំណួរទី៣ | | | | |
| សំណួរទី៤ | | | | |
| ពិន្ទុសរុប | | | | |

៣) តើអនុសាសន៍ដែលល្អជាងគេ បើប្រៀបធៀបជាមួយនឹងអនុសាសន៍ផ្សេងៗទៀតមានអ្វីខ្លះ?

៤) តើអនុសាសន៍ទាំងនេះត្រូវធ្វើឲ្យសម្រេចបានដោយរបៀបណា? និយាយម្យ៉ាងទៀត តើការសម្រេចឲ្យបាន ឬត្រូវតែបង្កើតឲ្យបានដើម្បីធ្វើឲ្យអនុសាសន៍នេះអាចប្រព្រឹត្តធ្វើទៅបាន ឬមានប្រសិទ្ធភាពអ្វីខ្លះ?

**ជំហានទី៦** ៖ គ្រូវាយតម្លៃរបាយការណ៍របស់សិស្សម្នាក់ៗនៅពេលទទួលបានពីសិស្ស និងការឡើងពន្យល់របាយការណ៍នីមួយៗនៅពេលបញ្ចប់ ដោយប្រើប្រាស់តារាងដែលបានរៀបរាប់ជាជំនួយ ។ បន្ទាប់ពីបញ្ចប់របាយការណ៍ និងការឡើងពន្យល់ សិស្សម្នាក់ៗទទួលបានពិន្ទុសរុប ដែលជាការសរុបពិន្ទុសម្រាប់របាយការណ៍របស់សិស្សម្នាក់ៗ និងពិន្ទុសម្រាប់ការឡើងពន្យល់របស់ក្រុម ។

**ជំហានទី៧** ៖ គ្រូរៀបចំធ្វើសកម្មភាពវាយតម្លៃក្រោយការធ្វើលំហាត់ចប់ ។ សិស្សម្នាក់ៗប្រគល់ចម្លើយអនាមិក

ចំពោះសំណួរខាងក្រោមដោយសរសេរនៅលើក្រដាស១សន្លឹក ។

១) តើចំណុច៣យ៉ាងដែលអ្នកចូលចិត្តអំពីសកម្មភាពនេះមានអ្វីខ្លះ?

២) តើចំណុច៣យ៉ាងដែលអ្នកចង់ធ្វើឲ្យប្រសើរឡើងអំពីសកម្មភាពនេះមានអ្វីខ្លះ?

## ឃ) សកម្មភាព ៖ កំណាព្យ

សិស្សស្រមៃថា ខ្លួនហាក់ដូចជាកំពុងតែរស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួចសរសេរកំណាព្យអំពីបទពិសោធន៍របស់ខ្លួន និងឡើងពន្យល់អំពីកំណាព្យនេះទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។

***វត្ថុបំណង***

១) សិស្សពន្យល់អំពីបទពិសោធន៍របស់ប្រជាជនកម្ពុជា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

២) សិស្សធ្វើសំយោគពីបទពិសោធន៍ទាំងអស់របស់ប្រជាជនកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ សម្រាប់ដាក់បញ្ចូលទៅក្នុងកំណាព្យ ហាក់ដូចជា ខ្លួនបានរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យអញ្ចឹងដែរ ។

៣) សិស្សអនុវត្តចំណេះដឹងរបស់ខ្លួនពីរបបកម្ពុជាប្រជាធិបតេយ្យ ។

៤) សិស្សតែងកំណាព្យពីជីវិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

**ការវាយតម្លៃ ៖** សិស្សទទួលបានការវាយតម្លៃក្រៅផ្លូវការ ។ សិស្សប្រគល់កំណាព្យរបស់ខ្លួនទៅឲ្យគ្រូ ដើម្បីផ្តល់យោបល់ ។ បន្ទាប់ពីទទួលបានយោបល់ពីគ្រូ សិស្សធ្វើការកែសម្រួលរួចប្រគល់កំណាព្យនេះទៅឲ្យគ្រូវិញ ដើម្បីរក្សាទុកនៅក្នុងសំណុំឯកសារសិក្សារបស់ខ្លួន ។

**ជំហានទី១ ៖** *កំណត់ចំណាំ ៖ សិស្សត្រូវបញ្ចប់សកម្មភាពការងារអំពីបទពិសោធន៍របស់ជនរងគ្រោះ៣ ឬ៤នាក់ជាមុនសិន ដូច្នេះទើបសិស្សមានចំណេះដឹងគ្រប់គ្រាន់ ដោយផ្អែកទៅលើបទពិសោធន៍របស់ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។*

**ជំហានទី២ ៖** សិស្សទទួលបានការណែនាំឲ្យសរសេរកំណាព្យ ដោយស្រមៃថា ខ្លួនកំពុងរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ កំណាព្យនេះគួរតែពិភាក្សាអំពីសំណួរខាងក្រោម ៖

១) តើជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យមានសភាពដូចម្តេចខ្លះ?

២) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើខ្ញុំមានអារម្មណ៍យ៉ាងណាខ្លះ?

៣) តើគោលដៅរបស់ខ្ញុំនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យមានអ្វីខ្លះ?

៤) តើខ្ញុំជានរណានៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ?

**ជំហានទី៣ ៖** សិស្សឡើងបង្ហាញកំណាព្យរបស់ខ្លួននៅក្នុងថ្នាក់ ។ គ្រូគួរតែលើកទឹកចិត្តដល់សិស្សដទៃទៀតឲ្យសួរសំណួរទៅកាន់សិស្សដែលកំពុងឡើងបកស្រាយកំណាព្យរបស់ខ្លួន ។ ខាងក្រោម គឺជាសំណួរដែលគ្រូអាចសួរដើម្បីជំរុញឲ្យមានការពិភាក្សា ៖

១) តើមាននរណាម្នាក់មានយោបល់អ្វី អំពីគោលគំនិតចម្បងនៅក្នុងកំណាព្យនេះ?

២) តើនរណាអាចពណ៌នាថា សិស្សម្នាក់នេះព្យាយាមចង់បង្ហាញពីអ្វី?

៣) តើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ឬប្រធានបទដែលនៅពីក្រោយកំណាព្យនេះគឺអ្វី?

៤) តើកំណាព្យនេះបានពណ៌នាអំពីគោលគំនិត ប្រធានបទ ឬបទពិសោធន៍ចម្បងណាមួយនៃជីវិតប្រជាជនកម្ពុជា ក្នុងរបបខ្មែរក្រហមដែរឬទេ?

**ជំហានទី៤** ៖ បន្ទាប់ពីសិស្សទាំងអស់បានបញ្ចប់ការឡើងពន្យល់អំពីកំណាព្យរួចមក គ្រូប្រមូលកំណាព្យទាំងនោះ ហើយផ្តល់យោបល់ដើម្បីឲ្យសិស្សពិនិត្យឡើងវិញ ឬក៏គ្រាន់តែប្រមូលកំណាព្យដើម្បីរក្សាទុកនៅក្នុងសំណុំឯកសារសិក្សារបស់សិស្ស ។

## ខ) គម្រោងស្រាវជ្រាវ ៖ បង្កើតបញ្ជី W

បញ្ជី «អ្វីដែលខ្ញុំចង់សិក្សា»

ការពិពណ៌នា ៖ សិស្សពិភាក្សាអំពីព័ត៌មានដែលខ្លួនចង់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

**វត្ថុបំណង** ៖ គោលបំណងរបស់សិស្សខុសៗគ្នា អាស្រ័យទៅលើប្រធានបទស្រាវជ្រាវរបស់ក្រុម ។ ទោះបីជាយ៉ាងណាក៏ដោយ ការរៀបរាប់ខាងក្រោម គឺជាគោលបំណងទូទៅ ៖

១) សិស្សរៀបរាប់អំពីព្រឹត្តិការណ៍ពិតនៃប្រធានបទរបស់ខ្លួន ។

២) សិស្សពន្យល់អំពីប្រធានបទរបស់ខ្លួន ។

៣) សិស្សវិភាគប្រធានបទទាំងឡាយណាដែលទាក់ទងនឹងប្រធានបទរបស់ខ្លួន ។

៤) សិស្សស្រាវជ្រាវលើប្រធានបទរបស់ខ្លួន ។

**គ្រូបង្រៀន** ៖

**ជំហានទី១** ៖ គ្រូណែនាំសិស្សម្នាក់ៗឲ្យបង្កើតបញ្ជីសំណួរដែលសិស្សចង់ឆ្លើយអំពីរបបខ្មែរក្រហម ។

*រយៈពេលប៉ាន់ស្មានសម្រាប់ជំហានទី១ គឺ១៥នាទី*

**ជំហានទី២** ៖ គ្រូណែនាំសិស្សឲ្យរាប់លេខ១ និងលេខ......... ។ (កំណត់ចំណាំ ៖ លេខរៀងអាស្រ័យទៅលើ ទំហំនៃថ្នាក់ ។ ក្រុមនីមួយៗមិនត្រូវឲ្យលើសពី៣ឬ៤នាក់ទេ) ។

**ជំហានទី៣** ៖ សិស្សដែលមានលេខរៀងទី១បង្កើតជាក្រុមមួយ ហើយសិស្សដែលមានលេខរៀងទី២ បង្កើតជាក្រុមមួយទៀត ។ល ។ គ្រូណែនាំសិស្សម្នាក់ៗដែលមានលេខរៀង រួចហើយឲ្យបង្កើតជាក្រុម ។ សិស្សផ្លាស់កន្លែងអង្គុយទៅតាមក្រុមដែលត្រូវបានកំណត់រួចហើយ ។

**ជំហានទី៤** ៖ គ្រូណែនាំសិស្សឲ្យពិភាក្សាក្នុងចំណោមក្រុមរៀងៗខ្លួនអំពីបញ្ជីសំណួរ ដែលខ្លួនគិតថាចង់សិក្សា ។ នៅក្នុងក្រុមសមាជិកម្នាក់ត្រូវផ្តល់សំណួរមួយដែលសិស្សគិតថា មានសារសំខាន់នៅក្នុងក្រុម ។ ក្រុមនីមួយៗគួរមានសំណួរ ៤ឬ៥ ដែលសិស្សគិតថា សំខាន់ ។ បន្ទាប់ពីសិស្សបានជ្រើសរើសសំណួរដែលខ្លួនចង់រៀនរួចមក សិស្សគួរផ្តល់អនុសាសន៍អំពីរបៀបដែលខ្លួនអាចស្វែងរកព័ត៌មាន ។ និយាយម្យ៉ាងទៀត ប្រសិនបើសិស្សចង់ដឹងចម្លើយចំពោះសំណួរ តើសិស្សត្រូវស្វែងរកចម្លើយដោយរបៀបណា? សំណួរនីមួយៗត្រូវរួមបញ្ចូលនូវផែនការក្នុងការទទួលបានចម្លើយ ។

**ជំហានទី៥** ៖ គ្រូឲ្យក្រុមនីមួយៗធ្វើការជ្រើសរើសអ្នកឡើងនិយាយ ដែលត្រូវពន្យល់អំពីសំណួរ និងផែនការ

*ស្រាវជ្រាវ ។*

*ពេលវេលាប៉ាន់ស្មានសម្រាប់ជំហានទី២ដល់ទី៥គឺពី២០ ទៅ៣០ នាទី ។*

***ជំហានទី៦ :*** *គ្រូឲ្យក្រុមទាំងអស់ជ្រើសរើសតំណាងក្រុម ឡើងបកស្រាយអំពីគំនិតរបស់ក្រុមទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់ ។ (កំណត់ចំណាំ : គ្រូកត់ត្រានូវសំណួរ និងផែនការស្រាវជ្រាវរបស់ក្រុមនីមួយៗ ។ ប្រសិនបើគ្រូយល់ឃើញថា សំណួររបស់ក្រុមទាំងអស់មានលក្ខណៈសមស្របសម្រាប់សិស្ស គ្រូធ្វើកំណត់ចំណាំទៅលើសំណួរ ហើយណែនាំសំណួរទាំងនេះទៅឲ្យក្រុមទាំងអស់ ។ ជាក់ស្តែងសំណួរ ឬផែនការស្រាវជ្រាវមួយចំនួនមានលក្ខណៈចម្រូងចម្រាសខ្លាំងសម្រាប់សិស្ស ឬមានលក្ខណៈពិបាកក្នុងការស្វែងរកប្រភព ។ នៅក្នុងករណីនេះ គ្រូត្រូវតែធ្វើការផ្លាស់ប្តូរគម្រោងស្រាវជ្រាវ ឬណែនាំសិស្សឲ្យជ្រើសរើសប្រធានបទស្រាវជ្រាវថ្មីមួយទៀត) ។*

*ពេលវេលាប៉ាន់ស្មានសម្រាប់ជំហានទី៦ អាស្រ័យទៅលើ ចំនួនសមាជិកនៅក្នុងក្រុម ហើយក្រុមនីមួយៗគួរតែមានពេលពី៣ ទៅ៥ នាទីសម្រាប់ឡើងបង្ហាញសំណួរ និងផែនការស្រាវជ្រាវរបស់ខ្លួន ដែលត្រូវចំណាយពេលពី១៥ -២០ នាទី ប្រសិនបើមាន៥ក្រុម ។*

***ជំហានទី៧ :*** *គ្រូពិភាក្សាជាមួយសិស្សទាំងអស់អំពីសំណួរអ្វីខ្លះនៅក្នុងក្រុមនីមួយៗដែលមានសារសំខាន់បំផុត សម្រាប់ថ្នាក់ ។ ក្រុមនីមួយៗត្រូវតែមានសំណួរស្រាវជ្រាវ និងផែនការស្រាវជ្រាវសមស្រប ។ បន្ទាប់ពីគ្រូពិភាក្សាអំពីសំណួរដែលក្រុមនីមួយៗចង់ស្រាវជ្រាវរួចហើយ គ្រូនឹងចាត់តាំងក្រុមនីមួយៗឲ្យធ្វើកិច្ចការក្នុងការឆ្លើយនឹងសំណួរទាំងនេះ ។*

***ជំហានទី៨ :*** *គ្រូរៀបចំកាលវិភាគសម្រាប់ការឡើងពន្យល់ ដែលក្រុមនីមួយៗត្រូវផ្តល់ពេលវេលាជាក់លាក់ណាមួយ ដើម្បីឡើងបង្ហាញអំពីសំណួរ និងការស្រាវជ្រាវរបស់ខ្លួនដែលឆ្លើយតបនឹងសំណួរនេះ ។*

***ជំហានទី៩ :*** *គ្រូណែនាំសិស្សថា ក្រុមនីមួយៗត្រូវមើលសំណួរឡើងវិញ គឺក្នុងករណីដែលមានការអនុញ្ញាតពីគ្រូ ។*

***ជំហានទី១០ :*** *គ្រូពន្យល់ធាតុផ្សំនៃការវាយតម្លៃសម្រាប់ក្រុមស្រាវជ្រាវ និងចែកក្រដាសណែនាំសម្រាប់ការឡើងបង្ហាញ ។ សិស្សម្នាក់ទទួលបាន៣ពិន្ទុ ដែលរួមមានពិន្ទុបន្ទាប់បន្សំចំនួន៣ ។*

***ពិន្ទុសរុបរួមមាន :***

*ពិន្ទុបន្ទាប់បន្សំទី១ : ការវាយតម្លៃរបស់សិស្ស និងពិន្ទុសម្រាប់ការខិតខំប្រឹងប្រែង និងអនុវត្តរបស់ខ្លួន ។ សិស្សអាចទទួលបានពិន្ទុខ្ពស់បំផុត ៣ពិន្ទុ ។*

*ពិន្ទុបន្ទាប់បន្សំទី២ : ការវាយតម្លៃរបស់សមាជិកក្រុម និងពិន្ទុសម្រាប់ការខិតខំប្រឹងប្រែង និងការអនុវត្តរបស់សមាជិកម្នាក់ៗ ។ សិស្សអាចទទួលបានពិន្ទុខ្ពស់បំផុត ៣ពិន្ទុ ។*

*ពិន្ទុបន្ទាប់បន្សំទី៣ : ការវាយតម្លៃរបស់គ្រូ និងពិន្ទុសម្រាប់ការខិតខំប្រឹងប្រែង និងការអនុវត្តរបស់សមាជិកម្នាក់ៗ ។ សិស្សអាចទទួលបានពិន្ទុខ្ពស់បំផុត ៣ពិន្ទុ ។*

*ពេលវេលាប៉ាន់ស្មានសម្រាប់ជំហានទី៧ដល់ទី១០ គឺ១៥ នាទី*

***ជំហានទី១១ :*** *គ្រូពន្យល់សិស្សថា មួយសប្តាហ៍មុនពេលថ្ងៃឡើងបង្ហាញ ក្រុមនីមួយៗត្រូវមកជួបគ្រូពី៥ ទៅ១០ នាទី ដើម្បីពិភាក្សាអំពីការស្រាវជ្រាវ និងពីរបៀបដែលសមាជិកក្រុមនីមួយៗចូលរួមចំណែកក្នុងការឡើងបង្ហាញរបស់ក្រុម ។ ក្រុមនីមួយៗត្រូវតែបង្ហាញអំពីការរៀបចំរចនាសម្ព័ន្ធក្នុងការឡើងពន្យល់ ។ ប្រសិនបើការស្រាវជ្រាវ និងការឡើងពន្យល់*

របស់ក្រុមមានការរៀបចំបានល្អ គ្រូត្រូវលើកទឹកចិត្តក្រុមនោះ ហើយប្រាប់ឲ្យបន្តកិច្ចការរបស់ខ្លួនក្នុងការឡើងបង្ហាញ ។ ប្រសិនបើក្រុមរៀបចំមិនបានល្អ ឬត្រូវធ្វើការផ្លាស់ប្តូរមួយចំនួន គ្រូគួរជួយក្រុមនោះដោយផ្តល់ជាយោបល់ ។ ប្រសិនបើក្រុមមិនបានរៀបចំអ្វីទាំងអស់ ឬប្រសិនបើគ្រូយល់ឃើញថា ក្រុមនេះមិនទាន់ត្រៀមខ្លួនរួចរាល់នៅឡើយសម្រាប់ការឡើងបង្ហាញ គ្រូត្រូវប្រាប់សមាជិកក្រុមនោះថា ពិន្ទុរបស់ក្រុមត្រូវកាត់បន្ថយពី១ ទៅ២ពិន្ទុ ហើយគ្រូផ្លាស់ប្តូរពេលឡើងពន្យល់របស់ក្រុមនេះទៅថ្ងៃក្រោយទៀត ដើម្បីឲ្យក្រុមនេះត្រៀមខ្លួន ។ នេះអាចត្រូវបានធ្វើតែក្នុងករណីដែលក្រុមនេះពិតជាមិនបានរៀបចំអ្វីទាំងអស់ ហើយត្រូវការពេលវេលាបន្ថែម ។ ប្រសិនបើក្រុមនេះត្រូវការជំនួយខ្លះពីគ្រូ ឬជួបការលំបាកដោយសារខ្វះខាតប្រភពព័ត៌មាន គ្រូមិនគួរកាត់បន្ថយពិន្ទុរបស់សមាជិកក្រុមនោះទេ ប៉ុន្តែត្រូវតែពន្យារពេលការឡើងបង្ហាញទៅថ្ងៃក្រោយវិញ ។

## ថ្ងៃឡើងពន្យល់

**ជំហានទី១** : គ្រូសួរក្រុមសិស្សថា តើបានត្រៀមខ្លួនរួចហើយឬនៅ ដើម្បីឡើងពន្យល់ ។ ប្រសិនបើត្រៀមរួចរាល់អស់ហើយ ក្រុមត្រូវបង្ហាញពីការស្រាវជ្រាវរបស់ខ្លួន ។

**ជំហានទី២** : គ្រូត្រូវពិនិត្យមើលពេលវេលា ឬចាត់តាំងសិស្សម្នាក់ៗឲ្យផ្ទៀងផ្ទាត់ពេលវេលា ។

**ជំហានទី៣** : បន្ទាប់ពីការឡើងពន្យល់ ក្រុមនេះត្រូវទទួលសំណួរពីសិស្សផ្សេងទៀត និងពីគ្រូ ។

**ជំហានទី៤** : (ឥតកំណត់) : គ្រូឲ្យសិស្សទាំងអស់ផ្តល់យោបល់អំពីចំណុចល្អ១ ឬ២ ដែលក្រុមមួយបានធ្វើនៅក្នុងការស្រាវជ្រាវ និងការឡើងពន្យល់អំពីចំណុចដែលធ្វើឲ្យកាន់តែប្រសើរឡើង១ ឬ២នៅក្នុងក្រុម ។ ការរិះគន់គួរតែជាការរិះគន់បែបស្ថាបនា មិនមែនជាការរិះគន់បំផ្លាញ ហើយនឹងមិនប៉ះពាល់ដល់ពិន្ទុរបស់សិស្សទេ ។

**ជំហានទី៥** : គ្រូណែនាំឲ្យសិស្សសរសេរឈ្មោះ និងបំពេញតារាងនៅក្នុងទំព័របន្ទាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រូគួរតែបញ្ជាក់ថា អ្វីដែលសិស្សបានសរសេរសម្រាប់ការឲ្យយោបល់ និងពិន្ទុដែលខ្លួនផ្តល់ឲ្យមិត្តភក្តិរបស់ខ្លួន គឺមានលក្ខណៈជាអនាមិក ។ នេះគឺជាចំណុចសំខាន់ដែលត្រូវតែបញ្ជាក់ឲ្យបានច្បាស់ ។

## ឯកសារណែនាំសម្រាប់សិស្សអំពីការឡើងពន្យល់ :

***សិស្ស*** : អ្នកនឹងត្រូវគេវាយតម្លៃលើការបូកសរុបពិន្ទុ៣នាក់ដាច់ដោយឡែកពីគ្នា ៖

**ពិន្ទុទី១** គឺជាការវាយតម្លៃទៅលើការអនុវត្តរបស់ខ្លួនឯង ។ អ្នកអាចផ្តល់ពិន្ទុឲ្យខ្លួនឯងពី១ ទៅ៣ពិន្ទុ ។ ការដាក់ពិន្ទុចំនួន៣ពិន្ទុមានន័យថា អ្នកជឿជាក់ថា អ្នកសម្តែងបានល្អ ហើយបានរួមចំណែកយ៉ាងច្រើននៅក្នុងក្រុម ។

**ពិន្ទុទី២** គឺជាការវាយតម្លៃរបស់សមាជិកនៅក្នុងក្រុមអំពីការសម្តែងរបស់អ្នក ។ អ្នកអាចទទួលបានពិន្ទុពី១ ទៅ៣ ពិន្ទុ ហើយ៣ពិន្ទុ គឺជាពិន្ទុខ្ពស់បំផុតដែលអ្នកអាចទទួលបាន ។ សមាជិកនៅក្នុងក្រុមត្រូវសរសេរយោបល់យ៉ាងតិចមួយ អំពីថាតើហេតុអ្វីបានជាគេគិតថា អ្នកគួរទទួលបានពិន្ទុដែលគេផ្តល់ឲ្យ ។ គ្រប់យោបល់ និងពិន្ទុដែលផ្តល់ឲ្យដោយសមាជិកក្រុមនឹងនៅជាអនាមិក ។

**ពិន្ទុទី៣** គឺជាការវាយតម្លៃរបស់គ្រូទៅលើការសម្តែងរបស់អ្នក ។ អ្នកអាចទទួលបានពិន្ទុពី១ ទៅ៣ពិន្ទុ ។ ៣ពិន្ទុ មាន

| ការឡើងពន្យល់របស់សិស្ស | ការឡើងពន្យល់<br>មិនល្អ ១ពិន្ទុ | ការឡើងពន្យល់<br>បានល្អ ២ពិន្ទុ | ការឡើងពន្យល់<br>បានល្អណាស់ ៣ពិន្ទុ |
|---|---|---|---|
| សិស្សដាក់ពិន្ទុឲ្យខ្លួនឯង | | | |
| យោបល់របស់សិស្ស | | | |
| ការដាក់ពិន្ទុរបស់សមាជិកក្រុមទី១ | | | |
| យោបល់របស់សមាជិកក្រុម | | | |
| ការដាក់ពិន្ទុរបស់សមាជិកក្រុមទី២ | | | |
| យោបល់របស់សមាជិកក្រុម | | | |
| ការដាក់ពិន្ទុរបស់សមាជិកក្រុមទី៣ | | | |
| យោបល់របស់សមាជិកក្រុម | | | |
| ការដាក់ពិន្ទុរបស់សមាជិកក្រុមទី៤ | | | |
| យោបល់របស់សមាជិកក្រុម | | | |
| ការដាក់ពិន្ទុរបស់គ្រូ | | | |
| យោបល់របស់គ្រូ | | | |
| ពិន្ទុសរុប | | | |

ន័យថាអ្នកសម្ដែងបានល្អ ដោយផ្អែកទៅលើការសង្កេតរបស់គ្រូ និងការងាររបស់អ្នក ។ គ្រូផ្ដល់ការពន្យល់ដោយសង្ខេបពីមូលហេតុដែលគាត់ផ្ដល់ពិន្ទុទៅឲ្យសមាជិកក្រុមនីមួយៗ ។

## គារាងដាក់ពិន្ទុសម្រាប់ការឡើងពន្យល់របស់សិស្ស

## ច) បង្កើតបញ្ជី L : សកម្មភាពក្រោយគម្រោងស្រាវជ្រាវ

បញ្ជី«អ្វីដែលខ្ញុំបានសិក្សា»

ការពិពណ៌នា : សិស្សពិភាក្សា និងពិនិត្យមើលព័ត៌មានដែលបានសិក្សាអំពីរបបខ្មែរក្រហម ។

### វត្ថុបំណង

១) សិស្សសង្ខេបការសិក្សារបស់ខ្លួន ។

២) សិស្សវាយតម្លៃការសិក្សារបស់ខ្លួន ។

៣) សិស្សប្រមូលផ្ដុំ និងពិនិត្យមើលសម្ភារសិក្សាទាំងឡាយ ។

៤) សិស្សរៀបចំ និងបង្កើតការស្រាវជ្រាវរបស់ខ្លួន ។

### គ្រូបង្រៀន

***ជំហានទី១*** *: គ្រូណែនាំសិស្សឲ្យបង្កើតបញ្ជីមួយដែលមានរបាយការណ៍ពិត ឬគំនិតដែលខ្លួនបានរៀនអំពីរបបខ្មែរក្រហមនៅក្នុងរយៈកាលនៃការធ្វើការស្រាវជ្រាវ ។ សិស្សសរសេរអំពីព្រឹត្តិការណ៍ថ្មីៗដែលខ្លួនបានរៀន ក៏ដូចជាព្រឹត្តិការណ៍ដែលខ្លួនបានស្វែងយល់ពីមិត្តរួមក្រុម និងព័ត៌មានទាំងឡាយដែលខ្លួនបានរៀនពីមិត្តនៅក្នុងក្រុមផ្សេងទៀត ។*

*រយៈពេលប៉ាន់ស្មានសម្រាប់ជំហានទី១ គឺពី១៥ ទៅ២០ នាទី*

***ជំហានទី២*** *: គ្រូឲ្យសិស្សសរសេរនូវអ្វីដែលខ្លួនចូលចិត្ត និងអ្វីដែលខ្លួនមិនចូលចិត្តអំពីគម្រោងស្រាវជ្រាវនេះ ។*

***ជំហានទី៣*** *: គ្រូប្រាប់សិស្សម្នាក់ៗអំពីរបៀបដែលត្រូវបង្រៀនគម្រោងស្រាវជ្រាវរបស់ខ្លួន ប្រសិនបើសិស្សជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យ ។ ប្រសិនបើសិស្សជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាអំពីប្រធានបទរបស់ខ្លួន តើសិស្សរៀនអំពីប្រធានបទតាមវិធីដែលងាយបំផុតបានដោយរបៀបណា? តើសិស្សគិតថា គ្រូគួរបង្រៀនយ៉ាងដូចម្ដេច?*

*ពេលវេលាប៉ាន់ស្មានសម្រាប់ជំហានទី២និងទី៣ គឺ១០ នាទី*

***ជំហានទី៤*** *: គ្រូណែនាំឲ្យសិស្សផ្ដល់យោបល់ទៅលើការសរសេររបស់ខ្លួន ។ គ្រូគួរកត់ត្រានូវអ្វីដែលសិស្សទាំងអស់មានការចាប់អារម្មណ៍ ។ ឧទាហរណ៍ ប្រសិនបើសិស្សចូលចិត្តធ្វើគម្រោងស្រាវជ្រាវជាលក្ខណៈបុគ្គល គ្រូគួរតែបង្កើតសកម្មភាពនេះបន្ថែមទៀត ។ ប្រសិនបើសិស្សចូលចិត្តធ្វើការជាក្រុមនោះគ្រូត្រូវបង្កើតក្រុមបន្ថែមទៀត ។ នេះគឺជាសកម្មភាពដំបូងសម្រាប់ឲ្យគ្រូមើលឃើញពីវិធីដែលធ្វើឲ្យសិស្សមានការចាប់អារម្មណ៍ទៅលើសកម្មភាពសិក្សានៅក្នុងថ្នាក់ ។*

***ជំហានទី៥*** *: គ្រូប្រមូលយោបល់របស់សិស្សទាំងអស់ និងរក្សាទុកនៅក្នុងសំណុំឯកសារសិក្សា ។*

### ឆ) ដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតបឹងជើងឯក

គ្រូត្រូវធ្វើការមួយចំនួនដូចខាងក្រោម ៖

១) សុំការអនុញ្ញាតពីថ្នាក់គ្រប់គ្រងសាលា ។

២) សុំការអនុញ្ញាតពីមាតាបិតា ឬអាណាព្យាបាល ។

៣) រៀបចំទំនាក់ទំនងជាមួយអ្នកគ្រប់គ្រងបូជនីយដ្ឋាននៃវាលពិឃាតបឹងជើងឯក និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។

៤) រៀបចំមធ្យោបាយធ្វើដំណើរ ។

៥) រៀបចំការធ្វើដំណើរជាមួយសិស្ស ។

៦) រៀបចំអាហារថ្ងៃត្រង់ ។

៧) ប្រមូលថសោហ៊ុយធ្វើដំណើរពីសិស្ស ។

៨) ផ្ដល់ឲ្យសិស្សនូវបញ្ជីនៃព័ត៌មាន ឬសំណួរដែលត្រូវសួរនៅកន្លែងដែលត្រូវទៅទស្សនា ។

#### វត្ថុបំណង

១) សិស្សពង្រឹង និងពង្រីកការសិក្សារបស់ខ្លួន តាមរយៈដំណើរទស្សនកិច្ច ។

២) សិស្សពិនិត្យមើលទីតាំងដែលបានសិក្សានៅក្នុងថ្នាក់ ។

៣) សិស្សពិភាក្សាថា តើដំណើរទស្សនកិច្ចមានឥទ្ធិពលចំពោះការយល់ដឹងរបស់ខ្លួនអំពីទីតាំងទាំងនោះដូចម្ដេចខ្លះ?

៤) សិស្សវាយតម្លៃលើការសិក្សារបស់ខ្លួន ដែលជាលទ្ធផលនៃការធ្វើដំណើរទស្សនកិច្ច ។

# ផ្នែកទី៣ ៖ តារាងវាយតម្លៃ

## តារាងវាយតម្លៃក្នុងការឡើងពន្យល់

| | ១ | ២ | ៣ | ៤ | សរុប |
|---|---|---|---|---|---|
| ការរៀបចំ | មិត្តរួមថ្នាក់មិនយល់ពីការឡើងពន្យល់នេះបាន ដោយសារតែ ព័ត៌មានមិនតាមលំដាប់លំដោយ | មិត្តរួមថ្នាក់មានការលំបាកក្នុងការតាមដានការឡើងពន្យល់ ដោយសារតែសិស្សដែលឡើងពន្យល់និយាយវិលចុះ វិលឡើង | សិស្សបង្ហាញព័ត៌មានតាមលំដាប់លំដោយ ដែលមិត្តរួមថ្នាក់អាចតាមដានបាន | សិស្សបង្ហាញព័ត៌មានតាមលំដាប់លំដោយ និងគួរឲ្យចាប់អារម្មណ៍ ដែលមិត្តរួមថ្នាក់អាចតាមដានបាន | |
| ចំណេះដឹងលើប្រធានបទ | សិស្សក្ដាប់ព័ត៌មានមិនបាន ។ សិស្ស មិនអាចឆ្លើយនឹងសំណួរអំពីប្រធានបទនោះបាន | សិស្សមិនចាំព័ត៌មានបានល្អ ហើយអាចឆ្លើយបានតែសំណួរតូចៗ ប៉ុណ្ណោះ | សិស្សអាចឆ្លើយនឹងសំណួរដែលរំពឹងទុកទាំងអស់បានល្អ ប៉ុន្តែមិនអាចបកស្រាយឲ្យបានល្អិតល្អន់ ។ | សិស្សបង្ហាញឲ្យឃើញពីការយល់ដឹងពេញលេញ (ច្រើនជាងការរំពឹងទុក) ដោយបានឆ្លើយរាល់សំណួរទាំងអស់ ដោយមានការពន្យល់ និងបកស្រាយល្អិតល្អន់ | |
| ក្រាហ្វិក | សិស្សប្រើក្រាហ្វិកច្រើនហួសហេតុ ឬមិនមានក្រាហ្វិកសោះ | សិស្សប្រើក្រាហ្វិក ម្ដងម្កាល ដែលមិនសមស្របជាមួយអត្ថបទ និងការឡើងពន្យល់ | ក្រាហ្វិករបស់សិស្ស ទាក់ទងជាមួយអត្ថបទ និងការឡើងពន្យល់ | ក្រាហ្វិករបស់សិស្ស ពន្យល់ និងផ្ដល់អត្ថន័យបន្ថែមដល់អត្ថបទ និងការឡើងពន្យល់ | |
| យន្តការផ្សេងៗ | ការឡើងពន្យល់របស់សិស្សមានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍ចំនួន ៤ ឬច្រើនជាងនេះ | ការឡើងពន្យល់របស់សិស្សមានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍ចំនួន៣ | ការឡើងពន្យល់របស់សិស្សមានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍មិនលើសពី ២ | ការឡើងពន្យល់ពុំមានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍អ្វីទាំងអស់ | |
| ការប្រើប្រាស់ក្រសែភ្នែក | សិស្សអានរបាយការណ៍ទាំងអស់ដោយមិនសម្លឹងមើលមិត្តរួមថ្នាក់ | សិស្សសម្លឹងមើល មិត្តរួមថ្នាក់ម្ដងម្កាល ប៉ុន្តែនៅតែអានរបាយការណ៍ស្ទើរតែទាំងអស់ | សិស្សរក្សាការសម្លឹងមើលមិត្តរួមថ្នាក់ ភាគច្រើន ប៉ុន្តែនៅតែមើលកំណត់ជាញឹកញាប់ | សិស្សរក្សាការសម្លឹងមើលមិត្តរួមថ្នាក់ ហើយកម្រក្រឡេក មើលកំណត់ហេតុណាស់ | |
| វចនៈ | សិស្សនិយាយលំៗ , មិនត្រូវតាមពាក្យ ហើយនិយាយតិចៗ ដែលសិស្សអង្គុយនៅខាងក្រោយមិនអាច ឮបាន | សំឡេងរបស់សិស្សគឺ ខ្សោយ សិស្សអានពាក្យមិនត្រូវ មិត្តរួមថ្នាក់មានការពិបាកស្ដាប់ការពន្យល់ | សំឡេងរបស់សិស្សឮច្បាស់ល្អ សិស្សអានពាក្យត្រូវស្ទើរតែទាំងអស់ មិត្តរួមថ្នាក់ភាគច្រើនអាចស្ដាប់ឮការឡើងពន្យល់ ។ | សិស្សមានសំឡេង ច្បាស់ល្អ និងអានពាក្យបានត្រឹមត្រូវ ហើយមិត្តរួមថ្នាក់អាចស្ដាប់ឮការពន្យល់បានល្អ | |
| | | | | | សរុប |

## តារាងវាយតម្លៃរបាយការណ៍

| ការកំណត់ | ១. មិនអាចទទួលយកបាន | ២. ក្រោមការរំពឹងទុក | ៣. ស្មើនឹងការរំពឹងទុក | ៤. លើសពីការរំពឹងទុក | ពិន្ទុ |
|---|---|---|---|---|---|
| យន្តការនៃរបាយការណ៍ | | | | | |
| ការរៀបចំ | អត្ថន័យក្នុងផ្នែកជាច្រើននៃរបាយការណ៍មិនសមហេតុផល | អត្ថន័យមួយចំនួនដាក់មិនត្រូវកន្លែងនៅក្នុងរបាយការណ៍ ។ | អត្ថន័យមានលក្ខណៈសមស្របនៅគ្រប់ផ្នែកទាំងអស់នៃរបាយការណ៍ | ការរៀបចំបានល្អ បង្កភាពងាយស្រួលដល់ការអាន និងការយល់អំពីរបាយការណ៍ ។ | |
| រៀបរាប់សាច់រឿងបានពេញលេញ | ការរៀបសាច់រឿងមិនបានពេញលេញ | ចំណុចមួយចំនួននៃសាច់រឿងមិនត្រូវបាននិយាយ | សាច់រឿងចប់សព្វគ្រប់បានល្អ | បន្ថែមឧបករណ៍ផ្សេងៗដែលបន្ថែមគុណភាពនៃសាច់រឿង | |
| សោភ័ណភាព | របាយការណ៍របស់សិស្សមានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍ចំនួន ៤ ឬច្រើនជាងនេះ | របាយការណ៍ មានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍ចំនួន៣ | របាយការណ៍ មានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍មិនលើសពី២ | របាយការណ៍ពុំមានកំហុសអក្ខរាវិរុទ្ធ និងវេយ្យាករណ៍អ្វីទាំងអស់ | |
| ទម្រង់ | មានកំហុសជាច្រើនចំពោះទម្រង់របាយការណ៍ ដែលនាំឲ្យគ្មានប្រសិទ្ធភាព | មានកំហុសនៅក្នុងទម្រង់បន្តិចបន្តួច | ធ្វើតាមទម្រង់របាយការណ៍ត្រឹមត្រូវ | របាយការណ៍ល្អប្រសើរដែលពង្រីកលទ្ធផលរបស់របាយការណ៍ | |
| អក្ខរាវិរុទ្ធ | មានកំហុសអក្ខរាវិរុទ្ធច្រើន | មានកំហុសអក្ខរាវិរុទ្ធចំពោះពាក្យដែលមានវចនៈសព្ទដូចគ្នា | មិនមានកំហុសអក្ខរាវិរុទ្ធសោះ | | |
| វេយ្យាករណ៍ និងវណ្ណយុត្តិ | គ្រប់ទំព័រ ឬកថាខណ្ឌ មានកំហុស វេយ្យាករណ៍ និងវណ្ណយុត្តិច្រើន | មានកំហុសវេយ្យាករណ៍ និងវណ្ណយុត្តិមួយចំនួន | មានកំហុសវេយ្យាករណ៍ និងវណ្ណយុត្តិបន្តិចបន្តួច | មិនមានកំហុស វេយ្យាករណ៍ និងវណ្ណយុត្តិសោះ | |
| អត្ថន័យ | | | | | |
| រៀបរាប់អំពីបញ្ហាដែលបានលើកឡើង និងសង្ខេបសេចក្ដីសន្និដ្ឋាន | មិនបានបង្ហាញ | គ្រាន់តែនិយាយ «នេះគឺជាបញ្ហា» | រួមបញ្ចូលនូវលទ្ធផលសំខាន់ៗ និងអនុសាសន៍ | ច្បាស់លាស់ និងចប់ចុងចប់ដើមដែលធ្វើឲ្យរបាយការណ៍កាន់តែប្រសើរឡើង | |

## តារាងវាយតម្លៃសៀវភៅកំណត់ហេតុ និងវិត្តប័ណ្ណ

| | គួរយកជាគំរូ ៤ | ការសម្រេចបាន ៣ | អភិវឌ្ឍន៍ ២ | ចាប់ផ្ដើម ១ | ពិន្ទុសរុប |
|---|---|---|---|---|---|
| ការកត់ត្រាកំណត់ហេតុប្រចាំថ្ងៃ | ការកត់ត្រាត្រឹមត្រូវ ពេញលេញ និងល្អិតល្អន់ ។ | ការកត់ត្រាត្រឹមត្រូវ ពេញលេញ និងរួមមានចំណុចលម្អិតមួយចំនួន | ការកត់ត្រាត្រឹមត្រូវផ្នែកខ្លះពេញលេញ និងមានចំណុចលម្អិតបន្តិចបន្តួច | ការកត់ត្រាមិនច្បាស់លាស់ មិនពេញលេញ និងមានចំណុចលម្អិតបន្តិចបន្តួច | |
| ការកត់ត្រាក្នុងសៀវភៅ ការយល់ដឹង និងវាក្យសព្ទ | ការសង្ខេបសៀវភៅ សំណួរ និងវាក្យសព្ទទាំងអស់ត្រឹមត្រូវ និងពេញលេញ ។ | ការសង្ខេបសៀវភៅ សំណួរ និងវាក្យសព្ទទាំងអស់ត្រឹមត្រូវភាគច្រើនពេញលេញ | ការសង្ខេបសៀវភៅ សំណួរ និងវាក្យសព្ទទាំងអស់ត្រឹមត្រូវដោយផ្នែក និងពេញលេញ | ការសង្ខេបសៀវភៅ សំណួរ និងវាក្យសព្ទទាំងអស់ មិនច្បាស់លាស់ និងមិនពេញលេញ | |
| គម្រោងអំពីវិត្តប័ណ្ណ | វិត្តប័ណ្ណរួមបញ្ចូលចំណុច និងព័ត៌មានសំខាន់ៗទាំងអស់ ។ ការផលិតប្រកបដោយការច្នៃប្រឌិត និងស្អាតល្អ ។ រូបភាពដាក់ត្រូវកន្លែង និងគួរឲ្យចាប់ចិត្ត | វិត្តប័ណ្ណរួមបញ្ចូលចំណុចនិងព័ត៌មានសំខាន់ៗ ទាំងអស់ ។ ការផលិតប្រកបដោយការច្នៃប្រឌិត និងស្អាតល្អបន្តិច ។ វិត្តប័ណ្ណមានរូបភាព ។ | វិត្តប័ណ្ណរួមបញ្ចូលចំណុច និងព័ត៌មានសំខាន់ៗទាំងអស់ ។ ការផលិតពេញលេញតែខ្វះខាតរូបភាព និងការរៀបចំ ។ | វិត្តប័ណ្ណមិនមានរួមបញ្ចូលចំណុច និងព័ត៌មានសំខាន់ៗ ។ ការផលិតមិនបានល្អមិនពេញលេញ និងរៀបចំមិនបានល្អ ។ | |

## តារាងវាយតម្លៃការសូត្រកំណាព្យផ្ទាល់មាត់

| ការបែងចែក | ៣ | ២ | ១ | ០ |
|---|---|---|---|---|
| ការណែនាំ | អនុវត្តតាមការណែនាំ បានត្រឹមត្រូវទាំងអស់ | អនុវត្តតាមការណែនាំ បានត្រឹមត្រូវស្ទើរតែទាំងអស់ | អនុវត្តតាមការណែនាំបានត្រឹមត្រូវតែពីរបីចំណុចប៉ុណ្ណោះ | អនុវត្តតាមការណែនាំមិនបានត្រឹមត្រូវទាល់តែសោះ |
| ការតែងកំណាព្យ | ការតែងកំណាព្យឆ្លើយតបតាមតម្រូវការទាំងពីរ ៖ ទម្រង់នៃកំណាព្យអនុលោមតាមខ្នាតគំរូ កំណាព្យប្រើប្រាស់ពាក្យពេចន៍សមរម្យ ដើម្បីពណ៌នាពីសិស្សឲ្យបានត្រឹមត្រូវការតែងកំណាព្យអនុលោមទៅតាមខ្នាតគំរូដែលផ្ដល់ឲ្យ | កំណាព្យប្រើប្រាស់ពាក្យពេចន៍មិនសមរម្យក្នុងការពណ៌នាពីសិស្ស ឬកំណាព្យមិនអនុលោមទៅតាមខ្នាតគំរូដែលផ្ដល់ឲ្យ ។ កំណាព្យប្រើពាក្យពេចន៍សមរម្យ ដើម្បីពណ៌នាអំពីសិស្សឲ្យបានត្រឹមត្រូវ ។ | ការតែងកំណាព្យមិនបានអនុលោមទៅតាមខ្នាតគំរូដែលបានផ្ដល់ឲ្យ ឬប្រើពាក្យត្រឹមត្រូវក្នុងការពណ៌នាពីសិស្ស ។ | ការផលិតដែលដាក់ឲ្យធ្វើ មិនបានបញ្ចប់ឲ្យបានពេញលេញ |
| ការឡើងពន្យល់ | សិស្សអានឮៗ និងច្បាស់ល្អ និងផ្ដោតតែលើប្រធានបទ ។ មានឥរិយាបថល្អ ។ ក្រសែភ្នែកសម្លឹងទៅកាន់មិត្តរួមថ្នាក់ | សិស្សខ្វះចំណុចមួយក្នុងចំណោមចំណុចខាងក្រោម ៖ អានឮ ហើយច្បាស់ល្អ និងផ្ដោតតែទៅលើប្រធានបទ ។ មានឥរិយាបថល្អ ។ ក្រសែភ្នែកសម្លឹងទៅកាន់មិត្តរួមថ្នាក់ ។ | សិស្សខ្វះចំណុចច្រើនជាងមួយក្នុងចំណោមចំណុចខាងក្រោម ៖ អានឮៗ និងច្បាស់ល្អ និងផ្ដោតតែលើប្រធានបទ ។ មានឥរិយាបថល្អ ។ ក្រសែភ្នែកសម្លឹងទៅកាន់មិត្តរួមថ្នាក់ ។ | មិនបានបង្ហាញពីកិច្ចការដែលដាក់ឲ្យធ្វើ ។ |

## តារាងវាយតម្លៃការសរសេរតែងសេចក្ដី

ទំនាក់ទំនងដែលមានប្រសិទ្ធិភាព ៖ សិស្សសរសេរសម្រាប់ភាពខុសគ្នានៃទស្សនិកជន និងគោលបំណង (ឧទាហរណ៍ ទម្រង់ជានិទានកថា ការបញ្ចុះបញ្ចូល ការផ្ដល់ព័ត៌មាន) ដោយប្រើប្រាស់កថាខណ្ឌរៀបរយល្អ ដែលមានភស្តុតាងគាំទ្រគ្រប់គ្រាន់ ។

**កិច្ចការដែលត្រូវធ្វើ ៖** សរសេរតែងសេចក្ដីអំពីប្រធានបទដែលកំណត់ឲ្យ ឬប្រធានបទតាមជម្រើសរបស់សិស្ស ។

| ចំណុចអនុវត្ត | ល្អណាស់ | ល្អ | មធ្យម | មិនល្អ | មិនអាចទទួលយកបាន |
|---|---|---|---|---|---|
| ការអភិវឌ្ឍន៍គំនិត (២០ពិន្ទុ) | តែងសេចក្ដីមានភាពរស់រវើកហើយមានអំណះអំណាងគាំទ្រនៅគ្រប់ចំណុចទាំងអស់ ។ (១៨-២០ពិន្ទុ) | តែងសេចក្ដីមានភាពរស់រវើក ហើយចំណុចស្ទើរតែទាំងអស់ត្រូវបានគាំទ្រ ។ (១៦ - ១៧ពិន្ទុ) | តែងសេចក្ដីមាន ភាពរស់រវើក ប៉ុន្តែមិនច្បាស់ ។ អំណះអំណាងគាំទ្រអាចងាកចេញពីប្រធានបទ ។ (១៤ - ១៥ ពិន្ទុ) | តែងសេចក្ដីមិនច្បាស់លាស់ ហើយមានអំណះអំណាងគាំទ្រតិចតួច ឬងាកចេញពីប្រធានបទ ។ (១២ - ១៣ពិន្ទុ) | ខ្វះអំណះអំណាង ឬការរៀបចំ គំនិត ។ (០ - ១១ពិន្ទុ) |
| ការបរិយាយ (៥០ពិន្ទុ) | សរសេរបានល្អ, បរិយាយចំណុចទាំងអស់បានល្អ បកស្រាយព័ត៌មានបានច្បាស់ត្រឹមត្រូវ និងល្អិតល្អន់ដើម្បីគាំទ្រតែងសេចក្ដី ។ (៤៥ - ៥០ពិន្ទុ) | សរសេរបានល្អ ចំណុចភាគច្រើនត្រូវបានរៀបរាប់ ជាមួយនឹងព័ត៌មានច្បាស់លាស់ និងល្អិតល្អន់ដើម្បីគាំទ្រតែងសេចក្ដី ប៉ុន្តែអាចថា មានកំហុសអំពីការពិតបន្តិចបន្តួច (៤០ - ៤៤ពិន្ទុ) | សរសេរបានល្អបង្គួរ ។ ចំណុចមួយចំនួនត្រូវបានបរិយាយ ។ អាចថាមានកំហុសអំពីការពិត ឬព័ត៌មានមិនទាក់ទងមួយចំនួន ។ (៣៥ - ៣៩ពិន្ទុ) | របៀបសរសេរ មិនបានល្អ ។ មានកំហុសទូទៅ និងកំហុសអំពីការពិត ហើយអាចងាកចេញពីប្រធានបទ ។ (៣០ - ៣៤ពិន្ទុ) | របៀបសរសេរមិនល្អ ឬមិនមានការបញ្ជាក់ឲ្យបានល្អិតជាក់លាក់ណាមួយ ។ ចាកប្រធាន និងមានកំហុសអំពីការពិត (០ -២៩ពិន្ទុ) |
| ការរៀបចំ (២០ពិន្ទុ) | រៀបចំបានល្អ និងផ្ដោតទៅលើប្រធានបទ ។ (១៨-២០ពិន្ទុ) | មានការរៀបចំល្អ ជាមួយនឹងការរៀបរាប់មួយចំនួនតូចខុសកន្លែង ។ (១៦ - ១៧ពិន្ទុ) | ការរៀបចំច្បាស់ តែមិនបានល្អ ។ អាចថាមានការរៀបរាប់ជាច្រើនខុសកន្លែង ។ មានបញ្ហានៅក្នុងសេចក្ដីផ្ដើម និងសេចក្ដីបញ្ចប់ ។ មិនមានប្រធានប្រយោគ ។ (១៤ - ១៥ពិន្ទុ) | ការរៀបចំធ្វើឲ្យអ្នកអានភាន់ច្រឡំ, ការសរសេរអាចខ្វះការរៀបចំកថាខណ្ឌឲ្យបានត្រឹមត្រូវ, មិនមានឃ្លាភ្ជាប់សាច់រឿង, ខ្វះប្រធានប្រយោគ, ការបកស្រាយ គាំទ្រ ឬព័ត៌មាន ទាក់ទងឲ្យបានត្រឹមត្រូវ ។ (១២ - ១៣ពិន្ទុ) | មានរចនាសម្ព័ន្ធ តិចតួច ឬគ្មានតែម្ដង ។ តែងសេចក្ដីមិនមានចុងដើម, មិនមានគោលដៅច្បាស់លាស់ពីចំណុចមួយទៅចំណុចមួយទៀត ឬចាកប្រធានទាំងស្រុង ។ (០ - ១១ពិន្ទុ) |
| យន្តការ (១០ពិន្ទុ) | មិនមានកំហុសធំដុំ និងមានការពន្យល់ទូលំទូលាយ ។ (៩ - ១០ ពិន្ទុ) | មានកំហុសធំៗ ១ ឬ២ ប៉ុន្តែមានការពន្យល់ទូលំទូលាយ ។ (៨ពិន្ទុ) | មានកំហុសធំៗ ៣ ឬ៤ ប៉ុន្តែមានការពន្យល់បានល្អ ។ (៧ពិន្ទុ) | មានកំហុសធំៗ ៥ ឬ ៦ ប៉ុន្តែមានការពន្យល់បានល្អ ។ (៦ពិន្ទុ) | មានកំហុសធំៗ ៧ ឬច្រើនជាងនេះ ប៉ុន្តែមានការពន្យល់បានល្អ (០ -៥ពិន្ទុ) |

## តារាងវាយតម្លៃការសិក្សាប្រៀបធៀបអំពើប្រល័យពូជសាសន៍

| | ចាប់ផ្ដើម ១ | អភិវឌ្ឍន៍ ២ | ការសម្រេចបាន ៣ | គួរយកជាគំរូ ៤ | ពិន្ទុ |
|---|---|---|---|---|---|
| ប្រធានបទដែលយកចិត្តទុកដាក់ | របាយការណ៍អត់ចុងអត់ដើមហើយមិនចង្អុលបង្ហាញ ចំណុចជាក់លាក់ណាមួយ សម្រាប់ការប្រៀបធៀប ។ | និយាយដោយសង្ខេបអំពីប្រធានបទមួយសម្រាប់ការប្រៀបធៀប ប៉ុន្តែឲ្យព័ត៌មានបន្តិចបន្តួច | ពណ៌នាប្រធានបទសម្រាប់ការប្រៀបធៀបរឿងរ៉ាវពីរហើយផ្ដល់ ឧទាហរណ៍ជាច្រើនចំពោះរឿងរ៉ាវនីមួយៗ | រាយការណ៍បានច្បាស់លាស់ កំណត់ប្រធានបទសម្រាប់ការប្រៀបធៀបនិងផ្ដល់ព័ត៌មានលម្អិត ។ | |
| ផ្ដល់ព័ត៌មាន ដែលប្លែកពីគេ ចំពោះប្រធានបទនីមួយៗ | មិនមាននិយាយអំពីព័ត៌មាន ពិសេសណាមួយទេ | ផ្ដល់ព័ត៌មានប្លែកៗបន្តិចបន្តួច | ផ្ដល់ព័ត៌មានមួយចំនួនដែលជាចំណុចពិសេសសម្រាប់រឿងរ៉ាវនីមួយៗ | ផ្ដល់ព័ត៌មានពិសេស និងដែលគួរឲ្យចាប់អារម្មណ៍ ។ | |
| ផ្ដល់ព័ត៌មានអំពីរបៀបដែលរឿងរ៉ាវពីរមានភាពស្រដៀងគ្នា | មិនបានប្រៀបធៀបភាពដូចគ្នា នៃរឿងរ៉ាវទាំងពីរ ។ | គ្រាន់តែបង្ហាញវិធីសាស្ត្រមួយ ឬពីរ ដែលរឿងរ៉ាវទាំងពីរមានភាពដូចគ្នា | ផ្ដល់វិធីមួយចំនួនក្នុងការបង្ហាញភាពដូចគ្នានៃរឿងរ៉ាវទាំងពីរ ។ | ផ្ដល់វិធីជាច្រើនក្នុងការបង្ហាញភាពដូចគ្នានៃរឿងរ៉ាវទាំងពីរ | |
| ការរៀបចំបានល្អ | ខ្វះប្រធានប្រយោគ និងមិនមានលំដាប់លំដោយត្រឹមត្រូវ ។ | របាយការណ៍មានប្រធានឃ្លាតែមួយហើយលំដាប់លំដោយមានការភាន់ច្រឡំ ។ | របាយការណ៍រួម មានប្រធានប្រយោគមួយចំនួនហើយមានលំដាប់លំដោយល្អបន្តួរ ។ | គ្រប់ផ្នែកនីមួយៗ ផ្ដើមដោយប្រធានឃ្លាច្បាស់លាស់ និងផ្នែកនីមួយមានលំដាប់លំដោយល្អ ។ | |
| ច្បាស់ និងងាយស្រួលយល់ | ពិបាកតាមដាន ។ | ភាគច្រើនពិបាក តាមដាននិងយល់ ។ | ភាគច្រើនមានភាពងាយស្រួលស្វែងយល់ ។ | មានភាពងាយស្រួលអាននិងតាមដានព័ត៌មាន ។ | |
| វេយ្យាករណ៍ និងអក្ខរាវិរុទ្ធត្រឹមត្រូវ | មានកំហុសវេយ្យាករណ៍និងអក្ខរាវិរុទ្ធច្រើន | មានកំហុស វេយ្យាករណ៍និងអក្ខរាវិរុទ្ធបន្តិច បន្តួច | មានកំហុសវេយ្យាករណ៍និងអក្ខរាវិរុទ្ធតែមួយឬពីរ | វេយ្យាករណ៍ និងអក្ខរាវិរុទ្ធទាំងអស់ត្រឹមត្រូវ | |
| | | | | | **ពិន្ទុសរុប** |

# ផ្នែកទី៩ : ប្រភពធនធាន និងឯកសារយោង

## តារាង ខេ-ដាប៊ែលយូ-អិល (K-W-L)

តារាង K-W-L គឺជាវិធីសាស្ត្របង្រៀនមួយ ដែលគ្រូអាចប្រើប្រាស់ដើម្បីក្រើនរំឭកនូវចំណេះដឹងរបស់សិស្សពីមុន ដោយផ្ដើការសាកសួរពីអ្វីដែលសិស្សបានដឹងរួចមកហើយ ។ បន្ទាប់មកទៀត សិស្សកំណត់គោលដៅចំពោះអ្វីដែលសិស្សចង់រៀន ហើយបន្ទាប់ពីបញ្ចប់មេរៀនមួយ ឬមុខវិជ្ជាទាំងមូល សិស្សពិភាក្សានូវអ្វីដែលខ្លួនបានរៀន ។ តារាង K-W-L ជួយសិស្សឲ្យអនុវត្តវិធីសាស្ត្រត្រិះរិះកម្រិតខ្ពស់ ក៏ដូចជាជួយសិស្សឲ្យពិនិត្យមើលពីភាពជឿនលឿនឆ្ពោះទៅរកគោលដៅរបស់ខ្លួន ។ ខាងក្រោមនេះគឺជាឧទាហរណ៍នៃតារាង K-W-L ។

| *K*<br>អ្វីដែលខ្ញុំបានដឹង | *W*<br>អ្វីដែលខ្ញុំចង់ | *L*<br>អ្វីដែលខ្ញុំបានរៀន |
|---|---|---|
| | | |

## តារាងទំនាក់ទំនងនៃសំណុំវែនដ្យាក្រាម (Venn Diagram)

តារាងទំនាក់ទំនងនៃសំណុំដែលភាសាអង់គ្លេសហៅថា វែន ដ្យាក្រាម គឺត្រូវបានបង្កើតឡើងរវាងរង្វង់២ ឬច្រើនជាងនេះ ហើយដាក់ឲ្យត្រួតស៊ីគ្នា ។ តារាងនេះជាញឹកញយ ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអំពីទំនាក់ទំនងរវាងបណ្ដុំ២ ឬច្រើន ។ តារាងទំនាក់ទំនងនៃសំណុំមានសារប្រយោជន៍សម្រាប់ពិនិត្យមើលភាពដូចគ្នា និងភាពខុសគ្នានៃចរិតលក្ខណៈ ។

តារាងនេះជាញឹកញយ ត្រូវបានប្រើជាសកម្មភាពមុនការសរសេរ ដើម្បីជួយឲ្យសិស្សមានគំនិត ឬការដកស្រង់អត្ថបទមុនពេលសរសេរអត្ថបទបែបប្រៀបធៀប ។ សកម្មភាពនេះអាចឲ្យសិស្សរៀបចំភាពដូចគ្នា និងភាពខុសគ្នាប្រកបដោយភាពរស់រវើក ។



## សកម្មភាពធ្វើការជាដៃគូ (គិត ធ្វើការជាដៃគូ ចែករំលែក)

សកម្មភាពធ្វើការជាដៃគូ គឺជាវិធីសាស្ត្រមួយដែលរៀបចំឡើងដើម្បីផ្ដល់ឲ្យសិស្សនូវ «បញ្ញាញាណ» លើប្រធានបទទាំងឡាយដែលត្រូវបានផ្ដល់ឲ្យ និងអនុញ្ញាតឲ្យសិស្សបង្កើតឡើងនូវការរិះគិតរៀងៗខ្លួន ហើយចែករំលែកគំនិតទាំងនេះជាមួយសិស្សម្នាក់ទៀត ។ សកម្មភាពធ្វើការជាដៃគូលើកទឹកចិត្តដល់ការឆ្លើយតបកម្រិតខ្ពស់ និងជួយរក្សាសិស្សឲ្យផ្ដោតលើកិច្ចការរបស់ខ្លួន ។ សកម្មភាពធ្វើការជាដៃគូក៏បានជួយឲ្យសិស្សអភិវឌ្ឍការស្វែងយល់ប្រកបដោយការត្រិះរិះអំពីប្រធានបទមួយ អភិវឌ្ឍសមត្ថភាពក្នុងការយល់ដឹងជ្រួតជ្រាបអំពីព័ត៌មាន និងធ្វើសេចក្ដីសន្និដ្ឋាន ហើយនិងអភិវឌ្ឍសមត្ថភាពក្នុងការពិចារណាទស្សនៈផ្សេងៗទៀត ។ សកម្មភាពធ្វើការជាដៃគូធ្វើឡើងដោយមានការណែនាំពីគ្រូ អំពីសម្ភារ ឬសំណួរដែលសិស្សត្រូវពិចារណា និងពិភាក្សា ។ សកម្មភាពមានប្រយោជន៍ចំពោះគ្រូទាំងឡាយណាដែលសិស្សមានការអៀនខ្មាស ដោយសារសកម្មភាពនេះផ្ដល់ឱកាសឲ្យសិស្សប្រភេទនេះ ពិភាក្សាគំនិតរបស់ខ្លួនជាមួយសិស្សម្នាក់ទៀត ជាជាងពិភាក្សាជាមួយសិស្សទាំងអស់នៅក្នុងថ្នាក់ ។ ដូចគ្នានេះដែរ សកម្មភាពនេះ អនុញ្ញាតឲ្យសិស្សស្វែងយល់ និងធ្វើការជំទាស់នឹងគំនិតរបស់ខ្លួនបានស៊ីជម្រៅជាងការពិភាក្សានៅក្នុងថ្នាក់រៀនទាំងមូល ។ បន្ទាប់ពីបញ្ចប់ការពិភាក្សាជាដៃគូ គ្រូអាចធ្វើការពិភាក្សានៅក្នុងថ្នាក់ទាំងមូល ឬជម្រើសមួយទៀត គ្រូអាចឲ្យសិស្សសរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រា ។ ពេលសិស្សសរសេររួចរាល់ហើយ គ្រូអាចប្រមូល និងពិនិត្យមើលសៀវភៅកត់ត្រានីមួយៗដើម្បីវាយតម្លៃការយល់ដឹងរបស់សិស្សម្នាក់ៗ ។ ជម្រើសមួយទៀតគ្រូអាចឲ្យសិស្ស«ចែករំលែក» សៀវភៅកត់ត្រាដោយផ្លាស់ប្ដូរជាមួយក្រុមផ្សេងទៀត ដែលមានសៀវភៅកត់ត្រា និងចម្លើយដែរ ។ វិធីសាស្ត្រនេះ មានសារប្រយោជន៍ ដោយសារបច្ចុប្បន្នសិស្សមិនចង់បង្ហាញចម្លើយរបស់ខ្លួនទេ ប៉ុន្តែចង់បង្ហាញចម្លើយរបស់អ្នកដទៃជាង ។ វិធីសាស្ត្រនេះអាចជួយលើកទឹកចិត្តដល់សិស្សឲ្យមានចិត្តចូលរួមនៅក្នុងសកម្មភាពដោយសារតែទស្សនៈរបស់ខ្លួនមិនត្រូវបានបង្ហាញ នៅពេលដែលខ្លួននិយាយ ។

## សកម្មភាពធ្វើការជាក្រុមជីក-សរ (JIGSAW ACTIVITY)

នៅក្នុងសកម្មភាពធ្វើការជាក្រុម សិស្សត្រូវបានបែងចែកទៅជាក្រុមដែលមានសមាជិកពី៤ ទៅ៦នាក់ ។ សិស្សម្នាក់ត្រូវបានតែងតាំងជាប្រធានក្រុម ។ ក្រុមនីមួយៗត្រូវបានចាត់តាំងឲ្យធ្វើការសិក្សាលើផ្នែកមួយ ហើយក្លាយទៅជាអ្នកជំនាញនៅក្នុងផ្នែកនោះ ។ អ្នកជំនាញនីមួយៗនៅក្នុងក្រុមនឹងត្រូវបានបែងចែកទៅក្រុមផ្សេងៗទៀត ដើម្បីបង្រៀនសមាជិកនៃក្រុមផ្សេងទៀតអំពីប្រធានបទរបស់ខ្លួន ។

## ភាពយន្តឯកសារមួយចំនួន

«កុមារកម្ពុជា» (១៩៧៩)

«ទីក្រុងភ្នំពេញ» (ឆ្នាំ១៩៧៩)

«ទួលស្លែងនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩»

«នៅខាងក្រោយជញ្ជាំងនៃមន្ទីរស-២១» (២០០៧)

## គន្ថនិទ្ទេស


Ea, Meng-Try and Sorya Sim. *Victims and Perpetrators: The Testimony of Young Khmer Rouge Cadres at S-21* (2001).

Osman Ysa. *Oukoubah: Genocide Justice for the Cham Muslims under Democratic Kampuchea* (2002).
Huy, Vannak. *The Khmer Rouge Division 703: From Victory to Self-Destruction* (2003).

Heder, Stephen P., with Brian Tittemore. *Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge* (2003).

Linton, Suzannah. *Reconciliation in Cambodia* (2004).

Ea, Meng-Try. *The Chain of Terror: The Khmer Rouge Southwest Zone Security System* (2004).

Cougill, Wynne with Pivoine Pang, Chhayran Ra, and Sopheak Sim. *Stilled Lives: Photographs from the Cambodian Genocide* (2004).

Chigas, George. *Tum Teav: A Translation of a Cambodian Literary Classic* (2005).

Ysa, Osman. *The Cham Rebellion: Survivors' Stories from the Villages* (2006).

Ciorciari, John D. , ed. *The Khmer Rouge Tribunal* (2006).

Corciari, John D. and Anne Heindel, eds. *On Trial: The Khmer Rouge Accountability Process (2009).*

Beang, Pivoine and Wynne Cougill. *Vanished: Stories from Cambodia's New People Under Democratic Kampuchea* (2006).

inton, Alex. *Night of The Khmer Rouge: Genocide and Justice in Cambodia* (2007)

Dy, Khamboly. *A History of Democratic Kampuchea* (2007).

Harris, Ian. *Buddhism under Pol Pot* (2007).

Bergstrom, Gunnar. *Living Hell: Democratic Kampuchea 1978* (2008)

Huy, Vannak. *Bou Meng, A Survivor from Khmer Rouge Prison S-21: Justice for the Future, Not for the Victims* (2008)


## សៀវភៅបកប្រែជាភាសាខ្មែរ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបកប្រែសៀវភៅពីភាសាអង់គ្លេសមកជាភាសាខ្មែរ (ពិនិត្យកែសម្រួលដោយ លោក ឆាំង យុ) ។ យើងមិនបកប្រែពីភាសាខ្មែរទៅភាសាផ្សេងៗទៀតនោះទេ ។ សូមកត់ចំណាំថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនផ្តល់មូលនិធិសម្រាប់ការបកប្រែ ឬការបោះពុម្ពសៀវភៅនោះទេ ។ អ្នកនិពន្ធទទួលខុសត្រូវក្នុងការបកប្រែ និងបោះពុម្ព ឬទទួលខុសត្រូវក្នុងការស្វែងរកមូលនិធិដើម្បីគោលបំណងទាំងពីរ ។


Ung, Loung. *First They Killed My Father: A Daughter of Cambodia Remembers*
Translated by Norng Lina (2002)

Frank, Anne. *The Diary of a Young Girl*
Translated by Ser Sayana (2002)

Chandler, David. *Voices from S-21: Terror and History in Pol Pot's Secret Prison*
Translated by Sour Bonsou (2003)

Ung, Loung. *Lucky Child*
Translated by Phat Rachana (2004)

Leclère, Adhemard. *Histoire du Cambodge Depuis Le 1er Siècle de Notre Ère*
Transllted by Tep Meng Kheang (2005)

Becker, Elizabeth. *When the War Was Over: Cambodia and the Khmer Rouge Revolution*
Translated by Sokha Irene (2005)

Yimsut, Ronnie. *Journey to Freedom*
Translated by Eng Kok-Thay (2006)

Chanda, Nayan. *Brother Enemy*
Translated by Tep Meng Khean (2007)

Ciorciari, John D. *The Khmer Rouge Tribunal*
Translated by Dy Khamboly (2008)

Javis, Helen and Fawthrop, Tom. *Getting Away with Genocide*
Translated by Chy Terith and Charya Chum (2009)





***រូបខាងលើ*** ៖ *សើន របស់សាសនាអ៊ីស្លាមនៅភូមិស្វាយឃ្លាំង ខេត្តកំពង់ចាម ដែលមានអាយុកាលជាង ១០០ឆ្នាំ។ អ្នកភូមិបានឲ្យដឹងថា កាលពីមុន សើន ត្រូវបានប្រើប្រាស់ជាកន្លែងប្រកាសព័ត៌មាន ដើម្បីជូនដំណឹងអំពីពេលវេលានៃការសូត្រធម៌ និងតាមដានមើលដំណើរព្រះច័ន្ទ ដើម្បីកំណត់អំពីរដូវរ៉ាមាដន។ រូបថត ៖ ជី ទេរិទ្ធ។*

***រូបខាងក្រោម*** ៖ *កម្មាភិបាលសិល្បៈនារីខ្មែរក្រហម ថតរូបនៅក្បែរបឹងមួយ ដែលមានវិហារអ៊ីស្លាមនៅពីក្រោយ ។*

*ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

## គេហទំព័រមួយចំនួន

មជ្ឈមណ្ឌលឯកសារកម្ពុជា

**www.dccam.org**

វិទ្យាស្ថានស្ទីករីត
**http://www.cambodiasri.org**

CIA World Factbook
- Iraq, (1996)
**http://www.umsl.edu/services/govdocs/wofact96/125.htm**

- Rwanda, (1993)
**http://www.umsl.edu/services/govdocs/wofact93/wf940194.txt**

- Yugoslavia, (1993)
**http://www.theodora.com/wfb1989/yugoslavia/yugoslavia_geography.html**

The Genocide Research Project, University of Memphis & Penn State University
**http://www.people.memphis.edu/~genocide/**

Human Rights Watch,
- Genocide in Iraq – The Anfal Campaign Against the Kurds, Report Summary
**http://www.hrw.org/legacy/english/docs/2006/08/14/iraq13979.htm**

- The Anfal Trial, "Questions and Answers"
**http://www.hrw.org/legacy/english/docs/2006/08/14/iraq13982.htm**

- Alison Des Forges, "Leave None to Tell the Story", March 1999
**http://www.hrw.org/legacy/reports/1999/rwanda/Geno1-3-04.htm#P95_39230**

Institute for the Study of Genocide
**http://www.isg-iags.org**

Montreal Institute for Genocide and Human Rights Studies
**http://www.migs.org**

Web Genocide Documentation Centre
**http://www.ess.uwe.ac.uk/genocide.htm**

Centre for Comparative Genocide Studies, Macquarie University
**http://www.genocide.mq.edu.au/ccgs.htm**

Australian Institute for Holocaust and Genocide Studies, Shalom College
**http://www.aihgs.com**

Yale Genocide Studies Program
**http://www.yale.edu/gsp/**

Danish Center from Holocaust and Genocide Studies
**http://www.dchf.dk/**

Center for the Study of the Holocaust, Genocide, & Human Rights
**http://www.webster.edu/~woolflm/cshghr.html**

United States Holocaust Memorial Museum
**http://www.ushmm.org**

"The Holocaust: An Overview"
**http://www.ushmm.org/education/foreducators/resource/pdf/history.pdf**

Personal Histories: Individuals
**http://www.ushmm.org/museum/exhibit/online/phistories/**

The Genocide Factor
**http://www.genocidefactor.com**

Center for Holocaust, Genocide & Peace Studies, University of Nevada, Reno
**http://www.unr.edu/chgps/blank.htm**

Fortunoff Video Archive for Holocaust Testimonies
**http://www.library.yale.edu/testimonies/index.html**

**Public Broadcasting Service (PBS)**

"Srebrenica: A Cry From the Grave"
**http://www.pbs.org/wnet/cryfromthegrave/**

Cultural Survival
**http://www.cs.org**

## ការប្រកាសអាសន្នជាបឋម ការទប់ស្កាត់ និងការកាត់ទោសបទឧក្រិដ្ឋ

Prosecutor v. Jean Paul Akayesu, "Judgment," Case No. ICTR-96-4-T (Sept. 2, 1998).

Minorities at Risk Project, University of Maryland
**http://www.bsos.umd.edu:80/cidcm/mar/**

Gregory H. Stanton, "The Eight Stages of Genocide," Genocide Watch, (1996)

Genocide Watch site

http://www.genocidewatch.co
The Grotian Moment Blog
http://law.case.edu/grotian-moment-blog

The Iraqi High Tribunal, "Verdict Decision," 1/2nd Criminal/ 2006, (June 24, 2007)
Available at The Grotian Moment Blog:
http://law.case.edu/grotian-moment-blog/documents/anfal_verdict_part_6.pdf

Prevent Genocide
http://www.preventgenocide.org

Rome Statue of the International Criminal Court
http://www.un.org/law/icc/index.html

Campaign to End Genocide
http://www.endgenocide.org/

Genocide Prevention Project
http://www.genocidepreventionmonth.org/

Center for the Study of Genocide and Human Rights
cghr.newark.rutgers.edu

Genocide Prevention Month
http://www.genocidepreventionmonth.org/

United Nations: Office of the Special Adviser on the Prevention of Genocide
OSAPG. The office is mandated to analyze situations that might turn genocidal and is empowered to take measures to prevent genocide.
http://un.org/preventgenocide/adviser/mandate.shtml



**រូបខាងលើ** ៖ អតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី (ឆ្វេង) និង វ៉ន វ៉េត (ស្តាំ) អតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច អង្គុយពិភាក្សាក្នុងអំឡុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូបរទេស ។ **រូបខាងក្រោម** ៖ កុមារ និងយុវជនកំពុងហូបបាយនៅក្នុងសហករណ៍មួយក្នុងរបបខ្មែរក្រហម ក្នុងខែសីហា ឆ្នាំ១៩៧៨ អំឡុងពេលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូមកពីប្រទេសស៊ុយអែត ។ អាហារទាំងនេះត្រូវបានរៀបចំទុកជាមុន ដើម្បីបន្លំភ្នែកគណៈប្រតិភូបរទេស ។ រូបថត ៖ ហ្គុណា បើកស្រ្តម ។



## អង្គការក្រៅរដ្ឋាភិបាលមួយចំនួន

មជ្ឈមណ្ឌលព័ត៌មានស្បៀងអាហារអាស៊ី
វាលពិឃាតបឹងជើងឯក
មជ្ឈមណ្ឌលឯកសារកម្ពុជា
សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
អង្គការសុខភាពពិភពលោក

## ការណែនាំបន្ថែមសម្រាប់គ្រូ លើការសិក្សាលំហាត់ប្រៀបធៀបនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ

### *សេចក្តីអត្ថាធិប្បាយ និងសេចក្តីណែនាំសម្រាប់សំណួរ ៖*

### *តើអ្វីខ្លះជាភាពដូចគ្នា និងភាពខុសគ្នារវាងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ?*

តារាង និងមតិយោបល់ទាំងឡាយខាងក្រោមគឺជាគំនិតមួយចំនួន ដើម្បីជួយគ្រូក្នុងការពិភាក្សា និងជំរុញការគិតរបស់សិស្ស ។ តារាងនេះ មិនមែនជាការកំណត់នូវបញ្ជីជាស្ថាពរនៃភាពដូចគ្នា និងភាពខុសគ្នានោះទេ ។ តារាងគឺគ្រាន់តែបង្កើតឡើងជាជំនួយដល់គ្រូ នៅពេលពិភាក្សាចម្លើយរបស់សិស្ស ។ គ្រូត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់តារាងនេះ ជាចំណុចចាប់ផ្តើមមួយសម្រាប់ការវិភាគប្រកបដោយលក្ខណៈមួយទូលំទូលាយជាង ថាតើអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងឡាយមានភាពខុសគ្នា និងដូចគ្នាយ៉ាងដូចម្តេច និងថាតើបទពិសោធន៍ក្នុងអំឡុងពេលនៃរបបដ៏ឃោរឃៅនេះមានភាពដូចគ្នា និងភាពខុសគ្នាយ៉ាងដូចម្តេច ។

ចំណុចជាច្រើនត្រូវតែគូសបញ្ជាក់ទាក់ទងជាមួយនឹងតារាង និងលំហាត់ដែលមានជាប់ពាក់ព័ន្ធទាំងឡាយ ។

ទី១ មិនមែនមនុស្សគ្រប់រូបស្ថិតនៅក្នុងជំពូក“ជនដៃដល់” ឬស្ថិតនៅក្នុងជំពូក“ជនរងគ្រោះ”ទាំងអស់នោះទេ ។ ជាញឹកញយ“ជនដៃដល់”អាចក្លាយទៅជា“ជនរងគ្រោះ” ឬមានទំនាក់ទំនងជាមួយនឹងជនរងគ្រោះ ។ អ្នកនឹងកត់សម្គាល់ឃើញថា នៅក្នុងសក្ខីកម្មមួយចំនួនអ្នកដែលមានទំនាក់ទំនងជាមួយនឹងជនរងគ្រោះ នឹងអាចក្លាយទៅជា“ជនដៃដល់”ភ្លាមៗ ។ ដូចគ្នានោះដែរ ជនដៃដល់នឹងអាចក្លាយទៅជាជនរងគ្រោះយ៉ាងងាយ ពេលកម្មាភិបាលធ្វើការជាមួយគ្នាមានការសង្ស័យទៅលើភក្តីភាពរបស់ខ្លួន ។ គ្រូគួរលើកទឹកចិត្តដល់សិស្សឲ្យធ្វើការស្វែងយល់ពីនិយមន័យនៃពាក្យ“ជនរងគ្រោះ”និង“ជនដៃដល់” និងពិនិត្យមើលអំពីបញ្ហាសីលធម៌ដែលមនុស្សគ្រប់រូបជួបប្រទះក្នុងអំឡុងពេលនៃអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងនោះ ។

ទី២ តារាងនេះមិនមែនបង្កើតឡើងក្នុងនាមជាទម្រង់ច្បាស់លាស់មួយនោះទេ ។ វាត្រូវបានផ្តល់ឲ្យដើម្បីជួយក្នុងការបង្កើតគំនិត និងសំណួរ ។ គ្រូមិនត្រូវរំពឹងថា នេះគឺជាវិធីសាស្ត្រតែមួយគត់ក្នុងការរៀបចំការពិភាក្សានោះទេ ។ ឧទាហរណ៍ជាជាងធ្វើការពិនិត្យមើលបទពិសោធន៍របស់ជនដៃដល់ដោយប្រៀបធៀបនឹងបទពិសោធន៍របស់ជនរងគ្រោះ គ្រូអាចឲ្យសិស្សធ្វើការប្រៀបធៀបថា តើអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងអស់ត្រូវបានរៀបចំឡើងដោយរបៀបណា ។ វិធីសាស្ត្រ និងសំណួរផ្សេងៗគ្នានឹងបង្កើតការឆ្លើយតបផ្សេងៗគ្នារហូតដល់ការឆ្លើយតបនឹងសំណួរចុងក្រោយគឺ “ហេតុអ្វី?” ។ គ្រូគួរឲ្យសិស្សពិនិត្យមើលសក្ខីកម្មទាំងឡាយទៅតាមកម្រិតផ្សេងៗគ្នា ។ បទពិសោធន៍មួយរបស់ជនរងគ្រោះអាចត្រូវបានវិភាគដោយផ្អែកលើមូលដ្ឋានបុគ្គល ក៏ដូចជាក្រុមគ្រួសារ សហគមន៍ វប្បធម៌ និងសង្គម ។

នៅទីបញ្ចប់ អ្នកមិនគួរចាត់ទុកតារាងនេះគឺជាសំណុំនៃចម្លើយតែមួយគត់ ឬគោលដៅតែមួយគត់សម្រាប់លំហាត់ណាមួយនោះទេ ។ ចម្លើយ និងគោលដៅនៃការពិភាក្សាទាំងឡាយគឺអាស្រ័យទៅលើការវាយតម្លៃរបស់គ្រូម្នាក់ៗចំពោះតម្រូវការរបស់សិស្ស និងការយល់ដឹងរបស់សិស្សនៅក្នុងវិសាលភាពនៃគោលដៅរបស់លំហាត់ ។

## តារាងសម្រាប់ទាញយកភាពដូចគ្នា និងភាពខុសគ្នា នៅក្នុងការប្រៀបធៀបអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ

១) ប្រភេទ
- ក) ជាតិពន្ធុ
- ខ) ជាតិសាសន៍
- គ) សាសនា
- ឃ) ជនជាតិ
- ង) នយោបាយ
- ច) សង្គម

២) សញ្ញាសម្គាល់
- ក) ឈ្មោះ
- ខ) ស្លាកសញ្ញា

៣) ការធ្វើឲ្យបាត់បង់ភាពជាមនុស្ស
- ក) ធ្វើឲ្យទៅជាសត្វ សត្វចង្រៃ សត្វល្អិត ឬជំងឺ
- ខ) ការបង្កើតឲ្យមានការគំរាមកំហែង

៤) ភាពប្រេះឆាគ្នា
- ក) ការគំរាមកំហែង
- ខ) ការផ្តោតទៅលើគំនិតជ្រុលហួសហេតុ

៥) ការរៀបចំ
- ក) ការបំបែកចេញពីក្រុមគ្រួសារ
- ខ) អត្តសញ្ញាណសាធារណៈ
- គ) ការដកហូតទ្រព្យសម្បត្តិ

៦) ការសម្លាប់ក្នុងទ្រង់ទ្រាយធំ
- ក) វិធីសាស្ត្រក្នុងការរៀបចំ
- ខ) គោលដៅយូរអង្វែង

៧) អង្គការចាត់តាំង
- ក) បណ្តាញសង្គមក្រៅផ្លូវការ
- ខ) អង្គការចាត់តាំងរបស់រដ្ឋាភិបាល

៨) តម្លៃនៅពីក្រោយការបែងចែក
- ក) តម្លៃនៃវប្បធម៌
- ខ) ការផ្តល់អំណាចទៅឲ្យក្រុមសង្គម
- គ) ការដណ្តើមអំណាចរបស់បុគ្គលជាមេដឹកនាំ
- ឃ) ការបែងចែកការទទួលខុសត្រូវចំពោះបញ្ហាដែលកើតមានលើក្រុមគោលដៅ
- ង) កំណើនសេដ្ឋកិច្ចដោយសារតែការដកហូតទ្រព្យសម្បត្តិ

៩) តម្លៃដែលមើលឃើញក្នុងអំឡុងពេលនៃអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ
- ក) ការតស៊ូប្រឆាំងនឹងអំពើអាក្រក់
- ខ) ការការពារអ្នកជាទីស្រឡាញ់
- គ) ការការពារតម្លៃរបស់មនុស្សម្នាក់
- ឃ) ការការពារវប្បធម៌
- ង) ការរស់រានមានជីវិត
- ច) ការសម្រុះសម្រួលដើម្បីសន្តិភាព
- ឆ) ការសម្រុះសម្រួលដើម្បីទទួលបានស្ថានភាពមួយល្អជាង

១០) ផលប៉ះពាល់មកលើសតិអារម្មណ៍
- ក) ការធ្លាក់ទឹកចិត្ត សេចក្តីអាណិត
- ខ) ការខឹងសម្បារ ការស្អប់ខ្ពើម
- គ) ភាពធូរស្រាលក្នុងចិត្ត
- ឃ) ភាពភ័យខ្លាច ការមួម៉ៅ

១១) ផលប៉ះពាល់មកលើរូបរាងកាយ
- ក) ការអត់អាហារ
- ខ) ការនឿយហត់
- គ) ជំងឺ
- ឃ) ការឈឺចាប់បណ្តាលមកពីការវាយដំ និងទារុណកម្ម

១២) ផលប៉ះពាល់ផ្លូវចិត្ត
- ក) បាត់បង់ក្តីសង្ឃឹម
- ខ) បាត់បង់ជំនឿសាសនា
- គ) ភាពមិនចង់រវីរវល់នឹងរឿងមនុស្សលោក

១៣) ផលប៉ះពាល់មកលើទំនាក់ទំនងជិតស្និទ្ធ
- ក) មានអារម្មណ៍ទំនាក់ទំនងបុគ្គល ឬបាត់បង់ជ្រៅៗ
- ខ) តម្រូវការការគាំទ្រច្រើនជាងមុន



ប្រាសាទបាយ័ន សង់ឡើងក្នុងសតវត្សរ៍ទី១៣ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ មានទីតាំងនៅចំកណ្ដាលទីក្រុងអង្គរធំ ។
រូបថត ៖ ញាណ សុជាតិ

១៤) ផលប៉ះពាល់មកលើសហគមន៍

ក) បាត់បង់ស្មារតីសហគមន៍

ខ) មានការមិនជឿទុកចិត្តសមាជិកផ្សេងទៀតរបស់សហគមន៍

គ) ការលះបង់អ្នកដទៃដើម្បីថែរក្សាខ្លួនឯង ឬគ្រួសារ

១៥) ទស្សនៈជាសាកល

ក) ការបំភ្លៃការពិត

ខ) ការកោតសរសើរកាន់តែខ្លាំងឡើងចំពោះមនុស្សជាទីស្រឡាញ់

## កំណត់ចំណាំសម្រាប់គ្រូ

គ្រូអាចសួរសំណួរទាំងនេះទៅសិស្ស ប្រសិនបើអ្នកជឿថា សិស្សត្រូវការការណែនាំបន្ថែមក្នុងការធ្វើលំហាត់ឬប្រើប្រាស់សម្ភារសិក្សាផ្សេងៗ ។ គ្រូត្រូវចងចាំថា ប្រសិនបើចាំបាច់ អ្នកអាចទៅរកមើល«តារាងសម្រាប់ទាញយកភាពដូចគ្នា និងភាពខុសគ្នា នៅក្នុងការប្រៀបធៀបអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ» ។ សូមរំឭកឡើងវិញ សំណួរទាំងនេះគឺគ្រាន់តែដើម្បីទាញយកគំនិតប៉ុណ្ណោះ ។ អ្នកអាចសួរសំណួរផ្សេងៗ និងពិភាក្សាលើប្រធានបទផ្សេងទៀត តាមតែអ្នកត្រូវការ ។

## អ៊ីរ៉ាក់

១) ពិភាក្សាថា តើហេតុអ្វីបានជារបប សាដាម ហ៊ូសេន សម្រេចចិត្តធ្វើការសម្លាប់រង្គាលជនជាតិខឺដ ។
២) ពិភាក្សាអំពីរបៀបដែលជនជាតិ ខឺដ ត្រូវបានសម្លាប់រង្គាល ។
៣) ពិភាក្សាអំពីរបៀបដែលរបប សាដាម ហ៊ូសេន ធ្វើឲ្យយុទ្ធនាការរបស់ខ្លួនក្លាយទៅជាស្របច្បាប់ ។
៤) តើតម្លៃ និងហេតុផលអ្វីខ្លះដែលរបប សាដាម ហ៊ូសេន ប្រើប្រាស់ដើម្បីបង្ហាញថា ទង្វើរបស់ខ្លួនត្រឹមត្រូវ?
៥) តើអ្នកគិតថា ជនដៃដល់ម្នាក់ៗ បង្ហាញពីភាពត្រឹមត្រូវចំពោះទង្វើរបស់ខ្លួនដោយរបៀបណា?
៦) ពិភាក្សាពីបទពិសោធន៍របស់ជនរងគ្រោះ តើមានភាពដូចគ្នា និងភាពខុសគ្នាដូចម្ដេចខ្លះ?
៧) តើអារម្មណ៍ប្រភេទណាខ្លះ ដែលអ្នកមើលឃើញនៅក្នុងសក្ខីកម្មរបស់ជនរងគ្រោះ?
៨) តើចំណុចណាខ្លះ នៅក្នុងបទពិសោធន៍របស់ជនរងគ្រោះ ដែលផ្ដល់ការលើកទឹកចិត្តដល់គាត់?
៩) តើតម្លៃ ឬអត្ថន័យចម្បងអ្វីខ្លះ ដែលអ្នកអាចមើលឃើញនៅក្នុងបទពិសោធន៍របស់ជនរងគ្រោះ?
១០) តើអ្នកពន្យល់សកម្មភាពរបស់ជនរងគ្រោះនៅក្នុងអំឡុងពេលនៃបទពិសោធន៍របស់គាត់ដោយរបៀបណា?
១១) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើរូបរាងកាយរបស់គាត់?
១២) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើអារម្មណ៍របស់គាត់?
១៣) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើស្មារតីរបស់គាត់?
១៤) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើទំនាក់ទំនងរបស់គាត់ជាមួយសមាជិកគ្រួសារ មិត្តភក្តិ និងអ្នកដទៃ?
១៥) តើបទពិសោធន៍ទាំងនោះមានផលប៉ះពាល់អ្វីខ្លះមកលើសហគមន៍របស់ជនរងគ្រោះ?
១៦) តើអ្វីខ្លះដែលអ្នកគិតថា ជាផលប៉ះពាល់នៃអំពើឃោរឃៅទាំងនេះមកលើសង្គមរបស់អ៊ីរ៉ាក់?
១៧) តើអ្នកគិតថា ទស្សនៈជាសាកលរបស់ជនរងគ្រោះនឹងត្រូវបានផ្លាស់ប្ដូរដោយរបៀបណា?
១៨) ពណ៌នាពីការសម្រេចចិត្តមួយចំនួន ដែលជនរងគ្រោះ និងជនដៃដល់ជួបប្រទះ? តើអ្នកនឹងពន្យល់ការសម្រេចចិត្តរបស់អ្នកទាំងនោះដោយរបៀបណា?

## ហូឡូខសត៍-អាល្លឺម៉ង់

១) ពិភាក្សា ហេតុអ្វីបានជាប្រជាជនអាល្លឺម៉ង់ គាំទ្រការឡើងកាន់អំណាចរបស់ក្រុមណាហ្ស៊ី ។
២) ពិភាក្សា ថាតើក្រុមណាហ្ស៊ីរៀបចំការសម្លាប់ជនជាតិជ្វីហ្វជាប្រព័ន្ធដោយរបៀបណា?
៣) តើក្រុមណាហ្ស៊ីរៀបចំប្រជាជនអាល្លឺម៉ង់សម្រាប់ផែនការរបស់ខ្លួនដោយរបៀបណា?
៤) តើក្រុមណាហ្ស៊ីរៀបចំជនជាតិជ្វីហ្វសម្រាប់ផែនការរបស់ខ្លួនដោយរបៀបណា?
៥) ពិភាក្សា ថាតើរបប អ៊ីត្លែ សម្លាប់រង្គាលជនជាតិជ្វីហ្វដោយរបៀបណា?
៦) តើរបប អ៊ីត្លែ រៀបចំការសម្លាប់រង្គាលជនជាតិជ្វីហ្វដោយរបៀបណា?
៧) តើតម្លៃមនោគមន៍វិជ្ជា និងហេតុផលអ្វីខ្លះ ដែលក្រុមណាហ្ស៊ីប្រើប្រាស់ ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃអំពើរបស់ខ្លួន ។

៨)	តើអ្នកគិតថា ជនដៃដល់ម្នាក់ៗនឹងបង្ហាញពីភាពត្រឹមត្រូវនៃអំពើរបស់ខ្លួនដោយរបៀបណា?
៩)	ពិភាក្សាអំពីបទពិសោធន៍របស់ជនរងគ្រោះ តើវាមានភាពដូចគ្នា និងភាពខុសគ្នាដូចម្តេចខ្លះ?
១០) តើអារម្មណ៍ប្រភេទណាខ្លះ ដែលអ្នកយល់ឃើញ នៅក្នុងសក្ខីកម្មរបស់ជនរងគ្រោះ?
១១) តើចំណុចណាខ្លះ នៅក្នុងបទពិសោធន៍របស់ជនរងគ្រោះ ដែលផ្តល់ការលើកទឹកចិត្តដល់គាត់?
១២) តើតម្លៃ ឬអត្ថន័យចម្បងអ្វីខ្លះ ដែលអ្នកអាចមើលឃើញនៅក្នុងបទពិសោធន៍របស់ជនរងគ្រោះ?
១៣) តើអ្នកពន្យល់សកម្មភាពរបស់ជនរងគ្រោះ នៅក្នុងអំឡុងពេលនៃបទពិសោធន៍របស់គាត់ដោយរបៀបណា?
១៤) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើរូបរាងកាយរបស់គាត់?
១៥) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើអារម្មណ៍របស់គាត់?
១៦) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើស្មារតីរបស់គាត់?
១៧) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើទំនាក់ទំនងរបស់គាត់ជាមួយសមាជិកគ្រួសារ មិត្តភក្តិ និងអ្នកដទៃ?
១៨) តើបទពិសោធន៍ទាំងនោះមានផលប៉ះពាល់អ្វីខ្លះមកលើសហគមន៍របស់ជនរងគ្រោះ?
១៩) តើអ្វីខ្លះដែលអ្នកគិតថា ជាផលប៉ះពាល់នៃអំពើឃោរឃៅទាំងនេះមកលើសង្គមទាំងមូល?
២០) តើអ្នកគិតថា ទស្សនៈជាសាកលរបស់ជនរងគ្រោះនឹងត្រូវបានផ្លាស់ប្តូរដោយរបៀបណា?
២១) ពណ៌នាពីការសម្រេចចិត្តមួយចំនួន ដែលជនរងគ្រោះ និងជនដៃដល់ជួបប្រទះ? តើអ្នកនឹងពន្យល់ការសម្រេចចិត្តរបស់អ្នកទាំងនោះដោយរបៀបណា?

## រ៉្វាន់ដា

១)	ពិភាក្សាអំពីស្ថានភាពប្រវត្តិសាស្ត្រ ដែលបង្កឲ្យមានអំពើហិង្សារវាងជនជាតិ ហ៊ូទូ និង ទុតស៊ី?
២)	ពិភាក្សាអំពីព្រឹត្តិការណ៍ ដែលរួមចំណែកដល់ការបង្កើនសមត្ថភាពរបស់ក្រុមហ៊ូទូជ្រុលនិយមក្នុងការសម្លាប់រង្គាលជនជាតិទុតស៊ី?
៣)	ពិភាក្សាថា តើជនជាតិ ទុតស៊ី ត្រូវបានសម្លាប់រង្គាលដោយរបៀបណា?
៤)	តើតម្លៃមនោគមន៍វិជ្ជា និងហេតុផលអ្វីខ្លះ ដែលក្រុមហ៊ូទូប្រើប្រាស់ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃអំពើរបស់ខ្លួន?
៥)	តើអ្នកគិតថា ជនដៃដល់ម្នាក់ៗនឹងបង្ហាញពីភាពត្រឹមត្រូវនៃអំពើរបស់ខ្លួនដោយរបៀបណា?
៦)	ពិភាក្សាប្រវត្តិជនដៃដល់ ៈ ជីន ប៉ូល អាកាយេស៊ូ ។ តើគាត់ជាមនុស្សយ៉ាងម៉េចនៅមុនអំពើហិង្សាកើតឡើង?
៧)	តើមានអ្វីកើតឡើងនៅ ឃុំតាបា រវាងថ្ងៃទី៧ ខែមេសា ដល់ខែមិថុនា ឆ្នាំ១៩៩៤?
៨)	តើ អាកាយេស៊ូ ចូលរួមនៅក្នុងព្រឹត្តិការណ៍ទាំងនេះមុនថ្ងៃទី១៨ មេសា ១៩៩៤ ដោយរបៀបណា?
៩)	តើ អាកាយេស៊ូ ចូលរួមនៅក្នុងព្រឹត្តិការណ៍ទាំងនេះក្រោយថ្ងៃទី១៨ មេសា ១៩៩៤ ដោយរបៀបណា?
១០) តើអ្នកពន្យល់ការផ្លាស់ប្តូរឥរិយាបថរបស់ អាកាយេស៊ូ ដោយរបៀបណា?
១១) តើហេតុអ្វីបានជាអ្នកគិតថា អាកាយេស៊ូ ធ្វើការផ្លាស់ប្តូរ?
១២) នៅពេលដែល អាកាយេស៊ូ និយាយទៅកាន់ហ្វូងមនុស្សនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៤ តើគាត់បានជំរុញ

ឲ្យហ្វូងមនុស្សធ្វើអ្វីខ្លះ?

១៣) តើ អាកាយេស៊ូ ជំរុញឲ្យហ្វូងមនុស្សបំពេញតាមការបញ្ជារបស់គាត់ដោយរបៀបណា?

១៤) តើគាត់លាបពណ៌ជនជាតិ ទុតស៊ី ដោយរបៀបណា?

១៥) តើអ្វីជាផលប៉ះពាល់នៃការលាបពណ៌នេះ?

១៦) ពណ៌នាពីការសម្រេចចិត្តមួយចំនួន ដែលជនរងគ្រោះ និងជនដៃដល់ជួបប្រទះ? តើអ្នកនឹងពន្យល់ការសម្រេចចិត្តរបស់អ្នកទាំងនោះដោយរបៀបណា?

## អតីតយូហ្គោស្លាវី

១) ពិភាក្សាអំពីព្រឹត្តិការណ៍ ដែលនាំទៅដល់អំពើហិង្សានៅ បូស្នៀ និង ហឺហ្សីហ្គូវីណា ។

២) ពិភាក្សាថា តើថ្នាក់ដឹកនាំរបស់បូស្នៀ-ស៊ែប រៀបចំផែនការសម្លាប់ជាប្រព័ន្ធទៅលើជនជាតិបូស្នៀ-ម៉ូស្លីម និង បូស្នៀ-ក្រូអាត ដោយរបៀបណា?

៣) ពិភាក្សាថា តើជនដៃដល់សម្លាប់រង្គាលជនរងគ្រោះដោយរបៀបណា?

៤) តើជនដៃដល់រៀបចំការសម្លាប់ដោយរបៀបណា?

៥) តើតម្លៃនៃមនោគមន៍វិជ្ជា និងហេតុផលអ្វីខ្លះដែលត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃអំពើរបស់ជនរងគ្រោះ?

៦) តើជនដៃដល់បង្ហាញពីភាពត្រឹមត្រូវនៃអំពើរបស់ខ្លួន ក្នុងចំណោមជនដៃដល់ទាំងនោះដោយរបៀបណា?

៧) ពិភាក្សាអំពីបទពិសោធន៍របស់ជនរងគ្រោះ តើវាមានភាពដូចគ្នា និងភាពខុសគ្នាដូចម្តេចខ្លះ?

៨) តើអារម្មណ៍ប្រភេទណាខ្លះ ដែលអ្នកមើលឃើញនៅក្នុងសក្ខីកម្មរបស់ជនរងគ្រោះ?

៩) តើចំណុចណាខ្លះ នៅក្នុងបទពិសោធន៍របស់ជនរងគ្រោះ ដែលផ្តល់ការលើកទឹកចិត្តដល់គាត់?

១០) តើតម្លៃ ឬអត្ថន័យចម្បងអ្វីខ្លះ ដែលអ្នកអាចមើលឃើញនៅក្នុងបទពិសោធន៍របស់ជនរងគ្រោះ?

១១) តើអ្នកពន្យល់សកម្មភាពរបស់ជនរងគ្រោះ នៅក្នុងអំឡុងពេលនៃបទពិសោធន៍របស់គាត់ដោយរបៀបណា?

១២) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើរូបរាងកាយរបស់គាត់?

១៣) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើសតិអារម្មណ៍របស់គាត់?

១៤) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើស្មារតីរបស់គាត់?

១៥) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើទំនាក់ទំនងរបស់គាត់ជាមួយសមាជិកគ្រួសារ មិត្តភក្តិ និងអ្នកដទៃ?

១៦) តើបទពិសោធន៍ទាំងនោះ មានផលប៉ះពាល់អ្វីខ្លះមកលើសហគមន៍របស់ជនរងគ្រោះ?

១៧) តើអ្វីខ្លះដែលអ្នកគិតថា ជាផលប៉ះពាល់នៃអំពើឃោរឃៅទាំងនេះមកលើសង្គមទាំងមូល?

១៨) តើអ្នកគិតថា ទស្សនៈជាសាកលរបស់ជនរងគ្រោះនឹងត្រូវបានផ្លាស់ប្តូរដោយរបៀបណា?

១៩) ពណ៌នាពីការសម្រេចចិត្តមួយចំនួន ដែលជនរងគ្រោះ និងជនដៃដល់ជួបប្រទះ? តើអ្នកនឹងពន្យល់ការសម្រេចចិត្តរបស់អ្នកទាំងនោះដោយរបៀបណា?

## ការប្រៀបធៀបអំពើប្រល័យពូជសាសន៍-អំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ កម្ពុជា អ៊ីរ៉ាក់ អាល្លឺម៉ង់ រ៉្វាន់ដា និង អតីតយូហ្គោស្លាវី

១) តើជនដៃដល់បែងចែកជនរងគ្រោះដោយរបៀបណា?

២) តើជនដៃដល់បែងចែកខ្លួនឯង និងអ្នកដទៃដោយរបៀបណា?

៣) តើសញ្ញាអ្វីដែលជនដៃដល់ប្រើ នៅពេលជនដៃដល់ទាំងនោះចង់បង្ហាញពីជនរងគ្រោះ?

៤) តើជនដៃដល់បំបាត់ភាពជាមនុស្សរបស់ជនរងគ្រោះដោយរបៀបណា?

៥) ហេតុអ្វីបានជាអ្នកគិតថា ជនដៃដល់ត្រូវការបំបាត់ភាពជាមនុស្សរបស់ជនរងគ្រោះ?

៦) តើជនដៃដល់ប្រព្រឹត្តយ៉ាងដូចម្តេច ចំពោះជនទាំងឡាយណាដែលប្រឆាំងនឹងទង្វើរបស់ខ្លួនដែលធ្វើលើជនរងគ្រោះ?

៧) តើជនដៃដល់រៀបចំយ៉ាងដូចម្តេច ក្នុងការប្រព្រឹត្តមកលើជនរងគ្រោះ?

៨) តើជនដៃដល់សម្លាប់ជនរងគ្រោះដោយរបៀបណា?

៩) តើជនដៃដល់រៀបចំការសម្លាប់នេះដោយរបៀបណា?

១០) តើតម្លៃនៃមនោគមន៍វិជ្ជា និងវប្បធម៌អ្វីខ្លះ ដែលជនដៃដល់ប្រើប្រាស់សម្រាប់បង្ហាញពីភាពត្រឹមត្រូវនៃទង្វើរបស់ខ្លួន?

១១) តើជនដៃដល់ទទួលបានផលប្រយោជន៍អ្វីខ្លះ ចំពោះទង្វើរបស់ខ្លួនដែលបានធ្វើទៅលើជនរងគ្រោះ?

១២) តើតម្លៃ និងហេតុផលអ្វីខ្លះ ដែលពន្យល់អំពីការតស៊ូរបស់ជនរងគ្រោះប្រឆាំងនឹងជនដៃដល់?

១៣) តើតម្លៃ និងហេតុផលអ្វីខ្លះ ដែលពន្យល់អំពីការយល់ស្របតាមរបស់ជនរងគ្រោះចំពោះជនដៃដល់?

១៤) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើសតិអារម្មណ៍របស់គាត់?

១៥) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើរូបរាងកាយរបស់គាត់?

១៦) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើស្មារតីរបស់គាត់?

១៧) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើទំនាក់ទំនងរបស់ខ្លួនជាមួយអ្នកដទៃ?

១៨) តើបទពិសោធន៍របស់ជនរងគ្រោះ មានផលប៉ះពាល់អ្វីខ្លះមកលើសហគមន៍របស់ខ្លួន?

១៩) តើបទពិសោធន៍របស់ជនរងគ្រោះមានផលប៉ះពាល់អ្វីខ្លះមកលើទស្សនៈជាសាកលរបស់ខ្លួន?

២០) តើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រអ្វីខ្លះ ដែលហាក់ដូចជានៅពីមុខអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ?

២១) តើព្រឹត្តិការណ៍ ឬកត្តាសម័យទំនើបអ្វីខ្លះ ដែលជំរុញឲ្យមានអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ?

២២) តើអត្ថន័យរួមអ្វីខ្លះ ដែលអ្នកអាចទាញយកពីបទពិសោធន៍របស់ជនដៃដល់ និងជនរងគ្រោះ?

២៣) ពណ៌នាអំពីការសម្រេចចិត្តមួយចំនួន ដែលជនរងគ្រោះ និងជនដៃដល់ជួបប្រទះ ។ តើអ្នកពន្យល់អំពីសេចក្តីសម្រេចចិត្តរបស់អ្នកទាំងនោះដោយរបៀបណា?

២៤) តើអ្នកអាចពន្យល់យ៉ាងដូចម្តេច ថាហេតុអ្វីបានមនុស្សមួយចំនួនជាជនរងគ្រោះ ហើយមួយចំនួនទៀត ជាជនដៃដល់? តើអ្នកគិតថា ជនដៃដល់ និងជនរងគ្រោះនឹងឆ្លើយសំណួរនេះដោយរបៀបណា?

២៥) តើអ្នកអាចពន្យល់ថា តើហេតុអ្វីបានជាអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរកើតឡើងក្នុងកម្រិតសង្គម? តើសង្គមត្រូវមានអ្វីខ្លះ

ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃអំពើឧក្រិដ្ឋកម្មទាំងនោះ?

២៦) តើអ្នកអាចពន្យល់ថា តើហេតុអ្វីបានជាអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរកើតឡើងក្នុងកម្រិតបុគ្គល? តើជនដៃដល់ត្រូវមានអ្វីខ្លះ ដើម្បីបង្ហាញពីភាពត្រឹមត្រូវរបស់ខ្លួន?

២៧) តើមនុស្សម្នាក់អាចការពារអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ មិនឲ្យកើតមានឡើងដោយរបៀបណា នៅពេលដែលខ្លួនដឹងថា អំពើទាំងនេះកើតឡើងក្នុងកម្រិតសង្គម ឬកម្រិតបុគ្គល?

## ប្រឡងបញ្ចប់ ក្រដាសចម្លើយ ៖

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ផ្នែកទី១ ៖ ចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

(៣៥សំណួរ x ១,៥ពិន្ទុសម្រាប់មួយសំណួរ = ៥២,៥ពិន្ទុ)

១) តើខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជានៅពេលណា?

ក) ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧០

ខ) ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៤

គ) ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ឃ) ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩

២) តើខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនរស់នៅក្នុងទីក្រុងយ៉ាងដូចម្តេចខ្លះ?

ក) ខ្មែរក្រហមបានបង្ខំប្រជាជនឲ្យចាកចេញពីទីក្រុង និងធ្វើការនៅតាមជនបទដាច់ស្រយាល ។

ខ) ខ្មែរក្រហមបានបង្ខំប្រជាជនឲ្យផលិតអាវុធនៅក្នុងទីក្រុង ។

គ) ខ្មែរក្រហមបានបង្ខំប្រជាជនឲ្យចាកចេញពីទីក្រុង បន្ទាប់ពីពីរបីខែក្រោយផែនការ ។

ឃ) ខ្មែរក្រហមបានបង្ខំប្រជាជនឲ្យបន្តរស់នៅក្នុងទីក្រុង ដើម្បីការពារទប់ទល់នឹងការទម្លាក់គ្រាប់បែក ។

៣) តើមានហេតុផលអ្វីដែលខ្មែរក្រហមធ្វើឲ្យទីក្រុងក្លាយជាទីក្រុងដែលគ្មានមនុស្សរស់នៅ?

ក) ខ្មែរក្រហមបានប្រាប់ប្រជាជនថា អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ ។

ខ) ខ្មែរក្រហមបានប្រាប់ប្រជាជនថា ប្រជាជនត្រូវតែចាកចេញពីទីក្រុង ពីព្រោះពុំមានឧបករណ៍ប្រើប្រាស់និងមធ្យោបាយធ្វើដំណើរក្នុងការនាំយកម្ហូបអាហារមកកាន់ទីក្រុងទេ ។

គ) ប៉ុល ពត ក្រោយមកនិយាយថា ការជម្លៀសនេះគឺជាការចាំបាច់ណាស់ដើម្បីបំបែក «អង្គការចាត់តាំងខ្មាំងសត្រូវ គិញសម្ងាត់» ។

ឃ) ទាំងបីចំណុចខាងលើ ។

៤) តើអ្នកដែលស្លាប់ក្នុងរបបខ្មែរក្រហមមានចំនួនប្រហែលប៉ុន្មាននាក់?

ក) ពី ៨ម៉ឺននាក់ ទៅ ១សែននាក់

ខ) ពី ១,៧ ទៅ ២ លាននាក់

គ) ពី ៨០លាននាក់ ទៅ ៩០លាននាក់

ឃ) ពី ១ម៉ឺននាក់ ទៅ ២ម៉ឺននាក់

៥) តើមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាជាអ្វី?

ក) ម៉ាក្សឡេនីន

ខ) សង្គមប្រជាធិបតេយ្យ

គ) លទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ

ឃ) មិនចូលចំណុចណាមួយក្នុងចំណោមចំណុចទាំងបីខាងលើ

៦) តើនរណាជាអ្នកធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងប្រមុខរដ្ឋដោយជោគជ័យនៅខែមីនា ឆ្នាំ១៩៧០?

ក) ប៉ុល ពត

ខ) សេនាប្រមុខ លន់ នល់

គ) ខៀវ សំផន

ឃ) តាម៉ុក

ង) នួន ជា

៧) តើឈ្មោះដើមរបស់ ប៉ុល ពត គឺអ្វី?

ក) ប៉ុល ពត ជាឈ្មោះពិតប្រាកដរបស់គាត់

ខ) កាំង ហ្គេកអ៊ាវ

គ) សាឡុត ស

ឃ) មិនមែនឈ្មោះទាំងបីខាងលើ

៨) តើ ប៉ុល ពត បានក្លាយខ្លួនជាសមាជិករបស់បក្សកុម្មុយនីស្តនៅកន្លែងណា?

ក) ក្រុងភ្នំពេញ ប្រទេសកម្ពុជា

ខ) ក្រុងហាណូយ ប្រទេសវៀតណាម

គ) ក្រុងប៉េកាំង ប្រទេសចិន

ឃ) ក្រុងប៉ារីស ប្រទេសបារាំង

៩) តើ ប៉ុល ពត បានក្លាយជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យនៅពេលណា?

ក) ឆ្នាំ១៩៧៦

ខ) ឆ្នាំ១៩៧៧

គ) ឆ្នាំ១៩៧៩

ឃ) ឆ្នាំ១៩៨០

១០) តើ ប៉ុល ពត ស្លាប់នៅពេលណា?

ក) ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨

ខ) ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០០

គ) ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៨០

ឃ) ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៩

១១) តើ នួន ជា ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅពេលណា?

ក) ឆ្នាំ១៩៨០

ខ) ឆ្នាំ២០០០

គ) ឆ្នាំ១៩៧៩

ឃ) ឆ្នាំ១៩៩៨

១២) តើប្រទេសណាខ្លះដែលបានគាំទ្រខ្មែរក្រហមក្នុងការតស៊ូដណ្តើមអំណាច?

ក) ចិន

ខ) វៀតណាម

គ) ប្រទេសទាំងពីរ (ក) និង (ខ)

ឃ) មិនមែនប្រទេសទាំងពីរខាងលើ

១៣) តើរដ្ឋាភិបាលរបស់របបសាធារណរដ្ឋខ្មែរ ត្រូវបានជួយទ្រទ្រង់ដោយរដ្ឋាភិបាលប្រទេសណាចាប់តាំងពីខែមករា ដល់ខែសីហា ឆ្នាំ១៩៧៣?

ក) វៀតណាម

ខ) សូវៀត

គ) សហរដ្ឋអាមេរិក

ឃ) ទាំងបីប្រទេសខាងលើ

១៤) សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកប្រហែលកន្លះលានតោនមកលើប្រទេសកម្ពុជា ។ តើការទម្លាក់គ្រាប់បែកនេះជះឥទ្ធិពលមកលើខ្មែរក្រហមដូចម្តេចខ្លះ?

ក) ជួយដល់ខ្មែរក្រហម ដោយកាត់បន្ថយកម្លាំងគ្រប់គ្រងរបស់វៀតណាម ។

ខ) ជួយដល់ខ្មែរក្រហម ដោយបំផ្លាញកម្លាំងរបស់របប លន់ នល់ ក្នុងទ្រង់ទ្រាយធំ ។

គ) អាចពន្យារពេលដល់ដំណើរឆ្ពោះទៅជ័យជម្នះរបស់ខ្មែរក្រហមបានពីរឆ្នាំទៀត ។

ឃ) មិនមែនទាំងបីខាងលើ ។

១៥) តើការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ជះឥទ្ធិពលមកលើប្រជាជនខ្មែរដូចម្តេចខ្លះ?

ក) មិនបានសម្លាប់ប្រជាជនខ្មែរច្រើននាក់ឡើយ ។ ហេតុដូច្នេះហើយទើបការទម្លាក់គ្រាប់បែកនេះមិនបានជះឥទ្ធិពល អ្វីចំពោះប្រជាជនខ្មែរជាសំខាន់ឡើយ ។

ខ) បានសម្លាប់ប្រជាជនខ្មែរអស់ចំនួន៣សែននាក់ ។ ប្រជាជនខ្មែរខ្លះបានបាត់បង់សមាជិកគ្រួសារ ។ អ្នកខ្លះទៀតបានចូលរួមជាមួយខ្មែរក្រហម ដើម្បីប្រឆាំងទល់នឹងរដ្ឋាភិបាល របស់លោកសេនាប្រមុខ លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។

គ) បានសម្លាប់ប្រជាជនខ្មែររាប់រយនាក់ ។ ទោះជាយ៉ាងណាក៏ដោយ ក្រៅពីចូលរួមជាមួយខ្មែរក្រហម ប្រជាជនខ្មែរភាគច្រើនគិតថា ការទម្លាក់គ្រាប់បែកគឺជាជំហានដ៏សំខាន់មួយ ក្នុងការការពារប្រទេសកម្ពុជាពីកម្លាំងរបស់វៀតណាម ។

ឃ) មិនមែនចំណុចទាំងបីខាងលើ ។

១៦) តើមានព្រឹត្តិការណ៍អ្វីកើតឡើងខ្លះចំពោះរាជវង្សានុវង្សរបស់សម្តេចព្រះ នរោត្តម សីហនុ ក្រោមរបបខ្មែរក្រហម?

ក) មានព្រះរាជវង្សានុវង្សប្រហែល២០អង្គបានចូលទិវង្គត ហើយយ៉ាងហោចណាស់៧អង្គផ្សេងទៀតត្រូវបានធ្វើគុតនៅគុកទួលស្លែង ។

ខ) ព្រះរាជវង្សានុវង្សទាំងអស់ បានរត់គេចខ្លួនចេញទៅកាន់ប្រទេសចិន ជាកន្លែងដែលព្រះរាជវង្សានុវង្សទាំងនោះបានរួចជីវិតពីរបបខ្មែរក្រហម ។

គ) ព្រះរាជវង្សានុវង្សទាំងអស់ បន្តគង់នៅក្នុងប្រទេសកម្ពុជាជាកន្លែងដែលទ្រង់បានទទួលតំណែងដ៏មានឥទ្ធិពលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ឃ) ព្រះរាជវង្សានុវង្សទាំងអស់បន្តគង់នៅក្នុងប្រទេសកម្ពុជា ជាកន្លែងដែលទ្រង់ត្រូវបានឃុំឃាំងនៅក្នុងផ្ទះសម្រាប់រយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

១៧) តើនរណាជាប្រធានសភាតំណាងប្រជាជន (នៃរបបកម្ពុជាប្រជាធិបតេយ្យ)?

ក) នួន ជា

ខ) ប៉ុល ពត

គ) វ៉ន វ៉េត

ឃ) មិនមែនទាំងបីខាងលើ

១៨) តើនរណាជានាយករដ្ឋមន្ត្រី (នៃរបបកម្ពុជាប្រជាធិបតេយ្យ)?

ក) នួន ជា

ខ) អៀង សារី

គ) ប៉ុល ពត

ឃ) មិនមែនទាំងបីខាងលើ



នង ចាន់ផល ជាកុមាររួចរស់ជីវិតម្នាក់ ក្នុងចំណោមកុមារ៤នាក់ ពីមន្ទីរ ស-២១ ។

១៩) តើនរណាជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស (នៃរបបកម្ពុជាប្រជាធិបតេយ្យ)?

ក) ប៉ុល ពត

ខ) អៀង សារី

គ) នួន ជា

ឃ) វ៉ន វ៉េត

២០) តើនរណាជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ (នៃរបបកម្ពុជាប្រជាធិបតេយ្យ)?

ក) អៀង សារី

ខ) វ៉ន វ៉េត

គ) ប៉ុល ពត

ឃ) សុន សេន

២១) តើការរស់នៅជាលក្ខណៈសមូហភាព មានផលប៉ះពាល់ដល់គ្រួសារកម្ពុជាដូចម្តេចខ្លះ?

ក) គ្រួសារទាំងអស់រួបរួមគ្នា ហើយត្រូវបានអនុញ្ញាតឲ្យធ្វើការជាមួយគ្នា ។ ប្តីនិងប្រពន្ធធ្វើការរួមគ្នាជាមួយកូនៗនៅក្នុងការដ្ឋានតែមួយ ។

ខ) គ្រួសារត្រូវបានបំបែក នៅពេលណាដែលអង្គការត្រូវការឲ្យមានការបំបែកតែប៉ុណ្ណោះ ។ និយាយជាទូទៅមានការខិតខំប្រឹងប្រែង ក្នុងការរក្សាគ្រួសារឲ្យរស់នៅរួមគ្នា ប្រសិនបើមានលទ្ធភាពធ្វើទៅបាន ។

គ) គ្រួសារត្រូវបានបំបែក ហើយប្រជាជនត្រូវបានចាត់តាំងឲ្យធ្វើការជាក្រុម ។ ប្តី និងប្រពន្ធ ត្រូវបានបំបែកចេញពីគ្នា ហើយក្មេងៗក៏ត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្លួន ព្រមទាំងត្រូវបានចាត់តាំងឲ្យធ្វើការនៅការដ្ឋានដាច់ដោយឡែកពីគ្នា ។

ឃ) នៅពេលដែលប្តី និងប្រពន្ធ ត្រូវអង្គការអនុញ្ញាតឲ្យរស់នៅជាមួយគ្នា កូនៗត្រូវបានបំបែកចេញពីឪពុកម្តាយដើម្បីជួយក្មេងៗទាំងនោះក្នុងការអប់រំ ។

២២) តើអាទិភាពចម្បងពីររបស់របបកម្ពុជាប្រជាធិបតេយ្យគឺអ្វី?

ក) ការរស់នៅជាសមូហភាពដើម្បីបង្កបង្កើនផល និងការពារជាតិ

ខ) ការរស់នៅជាសមូហភាពដើម្បីបង្កបង្កើនផល និងការអភិវឌ្ឍវិស័យអប់រំ

គ) ការការពារជាតិ និងការអប់រំ

ឃ) ការការពារជាតិ និងការអភិវឌ្ឍវិស័យឧស្សាហកម្ម

២៣) តើការរស់នៅជាសមូហភាព មានន័យយ៉ាងដូចម្តេច?

ក) មានន័យថា ទ្រព្យសម្បត្តិរបស់គ្រួសារទាំងអស់ត្រូវដាក់បញ្ចូលជាសម្បត្តិរួមដើម្បីភាពជោគជ័យរបស់សមាជិកគ្រួសារ ។

ខ) មានន័យថា កម្មសិទ្ធិឯកជនទាំងអស់ (រួមបញ្ចូលទាំងចានឆ្នាំងផង) ត្រូវតែលះបង់ និងទុកសម្រាប់ប្រើប្រាស់ជាសមូហភាព ។ ទ្រព្យសម្បត្តិឯកជនត្រូវបានលុបបំបាត់ ។

គ) មានន័យថា អគាររបស់រដ្ឋទាំងអស់ត្រូវបានរៀបចំឡើងក្រោមគម្រោងសេដ្ឋកិច្ចរួម សម្រាប់ការធ្វើឲ្យប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់ខ្មែរ ។

ឃ) មានន័យថា កម្មសិទ្ធឯកជនទាំងអស់ត្រូវបានចែករំលែកដោយសហករណ៍ក្នុងអំឡុងពេលការងារ នៅពេលដែលមានតម្រូវការក្នុងការធ្វើឲ្យសហករណ៍មានភាពប្រសើរឡើង ។ នៅពេលដែលការងារត្រូវបានបំពេញរួចរាល់ហើយ ទ្រព្យសម្បត្តិឯកជនទាំងនោះ នឹងត្រូវវិលត្រឡប់មករកម្ចាស់ទ្រព្យរៀងៗខ្លួនវិញ ។

២៤) តើគោលបំណងនៃការរស់នៅជាលក្ខណៈសមូហភាពនៅកម្ពុជាប្រជាធិបតេយ្យគឺជាអ្វី?

ក) ដើម្បីកែប្រែប្រទេសកម្ពុជាពីប្រទេសកសិកម្មទិនថយឲ្យទៅជាប្រទេសដែលសម្បូរទៅដោយអ្នកជំនាញលើពិភពលោក ។

ខ) ដើម្បីកែប្រែប្រទេសកម្ពុជាពីប្រទេសកសិកម្មទិនថយ ឲ្យទៅជាប្រទេសជឿនលឿនដោយពឹងផ្អែកលើគោលការណ៍ព្រះពុទ្ធសាសនា ។

គ) ដើម្បីកែប្រែប្រទេសកម្ពុជាពីប្រទេសកសិកម្មទិន់ថយ ឲ្យទៅជាប្រទេសកសិកម្មបែបទំនើប ។

ឃ) មិនមែនចំណុចទាំងបីខាងលើ

២៥) ហេតុអ្វីបានជាខ្មែរក្រហមបង្កើតសហករណ៍?

ក) ដើម្បីជួយសម្រួលដល់ការលុបបំបាត់កម្មសិទ្ធិឯកជន និងលទ្ធិសង្គមនិយម និងដើម្បីពង្រឹងវណ្ណៈនាយទុន ។

ខ) ដើម្បីជួយសម្រួលដល់ការលុបបំបាត់កម្មសិទ្ធិសាធារណៈ និងលទ្ធិសង្គមនិយម និងដើម្បីពង្រឹងវណ្ណៈគ្រូបង្រៀន និងអ្នកវិទ្យាសាស្ត្រ ។

គ) ដើម្បីជួយសម្រួលដល់ការលុបបំបាត់កម្មសិទ្ធិឯកជន និងមូលធននិយម និងដើម្បីពង្រឹងវណ្ណៈកម្មករ និងកសិករ ។

ឃ) មិនមែនចំណុចទាំងបីខាងលើ ។

២៦) តើវណ្ណៈចំនួនពីរដែលត្រូវបានបង្កើតឡើងក្នុងរបបខ្មែរក្រហម មានវណ្ណៈអ្វីខ្លះ?

ក) ប្រជាជនចាស់ និងប្រជាជនថ្មី

ខ) ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី

គ) ប្រជាជនមូលដ្ឋាន និងប្រជាជនចាស់

ឃ) អ្នកមាន និងអ្នកក្រ

២៧) តើការផ្ដោតការយកចិត្តទុកដាក់ដំបូងចំពោះការអប់រំរបស់ខ្មែរក្រហមជាអ្វី?

ក) ការបញ្ចុះបញ្ចូលតាមបែបសាសនា

ខ) ការសិក្សាពីវិទ្យាសាស្ត្រ

គ) ការបញ្ចុះបញ្ចូលតាមបែបនយោបាយ

ឃ) ទាំងពីរគឺចំណុច (ក) និង (ខ)

២៨) តើចរិតលក្ខណៈខាងក្រោមមួយណាដែលបង្ហាញថាជា "ប្រជាជនមូលដ្ឋាន"?

ក) ប្រជាជនមូលដ្ឋានមិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ឈរឈ្មោះឲ្យគេបោះឆ្នោត និងក្លាយទៅជាប្រធានសហករណ៍ ។

ខ) ប្រជាជនមូលដ្ឋានត្រូវបានអនុញ្ញាតឲ្យធ្វើការបោះឆ្នោត ឈរឈ្មោះឲ្យគេបោះឆ្នោត និងធ្វើជាប្រធានសហករណ៍ ។

គ) ជាទូទៅ ប្រជាជនមូលដ្ឋានត្រូវបានចាប់ដាក់ក្នុងមន្ទីរឃុំឃាំង ដោយសារមានការទាក់ទងនឹងរបបមុន ។

ឃ) ប្រជាជនមូលដ្ឋានត្រូវបានអនុញ្ញាតឲ្យធ្វើការបោះឆ្នោត ប៉ុន្តែគាត់ត្រូវបានហាមឃាត់ក្នុងការចូលកាន់តំណែងជាអ្នកដឹកនាំ ។

២៩) ចូរឲ្យចរិតលក្ខណៈពីរសម្រាប់ "ប្រជាជនថ្មី"

ក) ប្រជាជនថ្មីត្រូវបានចាត់ទុកថា ជាអ្នកដែលស្នេហាមាតុភូមិ និងទទួលបានការគោរពដោយសារតែភាពរួសរាយរាក់ទាក់របស់គាត់ ។

ខ) ប្រជាជនថ្មីត្រូវចាត់ទុកថា ជាអ្នកដែលមិនគួរឲ្យទុកចិត្តបាន និងមានសិទ្ធិតិចតួចបំផុត ។

គ) ប្រជាជនថ្មីត្រូវចាត់ទុកថា ជាអ្នកដែលគួរឲ្យទុកចិត្តបាន និងត្រូវបានផ្តល់ឲ្យនូវតំណែងជាអ្នកដឹកនាំ ។

ឃ) ចំណុច "ក" និង "គ"

៣០) តើនរណាដែលត្រូវបានចាត់ទុកថា ជា"អ្នកបដិវត្តន៍បរិសុទ្ធបំផុត" ក្រោមរបបខ្មែរក្រហម?

ក) បញ្ញវន្ត

ខ) គហបតី

គ) អ្នកក្រ

ឃ) មិនមែនទាំងបីចំណុចខាងលើ

៣១) តើមនុស្សប្រភេទណាដែលត្រូវបានរាប់បញ្ចូលជា"សត្រូវខាងក្នុង"?

ក) មន្ត្រីរបស់របបសាធារណរដ្ឋខ្មែរ

ខ) ក្រុមជនជាតិភាគតិច

គ) កុលសម្ព័ន្ធ

ឃ) មិនមែនប្រភេទមនុស្សទាំងបីក្រុមខាងលើ

៣២) តើអ្នកទោសប្រភេទណាដែលត្រូវបានឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ ស-២១?

ក) អ្នកទោសស្ទើរតែទាំងអស់ គឺជាកម្មាភិបាលនិងយោធាខ្មែរក្រហម ដែលត្រូវបានចោទប្រកាន់ពីបទក្បត់នឹងបដិវត្តន៍ ។

ខ) អ្នកទោសស្ទើរតែទាំងអស់ គឺជាទាហានវៀតណាមដែលត្រូវបានចាប់ជាឈ្លើយសឹកសង្គ្រាម

គ) អ្នកទោសស្ទើរតែទាំងអស់ គឺជាគ្រូបង្រៀនសាសនា

៣៣) តើនរណាជាប្រធានមន្ទីរសន្តិសុខ ស-២១?

ក) ប៉ុល ពត

ខ) កាំង ហ្កេកអ៊ាវ (ឌុច)

គ) អៀង សារី

ឃ) នួន ជា

៣៤) នៅក្នុងអគ្គភាពសួរចម្លើយរបស់មន្ទីរសន្តិសុខស-២១ មាន៣ក្រុមតូចៗ ។ តើក្រុមទាំងនោះហៅក្រុមអ្វីខ្លះ?

ក) ក្រុមក្តៅ, ក្រុមត្រជាក់ និង ក្រុមល្មម

ខ) ក្រុមក្តៅ, ក្រុមត្រជាក់ និង ក្រុមអង្កៀម

គ) ក្រុមក្តៅ, ក្រុមឈឺចាប់ និង ក្រុមជ្រមុជទឹក

ឃ) មិនមែនក្រុមទាំងបីចំណុចខាងលើ ។

៣៥) តើហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ?

ក) ចំនួនប្រជាជនទន់ខ្សោយ

ខ) ការប៉ះទង្គិចគ្នាជាមួយវៀតណាម

គ) ចំណុច "ក" និង "ខ"

ឃ) មិនមែនបីចំណុចខាងលើ

**ផ្នែកទី២ ៖ ស្វែងយល់ ៖ សំណួរដែលមានចម្លើយ**

(២សំណួរ X ១៦ពិន្ទុ = ៣២ពិន្ទុ)

១) តើអ្វីជាលទ្ធផលខ្លះៗនៃការរស់នៅជាសមូហភាព និងនយោបាយដទៃទៀតរបស់ខ្មែរក្រហម? ចូររៀបរាប់ឲ្យបាន ៤ចំណុចយ៉ាងតិច?

ចម្លើយដែលអាចទទួលយកបាន

- ការបង្អត់អាហារកើតឡើងនៅពេលដែលផលិតផលស្រូវមិនគ្រប់គ្រាន់ ឬមិនបានចែកចាយទៅឲ្យប្រជាជន ។
- ជំងឺរាតត្បាតកើតឡើង ដោយសារតែការខ្វះខាតអាហារូបត្ថម្ភ ដែលកើតចេញពីការខ្វះខាតចំណីអាហារនិងថ្នាំពេទ្យ ។
- ការសម្លាប់កើតឡើងនៅពេលដែលបញ្ញវន្ត អ្នកបច្ចេកទេស និងអតីតមេដឹកនាំរបស់របបមុនៗ ត្រូវបាននាំយកទៅសម្លាប់ចោល ។
- ការខ្វះចំណេះដឹងកើតឡើងនៅពេលដែលសកលវិទ្យាល័យ និងសាលាទាំងអស់ត្រូវបានបិទ ។
- ការប្រើប្រាស់កម្លាំងដែលគ្មានប្រសិទ្ធភាព ពីព្រោះកសិករដែលពុំមានជំនាញត្រូវបានដាក់ឲ្យធ្វើការនៅក្នុងរោងចក្រ ។
- ភាពមិនស្មើគ្នាកើតឡើងនៅពេលដែលយោធា និងកម្មាភិបាលខ្មែរក្រហមបានហូបគ្រប់គ្រាន់ ហើយប្រជាជនជួបប្រទះការអត់ឃ្លាន ។

២) ចូររៀបរាប់យ៉ាងតិច៤ចំណុចពីផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើប្រជាជនកម្ពុជា?

ចម្លើយដែលអាចទទួលយកបាន

- របបខ្មែរក្រហមបានបន្សល់ទុកនូវស្ត្រីមេម៉ាយ និងក្មេងកំព្រារាប់ម៉ឺននាក់ ។
- ប្រជាជនកម្ពុជារាប់រយពាន់នាក់បានរត់គេចចេញពីប្រទេស ។
- មីនរាប់លានគ្រាប់ត្រូវបានដាក់ពង្រាយពេញដី ដែលជាហេតុបណ្តាលឲ្យមានមនុស្សស្លាប់ និងពិការរាប់ពាន់នាក់ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ ។
- ប្រជាជនកម្ពុជាភាគច្រើនមានជំងឺផ្លូវចិត្ត ដោយសារតែសមាជិកគ្រួសាររបស់ខ្លួនត្រូវបានបាត់ខ្លួន ហើយស្នារតីរបស់អ្នកទាំងនោះត្រូវបានបំផ្លាញ ។

- បញ្ញវន្ត អ្នកដឹកនាំសាសនា និងអតីតមន្ត្រីរដ្ឋាភិបាលពីសង្គមចាស់មួយចំនួនត្រូវបានសម្លាប់ ដើម្បីកាត់បន្ថយសមត្ថភាពរបស់កម្ពុជា ក្នុងការស្តារស្ថាប័នសេដ្ឋកិច្ច និងសង្គមកិច្ចឡើងវិញ ។
- ប្រជាជនដែលប្រឆាំងនឹងរបបខ្មែរក្រហមមួយចំនួន ត្រូវបានសម្លាប់ចោល ។
- សាសនា រូបបិយប័ណ្ណ និងប្រពៃណីទំនៀមទម្លាប់ត្រូវបានបំផ្លាញ ។
- សិទ្ធិ និងតម្រូវការជាមូលដ្ឋានមិនត្រូវបានយកចិត្តទុកដាក់ ហើយទ្រព្យសម្បត្តិឯកជនត្រូវបានរឹបអូស ។

## ផ្នែកទី៣ ៖ ការវិភាគ ៖ សំណួរសាកល្បង

(២សំណួរ X ៨ពិន្ទុ = ១៦ពិន្ទុ)

១) ចូរប្រើប្រាស់ពាក្យស្លោកខាងក្រោមជាការណែនាំ រួចពិពណ៌នាពីមនោគមន៍វិជ្ជារបស់ខ្មែរក្រហម?

ប្រជាជន១៧មេសាគឺជាពួកបញ្ញើក្អែក ។ ប្រជាជនទាំងនោះ គឺជាអ្នកចាញ់សង្គ្រាម និងជាឈ្លើយសឹក ។

អង្គការបញ្ជាអី ធ្វើហ្នឹង! ត្រូវបំពេញតាមបញ្ជារបស់អង្គការឲ្យបានដាច់ខាត ។ មិត្ត មិនបាច់តថ្លៃ!

ស៊ូចាប់ខុស១០ ប្រសើរជាងលែងច្រឡំ១ ។

២) ចូរសរសេរសេចក្តីសង្ខេបចំនួនពីរទំព័រពីអ្វីដែលប្រជាជនកម្ពុជាត្រូវតែធ្វើ ដើម្បីព្យាបាលរបួសផ្លូវចិត្តដែលកើតឡើង ក្នុងអំឡុងពេលដ៏រន្ធត់ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ។ សូមចងចាំថា ការសរសេរនេះមិនត្រឹមតែសំដៅលើខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែសំដៅទៅលើសង្គមទាំងមូលផង ។

## ផ្នែកទី៤ ៖ ការផ្តល់មតិចំពោះកម្មវិធីសិក្សា (មិនមែនជាការដាក់ពិន្ទុទេ)

មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ចង់បានការផ្តល់មតិរបស់អ្នកចំពោះអ្វីដែលអ្នកចូលចិត្តអំពីកម្មវិធីសិក្សានេះ ក៏ដូចជាអ្វីដែលអ្នកគិតថាកម្មវិធីសិក្សានេះគួរតែធ្វើឲ្យល្អប្រសើរឡើង ។ សូមផ្តល់ភាពស្មោះត្រង់និងប្រកបដោយគំនិតស្ថាបនារបស់អ្នកក្នុងការកែលម្អកម្មវិធីសិក្សានេះ ។ សូមព្យាយាមផ្តល់គំនិតដែលអ្នកចូលចិត្តយ៉ាងតិចបី ឬច្រើនជាងនេះនៅក្នុងកម្មវិធីសិក្សា និងគំនិតបីទៀតដែលអ្នកគិតថា ត្រូវការសម្រាប់ការធ្វើឲ្យកម្មវិធីសិក្សានេះកាន់តែប្រសើរឡើង ។ គំនិតរបស់អ្នកមានសារសំខាន់ណាស់ និងអាចមានឥទ្ធិពលលើការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់សិស្សនាពេលអនាគតផង ។

## ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅទូទាំងប្រទេស

លោក ឌី ខាំបូលី ជាប្រធានគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍បានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៥ ដោយការធ្វើការស្រាវជ្រាវ និងប្រមូលទិន្នន័យ ដើម្បីបង្កើតនូវសៀវភៅសិក្សាដំបូងបង្អស់ស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដ៏មានសារសំខាន់នេះ ។ ចាប់តាំងពីការបោះពុម្ពផ្សាយដំបូងនៅឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយសៀវភៅជាង៣សែនក្បាល ទៅបណ្តាអនុវិទ្យាល័យ និងវិទ្យាល័យនៅទូទាំងប្រទេសកម្ពុជា និងមានគម្រោងចែកចាយសៀវភៅចំនួន៧សែនក្បាលបន្ថែមទៀតដើម្បីឲ្យច្បាស់ថា គ្រប់សិស្សានុសិស្សទាំងអស់នៅក្នុងប្រទេសបានទទួលនូវសៀវភៅនេះគ្រប់ៗគ្នា ។ ខាងក្រោមនេះគឺជារូបថតនៃការចែកចាយសៀវភៅកាលពីពេលថ្មីៗនេះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឆ្នាំ២០០៩ បន្ទាប់ពីវគ្គសិក្សាគ្រូបង្គោលថ្នាក់ជាតិដំបូងដែលប្រារព្ធនៅទីក្រុងភ្នំពេញចាប់ពីថ្ងៃទី២៩ ខែមិថុនា រហូតដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ក្រោមការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។







***រូបខាងលើឆ្វេង*** ៖ *យុវសិស្សម្នាក់កំពុងឈរអានពាក្យស្លោកឆ្លាក់នៅលើផ្ទាំងថ្មដែលដាក់តាំងនៅក្នុងបរិវេណវិទ្យាល័យព្រះបិតាជាតិ ខេត្តកំពត ក្នុងឆ្នាំ២០១១។ រូបថត ៖ ញាណ សុជាតិ។* ***រូបខាងលើស្តាំ*** ៖ *ប្រជាជនខ្មែរឥស្លាមកំពុងឈរអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលទើបទទួលបានលើកដំបូង កាលពីខែតុលា ឆ្នាំ២០០៩។* ***រូបខាងក្រោម*** ៖ *លោកជំទាវ ទន់ សាអុីម កំពុងចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅសិស្សវិទ្យាល័យព្រះសុីសុវត្ថិ។ ថតដោយ ៖ ដេង ពង្សរ៉ាសុី។*





***រូបខាងលើ*** *៖ ប្រជាជនខ្មែរឥស្លាមអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទើបទទួលបានក្នុងខែកញ្ញា ឆ្នាំ២០០៩ ។* ***រូបខាងក្រោម*** *៖ សិក្ខាកាមជាគ្រូ ប្រវត្តិវិទ្យា ក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅខេត្តបាត់ដំបង ក្នុងខែមករា ឆ្នាំ២០១៤ ។ រូបថត ៖ ញាណ សុជាតិ ។*






***រូបខាងលើ*** ៖ *ឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិយាយទៅកាន់សិក្ខាកាមនៃវគ្គបណ្តុះបណ្តាលក្នុងឆ្នាំ២០១៤។*

***រូបខាងក្រោម*** ៖ *សិក្ខាកាមដែលភាគច្រើនជាគ្រូបង្រៀនប្រវត្តិវិទ្យា ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅខេត្តបាត់ដំបង ក្នុងខែមករា ឆ្នាំ២០១៤។ រូបថត ៖ ញាណ សុជាតិ។*








### វាលស្ត្រីមេម៉ាយ

នេះគឺជារូបគំនូរដែលគូរដោយវិចិត្រករខ្មែរមួយរូបឈ្មោះ ស្វាយ គេន ដែលទើបតែទទួលមរណភាពថ្មីៗកន្លងទៅនេះ ។ គំនូរនេះគឺជាអំណោយផ្ទាល់ខ្លួនរបស់លោកស្រី ឡាទីត្យា វ៉ាន់ឌេន អាស៊ូម អគ្គរដ្ឋទូតហូឡង់ប្រចាំប្រទេសកម្ពុជា ជូនចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្នុងឆ្នាំ១៩៧៩ ភាគច្រើននៃអ្នករួចរស់ជីវិតពីរបបខ្មែរក្រហម គឺជាស្ត្រី ។ តាំងពីពេលនោះមក ស្ត្រីបានដើរតួរនាទីយ៉ាងសំខាន់ក្នុងការស្តាបនាប្រទេសកម្ពុជាឡើងវិញទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងស្មារតី ។

នាពេលជាមួយគ្នានេះដែរ យ៉ាងហោចណាស់កុមារចំនួនពីរសែននាក់បានក្លាយជាកុមារកំព្រា ។